# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៣០

បាលីប្រែ ៤៧ - ៤៨

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# មនោរថបូរណី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# អង្គុត្តរនិកាយ

# សត្តកនិបាត-អដ្ឋមភាគ

# អដ្ឋកនិបាត-នវមភាគ

# ៣០

# បាលីប្រែ ៤៧-៤៨

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៣០

# សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត

## អដ្ឋមភាគ

*សូមនមស្ការចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## បឋមបណ្ណាសក

## ធនវគ្គ

### បឋមអប្បិយសូត្រទី ១

[ ១ ] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ឆ្លើយតបព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង រមែងមិនជាទីស្រឡាញ់ផង មិនជាទីពេញចិត្តផង មិនជាទីគោរពផង មិនជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាលាភ ១ ប្រាថ្នាសក្ការៈ ១ មិនចង់ឲ្យគេមើលងាយខ្លួន ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ ប្រាថ្នាអាក្រក់ ១ ឃើញខុស ១ ។ ម្នាលភិក្ខុទាំងឡាយ*

ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះ រមែងមិនជាទីស្រឡាញ់ផង មិនជាទីពេញចិត្តផង មិនជាទីគោរពផង មិនជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រាថ្នាលាភ ១ មិនប្រាថ្នាសក្ការៈ ១ មិនប្រាថ្នា មិនចង់ឲ្យគេមើលងាយខ្លួន ១ ខ្មាសបាប ១ ខ្លាចបាប ១ ប្រាថ្នាតិច ១ ឃើញត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះ រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។

# អដ្ឋកថា
# អង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី
# សត្តកនិបាត
# បឋមបណ្ណាសក
# ធនវគ្គទី ១

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## បឋមអប្បិយសូត្រ

[ ១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអប្បិយសូត្រទី ១ នៃសត្តកនិបាត ដូចតទៅនេះ បទថា* **អនវញ្ញត្តិកាមោ** *ប្រែថា ដែលបំណងដើម្បីជាអ្នកមានឈ្មោះ ល្បោះសំឡេង ។*

**អដ្ឋកថា បឋមអប្បិយសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយអប្បិយសូត្រទី ២

[ ២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង រមែងមិនជាទីស្រឡាញ់ផង មិនជាទីពេញចិត្តផង មិនជាទីគោរពផង មិនជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាលាភ ១ ប្រាថ្នាសក្ការៈ ១ មិនចង់ឲ្យគេមើលងាយខ្លួន ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ មានសេចក្តីប្រណែន ១ មានសេចក្តីកំណាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះឯង រមែងមិនជាទីស្រឡាញ់ផង មិនជាទីពេញចិត្តផង មិនជាទីគោរពផង មិនជាទីសរសើរផង របស់សព្រហ្មចារីទាំង-ឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រាថ្នាលាភ ១ មិនប្រាថ្នាសក្ការៈ ១ មិនប្រាថ្នា មិនចង់ឲ្យគេមើលងាយខ្លួន ១ ខ្មាសបាប ១ ខ្លាចបាប ១ មិនមានសេចក្តីប្រណែន ១ មិនមានសេចក្តីកំណាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះឯង រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់សព្រហ្មចារីទាំងឡាយ ។

# អដ្ឋកថា

## ទុតិយអប្បិយសូត្រ

[ ២ ] ក្នុងអប្បិយសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយអប្បិយសូត្រទី ២ ចប់

# សុត្តន្តបិដក

## បឋមពលសូត្រទី ៣

[ ៣ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៧ យ៉ាង ។ កម្លាំង ៧ យ៉ាង តើអ្វីខ្លះ ។ កម្លាំង គឺសទ្ធា ១ កម្លាំង គឺសេចក្ដីព្យាយាម ១ កម្លាំង គឺហិរិ ១ កម្លាំង គឺឱត្តប្បៈ ១ កម្លាំង គឺសតិ ១ កម្លាំង គឺសមាធិ ១ កម្លាំង គឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងកម្លាំង ៧ យ៉ាង ។

កម្លាំង គឺសទ្ធា កម្លាំង គឺវិរិយៈ កម្លាំង គឺហិរិ កម្លាំង គឺ
ឱត្តប្បៈ កម្លាំង គឺសតិ កម្លាំង គឺសមាធិ កម្លាំង គឺបញ្ញា ជា
គម្រប់ ៧ ភិក្ខុជាបណ្ឌិត មានកម្លាំងដោយកម្លាំងទាំងនេះ រមែង
រស់នៅស្រួល ពិចារណាធម៌ដោយឧបាយ តែងឃើញច្បាស់
នូវអត្ថ ដោយបញ្ញាបាន ការរួចស្រឡះ ( ចាកអារម្មណ៍ )
នៃចិត្តរបស់ភិក្ខុនោះ ដូចជាការរលត់នៃប្រទីប ។

# អដ្ឋកថា

## បឋមពលសូត្រ

[ ៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមពលសូត្រទី ៣ ដូចតទៅនេះ បទថា **យោនិសោ វិចិនេ ធម្មំ** សេចក្ដីថា រមែងជ្រើសធម៌ គឺសច្ចៈ ៤ ដោយឧបាយ ។ បទថា **បញ្ញាយត្ថំ វិបស្សតិ** សេចក្ដីថា រមែងឃើញសច្ចធម៌ដោយបញ្ញាដែលសម្បយុត្តដោយមគ្គ មួយអន្លើដោយវិបស្សនា ។ បទថា **បជ្ជោតស្សេវ** សេចក្ដីថា ហាក់បីដូចការរលត់នៃប្រទីប ដូច្នោះ ។ បទថា **វិមោក្ខោ ហោតិ ចេតសោ** សេចក្ដីថា ចរិមកចិត្ត គឺចិត្តដួងចុងក្រោយរបស់ព្រះខីណាស្រពដែលប្រកបដោយពលទាំងនេះ រមែងរួចផុតចាកវត្ថុ និងអារម្មណ៍ ដូចការរលត់ទៅនៃប្រទីប ដូច្នោះ គឺរមែងមិនប្រាកដទីទៅ ។

**អដ្ឋកថា បឋមពលសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ទុតិយពលសូត្រទី ៤

[ ៤ ] ម្នាលភិក្ខុទាំងឡាយ ពលនេះមាន ៧ យ៉ាង ។ ៧ យ៉ាងតើអ្វីខ្លះ ។ គឺសទ្ធាពល ១ វីរិយពល ១ ហិរិពល ១ ឱត្តប្បពល ១ សតិពល ១ សមាធិពល ១ បញ្ញាពល ១ ។ ម្នាលភិក្ខុទាំងឡាយ សទ្ធាពល តើដូច

ម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធា រមែងជឿចំពោះពោធិញ្ញាណ របស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ។បេ។ ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ ទ្រង់កម្ចាត់បង់នូវត្រៃកព ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាសទ្ធាពល ។ ម្នាលភិក្ខុទាំងឡាយ វិរិយពល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ប្រារព្ធសេចក្តីព្យាយាម ដើម្បីលះនូវអកុសលធម៌ទាំងឡាយ ដើម្បីបំពេញនូវកុសលធម៌ទាំងឡាយ ជាអ្នកមានកម្លាំងព្យាយាម ប្រឹងប្រែងមុតមាំ មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិរិយពល ។ ម្នាលភិក្ខុទាំងឡាយ ហិរិពល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្តីអៀនខ្មាស រមែងអៀនខ្មាសកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងអៀនខ្មាសនូវការជួបប្រសព្វ នូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ហិរិពល ។ ម្នាលភិក្ខុទាំងឡាយ ឱត្តប្បពល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្តីតក់ស្លុត រមែងតក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងតក់ស្លុតនូវការជួបប្រសព្វ នូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឱត្តប្បពល ។ ម្នាលភិក្ខុទាំងឡាយ សតិពល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសតិ ប្រកប

ដោយសតិ និងភាពជាអ្នកមានបញ្ញាចាស់ក្លាដ៏ឧត្តម ជាអ្នកនឹករឭកចាំបាន នូវអំពើដែលខ្លួន ធ្វើយូរហើយផង នូវសម្តីដែលខ្លួននិយាយយូរហើយផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិពល ។ ម្នាលភិក្ខុទាំងឡាយ សមាធិពល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលដល់នូវចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមាធិពល ។ ម្នាលភិក្ខុទាំងឡាយ បញ្ញាពល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា រមែងប្រកបដោយបញ្ញា ជាគ្រឿងដឹងច្បាស់នូវការកើតឡើង និងសូន្យទៅ ( នៃខន្ធ ៥ ) ជាបញ្ញាប្រសើរមោះមុត ជាគ្រឿងដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បញ្ញាពល ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ពល ៧ យ៉ាង ។

> សទ្ធាពល វីរិយពល ហិរិពល ឱត្តប្បពល សតិពល
> សមាធិពល បញ្ញាពលជាគម្រប់ ៧ ។ ភិក្ខុជាបណ្ឌិត មាន
> កម្លាំងដោយពលទាំងនេះ រមែងរស់នៅស្រួល ពិចារណាធម៌
> ដោយឧបាយ ឃើញច្បាស់នូវអត្ថដោយបញ្ញា ការរួចស្រឡះ
> ( ចាកអារម្មណ៍ ) នៃចិត្ត ( របស់ភិក្ខុនោះ ) ដូចជាការ
> រលត់នៃប្រទីប ។

# អដ្ឋកថា

## ទុតិយពលសូត្រ

[ ៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយពលសូត្រទី ៤ ដូចតទៅនេះ ទុតិយពលសូត្រទី ៤ មានពាក្យថា **សទ្ធោ ហោតិ** ជាដើម បានពណ៌នាហើយ ក្នុងបញ្ចកនិបាតនោះឯង ។

### អដ្ឋកថា ទុតិយពលសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមធនសូត្រទី ៥

[ ៥ ] ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះមាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ ទ្រព្យ គឺសទ្ធា ១ ទ្រព្យ គឺសីល ១ ទ្រព្យ គឺហិរិ ១ ទ្រព្យ គឺឱត្តប្បៈ ១ ទ្រព្យ គឺសុតៈ ១ ទ្រព្យ គឺចាគៈ ១ ទ្រព្យ គឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះទ្រព្យ ៧ យ៉ាង ។

ទ្រព្យ គឺសទ្ធា ទ្រព្យ គឺសីល ទ្រព្យ គឺហិរិ ទ្រព្យ គឺឱត្តប្បៈ
ទ្រព្យ គឺសុតៈ ទ្រព្យ គឺចាគៈ ទ្រព្យ គឺបញ្ញាជាគម្រប់ ៧ ។
បុគ្គលណា ទោះស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ អ្នកប្រាជ្ញ
ទាំងឡាយ ហៅបុគ្គលនោះថា ជាអ្នកមិនទ័លក្រឡើយ ការ

*រស់នៅរបស់បុគ្គលនោះ មិនសោះសូន្យឡើយ ។ ហេតុនោះ អ្នកប្រាជ្ញ កាលរឭកនូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបរឿយៗ នូវសទ្ធា សីល សេចក្តីជ្រះថ្លា និងការឃើញនូវធម៌ ។*

# អដ្ឋកថា

## បឋមធនសូត្រ

[ ៥ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមធនសូត្រទី ៥ ដូចតទៅនេះ បទថា* **ធនានិ** *បានដល់ ឈ្មោះថា ទ្រព្យ ព្រោះអត្ថថា ព្រោះបុគ្គលដែលមិនក្រធ្វើបាន ។*

**អដ្ឋកថា បឋមធនសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយធនសូត្រទី ៦

[ ៦ ] *ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះមាន ៧ យ៉ាង ។ ៧ យ៉ាង តើ*

អ្វីខ្លះ ។ ទ្រព្យ គឺសទ្ធា ១ ទ្រព្យ គឺសីល ១ ទ្រព្យ គឺហិរិ ១ ទ្រព្យ គឺឱត្តប្បៈ ១ ទ្រព្យ គឺសុតៈ ១ ទ្រព្យ គឺចាគៈ ១ ទ្រព្យ គឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យ គឺសទ្ធា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធា រមែងជឿចំពោះពោធិញ្ញាណ របស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ។បេ។ ព្រះអង្គត្រាស់ដឹងនូវសច្ចធម៌ ទ្រង់កាច់បង់នូវត្រៃភព ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺសទ្ធា ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យ គឺសីល តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ ជាអ្នកវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺសីល ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យ គឺហិរិ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្ដីអៀនខ្មាស រមែងអៀនខ្មាសចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងខ្មាសនូវការជួបប្រសព្វ នូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺហិរិ ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យ គឺឱត្តប្បៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្ដីតក់ស្លុត រមែងតក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងតក់ស្លុតចំពោះការជួបប្រសព្វ នូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺឱត្តប្បៈ ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យ គឺ

សុតៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសានានេះ ជាពហុស្សូត ទ្រទ្រង់នូវចំណេះ សន្សំទុកនូវចំណេះ ធម៌ទាំងឡាយណា ពីរោះបទដើម ពីរោះបទកណ្តាល និងពីរោះបទចុង រមែងប្រកាសព្រហ្មចរិយធម៌ ប្រកបដោយអត្ថ និងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយនោះ ដែលអរិយសាវកមានសភាពដូច្នោះ បានស្តាប់មកច្រើន បានទ្រទ្រង់ទុក បានចាំស្ទាត់រត់មាត់ បានចូលចិត្តច្បាស់លាស់ បានយល់ច្បាស់ ដោយទិដ្ឋិ គឺបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺសុតៈ ។ ម្នាលភិក្ខុទាំង-ឡាយ ទ្រព្យ គឺចាគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ បានបរិច្ចាគរួចហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះ ជាអ្នកគួរដល់សូម ត្រេកអរក្នុងការចែករំលែកទាន រមែងនៅគ្រប់គ្រងផ្ទះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺចាគៈ ។ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានបញ្ញា ។បេ។ ជាគ្រឿងដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យ គឺបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះឯងទ្រព្យ ៧ យ៉ាង ។

ទ្រព្យ គឺសទ្ធា ទ្រព្យ គឺសីល ទ្រព្យ គឺហិរិ ទ្រព្យ គឺឱត្តប្បៈ
ទ្រព្យ គឺសុតៈ ទ្រព្យ គឺចាគៈ ទ្រព្យ គឺបញ្ញាជាគម្រប់ ៧
បុគ្គលណា ទោះស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ អ្នកប្រាជ្ញ

ទាំងឡាយ ហៅបុគ្គលនោះថា ជាអ្នកមិនទ័លក្រ ការរស់នៅរបស់បុគ្គលនោះ មិនសោះសូន្យឡើយ ។ ហេតុដូច្នោះ អ្នកប្រាជ្ញកាលរឭកនូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបរឿយៗ នូវសទ្ធា សីល សេចក្ដីជ្រះថ្លា និងការឃើញនូវធម៌ ។

# អដ្ឋកថា

## ទុតិយធនសូត្រ

[ ៦ ] ក្នុងទុតិយធនសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយធនសូត្រទី ៦ ចប់

# សុត្តន្តបិដក

## ឧគ្គសូត្រទី ៧

[ ៧ ] គ្រានោះឯង ឧគ្គរាជមហាមាត្យ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ

ក្នុងទីសមគួរ ។ លុះឧគ្គរាជមហាមាត្យអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះមិគារសេដ្ឋីជាចៅរបស់រោហណសេដ្ឋីនេះ ពេញជាមនុស្សស្តុកស្តម្ភផង ជាអ្នកមានទ្រព្យច្រើនផង មានភោគៈច្រើនផង ។ ម្នាលឧគ្គៈ មិគារសេដ្ឋីជាចៅរបស់រោហណ-សេដ្ឋីស្តុកស្តម្ភ តើអាស្រ័យរបស់អ្វី មានទ្រព្យច្រើន តើអាស្រ័យរបស់អ្វី មានភោគៈច្រើន តើអាស្រ័យរបស់អ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន មាសរាប់បានជាសែនទៅហើយ ចាំបាច់ពោលទៅថ្វីដល់រូបិយវត្ថុ ។ ម្នាលឧគ្គៈ ទ្រព្យនុ៎ះមានមែនហើយ ម្នាលឧគ្គៈ តថាគតមិននិយាយថា ទ្រព្យនុ៎ះគ្មានទេ ប៉ុន្តែទ្រព្យនោះឯង ជាសាធារណៈដល់ភ្លើង ទឹក ពួកស្តេច ពួកចោរ និងពួកញាតិមិនជាទីស្រឡាញ់ ។ ម្នាលឧគ្គៈ ទ្រព្យនេះមាន ៧ យ៉ាង ជារបស់មិនសាធារណៈដល់ភ្លើង ទឹក ពួកស្តេច ពួកចោរ និងពួកញាតិមិនជាទីស្រឡាញ់ ។ ៧ យ៉ាង តើអ្វីខ្លះ ។ សទ្ធាធនៈ ១ សីលធនៈ ១ ហិរិធនៈ ១ ឱត្តប្បធនៈ ១ សុតធនៈ ១ ចាគធនៈ ១ បញ្ញាធនៈ ១ ។ ម្នាលឧគ្គៈ ទ្រព្យ ៧ យ៉ាងនេះឯង មិនសាធារណៈដល់ភ្លើង ទឹក ពួកស្តេច ពួកចោរ និងពួកញាតិ មិនជាទីស្រឡាញ់បានឡើយ ។

សទ្ធាធនៈ សីលធនៈ ហិរិធនៈ ឱត្តប្បធនៈ សុតធនៈ ចាគ
ធនៈ បញ្ញាធនៈជាគម្រប់ ៧ ។ បុគ្គលណាទោះស្ត្រីក្តី បុរសក្តី

មានទ្រព្យទាំងនេះ បុគ្គលនោះឯង ឈ្មោះថា មានទ្រព្យច្រើន ដែលអ្នកណាមួយ មិនគប្បីផ្ដាញ់បាន ក្នុងទេវលោក និង មនុស្សលោក ។ ហេតុដូច្នោះ អ្នកប្រាជ្ញកាលរឭកនូវពាក្យ ប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបរឿយៗ នូវ សទ្ធា សីល សេចក្ដីជ្រះថ្លា និងការឃើញនូវធម៌ ។

# អដ្ឋកថា

## ឧគ្គសូត្រ

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧគ្គសូត្រទី ៧ ដូចតទៅនេះ បទថា **ឧគ្គោ រាជមហាមត្តោ** បានដល់ មហាមាត្យរបស់ព្រះបាទបសេនទិកោសល ។ បទថា **ឧបសង្កមិ** សេចក្ដីថា ជាអ្នកបរិភោគអាហារព្រឹកស្រេចហើយ ទើប ចូលទៅគាល់ ។

បទថា **អឌ្ឍោ** សេចក្ដីថា ជាអ្នកស្ដុកស្ដម្ភព្រោះទ្រព្យដែលបានរក្សា ។ បទថា **មិគារោ រោហណេយ្យោ** នេះ ព្រះមានព្រះភាគត្រាស់សំដៅ យក មិគារសេដ្ឋីដែលជាចៅរបស់រោហណសេដ្ឋី ។ បទថា **មហទ្ធនោ** បាន ដល់ ជាអ្នកមានទ្រព្យច្រើន ដោយទ្រព្យសម្រាប់ប្រើប្រាស់ ។ បទថា **មហាភោគោ** បានដល់ ជាអ្នកមានភោគៈច្រើន ព្រោះមានវត្ថុឧបភោគ និង

បរិភោគច្រើន ។ បទថា **ហិរញ្ញស្ស** បានដល់ មាសនោះឯង ។ ពិតហើយ ព្រោះមាសរបស់សេដ្ឋីនោះ រាប់បានច្រើនកោដិ ។ បទថា **រូបិយស្ស** សេចក្តីថា ពោលចំពោះគ្រឿងចាយវាយប្រើប្រាស់ ដូចជាទីដេក កន្ទេល ផ្តិល កម្រាល និងសំពត់ដណ្តប់ជាដើម ប្រមាណមិនបាន ។៚

**អដ្ឋកថា ឧគ្គសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សំយោជនសូត្រទី ៨

[ ៨ ] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈនេះមាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺអនុនយសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ភវរាគសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង សញ្ញោជនៈ ៧ យ៉ាង ។

# អដ្ឋកថា

## សំយោជនសូត្រ

[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសំយោជនសូត្រទី ៨ ដូចតទៅនេះ បទថា

**អនុនយសញ្ញោជនំ** បានដល់ កាមរាគសំយោជនៈ ។ សេចក្ដីពិត សំយោជនៈទាំងអស់នេះឯង គប្បីជ្រាបថា ឈ្មោះថា សំយោជនៈ ព្រោះអត្ថថា ជាគ្រឿងចង ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ចំពោះវដ្ដៈតែម្យ៉ាង ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ទាំងអស់ហើយ ។៙

**អដ្ឋកថាសំយោជនសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បហានសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្ដាច់ផ្ដិលនូវសញ្ញោជនៈ ៧ យ៉ាង ។ ៧ យ៉ាង តើដូចម្ដេច ។ គឺភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្ដាច់ផ្ដិលនូវអនុនយសញ្ញោជនៈ បដិឃសញ្ញោជនៈ ។បេ។ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្ដាច់ផ្ដិលនូវទិដ្ឋិសញ្ញោជនៈ វិចិកិច្ឆាសញ្ញោជនៈ មានសញ្ញោជនៈ ភវរាគសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្ដាច់ផ្ដិល នូវសញ្ញោជនៈទាំង ៧ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលណាអនុនយសញ្ញោជនៈ ភិក្ខុបានលះស្រឡះហើយ ផ្ដាច់ផ្ដិលឫសគល់

អស់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព មិនមានទីកើតតទៅទៀតជាធម្មតា បដិឃសញ្ញោជនៈ ។បេ។ ទិដ្ឋិសញ្ញោជនៈ វិចិកិច្ឆាសញ្ញោជនៈ មានសញ្ញោជនៈ ភវរាគសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ ភិក្ខុបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫលគល់អស់ហើយ មិនមានទីកើត ដូចជាដើមត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព មិនមានទីកើតតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ទើបហៅថា បានកាត់តណ្ហា បានស្រាយនូវសញ្ញោជនធម៌ ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះត្រាស់ដឹងនូវមានះដោយប្រពៃ ។

# អដ្ឋកថា

## បហានសូត្រ

[ ៩ ] ក្នុងបហានសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបហានសូត្រទី ៩ ចប់

# សុត្តន្តបិដក

## មច្ឆរិយសូត្រទី ១០

[ ១០ ] ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈនេះមាន ៧ យ៉ាង ៗ ៧ យ៉ាង តើអ្វីខ្លះ ៗ គឺអនុនយសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ឥស្សាសញ្ញោជនៈ ១ មច្ឆរិយសញ្ញោជនៈ ១ ៗ ម្នាលភិក្ខុទាំងឡាយ នេះសញ្ញោជនៈ ៧ យ៉ាង ៗ

ធនវគ្គទី ១ ចប់

### ឧទ្ទាននៃធនវគ្គនោះគឺ

និយាយពីភិក្ខុជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ពីរលើក កម្លាំង ១ ទ្រព្យ ១ ( ទាំងសង្ខេបទាំងពិស្តារ ) ឧគ្គរាជមហាមាត្យ ១ ការលះបង់សញ្ញោជនៈ ១ មានមច្ឆរិយៈជាទីបំផុត ១ ៗ

# អដ្ឋកថា

## មច្ឆរិយសូត្រ

[ ១០ ] ក្នុងមច្ឆរិយសូត្រទី ១០ មានអត្ថងាយយល់ហើយ ៗ

### អដ្ឋកថាមច្ឆរិយសូត្រទី ១០ ចប់

### ធនវគ្គទី ១ ចប់

# សុត្តន្តបិដក

## អនុសយវគ្គ

### បឋមអនុសយសូត្រទី ១

[ ១១ ] ម្នាលភិក្ខុទាំងឡាយ អនុសយៈនេះមាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺកាមរាគានុសយៈ ១ បដិឃានុសយៈ ១ ទិដ្ឋានុសយៈ ១ វិចិកិច្ឆានុសយៈ ១ មានានុសយៈ ១ ភវរាគានុសយៈ ១ អវិជ្ជានុសយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះអនុសយៈ ៧ យ៉ាង ។

### ទុតិយអនុសយសូត្រទី ២

[ ១២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវអនុសយៈទាំង ៧ ។ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិល នូវកាមរាគានុសយៈ បដិឃានុសយៈ ។បេ។ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិល នូវទិដ្ឋានុសយៈ វិចិកិច្ឆានុសយៈ មានានុសយៈ ភវរាគានុសយៈ អវិជ្ជានុសយៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីលះ ដើម្បីផ្តាច់ផ្តិលនូវអនុសយៈ ៧ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលណា កាមរាគានុសយៈ ភិក្ខុបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព មិនមានទីកើតតទៅទៀតជាធម្មតា បដិឃានុសយៈ ។បេ។ ទិដ្ឋានុសយៈ វិចិកិច្ឆា-

នុសយៈ មានានុសយៈ ភវរាគានុសយៈ អវិជ្ជានុសយៈ ភិក្ខុបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាត្នោតកំបុតក ធ្វើឲ្យលែងមានបែបភាព មិនមានទីកើតតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ទើបហៅថា បានកាត់តណ្ហា បានស្រាយនូវសញ្ញោជនៈ បានធ្វើនូវទីបំផុតនៃទុក្ខ ព្រោះបានត្រាស់ដឹងនូវមានះ ដោយប្រពៃ ។

# កុលសូត្រទី ៣

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាង ភិក្ខុមិនទាន់ចូលទៅជិត មិនគួរចូលទៅជិតទេ ឬបានចូលទៅជិតហើយ មិនគួរអង្គុយឡើយ ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺពួកជនមិនក្រោកទទួលដោយសេចក្តីពេញចិត្ត ១ មិនថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ មិនប្រគេនអាសនៈដោយសេចក្តីពេញចិត្ត ១ លាក់ទុកនូវទេយ្យធម៌របស់គេ ១ កាលបើទេយ្យធម៌មានច្រើនឲ្យតិច ១ កាលបើមានទេយ្យដ៏ឧត្តម ឲ្យរបស់សៅហ្មង ១ ឲ្យដោយសេចក្តីមិនគោរព មិនឲ្យដោយសេចក្តីគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាងនេះឯង ភិក្ខុមិនទាន់ចូលទៅជិត មិនគួរចូលទៅជិតទេ ឬបានចូលទៅជិតហើយ មិនគួរអង្គុយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាងភិក្ខុមិនទាន់ចូលទៅជិត គួរចូលទៅជិតបាន ឬបានចូលទៅជិតហើយ គួរអង្គុយបាន ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺពួកជនក្រោកទទួលដោយសេចក្តីពេញចិត្ត ១ ថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ ប្រគេនអាសនៈដោយសេចក្តីពេញចិត្ត ១ មិនលាក់ទុកនូវទេយ្យធម៌របស់គេ ១ កាលបើមានទេយ្យធម៌ច្រើនប្រគេនច្រើន ១ កាលបើមានទេយ្យ-

ធម៌ដ៏ឧត្តម ប្រគេនទេយ្យធម៌ដ៏ឧត្តម ១ តែងប្រគេនដោយសេចក្តីគោរព មិនប្រគេនដោយសេចក្តីមិនគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៧ យ៉ាងនេះឯង ភិក្ខុមិនទាន់ចូលទៅជិត គួរចូលទៅជិតបាន ឬចូលទៅជិតហើយ គួរអង្គុយបាន ។

# អដ្ឋកថា

# អនុសយវគ្គទី ២

## កុលសូត្រ

[ ១៣ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងកុលសូត្រទី ៣ នៃអនុសយវគ្គទី ២ ដូចតទៅនេះ បទថា* **ឆាលំ** *ប្រែថា មិនគួរ គឺមិនសមគួរ ។ បទថា* **ឆមនាបេន** *សេចក្ដីថា ក្រោកចាកអាសនៈដែលខ្លួនអង្គុយ ដោយអាការមិនសូវពេញចិត្ត គឺសម្ដែងអាការមិនពេញចិត្តនោះឯង ។ ពីរបទថា* **សន្តមស្ស បរិគូហន្តិ** *សេចក្ដីថា រមែងលាក់ គឺរមែងបិទបាំងទេយ្យធម៌ដែលមានដល់ភិក្ខុនោះ ។ បទថា* **អសក្កច្ចំ ទេន្តិ នោ សក្កច្ចំ** *សេចក្ដីថា ទោះជាវត្ថុសៅហ្មងក្ដី ប្រណីតក្ដី ឲ្យមិនមែនដោយដៃរបស់ខ្លួន គឺដោយអាការមិនគោរពក្រែង រមែងមិនឲ្យដោយអាការគោរពក្រែង ។៚*

**អដ្ឋកថា កុលសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## បុគ្គលសូត្រទី ៤

[ ១៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ គួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់នូវអញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ៧ ពួក តើអ្វីខ្លះ ។ គឺឧភតោភាគវិមុត្ត ១ បញ្ញាវិមុត្ត ១ កាយសក្ខិ ១ ទិដ្ឋិប្បត្តៈ ១ សទ្ធាវិមុត្ត ១ ធម្មានុសារី ១ សទ្ធានុសារី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះឯង គួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទានដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្មដែលសត្វលោកគប្បីធ្វើជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## បុគ្គលសូត្រ

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុគ្គលសូត្រទី ៤ ដូចតទៅនេះ បទថា **ឧភតោភាគវិមុត្តោ** សេចក្តីថា រួចផុតហើយដោយចំណែកទាំង ២ អធិប្បាយថា រួចផុតហើយចាករូបកាយ ដោយអរូបសមាបត្តិ និងរួចផុតហើយចាក

នាមកាយដោយមគ្គ ។ បុគ្គលនោះ មាន ៥ ពួក គឺបុគ្គលដែលចេញចាក អរូបសមាបត្តិ ៤ ណាមួយ ហើយពិចារណាសង្ខារ សម្រេចអរហត្ត ៤ ពួក និងព្រះអនាគាមី ចេញអំពីនិរោធហើយ សម្រេចអរហត្តមួយពួក ។ តែបាលីក្នុងព្រះសូត្រ មកហើយដោយអំណាចអ្នកបានវិមោក្ខ ៨ យ៉ាងនេះថា បុគ្គលជាឧភតោភាគវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បាន វិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈរបស់បុគ្គលនោះ ក៏អស់ទៅព្រោះ ឃើញដោយបញ្ញា នេះហៅថា បុគ្គលជាឧភតោភាគវិមុត្ត ។

បុគ្គលឈ្មោះថា បញ្ញាវិមុត្តិ ព្រោះរួចផុតដោយបញ្ញា ។ បញ្ញាវិមុត្តិ នោះ មាន ៥ ពួក បានដល់ បុគ្គលទាំងនេះ គឺព្រះអរហន្តសុក្ខវិបស្សកៈ ១ ពួក លោកដែលចេញចាកឈាន ៤ ហើយសម្រេចអរហត្ត ៤ ពួក ។ តែបាលីក្នុងសូត្រនេះ មកហើយដោយបដិសេធវិមោក្ខ ៨ ដូចព្រះធម្មសង្គាហកាចារ្យពោលថា បុគ្គលជាបញ្ញាវិមុត្តិ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនបានវិមោក្ខ ៨ ដោយនាមកាយទេ អាសវៈរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាបញ្ញាវិមុត្តិ ។

បុគ្គលឈ្មោះថា កាយសក្ខី ព្រោះធ្វើវិមោក្ខនោះ ដែលខ្លួនធ្វើឲ្យជាក់ច្បាស់ហើយ ដោយនាមកាយ ។ កាយសក្ខីបុគ្គលនោះ រមែងត្រូវឈានសម្ផស្សមុន រមែងធ្វើឲ្យជាក់ច្បាស់នូវនិរោធ គឺព្រះនិព្វានខាងក្រោយ ។ កាយសក្ខីបុគ្គលនោះ រាប់តាំងអំពីព្រះអរិយបុគ្គលដែលតាំងនៅក្នុងសោតា-

បត្តិផល រហូតដល់ព្រះអរិយបុគ្គល ដែលតាំងនៅក្នុងអរហត្តមគ្គ រួមជា ៦ ពួក ព្រោះហេតុនោះ ទើបលោកពោលថា បុគ្គលជាកាយសក្ខី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈពួកខ្លះរបស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាកាយសក្ខី ។

បុគ្គលឈ្មោះថា ទិដ្ឋិប្បត្ត ព្រោះដល់នូវអរិយសច្ចធម៌ ដែលខ្លួនឃើញហើយ ។ ក្នុងទិដ្ឋិប្បត្តបុគ្គលនោះ មានលក្ខណៈសង្ខេបដូចតទៅនេះ បុគ្គលឈ្មោះថា ទិដ្ឋិប្បត្ត ព្រោះដឹង ឃើញ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវដោយបញ្ញាថា សង្ខារទាំងឡាយជាទុក្ខ ការរម្ងត់សង្ខារជាសុខ ដូច្នេះ ។ តែកាលពោលដោយពិស្តារ បុគ្គលនោះ រមែងមាន ៦ ពួក ដូចកាយសក្ខីបុគ្គលដែរ ដោយហេតុនោះឯង ទើបលោកពោលថា បុគ្គលជាទិដ្ឋិប្បត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះធម៌រលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌រលត់ទុក្ខ ធម៌ទាំងឡាយ ដែលព្រះតថាគតសម្តែងហើយ បុគ្គលនោះ បានឃើញដោយល្អ បានប្រព្រឹត្តដោយល្អ ដោយបញ្ញាផង អាសវៈពួកខ្លះ របស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញាផង នេះហៅថា បុគ្គលជាទិដ្ឋិប្បត្ត ។

បុគ្គល ឈ្មោះថា សទ្ធាវិមុត្តិ ព្រោះរួចផុតដោយសទ្ធា សទ្ធាវិមុត្តបុគ្គល

នោះ ក៏មាន ៦ ពួក ដោយន័យដូចពោលហើយនោះឯង ។ ដោយហេតុនោះ ទើបលោកពោលថា បុគ្គលជាសទ្ធាវិមុត្តិ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះធម៌រលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាជាដំណើរទៅកាន់ធម៌រលត់ទុក្ខ ធម៌ទាំងឡាយដែលព្រះតថាគតសម្តែងហើយ បុគ្គលនោះបានឃើញដោយល្អ បានប្រព្រឹត្តដោយល្អ ដោយបញ្ញាផង អាសវៈពួកខ្លះរបស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញាផង តែមិនដូចជាទិដ្ឋិប្បត្តបុគ្គលទេ នេះហៅថា បុគ្គលជាសទ្ធាវិមុត្ត ។ ព្រោះការអស់កិលេសរបស់សទ្ធាវិមុត្តបុគ្គលនេះ ដូចការអស់កិលេស នៃបុគ្គលដែលជឿ ដាក់ចិត្តជឿ និងបង្អោនចិត្តជឿក្នុងមគ្គក្ខណៈ ដែលជាចំណែកខាងដើមដូច្នោះ ញាណដែលជាគ្រឿងកាត់កិលេស ក្នុងមគ្គក្ខណៈដែលជាចំណែកខាងដើមនៃទិដ្ឋិប្បត្តបុគ្គល ជាញាណមិនរហ័ស មិនខ្លាំងក្លា មិនមុតស្រួចកាត់កិលេសមិនបានរហ័ស ព្រោះហេតុនោះ ដូចបុគ្គលប្រើដាវ ដែលមិនមុតកាត់នូវដើមចេក ស្នាមដាច់នៃដើមចេក រមែងមិនរលោង ដាវក៏មិនស្ទុះទៅរហ័ស សំឡេងក៏ឮ ត្រូវប្រើសេចក្តីព្យាយាមខ្លាំងក្លា យ៉ាងណា មគ្គភាវនាដែលជាចំណែកខាងដើមនៃសទ្ធាវិមុត្តបុគ្គលនោះ គប្បីជ្រាបដូច្នោះ ។ តែបុគ្គលយកដាវដែលសំលៀងល្អហើយ កាប់ដើមចេក ស្នាមដាច់នៃដើមចេក រមែងរលោង ដាវរមែងស្ទុះទៅរហ័ស សំឡេងមិនឮ មិនសូវប្រើព្យាយាមខ្លាំង

យ៉ាងណា មគ្គភាវនាដែលជាចំណែកខាងដើម នៃបញ្ញាវិមុត្តបុគ្គល ក៏គប្បីជ្រាបដូច្នោះដូចគ្នា ។

បុគ្គល ឈ្មោះថា ធម្មានុសារី ព្រោះតាមរឭកដល់ធម៌ ។ បញ្ញា ឈ្មោះថា ធម្ម ។ អធិប្បាយថា បុគ្គលរមែងចម្រើនមគ្គ ដែលមានបញ្ញាជាអ្នកនាំ ក្នុងបុគ្គលដែលជាសទ្ធានុសារី ក៏មានន័យដូចគ្នា ។ បុគ្គលទាំង ២ នោះ គឺបុគ្គលតាំងនៅក្នុងសោតាបត្តិមគ្គនោះឯង ។ សមដូចពាក្យដែលធម្មសង្គាហកាចារ្យពោលថា បុគ្គលជាធម្មានុសារី តើដូចម្តេច ។ បុគ្គលណា កំពុងប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតបត្តិផល មានឥន្ទ្រិយ គឺបញ្ញាដ៏ក្រៃលែង ចម្រើនអរិយមគ្គ មានបញ្ញាជាគ្រឿងនាំ មានបញ្ញាជាប្រធាន នេះហៅថា បុគ្គលជាធម្មានុសារី ។ ក្នុងធម្មានុសារីនោះ មានសេចក្តីសង្ខេបប្រមាណប៉ុណ្ណេះ ។ តែពោលដោយពិស្តារ កថាពោលដោយឧកតោភាគវិមុត្តបុគ្គលជាដើមនេះ ក៏ពោលហើយ ក្នុងអធិការពោលដោយបញ្ញាភាវនា ក្នុងវិសុទ្ធិមគ្គ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងបករណ៍នោះចុះ ។ល។

## អដ្ឋកថា បុគ្គលសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ឧទកូបមសូត្រទី ៥

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រៀបដូចអ្នកមុជទឹកក្នុងលោកនេះមាន ៧ ពួក ។ ៧ ពួក តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមុជទៅហើយ ក៏មុជបាត់ទៅតែម្តង ១ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយមុជចុះទៅវិញ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយឈរ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយក្រឡេករមិលមើល ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយ ហែលឆ្លងទៅ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយ បានដល់នូវទីពឹង ហើយឈរនៅ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះជាព្រាហ្មណ៍ក្នុងលោកនេះ ងើបឡើងហើយឆ្លងទៅដល់ត្រើយ ហើយឈរនៅលើគោក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកមុជហើយ ក៏មុជបាត់ទៅតែម្តងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកប្រកបដោយអកុសលធម៌ខ្មៅសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមុជទៅហើយក៏មុជបាត់ទៅតែម្តងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលងើបឡើងហើយមុជទៅវិញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះរមែងងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំង-ឡាយជាការល្អ សេចក្តីខ្មាសបាបជាការល្អ សេចក្តីតក់ស្លុតចំពោះបាបជា

ការល្អ សេចក្តីព្យាយាមជាការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយជាការល្អ ។ សទ្ធារបស់បុគ្គលនោះ មិនតាំងនៅ មិនចម្រើនឡើង រមែងសាបសូន្យទៅវិញ ។ ហិរិរបស់បុគ្គលនោះ ឱត្តប្បៈរបស់បុគ្គលនោះ វិរិយៈរបស់បុគ្គលនោះ បញ្ញារបស់បុគ្គលនោះ រមែងមិនតាំងនៅ មិនចម្រើនឡើង មានតែសាបសូន្យទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងាល ហើយមុជទៅវិញយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងាលហើយឈរតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយជាការល្អ សេចក្តីខ្មាសបាបជាការល្អ សេចក្តីតក់ស្លុតចំពោះបាបជាការល្អ សេចក្តីព្យាយាមជាការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយជាការល្អ ។ សទ្ធារបស់បុគ្គលនោះ ក៏មិនសាបសូន្យទៅ មិនចម្រើនឡើង រមែងតាំងនៅដដែល ។ ហិរិរបស់បុគ្គលនោះ ឱត្តប្បៈរបស់បុគ្គលនោះ វិរិយៈរបស់បុគ្គលនោះ បញ្ញារបស់បុគ្គលនោះ រមែងមិនសាបសូន្យទៅ មិនចម្រើនឡើង រមែងតាំងនៅដដែល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកងើបផ្ងាល ហើយឈរនៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងាលហើយក្រឡេករមិលមើលតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយជាការល្អ សេចក្តីខ្មាសបាបជាការល្អ សេចក្តីតក់ស្លុតចំពោះបាបជាការល្អ សេចក្តីព្យាយាមជា

ការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយជាការល្អ ។ បុគ្គលនោះជាសោតាបន្ន ព្រោះអស់សញ្ញោជនៈ ៣ យ៉ាង ជាអ្នកមានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិប្រព្រឹត្តទៅក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបឡើងហើយ ក្រឡេករមិលមើល យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបឡើង ហើយឆ្លងទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយជាការល្អ សេចក្តីខ្មាសបាបជាការល្អ សេចក្តីតក់ស្លុតចំពោះបាបជាការល្អ សេចក្តីព្យាយាមជាការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយជាការល្អ ។ បុគ្គលនោះជាសកទាគាមី ព្រោះអស់សញ្ញោជនៈទាំង ៣ យ៉ាង ព្រោះរាគៈ ទោសៈ មោហៈក៏ស្រាលស្តើង រមែងមកកាន់លោកនេះ អស់វារៈតែម្តង ហើយធ្វើនូវទីបំផុតនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបឡើងហើយឆ្លងទៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបឡើងហើយ ដល់នូវទីពឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយជាការល្អ សេចក្តីខ្មាសបាបជាការល្អ សេចក្តីតក់ស្លុត ចំពោះបាបជាការល្អ សេចក្តីព្យាយាមជាការល្អ ការដឹងច្បាស់ក្នុងកុសលធម៌ ទាំងឡាយជាការល្អ ។ បុគ្គលនោះជាឱបបាតិកៈ ព្រោះអស់សញ្ញោជនៈជាចំណែកខាងក្រោម ៥ យ៉ាងហើយបរិនិព្វានក្នុងលោកនោះ

មិនបានត្រឡប់មកចាកលោកនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ងើបឆ្ពោលហើយ ដល់នូវទីពឹងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ជាព្រាហ្មណ៍ ងើបឆ្ពោលហើយឆ្លងទៅដល់ត្រើយនាយ ហើយឈរនៅលើ គោក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើង ដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ សេចក្តីខ្មាសបាបជាការល្អ សេចក្តីតក់ស្លុតចំពោះបាបជាការល្អ សេចក្តី ព្យាយាម ជាការល្អ ការដឹងច្បាស់ ក្នុងពួកកុសលធម៌ ជាការល្អ ។ បុគ្គល នោះបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមាន អាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនក្នុង បច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាព្រាហ្មណ៍ងើបឆ្ពោល ហើយ ឆ្លងទៅដល់ត្រើយខាងនាយ ហើយឈរនៅលើគោក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះឯងបុគ្គល ៧ ពួក ប្រៀបដូចអ្នកមុជទឹក រមែងមាន ប្រាកដក្នុងលោក ។

# អដ្ឋកថា

## ឧទកូបមសូត្រទី ៥

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧទកូបមសូត្រទី ៥ ដូចតទៅនេះ បទថា

**ឧទកូបមា** សេចក្តីថា លោកប្រៀបដូចទឹក ព្រោះកាន់យកអាការមានមុជចុះជាដើម ។ ពីរបទថា **សកឹ និមុគ្គោ** បានដល់ មុជចុះម្តង ។ បទថា **ឯកន្តកាឡកេហិ** ទ្រង់ត្រាស់សំដៅដល់និយតមិច្ឆាទិដ្ឋិ ។ បទថា **ឧម្មុជ្ជតិ** ប្រែថា ផុសឡើង ។ បទថា **សាធុ** សេចក្តីថា ស្អាត គឺល្អ ។ បទថា **ហាយតិយេវ** សេចក្តីថា រមែងសូន្យទៅអស់នោះឯង ដូចទឹកដែលបុគ្គលដាក់ក្នុងធម្មក្រក ដូច្នោះ ។ បទថា **ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ** សេចក្តីថា បុគ្គលដែលផុសឡើងបានហើយ ពិចារណា គឺក្រឡេកមើលទិសដែលគួរទៅ ។ បទថា **បតរតិ** សេចក្តីថា ឈ្មោះថា ជាអ្នកបែរមុខចំពោះទិសដែលគួរទៅ ឆ្លងទៅ ។ ពីរបទថា **បតិគាធប្បត្តោ ហោតិ** បុគ្គលផុសឡើងមកហើយ សម្ងឹងមើលឆ្លងទៅ ឈ្មោះថា រមែងជួបទីពឹង រមែងឈរក្នុងទីមួយ មិនវិលត្រឡប់មកទៀត ។ បទថា **តិណ្ណោ បារគតោ ថលេ តិដ្ឋតិ** សេចក្តីថា បុគ្គលឆ្លងអន្លង់ គឺកិលេសទាំងពួង ដល់ត្រើយនាយហើយ ឈ្មោះថា រមែងជាអ្នកឈរលើគោក គឺព្រះនិព្វាន ។ វដ្តៈ និងវិវដ្តៈ ព្រះមានព្រះភាគត្រាស់ក្នុងសូត្រនេះ ៕

## អដ្ឋកថាឧទកូបមសូត្រទី ៩ ចប់

# សុត្តន្តបិដក

## អនិច្ចសូត្រទី ៦

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះគួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទានដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ៧ ពួក តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថាមិនទៀង មានសេចក្តីសម្គាល់ថាមិនទៀង ដឹងច្បាស់ថាមិនទៀងក្នុងសង្ខារទាំងពួង ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញារឿយៗ មិនដាច់ មិនឲ្យប្រទ្បំគ្នា ។ បុគ្គលនោះបានធ្វើឲ្យជាក់ច្បាស់ សម្រេច ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំង-ឡាយ នេះបុគ្គលទី ១ ដែលគួរទទួលចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទានដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថា មិនទៀង មានសេចក្តីសម្គាល់ថា មិនទៀង ដឹងច្បាស់ថា មិនទៀងក្នុងសង្ខារទាំងពួង ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញារឿយៗ មិនដាច់ មិនឲ្យប្រទ្បំគ្នា ។ ការអស់ទៅនៃអាសវៈ និងការអស់ទៅនៃជីវិតរបស់បុគ្គលនោះដំណាលគ្នាតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ២ ដែលគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់

សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថា មិនទៀង មានសេចក្តីសម្គាល់ថា មិនទៀង ដឹងច្បាស់ថា មិនទៀងក្នុងសង្ខារទាំងពួង ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញា រឿយៗ មិនដាច់ មិនឲ្យប្រទាំគ្នា ។ បុគ្គលនោះ ឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។បេ។ ឈ្មោះថា ឧបហច្ចបរិនិព្វាយី ឈ្មោះថា អសង្ខារបរិនិព្វាយី ឈ្មោះថា សសង្ខារបរិនិព្វាយី ឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី ។ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ៧ ដែលគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះឯង ដែលគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទាន ដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## អនិច្ចសូត្រ

[ ១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនិច្ចសូត្រទី ៦ ដូចតទៅនេះ បុគ្គលឈ្មោះថា **អនិច្චានុបស្សី** ព្រោះតាមឃើញ ពង្រីកទៅដោយបញ្ញាយ៉ាងនេះថា សង្ខារទាំងឡាយមិនទៀង ។ បុគ្គលឈ្មោះថា **អនិច្ចសញ្ញី** ព្រោះមានការសម្គាល់យ៉ាងនេះថា សង្ខារទាំងឡាយមិនទៀង ។ បុគ្គលឈ្មោះថា **អនិច្ចប្បដិសំវេទី** ព្រោះដឹងច្បាស់ដោយញាណយ៉ាងនេះថា សង្ខារទាំងឡាយមិនទៀង ។ បទថា **សតតំ** បានដល់ គ្រប់កាល ។ បទថា **សមិតំ** សេចក្តីថា ចិត្តដួងក្រោយដល់ហើយ គឺចូលដល់ហើយ បន្តជាមួយចិត្តដួងមុន យ៉ាងណា ចិត្តដួងមុនក៏បន្តនឹងចិត្តដួងក្រោយយ៉ាងនោះ ។ បទថា **អព្វោកិណ្ណំ** សេចក្តីថា បន្តគ្នាមិនដាច់រយៈ គឺមិនលាយឡំដោយចិត្តដួងដទៃ ។ បទថា **ចេតសា អធិមុច្ចមានោ** បានដល់ បង្អោនចិត្តទៅ ។ បទថា **បញ្ញាយ បរិយោគាហមានោ** បានដល់ តាមចូលទៅដោយវិបស្សនាញាណ ។

បទថា **អបុព្វំ អចរិមំ** បានដល់ មិនមុនមិនក្រោយ គឺក្នុងខណៈតែមួយនោះឯង ។ ព្រះមានព្រះភាគត្រាស់សមសីសីបុគ្គលទុកក្នុងព្រះសូត្រនេះ ។

សមសីសីបុគ្គលនោះ មាន ៤ ពួក គឺរោគសមសីសី ១ វេទនាសមសីសី ១ ឥរិយាបថសមសីសី ១ និងជីវិតសមសីសី ១ ។ បណ្តាបុគ្គល ៤ ពួកនោះ បុគ្គលណា ត្រូវរោគណាមួយបៀតបៀនហើយ រោគស្ងប់រម្ងាប់ ហើយអាសវៈក៏អស់ទៅក្នុងគ្រាតែមួយនោះឯង បុគ្គលនេះ ឈ្មោះថា

រោគសមសីសី ។ ឯបុគ្គលណាសោយវេទនាណាមួយ វេទនានោះស្ងប់រម្ងាប់ទៅ ហើយអាសវៈក៏អស់ទៅ ក្នុងគ្រាតែមួយនោះឯង បុគ្គលនេះ ឈ្មោះថា វេទនាសមសីសី ។ ចំណែកបុគ្គលណា ដល់ព្រមដោយឥរិយាបថណាមួយ មានការឈរជាដើម ឃើញច្បាស់ ឥរិយាបថក៏អស់ ហើយអាសវៈក៏អស់ទៅ ក្នុងខណៈតែមួយនោះឯង បុគ្គលនេះ ឈ្មោះថា ឥរិយាបថសមសីសី ។ ឯបុគ្គលព្យាយាមសម្លាប់ខ្លួនឲ្យស្លាប់ ឬធ្វើសមណធម៌ ជីវិតក៏អស់ទៅ អាសវៈក៏អស់ទៅដោយខណៈមួយនោះឯង បុគ្គលនេះ ឈ្មោះថា ជីវិតសមសីសី ។ ជីវិតសមសីសីបុគ្គលនេះ លោកបំណងយកក្នុងព្រះសូត្រនេះ ។ ក្នុងជីវិត-សមសីសីបុគ្គលនោះ មានអធិប្បាយថា ការអស់ទៅនៃអាសវៈ រមែងមានដោយមគ្គចិត្ត ការអស់នៃជីវិត រមែងមានដោយចុតិចិត្ត ក៏ពិត តែឈ្មោះថា ការកើតព្រមនៃធម៌ដែលអស់អាសវៈ និងការអស់នៃជីវិតទាំង ២ យ៉ាង រមែងមានក្នុងខណៈតែមួយមិនបាន ព្រោះគ្រាន់តែអាសវៈ នៃជីវិតសមសីសីបុគ្គលនោះអស់ទៅ ការអស់នៃជីវិតក៏មកដល់ ក្នុងលំដាប់វារៈនៃបច្ចវេក្ខណៈនោះឯង មិនប្រាកដឱកាស ដូច្នោះ ទើបលោកពោលយ៉ាងនេះ ។

បទថា **អន្តរាបរិនិព្វាយី** នេះ ជាឈ្មោះនៃព្រះអនាគាមិបុគ្គល ដែលកើតក្នុងភូមិណាមួយ បណ្តាសុទ្ធាវាសភូមិទាំង ៥ ឬហួសទៅបន្តិច ឬតាំងនៅត្រង់កណ្តាល ។ ក្នុងខណៈដែលកើត ហើយសម្រេចអរហត្ត ។

បទថា **ឧបហច្ចបរិនិព្វាយី** បានដល់ ព្រះអនាគាមិបុគ្គលកន្លងពាក់

កណ្ដាលអាយុក្ខ័យហើយ ទើបសម្រេចអរហត្តក្នុងសុទ្ធាវាសភូមិនោះឯង ។ បទថា **អសង្ខារបរិនិព្វាយី** បានដល់ ព្រះអនាគាមិបុគ្គលដែលធ្វើកិលេសទាំងឡាយឲ្យអស់ទៅ ដោយមិនចាំបាច់ដាស់តឿន មិនចាំបាច់ធ្វើសេចក្ដីព្យាយាមនៃបុគ្គលទាំងអស់នោះ ។ បទថា **សសង្ខារបរិនិព្វាយី** បានដល់ព្រះអនាគាមិបុគ្គលធ្វើកិលេសទាំងឡាយឲ្យអស់ទៅ ដោយត្រូវដាស់តឿន ត្រូវមានសេចក្ដីព្យាយាម ។ បទថា **ឧទ្ធំសោតោ អកនិដ្ឋគាមី** បានដល់ ព្រះអនាគាមិបុគ្គលដែលកើតក្នុងសុទ្ធាវាសភូមិជាន់ទាប ៤ ជាន់ណាមួយច្យុតិអំពីភូមិនោះហើយ កើតក្នុងអកនិដ្ឋភូមិដោយលំដាប់ ហើយសម្រេចអរហត្ត ។៚

អដ្ឋកថា អនិច្ចសូត្រទី ៦ ចប់

# សុត្តន្តបិដក

## ទុក្ខសូត្រទី ៧ អនត្តសូត្រទី ៨

## និព្វានសូត្រទី ៩

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ គួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ៧ ពួក តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញ

ជាទុក្ខក្នុងសង្ខារទាំងពួង ។បេ។ ពិចារណាឃើញថាអនត្តាក្នុងធម៌ទាំងពួង ពិចារណាឃើញថាសុខ មានសេចក្តីសម្គាល់ថាសុខ ដឹងច្បាស់ថាសុខក្នុងព្រះនិព្វាន ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញារឿយៗ មិនដាច់មិនឲ្យប្រទ្បំគ្នា ។ បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់ សម្រេច ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ១ ដែលគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថាសុខ មានសេចក្តីសម្គាល់ថាសុខ ដឹងច្បាស់ថាសុខ ក្នុងព្រះនិព្វាន ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញារឿយៗ មិនដាច់ មិនឲ្យប្រទ្បំគ្នា ។ ការអស់ទៅនៃអាសវៈ និងការអស់ទៅនៃជីវិតរបស់បុគ្គលនោះដំណាលគ្នាតែម្តង ។ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ២ ដែលគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថាសុខ មានសេចក្តីសម្គាល់ថាសុខ ដឹងច្បាស់ថាសុខ ក្នុងព្រះនិព្វាន ហើយកំណត់ដោយចិត្ត ស្ទង់មើលដោយបញ្ញារឿយៗ មិនដាច់ មិនឲ្យប្រទ្បំគ្នា ។ បុគ្គលនោះ ឈ្មោះអន្តរាបរិនិព្វាយី ព្រោះអស់សញ្ញោជនៈជាចំណែកខាងក្រោម ៥ ។បេ។ ឈ្មោះឧបហច្ចបរិនិព្វាយី ឈ្មោះថា អសង្ខារបរិនិព្វាយី ឈ្មោះថា សសង្ខារបរិនិព្វាយី ឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី ។ ម្នាល

ភិក្ខុទាំងឡាយ នេះបុគ្គលទី ៧ ដែលគួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះឯង គួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## ទុក្ខសូត្រទី ៧ អនត្តសូត្រទី ៨ និងនិព្វានសូត្រទី ៩

[ ១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុក្ខសូត្រទី ៧ ជាដើម ដូចតទៅនេះ បទថា **ទុក្ខានុបស្សី** បានដល់ បុគ្គលតាមឃើញអាការ គឺការបៀតបៀនដោយភាពជាទុក្ខ ។

បទថា **អនត្តានុបស្សី** បានដល់ បុគ្គលតាមឃើញអាការ គឺការមិនប្រព្រឹត្តទៅក្នុងអំណាចថា ធម៌ទាំងឡាយជាអនត្តា ដូច្នេះ ។

បទថា **សុខានុបស្សី** បានដល់ បុគ្គលតាមឃើញដោយញាណ គឺបញ្ញាយ៉ាងនេះថា ព្រះនិព្វានជាសុខ ។៚

**អដ្ឋកថា ទុក្ខសូត្រទី ៧ ជាដើមចប់**

# សុត្តន្តបិដក

## និទ្ទសវត្ថុសូត្រទី ១០

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ និទ្ទសវត្ថុទាំងឡាយនេះមាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការសមាទាននូវសិក្ខាតទៅ ក្នុងកាលខាងមុខក៏នៅតែមានសេចក្តីស្រឡាញ់ក្នុងការសមាទាននូវសិក្ខា ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លាក្នុងការពិចារណានូវធម៌ តទៅក្នុងកាលខាងមុខក៏នៅតែមានសេចក្តីស្រឡាញ់ក្នុងការពិចារណានូវធម៌ ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លាក្នុងការកម្ចាត់បង់នូវឥច្ឆា គឺតណ្ហា តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ ក្នុងការកម្ចាត់បង់ឥច្ឆា គឺតណ្ហា ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លាក្នុងការពួនសម្ងំ តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ក្នុងការពួនសម្ងំ ១ ជាអ្នកមានសេចក្តីពេញចិត្ត ដ៏ក្លៀវក្លាក្នុងការប្រារព្ធព្យាយាម តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ក្នុងការប្រារព្ធព្យាយាម ១ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការតាំងស្មារតី និងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា តទៅក្នុងកាលខាងមុខ ក៏នៅតែមានសេចក្តីស្រឡាញ់ក្នុងការតាំងស្មារតី និងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា ១ ជាអ្នកមានសេចក្តីពេញចិត្ត ដ៏ក្លៀវក្លាក្នុងការចាក់ធ្លុះដោយទិដ្ឋិ តទៅក្នុងកាលខាងមុខក៏នៅតែមានសេចក្តីស្រឡាញ់ក្នុងការចាក់ធ្លុះដោយទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងនិទ្ទសវត្ថុ ៧ យ៉ាង ។

***អនុសយវគ្គទី ២ ចប់***

## ឧទ្ទាននៃអនុសយវគ្គនោះគឺ

និយាយពីអនុស័យពីរលើក ត្រកូល ១ បុគ្គលគួរបូជា ១ បុគ្គលប្រៀបដូចអ្នកមុជទឹក ១ បុគ្គលអ្នកពិចារណាឃើញក្នុងសង្ខារថាមិនទៀង ១ ជាទុក្ខ ១ ជាអនត្តា ១ ព្រះនិព្វាន ១ និទ្ទសវត្ថុ ១ ។

# អដ្ឋកថា

## និទ្ទសវត្ថុសូត្រ

[ ១៨ ] ក្នុងនិទ្ទសវត្ថុសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថានិទ្ទសវត្ថុសូត្រទី ១០ ចប់**

**អនុសយវគ្គទី ២ ចប់**

# សុត្តន្តបិដក
# វជ្ជីវគ្គ

## សារន្ទទសូត្រទី ១

[ ១៩ ] *សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងសារន្ទទចេតិយ ជិតក្រុងវេសាលី ។ គ្រានោះឯង ពួកស្តេចលិច្ឆវីជាច្រើន ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះពួកស្តេចលិច្ឆវីទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ពាក្យនេះថា បពិត្រស្តេចលិច្ឆវីទាំងឡាយ តថាគតនឹងសម្តែងនូវអបរិហានិយធម៌ ៧ យ៉ាងដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកស្តេចលិច្ឆវីទាំងនោះ បានទទួលស្តាប់ព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា បពិត្រស្តេចលិច្ឆវីទាំងឡាយ ចុះអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ បើពួកស្តេចក្នុងដែនវជ្ជីនឹងមានការប្រជុំគ្នារឿយៗ មានការប្រជុំគ្នាដោយច្រើនអស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជីព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រម*

ព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជីអស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជី មិនបញ្ញត្តច្បាប់ ( ដែលពួកស្តេចពីដើម ) មិនបានបញ្ញត្ត មិនដកច្បាប់ ដែលបានបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជីអំពីបុរាណ ដែលបានបញ្ញត្តរួចហើយយ៉ាងណា អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជី ធ្វើសក្ការៈ គោរពរាប់អាន បូជា ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនជាងស្តេច ក្នុងដែនវជ្ជីទាំងឡាយ ទាំងសម្គាល់ពាក្យដែលគួរស្តាប់ របស់ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនជាងនោះ អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជី មិនកំហែងបង្ខំនូវពួកស្ត្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូលឲ្យនៅរួម អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ បពិត្រ

ស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលជាខាងក្នុងនគរក្តី ខាងក្រៅនគរក្តី នឹងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះ ឲ្យសាបសូន្យឡើយ អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ ពួកស្តេចក្នុងដែនវជ្ជី បានចាត់ចែងត្រឹមត្រូវនូវការរក្សាការពារ និងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងពួកព្រះអរហន្តដោយបំណងថា ធ្វើម្តេចហ្ន៎ ! ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅសប្បាយក្នុងដែនរបស់យើង អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ បពិត្រស្តេចលិច្ឆវីទាំងឡាយ នេះអបរិហានិយធម៌ ៧ យ៉ាង រមែងតាំងនៅក្នុងពួកស្តេច ក្នុងដែនវជ្ជី ឬថាពួកស្តេចក្នុងដែនវជ្ជី ប្រតិបត្តិក្នុងអបរិហា-និយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា បពិត្រស្តេចលិច្ឆវីទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។

# អដ្ឋកថា
# វជ្ជីវគ្គទី ៣

## សារន្ទសូត្រ

[ ១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសារន្ទសូត្រទី ១ នៃវជ្ជីវគ្គទី ៣ ដូចតទៅនេះ បទថា **សារន្ទេ ចេតិយេ** បានដល់ ក្នុងវិហារមានឈ្មោះយ៉ាងនោះ ។ បានឮថា កាលព្រះសាស្តាមិនទាន់កើតឡើង លំនៅរបស់យក្ខឈ្មោះសារន្ទៈ ក្លាយជាចេតិយ ។ គ្រានោះ ជនទាំងឡាយបាននាំគ្នាសាងវិហារថ្វាយព្រះមានព្រះភាគ ត្រង់ចេតិយនោះឯង ។ បទថា **យាវកីវញ្ច** ប្រែថា អស់កាលត្រឹមណា ។ បទថា **អភិណ្ហសន្និបាតា** សេចក្តីថា ប្រជុំគ្នាមួយថ្ងៃ ៣ ដង ក្តី ប្រជុំគ្នាម្តងម្កាលក្តី ឈ្មោះថា ប្រជុំគ្នារឿយៗ ។ បទថា **សន្និបាតពហុលា** សេចក្តីថា ឈ្មោះថា ច្រើនដោយការប្រជុំ ព្រោះមិនគិតថា ទាំងម្សិលមិញ ទាំងក្នុងថ្ងៃមុនៗ យើងក៏ប្រជុំហើយ ដើម្បីប្រយោជន៍អ្វី ទើបប្រជុំគ្នាក្នុងថ្ងៃនេះទៀត ។ ពាក្យថា **វុឌ្ឍិយេវ លិច្ឆវី វជ្ជីនំ បាដិកង្ខា នោ បរិហានិ** សេចក្តីពិត ស្តេចលិច្ឆវីកាលមិនប្រជុំគ្នារឿយៗ រមែងមិនបានស្តាប់សាសន៍ដែលមកក្នុងទិសទាំងឡាយឡើយ ។ បន្ទាប់អំពីនោះ រមែងមិនជ្រាបថា ខេត្ត ដែន តំបន់នោះ ឬខេត្តដែននិគមនោះ វឹកវរ ពួកចោរពួនស្ទាក់ក្នុងទីនោះៗ ឯពួកចោរកាលដឹងថា អ្នកទាំងឡាយនាំគ្នាប្រមាទហើយ ក៏ចូលប្លន់ស្រុកជាដើម ធ្វើជនបទឲ្យវិនាស ។ ការវិនាស

*រមែងមានដល់អ្នកទាំងឡាយ ដោយអាការយ៉ាងនេះ ។ តែកាលប្រជុំគ្នារឿយៗ រមែងបានស្តាប់រឿងនោះៗ បន្ទាប់អំពីនោះ ក៏បានបញ្ជូនកម្លាំងទៅធ្វើការបង្ក្រាបសត្រូវ ពួកចោរគិតថា អ្នកទាំងឡាយមិនប្រមាទហើយ ពួកយើងមិនអាចត្រាច់ទៅ ដោយផ្តុំគ្នាជាពួកៗ ដូច្នេះបានឡើយ ហើយក៏បែកខ្ញែកគ្នាទៅ ។ ទើបអ្នកទាំងឡាយមានសេចក្តីចម្រើន ដោយអាការយ៉ាងនេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **វុឌ្ឍិយេវ លិច្ឆវី វជ្ជីនំ បាដិកង្ខា នោ បរិហានិ ។**

*ក្នុងបទថា* **សមគ្គា** *ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ។ កាលអស់សំឡេងស្គរហៅប្រជុំ ពួកស្តេចវជ្ជីធ្វើការគេចកែយ៉ាងនេះថា ថ្ងៃនេះ ខ្ញុំមានកិច្ច ខ្ញុំមានការមង្គល ដូច្នេះ ឈ្មោះថា ជាអ្នកមិនមានការព្រមព្រៀងប្រជុំគ្នា ម្យ៉ាងទៀត ពួកស្តេចវជ្ជីគ្រាន់តែបានឮសំឡេងស្គរ កំពុងបរិភោគអាហារក្តី កំពុងប្រដាប់អលង្ការក្តី កំពុងស្លៀកសំពត់ក្តី បរិភោគអាហារបានពាក់កណ្តាល តែងខ្លួនបានពាក់កណ្តាល កំពុងស្លៀកសំពត់ក៏មកប្រជុំ ឈ្មោះថា ព្រមព្រៀងគ្នាប្រជុំ ។ ម្យ៉ាងទៀត ពួកស្តេចវជ្ជីប្រជុំគិតប្រឹក្សាគ្នា ធ្វើកិច្ចដែលគួរធ្វើហើយ តែមិនព្រមព្រៀងគ្នា លើកនូវការប្រជុំ ឈ្មោះថា មិនព្រមព្រៀងគ្នា លើកនូវការប្រជុំ ព្រោះថា កាលពួកស្តេចវជ្ជីឈប់ប្រជុំយ៉ាងនេះ ពួកស្តេចវជ្ជីដែលឈប់ទៅមុន រមែងមានបរិវិតក្កយ៉ាងនេះថា ពួកយើងបានស្តាប់តែរឿងក្រៅការទាំងនោះ ឥឡូវនេះ នឹងមានរឿងវិនិច្ឆ័យដូច្នេះ ។ ម្យ៉ាងទៀត ពួក*

ស្តេចវជ្ជី កាលព្រមព្រៀងគ្នា បិទអន្តប្រជុំ ឈ្មោះថា ជាអ្នកព្រមព្រៀងគ្នាលើកនូវការប្រជុំ ។

ម្យ៉ាងទៀត កាលពួកស្តេចវជ្ជីស្តាប់មកថា គាមសីមា ឬនិគមសីមាក្នុងទីឈ្មោះនោះ វឹកវរ ឬមានពួកចោរចាំស្កាត់ប្លន់ ពោលថា អ្នកណានឹងទៅធ្វើការបង្ក្រាបពួកសត្រូវ ដូច្នេះហើយ ក៏ដណ្តើមគ្នាទៅថា ខ្ញុំទៅមុនៗ ឈ្មោះថា ជាអ្នកព្រមព្រៀងគ្នាលើកនូវការប្រជុំ ។ តែកាលការងាររបស់ស្តេចវជ្ជីម្នាក់ត្រូវគាំងដំណើរ ពួកស្តេចវជ្ជីក្រៅអំពីនោះ ក៏នាំគ្នាបញ្ជូនបុត្រនិងបងប្អូនប្រុសទៅជួយខ្លះ ពួកស្តេចវជ្ជីទាំងឡាយ កុំពោលនឹងស្តេចដែលជាអាគន្តុកៈថា ចូរទៅផ្ទះរបស់ស្តេចវជ្ជីនោះ ចូរទៅផ្ទះរបស់ស្តេចវជ្ជីនោះ ដូច្នេះ ក៏ព្រមព្រៀងគ្នាសង្គ្រោះខ្លះ កាលការមង្គលក្តី រោគក្តី ឬកាលសុខទុក្ខដទៃកើតឡើងដល់ស្តេចវជ្ជីម្នាក់ ពួកស្តេចវជ្ជីទាំងអស់ក៏នាំគ្នាជាសម្លាញ់ក្នុងការងារនោះខ្លះ ឈ្មោះថា រមែងជាអ្នកព្រមព្រៀងជួយធ្វើកិច្ច ដែលស្តេចវជ្ជីគួរធ្វើ ។

ក្នុងបទថា **អប្បញ្ញត្តំ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា ពួកស្តេចវជ្ជី កាលរក្សាសួយកាសុី ឬតម្លៃទំនិញ មិនបានធ្វើទុកក្នុងកាលមុន ឈ្មោះថា បញ្ញត្តប្រការដែលមិនបានបញ្ញត្ត ម្យ៉ាងទៀត ពួកវជ្ជីកាលឲ្យហូតសួយជាដើម ដែលមានតាមបវេណីបុរាណ ឈ្មោះថា រមែងមិនដកបញ្ញត្ត ដែលបញ្ញត្តទុកហើយ ពួកវជ្ជីកាត់សម្រេចពួកមនុស្សដែលត្រូវភ្ជាក់ងារ ដែលចាប់

មកបង្ហាញថាជាចោរ ដាក់ទោសខាងតែបាន ឈ្មោះថា កាន់វជ្ជីធម៌បុរាណបដិបត្តិ ។ កាលពួកស្តេចវជ្ជីទាំងនោះបញ្ញត្តវិន័យ ដែលមិនធ្លាប់បញ្ញត្ត ពួកមនុស្សត្រូវតម្លៃកាស៊ី កើនឡើងបៀតបៀន ប្រឹក្សាគ្នាថា ពួកយើងត្រូវពួកស្តេចវជ្ជីបៀតបៀនពន់ពេក នរណាហ្ន៎ នឹងអត់ធន់នៅក្នុងដែនរបស់ពួកស្តេចទាំងនេះបាន ដូច្នេះហើយ នាំគ្នាកៀសខ្លួនទៅកាន់ចុងដែន ធ្វើចោរខ្លះធ្វើជាបក្ខពួកចោរខ្លះ នាំគ្នាប្លន់អ្នកជនបទ ។ កាលស្តេចវជ្ជីទាំងនោះ ដកបទបញ្ញត្តដែលបញ្ញត្តទុកហើយ មិនដកសួយជាដើម ដែលមានតាមបវេណីឃ្លាំងទាំងឡាយរមែងស្រកចុះ លំដាប់នោះ ជនទាំងឡាយ មានពលសេះពលដំរី កងទាហាន និងស្រីស្នំជាដើម មិនបានទទួលប្រាក់ខែ ដែលធ្លាប់មានជាប្រចាំ រមែងថមថយកម្លាំងកំហែង ។ ជនទាំងនោះ រមែងអត់ធន់នូវភាពជាអ្នកចម្បាំងមិនបាន អត់ធន់ចំពោះការប្រណិប័តន៍មិនបាន ។ កាលស្តេចវជ្ជីទាំងឡាយ មិនកាន់យកបុរាណវជ្ជីធម៌បដិបត្តិ ពួកមនុស្សក្នុងដែននាំគ្នាក្រោធថា ស្តេចវជ្ជីទាំងឡាយកាត់ក្តីនូវបុត្រ និងបិតា របស់យើងដែលមិនមែនចោរ ឲ្យក្លាយជាចោរហើយ បំផ្លាញនូវទ្រព្យ ដូច្នេះហើយ នាំគ្នាកៀសខ្លួនទៅកាន់ជាយដែន ធ្វើចោរខ្លះ ធ្វើជាគ្នីគ្នារបស់ចោរខ្លះ នាំគ្នាប្លន់ជនបទ ស្តេចទាំងឡាយមានតែការវិនាស ដោយអាការយ៉ាងនេះ តែកាលស្តេចវជ្ជីទាំងឡាយមិនបញ្ញត្តច្បាប់ដែលមិនបានបញ្ញត្តទុក ពួកមនុស្សនាំគ្នាត្រេកអរ ពោលថា ស្តេចទាំងឡាយ ធ្វើតាមបញ្ញត្តដែលធ្លាប់មានមកហើយ

តាមបវេណីប៉ុណ្ណោះ ដូច្នេះហើយ រមែងចាត់ចែងការងារ មានកសិកម្ម និង ពាណិជ្ជកម្មជាដើមឲ្យសម្រេចផល កាលស្តេចវជ្ជីទាំងឡាយ មិនដកបទបញ្ញត្ត ហួតកាស៊ីដែលធ្លាប់មានមកតាមបវេណី ឃ្លាំងក៏រមែងចម្រើន បន្ទាប់អំពីនោះ ពលដំរី ពលសេះ ពលថ្មើរជើង និងស្រីស្នំជាដើម កាលបានប្រាក់បំណាច់ តាមដែលមានជាប្រចាំ រមែងសម្បូរដោយកម្លាំងកំហែង រមែងអត់ធន់ចំពោះ ការច្បាំង និងអត់ធន់ចំពោះការប្រណិប័តន៍ ។ កាលស្តេចវជ្ជីទាំងឡាយទាញ យកបុរាណវជ្ជីធម៌មកប្រព្រឹត្ត ពួកមនុស្សក៏មិនសម្លឹងទោស ចំពោះស្តេច ទាំងឡាយ ដែលទ្រង់ធ្វើតាមបុរាណបវេណី ព្រះអង្គក៏រក្សានីតិធម៌ ដែល សេនាបតី និងឧបរាជអ្នកឈ្លាសក្នុងប្រយោជន៍រក្សាហើយ ទ្រង់ឲ្យបង្រៀន គម្ពីរតាមបវេណី ទ្រង់ឲ្យដាក់អាជ្ញាដែលសមគួរប៉ុណ្ណោះ ពួកស្តេចទាំងនោះ មិនមានការខុស ពួកយើងឯណោះទេ មានកំហុស ដូច្នេះហើយ នាំគ្នាមិន ប្រមាទ ធ្វើការងារទាំងឡាយ ទើបមានតែសេចក្តីចម្រើន ដោយអាការ យ៉ាងនេះ ។

បទថា **សក្ករិស្សន្តិ** សេចក្តីថា ស្តេចវជ្ជីទាំងឡាយ កាលធ្វើសក្ការៈ ណាមួយដល់ស្តេចវជ្ជីដែលជាធំទាំងនោះ នឹងធ្វើតែវត្ថុដែលល្អប៉ុណ្ណោះ ។ បទថា **គរុករិស្សន្តិ** សេចក្តីថា នឹងចូលទៅតាំងសេចក្តីគោរពធ្វើ ។ បទថា **មានេស្សន្តិ** សេចក្តីថា នឹងជាទីស្រឡាញ់ដោយការរាប់អាន ។ បទថា **បូជេស្សន្តិ** សេចក្តីថា នឹងបូជាដោយបច្ច័យបូជា ។ បទថា **សោតព្វំ**

**មញ្ញិស្សន្តិ** សេចក្តីថា ពួកស្តេចវជ្ជី ទៅប្រព្រឹត្តមួយថ្ងៃ ២-៣ ដង សម្គាល់ពាក្យរបស់ស្តេចវជ្ជី ដែលជាធំទាំងនោះថា គួរស្តាប់ គួរជឿ បណ្តាស្តេចវជ្ជីទាំងនោះ ស្តេចវជ្ជីទាំងឡាយណា មិនធ្វើសក្ការៈជាដើមដល់ស្តេចវជ្ជីជាធំ ឬមិនទៅប្រណិប័តន៍ស្តេចវជ្ជីជាធំទាំងនោះ ដើម្បីជាប្រយោជន៍ដល់ការទទួលឱវាទយ៉ាងនេះ ស្តេចវជ្ជីទាំងនោះ ឈ្មោះថា ស្តេចវជ្ជីដែលជាស្តេចធំបោះបង់ចោលហើយ មិនឲ្យឱវាទ ត្រេកអរតែក្នុងការលេង រមែងវិនាសចាករាជការ តែស្តេចវជ្ជីណាបដិបត្តិដោយប្រការនោះ ស្តេចវជ្ជីជាធំ រមែងប្រាប់បុរាណ-បវេណីដល់ស្តេចវជ្ជីទាំងនោះថា កិច្ចនេះគួរធ្វើ កិច្ចនេះមិនគួរធ្វើ សូម្បីដល់ពេលសង្គ្រាមក៏សម្តែងឧបាយថា គួរចូលទៅយ៉ាងនេះ គួរដកថយយ៉ាងនេះ ។ ស្តេចវជ្ជីទាំងនោះ កាលត្រូវស្តេចវជ្ជីដែលជាធំឲ្យឱវាទ បដិបត្តតាមឱវាទ រមែងអាចធ្វើបវេណីនៃរាជការឲ្យតាំងនៅ ដោយហេតុនោះ ទើបព្រះមាន-ព្រះភាគត្រាស់ថា **វុឌ្ឍិយេវ លិច្ឆវី វជ្ជីនំ បដិសង្ខា** ដូច្នេះ ។

បទថា **កុលិត្ថិយោ** បានដល់ ស្រីមេផ្ទះក្នុងត្រកូល ។ បទថា **កុល-កុមារិយោ** បានដល់ ធីតាទាំងឡាយរបស់ស្រីមេផ្ទះទាំងនោះ ។ បទថា **ឱក្កស្ស** ក្តី **បសេយ្ហ** ក្តី នេះជាឈ្មោះនៃអាការ គឺការសង្កត់សង្កិននោះឯង ។ បាលីថា **ឱកាស** ដូច្នេះក៏មាន ។ ក្នុងបទទាំងនោះ បទថា **ឱក្កស្ស** ប្រែថា ទាញមក គឺអូសមក ។ បទថា **បសេយ្ហ** ប្រែថា គ្របសង្កត់ គឺបង្ខាប់ សេចក្តីពិត កាលស្តេចទាំងនោះធ្វើយ៉ាងនោះ មនុស្សទាំងឡាយ ក្នុងដែនក៏

ក្រោធថា បុត្រក្តី បងប្អូនក្នុងផ្ទះរបស់ពួកយើងក្តី ជីតាដែលយើងជូតទឹកមាត់ និងទឹកសម្បោរជាដើមក្តី បេញមុខចិញ្ចឹមឲ្យចម្រើនធំធាត់ ស្តេចវជ្ជីទាំងនោះ ចាប់ទៅដោយអំណាចឲ្យនៅក្នុងផ្ទះរបស់ខ្លួនយ៉ាងនេះ ហើយនាំគ្នាទៅកាន់ ជាយដែនធ្វើជាចោរខ្លះ ធ្វើជាសម្លាញ់របស់ចោរខ្លះ ហើយប្លន់ជនបទ ។ តែ បើស្តេចវជ្ជីមិនធ្វើយ៉ាងនោះ ពួកមនុស្សក្នុងដែន ជាអ្នកខ្វល់ខ្វាយតិច ធ្វើ ការងាររបស់ខ្លួន រមែងធ្វើឃ្លាំងស្តេចឲ្យចម្រើន គប្បីជ្រាបការចម្រើន និង ការវិនាសក្នុងសេចក្តីនេះ ដោយអាការយ៉ាងនេះ ។

បទថា **វជ្ជីនំ វជ្ជិចេតិយានិ** សេចក្តីថា ទីរបស់យក្ខដែលបាន ឈ្មោះថា ចេតិយ ដែលគេតាក់តែងឲ្យវិចិត្រក្នុងដែនវជ្ជីរបស់ស្តេចវជ្ជីទាំង-ឡាយ ។ បទថា **អព្ភន្តរានិ** បានដល់ តាំងនៅខាងក្រៅព្រះនគរ ។ បទថា **ទិន្នបុព្វំ កតបុព្វំ** ប្រែថា ដែលឲ្យ និងធ្វើមកអំពីមុន ។ បទថា **នោ បរិហាបេស្សន្តិ** បានដល់ ស្តេចវជ្ជីទាំងឡាយនឹងមិនបន្ថយ គឺធ្វើតាមដែល មានហើយនោះឯង ។ ពិតហើយ កាលស្តេចវជ្ជីទាំងឡាយបន្ថយពលិកម្ម ដែលជាធម៌ ទេវតាទាំងឡាយ ក៏មិនធ្វើការរក្សា ដែលចាត់ចែងទុកយ៉ាងល្អ កាលមិនអាចឲ្យកើតសុខដែលមិនទាន់កើត រមែងបណ្តាលរោគក្អក រោគ ក្បាលជាដើម ដែលកើតហើយឲ្យកម្រើក កាលកើតសង្គ្រាម ទេវតាក៏មិន ធ្វើជាបក្ខពួក គឺមិនរក្សា កាលពួកស្តេចវជ្ជីមិនបន្ថយពលិកម្ម ទេវតាទាំង-ឡាយ ក៏នឹងធ្វើការរក្សាយ៉ាងល្អ ឲ្យកើតសុខដែលមិនទាន់កើតផង ជាបក្ខ

ពួកក្នុងកាលមានសង្គ្រាមផង ដោយហេតុនោះ គប្បីជ្រាបការចម្រើន និង ការវិនាសក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។

ក្នុងបទថា **ធម្មិការក្ខាវរណាគុត្តិ** មានវិនិច្ឆ័យដូចតទៅនេះថា អារក្ខា នេះឯង ឈ្មោះថា ការពារ ព្រោះរាំងដោយប្រការដែលវត្ថុគួរប្រាថ្នាមិនទាន់ មកដល់ ឈ្មោះថា ឃុំគ្រង ព្រោះឃុំគ្រងដោយប្រការដែលវត្ថុគួរប្រាថ្នាមិន វិនាស ក្នុងការរក្សានោះ ការប្រើកងកម្លាំងចោមរោមរក្សា មិនឈ្មោះថា ធម្មិការក្ខាវរណាគុត្តិសម្រាប់បព្វជិតឡើយ ។ ចំណែកការធ្វើដោយប្រការ ដែលគ្រហស្ថទាំងឡាយ មិនកាប់ក្ការដើមឈើក្នុងព្រៃ ក្បែរវិហារ អ្នកចម្ការ មិនដាក់គ្រាប់ពូជក្នុងដែនរបស់វិហារ មិនចាប់ត្រីក្នុងស្រះក្បែរវិហារ ឈ្មោះ ថា ធម្មិការក្ខាវរណាគុត្តិ ។ បទថា **កិន្តិ** ប្រែថា ព្រោះហេតុអ្វីហ្ន៎ ។

ក្នុងពាក្យថា **ធម្មិការក្ខាវរណាគុត្តិ** មានវិនិច្ឆ័យដូចតទៅនេះថា ស្តេច វជ្ជីដែលមិនប្រាថ្នាការមករបស់ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មករមែង ឈ្មោះថា ជាអ្នកមិនមានសទ្ធា មិនមានការជ្រះថ្លា កាលបព្វជិតមកដល់ហើយ ខ្លួនមិនធ្វើការទទួល ទៅក៏មិនព្រមជួប មិនធ្វើបដិសណ្ឋារៈ មិនសួរបញ្ហា មិន ស្តាប់ធម៌ មិនថ្វាយទាន មិនស្តាប់ការអនុមោទនា មិនចាត់ចែងទីស្នាក់ អាស្រ័យឲ្យ កាលបើដូច្នោះ កិត្តិសព្ទមិនល្អរបស់ស្តេចវជ្ជីទាំងនោះ រមែងល្បី ទៅថា ស្តេចឈ្មោះនោះ ជាអ្នកមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា កាល បព្វជិតមកដល់ហើយ មិនចេញទៅទទួល ។បេ។ មិនចាត់ចែងទីស្នាក់

អាស្រ័យឲ្យ ។ បព្វជិតទាំងឡាយ បានស្តាប់ដូច្នោះហើយ សូម្បីទៅតាមផ្លូវក្រុង ក៏មិនចូលក្រុង កាលបើដូច្នោះ ព្រះអរហន្តដែលមិនធ្លាប់មក ក៏មិនមក ដែលធ្លាប់មកហើយ កាលនៅមិនផាសុក បុគ្គលដែលមិនដឹង ហើយមក ក៏តាំងចិត្តថា នឹងនៅ ទើបនាំគ្នាមក តើអ្នកណានឹងនៅបាន ដោយការមិនរាប់អានទាំងនេះ នៃពួកស្តេចទាំងនេះ ហើយក៏នាំគ្នាចេញទៅ កាលបើដូច្នេះ កាលព្រះអរហន្ត មិនទាន់មក ក៏មិនមក ដែលមកហើយ ក៏នៅជាទុក្ខ ប្រទេសនោះក៏ឈ្មោះថា មិនជាទីនៅសម្រាប់បព្វជិត ។ បន្ទាប់អំពីនោះ ការរក្សារបស់ទេវតាក៏មិនមាន កាលការរក្សារបស់ទេវតាមិនមាន ពួកអមនុស្ស រមែងបានឱកាស អមនុស្សនឹងកកកុញ រមែងធ្វើព្យាធិដែលមិនទាន់កើតឲ្យកើត បុណ្យដែលជាវត្ថុនៃការឃើញអ្នកមានសីល និងសួរបញ្ហាជាដើម ក៏មិនមកដល់ ដោយបរិយាយផ្ទុយគ្នា ក្នុងធម៌ចំណែកស តាមដែលពោលហើយ ក៏នឹងកើតឡើង ព្រោះហេតុនោះ គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តីវិនាស ក្នុងរឿងនេះ ដោយអាការយ៉ាងនេះ ។

## អដ្ឋកថាសារន្ទទសូត្រទី ១ ចប់

# សុត្តន្តបិដក

## វស្សការសូត្រទី ២

[ ២០ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះរាជាជាធំក្នុងដែនមគធៈ ព្រះនាមអជាតសត្តុវេទេហិបុត្រ មានបំណងនឹងយាត្រា ទៅជាន់យកពួកស្តេចក្នុងដែនវជ្ជី ។ ព្រះអង្គទ្រង់មានព្រះរាជឱង្ការ យ៉ាងនេះថា អញនឹងផ្តាច់ផ្តិលពួកអ្នកដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ អញ ( មានបំណងនឹងយាត្រាទៅជិះជាន់ ) ពួកស្តេចក្នុងដែនវជ្ជី នឹងបំផ្លាញពួកស្តេចក្នុងដែនវជ្ជី នឹងធ្វើពួកស្តេចក្នុងដែនវជ្ជី ឲ្យដល់នូវសេចក្តីវិនាស ។ គ្រានោះព្រះបាទអជាតសត្តុមាគធរាជវេទេហិបុត្រ ត្រាស់ហៅវស្សការព្រាហ្មណ៍ ដែលជាមហាមាត្យក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍ ចូរអ្នកមកនេះ ចូរអ្នកទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទាព្រះដ៏មានព្រះភាគដោយត្បូង តាមពាក្យរបស់ខ្ញុំ រួចទូលសួរអំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស ដោយកម្លាំងកាយ និងការនៅសប្បាយគ្រប់ឥរិយាបថ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហិបុត្តមាគធរាជ ថ្វាយបង្គំព្រះបាទាព្រះដ៏មានព្រះភាគដោយព្រះសិរ្ស ហើយផ្តាំមកក្រាបបង្គំទូលសួរ អំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស ដោយកម្លាំងកាយ និងការនៅសប្បាយមួយទៀត ចូរក្រាបទូលយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទ

អជាតសត្តុវេទេហិបុត្តមាគធរាជ មានបំណងនឹងយាត្រាទៅជិះជាន់ យកពួកអ្នកដែនវជ្ជី ។ ព្រះអង្គទ្រង់ត្រាស់យ៉ាងនេះថា អញនឹងផ្តាច់បង់នូវពួកស្តេចក្នុងដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ ( អញមានបំណងនឹងយាត្រាទៅជិះជាន់ ) ពួកស្តេចក្នុងដែនវជ្ជី នឹងបំផ្លាញពួកស្តេចក្នុងដែនវជ្ជី នឹងធ្វើពួកស្តេចក្នុងដែនវជ្ជី ឲ្យដល់នូវសេចក្តីវិនាស ។ ប៉ុន្តែបើព្រះដ៏មានព្រះភាគទ្រង់ព្យាករ យ៉ាងណា ចូរអ្នកចាំពាក្យនោះឲ្យជាក់ច្បាស់ ហើយនាំមកប្រាប់ខ្ញុំវិញ ។ ព្រោះព្រះតថាគតទាំងឡាយមិនដែលមានព្រះបន្ទូលខុសទេ ។ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ក៏ទទួលព្រះរាជឱង្ការព្រះបាទអជាតសត្តុវេទេហិបុត្តមាគធរាជ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭករួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហិបុត្រមាគធរាជ ក្រាបថ្វាយបង្គំព្រះបាទាព្រះគោតមដ៏ចម្រើន ដោយព្រះសិរ្សៈ ហើយឲ្យទូលសួរ អំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័សដោយព្រះកាយ-ពល និងការនៅសប្បាយ បពិត្រព្រះគោតមដ៏ចម្រើន ព្រះបាទអជាតសត្តុ

វេទេហីបុត្តមាគធរាជ មានបំណងនឹងយាត្រាទៅជាន់យក ពួកស្តេចក្នុងដែនវជ្ជី ។ ព្រះអង្គទ្រង់មានព្រះរាជឱង្ការ យ៉ាងនេះថា អញនឹងផ្តាច់ផ្តិល ពួកស្តេចដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ នឹងធ្វើពួកស្តេចក្នុងដែនវជ្ជី ឲ្យដល់នូវសេចក្តីវិនាស ។

សម័យនោះឯង ព្រះអានន្ទដ៏មានអាយុ ឋិតនៅអំពីខាងក្រោយ ព្រះដ៏មានព្រះភាគ កំពុងបក់ថ្វាយព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី មានការប្រជុំគ្នារឿយៗ មានការប្រជុំគ្នាដោយច្រើន ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី មានការប្រជុំគ្នារឿយៗ មានការប្រជុំគ្នាដោយច្រើន ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងមានការប្រជុំគ្នារឿយៗ មានការប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី ព្រមព្រៀងគ្នាប្រជុំព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ច ក្នុងដែនវជ្ជីដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី ព្រមព្រៀងគ្នា ប្រជុំព្រមព្រៀងគ្នា លើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ច ក្នុងដែនវជ្ជីដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹង

ព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នា លើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជី អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី មិនបញ្ញត្តច្បាប់ ( ដែលពួកស្តេចពីដើម ) មិនបានបញ្ញត្ត មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជី អំពីបុរាណ ដែលបានបញ្ញត្តរួចហើយយ៉ាងណា ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី មិនបញ្ញត្តច្បាប់ ( ដែលពួកស្តេចពីដើម ) មិនបានបញ្ញត្ត មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ កាន់តាមប្រព្រឹត្តតាមច្បាប់ ក្នុងដែនវជ្ជីអំពីបុរាណ ដែលបានបញ្ញត្តរួចហើយយ៉ាងណា ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងមិនបញ្ញត្តច្បាប់ ( ដែលពួកស្តេចពីដើម ) មិនបានបញ្ញត្តហើយ មិនដកច្បាប់ ដែលបានបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជីអំពីបុរាណដែលបានបញ្ញត្តរួចហើយយ៉ាងណា អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រិយ៍ទាំងឡាយ ទាំងសម្គាល់ពាក្យដែលគួរ

ស្តាប់របស់ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនទាំងនោះ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព រាប់អាន បូជា ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើន ជាងវជ្ជីក្សត្រិយ៍ទាំងឡាយ ទាំងសម្គាល់ពាក្យដែលគួរស្តាប់ របស់ពួកស្តេច ក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនទាំងនោះ ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងធ្វើសក្ការៈ គោរព រាប់អាន បូជា ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនជាង វជ្ជីក្សត្រិយ៍ទាំងឡាយ ទាំងសម្គាល់ពាក្យដែលគួរស្តាប់ របស់ពួកស្តេចក្នុងដែនវជ្ជី ដែលមានព្រះជន្មច្រើនទាំងនោះ អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី មិនកំហែងបង្ខំពួកស្ត្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូល ឲ្យនៅរួម ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី មិនកំហែងបង្ខំពួកស្ត្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូល ឲ្យនៅរួម ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី មិនកំហែងបង្ខំ ពួកស្ត្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូល ឲ្យនៅរួមអស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យ មិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេច

ក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជី របស់ពួកស្តេចក្នុងដែនវជ្ជី ដែលនៅខាងក្នុងនគរផង ខាងក្រៅនគរផង ទាំងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះឲ្យសាបសូន្យទៅដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរផង ខាងក្រៅនគរផង ទាំងមិនធ្វើគ្រឿងបូជាប្រកដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះ ឲ្យសាបសូន្យទៅ ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងធ្វើសក្ការៈ គោរព រាប់អាន បូជានូវចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរផង ខាងក្រៅនគរផង ទាំងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់បូជា ធ្លាប់ធ្វើដល់ចេតិយទាំងនោះឲ្យសាបសូន្យទៅអស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើន តែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី បានចាត់ចែងត្រឹមត្រូវ នូវការរក្សាការពារ និងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងអរហន្តទាំងឡាយ ដោយបំណងថា ធ្វើម្តេចហ្ន៎ ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅសប្បាយ ក្នុងដែនរបស់យើងដូច្នេះដែរឬ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនោះថា ពួកស្តេចក្នុងដែនវជ្ជី បានចាត់ចែងត្រឹមត្រូវ នូវការរក្សាការពារ និងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងព្រះអរហន្តទាំងឡាយ ដោយបំណងថា ធ្វើម្តេចហ្ន៎ ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅសប្បាយ ក្នុងដែនរបស់យើង ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជី នឹងបានចាត់ចែងត្រឹមត្រូវនូវការរក្សាការពារ និងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងព្រះអរហន្តទាំងឡាយ ដោយបំណងថា ធ្វើម្តេចហ្ន៎ ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅសប្បាយ ក្នុងដែនរបស់យើង អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍ សម័យមួយ តថាគតគង់នៅក្នុងសារន្ទទចេតិយ ទៀបក្រុងវេសាលី តថាគតបានសម្តែងអបរិហានិយ-ធម៌ទាំង ៧ ប្រការនេះ ដល់ពួកស្តេចក្នុងដែនវជ្ជី ក្នុងសារន្ទទចេតិយនោះឯង ។ ម្នាលព្រាហ្មណ៍ អបរិហានិយធម៌ ៧ យ៉ាងនេះ តាំងនៅក្នុងពួកស្តេចក្នុងដែនវជ្ជី ឬថា ពួកស្តេចក្នុងដែនវជ្ជី នឹងប្រតិបត្តិក្នុងអបរិហានិយធម៌ ៧

យ៉ាងនេះ អស់កាលត្រឹមណា ម្នាលព្រាហ្មណ៍ សេចក្ដីចម្រើនតែងមានប្រាកដ ដល់ពួកស្ដេច ក្នុងដែនវជ្ជី សេចក្ដីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្ដីចម្រើនតែងមានប្រាកដ សេចក្ដីសាបសូន្យ តែងមិនមាន ដល់ពួកស្ដេចក្នុងដែនវជ្ជី ដែលប្រកបដោយអបរិហានិយធម៌ សូម្បីតែមួយៗ ចាំបាច់និយាយទៅថ្វី ដល់ទៅគ្រប់អបរិហានិយធម៌ទាំង ៧ ( នោះ ) ។ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត ព្រះបាទអជាតសត្តុវេទេហីបុត្តមាគធរាជ មិនគប្បីចាប់ពួកស្ដេច ក្នុងដែនវជ្ជីដោយចម្បាំងបានទេ វៀរលែងតែការលួងលោមយកចិត្ត ឬការធ្វើឲ្យបែកគ្នា ។ បពិត្រព្រះគោតមដ៏ចម្រើន ណ្ហើយចុះ ខ្ញុំព្រះអង្គសូមលាទៅឥឡូវនេះ ( ព្រោះថា ) ខ្ញុំព្រះអង្គ មានកិច្ចច្រើន មានការងារច្រើន ។ ម្នាលព្រាហ្មណ៍ អ្នកចូរសម្គាល់នូវកាល នឹងទៅក្នុងវេលានេះចុះ ។ លំដាប់នោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ត្រេកអររីករាយនឹងភាសិត របស់ព្រះដ៏មានព្រះភាគ ហើយក្រោកចាកអាសនៈចេញទៅ ។

# អដ្ឋកថា

## វស្សការសូត្រ

[ ២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវស្សការសូត្រទី ២ ដូចតទៅនេះ បទថា **អភិយាតុកាមោ** សេចក្តីថា មានព្រះរាជបំណងនឹងយាត្រាទ័ពទៅញាំញី ។ បទថា **វជ្ជី** បានដល់ ស្តេចវជ្ជីទាំងឡាយ ។ ដោយបទថា **ឯវំ មហិទ្ធិកេ** បានដល់ ប្រកបដោយព្រះរាជឫទ្ធិធំយ៉ាងនេះ ។ ដោយបទថា **ឯវំ មហិទ្ធិកេ** នេះ ព្រះបាទអជាតសត្តុត្រាស់ដល់ភាពដែលស្តេចវជ្ជីទាំងនោះ មានការព្រមព្រៀងគ្នា ។ បទថា **ឯវំ មហានុភាវេ** បានដល់ ប្រកបដោយរាជានុភាពធំយ៉ាងនេះ ។ ដោយបទថា **ឯវំមហានុភាវេ** នេះ ព្រះបាទអជាតសត្តុត្រាស់ដល់ភាពដែលស្តេចវជ្ជីទាំងនោះ ជាអ្នកធ្វើការសិក្សាហើយ ក្នុងហត្ថីសិប្បៈជាដើម ដែលទ្រង់ត្រាស់សំដៅយកថា ស្តេចកំលោះលិច្ឆវីទាំងនេះ សិក្សាហើយហ្ន៎ ស្តេចលិច្ឆវីទាំងនេះ សិក្សាល្អហើយហ្ន៎ ដែលលេងព្រួញធំតូចដែលមានរឿងជាប់ខាងចុង មិនខុសក្តារប៉ោយពិតៗ ។ បទថា **ឧច្ឆេជ្ជិស្សាមិ** សេចក្តីថា នឹងកាត់ឲ្យដាច់ ។ បទថា **វិនាសេស្សាមិ** ប្រែថា ធ្វើមិនឲ្យប្រាកដឡើយ ។ បទថា **អនយព្យសនំ** បានដល់ មិនចម្រើន និងសេចក្តីលំបាកនៃញាតិ ។ បទថា **អាបាទេស្សាមិ** ប្រែថា ឲ្យដល់នូវការសាបសូន្យ និងសេចក្តីវិនាស ។

បានឮថា ព្រះបាទអជាតសត្តុនោះ ត្រាស់រឿងចម្បាំងក្នុងទីដែលប្រជាប់ឈរ និងទីដែលប្រជាប់គង់ជាដើម និងត្រាស់បញ្ជាកងកម្លាំងថា ពួក

អ្នកត្រៀមការ ចូរត្រៀមការយាត្រាទ័ព ដោយប្រការដូច្នេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា ត្រង់ឆ្នេរស្ទឹងគង្គា អាស្រ័យស្រុកបដ្ដនគាម ជាដែនដីរបស់ព្រះបាទអជាតសត្តុ ៨ យោជន៍ របស់ពួកស្តេចលិច្ឆវី ៨ យោជន៍ ក្នុងបដ្ដនគាមនោះ គន្ធជាតិមានតម្លៃច្រើន ហូរមកអំពីជើងភ្នំ កាលព្រះបាទអជាតសត្តុទ្រង់ឮរឿងនោះ ទ្រង់ប្រុងប្រៀបថា អញនឹងទៅថ្ងៃនេះ ស្អែកនេះ ពួកស្តេចលិច្ឆវីព្រមព្រៀង ក្សៀវក្សា មកមុន ប្រមូលយកទាំងអស់ ។

ព្រះបាទអជាតសត្តុទ្រង់មកឯក្រោយ ទ្រង់ជ្រាបរឿងនោះ ក៏ទ្រង់ព្រះពិរោធ ហើយយាងត្រឡប់ទៅ ។ ក្នុងឆ្នាំបន្ទាប់មក ស្តេចលិច្ឆវីទាំងនោះ ទ្រង់ធ្វើដូចមុននោះឯង គ្រានោះឯង ព្រះបាទអជាតសត្តុពិរោធយ៉ាងក្រៃលែង ក៏បានធ្វើយ៉ាងនោះ ក្នុងគ្រានោះ ។

លំដាប់នោះ ព្រះបាទអជាតសត្តុទ្រង់ព្រះតម្រិះថា ឈ្មោះថា ការច្បាំងជាមួយគណៈស្តេចលិច្ឆវី ជារឿងធ្ងន់ ការកាប់ចាក់គ្នាដោយឥតហេតុផលតែម្ដងមិនបាន អញត្រូវប្រឹក្សាជាមួយបណ្ឌិតម្នាក់ ទើបធ្វើការគង់មិនថ្លោះធ្លោយ តែបណ្ឌិតស្មើដូចព្រះសាស្ដាមិនមាន ហើយព្រះសាស្ដា ក៏ប្រថាប់នៅក្នុងវិហារក្បែរនេះ មិនឆ្ងាយ ណ្ហើយចុះ អញនឹងបញ្ជូនមនុស្សទៅទូលសួរ បើអញទៅឯង នឹងមានប្រយោជន៍អ្វី ព្រះសាស្ដាគង់ទ្រង់នៅស្ងៀម តែបើមិនមានប្រយោជន៍ ព្រះសាស្ដាមុខជាត្រាស់ថា ប្រយោជន៍អ្វីដោយការទៅក្នុងទីនោះ ទើបទ្រង់បញ្ជូនវស្សការព្រាហ្មណ៍ទៅ ។ ព្រាហ្មណ៍ទៅក្រាប

*ទូលរឿងនោះ ដល់ព្រះមានព្រះភាគហើយ ដោយហេតុនោះ ទើបលោកពោលថា* **អថខោ រាជា ។បេ។ អារោចេស្សាមិ វជ្ជីតិ ។**

*បទថា* **ភគវន្តំ វីជមានោ** *ព្រះថេរៈតាំងនៅក្នុងវត្ត គឺបក់ផ្លិតថ្វាយព្រះមានព្រះភាគ តែរងា ឬក្តៅ មិនមានដល់ព្រះមានព្រះភាគឡើយ ។ ព្រះមានព្រះភាគ កាលទ្រង់ស្តាប់ពាក្យរបស់ព្រាហ្មណ៍ហើយ ទ្រង់មិនបានពិភាក្សាជាមួយព្រាហ្មណ៍នោះ មានព្រះបំណង ក៏ប្រឹក្សាជាមួយព្រះថេរៈ ទើបត្រាស់ថា* **កិន្តិ តេ អានន្ទ សុតំ** *ដូច្នេះ ពាក្យនោះមានអត្ថដូចពោលហើយនោះឯង ។*

*ព្រះមានព្រះភាគត្រាស់ពាក្យនេះថា* **ឯកមិទាហំ** *ដើម្បីទ្រង់ប្រកាសភាពដែលវជ្ជីធម៌ ៧ ប្រការនេះ ដែលទ្រង់សម្តែងដល់ស្តេចវជ្ជីទាំងឡាយមុន ។ បទថា* **អករណីយា** *ប្រែថា មិនគួរធ្វើ អធិប្បាយថា មិនគួរកាន់យក ។ បទថា* **យទិទំ** *ត្រឹមតែជានិបាត ។ បទថា* **យុទ្ធស្ស** *ជាឆដ្ឋីវិភត្តិប្រើក្នុងអត្ថនៃតតិយាវិភត្តិ អធិប្បាយថា បុគ្គលណាមួយ មិនអាចកាន់យកបានដោយការច្បាំង ដែលជាការៈធូន់ ។ បទថា* **អញ្ញត្រ មិថុភេទា** *សេចក្តីថា វៀរការចរចា ការបញ្ជូនបណ្ណាការ មានដំរី សេះ រថ ប្រាក់ មាសជាដើម ធ្វើការសង្គ្រោះ ដោយពោលថា* **អលំ វិវាទេន** *កុំវិវាទគ្នាឡើយ ឥឡូវនេះ យើងនឹងសាមគ្គីគ្នា វិញផ្សះគ្នា ឈ្មោះថា ការចរចាគ្នា អធិប្បាយថា ធ្វើនូវការសង្គ្រោះយ៉ាងនេះ ក៏ទាញទឹកចិត្តគ្នានិងគ្នាបាន ដោយការស្និទ្ធ*

ស្ពាលតែម្យ៉ាង ។ បទថា **អញ្ញត្រ មិថុភេទា** បានដល់ វៀរការធ្វើឲ្យ ២ ចំណែកបែកគ្នា ។ ដោយបទនេះ ព្រះបាទអជាតសត្តុពោលថា ធ្វើឲ្យបែកគ្នានិងគ្នាហើយនឹងចាប់ស្តេចវជ្ជីទាំងនោះបាន ។

ព្រាហ្មណ៍បានន័យអំពីព្រះពុទ្ធតម្រាស់ហើយ ទើបពោលដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រាហ្មណ៍បានន័យអំពីព្រះតម្រាស់នេះឬ មែនទ្រង់ជ្រាប ។ សួរថា កាលទ្រង់ជ្រាប ហេតុអ្វី ទើបត្រាស់ ឆ្លើយថា ដើម្បីទ្រង់អនុគ្រោះ បានឮថា ទ្រង់មានព្រះតម្រិះយ៉ាងនេះថា ទោះបីតថាគតមិនពោល ២-៣ ថ្ងៃទៀតប៉ុណ្ណោះ ព្រះបាទអជាតសត្តុ នឹងយាងទៅចាប់ស្តេចវជ្ជីទាំងអស់នោះ តែកាលតថាគតពោលហើយ ព្រះបាទអជាតសត្តុ ត្រូវប្រើពេល ៣ ឆ្នាំ ទម្លាយពួកស្តេចលិច្ឆវី ដែលសាមគ្គីគ្នា ទើបចាប់បាន ការនៅមានជីវិតប្រមាណប៉ុណ្ណោះ ក៏ប្រសើរ ។ ពិតហើយ ស្តេចវជ្ជីរស់នៅអស់កាលប៉ុណ្ណោះក៏នឹងធ្វើបុណ្យដែលជាទីពឹងដល់ខ្លួនបាន ។ បទថា **អភិនន្ទិត្វា** ប្រែថា ត្រេកអរហើយដោយចិត្ត ។ បទថា **អនុមោទិត្វា** សេចក្តីថា ត្រេកអរដោយវាចាថា ព្រះតម្រាស់នេះ ព្រះគោតមត្រាស់ល្អហើយ ។ បទថា **បក្កាមិ** ប្រែថា ត្រឡប់ទៅគាល់ព្រះរាជាហើយ ចំណែកព្រះរាជា ក៏បញ្ជូនវស្សការព្រាហ្មណ៍នោះឯង ទៅទម្លាយស្តេចវជ្ជីទាំងអស់ឲ្យដល់នូវ សេចក្តីអន្តរាយ ។

**អដ្ឋកថា វស្សការសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ភិក្ខុសូត្រទី ៣

[ ២១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ មកក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ទាំង ៧ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរប្រុងស្តាប់ នូវភាសិតនោះ ចូរធ្វើទុកក្នុងចិត្ត ឲ្យជាក់ច្បាស់ចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុះអបរិហានិយធម៌ទាំង ៧ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រជុំគ្នារឿយៗ ប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចរបស់សង្ឃ អស់កាលត្រឹមណា ម្នាលភិក្ខុទាំង-ឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនបញ្ញត្តសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ មិនដកសិក្ខាបទ ដែលតថាគតបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមសិក្ខាបទ ដែលតថាគតបញ្ញត្តហើយយ៉ាងណា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ

សេចក្ដីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យ មិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងធ្វើសក្ការៈ គោរព រាប់អាន បូជាពួកភិក្ខុជាថេរៈ អ្នកដឹងរាត្រីច្រើន បួសយូរជាបិតានៃសង្ឃ ជាបរិនាយករបស់សង្ឃ ជាអ្នកណែនាំសង្ឃ ទាំងសម្គាល់ពាក្យដែលគួរស្ដាប់ របស់ភិក្ខុជាថេរៈទាំងនោះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំង-ឡាយ បើពួកភិក្ខុនឹងមិនលុះក្នុងអំណាចតណ្ហា ជាធម្មជាតនាំសត្វ ទៅក្នុងភពថ្មីទៀត ដែលកើតឡើងហើយ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមានសេចក្ដីប្រាថ្នា ក្នុងសេនាសនៈទាំងឡាយ ដែលតាំងនៅក្នុងព្រៃ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រុងស្មារតីក្នុងខ្លួនថា ធ្វើម្ដេចហ្ន៎ ពួកសព្រហ្មចារី មានសីលជាទីស្រឡាញ់ ដែលមិនទាន់មកដល់ ក៏សូមឲ្យនិមន្តមក ពួកសព្រហ្មចារី មានសីលជាទីស្រឡាញ់ ដែលមកដល់ហើយ ក៏សូមឲ្យនៅសប្បាយដូច្នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើន

តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ តាំងនៅក្នុងភិក្ខុទាំងឡាយ ឬថាភិក្ខុទាំងឡាយ នឹងប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ យ៉ាងនេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។

# អដ្ឋកថា

## ភិក្ខុសូត្រ

[ ២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភិក្ខុសូត្រទី ៣ ដូចតទៅនេះ បទថា **អភិណ្ហសន្និបាតា** នេះ ស្មើគ្នានឹងពាក្យដែលពោលហើយ ក្នុងវជ្ជីអបរិហានិយធម៌ ៧ ប្រការនោះឯង ។ ភិក្ខុទាំងឡាយក្នុងព្រះសាសនានេះ មិនប្រជុំគ្នាជានិច្ច រមែងមិនបានឮដំណឹង ដែលមកក្នុងទិសទាំងឡាយ ។ បន្ទាប់អំពីនោះ រមែងមិនដឹងដំណឹងជាដើមថា សីមាវិហារនោះ វិកវរ ឧបោសថ និងបវារណាតាំងនៅ ។ ភិក្ខុក្នុងទីឈ្មោះនេះ ធ្វើវេជ្ជកម្ម និងទូតកម្មជាដើម ភិក្ខុទាំងឡាយច្រើនទៅដោយវិញ្ញត្តិ រមែងចិញ្ចឹមជីវិត ដោយការឲ្យផ្លែឈើ និងផ្កាជាដើម សូម្បីពួកភិក្ខុអាក្រក់ទាំងឡាយ ដឹងថា សង្ឃប្រមាទហើយ

រមែងធ្វើពាក្យប្រៀនប្រដៅ ដែលគេទុកឲ្យវិនាស ។ ឯភិក្ខុទាំងឡាយ ដែលប្រជុំគ្នាជានិច្ច រមែងបានដឹងរឿងនោះ ។ លំដាប់នោះ ក៏បញ្ជូនភិក្ខុសង្ឃទៅធ្វើសីមាខូចឲ្យត្រង់ ញុំាងឧបោសថ និងបវារណាឲ្យប្រព្រឹត្តទៅ បញ្ជូនភិក្ខុដែលតាំងនៅក្នុងអរិយវង្ស ទៅក្នុងទីរបស់ពួកភិក្ខុមិច្ឆាជីវៈ ឲ្យបង្រៀនអរិយវង្ស ឲ្យភិក្ខុវិនយធរដាក់និគ្គហៈដល់ភិក្ខុអាក្រក់ទាំងឡាយ សូម្បីភិក្ខុអាក្រក់ទាំងឡាយដឹងថា សង្ឃមិនសើរើ ពួកភិក្ខុទាំងនោះមិនអាចត្រាច់ទៅជាពួក ជាក្រុមបាន ដូច្នេះហើយ ក៏បែកខ្ញែកគ្នាទៅ ។ គប្បីជ្រាបការចម្រើន និងការវិនាសក្នុងសេចក្តីនេះ ដោយអាការយ៉ាងនេះ ។

ក្នុងបទថា **សមគ្គា** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា កាលបុគ្គលវាយស្គរ ឬវាយជួងឲ្យសញ្ញាថា សូមសង្ឃប្រជុំគ្នា ដើម្បីជម្រះព្រះចេតិយ ឬប្រក់ខឿនពោធិព្រឹក្ស ឬរោងឧបោសថ ឬដើម្បីតាំងកតិកាវត្ត ភិក្ខុទាំងឡាយធ្វើការគេចកែថា ខ្ញុំមានចីវរកម្ម ខ្ញុំនឹងដុតបាត្រ ខ្ញុំមាននវកម្ម ឈ្មោះថា មិនព្រមព្រៀងគ្នាប្រជុំ ។ ភិក្ខុទាំងឡាយវៀរកម្មទាំងអស់នោះ ប្រញាប់ទៅមុនប្រជុំព្រមគ្នា ឈ្មោះថា ព្រមព្រៀងគ្នាប្រជុំ ។ ឯភិក្ខុទាំងឡាយប្រជុំគ្នា គិតប្រឹក្សាគ្នា ធ្វើកិច្ចដែលគួរធ្វើ មិនព្រមព្រៀងគ្នា លើកលែងប្រជុំនោះឯង ឈ្មោះថា មិនព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រោះថា កាលភិក្ខុទាំងឡាយលើកលែងប្រជុំ ដោយអាការយ៉ាងនេះ ពួកភិក្ខុដែលទៅដល់មុន រមែងមានការគិតយ៉ាងនេះថា អញស្តាប់តែក្រៅរឿង ចំណែកភិក្ខុទាំងឡាយដែលលើក

លែងប្រជុំព្រមៗ គ្នានោះឯង ឈ្មោះថា ព្រមព្រៀងគ្នាលើកលែងប្រជុំ ។

ម្យ៉ាងទៀត ភិក្ខុទាំងឡាយស្តាប់ដំណឹងថា សីមាវិហារក្នុងទីនោះវិបត្តិ ឧបោសថបវារណាជាប់គាំងក្នុងទីនោះ ពួកភិក្ខុអាក្រក់ធ្វើវេជ្ជកម្មជាដើមដ៏ក្រាស់ កាលព្រះថេរៈពោលថា អ្នកណានឹងទៅចុះនិគ្គហៈ ភិក្ខុទាំងនោះក៏ដណ្តើមគ្នាពោលថា ខ្ញុំមុនៗ ហើយក៏ទៅ ឈ្មោះថា ព្រមព្រៀងគ្នាលើកលែងប្រជុំ ។ ម្យ៉ាងទៀត ភិក្ខុទាំងឡាយឃើញភិក្ខុអាគន្តុកៈ មិនពោលថា អ្នកចូរទៅបរិវេណនេះ ចូរទៅបរិវេណនោះ ពួកយើងជានរណា ដូច្នេះ គ្រប់រូប ធ្វើវត្តខ្លះ ឃើញអាគន្តុកៈមានបាត្រចីវរចាស់ ក៏ស្វែងរកបាត្រ និងចីវរ ដោយភិក្ខាចារវត្ត ប្រគេនភិក្ខុអាគន្តុកៈនោះ ស្វែងរកគិលានភេសជ្ជដល់ភិក្ខុអាគន្តុកៈដែលអាពាធខ្លះ មិនពោលនឹងអាគន្តុកភិក្ខុដែលអាពាធ មិនមានទីពឹងថា ចូរទៅបរិវេណនោះ បម្រើនៅក្នុងបរិវេណរបស់ខ្លួននោះឯងខ្លះ ។ គម្ពីរដែលខុសឆ្គង ១ ក៏សង្គ្រោះភិក្ខុដែលមានបញ្ញា ឲ្យលោកលើកគម្ពីរនោះឡើងខ្លះ ឈ្មោះថា ព្រមព្រៀងគ្នា ធ្វើកិច្ចដែលគួរធ្វើរបស់សង្ឃ ។

ក្នុងបទថា **អប្បញ្ញត្តំ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា ភិក្ខុទាំង-ឡាយកាន់យកកតិកាវត្ត ឬសិក្ខាបទ ។ ដែលមិនមែនជាធម៌ថ្មី ឈ្មោះថាបញ្ញត្តបទដែលទ្រង់មិនបានបញ្ញត្ត ដូចភិក្ខុទាំងឡាយក្នុងក្រុងសាវត្ថី បញ្ញត្តបទដែលទ្រង់មិនបានបញ្ញត្ត ក្នុងរឿងសន្ថ័តចាស់ ដូច្នោះ ។

ភិក្ខុទាំងឡាយ សម្តែងពាក្យប្រៀនប្រដៅក្រៅធម៌ក្រៅវិន័យ ឈ្មោះថា

ដកបទដែលទ្រង់បញ្ញត្តហើយ ដូចភិក្ខុវជ្ជីបុត្រ អ្នកក្រុងវេសាលី ដកនូវសិក្ខាបទដែលទ្រង់បញ្ញត្តហើយ ក្នុងកាលព្រះមានព្រះភាគ ទ្រង់បរិនិព្វាន បាន ១០០ ឆ្នាំដូច្នោះ ។ ម្យ៉ាងទៀត ភិក្ខុទាំងឡាយតាំងចិត្តល្មើសនឹងអាបត្តិតូចតាច ឈ្មោះថា មិនអាចប្រព្រឹត្តសិក្ខាបទទាំងឡាយ តាមដែលទ្រង់បញ្ញត្តហើយ ដូចអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ ដូច្នោះ ។ ចំណែកភិក្ខុទាំងឡាយដែលមិនធ្វើយ៉ាងនោះ ឈ្មោះថា មិនបញ្ញត្តបទដែលទ្រង់មិនបានបញ្ញត្ត មិនដកបទបញ្ញត្តដែលទ្រង់បញ្ញត្តហើយ សមាទានប្រព្រឹត្តក្នុងសិក្ខាបទ ដែលទ្រង់បញ្ញត្តហើយ ដូចព្រះឧគ្គសេន ព្រះយសកាកណ្ឌកបុត្រ និងព្រះមហាកស្សប ដូច្នោះ ។ បទថា **វុឌ្ឍិយេវ** សេចក្តីថា គប្បីបំណងតែសេចក្តីចម្រើនដោយគុណ មានសីលគុណជាដើមប៉ុណ្ណោះ មិនគប្បីបំណងនូវសេចក្តីវិនាសឡើយ ។

បទថា **ថេរា** បានដល់ ជាអ្នកដល់នូវភាវៈមាំទាំ គឺប្រកបដោយគុណជាតិធ្វើភាពជាថេរៈ ព្រះថេរៈទាំងឡាយរមែងដឹងរាត្រីយូរ ហេតុនោះ ទើបឈ្មោះថា **រត្តញ្ញូ** ការបួសរបស់ភិក្ខុទាំងនេះអស់កាលយូរ ព្រោះហេតុនោះ ភិក្ខុទាំងនេះ ឈ្មោះថា **ចិរបព្វជិតា** ព្រះថេរៈទាំងឡាយ តាំងនៅក្នុងឋានៈជាបិតានៃសង្ឃ ហេតុនោះ ទើបឈ្មោះថា **សង្ឃបិតរោ** ព្រោះតាំងនៅក្នុងឋានៈជា **សង្ឃបិតរ** ។ ភិក្ខុពួកណានាំសង្ឃ គឺធ្វើជាប្រធានក្នុងភិក្ខុទាំងឡាយ ប្រព្រឹត្តក្នុងសិក្ខា ៣ ព្រោះហេតុនោះ ទើបព្រះថេរៈនោះ ឈ្មោះថា

**សង្ឃបរិណាយកា** *គឺអ្នកនាំសង្ឃ ។ ភិក្ខុទាំងឡាយណា មិនធ្វើសក្ការៈជាដើមដល់ព្រះថេរៈទាំងនោះ មិនប្រណិប័តន៍ ២-៣ វារៈ ដើម្បីជាប្រយោជន៍ដល់ការទទួលឱវាទ សូម្បីព្រះថេរៈទាំងនោះ រមែងមិនឲ្យឱវាទដល់ភិក្ខុទាំងនោះ មិនពោលវចនៈដែលជាបុរាណធម្មបវេណី ដល់ភិក្ខុទាំងនោះ មិនឲ្យសិក្សាធម្មបរិយាយដែលជាសារៈ ភិក្ខុទាំងនោះ កាលព្រះថេរៈទាំងនោះលះបង់ហើយ រមែងវិនាសចាកគុណទាំងឡាយជាដើមយ៉ាងនេះ គឺធម្មក្ខន្ធមានសីលក្ខន្ធជាដើម និងអរិយទ្រព្យ ៧ ប្រការ ។ ឯភិក្ខុទាំងឡាយណាធ្វើសក្ការៈជាដើមដល់ព្រះថេរៈទាំងនោះ ទៅប្រណិប័តន៍ព្រះថេរៈទាំងនោះ រមែងឲ្យឱវាទដល់ភិក្ខុទាំងនោះ មានពាក្យជាដើមថា អ្នកគប្បីឈានទៅខាងមុខ ដោយអាការយ៉ាងនេះ ពោលវាចាដែលជាធម្មបវេណី ឲ្យសិក្សាធម្មបរិយាយដែលជាខ្លឹម ប្រៀនប្រដៅដោយធុតង្គ ១៣ កថាវត្ថុ ១០ ភិក្ខុទាំងនោះតាំងនៅក្នុងឱវាទនៃព្រះថេរៈទាំងនោះ ចម្រើនដោយគុណ មានសីលគុណជាដើម រមែងសម្រេច តាមលំដាប់នូវប្រយោជន៍នៃសាមញ្ញផល ក្នុងសេចក្តីនេះ គប្បីជ្រាបការវិនាស និងការចម្រើនដោយអាការយ៉ាងនេះ ។*

*ការកើតជាថ្មីជាប្រក្រតីនៃតណ្ហានោះ ហេតុនោះ តណ្ហានោះ ឈ្មោះថា* **ពោនោព្ភវិកា** *អធិប្បាយថា ឲ្យនូវការកើតថ្មី ៗ នៃតណ្ហាដែលកើតថ្មីនោះ ។ ក្នុងពាក្យថា* **ន វសំ គច្ឆន្តិ** *នេះ មានវិនិច្ឆ័យដូចតទៅនេះថា ភិក្ខុទាំង-ឡាយណា ជាអ្នកប្រព្រឹត្តទៅតាមស្នាមឧបដ្ឋាកទាំងឡាយ ព្រោះហេតុនៃ*

បច្ច័យ ៤ រមែងត្រាច់ទៅស្រុកនោះខ្លះ ស្រុកនេះខ្លះ ភិក្ខុទាំងនោះ ឈ្មោះថា ទៅកាន់អំណាចនៃតណ្ហា ដែលមានការកើតជាថ្មីជាប្រក្រតីនោះ ។ ឯភិក្ខុមួយពួកទៀត មិនទៅកាន់អំណាចនៃតណ្ហាដែលមានប្រក្រតីកើតថ្មីនោះ ។ ក្នុងសេចក្តីនោះ ការវិនាស និងការចម្រើនទាំងឡាយ ប្រាកដហើយនោះឯង ។

បទថា **អារញ្ញកេសុ** បានដល់ ក្នុងទីនៃសេនាសនៈឆ្ងាយអំពីស្រុកប្រមាណ ៥០០ ធ្នូយ៉ាងតិច ។ បទថា **សាបេក្ខា** ប្រែថា នៅមានសេចក្តីអាល័យ ។ ពិតហើយ ភិក្ខុសូម្បីបានសម្រេចឈានក្នុងសេនាសនៈជិតស្រុក គ្រាន់តែចេញអំពីឈាននោះ បានស្តាប់សំឡេងស្រី ប្រុស និងកុមារជាដើម ព្រោះហេតុនោះ គុណវិសេសដែលភិក្ខុនោះសម្រេចហើយ រមែងវិនាសដោយពិត ។ ភិក្ខុសូម្បីត្រឡប់ទៅក្នុងសេនាសនៈព្រៃ លុះភ្ញាក់ឡើងបានឮសំឡេងរាជសីហ៍ សំឡេងខ្លាធំ និងសំឡេងក្ងោកជាដើម បាននូវបីតិក្នុងព្រៃ ពិចារណាសំឡេងនោះឯង ក៏តាំងនៅក្នុងផលដ៏ប្រសើរ ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់សរសើរភិក្ខុដែលសិងក្នុងព្រៃប៉ុណ្ណោះ សម្រាប់ភិក្ខុដែលបានឈានអង្គុយក្នុងសេនាសនៈជិតស្រុក ព្រោះហេតុនោះ អាស្រ័យអំណាចប្រយោជន៍នោះឯង ទើបត្រាស់ថា ភិក្ខុទាំងឡាយនឹងមានអាល័យក្នុងសេនាសនៈព្រៃដូច្នេះ ។

បទថា **បច្ចត្តញ្ញេវ សតឹ ឧបដ្ឋបេស្សន្តិ** សេចក្តីថា ចូលទៅតាំងសតិខាងក្នុងខ្លួន ។ បទថា **បេសលា** ប្រែថា ជាអ្នកមានសីលជាទីស្រឡាញ់

ភិក្ខុដែលជាម្ចាស់អាវាសទាំងឡាយ ទោះបីមិនប្រាថ្នាការមកនៃភិក្ខុសព្រហ្មចារី ទាំងឡាយ ក្នុងព្រះសាសនានេះ ជាអ្នកមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា មិនធ្វើវត្ត មានការចេញទៅទទួល ទទួលបាត្រ និងចីវរ ការក្រាលអាសនៈ និងការកាន់ផ្ចិតស្លឹកត្នោតជាដើម ដល់ភិក្ខុដែលមកដល់វិហារ ។ លំដាប់នោះ កិត្តិសព្ទដែលអាក្រក់របស់ភិក្ខុទាំងនោះ រមែងផ្សាយទៅថា ភិក្ខុទាំងឡាយ នៅក្នុងវិហារឈ្មោះនោះ ជាអ្នកមិនមានសទ្ធា មិនមានការជ្រះថ្លា មិនធ្វើវត្ត បដិបត្តិដល់ភិក្ខុដែលចូលទៅកាន់វិហារ ។ បព្វជិតទាំងឡាយ កាលបានដឹង រឿងនោះហើយ កាលដើរទៅតាមផ្លូវនោះ ក៏មិនចូលទៅកាន់វិហារ បព្វជិត ទាំងឡាយ ដែលមិនធ្លាប់មក ក៏មិនមក ដោយប្រការដូច្នេះ ។ ឯបព្វជិត ដែលមកដល់ហើយ កាលវិហារមិនមានផាសុក ចំណែកបព្វជិតដែលមកដល់ ព្រោះមិនដឹង ក៏នាំគ្នាត្រឡប់ចេញទៅ ដោយគិតថា ពួកយើងមកហើយដោយ បំណងថា ពួកយើងនឹងស្នាក់នៅ ទើបមកដោយបដិបត្តិទំនងនេះ របស់ ភិក្ខុម្ចាស់អាវាសទាំងនេះ អ្នកណានឹងស្នាក់នៅបាន ។ វិហារនោះ រមែងមិន ជាទីនៅរបស់ភិក្ខុដទៃទាំងឡាយ ដោយប្រការដូច្នេះ ។ លំដាប់នោះ ភិក្ខុ ដែលជាម្ចាស់អាវាសទាំងឡាយ កាលមិនបានឃើញភិក្ខុទាំងឡាយ ដែលជា អ្នកមានសីល រមែងមិនបានបន្ទោបង់សេចក្តីសង្ស័យ ដែលឲ្យសិក្សាអាចារ ឬការស្តាប់ធម៌ដ៏ពីរោះ ។ ភិក្ខុទាំងនោះ រមែងមិនបានរៀនធម៌ដែលធ្លាប់រៀន រមែងមិនបានធ្វើការស្វាធ្យាយធម៌ ដែលធ្លាប់រៀនមកហើយ ។ ដូច្នោះ ទើប

ភិក្ខុទាំងនោះ មានតែការសាបសូន្យតែម្យ៉ាង មិនមានការចម្រើនឡើយ ។

ឯភិក្ខុទាំងឡាយណា រមែងប្រាថ្នាការមកនៃសព្រហ្មចារីទាំងឡាយ ភិក្ខុទាំងនោះ ជាអ្នកមានសទ្ធា មានសេចក្ដីជ្រះថ្លា ធ្វើសាមីចិកម្ម មានការចេញទៅទទួលជាដើមដល់សព្រហ្មចារីទាំងឡាយ ដែលមកដល់ហើយ រមែងក្រាលអាសនៈប្រគេន នាំភិក្ខុដែលជាសព្រហ្មចារីទាំងនោះ ចូលទៅភិក្ខាចារ បន្ទោបង់នូវសេចក្ដីសង្ស័យ រមែងបាននូវការស្ដាប់ធម៌ដ៏ពីរោះ ។ លំដាប់នោះ កិត្តិនាមដ៏ល្អ របស់ភិក្ខុទាំងនោះក៏ផ្សាយទៅថា ភិក្ខុទាំងឡាយ ក្នុងវិហារឈ្មោះនោះ ជាអ្នកមានសទ្ធាជ្រះថ្លា សម្បូរទៅដោយវត្ត ជាអ្នកសង្គ្រោះដោយអាការយ៉ាងនេះ ភិក្ខុទាំងឡាយបានស្ដាប់ដំណឹងនោះ ទើបនាំគ្នាមកអំពីចម្ងាយ ។ ភិក្ខុទាំងឡាយដែលជាម្ចាស់អាវាស ធ្វើវត្តដល់ភិក្ខុទាំងនោះ ចូលទៅជិត ថ្វាយបង្គំភិក្ខុអាគន្តុកៈដែលចាស់ជាង ហើយគង់នៅ កាន់យកអាសនៈក្នុងសម្នាក់របស់ភិក្ខុដែលខ្ចីជាង ហើយអង្គុយ ។ សួរថា លោកម្ចាស់ទាំងឡាយនៅក្នុងទីនេះ ឬនឹងទៅ ។ កាលលោកពោលថា នឹងទៅ ទើបពោលពាក្យជាដើមថា សេនាសនៈជាសប្បាយ ភិក្ខារកបានងាយ ដូច្នេះហើយ ទើបមិនព្រមឲ្យទៅ បើភិក្ខុនោះ ជាព្រះវិនយធរសោត ក៏ស្វាធ្យាយព្រះវិន័យក្នុងសម្នាក់របស់លោក ។ បើលោកជាអ្នកទ្រទ្រង់ព្រះសូត្រជាដើម ក៏ស្វាធ្យាយធម៌ក្នុងសម្នាក់របស់លោក ភិក្ខុទាំងនោះតាំងនៅក្នុងឱវាទរបស់ព្រះថេរៈដែលជាអាគន្តុកៈ រមែងសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា

ទាំងឡាយ ។ អាគន្តុកភិក្ខុទាំងឡាយ រមែងជាអ្នកពោលថា ពួកខ្ញុំមកដោយគិតថា ពួកខ្ញុំនឹងសម្រាក ១ ថ្ងៃ ២ ថ្ងៃ តែពួកខ្ញុំក៏នៅ ១០ វស្សា ២០ វស្សា ដើម្បីជាប្រយោជន៍ដល់ការនៅជាសុខ សម្រាប់ភិក្ខុទាំងនេះ ។ គប្បីជ្រាបការវិនាស និងការចម្រើន ក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។ល។

## អដ្ឋកថា ភិក្ខុសូត្រទី ៣ ចប់

# សុត្តន្តបិដក

## កម្មសូត្រទី ៤

[ ២២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង អបរិហានិយធម៌ ៧ យ៉ាង ដល់អ្នកទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ឯអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុមិនត្រេកអរនឹងការងារ មិនប្រកបរឿយៗ នូវភាវៈជាអ្នកមានការងារជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំង-ឡាយ បើពួកភិក្ខុនឹងមិនជាអ្នកមានការនិយាយតិរច្ឆានកថា ជាទីត្រេកអរ ។បេ។ នឹងមិនជាអ្នកមានការដេកលក់ ជាទីត្រេកអរ នឹងមិនជាអ្នកមានគ្នីគ្នា

ជាទីត្រេកអរ នឹងមិនជាអ្នកមានសេចក្តីប្រាថ្នាអាក្រក់ មិនលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាអាក្រក់ មិនមានមិត្តអាក្រក់ មិនមានសម្លាញ់អាក្រក់ មិនងាកទៅរកបុគ្គលអាក្រក់ មិនដល់នូវសេចក្តីបន្ទរបន្ថយព្យាយាមក្នុងចន្លោះ ដោយការត្រាស់ដឹងនូវគុណវិសេស ត្រឹមតែជាន់ក្រោម អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ១ ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ ឋិតនៅក្នុងភិក្ខុទាំងឡាយ ឬថា ភិក្ខុទាំងឡាយ នឹងប្រតិបត្តិក្នុងអបរិហានិយធម៌ ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។

# អដ្ឋកថា

## កម្មសូត្រ

[ ២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកម្មសូត្រទី ៤ ដូចតទៅនេះ បទថា **ន កម្មារាមា** សេចក្តីថា ភិក្ខុពួកណាធ្វើកិច្ចកម្ម មានចីវរ វត្តពន្ធចង្កេះ សំពត់តម្រងទឹក ធម្មក្រក អំបោស តាំងរងជើងជាដើមប៉ុណ្ណោះ ប្រចាំថ្ងៃ ភិក្ខុទាំងនោះ ក៏ហាមឃាត់បានដោយសទ្ធា ឯភិក្ខុណា ក្នុងពេលធ្វើកិច្ចកម្មទាំងនោះ

ធ្វើកិច្ចកម្មទាំងនេះ ក្នុងវេលាខុសទេស ក៏រៀនខុសទេស វេលាធ្វើវត្តត្រង់លាន ចេតិយ ក៏ធ្វើវត្តត្រង់លានចេតិយ វេលាធ្វើមនសិការ ក៏ធ្វើមនសិការ ភិក្ខុ នោះឈ្មោះថា ជាអ្នកមិនត្រេកអរ ក្នុងការងារ ។

ភិក្ខុណា ធ្វើការជជែកគ្នាដល់ពណ៌សម្បុររបស់ស្រី និងប្រុសជាដើម ប៉ុណ្ណោះឲ្យកន្លងថ្ងៃ កន្លងយប់ទៅ មិនចប់នូវការជជែកគ្នាបែបនោះ ភិក្ខុនេះ ឈ្មោះថា ត្រេកអរក្នុងការនិយាយ ។ ម្យ៉ាងទៀត ភិក្ខុណាពោលសន្ទនាធម៌ ឆ្លើយបញ្ហាទាំងឡាយ ពេលយប់ និងពេលថ្ងៃ ភិក្ខុនេះ ទោះជាអ្នកនិយាយ តិច ក៏ពោលចប់ និយាយចប់ដូចគ្នា ព្រោះហេតុអ្វី ព្រោះព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រជុំគ្នាហើយ ត្រូវធ្វើកិច្ច ២ យ៉ាង គឺពាក្យប្រកបដោយធម៌ ១ ភាពជាអ្នកស្ងប់ស្ងៀមនៅដ៏ប្រសើរ ១ ។

ភិក្ខុណា ឈរក្តី ដើរក្តី អង្គុយក្តី ត្រូវថីនមិទ្ធៈគ្របសង្កត់ ក៏ដេកលក់ ទៅ ភិក្ខុនេះឈ្មោះថា ច្រើនដោយការដេកលក់ ។ ឯភិក្ខុណាមានចិត្តឈម ចុះកាន់ភវង្គ ព្រោះអាពាធនៃករជកាយ ភិក្ខុនេះមិនឈ្មោះថា មិនច្រើនដោយ ការដេកលក់ ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ តថាគតត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាបច្ឆាភត្ត ហើយក្រាលនូវសង្ឃាដិ មានជាន់ ៤ ហើយផ្ទាប់សិងដោយចំហៀងខាងស្តាំ មានសតិ និង សម្បជញ្ញៈ ចុះស៊ប់កាន់កិរិយាលក់ ក្នុងខែជាទីបំផុតនៃគិម្ហរដូវ ។

ភិក្ខុណាប្រឡូកប្រឡំយ៉ាងនេះ ជាបុគ្គលទី ២ សម្រាប់ភិក្ខុមួយរូប ជាមនុស្សទី ៣ សម្រាប់ភិក្ខុ ២ រូប ជាមនុស្សទី ៤ សម្រាប់មនុស្ស ៣ រូប នៅម្នាក់ឯង ក៏មិនបាននូវអស្សាទ គឺសេចក្ដីត្រេកអរ ភិក្ខុនេះឈ្មោះថា គាប់ចិត្តក្នុងការប្រឡូកប្រឡំ ចំណែកភិក្ខុណាម្នាក់ឯងប៉ុណ្ណោះ ក្នុងឥរិយាបថ ៤ រមែងបាននូវអស្សាទ ភិក្ខុនេះឈ្មោះថា មិនគាប់ចិត្តក្នុងការប្រឡូកប្រឡំ ។

ភិក្ខុដែលប្រកបដោយសេចក្ដីប្រាថ្នា ការសរសើរគុណដែលមិនមានក្នុងខ្លួន ជាអ្នកទ្រុស្តសីល ឈ្មោះថា មានសេចក្ដីប្រាថ្នាលាមក ។ ភិក្ខុពួកណា មានមិត្រអាក្រក់ សហាយអាក្រក់ មានសម្លាញ់អាក្រក់ ព្រោះបរិភោគរួមគ្នា ក្នុងឥរិយាបថទាំង ៤ ។ ភិក្ខុពួកណា ជាសម្លាញ់ក្នុងភិក្ខុអាក្រក់ទាំងឡាយ ព្រោះបង្អោនទៅ ទោរទន់ទៅ ទេរទៅក្នុងបាបមិត្រនោះ ភិក្ខុទាំងនោះ ឈ្មោះថា មិត្រអាក្រក់ សហាយអាក្រក់ សម្លាញ់អាក្រក់ ។

បទថា **ឱរមត្តកេន** បានដល់ មានប្រមាណតិចតួច គឺមានប្រមាណតិច ។ បទថា **អន្តរា** បានដល់ ក្នុងរវាងនេះ ព្រោះមិនទាន់បានសម្រេចអរហត្ត ។ បទថា **វោសានំ** បានដល់ ការចប់ ការរួញរាថា ប៉ុណ្ណោះក៏ល្មម ។

លោកអធិប្បាយដូច្នេះថា ភិក្ខុនឹងមិនដល់ទីបំផុតដោយគុណ មានសីលបរិសុទ្ធ ឈាន និងភាពជាសោតាបន្នជាដើមណាមួយ ដរាបណា ភិក្ខុទាំងឡាយ គប្បីបំណងតែសេចក្ដីចម្រើនតែម្យ៉ាង មិនវិនាសដរាបនោះ ៕

**អដ្ឋកថាកម្មសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## សទ្ធិយសូត្រទី ៥

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង អបរិហានិយធម៌ ៧ យ៉ាង ដល់អ្នកទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមានសេចក្តីជឿ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ ជាអ្នកមានសេចក្តីខ្មាសបាប ។បេ។ មានសេចក្តីខ្លាចបាប ជាពហុស្សូត ប្រារព្ធសេចក្តីព្យាយាម មានស្មារតី មានបញ្ញាអស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅក្នុងភិក្ខុទាំងឡាយ ឬថាភិក្ខុទាំងឡាយនឹងប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។

# អដ្ឋកថា

## សទ្ធិយសូត្រ

[ ២៣ ] ក្នុងសទ្ធិយសូត្រទី ៥ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសទ្ធិយសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ពោជ្ឈង្គសូត្រទី ៦

[ ២៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង អបរិហានិយធម៌ ៧ យ៉ាង ដល់អ្នកទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងចម្រើនសតិសម្ពោជ្ឈង្គ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងចម្រើនធម្មវិចយសម្ពោជ្ឈង្គ ។បេ។ នឹងចម្រើនវីរិយសម្ពោជ្ឈង្គ នឹងចម្រើនបីតិសម្ពោជ្ឈង្គ នឹងចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ នឹងចម្រើនសមាធិសម្ពោជ្ឈង្គ នឹងចម្រើនឧបេក្ខាសម្ពោជ្ឈង្គ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅក្នុងភិក្ខុទាំងឡាយ ឬថា ភិក្ខុទាំង

ឡាយនឹងប្រតិបត្តិ ក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។

# អដ្ឋកថា

## ពោជ្ឈង្គសូត្រទី ៦

[ ២៤ ] ក្នុងពោជ្ឈង្គសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាពោជ្ឈង្គសូត្រទី ៦ ចប់

# សុត្តន្តបិដក

## សញ្ញាសូត្រទី ៧

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង អបរិហានិយធម៌ ៧ យ៉ាង ដល់អ្នកទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចុះអបរិហានិយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ នឹងចម្រើនអនិច្ចសញ្ញា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់

ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាល ភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងចម្រើនអនត្តសញ្ញា ។បេ។ នឹងចម្រើនអសុភ-សញ្ញា នឹងចម្រើនអាទីនវសញ្ញា នឹងចម្រើនបហានសញ្ញា នឹងចម្រើនវិរាគ-សញ្ញា នឹងចម្រើននិរោធសញ្ញា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ ឋិតនៅក្នុងភិក្ខុទាំងឡាយ ឬថាភិក្ខុទាំងឡាយនឹងប្រតិបត្តិ ក្នុងអបរិ-ហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនតែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្ដីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។

# អដ្ឋកថា

## សញ្ញាសូត្រ

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសញ្ញាសូត្រទី ៧ ដូចតទៅនេះ សញ្ញាមានអនិច្ចសញ្ញាជាដើម គឺសញ្ញាដែលកើតព្រមជាមួយអនុបស្សនា មានអនិច្ចានុបស្សនាជាដើម ។ល។

**អដ្ឋកថា សញ្ញាសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សេក្ខសូត្រទី ៨

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៧ នេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់សេក្ខភិក្ខុ ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរ ក្នុងការនិយាយតិរច្ឆានកថា ១ សេចក្តីត្រេកអរក្នុងការដេកលក់ ១ សេចក្តីត្រេកអរ ក្នុងការប្រកបដោយគ្នីគ្នា ១ សេចក្តីមិនគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ ការមិនដឹងប្រមាណក្នុងភោជន ១ កិច្ចរបស់សង្ឃ តែងមានក្នុងសង្ឃ ភិក្ខុមិនពិចារណាក្នុងកិច្ចនោះថា ពួកព្រះថេរៈក្នុងសង្ឃ អ្នកដឹងរាត្រីវែង បួសយូរ អ្នកនាំទៅនូវភារៈ ពួកថេរៈទាំងនោះ ក៏នឹងប្រាកដដោយការងារនោះ ដូច្នេះហើយ ដល់នូវការប្រកបដោយខ្លួនឯង ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៧ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដល់សេក្ខភិក្ខុ ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់សេក្ខភិក្ខុឡើយ ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីមិនត្រេកអរ ក្នុងការងារ ១ សេចក្តីមិនត្រេកអរ ក្នុងការនិយាយតិរច្ឆានកថា ១ សេចក្តីមិនត្រេកអរក្នុងការដេកលក់ ១ សេចក្តីមិនត្រេកអរ ក្នុងការប្រកបដោយគ្នីគ្នា ១ ការគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ សេចក្តីដឹងប្រមាណក្នុងភោជន ១ កិច្ចរបស់សង្ឃ តែងមានក្នុងសង្ឃ ភិក្ខុពិចារណាក្នុងកិច្ចនោះថា ពួកព្រះថេរៈក្នុងសង្ឃ អ្នកដឹងនូវរាត្រីវែង បួសយូរ អ្នកនាំទៅនូវភារៈ ពួកព្រះថេរៈ

ទាំងនោះ នឹងប្រាកដ ដោយការងារនោះ ដូច្នេះហើយ មិនដល់នូវការប្រកប ដោយខ្លួនឯង ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះឯង រមែងប្រព្រឹត្ត ទៅ ដើម្បីមិនសាបសូន្យដល់សេក្ខភិក្ខុឡើយ ។

# អដ្ឋកថា

## សេក្ខសូត្រ

[ ២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសេក្ខសូត្រទី ៨ ដូចតទៅនេះ ភិក្ខុពួក ណា រមែងនាំទៅនូវការៈ ព្រោះជួយធ្វើកិច្ចរបស់សង្ឃដែលកើតឡើងហើយ ឲ្យសម្រេច ហេតុនោះ ភិក្ខុទាំងនោះ ឈ្មោះថា ជាអ្នកនាំការៈ ។ បទថា **តេ តេន បញ្ញាយិស្សន្តិ** សេចក្តីថា ព្រះថេរៈទាំងនោះនឹងប្រាកដ ដោយកិច្ចដែល សមគួរដល់ភាពជាព្រះថេរៈរបស់ខ្លួននោះ ។ បទថា **តេ យោគំ អាបជ្ជតិ** សេចក្តីថា រមែងដល់នូវការប្រកប គឺផ្តើមធ្វើកិច្ចទាំងនោះឯង ដូច្នេះ ។

**អដ្ឋកថា សេក្ខសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ហានិសូត្រទី ៩

[ ២៧ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ដល់ឧបាសក ។ ៧ យ៉ាង តើអ្វីខ្លះ ។ ឧបាសក ញុំាំងការឃើញនូវភិក្ខុឲ្យសាបសូន្យ ១ ប្រហែសនឹងការស្តាប់ព្រះសទ្ធម្ម ១ មិនសិក្សាក្នុងអធិសីល ១ ជាអ្នកមិនមានសេចក្តីជ្រះថ្លាច្រើន ក្នុងពួកភិក្ខុ ចាស់ ថ្មី កណ្តាល ១ ជាអ្នកមានចិត្តរិះគន់ ស្វែងរកទោសស្តាប់ធម៌ ១ ស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅសាសនានេះ ១ ធ្វើបុព្វការៈក្នុង ទក្ខិ-ណេយ្យបុគ្គល ខាងក្រៅសាសនានោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីសាបសូន្យដល់ឧបាសក ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ឧបាសក ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺឧបាសកមិនញុំាំងការឃើញ ភិក្ខុឲ្យសាបសូន្យ ១ មិនប្រហែសនឹងការស្តាប់ព្រះសទ្ធម្ម ១ សិក្សាក្នុងអធិសីល ១ ជាអ្នកមានសេចក្តីជ្រះថ្លាច្រើន ក្នុងពួកភិក្ខុ ចាស់ ថ្មី កណ្តាល ១ ជាអ្នកមានចិត្តមិនរិះគន់ មិនស្វែងរកទោសស្តាប់ធម៌ ១ មិនស្វែងរកទក្ខិណេយ្យ-បុគ្គល ខាងក្រៅសាសនានេះ ១ ធ្វើបុព្វការៈក្នុងទក្ខិណេយ្យបុគ្គល ក្នុងសាសនានេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ឧបាសក ។

ឧបាសកណា ញុំាំងការឃើញនូវពួកភិក្ខុ ដែលមានខ្លួនចម្រើន

ហើយ ឲ្យសាបសូន្យ ១ ប្រហែសនឹងការស្តាប់ នូវអរិយធម៌ទាំងឡាយ ១ មិនសិក្សាក្នុងអធិសីល ១ មានសេចក្តីមិនជ្រះថ្លាក្នុងពួកភិក្ខុ ចម្រើនឡើងដោយក្រៃលែង ១ មានចិត្តរិះគន់ប្រាថ្នាស្តាប់ព្រះសទ្ធម្ម ១ ស្វែងរកទក្ខិណេយ្យបុគ្គលដទៃ ខាងក្រៅសាសនានេះ ១ ឧបាសកធ្វើបុព្វការៈ ចំពោះទក្ខិណេយ្យ-បុគ្គលនោះ ១ ឧបាសក កាលសេពនូវបរិហានិយធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ រមែងសាបសូន្យចាកព្រះសទ្ធម្ម ។ ឧបាសកណាមិនញុំាងការឃើញនូវពួកភិក្ខុ ដែលមានខ្វះចម្រើនហើយ ឲ្យសាបសូន្យ ១ មិនប្រហែស នឹងការស្តាប់នូវអរិយធម៌ទាំង-ឡាយ ១ សិក្សាក្នុងអធិសីល ១ សេចក្តីជ្រះថ្លាក្នុងពួកភិក្ខុរបស់ឧបាសកនោះ ចម្រើនឡើងដោយក្រៃលែង ១ មានចិត្តមិនរិះគន់ ស្តាប់នូវព្រះសទ្ធម្ម ១ មិនស្វែងរកទក្ខិណេយ្យបុគ្គលដទៃ ខាងក្រៅសាសនានេះ ១ ឧបាសកតែងធ្វើបុព្វការៈ ចំពោះទក្ខិណេយ្យបុគ្គល ក្នុងសាសនានេះ ១ ឧបាសក កាលសេពនូវអបរិហានិយធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

# អដ្ឋកថា

## ហានិសូត្រ

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងហានិសូត្រទី ៩ ដូចតទៅនេះ បទថា **ភិក្ខុនស្សនំ ហាបេតិ** សេចក្តីថា ធ្វើការទៅសួរសុខទុក្ខភិក្ខុសង្ឃឲ្យវិនាសទៅ ។ បទថា **អធិសីលេ** បានដល់ ក្នុងសីលដ៏ឧត្តម ពោល គឺ សីល ៥ និងសីល ១០ ។ បទថា **ឥតោ ពហិទ្ធា** បានដល់ ក្រៅសាសនានេះ ។ បទថា **ទក្ខិណេយ្យំ គវេសតិ** សេចក្តីថា ស្វែងរកបុគ្គល អ្នកទទួលទេយ្យធម៌ ។ បទថា **តត្ថ ច បុព្វការំ ករោតិ** សេចក្តីថា ឲ្យទានដល់ពួកតិរ្ថិយខាងក្រៅទាំងនោះ ហើយថ្វាយទានដល់ភិក្ខុទាំងឡាយ ក្នុងកាលឯក្រោយ ពាក្យដ៏សេស ក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ។

អដ្ឋកថា ហានិសូត្រទី ៩ ចប់

# សុត្តន្តបិដក

## វិបត្តិសម្ភវសូត្រទី ១០

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ វិបត្តិរបស់ឧបាសកនេះមាន ៧ យ៉ាង ម្នាលភិក្ខុទាំងឡាយ សម្បត្តិរបស់ឧបាសកនេះមាន ៧ យ៉ាង ម្នាលភិក្ខុទាំងឡាយ សេចក្តីវិនាសរបស់ឧបាសកនេះមាន ៧ យ៉ាង ម្នាលភិក្ខុទាំងឡាយ

សេចក្ដីចម្រើនរបស់ឧបាសកនេះមាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺ ឧបាសកមិនញ៉ាំងការឃើញនូវភិក្ខុឲ្យសាបសូន្យ ១ មិនប្រហែសនឹងការស្ដាប់នូវព្រះសទ្ធម្ម ១ សិក្សាក្នុងអធិសីល ១ ជាអ្នកមានសេចក្ដីជ្រះថ្លាច្រើនក្នុងពួកភិក្ខុ ចាស់ ថ្មី កណ្ដាល ១ មិនមានចិត្តរិះគន់ មិនស្វែងរកទោសស្ដាប់ធម៌ ១ មិនស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅសាសនានេះ ១ ធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គលក្នុងសាសនានេះ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនរបស់ឧបាសកមាន ៧ យ៉ាងនេះឯង ។

ឧបាសកណា ញ៉ាំងការឃើញនូវពួកភិក្ខុ ដែលមានខ្លួនចម្រើនហើយឲ្យសាបសូន្យ ១ ប្រហែសក្នុងការស្ដាប់នូវអរិយធម៌ទាំងឡាយ ១ មិនសិក្សាក្នុងអធិសីល ១ មានសេចក្ដីមិនជ្រះថ្លាក្នុងពួកភិក្ខុចម្រើនដោយក្រៃលែង ១ ជាអ្នកមានចិត្តរិះគន់ ប្រាថ្នាស្ដាប់នូវព្រះសទ្ធម្ម ១ ស្វែងរកទក្ខិណេយ្យបុគ្គលដទៃខាងក្រៅសាសនានេះ ១ ឧបាសកធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គលខាងក្រៅសាសនានេះ ១ ឧបាសកកាលសេពនូវបរិហានិយធម៌ទាំង ៧ នេះឯង ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងហើយដោយប្រពៃ រមែងសាបសូន្យចាកព្រះសទ្ធម្ម ។

ឧបាសកណា មិនញ៉ាំងការឃើញនូវពួកភិក្ខុ ដែលមានខ្លួនចម្រើនហើយឲ្យសាបសូន្យ ១ មិនប្រហែសចំពោះការស្ដាប់នូវអរិយធម៌ទាំងឡាយ ១ សិក្សាក្នុងអធិសីល ១ សេចក្ដីជ្រះថ្លាក្នុងពួកភិក្ខុរបស់

ឧបាសកនោះ ចម្រើនដោយក្រៃលែង ១ មិនមានចិត្តរិះគន់ប្រាថ្នាស្តាប់នូវព្រះសទ្ធម្ម ១ មិនស្វែងរកទក្ខិណេយ្យបុគ្គលដទៃខាងក្រៅសាសនានេះ ១ ឧបាសកធ្វើបុព្វការៈ ចំពោះទក្ខិណេយ្យ-បុគ្គលក្នុងសាសនានេះ ១ ឧបាសកកាលសេពនូវអបរិហានិយ-ធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយដោយប្រពៃ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

វជ្ជីវគ្គទី ៣ ចប់

## ឧទ្ទាននៃវជ្ជីវគ្គនោះគឺ

និយាយពីសារន្ទទចេតិយ ១ វស្សការព្រាហ្មណ៍ ១ ភិក្ខុ ១ ការងារ ១ ធម្មជាតដែលគួរជឿ ១ ធម៌ជាចំណែកនៃការត្រាស់ដឹង ១ សញ្ញា ១ សេក្ខភិក្ខុ ១ សេចក្តីសាបសូន្យ ១ វិបត្តិ ១ សេចក្តីចម្រើន ១ ។

# អដ្ឋកថា

## វិបត្តិសម្ភវសូត្រ

[ ២៨ ] ក្នុងវិបត្តិសម្ភវសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាវិបត្តិសម្ភវសូត្រទី ១០ ចប់**

**វជ្ជីវគ្គទី ៣ ចប់**

# សុត្តន្តបិដក

## ទេវតាវគ្គ

### អប្បមាទសូត្រទី ១

[ ២៩ ] លំដាប់នោះឯង ទេវតាមួយអង្គ មានរស្មីដ៏រុងរឿង កាលដែលវេលារាត្រីបឋមយាមកន្លងផុតទៅ ក៏ធ្វើវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ឋិតនៅក្នុងទីសមគួរ ។ លុះទេវតានោះឋិតនៅក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តា ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ គោរពការមិនប្រមាទ ១ គោរពការធ្វើបដិសណ្ឋារៈ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ លុះទេវតានោះក្រាបបង្គំទូលសេចក្តីនេះចប់ហើយ ព្រះសាស្តាក៏ទ្រង់សព្វព្រះហឫទ័យ ។ លំដាប់នោះ ទេវតានោះគិតថា ព្រះសាស្តាទ្រង់សព្វព្រះហឫទ័យនឹងអាត្មាអញដូច្នេះហើយ ក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ រួចបាត់អំពីទីនោះឯង ។ លុះវេលាកន្លងរាត្រីនោះមក ព្រះដ៏មានព្រះភាគបានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ វេលាយប់មិញនេះ មានទេវតាមួយ

អង្គ មានរស្មីដ៏រុងរឿង កាលដែលវេលារាត្រីបឋមយាមកន្លងផុតទៅ ក៏ធ្វើវត្តជេតពន ទាំងមូលឲ្យភ្លឺស្វាង ហើយចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឋិតនៅក្នុងទីសមគួរ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ ឋិតនៅក្នុងទីសមគួរហើយ ក៏បាននិយាយសេចក្តីនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តា ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ គោរពការមិនប្រមាទ ១ គោរពការធ្វើបដិសណ្ឋារៈ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះបាននិយាយសេចក្តីនេះចប់ហើយ លុះថ្លែងសេចក្តីនេះរួចហើយ ក៏ថ្វាយបង្គំតថាគតធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះឯង ។

> គោរពព្រះសាស្តាផង គោរពព្រះធម៌ផង គោរពដ៏ក្លៀវក្លាចំពោះព្រះសង្ឃផង គោរពសមាធិផង គោរពដ៏ក្លៀវក្លាចំពោះសិក្ខាផង គោរពការមិនប្រមាទផង គោរពការធ្វើបដិសណ្ឋារៈផង ( ភិក្ខុនោះ ) មិនគួរនឹងសាបសូន្យ ( ចាកមគ្គ និងផលឡើយ រមែងឋិតនៅ ) ក្នុងទីជិតព្រះនិព្វាន ។

# អដ្ឋកថា

## ទេវតាវគ្គទី ៤

### អប្បមាទសូត្រ

[ ២៩ ] ក្នុងអប្បមាទសូត្រទី ១ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអប្បមាទសូត្រទី ១ ចប់

# សុត្តន្តបិដក

## ហិរិមាសូត្រទី ២

[ ៣០ ] ម្នាលភិក្ខុទាំងឡាយ វេលាយប់មិញនេះ មានទេវតាមួយអង្គ មានរស្មីដ៏រុងរឿង កាលដែលវេលារាត្រីបឋមយាមកន្លងផុតទៅ ក៏ធ្វើវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលមកគាល់តថាគត លុះចូលមកដល់ហើយ ថ្វាយបង្គំតថាគត រួចឋិតនៅក្នុងទីសមគួរ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះឋិតនៅក្នុងទីសមគួរហើយ បាននិយាយសេចក្ដីនេះ នឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្ដេចខ្លះ ។ គឺសេចក្ដីគោរពព្រះសាស្ដា ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ គោរពសេចក្ដីខ្មាសបាប ១ គោរពសេចក្ដីខ្លាចបាប ១ ។ បពិត្រព្រះអង្គដ៏

បម្រើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះបាននិយាយសេចក្តីនេះចប់ហើយ ថ្លែងសេចក្តីនេះរួចហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះ ។

ភិក្ខុមានសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីគោរពព្រះសាស្តាផង គោរពព្រះធម៌ផង គោរពដ៏ក្រៃក្លាចំពោះព្រះសង្ឃផង គោរពសមាធិផង គោរពដ៏ក្រៃក្លាក្នុងសិក្ខាផង បរិបូណ៌ដោយសេចក្តីខ្មាសបាប និងខ្លាចបាបផង ជាអ្នកប្រកបដោយសេចក្តីកោតក្រែង សេចក្តីគោរព ( ភិក្ខុនោះ ) មិនគួរនឹងសាបសូន្យ ( ចាកមគ្គ និងផលឡើយ រមែងឋិតនៅ ) ក្នុងទីជិតនៃព្រះនិព្វាន ។

# អដ្ឋកថា

## ហិរីមាសូត្រ

[ ៣០ ] ក្នុងហិរីមាសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាហិរីមាសូត្រទី ២ ចប់

# សុត្តន្តបិដក

## បឋមសុវចសូត្រទី ៣

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ វេលាយប់មិញនេះ មានទេវតាមួយអង្គ ។បេ។ បាននិយាយសេចក្តីនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តា ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ ភាពជាអ្នកប្រដៅងាយ ១ ភាពជាអ្នកមានមិត្តល្អ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះ បាននិយាយសេចក្តីនេះចប់ហើយ លុះបានថ្វាយសេចក្តីនេះរួចហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះឯង ។

ភិក្ខុមានសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តី
គោរពព្រះសាស្តាផង គោរពព្រះធម៌ផង គោរពដ៏ក្លៀវក្លាចំពោះ
ព្រះសង្ឃផង គោរពសមាធិផង គោរពដ៏ក្លៀវក្លាក្នុងសិក្ខាផង
ជាអ្នកមានមិត្តល្អផង គេប្រដៅងាយផង ជាអ្នកប្រកបដោយ
សេចក្តីកោតក្រែង សេចក្តីគោរព ( ភិក្ខុនោះ ) មិនគួរនឹង
សាបសូន្យ ( ចាកមគ្គ និងផលឡើយ រមែងឋិតនៅ ) ក្នុង
ទីជិតនៃព្រះនិព្វាន ។

# អដ្ឋកថា

## បឋមសុវចសូត្រ

[ ៣១ ] ក្នុងបឋមសុវចសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមសុវចសូត្រទី ៣ ចប់

## ទុតិយសុវចសូត្រទី ៤

[ ៣២ ] ម្នាលភិក្ខុទាំងឡាយ វេលាយប់មិញនេះ មានទេវតាមួយអង្គ ។បេ។ បាននិយាយសេចក្តីនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តា ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសមាធិ ១ ភាពជាអ្នកប្រដៅងាយ ១ ភាពជាអ្នកមានមិត្តល្អ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះឯង តែងប្រព្រឹត្តទៅដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះបាននិយាយសេចក្តីនេះចប់ហើយ បានថ្វាយសេចក្តីនេះរួចហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះឯង ។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដោយសេចក្តីសង្ខេបនេះ

ឯង ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីគោរពព្រះសាស្តា ដោយខ្លួនឯងផង ពណ៌នាគុណនៃសេចក្តីគោរព ព្រះសាស្តាផង ភិក្ខុដទៃណាមិនទាន់មាន សេចក្តីគោរពព្រះសាស្តា ក៏ដឹកនាំភិក្ខុទាំងនោះ ឲ្យគោរពព្រះសាស្តាផង ភិក្ខុដទៃណា មានសេចក្តីគោរពព្រះសាស្តាហើយ ក៏ពណ៌នាគុណរបស់ភិក្ខុ ទាំងនោះ តាមសេចក្តីពិតមែនក្នុងកាលគួរផង ។ ជាអ្នកមានសេចក្តីគោរព ព្រះធម៌ដោយខ្លួនឯង ។បេ។ ជាអ្នកមានសេចក្តីគោរពព្រះសង្ឃ មានសេចក្តី គោរពសិក្ខា មានសេចក្តីគោរពសមាធិ ជាអ្នកដែលគេប្រដៅងាយ ជាអ្នក មានមិត្តល្អ ពណ៌នាគុណនៃការមានមិត្តល្អផង ភិក្ខុដទៃណាមិនទាន់មានមិត្ត ល្អ ក៏ដឹកនាំភិក្ខុទាំងនោះ ឲ្យមានមិត្តល្អផង ភិក្ខុដទៃណា មានមិត្តល្អហើយ ក៏ពណ៌នាគុណរបស់ភិក្ខុទាំងនោះ តាមសេចក្តីពិតមែន ក្នុងកាលគួរផង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដោយ សេចក្តីសង្ខេបនេះឯង ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារយ៉ាងនេះ ។ ព្រះ ដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលសារីបុត្ត ប្រពៃហើយៗ ម្នាលសារីបុត្ត ប្រពៃណាស់ហើយ ធម៌នេះ តថាគតសម្តែងហើយដោយសង្ខេប អ្នកយល់ សេចក្តីដោយពិស្តារយ៉ាងនេះបាន ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ជា អ្នកមានសេចក្តីគោរព ព្រះសាស្តាដោយខ្លួនឯងផង ពណ៌នាគុណនៃសេចក្តី គោរពព្រះសាស្តាផង ភិក្ខុដទៃណាមិនទាន់មានសេចក្តីគោរពព្រះសាស្តា ក៏

ដឹកនាំភិក្ខុទាំងនោះ ឲ្យគោរពព្រះសាស្តាផង ភិក្ខុដទៃណាមានសេចក្តីគោរពព្រះសាស្តាហើយ ពណ៌នាគុណរបស់ភិក្ខុទាំងនោះតាមសេចក្តីពិតមែន ក្នុងកាលគួរផង ។ ជាអ្នកមានសេចក្តីគោរពព្រះធម៌ដោយខ្លួនឯងផង ។បេ។ ជាអ្នកមានសេចក្តីគោរពព្រះសង្ឃ មានសេចក្តីគោរពសិក្ខា មានសេចក្តីគោរពសមាធិ ជាអ្នកដែលគេប្រដៅងាយ ជាអ្នកមានមិត្តល្អផង ពណ៌នាគុណនៃការមានមិត្តល្អផង ភិក្ខុដទៃណាមិនទាន់មានមិត្តល្អ ក៏ដឹកនាំភិក្ខុទាំងនោះឲ្យមានមិត្តល្អផង ភិក្ខុដទៃណាមានមិត្តល្អហើយ ក៏ពណ៌នាគុណរបស់ភិក្ខុទាំងនោះ តាមសេចក្តីពិតមែន ក្នុងកាលគួរផង ។ ម្នាលសារីបុត្ត ធម៌នេះឯងតថាគតសម្តែងហើយ ដោយសេចក្តីសង្ខេប គប្បីយល់សេចក្តីដោយពិស្តារយ៉ាងនេះ ។

## អដ្ឋកថា

## ទុតិយសុវចសូត្រ

[ ៣២ ] ក្នុងទុតិយសុវចសូត្រទី ៤ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយសុវចសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមសខាសូត្រទី ៤

[ ៣៣ ] ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៧ ប្រការ គួរសេពគប់ ។ ប្រកបដោយអង្គ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺមិត្តឲ្យនូវរបស់ដែលគេឲ្យបានដោយកម្រ ១ ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ ១ អត់ធន់ ចំពោះហេតុដែលគេអត់ធន់បានដោយកម្រ ១ បើកបង្ហាញសេចក្តីកំបាំងរបស់ខ្លួនដល់គ្នា ១ បិទសេចក្តីកំបាំងរបស់គ្នា ១ មិនលះគ្នាក្នុងគ្រាមានសេចក្តីអន្តរាយ ១ មិនមើលងាយគ្នាព្រោះអស់ភោគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៧ ប្រការនេះឯង គួរសេពគប់ ។

មិត្តឲ្យនូវរបស់ដែលគេឲ្យបានដោយកម្រផង ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រផង មួយទៀត អត់ធន់ចំពោះពាក្យដែលពោលអាក្រក់ និងហេតុដែលអត់ធន់បានដោយកម្រផង ប្រាប់សេចក្តីកំបាំងរបស់ខ្លួនដល់គ្នាផង បិទសេចក្តីកំបាំងរបស់គ្នាផង មិនលះគ្នាក្នុងគ្រាមានសេចក្តីអន្តរាយផង មិនមើលងាយគ្នាព្រោះអស់ភោគៈផង ហេតុទាំងនេះមានក្នុងបុគ្គលណា ក្នុងលោកនេះ បុគ្គលមានសភាពដូច្នោះនោះ ហៅថា មិត្ត ជនអ្នកមានប្រាថ្នានូវមិត្ត គប្បីសេពគប់ ។

# អដ្ឋកថា

## បឋមសខាសូត្រ

[ ៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសខាសូត្រទី ៥ នៃទេវតាវគ្គទី ៤ ដូចតទៅនេះ បទថា **ទុទ្ទទំ** គឺរបស់ដែលមានតម្លៃច្រើន ដែលលះបាន លំបាក ។ បទថា **ទុក្ករំ ករោតិ** សេចក្ដីថា រមែងធ្វើកិច្ចកម្មដែលមិនងាយ នឹងធ្វើបាន ។

បទថា **ទុក្ខមំ ខមតិ** សេចក្ដីថា រមែងអត់សង្កត់បានលំបាក ដើម្បី ជាប្រយោជន៍ដល់សម្លាញ់ ។ បទថា **គុយ្ហមស្ស អាវិករោតិ** សេចក្ដីថា រមែងបើកផ្ការនូវអាថ៌កំបាំងរបស់ខ្លួនដល់សម្លាញ់នោះ ។ បទថា **គុយ្ហមស្ស បរិគូហតិ** សេចក្ដីថា មិនប្រាប់អាថ៌កំបាំងរបស់សម្លាញ់នោះដល់អ្នកដទៃ ។ បទថា **ខីណេន នាតិមញ្ញតិ** បានដល់ កាលភោគសម្បត្តិរបស់សម្លាញ់នោះ អស់ទៅហើយ ក៏មិនមើលងាយសម្លាញ់នោះ ព្រោះការវិនាសនោះ គឺមិនធ្វើ ការជាន់ឈ្លី និងមើលងាយក្នុងខ្លួនសម្លាញ់នោះ ។

**អដ្ឋកថា បឋមសខាសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយសខាសូត្រទី ៦

[ ៣៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយធម៌ ៧ ប្រការ បុគ្គលអ្នកស្វែងមិត្ត ទោះបីលោកបណ្តេញបំបរបង់ចេញ ក៏គួរតែសេពគប់ រាប់រក ចូលទៅអង្គុយជិត ។ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុជាអ្នក ( ធ្វើខ្លួន ) ឲ្យជាទីស្រឡាញ់ និងជាទីគាប់ចិត្ត ១ គួរគោរព ១ គួរសរសើរ ១ ឧស្សាហ៍ប្រៀនប្រដៅ ១ អត់ធន់ចំពោះពាក្យ ១ ជាអ្នកនិយាយពាក្យជ្រៅ ១ មិនដឹកនាំក្នុងហេតុដែលមិនគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយធម៌ ៧ ប្រការនេះឯង បុគ្គលអ្នកស្វែងមិត្ត បើទុកជាលោកបណ្តេញបំបរបង់ចេញ ក៏គួរតែសេពគប់ រាប់រក ចូលទៅអង្គុយជិត ។

ភិក្ខុជាអ្នក ( ធ្វើខ្លួន ) ឲ្យជាទីស្រឡាញ់ផង គួរគោរពផង
គួរសរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យ
ផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុដែល
មិនគួរផង ហេតុទាំងនេះ មានក្នុងបុគ្គលណា ក្នុងលោកនេះ
បុគ្គលជាអ្នកប្រាថ្នានូវប្រយោជន៍ អ្នកធ្វើនូវសេចក្តីអនុគ្រោះ
មានសភាពដូច្នោះនោះ ឈ្មោះថា ជាមិត្ត បុគ្គលអ្នកមានសេចក្តី
ត្រូវការដោយមិត្ត ទោះបីជាលោកធ្វើឲ្យវិនាស ក៏គួរតែតាម
សេពគប់ ។

# អដ្ឋកថា

## ទុតិយសខាសូត្រ

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសខាសូត្រទី ៦ ដូចតទៅនេះ បទថា **វត្តា** បានដល់ អ្នកឈ្លាសក្នុងវាចា ។ បទថា **វចនក្ខមោ** សេចក្តីថា ភិក្ខុរមែងអត់ធន់នូវពាក្យ គឺធ្វើតាមឱវាទដែលលោកឲ្យ ។ បទថា **គម្ភីរំ** បានដល់ វាចាដែលកំបាំង វាចាជ្រាលជ្រៅ ដែលអាស្រ័យឈាន អាស្រ័យវិបស្សនា មគ្គ ផល និងនិព្វាន ។៚

**អដ្ឋកថាទុតិយសខាសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមបដិសម្ភិទាសូត្រទី ៧

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ ប្រការ មិនយូរប៉ុន្មានទីនឹងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវបដិសម្ភិទា ៤ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងមិនខាន ។ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីប្រអូសចិត្តរបស់អញ ១ ឬចិត្តខាងក្នុងរួញរា ក៏ដឹងច្បាស់តាមពិតថា ចិត្តខាងក្នុងរបស់អញរួញរា ១ ឬចិត្តខាងក្រៅរាយមាយ ក៏ដឹងច្បាស់តាមពិតថា ចិត្តខាង

ក្រៅរបស់អញរាយមាយ ១ ភិក្ខុនោះដឹងនូវវេទនាទាំងឡាយ ដែលកើតឡើង ដឹងវេទនាទាំងឡាយប្រាដកឡើង ដឹងនូវវេទនាទាំងឡាយ ដែលដល់នូវសេចក្តីវិនាស ១ ដឹងនូវសញ្ញាទាំងឡាយដែលកើតឡើង ដឹងនូវសញ្ញាទាំង-ឡាយ ដែលប្រាកដឡើង ដឹងនូវសញ្ញាទាំងឡាយ ដែលដល់នូវសេចក្តីវិនាស ១ ដឹងនូវវិតក្កទាំងឡាយ ដែលកើតឡើង ដឹងនូវវិតក្កទាំងឡាយ ដែលប្រាកដឡើង ដឹងនូវវិតក្កទាំងឡាយ ដែលដល់នូវសេចក្តីវិនាស ១ ហេតុក្នុងធម៌ជាទីសប្បាយ ឬមិនជាទីសប្បាយ ថោកទាប ឬខ្ពង់ខ្ពស់ ជាចំណែកខ្មៅ ឬស ក៏ភិក្ខុនោះបានកំណត់ទុកល្អ ធ្វើទុកក្នុងចិត្តល្អ ចងចាំល្អ ដឹងច្បាស់ល្អហើយដោយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ ប្រការនេះឯង មិនយូរប៉ុន្មានទឹងធ្វើឲ្យជាក់ច្បាស់សម្រេចនូវបដិសម្ភិទា ៤ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងមិនខាន ។

## អដ្ឋកថា

## បឋមបដិសម្ភិទាសូត្រ

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមបដិសម្ភិទាសូត្រទី ៧ ដូចតទៅនេះ បទថា **ឥធម្ម ចេតសោ លីនត្តំ** សេចក្តីថា កាលចិត្តរួញរាកើតឡើង

ហើយ ភិក្ខុរមែងដឹងតាមសភាវៈពិតថា ចិត្តរបស់អាត្មាអញរួញរា ចិត្តទៅតាមថីនមិទ្ធៈ ឈ្មោះថា ចិត្តរួញរាក្នុងខាងក្នុង ចិត្តដែលរត់ច្រវាទៅក្នុងកាមគុណ ៥ ឈ្មោះថា ចិត្តរាយមាយទៅខាងក្រៅ ។ បទថា **វេទនា** ជាដើម ព្រះមានព្រះភាគទ្រង់កាន់យកដោយអំណាចមូលនៃធម៌ ដែលជាគ្រឿងយឺតយូរ ។ ដ្បិតថា វេទនាជាមូលនៃតណ្ហា ព្រោះតណ្ហាកើតឡើង ដោយអំណាចសេចក្ដីសុខសញ្ញាជាមូលរបស់ទិដ្ឋិ ព្រោះទិដ្ឋិកើតឡើងក្នុងអវិភូតារម្មណ៍ គឺអារម្មណ៍ដែលមិនជាក់ច្បាស់ វិតក្កជាមូលនៃមានះ ព្រោះអស្មិមានះកើតឡើង ដោយអំណាចវិតក្ក ។ បទថា **សប្បាយា សប្បាយេសុ** បានដល់ជាឧបការៈ និងមិនជាឧបការៈ ។ បទថា **និមិត្តំ** បានដល់ ហេតុ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា បឋមបដិសម្ភិទាសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយបដិសម្ភិទាសូត្រទី ៨

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌ ៧ ប្រការ ទើបធ្វើឲ្យជាក់ច្បាស់សម្រេចនូវបដិសម្ភិទា ៤ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួន

ឯង ។ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សារីបុត្តដឹងច្បាស់តាមពិតថា នេះជាសេចក្តីប្រមូលចិត្តរបស់អញ ១ ឬចិត្តខាងក្នុងរួញរា ក៏ដឹងច្បាស់តាមពិតថា ចិត្តខាងក្នុងរបស់អញរួញរា ១ ឬចិត្តខាងក្រៅរាយមាយ ក៏ដឹងច្បាស់តាមពិតថា ចិត្តខាងក្រៅរបស់អញរាយមាយ ១ ព្រះសារីបុត្តដឹងនូវវេទនាទាំងឡាយ ដែលកើតឡើង ដឹងនូវវេទនាដែលប្រាដកឡើង ដឹងនូវវេទនាដែលដល់នូវសេចក្តីវិនាស ១ ដឹងនូវសញ្ញាទាំងឡាយដែលកើតឡើង ដឹងនូវសញ្ញាដែលប្រាកដឡើង ដឹងនូវសញ្ញាដែលដល់នូវសេចក្តីវិនាស ១ ដឹងនូវវិតក្កទាំងឡាយដែលកើតឡើង ដឹងនូវវិតក្កដែលប្រាកដឡើង ដឹងនូវវិតក្កដែលដល់នូវសេចក្តីវិនាស ១ ហេតុក្នុងធម៌ជាទីសប្បាយ ឬមិនជាទីសប្បាយ ថោកទាបឬខ្ពង់ខ្ពស់ ជាចំណែកខ្មៅ ឬស ក៏សារីបុត្តបានកំណត់ទុកល្អ ធ្វើទុកក្នុងចិត្តល្អ ចងចាំល្អ ដឹងច្បាស់ល្អហើយដោយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌ ៧ ប្រការនេះឯង ធ្វើឲ្យជាក់ច្បាស់សម្រេចនូវបដិសម្ភិទា ៤ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ។

# អដ្ឋកថា

## ទុតិយបដិសម្ភិទាសូត្រ

[ ៣៦ ] ទុតិយបដិសម្ភិទាសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយបដិសម្ភិទាសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បឋមវសសូត្រទី ៩

[ ៣៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ ប្រការ រមែងញ៉ាំងចិត្តឲ្យលុះក្នុងអំណាច ( របស់ខ្លួន ) បាន មិនមែនភិក្ខុលុះអំណាចចិត្តទេ ។ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឈ្លាសវៃក្នុងសមាធិ ១ ឈ្លាសវៃក្នុងវិធីចូលសមាធិ ១ ឈ្លាសវៃក្នុងវិធីតម្កល់ទុកសមាធិ ១ ឈ្លាសវៃក្នុងវិធីចេញចាកសមាធិ ១ ឈ្លាសវៃក្នុងវិធីចែករលែកនូវសមាធិ ១ ឈ្លាសវៃក្នុងទីគោចរនៃសមាធិ ១ ឈ្លាសវៃក្នុងវិធីនាំមកនូវសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ ប្រការនេះឯង រមែងញ៉ាំងចិត្តឲ្យលុះក្នុងអំណាច ( របស់ខ្លួន ) បាន មិនមែនភិក្ខុលុះអំណាចចិត្តទេ ។

# អដ្ឋកថា

## បឋមវសសូត្រ

[ ៣៧ ] ក្នុងបឋមវសសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមវសសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ទុតិយវសសូត្រទី ១០

[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌ ៧ ប្រការ ទើបញុំាងចិត្តឲ្យលុះក្នុងអំណាច ( របស់ខ្លួន ) មិនមែនសារីបុត្តលុះអំណាចចិត្តទេ ។ ប្រកបដោយធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សារីបុត្តជាអ្នកឈ្លាសវៃក្នុងសមាធិ ១ ឈ្លាសវៃក្នុងវិធីចូលសមាធិ ១ ឈ្លាសវៃក្នុងវិធីតម្កល់ទុកសមាធិ ១ ឈ្លាសវៃក្នុងវិធីចេញចាកសមាធិ ១ ឈ្លាសវៃក្នុងវិធីចែករំលែកសមាធិ ១ ឈ្លាសវៃក្នុងទីគោចរនៃសមាធិ ១ ឈ្លាសវៃក្នុងវិធីនាំមកនូវសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌ ៧ ប្រការនេះឯង ទើបញុំាងចិត្តឲ្យលុះទៅ ក្នុងអំណាច ( របស់ខ្លួន ) មិនមែនសារីបុត្តលុះអំណាចចិត្តទេ ។

# អដ្ឋកថា

## ទុតិយវសសូត្រ

[ ៣៨ ] ក្នុងទុតិយវសសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយវសសូត្រទី ១០ ចប់

# សុត្តន្តបិដក

## បឋមនិទ្ទសសូត្រទី ១១

[ ៣៩ ] គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ដំណើរត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី ព្រឹកណាស់នៅឡើយ បើដូច្នោះ អញគួរចៀងចូលទៅឯអារាមរបស់បរិព្វាជក ជាអន្យតិត្ថិយសិន ។ ទើបព្រះសារីបុត្តដ៏មានអាយុ ចូលទៅឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិត្ថិយ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងពួកបរិព្វាជក ជាអន្យតិត្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់នៅក្នុងទីសមគួរ ។ ក៏ក្នុងសម័យនោះឯង ពួកបរិព្វាជក ជាអន្យតិត្ថិយទាំងនោះអង្គុយប្រជុំគ្នា ហើយបានផ្តើមសួរពាក្យជាចន្លោះនេះថា ម្នាលអាវុសោទាំងឡាយ

បុគ្គលណាមួយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិសុទ្ធ ពេញលេញអស់ ១២ ឆ្នាំ តើគួរនឹងហៅបុគ្គលនោះថា ជាភិក្ខុមិនមានអាយុ ១០ ឆ្នាំបានឬទេ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មិនបានត្រេកអរមិនបានហាមឃាត់ នូវភាសិតរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះឡើយ លុះមិនត្រេកអរមិនហាមឃាត់ ហើយក្រោកចាកអាសនៈដើរចេញទៅ ដោយមានបំណងថា អញគង់នឹងយល់នូវសេចក្តីនៃភាសិតនុ៎ះ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ ទើបព្រះសារីបុត្តដ៏មានអាយុ ត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់មកអំពីបិណ្ឌបាតក្នុងកាលជាខាងក្រោយភត្តវិញ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់នៅក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ គង់នៅក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលនូវដំណើរនោះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា ដំណើរត្រាច់ទៅ ដើម្បីបិណ្ឌបាត ក្នុងក្រុងសាវត្ថីព្រឹកណាស់នៅឡើយ បើដូច្នោះ អញគួរចៀងចូលទៅឯអារាមរបស់បរិព្វាជក ជាអន្យតិរ្ថិយសិន បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គក៏បានចូលឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់

ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចម្រើន សម័យនោះឯង ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ អង្គុយប្រជុំគ្នា បានផ្តើមពាក្យជាចន្លោះនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលណាមួយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិសុទ្ធ ពេញលេញអស់ ១២ ឆ្នាំ តើគួរនឹងហៅបុគ្គលនោះ ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំបានឬទេ បពិត្រព្រះអង្គដ៏ចម្រើន វេលានោះ ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានហាមឃាត់នូវភាសិតរបស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះឡើយ លុះមិនបានត្រេកអរ មិនបានហាមឃាត់ហើយ ក៏ក្រោកចាកអាសនៈ ដើរចេញទៅ ដោយមានបំណងថា អញនឹងយល់នូវសេចក្តីនៃភាសិតនុ៎ះ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះក្នុងធម្មវិន័យនេះ បុគ្គលអាចនឹងបញ្ញត្ត ( ខ្លួន ) ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំ ដោយគ្រាន់តែរាប់ឆ្នាំប៉ុណ្ណោះបានដែរឬ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលសារីបុត្ត ក្នុងធម្មវិន័យនេះ បុគ្គលមិនអាចនឹងបញ្ញត្ត ( ខ្លួន ) ថាជាភិក្ខុមិនមានអាយុ ១០ ដោយគ្រាន់តែរាប់ឆ្នាំប៉ុណ្ណោះបានឡើយ ។ ម្នាលសារីបុត្ត និទ្ទសវត្ថុ ៧ ប្រការនេះឯង តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសទុក ។ និទ្ទសវត្ថុ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការសមាទាននូវសិក្ខាតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការសមាទាន

នូវសិក្ខា ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការពិចារណានូវធម៌ តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការពិចារណានូវធម៌ ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការកម្ចាត់បង់នូវឥច្ឆា គឺតណ្ហា តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការកម្ចាត់បង់នូវឥច្ឆា ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការពួនសម្ងំ តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្តក្នុងការពួនសម្ងំ ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការប្រារព្ធព្យាយាម តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការប្រារព្ធព្យាយាម ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការតាំងស្មារតី និងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការតាំងស្មារតី និងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការចាក់ធ្លុះដោយទិដ្ឋិ គឺឃើញច្បាស់នូវមគ្គ តទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការចាក់ធ្លុះដោយទិដ្ឋិ ១ ។ ម្នាលសារីបុត្ត និទ្ទសវត្ថុ ៧ ប្រការនេះឯង ដែលតថាគតធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសទុក ។ ម្នាលសារីបុត្ត ភិក្ខុប្រកបដោយនិទ្ទសវត្ថុ ៧ ប្រការនេះ បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ ដ៏បរិសុទ្ធពេញលេញអស់ ១២ ឆ្នាំ ក៏គួរហៅថា ភិក្ខុមិនមានអាយុ ១២ ឆ្នាំបាន បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ពេញលេញអស់ ២៤ ឆ្នាំ ក៏គួរហៅថា ភិក្ខុ

មិនមានអាយុ ១០ ឆ្នាំបាន បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ពេញលេញអស់ ៣៦ ឆ្នាំ ក៏គួរហៅថា ភិក្ខុមិនមានអាយុ ១០ ឆ្នាំបាន បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ពេញលេញអស់ ៤៨ ឆ្នាំ ក៏គួរហៅថា ភិក្ខុមិនមានអាយុ ១០ ឆ្នាំបាន ។

# អដ្ឋកថា

## បឋមនិទ្ទសសូត្រ

[ ៣៩ ] ក្នុងបឋមនិទ្ទសសូត្រទី ១១ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមនិទ្ទសសូត្រទី ១១ ចប់

# សុត្តន្តបិដក

## ទុតិយនិទ្ទសសូត្រទី ១២

[ ៤០ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងកោសម្ពី ដើម្បីបិណ្ឌ-

បាត ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះថា ដំណើរ ត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងកោសម្ពី ព្រឹកណាស់នៅឡើយ បើដូច្នោះ អញគួរតៀងចូលទៅឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិ្ថិយសិន ។ ទើប ព្រះអានន្ទដ៏មានអាយុ ចូលទៅឯអារាមរបស់ពួកបរិព្វាជក ជាអន្យតិ្ថិយ លុះ ចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងពួកបរិព្វាជក ជាអន្យតិ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទី សមគួរ ។ ក៏ក្នុងសម័យនោះឯង ពួកបរិព្វាជកជាអន្យតិ្ថិយទាំងនោះ អង្គុយ ប្រជុំគ្នាហើយ បានផ្តើមសួរពាក្យជាចន្លោះនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលណាមួយ ប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ពេញលេញអស់ ១២ ឆ្នាំ តើគួរនឹងហៅ ( បុគ្គលនោះ ) ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំបានដែរឬ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មិនត្រេកអរ មិនហាមឃាត់នូវភាសិត របស់ពួកបរិព្វាជកជាអន្យតិ្ថិយទាំងនោះឡើយ ។ លុះមិនត្រេកអរ មិនហាម ឃាត់ហើយ ក្រោកចាកអាសនៈដើរចេញទៅ ដោយមានបំណងថា អញ គង់នឹងយល់នូវសេចក្តីនៃភាសិតនុ៎ះ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ ទើប ព្រះអានន្ទដ៏មានអាយុ ត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងកោសម្ពី លុះត្រឡប់ មកអំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយភត្ត ក៏ចូលទៅគាល់ព្រះដ៏មានព្រះ ភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទី សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ក៏បានក្រាប

បន្តិទូលនូវដំណើរនោះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហ-សម័យ ហើយចូលទៅកាន់ក្រុងកោសម្ពី ដើម្បីបិណ្ឌបាត បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា ដំណើរត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងកោសម្ពី ព្រឹកណាស់នៅឡើយ បើដូច្នោះ អញគួរចៀងចូលទៅឯអារាម របស់ពួកបរិព្វាជក ជាអន្យតិរ្ថិយសិន បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គបានចូលទៅ ឯអារាមរបស់បរិព្វាជក ជាអន្យតិរ្ថិយ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររព្ញកហើយ ក៏អង្គុយក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងសម័យនោះឯងពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ អង្គុយប្រជុំគ្នាហើយ បានផ្តើមនូវពាក្យជាចន្លោះនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គលណាមួយ ប្រព្រឹត្តព្រហ្ម-ចរិយធម៌បរិសុទ្ធ ពេញលេញអស់ ១២ ឆ្នាំ តើគួរនឹងហៅបុគ្គលនោះ ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំ បានដែរឬ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គមិនត្រេកអរ មិនហាមឃាត់នូវភាសិត របស់ពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះឡើយ លុះមិនត្រេកអរ មិនហាមឃាត់ ហើយក៏ក្រោកចាកអាសនៈដើរចេញទៅ ដោយមានបំណងថា អញគង់នឹងយល់នូវសេចក្តីនៃភាសិតនុ៎ះ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះ

ក្នុងធម្មវិន័យនេះ បុគ្គលអាចប្រើប្រាស់ ( ខ្លួន ) ថាជាភិក្ខុមិនមានអាយុ ១០ ឆ្នាំ ដោយគ្រាន់តែរាប់ឆ្នាំប៉ុណ្ណោះ បានដែរឬ ។ ព្រះដ៏មានព្រះភាគ ត្រាស់តបថា ម្នាលអានន្ទ ក្នុងធម្មវិន័យនេះ បុគ្គលមិនអាចនឹងប្រើប្រាស់ខ្លួន ថាជាភិក្ខុមិនមាន អាយុ ១០ ឆ្នាំ ដោយគ្រាន់តែរាប់ឆ្នាំប៉ុណ្ណោះបានឡើយ ។ ម្នាលអានន្ទ និទ្ទសវត្ថុ ៧ ប្រការនេះឯង តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ ឧត្តម ដោយខ្លួនឯង ហើយប្រកាសទុក ។ និទ្ទសវត្ថុ ៧ ប្រការ តើដូចម្តេច ខ្លះ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីជឿ ១ មាន សេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ មានការចេះដឹងច្រើន ១ ជា អ្នកប្រារព្ធសេចក្តីព្យាយាម ១ មានស្មារតី ១ មានប្រាជ្ញា ១ ។ ម្នាលអានន្ទ និទ្ទសវត្ថុ ៧ ប្រការនេះឯង ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា ដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសទុក ។ ម្នាលអានន្ទ ភិក្ខុប្រកបដោយ និទ្ទសវត្ថុ ៧ ប្រការនេះឯង បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ពេញ លេញអស់ ១២ ឆ្នាំ ក៏គួរហៅថា ភិក្ខុមិនមានអាយុ ១០ ឆ្នាំបាន បើទុកជា ប្រព្រឹត្តព្រហ្មចរិយធម៌ ដ៏បរិសុទ្ធពេញលេញអស់ ២៤ ឆ្នាំ ក៏គួរហៅថា ភិក្ខុ មិនមានអាយុ ១០ ឆ្នាំបាន បើទុកជាប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ពេញ លេញអស់ ៣៦ ឆ្នាំ ក៏គួរហៅថា ភិក្ខុមិនមានអាយុ ១០ ឆ្នាំបាន បើទុក ជាប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ពេញលេញអស់ ៤៨ ឆ្នាំ ក៏គួរហៅថា ភិក្ខុមិនមានអាយុ ១០ ឆ្នាំបាន ។

**ទេវតាវគ្គទី ៤ ចប់**

### ឧទ្ទាននៃទេវតាវគ្គនោះគឺ

និយាយពីភិក្ខុ មិនមានសេចក្តីប្រមាទ ១ ភិក្ខុមានសេចក្តីខ្លាចបាប ១ ភិក្ខុអ្នកប្រដៅងាយ ២ លើក សម្លាញ់ ២ លើក បដិសម្ភិទា ២ លើក ភិក្ខុលុះអំណាចចិត្ត ២ លើក និទ្ទសវត្ថុ ២ លើក ។

## អដ្ឋកថា

## ទុតិយនិទ្ទសសូត្រ

[ ៤០ ] ក្នុងទុតិយនិទ្ទសសូត្រទី ១២ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថាទុតិយនិទ្ទសសូត្រទី ១២ ចប់**

**ទេវតាវគ្គទី ៤ ចប់**

# សុត្តន្តបិដក

# មហាយញ្ញវគ្គ

## ចិត្តសូត្រទី ១

[ ៤១ ] ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដ្ឋិតិ ( ទីតាំងនៃវិញ្ញាណ ) នេះមាន ៧ ប្រការ ។ វិញ្ញាណដ្ឋិតិ ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សខ្លះ ទេវតាពួកខ្លះ និងវិនិបាតពួកខ្លះ នេះជាវិញ្ញាណដ្ឋិតិទី ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចទេវតាក្នុងពួកព្រហ្ម ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាវិញ្ញាណដ្ឋិតិទី ២ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជាវិញ្ញាណដ្ឋិតិទី ៣ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជាវិញ្ញាណដ្ឋិតិទី ៤ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយគិតថា អាកាសមិនមានទីបំផុត ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះវិនាសទៅនៃបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង នេះជាវិញ្ញាណដ្ឋិតិទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយគិតថា វិញ្ញាណមិនមានទីបំផុត នេះជា

វិញ្ញាណដ្ឋិតិទី ៦ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វកន្លងបង់នូវវិញ្ញាណ-ញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតន-ជ្ឈាន ដោយគិតថា វត្ថុតិចតួចមិនមាន នេះជាវិញ្ញាណដ្ឋិតិទី ៧ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដ្ឋិតិមាន ៧ យ៉ាង នេះឯង ។

# អដ្ឋកថា
# មហាយញ្ញវគ្គទី ៥

## ចិត្តសូត្រ

[ ៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចិត្តសូត្រទី ១ នៃមហាយញ្ញវគ្គទី ៥ ដូចតទៅនេះ បទថា **វិញ្ញាណដ្ឋិតិយោ** បានដល់ ទីតាំងនៃបដិសន្ធិវិញ្ញាណ ។ សព្ទថា **សេយ្យថាបិ** ជានិបាត ប្រើក្នុងអត្ថថា ជាឧបមា អធិប្បាយថា មនុស្សទាំងឡាយ ។ ពិតហើយ បណ្ដាមនុស្សទាំងឡាយ ដែលប្រមាណមិនបានក្នុងចក្រវាលដែលប្រមាណមិនបាន សូម្បី ២ នាក់ ឈ្មោះថា ដូចគ្នាដោយអំណាចពណ៌សម្បុរ និងទ្រង់ទ្រាយជាដើមមិនមាន ។ មនុស្សទាំងឡាយណា ជាបងប្អូនភ្លោះក្នុងទីណាមួយ រមែងដូចគ្នាដោយពណ៌ និងទ្រង់ទ្រាយ មនុស្សទាំងនោះ ប្លែកគ្នាត្រង់មើលទៅមុខ ក្រឡេកឆ្វេងស្ដាំ សើចដើរ និងឈរជាដើមនោះឯង ព្រោះដូច្នោះ ទើបត្រាស់ថា **នានត្តកាយា** មានកាយផ្សេងគ្នា ។ ឯបដិសន្ធិសញ្ញារបស់សត្វទាំងនោះ ជាត្រៃហេតុកៈក៏មាន ជាទុហេតុកៈក៏មាន ជាអហេតុកៈក៏មាន ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **នានត្តសញ្ញិនោ** គឺមានសញ្ញាផ្សេងគ្នា ។ បទថា **ឯកច្ចេ ច ទេវា** បានដល់ ទេវតាជាន់កាមាវចរ ៦ ជាន់ ។ ពិតហើយ បណ្ដាទេវតាជាន់កាមាវចរ ៦ ជាន់នោះ ទេវតាពួកខ្លះ មានកាយពណ៌ខៀវ ពួកទេវតាពួកខ្លះមានកាយពណ៌លឿងជាដើម ឯសញ្ញារបស់ទេវតាទាំងនោះ ជាទុហេតុកៈ

ក៏មាន តិហេតុកៈក៏មាន ដែលជាអហេតុកៈមិនមាន ។ បទថា **ឯកច្ចេ ច វិនិបាតិកា** សេចក្តីថា សត្វដែលផុតចាកអបាយ ៤ មានយ៉ាងនេះ គឺឧត្តរាមាតាយក្ខិនី បិយង្ករមាតាយក្ខិនី ផុស្សមិត្តាយក្ខិនី ធម្មគុត្តាយក្ខិនី និងវេមានិកប្រេតពួកដទៃ ។ សត្វទាំងនោះ មានកាយផ្សេងគ្នាដោយពណ៌សម្បុរ មានពណ៌សម្បុរលឿង ពណ៌សម្បុរស ពណ៌សម្បុរខ្មៅ និងពណ៌សម្បុរស្រគាំជាដើម និងដោយការស្គម ការធាត់ ការទាប និងការខ្ពស់ ។ សញ្ញាក៏ផ្សេងគ្នា ដោយជាទុហេតុកៈ តិហេតុកៈ និងអហេតុកៈ តែសត្វទាំងនោះមិនមានអំណាចច្រើនដូចទេវតា មានអំណាចតិច មានអាហារ និងគ្រឿងស្លៀកដណ្តប់រកបានដោយក្រ នៅជាទុក្ខ ដូចមនុស្សក្រីក្រពួកខ្លះ ត្រូវសេចក្តីទុក្ខខាងរនោច មានសេចក្តីសុខខាងខ្នើត ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា **វិនិបាតិកា** ព្រោះធ្លាក់ទៅអំពីគំនរនៃសេចក្តីសុខ ចំណែកសត្វទាំងនោះ សត្វពួកណាជាត្រៃហេតុកៈ សត្វទាំងនោះ ត្រាស់ដឹងធម៌ក៏មាន ដូចគ្នានឹងបិយង្ករមាតាយក្ខិនីជាដើម ។

បទថា **ព្រហ្មកាយិកា** បានដល់ ព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតា មហាព្រហ្មា ។ បទថា **បឋមាភិនិព្វត្តា** បានដល់ សត្វទាំងអស់នោះ កើតឡើងដោយបឋមជ្ឈាន ។ ចំណែកព្រហ្មបារិសជ្ជាកើតឡើងដោយបឋមជ្ឈានយ៉ាងទន់ ព្រហ្មបារិសជ្ជាទាំងនោះ មានអាយុប្រមាណប៉ុនគ្នានឹងចំណែកទី ៣ នៃកប្ប ព្រហ្មបុរោហិតា កើតឡើងដោយបឋមជ្ឈានជាកណ្តាល មានអាយុ

ប្រមាណកន្លះកប្ប ទើបព្រហ្មទាំងនោះ មានកាយតូចធំជាងគ្នា មហាព្រហ្ម កើតឡើងដោយបឋមជ្ឈានដ៏ប្រណីត មានអាយុប្រមាណ ១ កប្ប តែមហាព្រហ្មទាំងនោះ មានកាយធំក្រៃលែង ដូច្នោះ ព្រហ្មទាំងនោះ គប្បីជ្រាបថា **នានត្តកាយាឯកត្តសញ្ញិនោ** ព្រោះមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដោយអំណាចបឋមជ្ឈាន ។ សត្វក្នុងអបាយ ៤ ក៏ដូចគ្នានឹងព្រហ្មទាំងនោះ ។ ពិតហើយ ក្នុងនរកទាំងឡាយ សត្វពួកខ្លះ មានអត្តភាពមួយគាវុត ពួកខ្លះ កន្លះយោជន៍ ពួកខ្លះ មួយយោជន៍ តែរាងកាយរបស់ទេវទត្ត ១០០ យោជន៍ ក្នុងបណ្តាសត្វតិរច្ឆាន ពួកខ្លះតូច ពួកខ្លះធំ ក្នុងបេតវិស័យ ពួកខ្លះ ៦០ហត្ថ ពួកខ្លះ ៨០ ហត្ថ ពួកខ្លះមានពណ៌សម្បុរល្អ ពួកខ្លះមានពណ៌សម្បុរអាក្រក់ ពួកកាឡកញ្ជិកាសុរក៏ដូចគ្នា ។ ម្យ៉ាងទៀត ក្នុងពួកអសុរទាំងនោះ ឈ្មោះថា ទីឃបិដ្ឋិកាសុរ កម្ពស់ ៦០ យោជន៍ ឯសញ្ញារបស់អសុរទាំងអស់ ជាអកុសលវិបាកអហេតុកៈ ។ ដូច្នេះ សត្វដែលកើតក្នុងអបាយ រមែងរាប់ថា មានកាយផ្សេងគ្នា មានសញ្ញាតែមួយ ។

បទថា **អាភស្សរា** សេចក្តីថា ព្រហ្ម ឈ្មោះថា អាភស្សរា ព្រោះព្រហ្មទាំងនេះមានរស្មីផ្សាយចេញ គឺផ្សាយចេញទៅអំពីសរីរៈ ដូចដាច់ធ្លាក់ចុះ ដូចអណ្តាតភ្លើងនៃគប់ភ្លើង ដូច្នោះ បណ្តាអាភស្សរព្រហ្មទាំងនោះ ព្រហ្មដែលចម្រើនទុតិយជ្ឈាន និងតតិយជ្ឈានទាំង ២ យ៉ាងទន់ ក្នុងបញ្ចកន័យ កើតឡើង ឈ្មោះថា បរិត្តាភាព្រហ្ម ។ បរិត្តាភាព្រហ្មទាំងនោះ មានអាយុ

ប្រមាណ ២ កប្ប ដែលចម្រើនទុតិយជ្ឈាន តតិយជ្ឈានយ៉ាងកណ្តាលកើតឡើង ឈ្មោះថា អប្បមាណាភាព្រហ្ម ។ អប្បមាណាភាព្រហ្មទាំងនោះមានអាយុប្រមាណ ៤ កប្ប ដែលចម្រើនទុតិយជ្ឈាន តតិយជ្ឈានយ៉ាងប្រណីតកើតឡើង ឈ្មោះថា អាភស្សរាព្រហ្ម ។ អាភស្សរាព្រហ្មទាំងនោះ មានអាយុប្រមាណ ៨ កប្ប ក្នុងទីនេះ ទ្រង់កាន់យកព្រហ្មទាំងអស់នោះដោយការកំណត់យ៉ាងឧក្រិដ្ឋ តាមពិត ព្រហ្មទាំងនោះ មានកាយធំដូចគ្នា ចំណែកសញ្ញាផ្សេងៗ គ្នា មិនមានវិតក្ក មានត្រឹមវិចារៈខ្លះ មិនមានវិតក្កវិចារៈខ្លះ ។

បទថា **សុភកិណ្ហា** សេចក្តីថា ព្រហ្មទាំងឡាយមានរស្មីអំពីសរីរៈធៀលច្បាត់ដោយលម្អ រស្មីនៃសរីរៈរុងរឿង អធិប្បាយថា ក្រាស់ទៅដោយការស្អាត ។ ពិតហើយ សុភកិណ្ហាព្រហ្មទាំងនោះ រស្មីមិនដាច់ ដូចអាភស្សរព្រហ្មឡើយ ។ តែក្នុងបញ្ចកន័យ ពួកព្រហ្មដែលកើតឡើង ឈ្មោះថា បរិត្តសុភាព្រហ្ម អប្បមាណាសុភាព្រហ្ម និងសុភកិណ្ហាព្រហ្ម មានអាយុ ១៦ កប្ប ៣២ កប្ប និង ៦៤ កប្ប ដោយអំណាចចតុត្ថជ្ឈានយ៉ាងទន់ កណ្តាល និងប្រណីត ដូច្នោះ ព្រហ្មទាំងនោះ គប្បីជ្រាបថា មានកាយតែមួយ និងសញ្ញាតែមួយ ដោយសញ្ញាក្នុងចតុត្ថជ្ឈាន ។

ចំណែកវេហប្ផលាព្រហ្ម ក៏រមែងប្រៀបធៀបវិញ្ញាណដ្ឋិតិទី ៤ ប៉ុណ្ណោះ ពួកអសញ្ញីសត្វ ឬវិញ្ញាណាភាព្រហ្ម រមែងមិនសង្គ្រោះចូលក្នុងសេចក្តីនេះ តែសង្គ្រោះចូលក្នុងសត្តាវាសទាំងឡាយ សុទ្ធាវាសព្រហ្មតាំងនៅក្នុងចំណែក

វិវដ្ដៈ រមែងមិនមានសព្វកាល គឺមិនកើតឡើងក្នុងលោក ដែលមិនមានព្រះពុទ្ធត្រាស់អស់សែនកប្បខ្លះ មួយអសង្ខេយ្យកប្បខ្លះ ។ កាលព្រះពុទ្ធទាំង-ឡាយទ្រង់កើតឡើងហើយនោះឯង រមែងកើតឡើងខាងក្នុងខេត្តកំណត់អាយុ ១៦០០០ កប្ប ហាក់ដូចជាព្រះពន្លាសម្រាករបស់ព្រះមានព្រះភាគ ដែលជាធម្មចក្រពត្តិ ព្រោះហេតុនោះ ទើបមិនប្រៀបធៀបវិញ្ញាណដ្ឋិតិ និងសត្តាវាស ឯព្រះមហាសិវត្ថេរពោលថា ព្រហ្មជាន់សុទ្ធាវាសរមែងប្រៀបធៀបនឹងវិញ្ញា-ណដ្ឋិតិទី ៤ និងសត្តាវាសទី ៤ ដោយសូត្រនេះថា ម្នាលសារីបុត្ត អាវាសណាដែលតថាគតមិនធ្លាប់នៅហើយ ដោយកាលវែងនេះ វៀរលែងតែសុទ្ធាវាសទេវលោកទាំងឡាយចេញ អាវាសនុ៎ះឯង បុគ្គលមិនងាយរកបានទេ ម្នាលសារីបុត្ត ព្រោះថា បើតថាគតនៅក្នុងសុទ្ធាវាសទេវលោក តថាគតមិនបានមកកាន់កាមលោកនេះទៀតទេ ។ ពាក្យនោះ លោកអនុញ្ញាតហើយ ព្រោះមិនមានព្រះសូត្រហាម ។ នេវសញ្ញានាសញ្ញាយតនជ្ឈាន ឈ្មោះថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ព្រោះវិញ្ញាណជារបស់ល្អិតដូចសញ្ញាដូច្នោះ ព្រោះហេតុនោះ នេវសញ្ញានាសញ្ញាយតនជ្ឈាននោះ ទើបលោកមិនពោលក្នុងវិញ្ញាណដ្ឋិតិទាំងឡាយ ៕

## អដ្ឋកថាចិត្តសូត្រទី ១ ចប់

# សុត្តន្តបិដក

## បរិក្ខារសូត្រទី ២

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ សមាធិបរិក្ខារ ( អង្គរបស់សមាធិ ) នេះមាន ៧ ប្រការ ។ សមាធិបរិក្ខារ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មា-វាយាមៈ ១ សម្មាសតិ ១ ។ ម្នាលភិក្ខុទាំងឡាយ ភាពនៃចិត្ត ដែលមានអារម្មណ៍មូលតែមួយឯណា ដែលអង្គទាំង ៧ ប្រការនេះ ចោមរោមហើយ ម្នាលភិក្ខុទាំងឡាយ ភាពនៃចិត្ត ដែលមានអារម្មណ៍មូលតែមួយនេះ ហៅថាអរិយសមាធិ មានឧបនិស្ស័យដូច្នេះខ្លះ មានបរិក្ខារដូច្នេះខ្លះ ។

# អដ្ឋកថា

## បរិក្ខារសូត្រ

[ ៤២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិក្ខារសូត្រទី ២ ដូចតទៅនេះ បទថា **សមាធិបរិក្ខារា** បានដល់ អង្គប្រកបនៃសមាធិដែលសម្បយុត្តដោយមគ្គ ៕

### អដ្ឋកថាបរិក្ខារសូត្រទី ២ ចប់

# សុត្តន្តបិដក

## បឋមអគ្គិសូត្រទី ៣

*[ ៤៣ ] ម្នាលភិក្ខុទាំងឡាយ ភ្លើងនេះមាន ៧ ប្រការ ។ ភ្លើង ៧ ប្រការ តើដូចម្តេចខ្លះ ។ ភ្លើង គឺរាគៈ ១ ភ្លើង គឺទោសៈ ១ ភ្លើង គឺមោហៈ ១ ភ្លើង គឺអាហុនេយ្យបុគ្គល ១ ភ្លើង គឺបុគ្គលជាម្ចាស់ផ្ទះ ១ ភ្លើង គឺទក្ខិណេយ្យបុគ្គល ១ ភ្លើងឧស ១ ។ ម្នាលភិក្ខុទាំងឡាយ ភ្លើងមាន ៧ ប្រការនេះឯង ។*

# អដ្ឋកថា

## បឋមអគ្គិសូត្រ

*[ ៤៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអគ្គិសូត្រទី ៣ ដូចតទៅនេះ កិលេសទាំងឡាយ មានរាគៈជាដើម ឈ្មោះថា* **អគ្គី** *ព្រោះអត្ថថា តាមដុត ឯបទថា* **អាហុនេយ្យគ្គិ** *ជាដើមនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ*

*សក្ការៈ លោកហៅថា* **អាហុន** *ជនទាំងឡាយណា គួរដល់អាហុនៈ ហេតុនោះ ជននោះ ឈ្មោះថា* **អាហុនេយ្យា** *គឺជនគួរដល់អាហុនៈ ។ ពិតហើយ មាតា និងបិតាទាំងឡាយ រមែងគួរដល់អាហុនៈ ព្រោះលោកទាំង ២ ជាអ្នកមានឧបការៈច្រើនដល់បុត្រទាំងឡាយ បុត្រទាំងឡាយដែលបដិបត្តិខុស*

ក្នុងមាតា និងបិតាទាំង ២ នោះ រមែងកើតក្នុងអបាយ មាននរកជាដើម ព្រោះហេតុនោះ សូម្បីមាតា និងបិតា ទោះមិនបានតាមដុតក៏ពិត តែលោកទាំង ២ គង់ជាបច្ច័យដល់ការតាមដុត ដូច្នោះ លោកហៅមាតាបិតាថា **អាហុនេយ្យគ្គិ** ព្រោះអត្ថថា តាមដុតនោះឯង ។ អ្នកជាធំក្នុងផ្ទះ លោកហៅថា **គហបតិ** ពិតហើយ គហបតីនោះមានឧបការៈច្រើនដល់មាតុគ្រាម ដោយការប្រគល់ឲ្យនូវទីដេក សំពត់ និងគ្រឿងប្រដាប់ជាដើម មាតុគ្រាមដែលប្រព្រឹត្តក្រៅចិត្តប្តីនោះ រមែងកើតក្នុងអបាយ មាននរកជាដើម ព្រោះហេតុនោះ ស្វាមីនោះ លោកក៏ហៅថា **គហបតគ្គិ** ព្រោះអត្ថថា តាមដុតដោយន័យមុននោះឯង ។ ឯក្នុងពាក្យថា **ទក្ខិណេយ្យគ្គិ** នេះ មានវិនិច្ឆ័យដូចតទៅនេះ បច្ច័យ ៤ ឈ្មោះថា **ទក្ខិណា** ភិក្ខុសង្ឃ ឈ្មោះថា **ទក្ខិណេយ្យបុគ្គល** គឺបុគ្គលគួរដល់ទក្ខិណា ។ ពិតហើយ ភិក្ខុសង្ឃនោះ រមែងជាអ្នកមានឧបការៈច្រើនដល់គ្រហស្ថទាំងឡាយ ដោយការប្រកបទុកក្នុងកល្យាណធម៌ទាំងឡាយ មានសរណៈ ៣ សីល ៥ សីល ១០ ការទំនុកបម្រុងមាតានិងបិតា ការទំនុកបម្រុងសមណៈ និងព្រាហ្មណ៍ ដែលតាំងនៅក្នុងធម៌ជាដើម គ្រហស្ថដែលបដិបត្តិខុសក្នុងភិក្ខុសង្ឃនោះ មានជេរបរិភាសភិក្ខុសង្ឃ រមែងកើតក្នុងអបាយទាំងឡាយ មាននរកជាដើម ព្រោះហេតុនោះ ភិក្ខុសង្ឃនោះ លោកហៅថា **ទក្ខិណេយ្យគ្គិ** ភ្លើង គឺទក្ខិណេយ្យបុគ្គល ព្រោះអត្ថថា តាមដុតដោយន័យមុននោះឯង ។ ភ្លើងតាមប្រក្រតីដែលកើតអំពីឧស ឈ្មោះថា

កដ្ឋគ្គិ គឺភ្លើងកើតអំពីឈើ ៗ។

## អដ្ឋកថា បឋមអគ្គិសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ទុតិយអគ្គិសូត្រទី ៤

[ ៤៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ឧគ្គតសរីរ-ព្រាហ្មណ៍ ប្រុងទុកមហាយញ្ញ គឺចងក្រៀកគោបា ៥០០ នឹងឈើសទ្ទង់ ដើម្បីសម្លាប់បូជា ចងក្រៀកកូនគោឈ្មោល ៥០០ នឹងឈើសទ្ទង់ ដើម្បីសម្លាប់បូជា ចងក្រៀកកូនគោញី ៥០០ នឹងឈើសទ្ទង់ ដើម្បីសម្លាប់បូជា ចងក្រៀកពពែ ៥០០ នឹងឈើសទ្ទង់ ដើម្បីសម្លាប់បូជា ចងក្រៀកកែះ ៥០០ នឹងឈើសទ្ទង់ ដើម្បីសម្លាប់បូជា ។ វេលានោះ ឧគ្គតសរីរព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹង ព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររឭក ហើយ អង្គុយក្នុងទីសមគួរ ។ លុះឧគ្គតសរីរព្រាហ្មណ៍ អង្គុយក្នុងទីសមគួរ ហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន

ខ្ញុំព្រះអង្គបានឮថា ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ( ដើម្បីបូជាយញ្ញ ) ជាកិច្ចមានផលច្រើន មានអានិសង្សច្រើន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ដំណើរនោះតថាគតក៏បានឮថា ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូងជាកិច្ចមានផលច្រើន មានអានិសង្សច្រើនដែរ ។ ជាគម្រប់ពីរដង ។បេ។ ឧគ្គតសរីរព្រាហ្មណ៍ ក៏បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ជាគម្រប់បីដងដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮថា ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ជាកិច្ចមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលព្រាហ្មណ៍ ដំណើរនុ៎ះ តថាគតក៏បានឮថា ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ជាកិច្ចមានផលច្រើន មានអានិសង្សច្រើនដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ដំណឹងទាំងអស់ណា ដែលព្រះគោតមដ៏ចម្រើនឮហើយក្តី ដែលខ្ញុំព្រះអង្គឮហើយក្តី ដំណឹងនោះត្រូវគ្នា ( តែបែបមួយ ) ។ កាលបើឧគ្គតសរីរព្រាហ្មណ៍និយាយយ៉ាងនេះហើយ ទើបព្រះអានន្ទដ៏មានអាយុ រំលឹកឧគ្គតសរីរព្រាហ្មណ៍ដូច្នេះ ម្នាលព្រាហ្មណ៍ ព្រះតថាគតទាំងឡាយ បុគ្គលមិនគប្បីសួរថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮមកថា ការតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ជាកិច្ចមានផលច្រើន មានអានិសង្សច្រើនយ៉ាងនេះឡើយ ម្នាលព្រាហ្មណ៍ ព្រះតថាគតទាំងឡាយ បុគ្គលគប្បីសួរយ៉ាងនេះវិញថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានប្រាថ្នានឹងតាំងទុកនូវភ្លើង មានប្រាថ្នាលើក

ឡើងនូវឈើសន្ទុង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទូន្មានខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគប្រៀនប្រដៅខ្ញុំព្រះអង្គ ដោយពាក្យដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គ អស់កាលយូរអង្វែង ។ លំដាប់នោះ ឧគ្គតសរីរព្រាហ្មណ៍ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមានប្រាថ្នានឹងតាំងទុកនូវភ្លើង មានប្រាថ្នានឹងលើកឡើងនូវឈើសន្ទុង សូមព្រះគោតមដ៏ចម្រើនទូន្មានខ្ញុំព្រះអង្គ សូមព្រះគោតមដ៏ចម្រើន ប្រៀនប្រដៅខ្ញុំព្រះអង្គ ដោយពាក្យដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គអស់កាលយូរអង្វែង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុងក្នុងវិធីបូជាជាដំបូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រា ៣ យ៉ាង ដែលជាអកុសល មានតែចម្រើនសេចក្តីទុក្ខ មានទុក្ខជាផល ។ គ្រឿងសស្ត្រា ៣ យ៉ាង តើដូចម្តេចខ្លះ ។ គ្រឿងសស្ត្រា គឺកាយ ១ គ្រឿងសស្ត្រា គឺវាចា ១ គ្រឿងសស្ត្រា គឺចិត្ត ១ ។ ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុង ក្នុងវិធីបូជាជាដំបូងនុ៎ះឯង រមែងញ៉ាំងចិត្តឲ្យកើតឡើងយ៉ាងនេះថា ជនទាំងឡាយ ចូរសម្លាប់គោបាប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់កូនគោឈ្មោលប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់កូនគោញីប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់ពពែប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់សត្វកែះប៉ុណ្ណោះដើម្បីបូជា បុគ្គល

នោះធ្វើបាប ដោយសម្គាល់ថា អញធ្វើបុណ្យ ធ្វើអំពើអកុសល ដោយសម្គាល់ថា អញធ្វើអំពើកុសល ស្វែងរកផ្លូវទុគ្គតិដោយសម្គាល់ថា អញស្វែងរកផ្លូវសុគតិ ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូងក្នុងវិធី បូជាយញ្ញជាដំបូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រា គឺចិត្តដែលជាអកុសល មានតែចម្រើនសេចក្តីទុក្ខ មានទុក្ខជាផល នេះជាគ្រឿងសស្ត្រាទី ១ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ក្នុងវិធីបូជាជាដំបូងនុ៎ះឯង រមែងពោលនូវវាចាយ៉ាងនេះថា ជនទាំងឡាយ ចូរសម្លាប់គោបាប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់កូនគោឈ្មោលប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់កូនគោញីប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់ពពែប៉ុណ្ណោះដើម្បីបូជា ចូរសម្លាប់សត្វកែះប៉ុណ្ណោះដើម្បីបូជា បុគ្គលនោះធ្វើបាប ដោយសម្គាល់ថា អញធ្វើបុណ្យ ធ្វើអំពើអកុសលដោយសម្គាល់ថា អញធ្វើអំពើជាកុសល ស្វែងរកផ្លូវទុគ្គតិដោយសម្គាល់ថា អញស្វែងរកផ្លូវសុគតិ ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូងក្នុងវិធី បូជាជាដំបូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រា គឺវាចាដែលជាអកុសល មានតែចម្រើនសេចក្តីទុក្ខ មានទុក្ខជាផល នេះជាគ្រឿងសស្ត្រាទី ២ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទូង ក្នុងវិធីបូជាជាដំបូងនុ៎ះឯង រមែងប្រុងប្រៀបខ្លួនឯងជាមុនថា ជនទាំងឡាយ ចូរសម្លាប់គោបាដើម្បីបូជា ប្រុងប្រៀបខ្លួន

ឯងជាមុនថា ជនទាំងឡាយ ចូរសម្លាប់កូនគោឈ្មោលដើម្បីបូជា ប្រុងប្រៀបខ្លួនឯងជាមុនថា ជនទាំងឡាយ ចូរសម្លាប់កូនគោញីដើម្បីបូជា ប្រុងប្រៀបខ្លួនឯងជាមុនថា ជនទាំងឡាយ ចូរសម្លាប់ពពែដើម្បីបូជា ប្រុងប្រៀបខ្លួនឯងជាមុនថា ជនទាំងឡាយ ចូរសម្លាប់សត្វកែះដើម្បីបូជា បុគ្គលនោះធ្វើបាបដោយសម្គាល់ថា អញធ្វើបុណ្យ ធ្វើអំពើអកុសលដោយសម្គាល់ថា អញធ្វើអំពើកុសល ស្វែងរកផ្លូវទុគ្គតិដោយសម្គាល់ថា អញស្វែងរកផ្លូវសុគតិ ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុងក្នុងវិធីបូជា ជាដំបូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រា គឺកាយដែលជាអកុសល មានតែចម្រើនដោយសេចក្តីទុក្ខ មានទុក្ខជាផល នេះជាគ្រឿងសស្ត្រាទី ៣ ។ ម្នាលព្រាហ្មណ៍ បុគ្គលកាលតាំងទុកនូវភ្លើង លើកឡើងនូវឈើសន្ទុង ក្នុងវិធីបូជា ជាដំបូងនុ៎ះឯង រមែងលើកឡើងនូវគ្រឿងសស្ត្រា ៣ ប្រការនេះ ដែលជាអកុសល មានតែចម្រើនដោយសេចក្តីទុក្ខ មានទុក្ខជាផល ។ ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ភ្លើង ៣ ប្រការ តើដូចម្តេចខ្លះ ។ ភ្លើង គឺរាគៈ ១ ភ្លើង គឺទោសៈ ១ ភ្លើង គឺមោហៈ ១ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើង គឺរាគៈនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលជារាគចរិត ត្រូវរាគៈគ្របសង្កត់រួបរឹតចិត្តហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិត

ដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនោះ ភ្លើង គឺរាគៈនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើង គឺទោសៈនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលជាទោសចរិត ត្រូវទោសៈគ្របសង្កត់រួបរឹតចិត្តហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនោះ ភ្លើងគឺទោសៈនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើង គឺមោហៈនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលជាមោហចរិត ត្រូវមោហៈគ្របសង្កត់រួបរឹតចិត្តហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុនោះ

ភ្លើង គឺមោហៈនេះ បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ម្នាលព្រាហ្មណ៍ ភ្លើងទាំង ៣ ប្រការនេះឯង បុគ្គលគួរលះបង់ចេញ គួរចៀសវាងចេញ មិនគួរសេពគប់ឡើយ ។ ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះ បុគ្គលគួរធ្វើសក្ការៈ គោរពរាប់អាន បូជារក្សា បម្រើឲ្យល្អដោយប្រពៃ ។ ភ្លើង ៣ ប្រការ តើដូចម្តេចខ្លះ ។ ភ្លើង គឺអាហុនេយ្យបុគ្គល ១ ភ្លើង គឺបុគ្គលជាម្ចាស់ផ្ទះ ១ ភ្លើង គឺទក្ខិណេយ្យបុគ្គល ១ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើង គឺអាហុនេយ្យបុគ្គល តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ ជនទាំងឡាយនោះ ត្រូវជាមាតា ឬបិតារបស់បុគ្គលណា ក្នុងលោកនេះ ម្នាលព្រាហ្មណ៍ នេះហៅថា ភ្លើង គឺអាហុនេយ្យបុគ្គល (របស់បុគ្គលនោះ) ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលនោះ ដែលបានកើតមកដោយសារមាតាបិតានោះ ហេតុនោះ ភ្លើង គឺអាហុនេយ្យបុគ្គលនេះ បុគ្គលគួរធ្វើសក្ការៈគោរពរាប់អានបូជារក្សា បម្រើឲ្យល្អដោយប្រពៃ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើង គឺបុគ្គលជាម្ចាស់ផ្ទះ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ ជនទាំងឡាយនោះ ត្រូវជាកូន ឬប្រពន្ធ ឬខ្ញុំ ឬក៏អ្នកបម្រើរបស់បុគ្គលណា ក្នុងលោកនេះ ម្នាលព្រាហ្មណ៍ នេះហៅថា ភ្លើង គឺបុគ្គលជាម្ចាស់ផ្ទះរបស់បុគ្គលនោះ ព្រោះហេតុនោះ ភ្លើង គឺបុគ្គលម្ចាស់ផ្ទះ បុគ្គលគួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើ ឲ្យល្អ ដោយប្រពៃ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើង គឺទក្ខិនេយ្យបុគ្គល តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ សមណៈ ឬព្រាហ្មណ៍ណា ក្នុងលោកនេះ ជា

អ្នកវៀរស្រឡះ ចាកសេចក្តីស្រវឹង និងសេចក្តីប្រមាទ ឋិតនៅក្នុងខន្តិ និង សោរច្ចៈ ទូន្មាននូវចិត្តមួយ រម្ងាប់នូវចិត្តមួយ រម្ងត់នូវចិត្តមួយ ម្នាល ព្រាហ្មណ៍ នេះហៅថា ភ្លើង គឺទក្ខិណេយ្យបុគ្គល ព្រោះហេតុនោះ ភ្លើង គឺទក្ខិណេយ្យបុគ្គលនេះ បុគ្គលគួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើ ឲ្យល្អដោយប្រពៃ ។ ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះឯង បុគ្គល គួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើឲ្យល្អ ដោយប្រពៃ ។ ម្នាលព្រាហ្មណ៍ ចំណែកឯភ្លើងឧសនេះសោត បុគ្គលក៏គួរដុតតាមកាលគួរ បន្ទន់មើលតាមកាលគួរ គួរលត់តាមកាលគួរ គួរទុកដាក់តាមកាលគួរ ។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ឧគ្គតសរីរព្រាហ្មណ៍ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺ ច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជា ឧបាសកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះទៅ បពិត្រ ព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គនុ៎ះ នឹងលែងគោបា ៥០០ ឲ្យជីវិត នឹងលែង កូនគោឈ្មោល ៥០០ ឲ្យជីវិត នឹងលែងកូនគោញី ៥០០ ឲ្យជីវិត នឹង លែងពពែ ៥០០ ឲ្យជីវិត នឹងលែងសត្វកែះ ៥០០ ឲ្យជីវិត ចូរសត្វទាំង នោះទំពាស៊ីស្មៅខ្ចីផង ផឹកទឹកត្រជាក់ផង ទាំងខ្យល់ដ៏ត្រជាក់ ចូរបក់ផ្សាយ ដល់ពួកសត្វទាំងនោះចុះ ។

# អដ្ឋកថា

## ទុតិយអគ្គិសូត្រ

[ ៤៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអគ្គិសូត្រទី ៤ ដូចតទៅនេះ បទថា **ឧគ្គតសរីរស្ស** សេចក្តីថា បានឮថា ព្រាហ្មណមហាសាលនោះ ជាបុគ្គលខ្ពស់ដោយអត្តភាព ដល់នូវសារសម្បត្តិដោយភោគៈ ព្រោះហេតុនោះ ទើបប្រាកដឈ្មោះថា ព្រាហ្មណ៍ជាអ្នកមានខ្លួនខ្ពស់ ។ បទថា **ឧបក្ខដោ** បានដល់ ប្រុងប្រៀប ។ បទថា **ថូណូបនីតានិ** បានដល់ នាំចូលទៅកាន់សសរសន្ទូង ពោល គឺបង្គោលសម្រាប់បូជាយញ្ញ ។ បទថា **យញ្ញត្ថាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការសម្លាប់បូជាយញ្ញ ។ បទថា **ឧបសង្កមិ** សេចក្តីថា បានឮថា ព្រាហ្មណ៍នោះ ត្រៀមគ្រឿងប្រកបយញ្ញទាំងអស់នោះហើយ គិតថា បានឮថា ព្រះសមណគោតម ជាអ្នកមានបញ្ញាច្រើន ទ្រង់នឹងត្រាស់សរសើរយញ្ញរបស់អាត្មាអញឬហ្ន៎ ឬត្រាស់តិះដៀល អញនឹងទូលសួរ ទើបដឹងដោយហេតុនេះ ទើបចូលទៅគាល់ព្រះមានព្រះភាគ ។ បទថា **អគ្គិស្ស អាធានំ** សេចក្តីថា ការបង្កាត់ភ្លើងដែលជាមង្គល ៩ ប្រការ ដើម្បីបូជាយញ្ញ ។ ដោយបទថា **សុតៗ សុតំ** នេះ ឧគ្គតសរីរ-ព្រាហ្មណ៍សម្តែងថា សូត្រទាំងអស់ដែលខ្ញុំស្តាប់មកហើយ រមែងប្រៀបធៀបគ្នាបាន រមែងតែមួយ ដូចគ្នានឹងសូត្រទាំងអស់ ។

បទថា **សត្ថានិ** សេចក្តីថា ដែលឈ្មោះថា សស្ត្រា ព្រោះដូចជាសស្ត្រា ព្រោះអត្ថថា ជាគ្រឿងបៀតបៀន ។

*បទថា* **សយំ បឋមំ សមារភតិ** *សេចក្តីថា ផ្តើមដោយខ្លួនឯង មុននោះឯង ។ បទថា* **ហញ្ញន្តុ** *ប្រែថា ចូរសម្លាប់ ។ បទថា* **បរិហាតព្វោ** *ប្រែថា គប្បីបរិហារ ។ បទថា* **ឥតោ ហាយំ** *កាត់បទជា* **ឥតោ ហិ មាតាបិតិតោ អយំ** *ប្រែថា បុគ្គលនេះជាចំណែកមាតា និងបិតា ។ បទថា* **អាហុតោ** *ប្រែថា មកហើយ ។ បទថា* **សម្ភូតោ** *ប្រែថា កើតឡើងហើយ ។ បទថា* **អយំ វុច្ចតិ ព្រាហ្មណ គហបតគ្គិ** *សេចក្តីថា ពួកកូន និងភរិយាជាដើម លោកហៅថា* **គហបតគ្គិ** *ព្រោះដូចជាគហបតី ដូចជាម្ចាស់ផ្ទះ ត្រាច់ទៅ ។ បទថា* **អត្ថានំ** *បានដល់ ចិត្ត ។ បទថា* **ទមេន្តិ** *បានដល់ រមែងទូន្មានដោយការទូន្មានឥន្ទ្រិយ ។ បទថា* **សមេន្តិ** *បានដល់ ស្ងប់ដោយការស្ងប់រាគៈជាដើម អធិប្បាយថា រមែងរម្ងាប់កិលេស ដោយការឲ្យកិលេស មានរាគៈជាដើមរលត់អស់ទៅ ។ បទថា* **និក្ខិបិតព្វោ** *សេចក្តីថា គប្បីទុកដោយប្រការដែលមិនវិនាស ។ បទថា* **ឧបវាយតំ** *សេចក្តីថា ចូរផ្សាយខ្វះខ្វាយទៅ ។ ឯព្រាហ្មណ៍កាលពោលយ៉ាងនោះហើយ ទើបឲ្យជីវិតដល់សត្វទាំងឡាយនោះ ហើយទម្លាយរោងយញ្ញ ដូចអណ្តូងទឹក ( ហើយតាំងនៅ ) ក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះ ។៚

**អដ្ឋកថា ទុតិយអគ្គិសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមសញ្ញាសូត្រទី ៥

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ សញ្ញា ( សេចក្តីសម្គាល់ ) នេះមាន ៧ ប្រការ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត សេចក្តីសម្គាល់ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីសម្គាល់ថា មិនស្អាត ១ សេចក្តីសម្គាល់ក្នុងការស្លាប់ ១ សេចក្តីសម្គាល់ក្នុងអាហារ ថាជារបស់គួរខ្ពើម ១ សេចក្តីសម្គាល់ក្នុងលោកទាំងពួងថា មិនគួរត្រេកអរ ១ សេចក្តីសម្គាល់ថា មិនទៀង ១ សេចក្តីសម្គាល់ជាទុក្ខ ក្នុងការមិនទៀង ១ សេចក្តីសម្គាល់ថា មិនមែនរបស់ខ្លួនក្នុងរបស់ជាទុក្ខ ១ ។ ម្នាលភិក្ខុទាំង-ឡាយ សេចក្តីសម្គាល់ ៧ ប្រការនេះឯង ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។

# អដ្ឋកថា

## បឋមសញ្ញាសូត្រ

[ ៤៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសញ្ញាសូត្រទី ៥ ដូចតទៅនេះ

បទថា **អមតោគធា** សេចក្ដីថា តាំងនៅក្នុងព្រះនិព្វាន ។ បទថា **អមតបរិយោសានា** បានដល់ មានព្រះនិព្វានជាទីបំផុត ។

## អដ្ឋកថា បឋមសញ្ញាសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ទុតិយសញ្ញាសូត្រទី ៦

[ ៤៦ ] ម្នាលភិក្ខុទាំងឡាយ សញ្ញា ៧ ប្រការនេះដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។ សញ្ញា ៧ ប្រការ តើដូចម្ដេចខ្លះ ។ គឺអសុភសញ្ញា ១ មរណសញ្ញា ១ អាហារេបដិកូលសញ្ញា ១ សព្វលោកេអនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេទុក្ខសញ្ញា ១ ទុក្ខេអនត្តសញ្ញា ១ ។ ពាក្យថា ម្នាលភិក្ខុទាំងឡាយ អសុភសញ្ញាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះឯង តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយៗ

ហើយ ចិត្តរមែងរួញខ្វះ បែរចេញចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬទងសរសៃដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញខ្វះ ងឡើង មិនលាវិញឡើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយៗ ហើយ ចិត្តរមែងរួញខ្វះ បែរចេញចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយៗ ហើយ ចិត្តនៅតែត្រាច់ទៅរកការជួបប្រសព្វដោយមេថុនធម្ម ឬការមិនខ្ពើមរអើម នៅតែតាំងឡើងបាន ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អសុភសញ្ញា អញចម្រើនមិនទាន់បានទេ កាលខាងដើម និងកាលខាងចុងរបស់អញ មិនទាន់ប្លែកគ្នាទេ ផលនៃការចម្រើនរបស់អញ មិនទាន់សម្រេចទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអសុភសញ្ញានោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយៗ ហើយ ចិត្តក៏រួញខ្វះ បែរចេញចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី ក៏តាំងឡើង ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អសុភសញ្ញាអញចម្រើនបានហើយ កាលខាងដើម និងកាលខាងចុង របស់អញមានសេចក្ដីប្លែកគ្នា

ផលនៃការចម្រើន អញបានសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ ក្នុងអសុភសញ្ញានោះ ដោយប្រការដូច្នេះ ។ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ អសុភសញ្ញា ដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យថា ម្នាលភិក្ខុទាំងឡាយ មរណសញ្ញា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះនេះឯង តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំមរណសញ្ញារឿយៗ ហើយ ចិត្តរមែងរួញថយ បែរចេញចាកការត្រេកអរក្នុងជីវិត មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬទងសរសៃដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញថយ ងឡើង មិនលាវិញឡើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំមរណសញ្ញារឿយៗ ហើយ ចិត្តរមែងរួញថយ បែរចេញចាកការត្រេកអរក្នុងជីវិត មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង មានឧបមេយ្យយ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុ មានចិត្តសន្សំ

មរណសញ្ញារឿយៗ ហើយ តែចិត្តនៅតែត្រាច់ទៅរកសេចក្តីត្រេកអរក្នុងជីវិត ឬការមិនខ្ពើមរអើមនៅតែតាំងឡើងបាន ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា មរណសញ្ញាអញចម្រើនមិនទាន់បានទេ កាលខាងដើម និងកាលខាងចុងរបស់អញ មិនទាន់ប្លែកគ្នាទេ ផលនៃការចម្រើនរបស់អញ មិនទាន់សម្រេចទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងខ្លួន ក្នុងមរណសញ្ញានោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុមានចិត្តសន្សំមរណ-សញ្ញារឿយៗ ហើយ ចិត្តរមែងរួញខ្វរ បែរចេញចាកការត្រេកអរក្នុងជីវិត មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី ក៏តាំងឡើង ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា មរណសញ្ញា អញចម្រើនបានហើយ កាលខាងដើម និងកាលខាងចុងរបស់អញ មានសេចក្តីប្លែកគ្នា ផលនៃការចម្រើនរបស់អញសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងខ្លួនក្នុងមរណសញ្ញានោះ ដោយប្រការដូច្នេះ ។ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ មរណសញ្ញាដែលភិក្ខុបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យថា ម្នាលភិក្ខុទាំងឡាយ អាហា-រេបដិកូលសញ្ញាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វាន

ជាទីបំផុតដូច្នេះនេះឯង តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាភិក្ខុមានចិត្តសន្សំអាហារេបដិកូលសញ្ញារឿយៗ ហើយ ចិត្តរមែងរួញខ្វូរ បែរចេញចាករសតណ្ហា (ចំណង់ក្នុងរស) មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬទងសរសៃដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញខ្វូរ ងឡើង មិនលាវិញឡើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអាហារេបដិកូលសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្វូរ បែរចេញចាករសតណ្ហា មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តីរមែងតាំងឡើងព្រម មានឧបមេយ្យយ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានចិត្តសន្សំអាហារេបដិកូលសញ្ញារឿយៗ ហើយ តែចិត្តនៅតែត្រាច់ទៅរករសតណ្ហា ឬការមិនខ្ពើមរអើម នៅតែតាំងឡើងបាន ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អាហារេបដិកូលសញ្ញា អញចម្រើនមិនទាន់បានទេ កាលខាងដើម និងកាលខាងចុងរបស់អញ មិនទាន់ប្លែកគ្នាទេ ផលនៃការចម្រើនរបស់អញ មិនទាន់សម្រេចទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអាហារេបដិកូលសញ្ញានោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុមានចិត្តសន្សំអាហារេបដិកូលសញ្ញារឿយៗ ហើយ ចិត្តក៏រួញចាករសតណ្ហា ។បេ។ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើម

រអើមក្តី ក៏តាំងឡើង ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អាហារេបដិកូលសញ្ញា អញចម្រើនបានហើយ កាលខាងដើម និងកាលខាងចុង របស់អញ មានសេចក្តីប្លែកគ្នា ផលនៃការចម្រើនរបស់អញ បានសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអាហារេបដិកូលសញ្ញានោះ ដោយប្រការដូច្នេះឯង ។ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ អាហារេបដិកូលសញ្ញា ដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យថា ម្នាលភិក្ខុទាំងឡាយ សព្វលោកេ អនភិរតសញ្ញា ដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វាជាទីបំផុតដូច្នេះឯង តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាភិក្ខុមានចិត្តសន្សំសព្វលោកេ អនភិរតសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្វួរ បែរចេញចាកលោកសន្និវាស មិនលាវិញឡើយ សេចក្តីព្រងើយ កន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬទងសរសៃ ដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញ ខ្វួរ ងឡើង មិនលាវិញឡើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុមានចិត្តសន្សំ សព្វលោកេ អនភិរតសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្ញុរ បែរចេញចាកលោកសន្និវាស មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង មានឧបមេយ្យយ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានចិត្តសន្សំសព្វលោកេ អនភិរតសញ្ញារឿយៗ ហើយ តែចិត្តនៅតែត្រាច់ទៅរកលោកសន្និវាស ឬការមិនខ្ពើមរអើម នៅតែតាំងឡើងបាន ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា សព្វលោកេ អនភិរតសញ្ញា អញចម្រើនមិនទាន់បានទេ កាលខាងដើម និងកាលខាងចុង របស់អញ មិនទាន់ប្លែកគ្នាទេ ផលនៃការចម្រើនរបស់អញ មិនទាន់សម្រេចទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងសព្វលោកេ អនភិរតសញ្ញានោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុមានចិត្តសន្សំ សព្វលោកេ អនភិរតសញ្ញារឿយៗ ហើយ ចិត្តក៏រួញ ខ្ញុរ បែរចេញចាកលោកសន្និវាស មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី ក៏តាំងឡើង ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា សព្វលោកេ អនភិរតសញ្ញា អញចម្រើនបានហើយ កាលខាងដើម និងកាលខាងចុង របស់អញ មានសេចក្តីប្លែកគ្នា ផលនៃការចម្រើនរបស់អញ បានសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងសព្វលោកេ អនភិរតសញ្ញានោះ ដោយប្រការដូច្នេះ ។ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ សព្វលោកេ អនភិរតសញ្ញា ដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ

រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរក ព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យថា ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះនេះឯង តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយ តើព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំអនិច្ចសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្ញូរ បែរចេញចាកលាភសក្ការៈ និងសេចក្ដីសរសើរ មិនលាវិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬទងសរសៃដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញ ខ្ញូរ ងឡើង មិនលាវិញឡើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអនិច្ចសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្ញូរ បែរចេញចាកលាភ-សក្ការៈ និងសេចក្ដីសរសើរ មិនលាវិញឡើយ សេចក្ដីព្រងើយកន្តើយក្ដីការខ្ពើមរអើមក្ដី រមែងតាំងឡើង មានឧបមេយ្យយ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានចិត្តសន្សំអនិច្ចសញ្ញារឿយៗ ហើយ ប៉ុន្តែចិត្តនៅតែត្រាច់ទៅស្វែងរកលាភសក្ការៈ និងសេចក្ដីសរសើរ ឬការមិនខ្ពើមរអើម នៅតែតាំងឡើងបាន ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា

អនិច្ចសញ្ញា អញចម្រើនមិនទាន់បានទេ កាលខាងដើម និងកាលខាងចុង របស់អញមិនទាន់ប្លែកគ្នាទេ ផលនៃការចម្រើនរបស់អញ មិនទាន់សម្រេចទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអនិច្ចសញ្ញានោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុមានចិត្តសន្សំអនិច្ចសញ្ញារឿយៗ ហើយ ចិត្តក៏រួញ ខ្វូរ បែរចេញចាកលាភសក្ការៈ និងសេចក្តីសរសើរ មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី ក៏តាំងឡើង ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អនិច្ចសញ្ញា អញចម្រើនបានហើយ កាលខាងដើម និងកាលខាងចុងរបស់អញ មានសេចក្តីប្លែកគ្នា ផលនៃការចម្រើនរបស់អញ បានសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអនិច្ចសញ្ញានោះ ដោយប្រការដូច្នេះ ។ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះ ដែលតថាគតបានពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ក៏ពាក្យថា ម្នាលភិក្ខុទាំងឡាយ អនិច្ចេទុក្ខសញ្ញា ដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះនេះ តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី

ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំអនិច្ចទុក្ខសញ្ញារឿយៗ ហើយ សេចក្តីសម្គាល់ក្នុងការខ្ជិលច្រអូស ទម្រន់ ប្រហែសធ្វេស មិនព្យាយាម មិនពិចារណាថាជារបស់គួរខ្ពើចដ៏ពន្លឹក រមែងកើតឡើងហាក់ដូចពេជ្ឈឃាតដែលឆាដាវដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានចិត្តសន្សំអនិច្ចទុក្ខ-សញ្ញារឿយៗ ហើយ សេចក្តីសម្គាល់ក្នុងការខ្ជិលច្រអូស ទម្រន់ ប្រហែសធ្វេស មិនព្យាយាម មិនពិចារណាថាជារបស់គួរខ្ពើចដ៏ពន្លឹក នៅតែមិនបានកើតឡើង ដូចជាពេជ្ឈឃាតឆាដាវទេ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះភិក្ខុគប្បីដឹងថា អនិច្ចទុក្ខសញ្ញាអញចម្រើនមិនទាន់បានទេ កាលខាងដើម និងកាលខាងចុងរបស់អញ មិនទាន់ប្លែកគ្នាទេ ផលនៃការចម្រើនរបស់អញមិនទាន់សម្រេចទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអនិច្ចទុក្ខ-សញ្ញានោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុមានចិត្តសន្សំអនិច្ចទុក្ខសញ្ញារឿយហើយ សេចក្តីសម្គាល់ក្នុងការខ្ជិលច្រអូស ទម្រន់ ប្រហែសធ្វេស មិនព្យាយាម មិនពិចារណាថាជារបស់គួរខ្ពើចដ៏ពន្លឹក ក៏កើតឡើង ដូចពេជ្ឈឃាតឆាដាវដូច្នោះ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អនិច្ចទុក្ខសញ្ញា អញចម្រើនបានហើយ កាលខាងដើម និងកាលខាងចុងរបស់អញ មានសេចក្តីប្លែកគ្នា ផលនៃការចម្រើនរបស់អញ បានសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអនិច្ចទុក្ខ-សញ្ញានោះ ដោយប្រការដូច្នេះឯង ។ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ

អនិច្ចេទុក្ខសញ្ញាដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះ ដែលតថាគតបានពោលហើយ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ក៏ពាក្យថា ម្នាលភិក្ខុទាំងឡាយ ទុក្ខេអនត្តសញ្ញាដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះនេះ តថាគតពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាភិក្ខុមានចិត្តសន្សំទុក្ខេអនត្តសញ្ញារឿយៗ ហើយ ចិត្តក៏រមែងប្រាសចាកអហង្ការ មមង្ការ និងមានះក្នុងកាយដែលមានវិញ្ញាណនេះផង ក្នុងនិមិត្តទាំងពួងខាងក្រៅផង ជាចិត្តកន្លងបង់នូវវិធា ៣ ប្រការ ស្ងប់រម្ងាប់ ( ចាកសត្រូវគឺកិលេស ) ផុតស្រឡះដោយប្រពៃ ( ចាកមិច្ឆាវិមុត្តិ ) ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានចិត្តសន្សំទុក្ខេអនត្តសញ្ញារឿយៗ ហើយ តែចិត្តនៅតែមិនប្រាសចាកអហង្ការ មមង្ការ និងមានះក្នុងកាយដែលមានវិញ្ញាណនេះផង ក្នុងនិមិត្តទាំងពួងខាងក្រៅផង មិនកន្លងបង់វិធា ៣ ប្រការ មិនស្ងប់រម្ងាប់ មិនផុតទុក្ខស្រឡះ ដោយប្រពៃទេ ម្នាលភិក្ខុទាំងឡាយ ជំណើរនុ៎ះភិក្ខុគប្បីដឹងថា ទុក្ខេអនត្តសញ្ញា អញចម្រើនមិនទាន់បានទេ កាលខាងដើម និងកាលខាងចុងរបស់អញមិនទាន់ប្លែកគ្នាទេ ផលនៃការចម្រើនរបស់អញមិនទាន់សម្រេចទេ

ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងទុក្ខេអនត្តសញ្ញានោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុមានចិត្តសន្សំទុក្ខេ-អនត្តសញ្ញារឿយៗ ហើយ ចិត្តក៏រួចចាកអហង្ការ មមង្ការ និងមានះក្នុងកាយដែលមានវិញ្ញាណនេះផង ក្នុងនិមិត្តទាំងពួងខាងក្រៅផង ចិត្តកន្លងបង់នូវវិធា ៣ ប្រការ ស្ងប់រម្ងាប់ ផុតស្រឡះដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា ទុក្ខេអនត្តសញ្ញា អញចម្រើនបានហើយ កាលខាងដើម និងកាលខាងចុងរបស់អញ មានសេចក្តីប្លែកគ្នា ផលនៃការចម្រើនរបស់អញបានសម្រេចហើយ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងទុក្ខេអនត្តសញ្ញានោះ ដោយប្រការដូច្នេះឯង ។ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ ទុក្ខេអនត្តសញ្ញាដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញា ៧ ប្រការនេះឯង ដែលបុគ្គលបានចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។

# អដ្ឋកថា

## ទុតិយសញ្ញាសូត្រ

[ ៤៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសញ្ញាសូត្រទី ៦ ដូចតទៅនេះ បទថា **មេថុនធម្មសមាបត្តិយា** ដល់ព្រមដោយមេថុនធម្ម ។ បទថា **ឆ្វារុនុទ្ធុលំ** បានដល់ សរសៃ ឬទងសរសៃ ។ បទថា **អនុសន្ទតិ** សេចក្តីថា ប្រព្រឹត្តទៅ ។ បទថា **នត្ថិ មេ បុព្វាបរំ វិសេសោ** សេចក្តីថា ក្នុងកាលជាទីចម្រើនសញ្ញាមុន និងកាលចម្រើនសញ្ញាក្រោយរបស់ខ្ញុំមិនប្លែកគ្នា ។

បទថា **លោកចិត្តេសុ** សេចក្តីថា លោកដ៏វិចិត្រ ពោល គឺសន្និវាសដែលប្រកបដោយធាតុ ៣ ។

បទថា **អាលស្សេ** បានដល់ ក្នុងការខ្ជិលច្រអូស ។ បទថា **វិស្សជ្ជិយេ** បានដល់ ការរួញរា ។ បទថា **អនុយោគេ** បានដល់ មិនប្រកបដោយសេចក្តីព្យាយាម ។ បទថា **អហង្ការមមង្ការមានាបគតំ** បានដល់ ប្រាសចាកទិដ្ឋិថាជាអញ ប្រាសចាកតណ្ហាថាជារបស់អញ ប្រាសចាកមានះ ៩ យ៉ាង ។ បទថា **វិធាសមតិក្កន្តំ** សេចក្តីថា ឈានកន្លងកិលេស ៣ យ៉ាង ។ បទថា **សន្តំ** បានដល់ ស្ងប់ចាកកិលេស ដែលជាសត្រូវដល់ការចម្រើនសញ្ញានោះ ។ បទថា **សុវិមុត្តំ** បានដល់ រួចផុតដោយល្អ ដោយវិមុត្តិ ៥ ។ល។

**អដ្ឋកថាទុតិយសញ្ញាសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## មេថុនសូត្រទី ៧

[ ៤៧ ] គ្រានោះ ព្រាហ្មណ៍ឈ្មោះជាណុស្សោណិ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ត្រេកអររីករាយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា ព្រះគោតមដ៏ចម្រើនប្តេជ្ញាថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរឬ ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ គេកាលបើពោលត្រឹមត្រូវ គប្បីពោលចំពោះបុគ្គលដែលប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធ មិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ។ ម្នាលព្រាហ្មណ៍ កាលគេពោលដោយត្រឹមត្រូវ គប្បីពោលចំពោះតថាគតនោះឯងថា ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធ មិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះការដាច់ក្តី ធ្លុះក្តី ពពាលក្តី ពព្រុសក្តី នៃព្រហ្មចរិយធម៌ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ប្តេជ្ញាថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយប្រពៃ មិនបានប៉ះពាល់នូវការប៉ះពាល់ ដោយបុគ្គលពីរៗ មួយអន្លើដោយមាតុគ្រាម ( សេពមេថុន ) តែថា រមែងត្រេកអរនឹងការដុសខាត់ នួត ងូតប្របាច់របស់មាតុគ្រាម ។ បុគ្គលនោះ រមែងត្រេកអរនឹងការដុសខាត់នោះ រីករាយនឹងការដុសខាត់នោះ ដល់នូវសេចក្តីត្រេកអរ ដោយការដុសខាត់នោះ ។

ម្នាលព្រាហ្មណ៍ នេះឯង ហៅថា ដាច់ផង ធ្លុះផង ពពាលផង ពព្រុសផង នៃព្រហ្មចរិយធម៌ ម្នាលព្រាហ្មណ៍ នេះហៅថា បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ មិនបរិសុទ្ធ ជាអ្នកប្រកបដោយមេថុនសំយោគ រមែងមិនផុតចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស តថាគត ហៅថា រមែងមិនរួចចាកវដ្តទុក្ខឡើយ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ ប្តេជ្ញាថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយប្រពៃ រមែងមិនប៉ះពាល់ចំពោះការប៉ះពាល់ដោយបុគ្គលពីរៗ មួយអន្លើ ដោយមាតុគ្រាម ទាំងមិនត្រេកអរនឹងការដុសខាត់ នួត ងូត ច្របាច់របស់ មាតុគ្រាមទេ តែថារមែងចំអកឡកឡឺយ សើចក្អាកក្អាយជាមួយនឹងមាតុគ្រាម ។បេ។ បើមិនចំអកឡកឡឺយ សើចក្អាកក្អាយជាមួយនឹងមាតុគ្រាមទេ រមែងនៅមៀងភ្នែកដោយភ្នែក ដៀងចំពោះមាតុគ្រាម បើមិនបានមៀងភ្នែកដោយភ្នែក ដៀងចំពោះមាតុគ្រាមទេ រមែងស្តាប់សំឡេងនៃមាតុគ្រាម កាលសើចក្តី កាលនិយាយក្តី ច្រៀងក្តី យំក្តីខាងក្រៅជញ្ជាំង ឬខាងក្រៅកំពែង បើមិនស្តាប់សំឡេងនៃមាតុគ្រាម កាលសើចក្តី និយាយក្តី ច្រៀងក្តី យំក្តីខាងក្រៅជញ្ជាំង ឬខាងក្រៅកំពែងទេ តែថា រឭករឿយៗ នូវហេតុដែលធ្លាប់សើច ធ្លាប់និយាយ ធ្លាប់លេងជាមួយនឹងមាតុគ្រាមក្នុងកាលពីដើម បើមិនរឭករឿយៗ នូវហេតុដែលធ្លាប់សើច ធ្លាប់និយាយ ធ្លាប់លេងជាមួយនឹងមាតុគ្រាមក្នុងកាលពីដើមទេ តែថា រមែងឃើញនូវគហបតី ឬគហបតិបុត្តដែលស្កប់

ស្គាល់ មូលមិត្ត បម្រើដោយកាមគុណទាំង ៥ បើមិនបានឃើញនូវគហបតី ឬគហបតិបុត្តដែលស្គប់ស្គាល់ មូលមិត្ត បម្រើដោយកាមគុណទាំង ៥ ទេ តែថា ប្រព្រឹត្តព្រហ្មចរិយធម៌ដើម្បីប្រាថ្នានូវទេពនិកាយណាមួយថា អញសុំឲ្យបានជាទេវតា ទោះជាទេវតាណាមួយដោយសីលនេះផង ដោយវត្តនេះផង ដោយតបធម៌នេះផង ដោយព្រហ្មចរិយធម៌នេះផង ។ បុគ្គលនោះ រមែងត្រេកអរនឹងធម៌នោះ រីករាយនឹងធម៌នោះ ដល់នូវសេចក្តីត្រេកអរចំពោះធម៌នោះ ។ ម្នាលព្រាហ្មណ៍ នេះឈ្មោះថា ដាច់ផង ធ្លុះផង ពពាលផង ពព្រុសផងនៃព្រហ្មចរិយធម៌ ម្នាលព្រាហ្មណ៍ បុគ្គលនេះ ហៅថា ប្រព្រឹត្តព្រហ្មចរិយធម៌មិនបរិសុទ្ធ ជាអ្នកប្រកបដោយមេថុនសំយោគ រមែងមិនរួចចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស តថាគត ហៅថា មិនរួចចាកវដ្តទុក្ខឡើយ ។ ម្នាលព្រាហ្មណ៍ បណ្តាមេថុនសំយោគទាំង ៧ យ៉ាងនេះ តថាគតឃើញច្បាស់នូវមេថុនសំយោគណាមួយក្នុងខ្លួន ដែលមិនទាន់លះបង់ដរាបណា ម្នាលព្រាហ្មណ៍ តថាគតមិនទាន់ប្តេជ្ញាថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសដរាបនោះដែរ ម្នាលព្រាហ្មណ៍ បណ្តាមេថុនសំយោគទាំង ៧ យ៉ាងនេះ តថាគតមិនឃើញច្បាស់នូវមេថុនសំយោគណាមួយក្នុងខ្លួន ដែលមិនលះបង់ក្នុងកាលណាទេ ម្នាលព្រាហ្មណ៍ តថាគត

*ក៏ប្តេជ្ញាថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលនោះដែរ ។ លុះតែបញ្ញាដែលដឹងច្បាស់ ឃើញច្បាស់កើតឡើងហើយ ដល់តថាគតដូច្នេះថា ការរួចស្រឡះរបស់តថាគតមិនកម្រើក ជាតិនេះជាទីបំផុត កពថ្មីទៀតមិនមានឡើយ ។ កាលព្រះសម្ពុទ្ធទ្រង់ត្រាស់យ៉ាងនេះហើយ ជាណុស្សោណិព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើនចាំនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។*

# អដ្ឋកថា

## មេថុនសូត្រ

*[ ៤៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមេថុនសូត្រទី ៧ ដូចតទៅនេះ បទថា* **ឧបសង្កមិ** *សេចក្តីថា ជាណុស្សោណិព្រាហ្មណ៍ បរិភោគអាហារព្រឹកហើយ ចោមរោមទៅដោយទាសៈ និងកម្មករ ចូលទៅគាល់ព្រះមានព្រះភាគ ។ បទ*

ថា **ភវំបិ ឆោ** កាត់បទជា **ភវំបិ ឆុ ។** បទថា **ព្រហ្មចារី បដិជានាតិ** សេចក្ដីថា ព្រាហ្មណ៍នោះសួរថា ព្រះគោតមដ៏ចម្រើនប្ដេជ្ញាការនៅប្រព្រឹត្ត ព្រហ្មចរិយៈយ៉ាងនេះថា តថាគតជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ បានឮថា ព្រាហ្មណ៍មានការគិតយ៉ាងនេះថា ព្រាហ្មណ៍ទាំងឡាយ រៀនវេទក្នុងលទ្ធិ របស់ព្រាហ្មណ៍ ប្រព្រឹត្តព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ ឯព្រះសមណគោតម កាលនៅគ្រប់គ្រងផ្ទះ បានអភិរម្យជាមួយស្រីស្នំ ៣ ក្រុម ក្នុងប្រាសាទទាំង ៣ ឥឡូវនេះ ព្រះសមណគោតមត្រាស់ដូចម្ដេចហ្ន៎ ដូច្នេះហើយ ទើបបាន សួរយ៉ាងនេះ សំដៅយកសេចក្ដីនេះ ។ លំដាប់នោះឯង ព្រះមានព្រះភាគ កាលទ្រង់បន្លឺសីហនាទ សំដៅដល់សូម្បីត្រឹមតែវិតក្កក៏មិនកើតឡើង ប្រារព្ធសុខ ក្នុងរាជសម្បត្តិ ឬការដល់ព្រមដោយអ្នករបាំ ក្នុងប្រាសាទទាំងឡាយ ព្រោះ ព្រះអង្គទ្រង់បំពេញសេចក្ដីព្យាយាមអស់ ៦ វស្សា ក្នុងកាលដែលទ្រង់នៅ មានកិលេស ដូចបុគ្គលចាប់ពស់វែកដោយមន្ត និងដូចយកជើងជាន់កសត្រូវ ដូច្នោះ ទើបត្រាស់ពាក្យជាដើមថា **យញ្ហិ តំ ព្រាហ្មណ ។**

បណ្ដាបទទាំងនោះ បទថា **ទ្វយន្ទ្វយសមាបត្តឹ** សេចក្ដីថា ភាពដែល គប្បីបដិបត្តិ ២ ចំពោះ ២ ។ បទថា **ឧច្ឆាទន** បានដល់ ចាកទុក្ខក្នុងវដ្ដៈ ទាំងមូល ។ បទថា **សញ្ជគ្ឃតិ** បានដល់ សម្ដែងនូវការញញឹម ។ បទថា **សំកីឡតិ** បានដល់ ធ្វើការចំអកលេង ។ បទថា **សំកេឡាយតិ** បានដល់ សើចខ្លាំង ។ បទថា **ចក្ខុនា ចក្ខុំ** សេចក្ដីថា ប្រើភ្នែករបស់ខ្លួនសម្លឹងមើល

ក្អែករបស់ស្រីនោះ ។ បទថា **តិរោកុឌ្ឌំ វា តិរោបាការំ វា** សេចក្តីថា ត្រង់ជញ្ជាំងផ្ទះនោះ ឬកំពែងនោះ ។ បទថា **ទេវោ** បានដល់ រាជានៃទេវតាមួយអង្គ ។ បទថា **ទេវញ្ញតរោ** បានដល់ ទេវបុត្រអង្គណាមួយ ។ បទថា **អនុត្តរំ សម្មាសម្ពោធឹ** បានដល់ អរហត្ត និងព្រះសព្វញ្ញុតញ្ញាណ ។៚

### អដ្ឋកថាមេថុនសូត្រទី ៧ ចប់

# សុត្តន្តបិដក

## សំយោគសូត្រទី ៨

[ ៤៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម្មបរិយាយដែលសម្រេចអំពីសញ្ញោគ ( ការប្រកប ) និងវិសញ្ញោគ ( ការនឿយណាយ ) ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះធម្មបរិយាយសម្រេចអំពីសញ្ញោគ និងវិសញ្ញោគ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីរមែងកំណត់ក្នុងចិត្តនូវឥន្ទ្រិយនៃស្ត្រីខាងក្នុង គឺកិរិយានៃស្ត្រី ឫកពានៃស្ត្រី បែបផែននៃស្ត្រី សេចក្តីប្រាថ្នានៃស្ត្រី សំឡេងនៃស្ត្រី

អលង្ការនៃស្ត្រី ។ ស្ត្រីនោះរមែងត្រេកអរក្នុងហេតុទាំងនោះ រីករាយក្នុងហេតុទាំងនោះ លុះស្ត្រីនោះត្រេកអរក្នុងហេតុទាំងនោះ រីករាយក្នុងហេតុទាំងនោះហើយ រមែងកំណាត់ក្នុងចិត្តចំពោះឥន្ទ្រិយនៃបុរសខាងក្រៅ គឺកិរិយានៃបុរស ឫកពានៃបុរស បែបផែននៃបុរស សេចក្តីប្រាថ្នានៃបុរស សំឡេងនៃបុរស អលង្ការនៃបុរស ។ ស្ត្រីនោះរមែងត្រេកអរក្នុងហេតុទាំងនោះ រីករាយក្នុងហេតុទាំងនោះ លុះស្ត្រីនោះត្រេកអរក្នុងហេតុទាំងនោះ រីករាយក្នុងហេតុទាំងនោះហើយ រមែងប៉ុនប៉ងនូវការប្រកបខាងក្រៅ សេចក្តីសុខ និងសោមនស្សណា កើតឡើងដល់ស្ត្រីនោះ ព្រោះការប្រកបជាបច្ច័យ ស្ត្រីនោះឯង រមែងប៉ុនប៉ងនូវសេចក្តីសុខ និងសោមនស្សនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលត្រេកអរក្នុងឥត្ថីភាព រមែងដល់នូវការប្រកបក្នុងបុរិសភាព ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីរមែងមិនកន្លងភាពនៃស្ត្រីយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ បុរសរមែងកំណាត់ទុកក្នុងចិត្តចំពោះឥន្ទ្រិយនៃបុរសខាងក្នុងសន្តាន គឺកិរិយានៃបុរស ឫកពានៃបុរស បែបផែននៃបុរស សេចក្តីប្រាថ្នានៃបុរស សំឡេងនៃបុរស អលង្ការនៃបុរស ។ បុរសនោះរមែងត្រេកអរក្នុងហេតុទាំងនោះ រីករាយក្នុងហេតុទាំងនោះ លុះបុរសនោះត្រេកអរក្នុងហេតុទាំងនោះ រីករាយក្នុងហេតុទាំងនោះហើយ រមែងកំណាត់ទុកចិត្តចំពោះឥន្ទ្រិយនៃស្ត្រីខាងក្រៅវិញ គឺកិរិយានៃស្ត្រី ឫកពានៃស្ត្រី បែបផែននៃស្ត្រី សេចក្តីប្រាថ្នានៃស្ត្រី សំឡេងនៃស្ត្រី អលង្ការនៃស្ត្រី ។ បុរសនោះរមែងត្រេកអរក្នុងហេតុនោះ

រីករាយក្នុងហេតុនោះ លុះបុរសនោះត្រេកអរក្នុងហេតុនោះ រីករាយក្នុងហេតុនោះហើយ រមែងប៉ុនប៉ងនូវសេចក្តីប្រកបខាងក្រៅ ។ សេចក្តីសុខ និងសោមនស្សណាកើតឡើងដល់បុរសនោះ ព្រោះការប្រកបជាបច្ច័យ បុរសនោះតែងប៉ុនប៉ងនូវសេចក្តីសុខ និងសោមនស្សនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលត្រេកអរក្នុងភាពនៃបុរស តែងដល់នូវការប្រកបក្នុងពួកស្ត្រី ។ ម្នាលភិក្ខុទាំងឡាយ បុរសរមែងមិនកន្លងនូវភាពនៃបុរសយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញោគៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះវិសញ្ញោគ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីមិនកំណត់ក្នុងចិត្ត ចំពោះឥន្ទ្រិយនៃស្ត្រីខាងក្នុងសន្តាន គឺកិរិយានៃស្ត្រី ឫកពានៃស្ត្រី បែបផែននៃស្ត្រី សេចក្តីប្រាថ្នានៃស្ត្រី សំឡេងនៃស្ត្រី អលង្ការនៃស្ត្រី ។ ស្ត្រីនោះរមែងមិនត្រេកអរក្នុងហេតុនោះ មិនរីករាយក្នុងហេតុនោះ លុះស្ត្រីនោះមិនត្រេកអរក្នុងហេតុនោះ មិនរីករាយក្នុងហេតុនោះហើយ រមែងមិនកំណត់ទុកក្នុងចិត្ត ចំពោះឥន្ទ្រិយនៃបុរសខាងក្រៅ គឺកិរិយានៃបុរស ឫកពានៃបុរស បែបផែននៃបុរស សេចក្តីប្រាថ្នានៃបុរស សំឡេងនៃបុរស អលង្ការនៃបុរស ។ ស្ត្រីនោះរមែងមិនត្រេកអរក្នុងហេតុនោះ មិនរីករាយក្នុងហេតុនោះ លុះស្ត្រីនោះមិនត្រេកអរក្នុងហេតុនោះ មិនរីករាយក្នុងហេតុនោះហើយ រមែងមិនប៉ុនប៉ងនូវការប្រកបខាងក្រៅ សេចក្តីសុខ និងសោមនស្សណា កើតឡើងដល់ស្ត្រីនោះ ព្រោះការប្រកបជាបច្ច័យ ស្ត្រីនោះតែងមិនប៉ុនប៉ងនូវសេចក្តីសុខ

និងសោមនស្សនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមិនត្រេកអរក្នុងភាពនៃស្ត្រី តែងដល់នូវការនឿយណាយក្នុងបុរសទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីរមែងកន្លងភាពនៃស្ត្រីយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ បុរសមិនធ្វើទុកក្នុងចិត្តនូវឥន្ទ្រិយរបស់បុរសខាងក្នុងសន្តាន គឺកិរិយានៃបុរស ឫកពានៃបុរស បែបផែននៃបុរស សេចក្ដីប្រាថ្នានៃបុរស សំឡេងនៃបុរស អលង្ការនៃបុរស ។ បុរសនោះមិនត្រេកអរក្នុងហេតុនោះ មិនរីករាយក្នុងហេតុនោះ លុះបុរសនោះមិនត្រេកអរក្នុងហេតុនោះ មិនរីករាយក្នុងហេតុនោះហើយ រមែងមិនធ្វើទុកក្នុងចិត្តនូវឥន្ទ្រិយនៃស្ត្រីខាងក្រៅ គឺកិរិយានៃស្ត្រី ឫកពានៃស្ត្រី បែបផែននៃស្ត្រី សេចក្ដីប្រាថ្នានៃស្ត្រី សំឡេងនៃស្ត្រី អលង្ការនៃស្ត្រី ។ បុរសនោះមិនត្រេកអរក្នុងហេតុនោះ មិនរីករាយក្នុងហេតុនោះ លុះបុរសនោះមិនត្រេកអរក្នុងហេតុនោះ មិនរីករាយក្នុងហេតុនោះហើយ រមែងមិនប្រាថ្នានូវការប្រកបខាងក្រៅ សេចក្ដីសុខ និងសោមនស្សណា កើតឡើងដល់បុរសនោះ ព្រោះការប្រកបជាបច្ច័យ បុរសនោះតែងមិនប្រាថ្នានូវសេចក្ដីសុខ និងសោមនស្សនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមិនត្រេកអរក្នុងភាពនៃបុរស តែងដល់នូវការនឿយណាយក្នុងស្ត្រីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បុរសកន្លងនូវភាពនៃបុរសយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ វិសញ្ញោគយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម្មបរិយាយនេះឯង ដែលសម្រេចអំពីការប្រកប និងការនឿយណាយ ។

# អដ្ឋកថា

## សំយោគសូត្រ

[ ៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសំយោគសូត្រទី ៨ ដូចតទៅនេះ បទថា **សញ្ញោគវិសញ្ញោគំ** សេចក្តីថា ធ្វើការប្រកប និងការមិនប្រកបឲ្យសម្រេច ។ បទថា **ធម្មបរិយាយំ** បានដល់ ហេតុនៃធម៌ ។ បទថា **អជ្ឈត្តំ ឥត្ថិន្ទ្រិយំ** បានដល់ ភាពជាស្រីខាងក្នុងរបស់ខ្លួន ។ បទថា **ឥត្ថីកុត្តំ** បានដល់ កិរិយារបស់ស្រី ។ បទថា **ឥត្ថាកប្បំ** បានដល់ មារយាទរបស់ស្រី មានការស្លៀក និងដណ្តប់ជាដើម ។ បទថា **ឥត្ថីវិធំ** បានដល់ បែបផែនរបស់ស្រី ។ បទថា **ឥត្ថិច្ឆន្ទំ** បានដល់ ការពេញចិត្តអធ្យាស្រ័យនៃស្រី ។ បទថា **ឥត្ថិស្សរំ** ប្រែថា សំឡេងរបស់ស្រី ។ បទថា **ឥត្ថាលង្ការំ** បានដល់ អលង្ការរបស់ស្រី ។ សូម្បីក្នុងបុរិសិន្ទ្រិយជាដើមក៏មានន័យដូចគ្នា ។ បទថា **ពហិទ្ធា សញ្ញោគំ** បានដល់ សេពគប់នឹងបុរស ។ បទថា **អតិវត្តតិ** សត្វកន្លងផុតភាពជាស្រី ភាពជាបុរស ព្រោះបានសម្រេចអរិយមគ្គ ដោយវិបស្សនាមានកម្លាំង ដែលពោលយ៉ាងនេះថា មិនត្រេកអរក្រៃលែង ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់វដ្តៈផង វិវដ្តៈផង ៕

**អដ្ឋកថា សំយោគសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ធានសូត្រទី ៩

[ ៤៩ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ទៀបឆ្នេរស្រះបោក្ខរណីឈ្មោះគគ្គរា ជិតក្រុងចម្បា ។ គ្រានោះឯង ពួកឧបាសកច្រើននាក់នៅក្នុងស្រុកចម្បា ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះសារីបុត្តដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះពួកឧបាសកក្នុងស្រុកចម្បាអង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយនឹងព្រះសារីបុត្តដ៏មានអាយុដូច្នេះថា បពិត្រលោកដ៏ចម្រើន ធម្មីកថាចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ យើងខ្ញុំខានស្តាប់អស់កាលយូរហើយ បពិត្រលោកដ៏ចម្រើន សូមឲ្យយើងខ្ញុំគប្បីបានស្តាប់នូវធម្មីកថា នៃព្រះដ៏មានព្រះភាគ ។ ម្នាលអ្នកដ៏មានអាយុទាំងឡាយ បើដូច្នេះ អ្នកទាំងឡាយ គប្បីមកក្នុងថ្ងៃឧបោសថចុះ ធ្វើដូច្នេះ អ្នកទាំងឡាយ គប្បីបានស្តាប់នូវធម្មីកថា ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ ពួកឧបាសកនៅក្នុងស្រុកចម្បា ទទួលស្តាប់ព្រះសារីបុត្តដ៏មានអាយុថា ព្រះករុណាលោកម្ចាស់ ហើយក្រោកចាកអាសនៈថ្វាយបង្គំព្រះសារីបុត្តដ៏មានអាយុ ធ្វើប្រទក្សិណាចៀសចេញទៅ ។ លំដាប់នោះ ពួកឧបាសកអ្នកស្រុកចម្បា ចូលទៅរកព្រះសារីបុត្តដ៏មានអាយុក្នុងថ្ងៃឧបោសថ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះសារីបុត្ត ហើយឋិតនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ជាមួយនឹងពួកឧបាសកអ្នកស្រុកចម្បានោះ លុះចូលទៅដល់ ក៏ថ្វាយ

បង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទានបែបនោះ ដែលបុគ្គលឲ្យហើយចំពោះបុគ្គលខ្លះក្នុងលោកនេះ មានផលច្រើន តែមិនមានមានអានិសង្សច្រើន មានដែរឬ បពិត្រព្រះអង្គដ៏ចម្រើន ទានបែបនោះ ដែលបុគ្គលឲ្យហើយចំពោះបុគ្គលខ្លះក្នុងលោកនេះ មានផលច្រើន មានអានិសង្សច្រើន មានដែរឬ ។ ព្រះអង្គត្រាស់ថា ម្នាលសារីបុត្ត ទានដែលបុគ្គលឲ្យហើយចំពោះបុគ្គលខ្លះក្នុងលោកនេះ មានផលច្រើន តែមិនមានអានិសង្សច្រើនក៏មាន ម្នាលសារីបុត្ត ទានដែលបុគ្គលឲ្យហើយ ចំពោះបុគ្គលខ្លះ ក្នុងលោកនេះ មានផលច្រើន មានអានិសង្សច្រើនក៏មាន ។ បពិត្រព្រះអង្គចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យដែលនាំឲ្យទានបែបនោះឯង ដែលបុគ្គលឲ្យហើយ ចំពោះបុគ្គលខ្លះក្នុងលោកនេះជាទានមានផលច្រើន តែមិនមានអានិសង្សច្រើន បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យទានបែបនោះឯង ដែលបុគ្គលឲ្យហើយចំពោះបុគ្គលខ្លះ ក្នុងលោកនេះ ជាទានមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលសារីបុត្ត បុគ្គលខ្លះក្នុងលោកនេះ ឲ្យទានទាំងប្រកបដោយតណ្ហា ឲ្យទានទាំងចិត្តជាប់ជំពាក់ ឲ្យទានទាំងសម្លឹងនូវការសន្សំទុក ឲ្យទានដោយគិតថា អាត្មាអញលះលោកនេះទៅ នឹងបរិភោគ ។ បុគ្គលនោះឲ្យបាយ ទឹកសំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿង

ឧបករណ៍ដល់ប្រទីបជាទាន ចំពោះសមណៈ ឬព្រាហ្មណ៍ ។ ម្នាលសារីបុត្ត អ្នកសម្គាល់នូវហេតុនោះដូចម្តេច បុគ្គលខ្លះក្នុងលោកនេះ គប្បីឲ្យទានមានសភាពបែបនេះដែរឬ ។ មានព្រះអង្គ ។ ម្នាលសារីបុត្ត ក្នុងជំណើរនោះ បុគ្គលណាឲ្យទានទាំងប្រកបដោយតណ្ហា ឲ្យទានទាំងចិត្តជាប់ជំពាក់ ឲ្យទានទាំងសម្លឹងនូវការសន្សំទុក ឲ្យទានដោយគិតថា អាត្មាអញលះលោកនេះទៅនឹងបរិភោគ លុះបុគ្គលនោះ ឲ្យទាននោះរួចហើយ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងទេវតា ជាធំក្នុងជាន់ចាតុម្មហារាជិកៈ ។ លុះបុគ្គលនោះ អស់កម្មនោះហើយ ក៏បានមកកាន់អត្តភាពនេះ បាននូវឫទ្ធិនោះ យសនោះ អធិបតេយ្យនោះទៀត ។ ម្នាលសារីបុត្ត បុគ្គលខ្លះក្នុងលោកនេះ មិនឲ្យទានប្រកបដោយតណ្ហា មិនឲ្យទានទាំងចិត្តជាប់ជំពាក់ មិនឲ្យទានទាំងសម្លឹងនូវការសន្សំទុក មិនឲ្យទានដោយគិតថា អាត្មាអញលះលោកនេះទៅ នឹងបរិភោគចំណែកខ្លះ ឲ្យទានដោយគិតថា ទានជាការល្អ ។បេ។ ទាំងមិនឲ្យទានដោយគិតថា ទានជាការល្អ ចំណែកខ្លះឲ្យទានដោយគិតថា អាត្មាអញមិនគួរដើម្បីញុំាងវង្សរបស់ត្រកូលបុរាណ ដែលជីដូនជីតាធ្លាប់ឲ្យ ធ្លាប់ធ្វើឲ្យសាបសូន្យសោះ ទាំងមិនឲ្យទានដោយគិតថា អាត្មាអញមិនគួរញុំាងវង្សត្រកូលបុរាណដែលជីដូនជីតាធ្លាប់ឲ្យ ធ្លាប់ធ្វើ ឲ្យសាបសូន្យសោះ ចំណែកខ្លះឲ្យទានដោយគិតថា អាត្មាអញចម្អិន ( បាយ ) ជនទាំងឡាយនេះមិនទាន់ចម្អិន កាលអញចម្អិន មិនគួរដើម្បីមិនឲ្យទាន ដល់ជនដែលមិនទាន់ចម្អិន ទាំងមិនឲ្យទាន

ដោយគិតថា អាត្មាអញចម្អិន ជនទាំងឡាយនេះមិនទាន់ចម្អិន កាលអញចម្អិន មិនគួរដើម្បីមិនឲ្យទាន ដល់ជនមិនទាន់ចម្អិន ចំណែកខ្លះឲ្យទានដោយគិតថា មហាយញ្ញទាំងឡាយនោះ របស់ឥសីជាន់មុនទាំងនោះ គឺឥសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមទគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ យ៉ាងណា ទាន និងការចែករំលែកនេះ នឹងមានដល់អាត្មាអញយ៉ាងនោះដែរ ទាំងមិនឲ្យទានដោយគិតថា មហាយញ្ញទាំងឡាយនោះ របស់ឥសីជាន់មុនទាំងនោះ គឺឥសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមទគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ យ៉ាងណា ទាន និងការចែករំលែក នឹងមានដល់អាត្មាអញយ៉ាងនោះដែរ ចំណែកខ្លះឲ្យទានដោយគិតថា កាលអាត្មាអញឲ្យទាននេះ ចិត្តក៏រមែងជ្រះថ្លា ការពេញចិត្ត និងសេចក្តីសោមនស្ស ក៏រមែងកើតឡើង ទាំងមិនឲ្យទានដោយគិតថា កាលអាត្មាអញឲ្យទាននេះ ចិត្តក៏ជ្រះថ្លា ការពេញចិត្ត និងសេចក្តីសោមនស្ស ក៏រមែងកើតឡើង ចំណែកខ្លះឲ្យទានជាគ្រឿងប្រដាប់នៃចិត្ត ជាបរិក្ខារនៃចិត្ត ។ បុគ្គលនោះតែងឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងឧបករណ៍ដល់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍ ។ ម្នាលសារីបុត្ត អ្នកសម្គាល់នូវហេតុនោះដូចម្តេច បុគ្គលខ្លះក្នុងលោកនេះ គប្បីឲ្យទានមានសភាពយ៉ាងនេះដែរឬ ។ មានព្រះអង្គ ។ ម្នាលសារីបុត្ត ក្នុងដំណើរនោះ បុគ្គលណាមិនឲ្យទានប្រកប

ដោយតណ្ហា មិនឲ្យទានទាំងចិត្តជាប់ជំពាក់ មិនឲ្យទានទាំងសម្លឹងនូវការសន្សំទុក មិនឲ្យទានដោយគិតថា អាត្មាអញលះលោកនេះទៅ នឹងបរិភោគ ទាំងមិនឲ្យទានដោយគិតថា ទានជាការល្អ ទាំងមិនឲ្យទានដោយគិតថា អាត្មាអញមិនគួរញុំាងវង្សត្រកូលបុរាណ ដែលជីដូនជីតាធ្លាប់ឲ្យ ធ្លាប់ធ្វើ ឲ្យសាបសូន្យសោះ ទាំងមិនឲ្យទានដោយគិតថា អាត្មាអញចម្អិន ជនទាំងឡាយនេះមិនទាន់ចម្អិន កាលអញចម្អិន មិនគួរដើម្បីនឹងមិនឲ្យទាន ដល់ពួកបុគ្គលមិនចម្អិន ទាំងមិនឲ្យទានដោយគិតថា មហាយញ្ញទាំងឡាយនោះ របស់ឥសីទាំងនោះ គឺឥសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមទគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ យ៉ាងណា ទាននិងការចែករំលែកនេះ នឹងមានដល់អាត្មាអញយ៉ាងនោះដែរ ទាំងមិនឲ្យទានដោយគិតថា កាលអាត្មាអញឲ្យទាននេះ ចិត្តក៏ជ្រះថ្លា ការពេញចិត្ត និងសេចក្ដីសោមនស្ស ក៏កើតឡើង ចំណែកខ្លះឲ្យទាន ជាគ្រឿងប្រដាប់នៃចិត្ត ជាបរិក្ខារនៃចិត្ត លុះបុគ្គលនោះ ឲ្យទាននោះរួចហើយ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងព្រហ្មកាយិកទេវតា បុគ្គលនោះ ញុំាងផលនៃកម្មនោះ ញុំាងឫទ្ធិនោះ ញុំាងយសនោះ ញុំាងអធិបតេយ្យនោះ ឲ្យអស់ហើយ ជាអនាគាមី មិនមកកាន់ភាពនេះទេ ម្នាលសារីបុត្ត នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យទានបែបនោះឯង ដែលបុគ្គលឲ្យហើយចំពោះបុគ្គលខ្លះ ក្នុងលោកនេះ ជាទានមានផលច្រើន តែមិនមានអានិសង្សច្រើន ម្នាលសារីបុត្ត នេះឯង

*ជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យទានបែបនោះឯង ដែលបុគ្គលឲ្យហើយ ចំពោះបុគ្គលខ្លះក្នុងលោកនេះ ជាទានមានផលច្រើន មានអានិសង្សច្រើន ។*

# អដ្ឋកថា

## ទានសូត្រ

*[ ៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទានសូត្រទី ៩ ដូចតទៅនេះ បទថា* **សាបេក្ខោ** *ប្រែថា មានតណ្ហា គឺការចង់បាន ។ បទថា* **បដិពទ្ធចិត្តោ** *បានដល់ ដែលមានចិត្តជាប់ជំពាក់ក្នុងផលទាន ។ បទថា* **សន្និធិបេក្ខោ** *បានដល់ បុគ្គលបំណង គឺដាក់ចិត្តក្នុងទាន ។ បទថា* **បេច្ច** *បានដល់ ទៅដល់លោកដទៃហើយ ។ បទថា* **តំ កម្មំ ខេបេត្វា** *ឲ្យផលរបស់កម្មនោះអស់ទៅ ។ បទថា* **ឥទ្ធិំ** *បានដល់ ឫទ្ធិ គឺវិបាក ។ បទថា* **យសំ** *បានដល់ ការដល់ព្រមដោយបរិវារ ។ បទថា* **អធិបតេយ្យំ** *បានដល់ ហេតុនៃភាពជាធំ ។ បទថា* **អាគន្តា ឥត្ថត្តំ** *សេចក្តីថា នៅត្រឡប់មកយ៉ាងនេះ គឺត្រឡប់មកកាន់ខន្ធបញ្ចកៈនេះទៀត អធិប្បាយថា បុគ្គលនោះនឹងមិនរួចផុតក្នុងការកើតក្នុងភពនោះទៀត និងផុតពីការកើតឡើងក្នុងភពខាងលើ តែនឹងត្រឡប់មកខាងក្រោមប៉ុណ្ណោះ ។ បទថា* **សាធុ ទានំ** *ឈ្មោះថា ទាននេះញ៉ាំងប្រយោជន៍ឲ្យសម្រេច ល្អរុងរឿង ។ បទថា* **តានិ មហាយញ្ញានិ**

សេចក្តីថា មហាទានទាំងនោះ សម្រេចដោយសប្បិ នវនីត ទធិ ទឹកឃ្មុំ និង ទឹកអំពៅជាដើម ។ បទថា **ចិត្តាលង្ការំ ចិត្តបរិក្ខារំ** សេចក្តីថា ជាគ្រឿងប្រដាប់ និងជាគ្រឿងចោមរោមចិត្ត ដែលសម្បយុត្តដោយសមថៈ និងវិបស្សនា ។ បទថា **ព្រហ្មកាយិកានំ ទេវានំ សហព្យតំ** សេចក្តីថា បុគ្គលនោះ មិនអាចកើតឡើងក្នុងភូមិនោះបានដោយទាន ព្រោះទាននោះ ជាអលង្ការចិត្ត ដែលប្រកបដោយសមថៈ និងវិបស្សនា ដូច្នោះ ទើបបុគ្គលនោះធ្វើឈាន និងអរិយមគ្គឲ្យកើតឡើងដោយចិត្ត ដែលប្រដាប់ដោយទាននោះ ហើយរមែងកើតឡើងក្នុងភូមិនោះដោយឈាន ។ បទថា **អនាគាមី ហោតិ** សេចក្តីថា ជាព្រះអនាគាមីដែលមិនត្រឡប់មកព្រោះឈាន ។ បទថា **អនាគន្តា ឥត្ថត្តំ** សេចក្តីថា មិនត្រឡប់មកកាន់ភាវៈយ៉ាងនេះទៀត មិនផុស គឺកើតក្នុងភពខាងលើ ឬក្នុងភពនោះទៀត រមែងបរិនិព្វានក្នុងភពនោះឯង ។

ដូច្នោះ បណ្តាទានទាំងនេះ ទានទី ១ ឈ្មោះថា **តណ្ហុត្តរិយទានំ** ការឲ្យដែលក្រៃលែងដោយតណ្ហា ។ ទានទី ២ ឈ្មោះថា **វិត្តីការទានំ** ឲ្យដោយការគោតក្រែង ។ ទានទី ៣ ឈ្មោះថា **ហិរោត្តប្បទានំ** ឲ្យដោយខ្មាស និងខ្លាចបាប ។ ទានទី ៤ ឈ្មោះថា **និរវសេសទានំ** ឲ្យដោយមិនឲ្យសេសសល់ ។ ទានទី ៥ ឈ្មោះថា **ទក្ខិណេយ្យទានំ** ឲ្យដល់ព្រះទក្ខិណេយ្យបុគ្គល ។ ទានទី ៦ ឈ្មោះថា **សោមនស្សុបវិចារទានំ** ឲ្យដោយ

អាស្រ័យសោមនស្ស ។ ទានទី ៧ ឈ្មោះថា **អលង្ការបរិវារទានធំ** ឲ្យទានជាគ្រឿងប្រដាប់ និងជាបរិវារនៃចិត្ត ។

## អដ្ឋកថា ទានសូត្រទី ៩ ចប់

# សុត្តន្តបិដក

## នន្ទមាតាសូត្រទី ១០

[ ៥០ ] សម័យមួយ ព្រះមានព្រះភាគ ព្រះសារីបុត្តដ៏មានអាយុ និងព្រះមហាមោគ្គល្លានដ៏មានអាយុ ត្រាច់ទៅកាន់ចារិក ក្នុងទក្ខិណាគិរី ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ សម័យនោះឯង នន្ទមាតាឧបាសិកា នៅក្នុងក្រុងឈ្មោះវេឡុកណ្ដកៈ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី សូត្របារាយនធម៌ គឺព្រះនិព្វាន ដោយសំឡេងដ៏ពីរោះ ។ សម័យនោះឯង មហារាជឈ្មោះវេស្សវណ ស្ដេចចេញទៅអំពីទិសខាងជើង ទៅកាន់ទិសខាងត្បូង ដោយកិច្ចនីមួយ ។ មហារាជឈ្មោះវេស្សវណ បានឮនន្ទមាតាឧបាសិកា កំពុងសូត្របារាយនធម៌ ដោយសំឡេង ( ដ៏ពីរោះ ) ក៏បង្អង់ឈរចាំស្ដាប់ត្រាតែចប់ពាក្យពោល ។ លុះនន្ទមាតាឧបាសិកា សូត្រនូវបារាយនធម៌ ដោយសំឡេង ( ដ៏ពីរោះ ) រួចហើយ ក៏នៅស្ងៀម ។ លំដាប់នោះ មហារាជឈ្មោះវេស្សវណ ជ្រាបច្បាស់នូវការចប់នៃកថា របស់នន្ទមាតាឧបាសិកាហើយ ក៏អនុមោទនាថា

ម្នាលនាង ពីរោះណាស់ ម្នាលនាង ពីរោះណាស់ ។ ( នន្ទមាតាឧបាសិកាសួរថា ) បពិត្រព្រះអង្គមានមុខដ៏ចម្រើន ចុះអ្នកជាអ្វី ។ ម្នាលនាង ខ្ញុំជាមហារាជឈ្មោះវេស្សវ័ណ ជាប្អូននៃនាង ។ បពិត្រព្រះអង្គ អ្នកមានមុខដ៏ចម្រើន ប្រពៃហើយ បើដូច្នោះ ធម្មបរិយាយដែលខ្ញុំពោលហើយនេះ សូមជាបណ្ណាការយ៉ាងវិសេសដល់ព្រះអង្គ ។ វេស្សវ័ណមហារាជពោលថា ម្នាលនាង ប្រពៃហើយ ពាក្យនុ៎ះ សូមជាបណ្ណាការយ៉ាងវិសេសដល់ខ្ញុំចុះ ភិក្ខុសង្ឃ មានព្រះសារីបុត្ត និងព្រះមហាមោគ្គល្លានជាប្រធាន មិនទាន់បានធ្វើភត្តកិច្ចក្នុងវេលាព្រឹក នឹងមកកាន់វេឡុកណ្ដកនគរក្នុងថ្ងៃស្អែក នាងចូរអង្គាសនូវភិក្ខុសង្ឃនោះ ឧទ្ទិសនូវចំណែកបុណ្យដល់ខ្ញុំផង បណ្ណាការយ៉ាងវិសេសនឹងមានដល់ខ្ញុំយ៉ាងនេះឯង ។ គ្រានោះ នន្ទមាតាឧបាសិកា លុះកាលកន្លងទៅក៏ប្រើបុរសមួយនាក់ ឲ្យចាត់ចែងខាទនីយភោជនីយាហារដ៏ឧត្តម ក្នុងលំនៅរបស់ខ្លួន ។ លំដាប់នោះ ភិក្ខុសង្ឃមានព្រះសារីបុត្ត និងព្រះមហាមោគ្គល្លានជាប្រធាន មិនទាន់ធ្វើភត្តកិច្ចក្នុងពេលព្រឹកនៅឡើយ ក៏សំដៅទៅកាន់វេឡុ-កណ្ដកនគរ ។ ចំណែកខាងនន្ទមាតាឧបាសិកា ក៏ហៅបុរសមួយនាក់ថា នែបុរសដ៏ចម្រើន អ្នកចូរមក អ្នកចូរទៅឯអារាម ចូរក្រាបទូលនូវភត្តកាលចំពោះភិក្ខុសង្ឃថា បពិត្រលោកទាំងឡាយដ៏ចម្រើន កាលគួរហើយ ភត្តក្នុងលំនៅនៃនន្ទមាតាជាម្ចាស់ ក៏សម្រេចហើយ ។ បុរសនោះ ក៏ទទួលស្ដាប់នន្ទមាតាឧបាសិកាថា បាទអ្នកម្ចាស់ហើយ ក៏សំដៅទៅឯអារាម ក្រាបទូល

នូវកាលដល់ភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន កាលគួរហើយ កត្តក្នុងលំនៅនៃនន្ទមាតាឧបាសិកាជាម្ចាស់ ក៏សម្រេចហើយ ។ លំដាប់នោះ ភិក្ខុសង្ឃមានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាប្រធាន ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅត្រង់លំនៅដែលនន្ទមាតាឧបាសិកានៅ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលស្រេចហើយ ។ ចំណែកខាងនន្ទមាតាឧបាសិកា អង្គាសភិក្ខុសង្ឃ មានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ឧត្តម ដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ត្រាតែហាមឃាត់ ។ នន្ទមាតាឧបាសិកា លុះកំណត់ដឹងនូវព្រះសារីបុត្តដ៏មានអាយុ កាលឆាន់រួច មានព្រះហស្តដាក់ចេញពីបាត្រហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះនន្ទមាតាឧបាសិកា អង្គុយក្នុងទីដ៏សមគួរហើយ ព្រះសារីបុត្តដ៏មានអាយុ ក៏សួរដូច្នេះថា ម្នាលនន្ទមាតា ចុះអ្នកណាប្រាប់ដំណើរមកនៃភិក្ខុសង្ឃដល់នាង ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រីឯណោះ សូត្រពាក្យនធម៌ដោយសំឡេង ( ដ៏ពីរោះ ) ហើយនៅស្ងៀម ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ស្រាប់តែមហារាជឈ្មោះវេស្សវ័ណ ដឹងច្បាស់នូវទីបំផុតនៃធម្មកថារបស់ខ្ញុំ ក៏អនុមោទនាថា ម្នាលនាង ពីរោះណាស់ ម្នាលនាង ពីរោះណាស់ ។ ( ខ្ញុំម្ចាស់សួរថា ) ម្នាលអ្នកមានមុខដ៏ចម្រើន ចុះអ្នកជាអ្វី ។ ម្នាលនាង ខ្ញុំជាមហារាជឈ្មោះវេស្សវ័ណ ជាប្អូននៃនាង ។ បពិត្រព្រះអង្គមានភក្រ្តដ៏ចម្រើន ការមករបស់

ព្រះអង្គ ប្រពៃណាស់ បើដូច្នោះ ធម្មបរិយាយដែលខ្ញុំបានពោលហើយនេះ សូមជាបណ្ណាការយ៉ាងវិសេសដល់ព្រះអង្គ ។ ម្នាលនាង ប្រពៃហើយ ពាក្យនុ៎ះឯង សូមជាបណ្ណាការយ៉ាងវិសេសដល់ខ្ញុំ ភិក្ខុសង្ឃមានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាប្រធាន មិនទាន់ធ្វើភត្តកិច្ចក្នុងវេលាព្រឹកនៅឡើយ និមន្តមកកាន់វេឡុកណ្ដកនគរ ក្នុងថ្ងៃស្អែក ចូរនាងអង្គាសភិក្ខុសង្ឃហើយ ឧទ្ទិសជូនចំណែកបុណ្យដល់ខ្ញុំផង ។ បណ្ណាការយ៉ាងវិសេស នឹងមានដល់ខ្ញុំយ៉ាងនេះឯង ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បុណ្យក្នុងទាននេះ សូមឲ្យជាបុណ្យដែលខ្ញុំបូជាហើយ ដើម្បីសេចក្ដីសុខដល់មហារាជ ឈ្មោះវេស្សវណចុះ ។ ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចម្លែកណាស់ ព្រោះនាងបានចរចាក្នុងទីចំពោះមុខ ជាមួយនឹងមហារាជឈ្មោះវេស្សវណ ជាទេវបុត្តមានឫទ្ធិធំយ៉ាងនេះ មានសក្តិធំយ៉ាងនេះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យចម្លែករបស់ខ្ញុំទេ នៅមានធម៌ឯទៀត ដែលអស្ចារ្យចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងគ្រានេះ ខ្ញុំមានកូនប្រុសម្នាក់ឈ្មោះនន្ទៈ ជាទីស្រឡាញ់ ជាទីពេញចិត្ត ព្រះរាជាទាំងឡាយ ចាប់ទាញកំហែងកូននោះ ព្រោះហេតុនីមួយមកផ្ដាច់ជីវិត បពិត្រលោកម្ចាស់ដ៏ចម្រើន កាលទារកនោះ គេចាប់យកទៅហើយក្ដី កំពុងចាប់ក្ដី សម្លាប់ហើយក្ដី កំពុងសម្លាប់ក្ដី បៀតបៀនហើយក្ដី កំពុងបៀតបៀនក្ដី ខ្ញុំម្ចាស់មិនដឹងនូវសេចក្ដីប្រែប្រួលនៃចិត្តឡើយ ។ ម្នាលនាងនន្ទមាតា អស្ចារ្យណាស់ ម្នាលនាងនន្ទ-

មាតា ចម្លែកណាស់ កោតតែនាងជម្រះនូវហេតុត្រឹមតែការកើតឡើងនៃចិត្ត បាន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនអស្ចារ្យចម្លែកនៃខ្ញុំទេ នៅមានធម៌ឯទៀត អស្ចារ្យចម្លែករបស់ខ្ញុំ បពិត្រលោកដ៏ចម្រើន ក្នុងគ្រានេះ ស្វាមីរបស់ខ្ញុំធ្វើមរណកាលទៅ ក៏ទៅកើតក្នុងកំណើតនៃយក្សមួយ ស្វាមីរបស់ខ្ញុំនោះ សម្តែងនូវអត្តភាពដល់ខ្ញុំ ដូចក្នុងកាលមុន បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់មិនដឹងនូវសេចក្តីប្រែប្រួលនៃចិត្ត ដែលជាហេតុជាងនោះឡើយ ។ ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចម្លែកណាស់ កោតតែនាងជម្រះនូវហេតុ ត្រឹមតែការកើតឡើងនៃចិត្តបាន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នោះឯង មិនមែនអស្ចារ្យចម្លែករបស់ខ្ញុំទេ នៅមានធម៌ឯទៀត ជាអស្ចារ្យចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំម្ចាស់នៅក្រមុំ គេនាំមកឲ្យស្វាមីកំលោះ ខ្ញុំមិនដែលប្រព្រឹត្តកន្លងដោយចិត្តទេ មិនបាច់និយាយដល់ការប្រព្រឹត្តកន្លងដោយកាយឡើយ ។ ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចម្លែកណាស់ កោតតែនាងជម្រះនូវហេតុ ត្រឹមតែការកើតឡើងនៃចិត្តបាន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នោះឯង មិនមែនជាអស្ចារ្យចម្លែករបស់ខ្ញុំទេ នៅមានធម៌ឯទៀត ជាអស្ចារ្យ ចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំម្ចាស់សម្តែងខ្លួន ជាឧបាសិកាឡើង មិនធ្លាប់ក្លែងប្រព្រឹត្តកន្លងនូវសិក្ខាបទណាមួយទេ ។ ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចម្លែកណាស់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន

ធម៌នោះឯង មិនមែនជាអស្ចារ្យចម្លែករបស់ខ្ញុំទេ នៅមានធម៌ឯទៀត ជាអស្ចារ្យចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ប៉ុនប៉ងជាបមក ក្នុងទីនេះថា ខ្ញុំស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិ និងសុខ កើតអំពីសេចក្ដីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្ដានខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិ និងសុខ កើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះវិនាសទៅនៃបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង ខ្ញុំជាអ្នកនឹករឭក ដឹងច្បាស់ ទទួលនូវសុខដោយនាមកាយផង បានដល់នូវតតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយ តែងសរសើរថា បុគ្គលមានសតិប្រកបដោយឧបេក្ខា នៅជាសុខ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង វិនាសទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុនផង ខ្ញុំក៏បានដល់នូវចតុត្ថជ្ឈាន មានសតិដ៏បរិសុទ្ធដោយឧបេក្ខា មិនជាទុក្ខមិនជាសុខ ។ ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចម្លែកណាស់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌នេះឯង មិនមែនជាអស្ចារ្យចម្លែករបស់ខ្ញុំទេ នៅមានធម៌ឯទៀត ជាអស្ចារ្យចម្លែករបស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចម្រើន សញ្ញោជនៈខាងក្រោមទាំង ៥ ណា ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ បណ្ដាសញ្ញោជនៈទាំងនោះ ខ្ញុំម្ចាស់ពិចារណាមិនឃើញ នូវសញ្ញោជនៈណាមួយក្នុងខ្លួន ដែល

មិនទាន់លះបង់សោះឡើយ ។ ម្នាលនន្ទមាតា អស្ចារ្យណាស់ ម្នាលនន្ទមាតា ចម្លែកណាស់ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ញុំាងនន្ទមាតាឧបាសិកា ឲ្យឃើញច្បាស់ ឲ្យប្រតិបត្តិតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក្រោកចាកអាសនៈចេញទៅ ។

មហាយញ្ញវគ្គទី ៥ ចប់

## ឧទ្ទាននៃមហាយញ្ញវគ្គនោះគឺ

និយាយអំពីចិត្ត ១ បរិក្ខារ ១ អំពីភ្លើងពីរលើក
អំពីសញ្ញា ២ លើកទៀត អំពីមេថុន ១ អំពីសញ្ញោគ
និងវិសញ្ញោគ ១ អំពីទាន ១ អំពីនន្ទមាតាឧបាសិកា
១ រួមជា ១០ ។

បណ្ណាសក ចប់

# អដ្ឋកថា

## នន្ទមាតាសូត្រ

[ ៥០ ] មាតាសូត្រទី ១០ ព្រះមានព្រះភាគ ទ្រង់សម្ដែងដោយអត្ថុប្បត្តិហេតុ ដូចតទៅនេះ

បានឮថា ព្រះសាស្ដាទ្រង់ចាំវស្សា បវារណាហើយ ទ្រង់លះអគ្គសាវក

ទាំងពួង ទ្រង់ចេញទៅ ដោយបំណងនឹងចារិកក្នុងទក្ខិណាគិរីជនបទ ។ ព្រះបាទបសេនទិកោសល អនាថបិណ្ឌិកគហបតី វិសាខាមហាឧបាសិកា និងជនដទៃជាច្រើន មិនអាចឲ្យព្រះសាស្តាត្រឡប់បាន អនាថបិណ្ឌិកគហបតីអង្គុយគិតក្នុងទីកំបាំងថា អញមិនអាចឲ្យព្រះសាស្តាយាងត្រឡប់បាន ។ គ្រានោះ នាងទាសីឈ្មោះបុណ្ណា ឃើញសេដ្ឋីហើយ ទើបសួរថា លោកម្ចាស់មានឥន្ទ្រិយមិនផូរផង់ដូចអំពីមុន ព្រោះហេតុអ្វីហ្ន៎ គហបតីឆ្លើយថា អើ ! បុណ្ណា ព្រះសាស្តាយាងទៅកាន់ទីចារិកហើយ អញមិនអាចធ្វើព្រះអង្គ ឲ្យត្រឡប់បានផង មិនជ្រាបថា ព្រះអង្គយាងត្រឡប់មកឆាប់ឬហ្ន៎ផង ព្រោះហេតុនោះ ទើបអញអង្គុយគិត ។ ទាសីសួរថា បើខ្ញុំឲ្យព្រះទសពលត្រឡប់បាន លោកសេដ្ឋីធ្វើដូចម្ដេចដល់ខ្ញុំ ។ គហបតីឆ្លើយថា អញនឹងធ្វើឯងឲ្យជាអ្នកជា ។ ទាសីទៅថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាយាងត្រឡប់ចុះ ។ ព្រះសាស្តាត្រាស់ថា ព្រោះហេតុដែលតថាគតត្រឡប់ នាងនឹងធ្វើដូចម្ដេច ទាសីទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ជ្រាបថា ខ្ញុំម្ចាស់ជាអ្នកអាស្រ័យអ្នកដទៃ ខ្ញុំម្ចាស់មិនអាចធ្វើអ្វីដទៃបាន តែខ្ញុំម្ចាស់នឹងតាំងនៅក្នុងសរណៈ រក្សាសីល ៥ ។ ព្រះសាស្តាត្រាស់ថា សាធុ សាធុ បុណ្ណា ហើយទ្រង់យាងត្រឡប់ ត្រឹមតែឈានព្រះបាទទៅមួយប៉ុណ្ណោះ ព្រោះសេចក្ដីគោរពក្នុងធម៌ សមដូចព្រះតម្រាស់ដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតគោរពក្នុងធម៌ មានធម៌

*ជាទីគោរព ។ ព្រះសាស្តាយាងត្រឡប់ចូលកាន់ជេតពនមហាវិហារ ។ មហាជន បានឲ្យសាធុការមួយពាន់ដល់នាងបុណ្ណា ព្រះសាស្តាទ្រង់សម្តែងធម៌ក្នុង សមាគមនោះ សត្វ ៨៤០០០ ផឹកនូវអមតៈហើយ ។ ចំណែកនាងបុណ្ណា ដែលសេដ្ឋីអនុញ្ញាត បានទៅកាន់សម្នាក់របស់ភិក្ខុនី ហើយបួស ។ ព្រះ សម្មាសម្ពុទ្ធឲ្យត្រាស់ហៅព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានមកហើយ ត្រាស់ថា តថាគតចេញចារិកទៅក្នុងទិសណា តថាគតមិនទៅក្នុងទិសនោះ ពួកអ្នក មួយអន្លើនឹងបរិស័ទរបស់អ្នក ចូរចារិកទៅក្នុងទិសនោះ ដូច្នេះហើយ ទើបបញ្ជូនទៅ ពាក្យថា* **ឯកំ សមយំ អាយស្មា សារីបុត្តោ** *ជាដើម ព្រះមានព្រះភាគ ត្រាស់ព្រោះអត្ថុប្បត្តិហេតុនៃរឿងនេះ ។*

*បណ្តាបទទាំងនោះ បទថា* **វេឡុកណ្ឌកី** *បានដល់ អ្នកនៅក្នុងក្រុង វេឡុកណ្ឌកៈ ។ បានឮថា អ្នកក្រុងទាំងនោះនាំគ្នាដាំដើមឫស្សីជុំវិញកំពែង ដើម្បីរក្សាកំពែងក្រុងនោះ ។ ព្រោះហេតុនោះ ទើបក្រុងនោះឈ្មោះថា វេឡុ-កណ្ឌកៈនោះ ។ បទថា* **ចារាយនំ** *សេចក្តីថា នូវធម៌ដែលបានវោហារថា បារាយនៈ ព្រោះដំណើរទៅដល់ត្រើយ គឺព្រះនិព្វាន ។ បទថា* **សរេន ភាសតិ** *សេចក្តីថា នន្ទមាតាអរិយសាវិកាអង្គុយក្នុងទីមានការរក្សា ដែលគេ រៀបចំទុកល្អហើយ លើប្រាសាទជាន់ទី ៧ ឲ្យកន្លះរាត្រីកន្លងទៅ ដោយកម្លាំង នៃសមាបត្តិ កាលចេញចាកសមាបត្តិហើយ គិតថា អញនឹងឲ្យរាត្រីដ៏សេស មានប្រមាណប៉ុណ្ណោះកន្លងទៅ ដោយការត្រេកអរត្រឹមណា ហើយធ្វើការ*

សម្រេចថា នឹងឲ្យកន្ទេលទៅ ដោយការត្រេកអរក្នុងធម៌ ដូច្នេះហើយ អន្ទុយ សម្រេចផល ៣ ទើបពោលបារាយនសូត្រប្រមាណ ២៥០ គាថា ដោយ ទំនងសរភញ្ញដ៏ពីរោះ ។

បទថា **អស្សោសិ ខោ** សេចក្តីថា ស្តេចវេស្សវណមហារាជ ទ្រង់ពិនិត្យមើលវិមានដែលតាំងនៅក្នុងអាកាសហើយ ឡើងកាន់យាននាវាហនៈ យានចេញទៅដោយផ្លូវដែលឆ្លងកាត់ខាងលើប្រាសាទនោះ បានឮសំឡេងបារាយនសូត្រហើយ ។ បទថា **កថាបរិយោសានំ អាគមយមានោ អដ្ឋាសិ** សេចក្តីថា វេស្សវណមហារាជ កាលត្រាស់សួរថា នែអ្នក នុ៎ះសំឡេងអ្វី កាលយក្ខបរិស័ទទូលថា នុ៎ះសំឡេងសូធ្យដោយទំនងសរភញ្ញរបស់នន្ទមាតាឧបាសិកា ដូច្នេះហើយ ទ្រង់ចុះរង់ចាំការចប់ទេសនានេះថា **ឥធមវោច** ហើយ ប្រថាប់ឈរលើអាកាសក្នុងទីមិនឆ្ងាយពេក ។ បទថា **សាធុ ភគិនិ សាធុ ភគិនិ** សេចក្តីថា វេស្សវណមហារាជត្រាស់ថា បងស្រី ព្រះធម្មទេសនា បងទទួលមកល្អហើយ ពោលល្អហើយ ខ្ញុំមិនឃើញអ្វីដែលផ្សេងគ្នារវាងថ្ងៃដែលព្រះសម្មាសម្ពុទ្ធប្រថាប់ត្រង់បាសាណកចេតិយ ត្រាស់ដល់បារាយនិកព្រាហ្មណ៍ ១៦ នាក់ និងទីនេះ បងពោលថ្ងៃនេះ ពាក្យដែលបងពោលហើយ ដូចគ្នានឹងព្រះតម្រាស់ព្រះសាស្តាត្រាស់ហើយនោះឯង ដូចគ្នានឹងមាសដែលបាក់ត្រង់កណ្តាល កាលនឹងឲ្យសាធុការ ទើបត្រាស់យ៉ាងនោះ ។

បទថា **កោ បនេសោ ភទ្ទមុខ** សេចក្តីថា ព្រោះសំឡេងដែលខ្លាំង

ដល់ម្ទេះ រំពងទៅក្នុងទីដែលមានការរក្សាទុក ដូច្នេះ នន្ទមាតាអរិយសាវិកា ជាអ្នកសម្រេចផល ៣ ហើយ ប្រាសចាកការខ្លាច ចិទបន្លិច មានពណ៌ដូចផ្កាំងមាស ពោលថា បុរសមានមាត់ល្អ បុរសមានមាត់ស្អាត អ្នកជានរណា ជានាគ គ្រុឌ ទេវតា មារ ឬជាព្រហ្ម ដូច្នេះហើយ កាលនឹងពោលជាមួយស្តេចវេស្សវ័ណ ទើបពោលយ៉ាងនេះ ។ បទថា **អបាគ្គ ភគិនិ ភាតា** សេចក្តីថា ស្តេចវេស្សវ័ណទ្រង់សម្គាល់ព្រះអរិយសាវិកា ដែលជាព្រះអនាគាមីថាជាបង ព្រោះព្រះអង្គឯង ជាសោតាបន្ន ទើបត្រាស់ថា **ភគិនី** ហើយទើបសម្គាល់ព្រះអរិយសាវិកា ដែលជាព្រះអនាគាមីនោះថាជាប្អូនរបស់ទ្រង់ទៀត ព្រោះនាងនៅក្នុងបឋមវ័យ ព្រះអង្គចាស់ជាង ព្រោះព្រះអង្គមានព្រះជន្មាយុ ៩ លានឆ្នាំហើយ ទើបត្រាស់ហៅព្រះអង្គឯងថា **ភាតា** គឺបងប្រុស ដូច្នេះ ។

បទថា **សាធុ ភទ្រមុខ** សេចក្តីថា អ្នកមានភក្ត្រដ៏ចម្រើន ការមករបស់អ្នកជាប្រយោជន៍ ជាការល្អ ជាការមកល្អ អធិប្បាយថា មកក្នុងឋានៈដែលសមដែលនឹងមកពិត ។ បទថា **ឥទំ តេ ហោតុ អាតិថេយ្យំ** សេចក្តីថា សូមការពោលធម៌នេះឯង ជាបណ្ណាការយ៉ាងល្អក្រៃលែងសម្រាប់អ្នក ព្រោះខ្ញុំមិនឃើញវត្ថុដទៃដែលគួរឲ្យដល់អ្នកដ៏ក្រៃលែងជាងនេះឡើយ ។ ពាក្យថា **ឯវញ្ច មេ ភវិស្សតិ អាតិថេយ្យំ** សេចក្តីថា ព្រះបាទវេស្សវ័ណនោះ កាលសូមបត្តិទានដើម្បីខ្លួនយ៉ាងនេះហើយ ពោលថា នេះជាសក្ការៈដើម្បីភាពជា

ព្រះធម្មកថិករបស់នាង ធ្វើជង្រុក ១២៥០ ឲ្យពេញដោយស្រូវសាលីក្រហម ហើយអធិដ្ឋានថា ចូរស្រូវទាំងនេះកុំអស់ទៅ ដរាបណាឧបាសិកានេះនៅ ត្រាច់ទៅ ហើយក៏ចៀសចេញទៅ ។ ជនទាំងឡាយមិនអាចឃើញបាតខាង ក្រោមរបស់ជង្រុក ដរាបណាឧបាសិកានៅមានជីវិត ។ តាំងអំពីនោះមក ទើបកើតវោហារឡើងថា **ឆន្នមាតាយ កោដ្ឋាគារំ វិយ** ដូចជង្រុករបស់ នន្ទមាតាៗ ។ បទថា **អកតបាតរាសោ** បានដល់ ដែលមិនទាន់បរិភោគ អាហារព្រឹក ។

បទថា **បុញ្ញំ** បានដល់ បុព្វចេតនា គឺចេតនាមុនឲ្យទាន និងមុញ្ចន-ចេតនា ចេតនាខណៈឲ្យទាន ។ បទថា **បុញ្ញមហិតំ** បានដល់ អបរចេតនា ចេតនាខាងក្រោយឲ្យទានហើយ ។ បទថា **សុខាយ ហោតុ** សេចក្តីថា ចូរ មានដើម្បីជាប្រយោជន៍ដល់សេចក្តីសុខ ដើម្បីជាប្រយោជន៍ដល់ឧបការៈ នន្ទមាតាអរិយសាវិកាបានឲ្យបត្តិទាន ដល់ព្រះបាទវេស្សវណក្នុងទានរបស់ ខ្លួន ដោយប្រការដូច្នេះ ។ បទថា **បករណោ** បានដល់ ក្នុងហេតុ ។ បទថា **ឱក្កន្តស្ស បសយ្ហ** បានដល់ ប្រានមក គ្របសង្កត់ហើយ ។ បទថា **យក្ខ-យោនឹ** បានដល់ ការកើតជាភុម្មទេវតា ។ បទថា **តេនេវ បរិមេន អត្ត-**

**ភាវេន ឧទ្ធស្សេសិ** *សេចក្តីថា កុម្ភទេវតានោះនិម្មិតរាងកាយឲ្យដូចរាងកាយចាស់នោះឯង ប្រដាប់តាក់តែងហើយ បង្ហាញខ្លួនត្រង់ទីដេក ក្នុងបន្ទប់ដ៏មានសិរី ។ បទថា* **ឧបាសិកា បដិវេទិតា** *សេចក្តីថា សម្តែងភាពដែលខ្លួនជាឧបាសិកាយ៉ាងនេះថា ខ្ញុំជាឧបាសិកា ដូច្នេះ ។ បទថា* **យាវទេ** *ប្រែថា ដរាបណានោះឯង ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ហើយ ៕*

**អដ្ឋកថា ឆន្ទមាតាសូត្រទី ១០ ចប់**

**មហាយញ្ញវគ្គទី ៥ ចប់**

**បឋមវណ្ណាសក ចប់**

# សុត្តន្តបិដក
# បណ្ណាសកាសង្គហិតវគ្គ

## អព្យាកតវគ្គ
### អព្យាកតសូត្រទី ១

[ ៥១ ] គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យវិចិកិច្ឆារបស់អរិយសាវក អ្នកមានសេចក្តីចេះដឹង មិនកើតឡើង ក្នុងអព្យាកតវត្ថុទាំងឡាយ ។ ម្នាលភិក្ខុ វិចិកិច្ឆារបស់អរិយសាវក អ្នកមានសេចក្តីចេះដឹងរមែងមិនកើតឡើង ក្នុងអព្យាកតវត្ថុទាំងឡាយ ព្រោះរលត់ទិដ្ឋិ ។ ម្នាលភិក្ខុ ទិដ្ឋិកើតឡើងថា សត្វស្លាប់ទៅរមែងកើតទៀត ម្នាលភិក្ខុ ទិដ្ឋិកើតឡើងថា សត្វស្លាប់ទៅមិនកើតទៀត ម្នាលភិក្ខុ ទិដ្ឋិកើតឡើងថា សត្វស្លាប់ទៅរមែងកើតទៀតក៏មាន មិនកើតទៀតក៏មាន ម្នាលភិក្ខុ ទិដ្ឋិកើតឡើងថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ ម្នាលភិក្ខុ បុថុជ្ជនអ្នកមិនចេះដឹង រមែងមិនដឹងច្បាស់នូវទិដ្ឋិ មិនដឹងច្បាស់នូវហេតុ ជាទីកើតឡើងនៃទិដ្ឋិ មិនដឹងច្បាស់នូវសេចក្តីរលត់ទៅនៃទិដ្ឋិ មិនដឹងច្បាស់នូវបដិបទា ដែល

ដល់នូវការរលត់ទៅនៃទិដ្ឋិ ទិដ្ឋិនោះរមែងចម្រើនដល់បុថុជ្ជននោះ បុថុជ្ជននោះ រមែងមិនរួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីតានតឹង តថាគត ហៅថា រមែងមិនរួចចាកវដ្តទុក្ខឡើយ ។ ម្នាលភិក្ខុ អរិយសាវកអ្នកមានសេចក្តីចេះដឹង រមែងដឹងច្បាស់នូវទិដ្ឋិ ដឹងច្បាស់នូវហេតុជាទីកើតឡើងនៃទិដ្ឋិ ដឹងច្បាស់នូវសេចក្តីរលត់ទៅនៃទិដ្ឋិ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ទីរលត់ទៅនៃទិដ្ឋិ ទិដ្ឋិនោះរបស់អរិយសាវកនោះ រមែងរលត់ទៅ អរិយសាវកនោះ ទើបរួចស្រឡះចាកជាតិ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីតានតឹង តថាគត ហៅថា រមែងរួចស្រឡះចាកវដ្តទុក្ខ ។ ម្នាលភិក្ខុ អរិយសាវកអ្នកមានសេចក្តីចេះដឹង កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ រមែងមិនពោលថា សត្វស្លាប់ទៅ កើតទៀតដូច្នេះខ្លះ មិនពោលថា សត្វស្លាប់ទៅ មិនកើតទៀតដូច្នេះខ្លះ មិនពោលថា សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះខ្លះ ។ ម្នាលភិក្ខុ អរិយសាវក អ្នកមានសេចក្តីចេះដឹង កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ជាអ្នកមានកិរិយាមិនពោលជាធម្មតាក្នុងអព្យាកតវត្ថុទាំងឡាយយ៉ាងនេះឯង ។ ម្នាលភិក្ខុ អរិយសាវក អ្នកមានសេចក្តីចេះដឹង កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបមិនរន្ធត់ មិនចំប្រប់ មិនញាប់ញ័រ មិនដល់នូវសេចក្តីតក់ស្លុតក្នុងអព្យាកតវត្ថុទាំងឡាយទេ ។ ម្នាលភិក្ខុ តណ្ហា សញ្ញា មានះ បបញ្ចធម៌ ( សេចក្តីយឺតយូរ ) ឧបាទាន និង

វិប្បដិសារៈនុ៎ះកើតឡើងថា សត្វស្លាប់ទៅ កើតទៀតក៏មាន ម្នាលភិក្ខុ វិប្ប-ដិសារៈនុ៎ះកើតឡើងថា សត្វស្លាប់ទៅ មិនកើតទៀតក៏មាន ម្នាលភិក្ខុ វិប្ប-ដិសារៈនុ៎ះកើតឡើងថា សត្វស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ម្នាលភិក្ខុ វិប្បដិសារៈនុ៎ះកើតឡើងថា សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ ម្នាលភិក្ខុ បុថុជ្ជន អ្នកមិនមានសេចក្តីចេះដឹង រមែងមិនដឹងច្បាស់នូវវិប្បដិសារៈ មិនដឹងច្បាស់នូវហេតុ ជាទីកើតឡើងនៃវិប្បដិសារៈ មិនដឹងច្បាស់នូវសេចក្តីរលត់ទៅនៃវិប្បដិសារៈ មិនដឹងច្បាស់នូវបដិបទា ដែលដល់នូវការរលត់ទៅនៃវិប្បដិសារៈ វិប្បដិសារៈនោះ របស់បុថុជ្ជននោះ រមែងចម្រើនឡើង បុថុជ្ជននោះ រមែងមិនរួចចាកជាតិ ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខ ទោមនស្ស សេចក្តីតានតឹង តថាគតពោលថា រមែងមិនរួចចាកវដ្តទុក្ខឡើយ ។ ម្នាលភិក្ខុ លុះតែអរិយសាវក អ្នកមានសេចក្តីចេះដឹង ទើបដឹងច្បាស់នូវវិប្បដិសារៈ ដឹងច្បាស់នូវហេតុជាទីកើតឡើងនៃវិប្បដិសារៈ ដឹងច្បាស់នូវសេចក្តីរលត់នៃវិប្បដិសារៈ ដឹងច្បាស់នូវបដិបទា ដែលដល់នូវការរលត់នូវវិប្បដិសារៈ វិប្បដិសារៈនោះ របស់អរិយសាវកនោះ រមែងរលត់ទៅ ។បេ។ ម្នាលភិក្ខុ អរិយសាវកអ្នកមានសេចក្តីចេះដឹង កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបមិនខ្វែត មិនចំប្រប់ មិនញាប់ញ័រ មិនដល់នូវសេចក្តីតក់ស្លុតក្នុងអព្យាកតវត្ថុទាំងឡាយទេ ។ ម្នាលភិក្ខុ នេះជាហេតុ នេះជាបច្ច័យ ដែលនាំវិចិកិច្ឆារបស់

អរិយសាវក អ្នកមានសេចក្តីចេះដឹង មិនកើតឡើងក្នុងអព្យាកតវត្ថុទាំង-ឡាយ ។

# អដ្ឋកថា

# វគ្គដែលមិនសង្គ្រោះចូលក្នុងបណ្ណាសក

## អព្យាកតវគ្គទី ៦

### អព្យាកតសូត្រ

[ ៥១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអព្យាកតសូត្រទី ១ នៃអព្យាកតវគ្គទី ៦ ដូចតទៅនេះ បទថា **អព្យាកតវត្ថូសុ** សេចក្តីថា ក្នុងវត្ថុដែលព្រះមានព្រះភាគមិនបានត្រាស់ដោយព្យាករ មានឯកង្សព្យាករជាដើម ។ បទថា **តថាគតោ** បានដល់ សត្វ ។ បទថា **ទិដ្ឋិគតមេតំ** នេះ ត្រឹមតែជាមិច្ឆាទិដ្ឋិ ។ ឈ្មោះថា សត្វដែលមិនត្រូវទិដ្ឋិនោះប្រកាន់ មិនមាន ។ បទថា **បដិបទំ** បានដល់ អរិយមគ្គ ។ បទថា **ន ឆម្ភតិ** សេចក្តីថា រមែងមិនញាប់ញ័រដោយអំណាចទិដ្ឋិ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា

**តណ្ហាគតំ** សេចក្ដីថា តណ្ហាដែលសម្បយុត្តដោយទិដ្ឋិ ។ ក្នុងបទជាដើមថា **សញ្ញាគតំ** ក៏មានន័យនេះដូចគ្នា ។ ដ្បិតថា បណ្ដាបទទាំងនោះ សញ្ញាដែលសម្បយុត្តដោយទិដ្ឋិនោះឯង គប្បីជ្រាបថា **សញ្ញាគត** ដោយអត្ថថា ចាំ មានះដែលអាស្រ័យទិដ្ឋិនោះឯង ឬសញ្ញាដែលអាស្រ័យទិដ្ឋិនោះឯង គប្បីជ្រាបថា **មញ្ញិត** គឺការសម្គាល់ធម៌ដែលជាហេតុឲ្យយឺតយូរ ដែលអាស្រ័យទិដ្ឋិនោះឯង គប្បីជ្រាបថា **បបញ្ចិត** គឺធម៌ជាហេតុឲ្យយឺតយូរ ឧបាទាន គឺការប្រកាន់មាំ ដោយអំណាចទិដ្ឋិនោះឯង គប្បីជ្រាបថា ជាឧបាទាន ការៈ គឺការវិលវរញកខុសដោយទិដ្ឋិនោះឯង គប្បីជ្រាបថា ឈ្មោះថា **វិប្បដិសារ** គឺការក្ដៅក្រហាយចិត្ត ។ ក្នុងព្រះសូត្រនេះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់កាន់យកទិដ្ឋិ ៦២ ដោយ **ទិដ្ឋិ** សព្ទ ហើយទ្រង់កាន់យកសោតាបត្តិមគ្គនោះឯង ដោយ **ទិដ្ឋិនិរោធគាមិនីបដិបទា** សព្ទ ។៚

## អដ្ឋកថាអព្យាកតសូត្រទី ១ ចប់

# សុត្តន្តបិដក

## បុរិសគតិសូត្រទី ២

[ ៥២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវគតិ របស់បុរស ទាំង ៧ ប្រការផង នូវអនុបាទាបរិនិព្វានផង ចូរអ្នកទាំងឡាយស្តាប់នូវធម៌ នោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួល ស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះ ភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះគតិរបស់បុរស ៧ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិ យ៉ាងនេះ រមែងបាននូវឧបេក្ខាថា បើកម្ម ( ដែលញុំាងសត្វឲ្យកើតក្នុងអត្តភាព នេះ ) មិនធ្លាប់មានទេ អត្តភាពរបស់អញក៏មិនមាន ( ក្នុងកាលឥឡូវនេះដែរ ) បើកម្ម ( ដែលញុំាងសត្វឲ្យកើតក្នុងអនាគត ) របស់អញមិនមាន ( ក្នុងកាល ឥឡូវនេះ ) ទេ អត្តភាពរបស់អញ ( ក្នុងអនាគត ) ក៏មិនមានដែរ ខន្ធបញ្ចកៈ ណាដែលកើតមាន អញលះបង់នូវខន្ធបញ្ចកៈនោះចេញ ។ ភិក្ខុនោះ មិន ត្រេកអរក្នុងភព មិនជាប់ជំពាក់ក្នុងសម្ភវៈ រមែងឃើញនូវព្រះនិព្វាន ជាចំណែក ដ៏ស្ងប់ក្រៃលែង ដោយបញ្ញាដ៏ប្រពៃ តែព្រះនិព្វាននោះ ភិក្ខុនោះ មិនទាន់បាន ធ្វើឲ្យជាក់ច្បាស់ ដោយសព្វគ្រប់នៅឡើយ ភិក្ខុនោះ មិនទាន់លះបង់មានា- នុស័យ ដោយសព្វគ្រប់នៅឡើយ មិនទាន់លះបង់ភវរាគានុស័យ ដោយសព្វ គ្រប់នៅឡើយ មិនទាន់លះបង់អវិជ្ជានុស័យ ដោយសព្វគ្រប់នៅឡើយ ។ ភិក្ខុនោះឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែក

ខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាអំបែងដែក ដែលក្ដៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមរផ្កាភ្លើងខ្ទាត់ឡើង ហើយរលត់ទៅវិញយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ រមែងបាននូវឧបេក្ខាថា បើកម្ម ( ដែលញ៉ាំងសត្វឲ្យកើតក្នុងអត្តភាព កន្លងមកហើយ ) មិនធ្លាប់មានទេ អត្តភាពរបស់អញ ( ក្នុងកាលឥឡូវនេះ ) ក៏មិនមានដែរ បើកម្ម ( ដែលញ៉ាំងសត្វឲ្យកើតក្នុងអនាគត ) មិនមានទេ អត្តភាពរបស់អញ ( ក្នុងអនាគត ) ក៏មិនមានដែរ ខន្ធបញ្ចកៈណាដែលកើតមាន អញលះបង់នូវខន្ធបញ្ចកៈនោះចេញ ។ ភិក្ខុនោះមិនត្រេកអរក្នុងភព មិនជាប់ជំពាក់ក្នុងសម្ភវៈ រមែងឃើញនូវព្រះនិព្វាន ជាចំណែកស្ងប់ដ៏ក្រៃលែង ដោយបញ្ញាដ៏ប្រពៃ តែព្រះនិព្វាននោះ ភិក្ខុនោះមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ដោយសព្វគ្រប់នៅឡើយ មិនទាន់បានលះបង់មានានុស័យ ដោយសព្វគ្រប់នៅឡើយ មិនទាន់បានលះបង់ភវ-រាគានុស័យ ដោយសព្វគ្រប់នៅឡើយ មិនទាន់បានលះបង់ អវិជ្ជានុស័យ ដោយសព្វគ្រប់នៅឡើយ ។ ភិក្ខុនោះឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ រមែងបាននូវឧបេក្ខាថា បើកម្ម ( ដែលញ៉ាំងសត្វឲ្យកើតក្នុងអត្តភាពនេះ ) មិនធ្លាប់មានទេ អត្តភាពរបស់អញ ក៏មិនមាន ( ក្នុងកាលឥឡូវនេះដែរ ) បើកម្ម ( ដែលញ៉ាំងសត្វឲ្យកើតក្នុងអនាគត ) របស់អញមិនមាន ( ក្នុងកាលឥឡូវនេះទេ ) អត្តភាពរបស់អញ ( ក្នុងអនាគត )

ក៏មិនមាន ខន្ធបញ្ចកៈណាដែលកើតមាន អញលះបង់នូវខន្ធបញ្ចកៈនោះចេញ ។ ភិក្ខុនោះមិនត្រេកអរក្នុងភព មិនជាប់ជំពាក់ក្នុងសម្ភវៈ រមែងឃើញនូវព្រះនិព្វាន ជាចំណែកដ៏ស្ងប់ក្រៃលែង ដោយបញ្ញាដ៏ប្រពៃ តែព្រះនិព្វាននោះ ភិក្ខុនោះមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ដោយសព្វគ្រប់នៅឡើយ មិនទាន់លះបង់មានានុស័យ ដោយសព្វគ្រប់នៅឡើយ មិនទាន់លះបង់ភវរាគានុស័យ ដោយសព្វគ្រប់នៅឡើយ មិនទាន់លះបង់អវិជ្ជានុស័យ ដោយសព្វគ្រប់នៅឡើយ ភិក្ខុនោះ ឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែក ដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមវផ្កាភ្លើងខ្ទាត់អណ្តែតឡើង ហើយរលត់បាត់ទៅវិញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះ ឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែកដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមវផ្កាភ្លើងខ្ទាត់អណ្តែតឡើងទៅទល់ផ្ទៃ ( ខាងលើ ) ហើយរលត់បាត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែក

ខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា ឧបហច្ចបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែក ដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលជំ ក្រមផ្កាភ្លើង ខ្ទាត់អណ្តែតឡើងទៅទល់ផ្ទៃ ( ខាងលើ ) ហើយរលត់បាត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា ឧបហច្ចបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា អសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែកដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលជំ ក្រមផ្កាភ្លើងខ្ទាត់អណ្តែតឡើង ហើយធ្លាក់ទៅលើគំនរស្មៅ ឬគំនរឧសដែលមានប្រមាណតិច ផ្កាភ្លើងនោះ គប្បីញុំាងភ្លើងក្នុងគំនរទាំងនោះ ឲ្យកើតឡើងផង ញុំាងផ្សែងឲ្យកើតឡើងផង លុះញុំាងភ្លើងឲ្យកើត ញុំាងផ្សែងឲ្យកើតឡើងហើយ ក៏ឆាបឆេះនូវគំនរស្មៅ ឬគំនរឧសមានប្រមាណតិចនោះឯង ឲ្យទៅជារបស់ខ្ទេចខ្ទី ហើយរលត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះ ឈ្មោះថា អសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំង-

ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា សសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែកដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមរផ្កាភ្លើងខ្ទាត់អណ្តែតឡើងទៅ ហើយធ្លាក់ចុះលើគំនរស្មៅ ឬគំនរឧសដ៏ធំ ផ្កាភ្លើងនោះ គប្បីញុំាងភ្លើងក្នុងគំនរទាំងនោះ ឲ្យកើតឡើងផង ញុំាងផ្សែងឲ្យកើតឡើងផង លុះញុំាងភ្លើងឲ្យកើត ញុំាងផ្សែងឲ្យកើតឡើងហើយ ក៏ឆាបឆេះនូវគំនរស្មៅ ឬគំនរឧសដ៏ធំនោះឯង ឲ្យទៅជារបស់ខ្ទេចខ្ទីហើយរលត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះ ឈ្មោះថា សសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុ ប្រៀបដូចអំបែងដែក ដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមរផ្កាភ្លើងខ្ទាត់អណ្តែតឡើង ហើយធ្លាក់ចុះលើគំនរស្មៅ ឬគំនរឧសច្រើន ផ្កាភ្លើងនោះ គប្បីញុំាងភ្លើងក្នុងគំនរទាំងនោះ ឲ្យកើតឡើងផង ញុំាងផ្សែងឲ្យកើតឡើងផង លុះញុំាងភ្លើងឲ្យកើតឡើង ញុំាងផ្សែងឲ្យកើតឡើងហើយ ក៏ឆាបឆេះនូវគំនរស្មៅ ឬគំនរឧស គប្បីឆេះគុម្ពឈើ ( ដែលគ្មានគេរក្សា ) ខ្លះ ឆេះព្រៃ ( ដែលគេរក្សា ) ខ្លះ លុះឆេះគុម្ពឈើ ( ដែល

គ្មានគេរក្សា ) ឆេះព្រៃ ( ដែលគេរក្សា ) ហើយ ក៏ទៅជារបស់ខ្ទេចខ្ទី ហើយរលត់ទៅ ព្រោះអាស្រ័យនូវវត្ថុមានពណ៌ខៀវខ្លះ នូវថ្មខ្លះ នូវទឹកខ្លះ នូវចំណែកនៃផែនដីជាទីរីករាយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះ ឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ គតិនៃបុរសមាន ៧ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះអនុបា-ទាបរិនិព្វាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ រមែងបាននូវឧបេក្ខាថា បើកម្ម ( ដែលញុំាងសត្វឲ្យកើតក្នុងអត្តភាព ) មិនធ្លាប់មានទេ អត្តភាពរបស់អញក៏មិនមាន ( ក្នុងកាលឥឡូវនេះ ) បើកម្ម ( ដែលញុំាងសត្វឲ្យកើតក្នុងអនាគត ) របស់អញមិនមាន ( ក្នុងកាលឥឡូវនេះទេ ) អត្តភាពរបស់អញ ( ក្នុងអនាគត ) ក៏មិនមានដែរ ខន្ធបញ្ចកៈណាដែលកើតមាន អញលះបង់នូវខន្ធបញ្ចកៈនោះចេញ ។ ភិក្ខុនោះមិនត្រេកអរក្នុងភព មិនជាប់ជំពាក់ក្នុងសម្ភវៈ រមែងឃើញនូវព្រះនិព្វានជាចំណែកស្ងប់ដ៏ក្រៃលែង ដោយបញ្ញាដ៏ប្រពៃ ទាំងព្រះនិព្វាននោះ ភិក្ខុនោះក៏បានធ្វើឲ្យជាក់ច្បាស់ដោយសព្វគ្រប់ ភិក្ខុនោះបានលះបង់មានានុស័យ ដោយសព្វគ្រប់ បានលះបង់នូវភវរាគានុស័យ ដោយសព្វគ្រប់ បានលះបង់នូវអវិជ្ជានុស័យ ដោយសព្វគ្រប់ ។ ភិក្ខុនោះព្រោះអស់ទៅនៃអាសវៈ ។បេ។ រមែងបានធ្វើឲ្យជាក់ច្បាស់សម្រេច ។ ម្នាលភិក្ខុ

*ទាំងឡាយ នេះហៅថា អនុបាទាបរិនិព្វាន ។ម្នាលភិក្ខុទាំងឡាយ គតិនៃបុរសមាន ៧ យ៉ាង និងអនុបាទាបរិនិព្វានយ៉ាងនេះឯង ។*

# អដ្ឋកថា

## បុរិសគតិសូត្រ

*[ ៥២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុរិសគតិសូត្រទី ២ ដូចតទៅនេះ បទថា* **បុរិសគតិយោ** *បានដល់ ញាណគតិរបស់បុរស ។ បទថា* **អនុបាទាបរិនិព្វានំ** *បានដល់ បរិនិព្វានដែលមិនមានបច្ច័យតាក់តែង ។ បទថា* **នោ ចស្ស** *សេចក្តីថា បើកម្មកើតឡើងក្នុងអត្តភាពដែលជាអតីតមិនមានហើយសោត ។ បទថា* **នោ ច មេ សិយា** *សេចក្តីថា ក្នុងអត្តភាពនេះក្នុងកាលឥឡូវនេះ កម្មក៏មិនគប្បីមានដល់អញ ។ បទថា* **ន ភវិស្សតិ** *សេចក្តីថា ឥឡូវនេះ កម្មដែលនឹងញុំាងអត្តភាពដែលជាអនាគតរបស់អាត្មាអញឲ្យកើតឡើង នឹងមិនមាន ។ បទថា* **ន មេ ភវិស្សតិ** *សេចក្តីថា អត្តភាពរបស់អាត្មាអញក្នុងអនាគត នឹងមិនមាន ។ បទថា* **យទត្ថិ យំ ភូតំ** *សេចក្តីថា បញ្ចក្ខន្ធដែលកំពុងមាន ដែលមានហើយ ដែលជាបច្ចុប្បន្នកើតឡើងចំពោះមុខ ។ បទថា* **តំ បជហាមីតិ ឧបេក្ខំ បដិលភតិ** *សេចក្តីថា រមែងបានឧបេក្ខាដែលសម្បយុត្តដោយវិបស្សនាញាណថា អញនឹងលះបង់*

បញ្ចក្ខន្ធនោះ ដោយការលះឆន្ទរាគៈក្នុងបញ្ចក្ខន្ធនោះចេញ ។ បទថា **ភវេ ន រជ្ជតិ** សេចក្តីថា រមែងមិនមានតម្រេកក្នុងបញ្ចក្ខន្ធដែលជាអតីត ដោយតណ្ហា និងទិដ្ឋិ ។ បទថា **សម្ភវេ ន រជ្ជតិ** សេចក្តីថា រមែងមិនមានតម្រេកក្នុងបញ្ចក្ខន្ធដែលជាអនាគតដូចគ្នានោះឯង ។ បទថា **អត្ថុត្តរិ បទំ សន្តំ** សេចក្តីថា ឈ្មោះថា បទ គឺព្រះនិព្វាន ជាសន្តិបទដ៏ក្រៃលែងមាន ។ បទថា **សម្មប្បញ្ញាយ បស្សតិ** សេចក្តីថា រមែងឃើញដោយប្រពៃនូវបទ គឺព្រះនិព្វាននោះ ដោយមគ្គប្បញ្ញា មួយអន្លើដោយវិបស្សនា ។ បទថា **ន សព្វេន សព្វំ** សេចក្តីថា បទទាំងពួង ដែលភិក្ខុធ្វើឲ្យជាក់ច្បាស់ហើយ ដោយអាការទាំងពួង ព្រោះលះកិលេសពួកខ្លះមិនទាន់បាន ព្រោះអវិជ្ជាដែលបិទបាំងសច្ចៈមិនទាន់កម្ចាត់បានដោយប្រការទាំងពួង ។ បទថា **ឋាញ្ញមានេ** សេចក្តីថា ដូចបន្ទះដែកដែលឆេះសន្ធោសន្ធៅ ដែលនាយជាងយកអន្ទឹចាប់ហើយយកញញួរដំ ។ បទថា **អន្តរាបរិនិព្វាយី** សេចក្តីថា ចាប់តាំងអំពីកាលដែលជាលំដាប់អំពីហេតុកើតឡើង ព្រះអនាគាមិបុគ្គល មិនកន្លងពាក់កណ្តាលអាយុ ហើយបរិនិព្វានដោយកិលេស បរិនិព្វានក្នុងចន្លោះនេះ ។ បទថា **អនុបហច្ចតលំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងអន្តរាបរិនិព្វាយិបុគ្គល ៣ ពួក ដោយឧបមាទាំងឡាយ ៣ គឺកម្ទេចផ្កាភ្លើងមិនហើរទៅក្នុងអាកាស មិនធ្លាក់មកប៉ះផែនដី រលត់ក្នុងអាកាសនោះឯង ។

បទថា **ឧបហច្ចបរិនិព្វាយី** សេចក្តីថា ព្រះអនាគាមិបុគ្គលកន្លងពាក់

*កណ្តាលអាយុ ទល់គ្នានឹងចិត្តដួងចុងក្រោយ ហើយបរិនិព្វាន ។ បទថា* **ឧបហច្ចតលំ** *សេចក្តីថា កម្ទេចភ្លើងធំហើរទៅលើអាកាសធ្លាក់ចុះមកប៉ះផែនដីប៉ុណ្ណោះក៏រលត់ទៅ ។*

*ព្រះអនាគាមិបុគ្គល ដែលធ្វើកិលេសទាំងឡាយឲ្យអស់ទៅ ដោយមិនមានសង្ខារជទៃជាស់តឿន គឺដោយមិនមានសេចក្តីព្យាយាម ហើយបរិនិព្វាន ព្រោះហេតុនោះ ទើបព្រះអនាគាមីនោះ ឈ្មោះថា អសង្ខារបរិនិព្វាយី គឺបុគ្គលបរិនិព្វាន ដោយមិនចាំបាច់មានសង្ខារជទៃជួយជាស់តឿន ។*

*ព្រះអនាគាមិបុគ្គល ដែលធ្វើកិលេសទាំងឡាយឲ្យអស់ទៅ ដោយមានសង្ខារជទៃជួយជាស់តឿន ត្រូវប្រកបព្យាយាម ហើយបរិនិព្វាន ព្រោះហេតុនោះ ទើបឈ្មោះថា សសង្ខារបរិនិព្វាយី គឺបុគ្គលដែលបរិនិព្វានដោយមានសង្ខារជទៃជួយជាស់តឿន ។*

*បទថា* **គច្ឆំ** *សេចក្តីថា ព្រៃដែលប្រាសចាកការរក្សា ។ បទថា* **ទាយំ** *សេចក្តីថា ព្រៃមានការរក្សា គឺដែលលោកឲ្យដើម្បីប្រយោជន៍ដល់ការអភ័យហើយ ។ ពាក្យដ៏សេស ក្នុងបទទាំងនោះ មានអត្ថងាយយល់ហើយ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់ព្រះអរិយបុគ្គលទាំងឡាយដូច្នេះឯង ។*

## អដ្ឋកថាបុរិសគតិសូត្រទី ២ ចប់

# សុត្តន្តបិដក

## តិស្សសូត្រទី ៣

[ ៥៣ ] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ ទេវតាពីរអង្គ កាលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ បានធ្វើភ្នំគិជ្ឈកូដទាំងអស់ឲ្យភ្លឺហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតាមួយអង្គ ឋិតនៅក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីទាំងនោះរួចស្រឡះហើយ ( ចាកកិលេស ) ទេវតាមួយអង្គទៀត បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីទាំងនោះបានជាអនុបាទិសេសនិព្វាន រួចស្រឡះដោយប្រពៃ ( ចាកកិលេស ) លុះទេវតាទាំងនោះបានពោលពាក្យនេះហើយ ព្រះសាស្តាក៏ទ្រង់ពេញព្រះហឫទ័យ ។ គ្រានោះ ទេវតាទាំងនោះគិតថា ព្រះសាស្តាពេញព្រះហឫទ័យ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ រួចក៏បាត់ចាកទីនោះឯង ។ លំដាប់នោះ កាលរាត្រីនោះកន្លងទៅ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងរាត្រីនេះទេវតាពីរអង្គ កាលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ធ្វើភ្នំគិជ្ឈកូដទាំងអស់ឲ្យភ្លឺ ហើយចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគតហើយ ឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតាមួយអង្គឋិតក្នុងទីសមគួរហើយ បានពោលនឹងតថាគត

ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីទាំងនោះរួចស្រឡះ ( ចាកកិលេស ) ទេវតាមួយអង្គទៀត ក៏ពោលនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីទាំងនោះ ជាអនុបាទិសេសនិព្វាន រួចស្រឡះដោយប្រពៃ ( ចាកកិលេស ) ម្នាលភិក្ខុទាំងឡាយ លុះទេវតាទាំងនោះបានពោលពាក្យដូច្នេះហើយ ពោលនូវហេតុនេះហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ រួចក៏បាត់ចាកទីនោះឯង ។ សម័យនោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុអង្គុយក្នុងទីជិតព្រះដ៏មានព្រះភាគដែរ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុមានសេចក្តីត្រិះរិះដូច្នេះថា ពួកទេវតាដូចម្តេចមានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈ ក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេសៈ ក្នុងអនុ-បាទិសេសៈដូច្នេះខ្លះ ។ សម័យនោះឯង ភិក្ខុឈ្មោះតិស្សៈធ្វើមរណកាលក្នុងកាលឥឡូវនេះ បានទៅកើតក្នុងព្រហ្មលោកណាមួយ ជនទាំងឡាយតែងដឹងនូវព្រហ្មនោះ ក្នុងរឿងនោះយ៉ាងនេះថា ព្រហ្មឈ្មោះតិស្សៈ ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុក៏ស្រាប់តែបាត់ពីភ្នំគិជ្ឈកូដ ទៅប្រាកដឯព្រហ្មលោកនោះឯង ដូចជាបុរសមានកម្លាំងលានូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញដូច្នោះឯង ។ លុះព្រហ្មឈ្មោះតិស្សៈបានឃើញព្រះមហាមោគ្គល្លានដ៏មានអាយុ មកពីចម្ងាយលុះឃើញហើយ បានពោលនឹងព្រះមហាមោគ្គល្លានដ៏មានអាយុ ដូច្នេះថា បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ លោកម្ចាស់ចូរនិមន្តមក បពិត្រព្រះ

មោគ្គល្លានអ្នកនិរទុក្ខ លោកម្ចាស់និមន្តមកស្រួលហើយ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ លោកម្ចាស់ខានធ្វើនូវបរិយាយ ដែលជាបរិយាយអំពីដំណើរមកក្នុងទីនេះអស់កាលយូរហើយ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ លោកម្ចាស់ចូរគង់ចុះ នេះជាអាសនៈដែលខ្ញុំម្ចាស់ក្រាលទុក ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏គង់លើអាសនៈដែលព្រហ្មក្រាលហើយ ។ តិស្សព្រហ្មបានថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយអង្គុយក្នុងដ៏ទីសមគួរ ។ លុះតិស្ស-ព្រហ្មអង្គុយក្នុងទីសមគួរហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុបានសួរដូច្នេះថា ម្នាលតិស្សៈ ទេវតាពួកណាខ្លះ មានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេសៈក្នុងអនុបា-ទិសេសៈដូច្នេះខ្លះ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ញាណរមែងកើតដល់ទេវតាក្នុងពួកព្រហ្មយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេសៈក្នុងអនុបាទិសេសៈដូច្នេះខ្លះ ។ ម្នាលតិស្សៈ ពួកទេវតាក្នុងពួកព្រហ្មទាំងអស់ឬដែលមានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេសៈក្នុងអនុបាទិសេសៈ ដូច្នេះខ្លះ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ មិនមែនទេវតាក្នុងពួកព្រហ្មទាំងអស់ទេ ដែលមានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេសៈក្នុងអនុបាទិសេសៈដូច្នេះខ្លះ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ទេវតាក្នុងពួកព្រហ្មដែលត្រេកអរដោយអាយុដ៏ប្រសើរ ដោយ

ពណ៌សម្បុរដ៏ប្រសើរ ដោយសេចក្តីសុខដ៏ប្រសើរ ដោយយសដ៏ប្រសើរ ដោយអាធិបតេយ្យដ៏ប្រសើរ រមែងមិនដឹងនូវការរលាស់ចេញនូវធម៌នោះ តទៅតាមសេចក្តីពិតទេ ទេវតានោះមិនមែនមានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេសៈក្នុងអនុបាទិសេសៈ ដូច្នេះខ្លះទេ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ពួកទេវតាក្នុងពួកព្រហ្មណាដែលមិនត្រេកអរដោយអាយុដ៏ប្រសើរ ដោយពណ៌សម្បុរដ៏ប្រសើរ ដោយសេចក្តីសុខដ៏ប្រសើរ ដោយយសដ៏ប្រសើរ មិនត្រេកអរដោយអាធិបតេយ្យដ៏ប្រសើរ ទើបដឹងនូវការរលាស់ចេញនូវធម៌នោះតទៅទៀតតាមសេចក្តីពិត ទេវតាទាំងនោះ ទើបមានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈដូច្នេះខ្លះ អនុបាទិសេសៈក្នុងអនុបាទិសេសៈ ដូច្នេះខ្លះ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ភិក្ខុក្នុងសាសនានេះ ជាឧភតោភាគវិមុត្ត ( រួចចាកកិលេសដោយចំណែកទាំងពីរ ) ទេវតាទាំងនោះ រមែងដឹងច្បាស់នូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុអង្គនេះឯងជាឧភតោភាគវិមុត្ត កាយរបស់ភិក្ខុនោះឋិតនៅត្រឹមណា ពួកទេវតា និងមនុស្ស រមែងឃើញនូវភិក្ខុនោះត្រឹមណោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ពួកទេវតា និងមនុស្សមិនបានឃើញនូវភិក្ខុនោះឡើយ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ពួកទេវតាទាំងនោះ រមែងមានញាណកើតឡើងយ៉ាងនេះថា អនុបាទិសេសៈក្នុងអនុបាទិសេសៈដូច្នេះ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ភិក្ខុ

ក្នុងសាសនានេះ ជាបញ្ញាវិមុត្ត ពួកទេវតាទាំងនោះ រមែងដឹងនូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះឯង ជាបញ្ញាវិមុត្ត កាយរបស់ភិក្ខុនោះឋិតនៅត្រឹមណា ពួកទេវតា និងមនុស្សតែងឃើញនូវភិក្ខុនោះត្រឹមណោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ពួកទេវតា និងមនុស្សមិនបានឃើញនូវភិក្ខុនោះឡើយ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ពួកទេវតាទាំងនោះ រមែងមានញាណកើតឡើងយ៉ាងនេះថា អនុបាទិសេសៈក្នុងអនុបាទិសេសៈ ដូច្នេះ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ភិក្ខុក្នុងសាសនានេះ ជាកាយសក្ខី ពួកទេវតាទាំងនោះ រមែងដឹងភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះឯងជាកាយសក្ខី ធ្វើម្តេចទៅហ្ន៎ លោកដ៏មានអាយុនេះ អាស្រ័យសេពនូវសេនាសនៈដ៏សមគួរ គប់រកនូវកល្យាណមិត្រ ប្រមូលនូវឥន្ទ្រិយទាំងឡាយ កុលបុត្រទាំងឡាយចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់គុណវិសេសណា ក៏ធ្វើឲ្យជាក់ច្បាស់សម្រេចនូវគុណវិសេសនោះ មានព្រហ្មចរិយធម៌ជាទីបំផុត ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ពួកទេវតាទាំងនោះ រមែងមានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈ ដូច្នេះ ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ភិក្ខុក្នុងសាសនានេះ ជាទិដ្ឋិប្បត្ត ។បេ។ ជាសទ្ធាវិមុត្ត ជាធម្មានុសារី ពួកទេវតាទាំងនោះ តែងដឹងនូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះឯង ជាធម្មានុសារី ធ្វើម្តេចទៅហ្ន៎ លោកដ៏មានអាយុនេះ

អាស្រ័យសេពនូវសេនាសនៈសមគួរ គប់រកនូវកល្យាណមិត្រ ប្រមូលនូវឥន្ទ្រិយទាំងឡាយ កុលបុត្រទាំងឡាយចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់គុណវិសេសណា ក៏ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវគុណវិសេសនោះ មានព្រហ្មចរិយធម៌ជាទីបំផុតដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ បពិត្រព្រះមោគ្គល្លានអ្នកនិរទុក្ខ ទេវតាទាំងនោះ មានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈ ដូច្នេះ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ត្រេកអរពីករាយចំពោះភាសិតរបស់ព្រហ្មឈ្មោះតិស្សៈហើយ ស្រាប់តែបាត់អំពីព្រហ្មលោក មកប្រាកដឯភ្នំឈ្មោះគិជ្ឈកូដភ្លាម ដូចបុរសមានកម្លាំង លានូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញដូច្នោះឯង ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលដំណើរដែលបានចរចាត្រឹមណា ជាមួយនឹងព្រហ្មឈ្មោះតិស្សៈ ដោយសព្វគ្រប់ចំពោះព្រះដ៏មានព្រះភាគ ។ ម្នាលមោគ្គល្លាន តិស្សព្រហ្មសម្តែងនូវបុគ្គលអ្នកនៅដោយអនិមិត្តសមាធិទី ៧ ដល់អ្នកមិនបានទេ ។ ព្រះដ៏មានព្រះភាគគប្បីសម្តែងនូវបុគ្គលអ្នកនៅដោយអនិមិត្តសមាធិទី ៧ ណា បពិត្រព្រះដ៏មានព្រះភាគ កាលនេះជាកាលគួរដល់សេចក្តីនោះ បពិត្រព្រះសុគត កាល

នេះជាកាលគួរដល់សេចក្តីនោះហើយ ភិក្ខុទាំងឡាយ បានស្តាប់ព្រះដ៏មានព្រះភាគហើយ នឹងចងចាំទុក ។ ម្នាលមោគ្គល្លាន បើដូច្នោះ ចូរអ្នកស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែង ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានទទួលស្តាប់ព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលមោគ្គល្លាន ភិក្ខុក្នុងសាសនានេះ បានដល់នូវចេតោសមាធិដែលមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងអស់ ទេវតាទាំងនោះតែងដឹងនូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះឯង បានដល់នូវចេតោសមាធិដែលមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងអស់ ធ្វើម្តេចទៅហ្ន៎ លោកដ៏មានអាយុនេះអាស្រ័យសេពនូវសេនាសនៈដ៏សមគួរ គប់រកនូវកល្យាណមិត្រ ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ កុលបុត្រទាំងឡាយចេញចាកផ្ទះ ចូលកាន់ផ្នួសដើម្បីប្រយោជន៍ដល់គុណវិសេសណា ក៏បានធ្វើឲ្យជាក់ច្បាស់សម្រេចនូវគុណ-វិសេសនោះ មានព្រហ្មចរិយធម៌ជាទីបំផុតដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលមោគ្គល្លាន ពួកទេវតាទាំងនោះ មានញាណកើតឡើងយ៉ាងនេះថា សឧបាទិសេសៈក្នុងសឧបាទិសេសៈ ដូច្នេះ ។

# អដ្ឋកថា

## តិស្សសូត្រ

[ ៥៣ ] ក្នុងតិស្សសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាតិស្សសូត្រទី ៣ ចប់

# សុត្តន្តបិដក

## សីហសូត្រទី ៤

[ ៥៤ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ សីហសេនាបតី ( សេនាបតីឈ្មោះសីហៈ ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសីហសេនាបតីអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គអាចនឹងពន្យល់នូវផលនៃទាន ដែលបុគ្គលឃើញដោយខ្លួនឯងបានដែរឬ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសីហៈ បើដូច្នោះតថាគតនឹងត្រឡប់សួរអ្នកក្នុងរឿងនុ៎ះវិញ អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះស្រាយនូវរឿងនោះយ៉ាងនោះចុះ ។ ម្នាលសីហៈ អ្នកសម្គាល់នូវរឿងនោះដូចម្តេច ។ ក្នុងលោកនេះ មានបុរសពីរនាក់ បុរសម្នាក់មិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច បុរសម្នាក់មានសទ្ធា ជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការ

ឲ្យទានរឿយៗ ។ ម្នាលសីហៈ អ្នកសម្គាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលអនុគ្រោះ តើគួរនឹងអនុគ្រោះបុរសណាមុន ( អនុគ្រោះ ) បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ ( អនុគ្រោះ ) បុរសដែលមានសទ្ធាជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ព្រះអរហន្តទាំងឡាយ កាលអនុគ្រោះ នឹងអនុគ្រោះបុរសនោះមុនដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមានសទ្ធា ជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ព្រះអរហន្តទាំងឡាយ កាលអនុគ្រោះ គួរអនុគ្រោះបុរសនោះឯងមុន ។ ម្នាលសីហៈ អ្នកសម្គាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលចូលទៅរក តើគួរចូលទៅរកបុរសណាមុន ( ចូលទៅរក ) បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ ( ចូលទៅរក ) បុរសដែលមានសទ្ធាជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ព្រះអរហន្តទាំងឡាយកាលចូលទៅរក នឹងចូលទៅរកបុរសនោះមុន ដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ព្រះអរហន្តទាំងឡាយ កាលចូលទៅរក គួរចូលទៅ

រកបុរសនោះឯងមុន ។ ម្នាលសីហៈ អ្នកសម្គាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលទទួលយក ( ទាន ) គួរទទួលយក ( ទាន ) របស់បុរសណាមុន ( ទទួលយកទាន ) របស់បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ ( ទទួលយកទាន ) របស់បុរសដែលមានសទ្ធាជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ព្រះអរហន្តទាំងឡាយ កាលទទួលយក ( ទាន ) នឹងទទួលយក ( ទាន ) របស់បុរសនោះមុនដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ព្រះអរហន្តទាំងឡាយកាលទទួលយក ( ទាន ) គួរទទួលយក ( ទាន ) របស់បុរសនោះឯងមុន ។ ម្នាលសីហៈ អ្នកសម្គាល់នូវរឿងនោះដូចម្តេច ។ ព្រះអរហន្តទាំងឡាយ កាលសម្តែងធម៌ តើគួរសម្តែងដល់បុរសណាមុន ( សម្តែង ) ដល់បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬ ( សម្តែង ) ដល់បុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមិនមានសទ្ធា មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ព្រះអរហន្តទាំងឡាយកាលសម្តែងធម៌ នឹងសម្តែងដល់បុរសនោះមុនដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមានសទ្ធា ជាម្ចាស់នៃទាន

ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ព្រះអរហន្តទាំងឡាយ កាលសំដែងធម៌ គួរសំដែងដល់បុរសនោះឯងមុន ។ ម្នាលសីហៈ អ្នកសម្គាល់នូវរឿងនោះ ដូចម្ដេច ។ កិត្តិសព្ទដ៏ពីរោះរបស់បុរសណាហ្ន៎ គប្បីខ្ចរខ្ចាយទៅ ( កិត្តិសព្ទ ) របស់បុរសដែលមិនមានសទ្ធា មានសេចក្ដីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ( ខ្ចរខ្ចាយទៅ ) ឬ ( កិត្តិសព្ទ ) របស់បុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ( ខ្ចរខ្ចាយទៅ ) ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមិនមានសទ្ធា មានសេចក្ដីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច កិត្តិសព្ទដ៏ពីរោះរបស់បុរសនោះ នឹងខ្ចរខ្ចាយទៅដូចម្ដេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ កិត្តិសព្ទដ៏ពីរោះរបស់បុរសនោះឯង គួរនឹងខ្ចរខ្ចាយទៅបាន ។ ម្នាលសីហៈ អ្នកសម្គាល់នូវរឿងនោះដូចម្ដេច ។ បុរសដូចម្ដេចហ្ន៎ គប្បីចូលទៅរកបរិស័ទណា ទោះជាខត្តិយបរិស័ទក្ដី ព្រាហ្មណបរិស័ទក្ដី គហបតិបរិស័ទក្ដី សមណបរិស័ទក្ដី ជាអ្នកក្លៀវក្លា មិនញញើតញញើម គប្បីចូលទៅរកបរិស័ទនោះបាន បុរសដែលមិនមានសទ្ធា មានសេចក្ដីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬបុរសដែលមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ ( គប្បីចូលទៅរកបរិស័ទនោះបាន ) ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមិនមានសទ្ធា មានសេចក្ដីកំណាញ់ស្វិតស្វាញ ជាអ្នកជេរប្រទេច បុរសនោះនឹងចូល

ទៅរកបរិស័ទណា ទោះជាជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិ-
បរិស័ទក្តី សមណបរិស័ទក្តី ជាអ្នកក្លៀវក្លា មិនញញើតញញើម នឹងចូល
ទៅរកបរិស័ទនោះដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែល
មានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ បុរសនោះ
គប្បីចូលទៅរកបរិស័ទណា ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី
គហបតិបរិស័ទក្តី សមណបរិស័ទក្តី ជាអ្នកក្លៀវក្លា មិនញញើតញញើម
គប្បីចូលទៅរកបរិស័ទនោះបាន ។ ម្នាលសីហៈ អ្នកសម្គាល់នូវរឿងនោះ
ដូចម្តេច ។ បុរសណាហ្ន៎ លុះបែកធ្លាយរាងកាយស្លាប់ទៅ គប្បីទៅកើត
ក្នុងសុគតិសួគ៌ទេវលោកបាន បុរសដែលមិនមានសទ្ធា មានសេចក្តីកំណាញ់
ស្វិតស្វាញ ជាអ្នកជេរប្រទេច ឬបុរសដែលមានសទ្ធាជាម្ចាស់នៃទាន ជាអ្នក
ត្រេកអរក្នុងការឲ្យទានរឿយៗ ( គប្បីទៅកើតក្នុងសុគតិសួគ៌ទេវលោក ) ។
បពិត្រព្រះអង្គដ៏ចម្រើន បុរសណាដែលមិនមានសទ្ធា មានសេចក្តីកំណាញ់
ស្វិតស្វាញ ជាអ្នកជេរប្រទេច បុរសនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ
នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោកដូចម្តេចបាន ។ បពិត្រព្រះអង្គដ៏ចម្រើន
បុរសណាដែលមានសទ្ធា ជាម្ចាស់ទាន ជាអ្នកត្រេកអរក្នុងការឲ្យទានរឿយៗ
បុរសនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ គប្បីទៅកើតក្នុងសុគតិសួគ៌
ទេវលោកបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ផលនៃទានដែលបុគ្គលឃើញ
ច្បាស់ដោយខ្លួនឯង ទាំង ៦ នេះ ព្រះដ៏មានព្រះភាគសម្តែងហើយ ខ្ញុំព្រះអង្គ

មិនបានដល់នូវសេចក្ដីជឿព្រះដ៏មានព្រះភាគក្នុងហេតុនុ៎ះទេ ខ្ញុំព្រះអង្គក៏បាន ដឹងច្បាស់នូវផលនៃទានទាំងនុ៎ះដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជា ទាយក ជាម្ចាស់ទាន ព្រះអរហន្តទាំងឡាយ កាលអនុគ្រោះ រមែងអនុគ្រោះ នូវខ្ញុំព្រះអង្គមុន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ព្រះអរហន្តទាំងឡាយ កាលចូលទៅរក រមែងចូលទៅរកខ្ញុំព្រះអង្គមុន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ព្រះអរហន្តទាំង-ឡាយ កាលទទួលយកទាន រមែងទទួលយកទានរបស់ខ្ញុំព្រះអង្គមុន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ព្រះអរហន្តទាំង-ឡាយ កាលសម្ដែងធម៌ រមែងសម្ដែងដល់ខ្ញុំព្រះអង្គមុន ។ បពិត្រព្រះអង្គដ៏ ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន កិត្តិសព្ទដ៏ពីរោះ របស់ខ្ញុំព្រះអង្គ ខ្ចរខ្ចាយទៅថា សីហសេនាបតីជាទាយក ជាអ្នកធ្វើ ជាអ្នកបម្រើសង្ឃ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ជាម្ចាស់ទាន ចូលទៅរកបរិស័ទ ណា ទោះជាខត្តិយបរិស័ទក្ដី ព្រាហ្មណបរិស័ទក្ដី គហបតិបរិស័ទក្ដី សមណ-បរិស័ទក្ដី ខ្ញុំព្រះអង្គជាអ្នកក្លៀវក្លា មិនញញើតញញើម រមែងចូលទៅរក បរិស័ទនោះបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ផលនៃទានដែលបុគ្គលឃើញ ច្បាស់ដោយខ្លួនឯង ទាំង ៦ នេះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងហើយ ខ្ញុំ ព្រះអង្គមិនដល់នូវសេចក្ដីជឿព្រះដ៏មានព្រះភាគ ក្នុងហេតុនុ៎ះទេ ខ្ញុំព្រះអង្គក៏ បានដឹងច្បាស់នូវផលនៃទានទាំងនុ៎ះដែរ ចំណែកដែលព្រះដ៏មានព្រះភាគ

ទ្រង់ត្រាស់នូវផលនៃទានណា នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ បុគ្គល ជាទាយក ជាម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកើត ក្នុងសុគតិសួគ៌ទេវលោក ខ្ញុំព្រះអង្គមិនបានដឹងច្បាស់នូវផលនៃទាននោះទេ ឥឡូវ ខ្ញុំព្រះអង្គ ដល់នូវសេចក្ដីជឿព្រះដ៏មានព្រះភាគ ត្រង់ផលនៃទាននុ៎ះ ។ ម្នាលសីហៈ ដំណើរនុ៎ះ យ៉ាងហ្នឹងហើយ ម្នាលសីហៈ ដំណើរនុ៎ះ យ៉ាង ហ្នឹងហើយ ម្នាលសីហៈ បុគ្គលជាទាយក ជាម្ចាស់ទាន លុះបែកធ្លាយរាង កាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។

# អដ្ឋកថា

## សីហសូត្រ

[ ៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីហសូត្រទី ៤ ដូចតទៅនេះ បទថា **មច្ឆរី** បានដល់ បុគ្គលដែលប្រកបដោយសេចក្ដីកំណាញ់ ៥ យ៉ាង ។ បទ ថា **កទរិយោ** សេចក្ដីថា បុគ្គលដែលមានការកំណាញ់ស្វិតស្វាញ រមែង ហាមសូម្បីជនដទៃដែលនឹងឲ្យទាន ។ បទថា **អនុប្បទានរតោ** សេចក្ដីថា កាលនឹងឲ្យទានរឿយៗ ក៏រមែងត្រេកអរ ។ បទថា **អនុកម្បន្តោ** សេចក្ដីថា ដែលអនុគ្រោះដោយគិតយ៉ាងនេះថា ថ្ងៃនេះ អញនឹងអនុគ្រោះនរណា ពួក

យើងគប្បីទទួលទេយ្យធម៌របស់អ្នកណា ឬពួកយើងគប្បីសម្តែងធម៌ដល់អ្នកណា ។ល។

## អដ្ឋកថាសីហសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អរក្ខិយសូត្រទី ៥

[ ៥៥ ] ម្នាលភិក្ខុទាំងឡាយ ហេតុទាំងឡាយ ៤ យ៉ាងនេះ តថាគតមិនបាច់រក្សាផង មិនមានការតិះដៀលដោយហេតុ ៣ យ៉ាងផង ។ ហេតុទាំង ៤ យ៉ាង ដែលតថាគតមិនបាច់រក្សា តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ តថាគតមានកាយសមាចារបរិសុទ្ធហើយ កាយទុច្ចរិត របស់តថាគតមិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃដឹងនូវកាយទុច្ចរិតនេះ របស់តថាគតឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានវចីសមាចារបរិសុទ្ធហើយ វចីទុច្ចរិតរបស់តថាគតមិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃ ដឹងនូវវចីទុច្ចរិតនេះ របស់តថាគតឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានមនោសមាចារបរិសុទ្ធហើយ មនោទុច្ចរិតរបស់តថាគតមិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃ ដឹងនូវមនោទុច្ចរិតនេះ របស់តថាគតឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគត មានការចិញ្ចឹមជីវិតបរិសុទ្ធហើយ ការចិញ្ចឹមជីវិតខុស របស់តថាគត

មិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃដឹងនូវការចិញ្ចឹមជីវិតខុស នេះ របស់តថាគតឡើយ ។ ហេតុទាំង ៤ យ៉ាងនេះ តថាគតមិនបាច់រក្សាទេ ។ តថាគតមិនមានការតិះដៀលដោយហេតុ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុ ទាំងឡាយ តថាគតមានធម៌សម្តែងល្អហើយ សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តីក្នុងលោក នឹងចោទចំពោះតថាគតក្នុងរឿងនោះ ប្រកបដោយហេតុថា ព្រះអង្គមិនមែនមានធម៌ សម្តែងដោយល្អដូច្នេះក្តី ។ ម្នាល ភិក្ខុទាំងឡាយ តថាគតមិនដែលឃើញនូវនិមិត្តនុ៎ះ ម្នាលភិក្ខុទាំងឡាយ កាល តថាគតមិនបានឃើញនូវនិមិត្តនុ៎ះហើយ ក៏ដល់នូវសេចក្តីក្សេមក្សាន្ត ដល់នូវ សេចក្តីមិនមានភ័យ ដល់នូវសេចក្តីក្លាហាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តី ប្រតិបត្តិជាទីទៅកាន់ព្រះនិព្វាន ដែលតថាគតបញ្ញត្តហើយ ដោយប្រពៃដល់ ពួកសាវករបស់តថាគត ពួកសាវករបស់តថាគត ដែលប្រតិបត្តិតាម រមែង មានអាសវៈអស់ហើយ បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួន ឯង ក្នុងបច្ចុប្បន្នហើយ បានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិន មានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្ត នៅ ។ សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយ ក្តីក្នុងលោក នឹងចោទចំពោះតថាគត ក្នុងរឿងនោះ ប្រកបដោយហេតុថា សេចក្តីប្រតិបត្តិជាទីទៅកាន់ព្រះនិព្វាន ព្រះអង្គមិនមែនជាបញ្ញត្ត ដោយប្រពៃ ដល់ពួកសាវក គួរឲ្យពួកសាវករបស់ព្រះអង្គ ដែលប្រតិបត្តិតាមហើយ បាន

ធ្វើឲ្យជាក់ច្បាស់ បានដល់ ។បេ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅដូច្នេះក្តី ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញនូវនិមិត្តនុ៎ះ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនឃើញនូវនិមិត្តនុ៎ះ ក៏ដល់នូវសេចក្តីក្សេមក្សាន្ត ដល់នូវសេចក្តីមិនមានភ័យ ដល់នូវសេចក្តីក្លាហាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវកបរិស័ទរបស់តថាគតជាច្រើនរយ បានធ្វើឲ្យជាក់ច្បាស់ បានដល់ ។បេ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។ សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តីក្នុងលោក នឹងចោទតថាគតក្នុងរឿងនោះ ប្រកបដោយហេតុថា ពួកសាវករបស់ព្រះអង្គជាច្រើនរយ មិនមែនបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ហើយបានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ដូច្នេះក្តី ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញនូវនិមិត្តនុ៎ះ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនឃើញនូវនិមិត្តនុ៎ះហើយ ក៏ដល់នូវសេចក្តីក្សេមក្សាន្ត ដល់នូវសេចក្តីមិនមានភ័យ ដល់នូវសេចក្តីក្លាហាន ហើយសម្រេចសម្រាន្តនៅ ។ តថាគតមិនមានការតិះដៀល ដោយហេតុ ៣ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៤ យ៉ាងនេះឯង ព្រះតថាគតមិនបាច់រក្សាផង មិនមានការតិះដៀលដោយហេតុ ៣ យ៉ាងនេះផង ។

# អដ្ឋកថា

## រក្ខិតសូត្រ

[ ៥៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរក្ខិតសូត្រទី ៥ ដូចតទៅនេះ បទថា **ឆនិមិត្តំ** បានដល់ នូវធម្មនិមិត្តខ្លះ បុគ្គលនិមិត្តខ្លះ ។ ពិតហើយ ព្រះតថាគត កាលមិនពិចារណាឃើញ សូម្បី ១ បទ ក្នុងធម៌ដែលតថាគតសម្តែងហើយ ដោយខ្លួនឯង ថាជាធម៌ដែលពោលមិនល្អ នាំសត្វចេញចាកទុក្ខក្នុងវដ្តៈមិន បាន ឈ្មោះថា មិនពិចារណាឃើញធម្មនិមិត្ត ។ ព្រះតថាគតមិនពិចារណា ឃើញបុគ្គលណាមួយ ដែលអាចក្រោកឡើងឆ្លើយឆ្លងថា ធម៌ដែលព្រះអង្គ ពោលហើយខុស ធម៌ដែលព្រះអង្គពោលមិនល្អ ឈ្មោះថា មិនពិចារណា ឃើញបុគ្គលនិមិត្ត ។ ក្នុងបទដ៏សេសទាំង ២ ក៏មានន័យនេះដូចគ្នា ។

**អដ្ឋកថា រក្ខិតសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## កិម្មិលសូត្រទី ៦

[ ៥៦ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តវេឡុវន ជិតក្រុងកិមិលា ។ គ្រានោះ ព្រះកិមិលៈដ៏មានអាយុ ចូលទៅគាល់ព្រះមាន ព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយ

អន្ទុយក្នុងទីសមគួរ ។ លុះព្រះកិមិលៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ កាលបើព្រះតថាគតបរិនិព្វានហើយ ព្រះសទ្ធម្មមិនតាំងនៅអស់កាលយូរបាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកិមិលៈ ក្នុងសាសនានេះ កាលតថាគតបរិនិព្វានហើយ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា មិនមានសេចក្ដីគោរព កោតក្រែងក្នុងព្រះសាស្ដា មិនមានសេចក្ដីគោរព កោតក្រែងក្នុងព្រះធម៌ មិនមានសេចក្ដីគោរព កោតក្រែងក្នុងព្រះសង្ឃ មិនមានសេចក្ដីគោរព កោតក្រែងក្នុងសិក្ខា មិនមានសេចក្ដីគោរព កោតក្រែងក្នុងសមាធិ មិនមានសេចក្ដីគោរពកោតក្រែងក្នុងអប្បមាទ មិនមានសេចក្ដីគោរព កោតក្រែងក្នុងបដិសណ្ឋារៈ ។ ម្នាលកិមិលៈ នេះជាហេតុ នេះជាបច្ច័យ កាលតថាគតបរិនិព្វានហើយ ព្រះសទ្ធម្មមិនតាំងនៅអស់កាលយូរ ។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ កាលបើព្រះតថាគតបរិនិព្វានហើយ ព្រះសទ្ធម្មតាំងនៅអស់កាលយូរបាន ។ ម្នាលកិមិលៈ ក្នុងសាសនានេះ កាលបើតថាគតបរិនិព្វានហើយ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា មានសេចក្ដីគោរពកោតក្រែងក្នុងព្រះសាស្ដា មានសេចក្ដីគោរព កោតក្រែងក្នុងព្រះធម៌ មានសេចក្ដីគោរព កោតក្រែងក្នុងព្រះសង្ឃ មានសេចក្ដីគោរព កោតក្រែងក្នុងសិក្ខា មានសេចក្ដីគោរព កោតក្រែងក្នុងសមាធិ មានសេចក្ដីគោរព កោតក្រែងក្នុងអប្បមាទ មានសេចក្ដីគោរព កោតក្រែងក្នុងបដិសណ្ឋារៈ ។ ម្នាល

កិមិលៈ នេះជាហេតុ នេះជាបច្ច័យ កាលបើតថាគតបរិនិព្វានហើយ ទើបព្រះសទ្ធម្មតាំងនៅអស់កាលយូរបាន ។

# អដ្ឋកថា

## កិម្មិលសូត្រ

[ ៥៦ ] ក្នុងកិម្មិលសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាកិម្មិលសូត្រទី ៦ ចប់

# សុត្តន្តបិដក

## សត្តធម្មសូត្រទី ៧

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង មិនយូរប៉ុន្មាន នឹងបានធ្វើឲ្យជាក់ច្បាស់ បានដល់ ។បេ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានសីល ១ ជាពហុស្សូត ១ ជាអ្នកសម្ងំនៅក្នុងទីស្ងាត់ ១ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ១ មានសតិ ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ

ប្រកបដោយធម៌ ៧ យ៉ាងនេះឯង មិនយូរប៉ុន្មាន នឹងបានធ្វើឲ្យជាក់ច្បាស់បានដល់ ។បេ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ។

# អដ្ឋកថា

## សត្តធម្មសូត្រ

[ ៥៧ ] ក្នុងសត្តធម្មសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសត្តធម្មសូត្រទី ៧ ចប់

# សុត្តន្តបិដក

## មោគ្គល្លានសូត្រទី ៨

[ ៥៨ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងសុំសុមារគិរី នាភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងភគ្គៈ ។ សម័យនោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយងោកងក់ ក្នុងកល្លវាលមុត្តគ្រាម ក្នុងដែនមគធៈ ។ ព្រះដ៏មានព្រះភាគ ទ្រង់មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ទ្រង់បានឃើញនូវព្រះមហាមោគ្គល្លានដ៏មានអាយុ កំពុងអង្គុយ

ងោកងក់ ក្នុងកល្លវាលមុត្តគ្រាម ក្នុងដែនមគធៈ លុះឃើញហើយ ក៏ទ្រង់បាត់អំពីភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងសុំសុមារគិរី ក្នុងដែនភគ្គៈ ទៅប្រាកដក្នុងទីចំពោះមុខ នៃមហាមោគ្គល្លានដ៏មានអាយុ ក្នុងកល្លវាលមុត្តគ្រាម ក្នុងដែនមគធៈ ប្រៀបដូចបុរសមានកម្លាំងគប្បីលាទូវដៃដែលបត់ចូល ឬគប្បីបត់ចូលនូវដៃដែលលាចេញ ក៏យ៉ាងនោះដែរ ។ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ក៏ត្រាស់ទៅនឹងព្រះមហាមោគ្គល្លានដ៏មានអាយុ ដូច្នេះថា នែមោគ្គល្លាន អ្នកងោកងក់ឬ នែមោគ្គល្លាន អ្នកងោកងក់ឬ ។ ព្រះមហាមោគ្គល្លានតបថា ព្រះករុណាព្រះអង្គ ។ នែមោគ្គល្លាន ព្រោះហេតុនោះ ក្នុងសាសនានេះ កាលបើអ្នកមានសញ្ញាយ៉ាងណាហើយ សេចក្តីងងុយងោក នៅតែគ្របសង្កត់អ្នក អ្នកគប្បីធ្វើទុកក្នុងចិត្តនូវសញ្ញានោះ គប្បីធ្វើនូវសញ្ញានោះឲ្យក្រាស់ក្រែលឡើង ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះហើយ នឹងលះសេចក្តីងងុយងោកនោះ បានមិនខាន ។ បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះ មិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីត្រិះរិះរឿយៗ គប្បីពិចារណារឿយៗ គប្បីរំពឹងរឿយៗ នូវធម៌ដែលធ្លាប់ស្តាប់ហើយ ធ្លាប់រៀនសូត្រហើយដោយចិត្ត ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងអាចលះសេចក្តីងងុយងោកនោះបានមិនខាន ។ បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបាន

ទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីស្វាធ្យាយ នូវធម៌ដែលអ្នកធ្លាប់ស្តាប់ហើយ ធ្លាប់រៀនសូត្រហើយដោយពិស្តារ ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកបានធ្វើយ៉ាងនេះ នឹងលះសេចក្តីងងុយងោកនោះបានមិនខាន ។ កាលបើអ្នកធ្វើយ៉ាងនេះ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីខ្វៀល នូវប្រហោងត្រចៀកទាំងពីរ ហើយគប្បីស្ទាបអង្អែលខ្លួនដោយដៃ ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងលះសេចក្តីងងុយងោកនោះបានមិនខាន ។ បើអ្នកធ្វើយ៉ាងនេះហើយ នៅតែលះសេចក្តីងងុយងោកនោះមិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីក្រោកពីអាសនៈ ហើយយកទឹកលាបភ្នែក រួចគប្បីក្រឡេកមើលទិសទាំង-ឡាយ គប្បីក្រឡេកមើលផ្កាយនក្ខត្តឫក្ស ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកបានធ្វើយ៉ាងនេះ នឹងអាចលះសេចក្តីងងុយងោកនោះ បានមិនខាន ។ កាលបើអ្នកបានធ្វើយ៉ាងនេះ នៅតែលះសេចក្តីងងុយងោកនោះ មិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីធ្វើទុកក្នុងចិត្ត នូវអាលោកសញ្ញា ( សេចក្តីសម្គាល់នូវពន្លឺ ) គប្បីអធិដ្ឋាននូវសញ្ញាថា វេលាថ្ងៃ គឺអធិដ្ឋានថា វេលាថ្ងៃយ៉ាងណា វេលាយប់ក៏យ៉ាងនោះ វេលាយប់យ៉ាងណា វេលាថ្ងៃក៏យ៉ាងនោះដែរ គប្បីមានចិត្តបើកស្រឡះដូច្នេះ មិនមានអ្វីរួបរឹត ចម្រើននូវចិត្តប្រកបដោយពន្លឺ ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកបានធ្វើយ៉ាងនេះ នឹងលះសេចក្តីងងុយងោកនោះ បានមិនខាន ។ កាលបើអ្នកបានធ្វើយ៉ាងនេះ នៅតែលះ

សេចក្តីងងុយងោកនោះ មិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីមាន សេចក្តីសម្គាល់ក្នុងខាងក្រោយ និងខាងមុខ មានឥន្ទ្រិយតាំងនៅខាងក្នុង មានចិត្តមិនប្រព្រឹត្តទៅខាងក្រៅ ហើយគប្បីអធិដ្ឋាននូវទីចង្ក្រម ហេតុនុ៎ះរមែងមានជាប្រាកដ កាលបើអ្នកធ្វើយ៉ាងនេះ នឹងលះសេចក្តីងងុយងោកនោះ បានមិនខាន ។ កាលបើអ្នកបានធ្វើយ៉ាងនេះ នៅតែលះសេចក្តីងងុយងោកនោះ មិនបានទេ នែមោគ្គល្លាន តពីនោះទៅ អ្នកគប្បីសម្រេចនូវសីហសេយ្យ គឺដេកដូចជាសត្វសីហៈ ផ្អៀងទៅខាងស្តាំ គប្បីតម្រួតជើងដោយជើង ជាអ្នកមានសតិ មានសម្បជញ្ញៈ គប្បីធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា គឺសេចក្តីសម្គាល់ថានឹងក្រោកឡើង នែមោគ្គល្លាន កាលបើអ្នកភ្ញាក់ហើយ គប្បីក្រោកឡើងឲ្យឆាប់ ដោយគិតថា អាត្មាអញនឹងមិនប្រកបរឿយៗ នូវសេចក្តីសុខ ព្រោះការដេក មិនប្រកបរឿយៗ នូវសេចក្តីសុខ ព្រោះការទម្រេត មិនប្រកបរឿយៗ នូវសេចក្តីសុខ ព្រោះសេចក្តីងងុយងោកទេ ។ នែមោគ្គល្លាន អ្នកត្រូវសិក្សាយ៉ាងនេះឯង ។ នែមោគ្គល្លាន ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញមិនលើកឡើងនូវប្រមោយ គឺមានះឲ្យខ្ពស់ ហើយចូលទៅរកត្រកូលទាំងឡាយទេ ។ នែមោគ្គល្លាន អ្នកគប្បីសិក្សាយ៉ាងនេះ ។ នែមោគ្គល្លាន បើភិក្ខុលើកឡើងនូវប្រមោយ គឺមានះឲ្យខ្ពស់ចូលទៅរកត្រកូលទាំងឡាយហើយ នែមោគ្គល្លាន ព្រោះក្នុងត្រកូលទាំងឡាយ រមែងមានកិច្ចដែលគួរធ្វើច្រើន មនុស្សទាំងឡាយ រមែងមិនយកចិត្តទុកដាក់

នឹងភិក្ខុដែលមកដល់ទេ ។ ក្នុងរឿងនោះ ភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ក្នុងវេលានេះ អ្នកណាហ្ន៎ បំបែកអាត្មាអញចេញពីត្រកូលនេះ បានជាមនុស្ស ទាំងនេះ មានសេចក្តីធុញទ្រាន់ក្នុងអាត្មាអញ ។ សេចក្តីអៀនខ្មាស រមែងមាន ដល់ភិក្ខុនោះ ដោយមិនមានលាភ កាលបើភិក្ខុមានសេចក្តីអៀនខ្មាសកើត ឡើងហើយ សេចក្តីរាយមាយក៏កើតឡើង កាលបើភិក្ខុមានសេចក្តីរាយមាយ កើតឡើងហើយ សេចក្តីមិនសង្រួមក៏កើតឡើង កាលបើសេចក្តីមិនសង្រួម កើតឡើងហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ។ នែមោគ្គល្លាន ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនពោលនូវពាក្យ ទាស់ទែង ។ នែមោគ្គល្លាន អ្នកគប្បីសិក្សាយ៉ាងនេះចុះ នែមោគ្គល្លាន កាល បើពាក្យទាស់ទែងមានហើយ ការល្មោកនិយាយច្រើន ក៏ប្រាកដឡើង កាលបើ ការល្មោកនិយាយច្រើនមានហើយ សេចក្តីរាយមាយក៏ប្រាកដឡើង កាលបើ សេចក្តីរាយមាយមានហើយ សេចក្តីមិនសង្រួមក៏ប្រាកដឡើង កាលបើសេចក្តី មិនសង្រួមមានហើយ ចិត្តក៏ឆ្ងាយអំពីសមាធិ ។ នែមោគ្គល្លាន តថាគតមិន បានសរសើរនូវការជាប់ជំពាក់ ដោយវត្ថុទាំងអស់ នែមោគ្គល្លាន ប៉ុន្តែតថាគត មិនមែនជាមិនសរសើរ ការជាប់ជំពាក់ដោយវត្ថុទាំងអស់ទេ នែមោគ្គល្លាន តថាគតមិនបានសរសើរ តែនូវការជាប់ជំពាក់ដោយគ្រហស្ថ និងបព្វជិតទាំង-ឡាយប៉ុណ្ណោះ ឯសេនាសនៈណា មានសំឡេងតិច មិនមានសំឡេងគឹកកង មានខ្យល់បក់រហើយ គួរជាទីធ្វើនូវការកំបាំងរបស់មនុស្ស សមគួរដល់ការពួន

សម្ពំ តថាគតរមែងសរសើរ នូវការជាប់ជំពាក់ដោយសេនាសនៈ មានសភាពដូច្នោះ ។ កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុមានចិត្តផុតស្រឡះពិត ក្នុងការអស់ទៅនៃតណ្ហា មានសេចក្តីសម្រេចដ៏ទៀង មានសេចក្តីក្សេមចាកយោគៈដ៏ទៀង មានព្រហ្មចារ្យដ៏ទៀង មានទីបំផុតដ៏ទៀង ជាបុគ្គលប្រសើរជាងទេវតា និងមនុស្សទាំងឡាយ យ៉ាងសង្ខេប តើដោយហេតុប៉ុន្មានហ្ន៎ ។ នៃមោគ្គល្លាន ភិក្ខុក្នុងសាសនានេះ មានការចេះដឹងថា ធម៌ទាំងអស់ មិនគួរប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រកាន់មាំឡើយ នៃមោគ្គល្លាន ភិក្ខុមានការចេះដឹងនុ៎ះថា ធម៌ទាំងអស់ មិនគួរប្រព្រឹត្តទៅដើម្បីសេចក្តីប្រកាន់មាំ យ៉ាងនេះឡើយ ។ ភិក្ខុនោះ រមែងដឹងច្បាស់នូវធម៌ទាំងអស់ លុះដឹងច្បាស់នូវធម៌ទាំងអស់ហើយ ក៏កំណត់ដឹងនូវធម៌ទាំងអស់ លុះកំណត់ដឹងនូវធម៌ទាំងអស់ហើយ ក៏ទទួលនូវវេទនាណាមួយ គឺវេទនាជាសុខ ឬជាទុក្ខ ឬមិនមែនជាទុក្ខ មិនមែនជាសុខ ។ ភិក្ខុនោះ ជាអ្នកពិចារណាឃើញរឿយៗ ថា មិនទៀងក្នុងវេទនាទាំងនោះ ពិចារណាឃើញរឿយៗ នូវការប្រាសចាកតម្រេក ពិចារណាឃើញរឿយៗ នូវការរម្ងត់ទុក្ខ ពិចារណាឃើញរឿយៗ នូវកិរិយាលះបង់ ។ កាលភិក្ខុនោះ ពិចារណាឃើញរឿយៗ ថា មិនទៀងក្នុងវេទនាទាំងនោះ ពិចារណាឃើញរឿយៗ នូវការប្រាសចាកតម្រេក ពិចារណាឃើញរឿយៗ នូវការរម្ងត់ទុក្ខ ពិចារណាឃើញរឿយៗ នូវកិរិយាលះបង់

ក៏លែងប្រកាន់មាំ នូវវត្ថុណាមួយក្នុងលោក កាលបើមិនប្រកាន់មាំហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ ក៏រមែងបរិនិព្វានដោយពិត ( ភិក្ខុនោះ ) ដឹងច្បាស់ថាជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបាន អប់រំហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលមោគ្គល្លាន ភិក្ខុមានចិត្តផុតស្រឡះ ព្រោះធ្វើធម៌នោះឲ្យជាអារម្មណ៍ ក្នុងការអស់ទៅនៃ តណ្ហា មានសេចក្តីសម្រេចដ៏ទៀង មានសេចក្តីក្សេមចាកយោគៈដ៏ទៀង មាន ព្រហ្មចារ្យដ៏ទៀង មានទីបំផុតដ៏ទៀង ជាបុគ្គលប្រសើរជាងទេវតា និងមនុស្ស ទាំងឡាយ យ៉ាងសង្ខេបដោយហេតុដូច្នេះឯង ។

# អដ្ឋកថា

## មោគ្គល្លានសូត្រ

[ ៥៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមោគ្គល្លានសូត្រទី ៨ ដូចតទៅនេះ បទថា **ចបលាយមានោ** សេចក្តីថា ព្រះមហាមោគ្គល្លាន ចូលទៅអាស្រ័យ ស្រុកនោះ ធ្វើសមណធម៌ក្នុងដងព្រៃមួយ មានរាងកាយលំបាក ព្រោះត្រូវ សេចក្តីព្យាយាមក្នុងការចង្ក្រមអស់ ៧ ថ្ងៃបៀតបៀន ទើបអង្គុយងក់ខាងចុង ទីចង្ក្រម ។ បទថា **ចបលាយសិ នោ** កែជា **និទ្ទាយសិ នុ** ប្រែថា អ្នក

*ដេកឬ ។ បទថា* **អនុមជ្ជិត្វា** *ប្រែថា ស្ទាបអង្អែលហើយ ។ បទថា* **អាលោកសញ្ញំ** *បានដល់ ការសម្គាល់ក្នុងពន្លឺ ដើម្បីបន្ទោបង់នូវការដេក ។ បទថា* **ទិវាសញ្ញំ** *បានដល់ ការសម្គាល់ថាជាពេលថ្ងៃ ។ បទថា* **យថា ទិវា តថា រត្តឹ** *សេចក្តីថា លោកតាំងនូវការសម្គាល់ថា ពន្លឺក្នុងពេលថ្ងៃ យ៉ាងណា លោកតាំងការសម្គាល់ថា ពន្លឺនោះសូម្បីក្នុងពេលយប់ ក៏ដូច្នោះ ។ ពាក្យថា* **យថា រត្តឹ តថា ទិវា** *លោកតាំងសេចក្តីសម្គាល់ថា ពន្លឺក្នុងពេលយប់ យ៉ាងណា លោកតាំងសេចក្តីសម្គាល់ថា ពន្លឺនោះសូម្បីក្នុងពេលថ្ងៃក៏ដូច្នោះ ។ បទថា* **សប្បភាសំ** *លោកគប្បីឲ្យប្រព្រឹត្តទៅ មួយអន្លើដោយពន្លឺ ដើម្បីប្រយោជន៍ដល់ទិព្វចក្ខុញ្ញាណ ។ បទថា* **បច្ឆាបុរេសញ្ញី** *សេចក្តីថា ជាអ្នកមានសញ្ញា ដោយសញ្ញាដែលនាំទៅទាំងខាងមុខ និងខាងក្រោយ ។ បទថា* **អន្តោគតេហិ ឥន្ទ្រិយេហិ** *បានដល់ ដោយឥន្ទ្រិយ ៥ ដែលមិនផ្សាយទៅខាងក្រៅ ដែលចូលមកតាំងនៅខាងក្នុងប៉ុណ្ណោះ ។ បទថា* **មិទ្ធសុខំ** *បានដល់ សេចក្តីសុខដែលកើតអំពីការដេកលក់ ព្រះមានព្រះភាគសម្តែងកម្មដ្ឋាន ជាគ្រឿងបន្ទោបង់នូវការងោកងុយដល់ព្រះថេរៈ ដោយឋានៈមានប្រមាណប៉ុណ្ណោះ ។*

*បទថា* **សោណ្ឌំ** *បានដល់ ងោកងុយ គឺមានះ ។ បទថា* **កិច្ច-ករណីយានិ** *នេះ មានវិនិច្ឆ័យដូចតទៅនេះ កម្មដែលខ្លួនគប្បីធ្វើពិត ឈ្មោះថា* **កិច្ចានិ** *ចំណែកកិច្ចក្រៅអំពីនេះ ឈ្មោះថា* **ករណីយានិ ។** *បទថា*

**មង្កុភាវោ** បានដល់ ភាពជាអ្នកគ្មានអំណាច ការទោមនស្ស ខូចចិត្ត ។ ព្រះសាស្ដាត្រាស់កិច្ចាចារវត្តដល់ព្រះថេរៈដោយឋានៈ មានប្រមាណប៉ុណ្ណេះ ។ ឥឡូវនេះ ដើម្បីទ្រង់ដឹកនាំឲ្យដល់ទីបំផុត ទើបត្រាស់ពាក្យជាដើមថា **តស្មាតិហ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **វិគ្គាហិកកថំ** សេចក្ដីថា ពាក្យដែលជាហេតុឲ្យដល់នូវកំហុស ប្រព្រឹត្តទៅដោយន័យជាដើមថា លោករមែងមិនដឹងធម៌ និងវិន័យនេះ ដើម្បីនឹងវៀរចាកការប្រឡូកប្រឡំនឹងបាបមិត្ត ទើបព្រះសាស្ដាត្រាស់ពាក្យជាដើមថា **នាហំ មោគ្គល្លាន** ដូច្នេះ ។

បទថា **កិត្តាវតា នុ ខោ** សេចក្ដីថា ដោយបដិបត្តិមានប្រមាណប៉ុនណាហ្ន៎ ។ បទថា **តណ្ហាសង្ខយវិមុត្តោ ហោតិ** សេចក្ដីថា ភិក្ខុឈ្មោះថា តណ្ហាសង្ខយវិមុត្តិ ព្រោះជាអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ដែលជាទីអស់តណ្ហា ធ្វើនិព្វាននោះជាអារម្មណ៍ ព្រះមហាមោគ្គល្លានទូលសួរថា ដោយសង្ខេប បដិបទាប៉ុន្មាន ភិក្ខុរមែងឈ្មោះថា **តណ្ហាសង្ខយវិមុត្តិ** សូមទ្រង់សម្ដែងបដិបទានោះឯង ដែលជាបដិបទាចំណែកខាងដើម នៃភិក្ខុដែលជាខីណាស្រព ដោយសង្ខេបចុះ ។

បទថា **អច្ចន្តនិដ្ឋោ** សេចក្ដីថា ឈ្មោះថា **អច្ចន្តា** ព្រោះប្រព្រឹត្តទៅកន្លងចំណែក ពោល គឺការអស់ទៅ និងការវិនាសទៅ ។ ភិក្ខុ ឈ្មោះថា **អច្ចន្តនិដ្ឋោ** ព្រោះមានការសម្រេចកន្លងចំណែក អធិប្បាយថា មានការសម្រេចដោយចំណែកមួយ មានការសម្រេចជាប់តគ្នា ។ បទថា **អច្ចន្ត–**

**យោគក្ខេមី** *សេចក្តីថា ជាអ្នកមានធម៌ជាដែនក្សេមចាកយោគៈកន្លងចំណែក អធិប្បាយថា មានធម៌ជាដែនក្សេមចាកយោគៈជានិច្ច ។ បទថា* **អច្ចន្តព្រហ្ម-ចារី** *សេចក្តីថា ជាព្រហ្មចារីកន្លងចំណែក អធិប្បាយថា ជាព្រហ្មចារីជានិច្ច ។ បទថា* **អច្ចន្តបរិយោសានោ** *សេចក្តីថា មានទីបំផុតកន្លងចំណែក ដោយន័យមុននោះឯង ។ បទថា* **សេដ្ឋោ ទេវមនុស្សានំ** *សេចក្តីថា ប្រសើរបំផុត គឺឧត្តមជាងទេវតា និងមនុស្សទាំងឡាយ ។ ព្រះមហាមោគ្គល្លានទូលសួមថា ភិក្ខុឈ្មោះថា បែបនេះ ដោយបដិបទាមានប្រមាណប៉ុនណា សូមទ្រង់សម្តែងសម្រាប់ភិក្ខុនោះដោយសង្ខេបចុះ ។*

*ក្នុងពាក្យថា* **សព្វេ ធម្មា នាលំ អភិនិវេសាយ** *នេះ មានវិនិច្ឆ័យដូចតទៅនេះថា ឈ្មោះថា ធម៌ទាំងពួង គឺខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ធម៌ទាំងអស់នោះ មិនគួរ គឺមិនត្រូវ មិនប្រពៃ មិនសម ប្រកាន់មាំ ដោយអំណាចតណ្ហា និងទិដ្ឋិ ។ ព្រោះហេតុអ្វី ទើបធម៌មិនគួរប្រកាន់មាំ ព្រោះធម៌ទាំងនោះ មិនតាំងនៅដោយការប្រកាន់ទុក ពិតហើយ ធម៌ទាំងនោះ សូម្បីខ្ជួនប្រកាន់ថា សង្ខារទាំងឡាយជារបស់ទៀង ជាសុខ និងជាអត្តា រមែងសម្រេចផលថា ជារបស់មិនទៀង ជាទុក្ខ និងជាអនត្តានោះឯង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា មិនគួរប្រកាន់មាំ ដូច្នេះ ។ បទថា* **អភិជានាតិ** *សេចក្តីថា រមែងដឹងក្រៃលែង គឺដឹងដោយញាតបរិញ្ញាថា សង្ខារទាំងឡាយ មិនទៀង ជាទុក្ខ ធម៌ទាំងពួងជាអនត្តា ។ បទថា* **បរិ-**

**ជានាតិ** សេចក្តីថា រមែងកំណត់ដឹងដោយតីរណបរិញ្ញា យ៉ាងនោះឯង ។ បទថា **យំកញ្ចិ វេទនំ** សេចក្តីថា រមែងសោយវេទនាណាមួយ សូម្បីមានប្រមាណតិច ដោយហោច ប្រកបដោយបញ្ចវិញ្ញាណ ។ ដោយបទនេះ ព្រះមានព្រះភាគ ទ្រង់ពញ្ញាក់ដោយអំណាចវេទនា ទើបសម្តែងការកំណត់អរូបធម៌ជាអារម្មណ៍ដល់ព្រះថេរៈ ។

បទថា **អនិច្ចានុបស្សី** បានដល់ ពិចារណាឃើញដោយការមិនទៀង ។ **វិរាគ** ក្នុងបទថា **វិរាគានុបស្សី** នេះ មាន ២ គឺ **ខយវិរាគ** ប្រាសចាកតម្រេក ព្រោះអស់ទៅ ១ **អច្ចន្តវិរាគ** ប្រាសចាកតម្រេក ព្រោះកន្លងចំណែក ១ ក្នុង ២ បទយ៉ាងនោះ វិបស្សនាដែលឃើញការអស់ទៅនៃសង្ខារទាំង-ឡាយ ដោយការអស់ក្តី មគ្គញាណ គឺការឃើញនូវការប្រាសចាកតម្រេកកន្លងចំណែក គឺព្រះនិព្វាន ដោយការប្រាសចាកតម្រេកក្តី ឈ្មោះថា **វិរាគា-នុបស្សនា ។** គឺការពិចារណាឃើញដោយការប្រាសចាកតម្រេក ។ បុគ្គលដល់ព្រម ដោយវិរាគធម៌ទាំង ២ នោះ ឈ្មោះថា **វិរាគានុបស្សី** គឺអ្នកតាមឃើញការប្រាសចាកតម្រេក ។ ព្រះមានព្រះភាគ ទ្រង់សំដៅដល់វិរាគៈនោះ ទើបត្រាស់ថា **វិរាគានុបស្សី** អធិប្បាយថា បុគ្គលពិចារណាឃើញការប្រាសចាកតម្រេក ។

ក្នុងនិរោធានុបស្សីបុគ្គល ក៏ន័យនេះដូចគ្នា ។ ព្រោះនិរោធ គឺការរលត់ ក៏មាន ២ ដូចគ្នា គឺ **ខយនិរោធ** និង **អច្ចន្តនិរោធ ។** បទថា **បដិ-**

**ឆិស្សគ្គានុបស្សី** *នេះ* **វោស្សគ្គ** *( ការលះ ) លោកហៅថា* **បដិនិស្សគ្គ** *( ការលះបង់ ) ការលះបង់នោះ ក៏មាន ២ យ៉ាង គឺ* **បរិច្ចាគវោស្សគ្គ** *ការលះបង់ដោយបរិច្ចាគ និង* **បក្ខន្ទនវោស្សគ្គ** *គឺការលះបង់ដោយស្ទុះទៅ ។ បណ្តាការលះ ២ យ៉ាងនោះ វិបស្សនា ឈ្មោះថា* **បរិច្ចាគវោស្សគ្គ** *។ ពិតហើយ វិបស្សនានោះ រមែងលះបាននូវកិលេស និងខន្ធ ដោយអំណាចតទង្គប្បហាន ។ មគ្គ ឈ្មោះថា* **បក្ខន្ទនវោស្សគ្គ** *ដ្បិតថា មគ្គនោះ រមែងស្ទុះទៅកាន់ព្រះនិព្វានដោយជាអារម្មណ៍ ។ ម្យ៉ាងទៀត មគ្គនោះ ឈ្មោះថា* **វោស្សគ្គ** *ព្រោះហេតុទាំង ២ គឺព្រោះលះខន្ធ និងកិលេស ដោយអំណាចសមុច្ឆេទប្បហាន និងព្រោះការស្ទុះទៅក្នុងព្រះនិព្វាន ព្រោះហេតុនោះ ទើបវិបស្សនា ឈ្មោះថា* **បរិច្ចាគវោស្សគ្គ** *ព្រោះវិបស្សនា រមែងលះកិលេសនិងខន្ធ ឯមគ្គដែលឈ្មោះថា* **បក្ខន្ទនវោស្សគ្គ** *ព្រោះចិត្ត រមែងស្ទុះទៅក្នុងការរលត់ដោយឥតសេសសល់ គឺនិព្វានធាតុ ព្រោះហេតុនេះ ទើបពាក្យទាំង ២ ចាត់ចូលបានក្នុងមគ្គ ។ បុគ្គលដល់ព្រមដោយវិបស្សនា និងមគ្គទាំង ២ នោះ រមែងជាបុគ្គលឈ្មោះថា* **បដិនិស្សគ្គានុបស្សី** *គឺអ្នកតាមឃើញការលះបង់ ព្រោះប្រកបដោយបដិនិស្សគ្គានុបស្សនានោះ ។ ព្រះមានព្រះភាគទ្រង់សំដៅដល់បុគ្គលនោះ ទើបត្រាស់យ៉ាងនេះ ។*

*ពាក្យថា* **ន ច កិញ្ចិ លោកេ ឧបាទិយតិ** *សេចក្តីថា ភិក្ខុនោះរមែងមិនប្រកាន់ មិនកាន់យក មិនពាល់ត្រូវនូវធម្មជាតិណា គឺសង្ខារណាមួយដោយ*

អំណាចតណ្ហា ។ បទថា **អនុចាធិយំ ឆ បរិតស្សតិ** សេចក្តីថា កាលមិនប្រកាន់មាំ រមែងមិនតក់ស្លុត ព្រោះការតក់ស្លុតដោយអំណាចតណ្ហា ។ បទថា **បច្ចត្តំយេវ បរិនិព្វាយតិ** សេចក្តីថា រមែងបរិនិព្វានដោយកិលេសប្បរិនិព្វានដោយខ្លួនឯង ។ បច្ចវេក្ខណញ្ញាណរបស់ភិក្ខុនោះ ព្រះមានព្រះភាគទ្រង់សម្តែងដោយន័យជាដើមថា **ខីណាជាតិ** ជាតិអស់ហើយ ដូច្នេះ ។ ដូច្នោះ ព្រះមានព្រះភាគ ត្រូវព្រះមហាមោគ្គល្លានទូលសួរដល់បដិបទាដែលជាចំណែកខាងដើមរបស់ព្រះខីណាស្រព ដោយសង្ខេបហើយ ទើបត្រាស់ដោយសង្ខេបដូចគ្នា ។ តែព្រះសូត្រនេះ ជាព្រះឱវាទផង ជាវិបស្សនាផង សម្រាប់ព្រះថេរៈ ព្រះថេរៈនោះចម្រើនវិបស្សនា ក្នុងព្រះសូត្រនេះហើយ សម្រេចអរហត្ត ដូច្នេះឯង ៕

**អដ្ឋកថា មោគ្គល្លានសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បុញ្ញាវិបាកសូត្រទី ៩

[ ៥៩ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំខ្លាចនូវបុណ្យឡើយ ម្នាលភិក្ខុទាំងឡាយ ពាក្យថាបុណ្យនេះ ជាឈ្មោះនៃសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់ថា តថាគតបានចម្រើនមេត្តាចិត្ត ដែលជាទីប្រាថ្នា

ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាផលដែលបុគ្គលទទួលរឿយៗ អស់ឆ្នាំ ៧ ជាយូរអង្វែង លុះតថាគតចម្រើននូវមេត្តាចិត្តអស់ឆ្នាំ ៧ ហើយ ក៏មិនបានមកកាន់លោកនេះទៀត អស់សំវដ្តកប្បនិងវិវដ្តកប្ប ៧ ម្នាលភិក្ខុទាំងឡាយ កាលដែលលោកវិនាសទៅ តថាគតបានទៅកើតក្នុងអាភស្សរព្រហ្ម កាលដែលលោកចម្រើនឡើង តថាគតបានទៅកាន់ព្រហ្មវិមានដែលសូន្យ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងព្រហ្មវិមាននោះ តថាគតជាព្រហ្ម ជាមហាព្រហ្ម គ្របសង្កត់លើព្រហ្មឯទៀត ព្រហ្មឯទៀតមិនអាចគ្របសង្កត់តថាគតបាន តថាគតជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើព្រហ្មទាំងពួង ឲ្យលុះក្នុងអំណាចខ្លួន ។ ម្នាលភិក្ខុទាំងឡាយ តថាគតកើតជាសក្កទេវរាជ ៣៦ ដង ។ តថាគតបានជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាធម្មរាជ ជាឥស្សរៈក្នុងផែនដី មានព្រំប្រទល់ក្នុងទីបំផុតនៃសមុទ្ទទាំង ៤ មានជ័យជម្នះ ដល់នូវការៈមាំមួនក្នុងជនបទ បរិបូណ៌ដោយរតនៈទាំង ៧ ប្រការ ជាច្រើនរយដង ។ ម្នាលភិក្ខុទាំងឡាយ រតនៈ ៧ ប្រការនេះ កើតដល់តថាគតនោះ គឺចក្ករតនៈ ១ ហត្ថិរតនៈ ១ អស្សរតនៈ ១ មណិរតនៈ ១ ឥត្ថីរតនៈ ១ គហបតិរតនៈ ១ បរិនាយករតនៈ ១ ជាគម្រប់ ៧ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានកូនច្រើនពាន់ ជាអ្នកក្លៀវក្លា មានសភាពជាអ្នកមានសេចក្តីព្យាយាម អាចញាំញីនូវសេនានៃស្តេចដទៃបាន ។ តថាគតបានឈ្នះហើយ នៅគ្រប់គ្រងនូវផែនដីនេះ ដែលមានសាគរជាទីបំផុត ដោយធម៌មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿង

សស្ត្រាទេ ។

ម្នាលភិក្ខុទាំងឡាយ តថាគត បានឃើញនូវផលនៃបុណ្យ ជាកុសលហើយ ក៏បានប្រាប់ពួកសត្វ អ្នកស្វែងរកនូវសេចក្តីសុខ ហើយចម្រើននូវមេត្តាចិត្តអស់ ៧ ឆ្នាំ មិនបានមកកាន់លោកនេះទៀត អស់សំវដ្តកប្ប និងវិវដ្តកប្ប ៧ ដង កាលដែលលោកវិនាស តថាគតទៅកើតក្នុងអាភស្សរព្រហ្ម កាលដែលលោកចម្រើន តថាគតចូលទៅកាន់ព្រហ្មលោក ដែលសូន្យ ក្នុងកាលនោះ តថាគតបានជាមហាព្រហ្ម ជាអ្នកធ្វើព្រហ្មឯទៀត ឲ្យលុះក្នុងអំណាចនៃខ្លួនអស់ ៧ ដង បានជាស្តេចនៃទេវតា ជាកំពូលនៃទេវ្តាអស់ ៣៦ ដង បានជាស្តេចចក្រពត្តិ ជាធំក្នុងជម្ពូទ្វីប ។ បានជាក្សត្រដែលបានមុទ្ធាភិសេកជាអធិបតីរបស់មនុស្ស បានឈ្នះនូវផែនដីនេះដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រា មិនបាច់កំហែងកំហល់ទេ បានប្រៀនប្រដៅដោយធម៌ដ៏ស្មើ ហើយបានសោយរាជ-សម្បត្តិនោះ លើមណ្ឌលនៃផែនដីនេះ ដោយធម៌ តែងបានកើតក្នុងត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន បរិបូណ៌ដោយកាមទាំងពួងផង ដោយរតនៈទាំង ៧ ផង ព្រះពុទ្ធទាំងឡាយ ជាអ្នកសង្គ្រោះពួកសត្វលោក ព្រះពុទ្ធទាំង

នោះ ទ្រង់សម្តែងដោយប្រពៃ នូវហេតុនុ៎ះ នេះជាហេតុ ហៅថា ជាម្ចាស់នៃផែនដី របស់ជនដ៏ច្រើន តថាគតជាស្តេច មានទ្រព្យសម្បត្តិច្រើន ជាអ្នកអង់អាច ជាអ្នកមានឫទ្ធិ មានយសជាឥស្សរៈក្នុងជម្ពូទ្វីប ។ បុគ្គលណាស្តាប់ហើយ មិនជ្រះថ្លាចាត់ជាកណ្ហាភិជាតិ ព្រោះហេតុនោះ បុគ្គលមានប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវការៈជាធំ រឭកនូវពុទ្ធសាសនា គប្បីធ្វើនូវសេចក្តីគោរពនូវព្រះសទ្ធម្មចុះ ។

# អដ្ឋកថា

## បុញ្ញវិបាកសូត្រ

[ ៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុញ្ញវិបាកសូត្រទី ៩ ដូចតទៅនេះ ពាក្យថា **មា ភិក្ខវេ បុញ្ញានំ ភាយិត្ថ** សេចក្តីថា ពួកអ្នកកាលធ្វើបុណ្យកុំខ្លាចចំពោះបុណ្យនោះឡើយ ។ ដោយពាក្យថា **មេត្តចិត្តំ ភាវេសឹ** ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគតអប់រំចិត្ត ធ្វើឲ្យប្រណីត ប្រកបមេត្តាដែលប្រកបដោយឈានពួក ៣ និងពួក ៤ ។

ពាក្យថា **សំវដ្តមានេ សុទាហំ** កាត់បទជា **សំវដ្តមានេ សុទំ អហំ ។** បទថា **សំវដ្តមានេ** សេចក្តីថា កាលលោកដែលត្រូវភ្លើងឆេះ គឺដែលភ្លើងធ្វើ

ឲ្យវិនាស ។ បទថា **ធម្មិកោ** បានដល់ ប្រកបដោយកុសលធម៌ ១០ ប្រការ ។ បទថា **ធម្មរាជា** នេះ ជាវេវចនៈនៃបទថា **ធម្មិកោ** នោះ ។ ម្យ៉ាងទៀត ឈ្មោះថា ជាធម្មរាជា ព្រោះទ្រង់បានរាជសម្បត្តិដោយធម៌ ។ បទថា **ចាតុរន្តោ** បានដល់ មានភាពជាធំក្នុងផែនដី ដែលឈ្មោះថា **ចតុរន្ត** ដោយអំណាចមានមហាសមុទ្រទាំង ៤ ក្នុងទិសបូព៌ជាដើម ។ បទថា **វិជិតាវី** ប្រែថា អ្នកឈ្នះសង្គ្រាម ។ ជនបទក្នុងដែនស្ដេចចក្រពត្តិនោះ ដល់នូវការមាំទាំជាថាវរៈ ព្រោះហេតុនោះ ទើបឈ្មោះថា **ជនបទត្ថាវរិយប្បត្តោ**។

បទថា **បរោសហស្សំ** ប្រែថា មានឱរសច្រើនជាង ១០០០ អង្គ ។ បទថា **សូរា** បានដល់ ជាអ្នកមិនខ្លាច ។ ក្នុងបទថា **វីរង្គរូបា** មានរូបវិគ្គហៈដូចតទៅនេះ អង្គរបស់បុគ្គលអង់អាច ឈ្មោះថា **វីរង្គ** វីរង្គៈជារូបនៃឱរសទាំងនោះ ហេតុនោះ ឱរសទាំងនោះ ឈ្មោះថា **វីរង្គរូបា** គឺមានអង្គនៃអ្នកក្លៀវក្លាជារូប ។ លោកអធិប្បាយថា ឱរសទាំងនោះមិនខ្ជិលច្រអូស ជាអ្នកមានសេចក្ដីព្យាយាមជាប្រក្រតី មានសេចក្ដីព្យាយាមជាសភាវៈ និងមានសេចក្ដីព្យាយាមច្រើន ។ លោកអធិប្បាយថា សូម្បីច្បាំងអស់មួយថ្ងៃក៏មិនហត់នឿយ ។ បទថា **សាគរបរិយន្តំ** សេចក្ដីថា មានមហាសមុទ្រដែលទល់គ្នានឹងភ្នំកណ្ដាប់ចក្រវាល ជាព្រំដែនជុំវិញ ។ បទថា **អទណ្ឌេន** បានដល់ វៀរចាកអាជ្ញា គឺការទទួលសំណូកដោយទ្រព្យខ្លះ ដាក់អាជ្ញាដោយច្បាប់ ដោយបញ្ជាឲ្យដាក់គុក កាត់ដៃជើង និងប្រហារជីវិតខ្លះ ។ បទថា

**អសត្ថេន** បានដល់ វៀរចាកការប្រើសស្ត្រាបៀតបៀនអ្នកដទៃ មានកាំបិតមុខម្ខាងជាដើម ។ បទថា **ធម្មេន អភិវិជិយ** សេចក្តីថា ទ្រង់ឈ្នះពេញផែនដី មានប្រការដូចពោលហើយ ដោយធម៌ ១ ដោយន័យជាដើមថា មិនគប្បីសម្លាប់សត្វ ដែលព្រះរាជាជាសត្រូវ ទទួលទ្រង់យ៉ាងនេះថា បពិត្រមហារាជ សូមទ្រង់យាងមកចុះ ។

បទថា **សុខេសិនំ** សេចក្តីថា រមែងហៅសត្វទាំងឡាយដែលស្វែងរកសេចក្តីសុខ ។ បទថា **សុញ្ញព្រហ្មុបគោ** សេចក្តីថា ដែលចូលដល់វិមានព្រហ្មដែលទទេ ។ បទថា **បឋវឹ ឥមំ** សេចក្តីថា នូវផែនដីធំដែលមានសាគរដោយជុំវិញ ។ បទថា **អសាហសេន** ប្រែថា ដោយកម្មដែលមិនបានគិត ។ បទថា **សមេន មនុសាសិតំ** សេចក្តីថា ប្រៀនប្រដៅដោយកម្មដ៏ស្មើ ។ បទថា **គេហិ ឯតំ សុទេសិតំ** សេចក្តីថា ឋានៈនេះ គឺមានប្រមាណប៉ុណ្ណោះ ដែលព្រះសុគតទាំងឡាយសម្តែងល្អហើយ ត្រាស់ល្អហើយ ។ បទថា **បថព្យា** ប្រែថា ម្ចាស់ផែនដី ។

## អដ្ឋកថា បុញ្ញាភិធានសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ភរិយាសូត្រទី ១០

[ ៦០ ] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅលំនៅ របស់អនាថបិណ្ឌិកគហបតី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ សម័យនោះឯង មនុស្សទាំងឡាយ មានសំឡេងហ៊ោកញ្ជ្រៀវ ក្នុងលំនៅនៃអនាថបិណ្ឌិក-គហបតី ។ លំដាប់នោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី មនុស្សទាំងឡាយ មានសំឡេងហ៊ោកញ្ជ្រៀវក្នុងលំនៅនៃអ្នក ទំនងដូចជាព្រានសន្ទូចចាប់ត្រីដូចម្តេចហ្ន៎ ។ បពិត្រព្រះអង្គដ៏ចម្រើន នាងសុជាតានេះ ជាឃរសុណ្ហា ( កូនប្រសាស្រីក្នុងផ្ទះ ) ខ្ញុំព្រះអង្គបាននាំមកអំពីត្រកូលស្តុកស្តម្ភ នាងសុជាតានោះ មិនអើពើនឹងឪពុកក្មេក មិនអើពើនឹងម្តាយក្មេក មិនអើពើនឹងស្វាមី ទាំងមិនបានធ្វើសក្ការៈ មិនបានគោរព មិនបានរាប់អាន មិនបានបូជាព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅនាងសុជាតាជាឃរសុណ្ហាថា ម្នាលនាងសុជាតា ចូរនាងមកនេះ ។ នាងសុជាតាជាឃរ-សុណ្ហា បានទទួលព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយ

បង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងសុជាតាជាយរ-សុណ្ហា អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលនាងសុជាតា ភរិយារបស់បុរសនេះមាន ៧ ពួក ។ ភរិយា ៧ ពួក តើដូចម្តេចខ្លះ ។ គឺវធសមាភរិយា ( ភរិយាស្មើដោយអ្នកសម្លាប់ ) ១ ចោរសមាភរិយា ( ភរិយាស្មើដោយចោរ ) ១ អយ្យសមាភរិយា ( ភរិយាស្មើដោយម្ចាស់ ) ១ មាតុសមាភរិយា ( ភរិយាស្មើដោយមាតា ) ១ ភគិនិ-សមាភរិយា ( ភរិយាស្មើដោយប្អូនស្រី ) ១ សខីសមាភរិយា ( ភរិយាស្មើដោយសម្លាញ់ ) ១ ទាសីសមាភរិយា ( ភរិយាស្មើដោយខ្ញុំស្រី ) ១ ។ ម្នាលនាងសុជាតា នេះជាភរិយា ៧ ជំពូក របស់បុរស ។ បណ្តាភរិយាទាំង ៧ ពួកនោះ នាងជាភរិយាដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានដឹងនូវអត្ថនៃភាសិតនេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដោយសេចក្តីសង្ខេប ឲ្យពិស្តារបានទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីដឹងនូវអត្ថនៃភាសិតនេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយសេចក្តីសង្ខេប ឲ្យពិស្តារបានយ៉ាងណា សូមព្រះដ៏មានព្រះភាគ សម្តែងនូវធម៌ឲ្យប្រពៃ ដល់ខ្ញុំព្រះអង្គយ៉ាងនោះ ។ ម្នាលនាងសុជាតា បើដូច្នោះ ចូរនាងចាំស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃ តថាគតនឹងសម្តែង ។ នាងសុជាតាជាយរសុណ្ហាបានទទួលព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា

កិរិយាដែលស្វាមី លោះមកដោយទ្រព្យ ស្ត្រីមានចិត្តប្រទូស្ត ( នឹងស្វាមី ) មានសេចក្តីមិនអនុគ្រោះនូវប្រយោជន៍ ជាអ្នកត្រេកត្រអាលក្នុងបុរសដទៃ មើលងាយប្តី ខ្វល់ខ្វាយដើម្បីសម្លាប់ ( ប្តី ) ស្ត្រីណាជាកិរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា វធកាកិរិយា ។ ស្វាមីនៃស្ត្រី បាននូវទ្រព្យណា ហើយតម្កល់ទុក ដើម្បីធ្វើនូវសិល្បៈក្តី នូវជំនួញក្តី នូវកសិកម្មក្តី ស្ត្រីនោះប្រាថ្នាដើម្បីលួច គិបយកនូវទ្រព្យ សូម្បីបន្តិចបន្តួចអំពីទ្រព្យនោះ ស្ត្រីណាជាកិរិយា នៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា ចោរីកិរិយា ។ ស្ត្រីមិនមានសេចក្តីប្រាថ្នា នឹងធ្វើនូវការងារ ជាអ្នកខ្ជិលច្រអូស ស៊ីច្រើន រឹងរូស កាច ពោលនូវពាក្យអាក្រក់ ប្រព្រឹត្តគ្របសង្កត់នូវស្វាមី ដែលមានព្យាយាមប្រឹងប្រែង ស្ត្រីណា ជាកិរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា អយ្យាកិរិយា ។ ស្ត្រីណា មានសេចក្តីអនុគ្រោះនូវប្រយោជន៍ សព្វៗ កាល ចេះរក្សាប្តីដូចជាមាតារក្សាកូន ទាំងរក្សានូវទ្រព្យដែលស្វាមីនោះ បានមកអំពីទីនោះៗ ស្ត្រីណា ជាកិរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះហៅថា មាតាកិរិយា ។ ស្ត្រីមានសេចក្តីគោរព ក្នុងស្វាមីរបស់ខ្លួន ដូចប្អូនស្រីគោរពបងប្រុស មានសេចក្តីអៀនខ្មាស ប្រព្រឹត្តទៅតាមអំណាចនៃភស្តា

ស្ត្រីណា ជាភរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា ភគិនីភរិយា ។ ស្ត្រីណា ក្នុងលោកនេះ បានឃើញនូវប្តីហើយ ក៏រីករាយ ដូចជាសម្លាញ់ បានឃើញសម្លាញ់ ដែលមកអស់ កាលយូរ ស្ត្រីនោះ បរិបូណ៌ដោយត្រកូល មានសីលធម៌ ជា ស្ត្រីមានវត្តប្រតិបត្តិ ក្នុងប្តី ស្ត្រីណា ជាភរិយានៃបុរស មាន សភាពដូច្នេះ ស្ត្រីនោះ ហៅថា សខីភរិយា ។ ស្ត្រីដែលស្វាមី ជេរ វាយ គំរាម ដោយដំបង មិនមានចិត្តប្រទូស្តវិញ ចេះអត់ សង្កត់ដល់ប្តី មិនក្រោធ ប្រព្រឹត្តទៅតាមអំណាចនៃកស្តា ស្ត្រី ណា ជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះហៅថា ទាសី ភរិយា ។ ភរិយាណាក្នុងលោកនេះ ដែលហៅថាវធកាភ្គី ហៅ ថា ចោរីភ្គី ហៅថា អយ្យាភ្គី ភរិយាទាំងនោះ មានសភាពជា ស្ត្រីទ្រុស្តសីល រឹងរូស មិនមានសេចក្តីគោរព លុះបែកធ្លាយ រាងកាយស្លាប់ទៅ រមែងទៅកាន់នរក ។ ភរិយាណា ក្នុងលោក នេះ ដែលហៅថា មាតាភ្គី ភគិនីភ្គី សខីភ្គី ទាសីភ្គី ភរិយាទាំង នោះជាស្ត្រីសង្រួមអស់កាលជាយូរអង្វែង ព្រោះតាំងនៅក្នុងសីល-ធម៌ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកាន់សុគតិ ។

ម្នាលនាងសុជាតា នេះជាភរិយារបស់បុរស ៧ ពួក បណ្តាភរិយាទាំង ៧ ពួកនោះ នាងតើជាភរិយាដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មាន

ព្រះភាគ សម្គាល់ទុកនៅខ្ញុំព្រះអង្គជាថាកិរិយាស្មើដោយទាសីរបស់ស្វាមី ចាប់ដើមអំពីថ្ងៃនេះតទៅ ។

# អដ្ឋកថា

## ភរិយាសូត្រ

[ ៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភរិយាសូត្រទី ១០ ដូចតទៅនេះ បទថា **កេវដ្ដា មញ្ញេ មច្ឆេ វិលោបេតិ** សេចក្ដីថា ក្នុងទីដែលអ្នក ប្រមង់ឈរលើកត្រកត្រីចុះ គ្រាន់តែលើកអួនឡើងអំពីទឹកប៉ុណ្ណោះ អ្នកចាប់ត្រីក៏បន្លឺសំឡេងខ្លាំង ព្រះមានព្រះភាគទ្រង់សំដៅយកសេចក្ដីនោះ ទើបត្រាស់ពាក្យនោះ ។ បទថា **សុជាតា** បានដល់ ស្រីដែលជាប្អូនមហាឧបាសិកាឈ្មោះវិសាខា ។ បទថា **សា នេវ សស្សុំ អាទិយតិ** សេចក្ដីថា នាងសុជាតានោះមិនធ្វើវត្តបដិបត្តិដែលឈ្មោះថា វត្តដែលស្រីកូនប្រសាគប្បីធ្វើដល់មាតាក្មេកទាំងមិនព្រមទទួលរាប់អានមាតាក្មេកថា ជាមាតា ។ បទថា **ន សស្សុរំ អាទិយតិ** សេចក្ដីថា នាងសុជាតានោះ មិនព្រមស្ដាប់ពាក្យបិតាក្មេក កាលបើដូច្នេះ ទើបឈ្មោះថា នាងមិនស្ដាប់ ព្រោះនាងមិនអើពើខ្វះ ព្រោះនាងមិនព្រមទទួលខ្វះ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា អនាថបិណ្ឌិកសេដ្ឋីកាន់យកមារយាទរបស់ស្រីកូនប្រសានោះ ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្ដា ដោយ

ប្រការដូច្នេះ ។ ចំណែកនាងសុជាតាគិតថា សេដ្ឋីនេះនឹងពោលសរសើរគុណរបស់អញក្នុងសម្នាក់ព្រះទសពល ឬពោលទោសហ្ន៎ ដូច្នេះហើយ បានទៅឈរស្តាប់សំឡេងនោះ ក្នុងទីមិនឆ្ងាយ លំដាប់នោះ ព្រះសាស្តាត្រាស់ហៅនាងមក ហើយត្រាស់ថា ម្នាលនាងសុជាតា នាងចូរមកអាយ ។ បទថា **អហិតានុកម្បិនី** ប្រែថា ដែលមិនអនុគ្រោះដោយប្រយោជន៍ ។ បទថា **អញ្ញេសុ** បានដល់ ក្នុងបុរសដទៃ ។ បទថា **អតិមញ្ញតេ** សេចក្តីថា រមែងលើកខ្លួន គឺរមែងមើលងាយដោយអំណាចមានះ ។ បទថា **ធនេន កីតស្ស** ភាពជាបុគ្គលដែលគេទិញមកដោយទ្រព្យ ។ បទថា **វធាយ ឧស្សុក្កា** សេចក្តីថា ព្យាយាមនឹងសម្លាប់ ។ បទថា **យំ ឥត្ថិយា វិន្ទតិ សាមិកោ ធនំ** សេចក្តីថា ប្តីរបស់ស្រីបានទ្រព្យណាមក ។ បទថា **អប្បម្បិស្ស អបហាតុមិច្ឆតិ** សេចក្តីថា កិរិយាប្រាថ្នានឹងលួចទ្រព្យ សូម្បីមានតិចតួចនោះ គឺព្យាយាមលួចទ្រព្យដែលតិចតួច សូម្បីអង្ករដែលល្មមប្រកឆ្នាំង ដែលលើកឡើងដាក់ជើងប្រាន ។ បទថា **អលសា** សេចក្តីថា ជាអ្នកអង្គុយដំអក់ក្នុងទីដែលខ្លួនអង្គុយ ឈរដំអក់ក្នុងទីដែលខ្លួនឈរ ។ បទថា **ផរុសា** ប្រែថា រឹង ។ បទថា **ទុរុត្តវាទិនី** សេចក្តីថា ជាអ្នកមានប្រក្រតីពោលវាចាដែលជាទុព្ភាសិត វាចាអាក្រក់ គឺពោលពាក្យគ្រោតគ្រាត និងរឹងត្អឹងនោះឯង ។ ក្នុងពាក្យថា **ឧដ្ឋាយកានំ អភិភុយ្យ វត្តតិ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ព្រះមានព្រះភាគ ត្រាស់ដល់ប្តីដែលសម្បូរដោយសេចក្តីព្យាយាម ជាគ្រឿង

ភ្ញាក់រឭក ដោយសព្ទដែលជាពហុវចនៈថា **ឧដ្ឋាយកាធំ** ដូច្នេះ ។ កិរិយាប្រព្រឹត្តសង្កត់សង្កិនប្តីដែលសម្បូរដោយការព្យាយាមនោះ ហើយធ្វើប្តីនោះឲ្យនៅខាងក្រោមអំណាចខ្លួន ។ បទថា **បមោទតិ** សេចក្តីថា រមែងជាអ្នកត្រេកអររីករាយ ។ បទថា **កោលេយ្យកា** សេចក្តីថា ដល់ព្រមដោយត្រកូល ។ បទថា **បតិព្វតា** បានដល់ បតិទេវតា គឺជាប្តីដូចទេវតា ។ បទថា **វធទណ្ឌតជ្ជិតា** សេចក្តីថា កិរិយាដែលស្វាមីកាន់ដំបង សម្លុតដោយការសម្លាប់ថា អញនឹងសម្លាប់ហង ដូច្នេះ ។ បទថា **ទាសីសមំ** សេចក្តីថា នាងសុជាតាក្រាបទូលថា សូមព្រះមានព្រះភាគទ្រង់ចាំនូវខ្ញុំម្ចាស់ថាជាទាសី បរិបូណ៌ដោយវត្តបដិបត្តិប្តី ដូច្នេះហើយ តាំងនៅក្នុងសរណៈទាំង ៣ ។៚

អដ្ឋកថា ភរិយាសូត្រទី ១០ ចប់

# សុត្តន្តបិដក

## កោធនាសូត្រទី ១១

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្តីក្រោធ ។ ធម៌ ៧ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សត្រូវក្នុងលោកនេះ

រមែងប្រាថ្នានូវហេតុយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះមានវណ្ណៈអាក្រក់ ៗ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិនត្រេកអរដល់សត្រូវព្រោះវណ្ណៈទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ ( កាលបើ ) មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ បុរសបុគ្គលនោះ ទុកជាងូតស្អាត លាបស្រឡាបល្អ បានកោសក់ និងពុកមាត់ ហើយស្លៀកសំពត់មានពណ៌សក៏មែនពិតហើយ ប៉ុន្តែបុរសបុគ្គលនោះ ឈ្មោះថា មានវណ្ណៈអាក្រក់ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ទី ១ ជាទីត្រេកអរនៃសត្រូវជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរសភាពដែលមានសេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នានូវហេតុយ៉ាងនេះដល់សត្រូវថា ឱហ្ន៎សូមឲ្យបុគ្គលនេះដេកជាទុក្ខ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិនត្រេកអរក្នុងការដេកជាសុខរបស់សត្រូវទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ បុរសបុគ្គលនោះ ទុកជាដេកលើបល្ល័ង្ក លើកម្រាលព្រំដែលមានរោមវែងជាង ៤ ធ្នាប់ លើកម្រាលមានពណ៌សដែលធ្វើដោយរោមសត្វ លើកម្រាលដែលគេធ្វើដោយរោមសត្វជាផ្កាចង្កោម លើកម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកឈ្លូស មានខ្នើយមានពណ៌ក្រហមទាំងពីរខាង ព្រមទាំងពិតានដែលមានពណ៌ក្រហម ក៏មែនពិត

ហើយ ប៉ុន្តែបុរសបុគ្គលនោះ ត្រូវសេចក្ដីក្រោធគ្របសង្កត់ហើយ ក៏ឈ្មោះថា ដេកជាទុក្ខដោយពិត ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្ដីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានប្រយោជន៍ច្រើនឡើយ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិនត្រេកអរក្នុងប្រយោជន៍ដ៏ច្រើនរបស់សត្រូវទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ ជាអ្នកមានសេចក្ដីក្រោធ មានសេចក្ដីក្រោធគ្របសង្កត់ មានសេចក្ដីក្រោធរួបរឹតហើយ កាន់យកនូវហេតុមិនមែនជាប្រយោជន៍ សម្គាល់ជាប្រយោជន៍ អាត្មាអញបានកាន់យកហើយផង កាន់យកនូវហេតុជាប្រយោជន៍ សម្គាល់ថា ហេតុមិនមែនជាប្រយោជន៍ អាត្មាអញបានកាន់យកហើយផង ។ នេះជាធម៌ ជាសត្រូវដល់គ្នានិងគ្នា ដែលសត្រូវនោះ មានសេចក្ដីក្រោធគ្របសង្កត់កាន់យកហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលជាយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្ដីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានភោគៈឡើយ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ

សត្រូវរមែងមិនត្រេកអរដល់សត្រូវ ព្រោះមានភោគៈទេ ម្នាលភិក្ខុទាំង-ឡាយ កាលបើបុរសបុគ្គលមានសេចក្ដីក្រោធ មានសេចក្ដីក្រោធគ្របសង្កត់ មានសេចក្ដីក្រោធរួបរឹតហើយ ភោគៈទាំងឡាយណាដែលបុគ្គលនោះ បានមកដោយសេចក្ដីប្រឹងប្រែង ព្យាយាមសន្សំដោយកម្លាំងដៃ បែកញើស ហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ព្រះរាជាទាំងឡាយរមែងញុំាងភោគៈទាំងនោះ របស់បុគ្គលដែលមានសេចក្ដីក្រោធគ្របសង្កត់ ឲ្យចូលទៅកាន់ព្រះឃ្លាំង ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្ដីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានយសឡើយ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិនត្រេកអរដល់សត្រូវ ព្រោះមានយសទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះមានសេចក្ដីក្រោធ មានសេចក្ដីក្រោធគ្របសង្កត់ មានសេចក្ដីក្រោធរួបរឹតហើយ យសណារបស់បុគ្គលនោះ ដែលបានមកដោយសេចក្ដីមិនប្រមាទ ( កាលបើ ) មានសេចក្ដីក្រោធគ្របសង្កត់ហើយ ក៏រមែងភ្លាត់ចេញចាកយសនោះមិនខានឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្ដីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់

សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានមិត្តឡើយ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិនត្រេកអរដល់សត្រូវ ព្រោះមានមិត្តទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះមានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ ពួកមិត្តអាមាត្យ ញាតិ-សាលោហិតណាបស់បុរសបុគ្គលនោះ ពួកជនទាំងនោះ រមែងវៀរបង់នូវបុរសបុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់នោះអំពីចម្ងាយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៦ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវរមែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ គប្បីចូលទៅកើតក្នុងតិរច្ឆានប្រេត អសុរកាយ នរក ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិនត្រេកអរដល់សត្រូវ ដោយដំណើរទៅកាន់សុគតិទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែបុរសបុគ្គលនេះ មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ មានសេចក្តីក្រោធរួបរឹតហើយ ក៏ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ លុះបុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់នោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ ម្នាលភិក្ខុទាំងឡាយ នេះជា

ធម៌ទី ៧ ដែលជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ ប្រការនេះ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្តីក្រោធជាប្រក្រតី ។

បុគ្គលមានសេចក្តីក្រោធ រមែងមានវណ្ណៈអាក្រក់ ទាំងបុគ្គលនោះរមែងដេកជាទុក្ខ ទោះបីកាន់យកនូវប្រយោជន៍ហើយ រមែងប្រតិបត្តិមិនជាប្រយោជន៍វិញ បុរសមានសេចក្តីក្រោធ ត្រូវសេចក្តីក្រោធគ្របសង្កត់ ធ្វើនូវការសម្លាប់ដោយកាយ ដោយវាចាក្នុងកាលនោះហើយ រមែងដល់នូវសេចក្តីសាបសូន្យចាកទ្រព្យមិនខាន បុរសដែលស្រវឹង ព្រោះស្រវឹងដោយសេចក្តីក្រោធហើយ រមែងដល់នូវសេចក្តីអាប់យស ពួកញាតិមិត្ត និងអ្នកមានចិត្តល្អ សម្លាញ់ រមែងជៀសវាងនូវបុគ្គលអ្នកមានសេចក្តីក្រោធ ។ សេចក្តីក្រោធជាហេតុឲ្យកើតសេចក្តីវិនាស សេចក្តីក្រោធជាហេតុញុំាងចិត្តឲ្យកម្រើក ភ័យកើតឡើងក្នុងសន្តាន ជនមិនបានដឹងនូវភ័យនោះឡើយ ។ បុគ្គលអ្នកក្រោធ មិនដឹងនូវសេចក្តីចម្រើន បុគ្គលអ្នកក្រោធមិនឃើញនូវធម៌ សេចក្តីក្រោធគ្របសង្កត់នូវជនណា សេចក្តីងងឹតរមែងមានប្រាកដដល់ជននោះក្នុងកាលនោះដែរ ។ បុគ្គលអ្នកក្រោធ បៀតបៀននូវបុគ្គលណា

កាលធ្វើនូវអំពើអាក្រក់ ហាក់ដូចជាអំពើល្អ បុគ្គលអ្នកក្រោធនោះ កាលបើសេចក្ដីក្រោធប្រាសចេញហើយ រមែងក្ដៅក្រហាយជាខាងក្រោយ ដូចជាត្រូវភ្លើងឆេះ ។ សេចក្ដីក្រោធធូលឡើងក្នុងវេលាណា មាណពទាំងឡាយទឹងក្នុងវេលាណា រមែងសម្ដែងនូវមុខក្រញូវជាដំបូង ក្នុងវេលានោះ ដូចភ្លើងកាលបង្ហុយនូវផ្សែង ។ បុគ្គលនោះមិនមានហិរិ មិនមានឱត្តប្បៈ មិនមានសេចក្ដីគោរពឡើយ បុគ្គលត្រូវសេចក្ដីក្រោធគ្របសង្កត់ហើយ រមែងរកទីពឹងបន្តិចបន្តួចគ្មាន ។ កម្មទាំងឡាយណា ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ក៏រមែងឆ្ងាយអំពីធម៌ តថាគតនឹងសម្ដែងប្រាប់នូវកម្មទាំងនោះ ចូរអ្នកទាំងឡាយចាំស្ដាប់នូវធម៌នោះតាមសេចក្ដីពិត ។ បុគ្គលក្រោធសម្លាប់នូវបិតាក៏មាន បុគ្គលក្រោធសម្លាប់នូវមាតារបស់ខ្លួនក៏មាន បុគ្គលក្រោធសម្លាប់នូវទីណាសវ-ព្រាហ្មណ៍ក៏មាន បុគ្គលក្រោធសម្លាប់នូវបុថុជ្ជនក៏មាន ។ បុរសដែលមាតាចិញ្ចឹមហើយ បានឃើញច្បាស់នូវលោកនេះ បុថុជ្ជនដែលក្រោធរមែងសម្លាប់នូវមាតា ដែលឲ្យនូវជីវិតនោះក៏មាន ។ សត្វទាំងនោះមានខ្លួនជាឧបមា ព្រោះខ្លួនជាទីស្រឡាញ់ដ៏ឧត្តម បុគ្គលក្រោធដែលជ្រប់ទៅក្នុងរូបផ្សេងៗ រមែងសម្លាប់នូវខ្លួនដោយហេតុផ្សេងៗ ។ ពួកជនដែលជ្រប់ទៅ ( ក្នុងរូបផ្សេងៗ )

ហើយរមែងសម្លាប់ខ្លួនដោយដាវ ទំពារស៊ីនូវថ្នាំពិស ចងកសម្លាប់ ទម្លាក់ខ្លួនក្នុងជ្រោះភ្នំ ។ ជនទាំងឡាយ កាលធ្វើនូវអំពើជាហេតុ នាំឲ្យសាបសូន្យចាកសេចក្តីចម្រើនផង ជាហេតុនឹងសម្លាប់ខ្លួនផង រមែងមិនបានដឹងខ្លួនទេ បុគ្គលដែលមានសេចក្តីក្រោធកើតឡើងហើយ រមែងវិនាសមិនខាន ។ អន្ទាក់ គឺសេចក្តីស្លាប់នេះ ជាគុហា ជាទីអាស្រ័យនៅដោយសភាពនៃសេចក្តីក្រោធ ដោយប្រការដូច្នេះ បុគ្គលគួរផ្តាច់ផ្តិលនូវសេចក្តីក្រោធនោះចេញ ដោយទមៈ បញ្ញា ព្យាយាម និងមគ្គសម្មាទិដ្ឋិ បណ្ឌិតគប្បីផ្តាច់ផ្តិលនូវអកុសលមួយៗ ។ បុគ្គលគប្បីសិក្សានូវធម៌ទាំងឡាយ ដូច្នោះថា យើងទាំងឡាយ កុំមានមុខក្រញូវឡើយ ។ កាលបើអ្នកមិនមានសេចក្តីក្រោធ មិនមានសេចក្តីប៉ុនប៉ង មិនមានសេចក្តីលោភ មិនមានសេចក្តីខ្វល់ខ្វាយ មានខ្លួនទូន្មានហើយ សម្លាប់បង់នូវសេចក្តីក្រោធហើយ នឹងបានជាអនាសវបុគ្គល បរិនិព្វានពុំខាន ។

**អព្យាកតវគ្គទី ១ ចប់**

## ឧទ្ទាននៃអព្យាកតវគ្គនោះគឺ

និយាយអំពីវត្ថុដែលគេមិនបានពោល ១ អំពីញាណគតិរបស់បុរស ១ អំពីភិក្ខុឈ្មោះតិស្សៈ ១ អំពីសេនាបតី

ឈ្មោះសីហៈ ១ អំពីហេតុដែលព្រះដ៏មានព្រះភាគមិនបាច់រក្សា ជាគម្រប់ប្រាំ អំពីព្រះកិមិលៈ ១ អំពីករិយា ៧ ពួក ១ អំពីសេចក្តីក្រោធ ១ ។

# អដ្ឋកថា

## កោធនាសូត្រ

[ ៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកោធនាសូត្រទី ១១ ដូចតទៅនេះ បទថា **សបត្តកន្តា** បានដល់ ជាទីពេញចិត្ត គឺជាទីស្រឡាញ់របស់បុគ្គលដែលជាសត្រូវ ដែលមានពៀរចំពោះគ្នា គឺជាអ្នកតាំងនៅក្នុងភាវៈដែលជាសត្រូវទាំងនោះប្រាថ្នាហើយ ។ បទថា **សបត្តការណា** បានដល់ ហេតុនៃប្រយោជន៍របស់បុគ្គលដែលជាសត្រូវមានពៀរនឹងគ្នា ។ បទថា **កោធបរេតោ** បានដល់ នៅក្នុងអំណាចសេចក្តីក្រោធ ។ បទថា **បចុរត្ថតាយ** បានដល់ ដើម្បីជាប្រយោជន៍ច្រើន ដើម្បីឧបការៈច្រើន ។ បទថា **អនត្ថំបិ** បានដល់ នូវសេចក្តីមិនចម្រើន ។ បទថា **អត្ថោ មេ គហិតោ** សេចក្តីថា អាត្មាអញកាន់យកតែសេចក្តីចម្រើន ។ បទថា **អថោ អត្ថំ គហេត្វាន** សេចក្តីថា ម្យ៉ាងទៀត កាលកាន់យកការចម្រើនបានហើយ ។ បទថា **អនត្ថំ បដិបជ្ជតិ** សេចក្តីថា រមែងកំណត់ថា អាត្មាអញកាន់យកវត្ថុដែលមិនជាប្រយោជន៍

ហើយ ។ បទថា **វធំ កត្វាន** សេចក្តីថា ធ្វើកម្ម គឺបាណាតិបាតហើយ ។ បទថា **កោធសម្មទសម្មត្តោ** សេចក្តីថា បុគ្គលស្រវឹងហើយ ដោយសេចក្តីស្រវឹង គឺសេចក្តីក្រោធ អធិប្បាយថា បុគ្គលមានសេចក្តីស្រវឹង ដែលខ្លួនប្រកាន់ពាល់ត្រូវហើយ ។ បទថា **អាយសក្យំ** បានដល់ នូវការមិនមានយស អធិប្បាយថា ជាអ្នកប្រាសចាកយស គឺភាពជាអ្នកឥតយស ។ បទថា **អន្តរតោ ជាតំ** បានដល់ កើតឡើងហើយខាងក្នុង ។ បទថា **អត្ថំ ន ជានាតិ** សេចក្តីថា មិនស្គាល់ប្រយោជន៍ គឺសេចក្តីចម្រើន ។ បទថា **ធម្មំ ន បស្សតិ** សេចក្តីថា រមែងមិនឃើញធម៌ គឺសមថៈ និងវិបស្សនា ។ បទថា **អន្ធតមំ** សេចក្តីថា អវិជ្ជាដែលធ្វើនូវការខ្វាក់ ឬការងងឹតស្លុប ។ បទថា **សហតេ** បានដល់ រមែងគ្របសង្កត់ ។ បទថា **ទុម្មង្កុយំ** សេចក្តីថា ដល់នូវភាពសោះកក្រោះ គឺដល់នូវភាពជាអ្នកមិនមានអំណាច គឺភាពជាអ្នកមានមុខក្រញូវ ។ ពីរបទថា **យតោ បតាយតិ** សេចក្តីថា កើតឡើងក្នុងកាលណា ។ បាទព្រះគាថាថា **ន វាចោ ហោតិ គារវោ** សេចក្តីថា ពាក្យដែលមិនគួរជាទីគោរព ។ បាទព្រះគាថាថា **ន ទីបំ ហោតិ កិញ្ចនំ** សេចក្តីថា ឈ្មោះថា ទីពឹងណាមួយរមែងមិនមាន ។ បទថា **តបនីយានិ** បានដល់ ដែលធ្វើនូវការក្តៅក្រហាយឲ្យកើត ។ បទថា **ធម្មេហិ** បានដល់ ដោយធម៌ គឺសមថៈ និងវិបស្សនា ។ បទថា **អារកា** ប្រែថា ក្នុងទីឆ្ងាយ ។ បទថា **ព្រាហ្មណំ** បានដល់ នូវព្រាហ្មណ៍ គឺព្រះខីណាស្រព ។

បទថា **យាយ មាតុ ភតោ** សេចក្តីថា ដែលមាតាណាចិញ្ចឹម គឺបីបាច់រក្សាហើយ ។ បទថា **ចាណានធី សន្តី** បានដល់ ដែលឲ្យជីវិត ។ បទថា **ហន្តិ កុទ្ធោ បុថុត្តានំ** សេចក្តីថា បុគ្គលក្រោធហើយ រមែងសម្លាប់ខ្លួនដោយហេតុផលផ្សេងៗ ដ៏ច្រើន ។ បទថា **នានារូបេសុ មុច្ឆិតោ** សេចក្តីថា ជាបុគ្គលវេងវោងហើយក្នុងអារម្មណ៍ផ្សេងៗ ។ បទថា **រជ្ជុយា ពជ្ឈមិយ្យន្តិ** សេចក្តីថា យកខ្សែចង-កស្លាប់ ។ បទថា **បព្វតាមបិ កន្ទរេ** សេចក្តីថា លោតពីលើភ្នំស្លាប់ក៏មាន ។ បទថា **ភូតហច្ចានិ** សេចក្តីថា កម្ចាត់នូវសេចក្តីចម្រើនចោល ។ សព្ទថា **ឥតាយំ** កាត់បទជា **ឥតិ អយំ** ។ បទថា **តំ ទមេន សមុច្ឆិន្ទេ** សេចក្តីថា គប្បីកាត់នូវសេចក្តីក្រោធបានដោយទមៈ គឺទូន្មានខ្លួន សួរថា ដោយទមៈមួយណា ឆ្លើយថា ដោយទមៈ គឺបញ្ញា វីរិយៈ និងទិដ្ឋិ ។ បទថា **បញ្ញាវីរិយេន ទិដ្ឋិយា** សេចក្តីថា ដោយបញ្ញាដែលសម្បយុត្តដោយវិបស្សនា ដោយសេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្តដែលសម្បយុត្តដោយវិបស្សនា និងដោយសម្មាទិដ្ឋិក្នុងមគ្គនោះឯង ។ បទថា **តថេវ ធម្មេ សិក្ខេថ** សេចក្តីថា បុគ្គលគប្បីកាត់នូវអកុសលចេញបានដោយប្រការណា គប្បីសិក្ខាក្នុងធម៌ គឺសមថៈ និងវិបស្សនា ដោយប្រការនោះឯង ។ បទថា **មា នោ ទុម្មង្កុយំ អហុ** សេចក្តីថា ប្រាថ្នាប្រយោជន៍នេះថា សូមជាបុគ្គលដែលមានមុខក្រញូវកុំមានហើយដល់យើងទាំងឡាយ ។

*បទថា* **អណាយាសា** *បានដល់ មិនមានការចង្អៀតចង្អល់ ។ បទថា* **អនុស្សុក្កា** *សេចក្តីថា មិនដល់នូវការខ្វល់ខ្វាយក្នុងទីណាមួយឡើយ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ហើយ ៕*

## អដ្ឋកថា កោធនាសូត្រទី ១១ ចប់

# សុត្តន្តបិដក

## មហាវគ្គ

### ហិរិសូត្រទី ១

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ កាលបើហិរិ និងឱត្តប្បៈមិនមាន ឥន្ទ្រិយ-សំវរៈនៃបុគ្គលអ្នកវិបត្តិចាកហិរិ និងឱត្តប្បៈ ឈ្មោះថា មានហេតុសាបសូន្យ កាលបើឥន្ទ្រិយសំវរៈមិនមាន សីលនៃបុគ្គលអ្នកវិបត្តិចាកឥន្ទ្រិយសំវរៈ ឈ្មោះថា មានហេតុសាបសូន្យ កាលបើសីលមិនមានសម្មាសមាធិ នៃបុគ្គលអ្នកវិបត្តិចាកសីល ឈ្មោះថា មានហេតុសាបសូន្យ កាលបើសម្មា-សមាធិមិនមាន យថាភូតញ្ញាណទស្សនៈនៃបុគ្គលអ្នកវិបត្តិចាកសម្មាសមាធិ ឈ្មោះថា មានហេតុសាបសូន្យ កាលបើយថាភូតញ្ញាណទស្សនៈមិនមាន និព្វិទាវិរាគៈនៃបុគ្គលអ្នកវិបត្តិចាកយថាភូតញ្ញាណទស្សនៈ ឈ្មោះថា មានហេតុសាបសូន្យ កាលបើនិព្វិទាវិរាគៈមិនមាន វិមុត្តិញ្ញាណទស្សនៈនៃបុគ្គលអ្នកវិបត្តិចាកនិព្វិទាវិរាគៈ ឈ្មោះថា មានហេតុសាបសូន្យ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើដែលវិបត្តិចាកមែក និងស្លឹក ក្រមរនៃឈើនោះក្តីក៏មិនសូវបរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនសូវបរិបូណ៌យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើហិរិ និងឱត្តប្បៈមិនមាន ឥន្ទ្រិយសំវរៈនៃបុគ្គលអ្នកវិបត្តិចាកហិរិ និងឱត្តប្បៈ ឈ្មោះថា មានហេតុសាបសូន្យ ។បេ។ វិមុត្តញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើហិរិ

និងឱត្តប្បៈមាន ឥន្ទ្រិយសំវរៈនៃបុគ្គលអ្នកបរិបូណ៌ដោយហិរិ និងឱត្តប្បៈ ឈ្មោះថា បរិបូណ៌ដោយហេតុ កាលបើឥន្ទ្រិយសំវរៈមាន សីលនៃបុគ្គលអ្នកបរិបូណ៌ដោយឥន្ទ្រិយសំវរៈ ឈ្មោះថា បរិបូណ៌ដោយហេតុ កាលបើសីលមាន សម្មាសមាធិនៃបុគ្គលអ្នកបរិបូណ៌ដោយសីល ឈ្មោះថា បរិបូណ៌ដោយហេតុ កាលបើសម្មាសមាធិមាន យថាភូតញ្ញាណទស្សនៈនៃបុគ្គលអ្នកបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា បរិបូណ៌ដោយហេតុ កាលបើយថា-ភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគៈនៃបុគ្គលអ្នកបរិបូណ៌ដោយយថា-ភូតញ្ញាណទស្សនៈ ឈ្មោះថា បរិបូណ៌ដោយហេតុ កាលបើនិព្វិទាវិរាគៈមាន វិមុត្តិញ្ញាណទស្សនៈនៃបុគ្គលអ្នកបរិបូណ៌ ដោយនិព្វិទាវិរាគៈ ឈ្មោះថា បរិបូណ៌ដោយហេតុ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដើមឈើដែលបរិបូណ៌ដោយមែក និងស្លឹក ក្រមរនៃឈើនោះក្តីក៏បរិបូណ៌ សំបកក្តី ស្រាយក្តី ខ្លឹមក្តី ក៏បរិបូណ៌ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើហិរិ និងឱត្តប្បៈមាន ឥន្ទ្រិយសំវរៈនៃបុគ្គលអ្នកបរិបូណ៌ដោយហិរិ និងឱត្តប្បៈ ឈ្មោះថា បរិបូណ៌ដោយហេតុ ។បេ។ វិមុត្តិញ្ញាណទស្សនៈក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

# មហាវគ្គទី ៧

## ហិរិសូត្រ

[ ៦២ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងហិរិសូត្រទី ១ នៃមហាវគ្គទី ៧ ដូច្នេះ បទថា* **ហតូបនិសោ** *បានដល់ មានហេតុត្រូវកម្ចាត់ហើយ មានបច្ច័យកាត់ហើយ ។ បទថា* **យថាភូតញ្ញាណទស្សនំ** *បានដល់ វិបស្សនាយ៉ាងទន់ ។ បទថា* **និព្វិទាវិរាគោ** *បានដល់ វិបស្សនាមានកម្លាំង និងមគ្គ ។ បទថា* **វិមុត្តិញ្ញាណទស្សនំ** *បានដល់ អរហត្តវិមុត្តិ និងបច្ចវេក្ខណញ្ញាណ ។*

អដ្ឋកថា ហិរិសូត្រទី ១ ចប់

# សុត្តន្តបិដក

## សុរិយសូត្រទី ២

[ ៦៣ ] *សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងអម្ពបាលិវ័ន ទៀបក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងទាត់*

ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនខ្ជាប់ខ្ជួន ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនឋិតថេរ ម្នាលភិក្ខុទាំងឡាយ ហេតុនោះបុគ្គលគួរនឿយណាយ គួរធុញទ្រាន់ គួររួចស្រឡះចាកសង្ខារទាំងពួង ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងស្តេចភ្នំឈ្មោះសិនេរុ ទទឹង ៨ ម៉ឺន ៤ ពាន់យោជន៍ បណ្តោយ ៨ ម៉ឺន ៤ ពាន់យោជន៍ លិចចុះក្នុងមហាសមុទ្រ ៨ ម៉ឺន ៤ ពាន់យោជន៍ ផុសឡើងអំពីមហាសមុទ្រ ៨ ម៉ឺន ៤ ពាន់យោជន៍ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលភ្លៀងមិនបង្អុរចុះ អស់ច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ច្រើនសែនឆ្នាំ ម្នាលភិក្ខុទាំងឡាយ កាលបើភ្លៀងមិនបង្អុរចុះ ពីជគាម ភូតគាម ឈើជាថ្នាំ ស្មៅ និងឈើជាធំក្នុងព្រៃណាមួយ ពីជគាម ភូតគាម និងឈើជាថ្នាំ ស្មៅ និងឈើជាធំក្នុងព្រៃទាំងនោះ នឹងស្វិតស្ងួតមិនកើតឡើង ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនខ្ជាប់ខ្ជួនយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនឋិតថេរយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ បុគ្គលគួរនឿយណាយ គួរធុញទ្រាន់ គួររួចស្រឡះចាកសង្ខារទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យជាគម្រប់ពីរ កើតប្រាកដដោយអំណើះនៃកាលដ៏វែងម្តងៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យជាគម្រប់ពីរកើតប្រាកដហើយ ស្ទឹងតូចទាំងឡាយ បារាយណ៍ទឹកតូចទាំងឡាយណាមួយ ស្ទឹង និងបារាយណ៍តូចទាំងអស់នោះ នឹងគោករីងស្ងួតមិនមានប្រាជក ។ ម្នាលភិក្ខុទាំងឡាយ

សង្ខារទាំងឡាយមិនទៀងយ៉ាងនេះ ... គួររួចស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យជាគម្រប់បីកើតប្រាកដ ដោយអំណើះនៃកាលដ៏វែងម្ដងៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យជាគម្រប់បីកើតមានប្រាកដហើយ ទន្លេធំទាំងឡាយណា គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេធំទាំងអស់នោះគង់នឹងរីងស្ងួតមិនមានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះ ... គួររួចស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យជាគម្រប់ ៤ កើតមានប្រាកដ ដោយអំណើះនៃកាលដ៏វែងម្ដងៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យជាគម្រប់ ៤ កើតប្រាកដហើយ ស្រះធំទាំងឡាយណា ( ក្ដី ) ទន្លេធំទាំងឡាយនេះ គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី រមែងកើតអំពីស្រះធំណា ( ក្ដី ) ស្រះធំនិងទន្លេធំទាំងអស់នោះ ក៏គោករីងស្ងួតមិនមានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ... គួររួចស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យជាគម្រប់ ៥ កើតប្រាកដដោយអំណើះនៃកាលដ៏វែងម្ដងៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យជាគម្រប់ ៥ កើតប្រាកដហើយ ទឹកក្នុងមហាសមុទ្រ ស្រកអស់មួយរយយោជន៍ខ្លះ ទឹកក្នុងមហាសមុទ្រ ស្រកអស់ ២ រយយោជន៍ខ្លះ ៣ រយយោជន៍ខ្លះ ៤ រយយោជន៍ខ្លះ ៥ រយយោជន៍ខ្លះ ៦ រយយោជន៍ខ្លះ ៧ រយយោជន៍ខ្លះ ទឹករមែងដក់នៅក្នុងមហាសមុទ្រ ៧ ជំហរដើមត្នោតខ្លះ ទឹកក្នុងមហាសមុទ្ររមែងដក់នៅ ៦

ជំហរដើមត្នោតខ្លះ ៥ ជំហរដើមត្នោតខ្លះ ៤ ជំហរដើមត្នោតខ្លះ ៣ ជំហរដើមត្នោតខ្លះ ២ ជំហរដើមត្នោតខ្លះ ១ ជំហរដើមត្នោតខ្លះ ទឹកក្នុងមហាសមុទ្រ រមែងជក់នៅ ៧ ជំហរបុរសខ្លះ ទឹកក្នុងមហាសមុទ្ររមែងជក់នៅ ៦ ជំហរបុរសខ្លះ ៥ ជំហរបុរសខ្លះ ៤ ជំហរបុរសខ្លះ ៣ ជំហរបុរសខ្លះ ២ ជំហរបុរសខ្លះ ១ ជំហរបុរសខ្លះ ពាក់កណ្តាលជំហរបុរសខ្លះ ត្រឹមចង្កេះខ្លះ ត្រឹមជង្គង់ខ្លះ ត្រឹមកែ្នកគោរខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភ្លៀងមានគ្រាប់ធ្ងាសៗ បង្អុរចុះ ក្នុងសរទសម័យ ទឹករមែងជក់នៅក្នុងស្នាមជើងគោក្នុងប្រទេសនោះៗ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ទឹកក្នុងមហាសមុទ្រជក់នៅប៉ុនប្រឡង់ជើងគោ ក្នុងប្រទេសនោះៗ ក៏យ៉ាងនេះដែរ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យជាគម្រប់ ៥ កើតប្រាកដហើយ ទឹកក្នុងមហាសមុទ្រសូម្បីត្រឹមតែមួយថ្នាំងនៃម្រាមដៃក៏មិនមានឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះ ... គួររួចស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យជាគម្រប់ ៦ កើតប្រាកដ ដោយអំណោះនៃកាលដ៏វែងមួងៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យជាគម្រប់ ៦ កើតប្រាកដហើយ មហាប្រឹថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង រមែងហុយផ្សែងឡើង ហុយផ្សែងឡើងព្រម ហុយផ្សែងឡើងសព្វ ។ ម្នាលភិក្ខុទាំងឡាយ ឡដុតឆ្នាំង ដែលស្ងួនឆ្នាំងបិទហើយ រមែងហុយផ្សែងឡើង ហុយផ្សែងឡើងព្រម ហុយផ្សែងឡើងសព្វ យ៉ាងណាមិញ ម្នាលភិក្ខុទាំង-

ឡាយ លុះព្រះអាទិត្យជាគម្រប់ ៦ កើតប្រាកដហើយ មហាប្រឹថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង ក៏ហុយផ្សែងឡើង ហុយផ្សែងឡើងព្រមយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះ ... គួររួចស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលព្រះអាទិត្យជាគម្រប់ ៧ កើតប្រាកដ ដោយអំណើះនៃកាលដ៏វែងម្តងៗ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះអាទិត្យជាគម្រប់ ៧ កើតប្រាកដហើយ មហាប្រឹថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង រមែងឆេះសព្វ រុងរឿង មានអណ្តាតតែមួយ ម្នាលភិក្ខុទាំងឡាយ កាលបើមហាប្រឹថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង ដែលភ្លើងកំពុងឆេះក្តៅ អណ្តាតភ្លើងដែលត្រូវខ្យល់បក់ឡើងទៅ ដរាបដល់ព្រហ្មលោក ម្នាលភិក្ខុទាំងឡាយ កាលបើស្តេចភ្នំឈ្មោះសិនេរុដែលភ្លើងកំពុងឆេះក្តៅ កំពុងវិនាស ដែលគំនរភ្លើងដ៏ធំគ្របសង្កត់ហើយ កំពូលភ្នំទាំងឡាយ ១ រយយោជន៍ខ្លះ ក៏ដាច់រាត់រាយ កំពូលភ្នំទាំងឡាយ ២ រយយោជន៍ខ្លះ ៣ រយយោជន៍ខ្លះ ៤ រយយោជន៍ខ្លះ ៥ រយយោជន៍ខ្លះ ក៏ដាច់រាត់រាយ ម្នាលភិក្ខុទាំងឡាយ កាលបើមហាប្រឹថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុផង ដែលភ្លើងកំពុងឆេះក្តៅ ផេះក៏មិនប្រាកដ កំញមក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសប្បិក្តី ប្រេងក្តី កាលដែលភ្លើងកំពុងឆេះក្តៅ ផេះក៏មិនប្រាកដ កំញមក៏មិនប្រាកដ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មហាប្រឹថពីនេះផង ស្តេចភ្នំឈ្មោះសិនេរុនេះផង កាលដែលភ្លើងកំពុងឆេះក្តៅ ផេះក៏មិនប្រាកដ

*កំញមក៏មិនប្រាកដយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនខ្ជាប់ខ្ជួនយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនបិតថេរយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ បុគ្គលគួរនឿយណាយ គួរធុញទ្រាន់ គួររួចស្រឡះចាកសង្ខារទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ នរណាដឹង នរណាជឿក្នុងសង្ខារនោះថា ផែនដីនេះក្តី ស្តេចភ្នំឈ្មោះសិនេរុក្តី គង់នឹងឆេះរលាយ គង់នឹងវិនាសមិនមានប្រាកដយ៉ាងនេះ វៀរលែងតែអរិយសាវកទាំងឡាយ អ្នកមានបទ គឺធម៌ឃើញហើយ ។*

*ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានគ្រូឈ្មោះសុនេត្តៈ ជាអ្នកធ្វើនូវលទ្ធិដូចជាកំពង់ ជាអ្នកប្រាសចាករាគៈ ក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ គ្រូឈ្មោះសុនេត្តៈ មានរយនៃសាវកដ៏ច្រើន ។ គ្រូឈ្មោះសុនេត្តៈ សម្តែងធម៌ដល់ពួកសាវក ដើម្បីឲ្យបានទៅកើតក្នុងព្រហ្មលោក ។ ម្នាលភិក្ខុទាំងឡាយ កាលគ្រូឈ្មោះសុនេត្តៈ កំពុងសម្តែងធម៌ ដើម្បីឲ្យបានទៅកើតក្នុងព្រហ្មលោក ពួកសាវកណា ដឹងច្បាស់នូវពាក្យប្រៀនប្រដៅទាំងអស់ ដោយសព្វគ្រប់ ពួកសាវកទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតឯសុគតិព្រហ្មលោក ។ ពួកសាវកណា មិនដឹងច្បាស់នូវពាក្យប្រៀនប្រដៅដោយសព្វគ្រប់ទេ ពួកសាវកនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតា ជាន់បរនិម្មិតវសវត្តី ពួកខ្លះ ទៅកើត*

ជាមួយនឹងពួកទេវតាជាន់និម្មានរតី ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតាជាន់តុសិត ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតាជាន់យាមៈ ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ពួកខ្លះ ទៅកើតជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិក ពួកខ្លះ ទៅកើតជាមួយនឹងពួកខត្តិយមហាសាល ពួកខ្លះ ទៅកើតជាមួយនឹងពួកព្រាហ្មណមហាសាល ពួកខ្លះ ទៅកើតជាមួយនឹងពួកគហបតិមហាសាល ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះ គ្រូឈ្មោះសុនេត្តៈ មានសេចក្តីត្រិះរិះដូច្នេះថា ហេតុនេះមិនសមគួរសោះ ដែលអាត្មាអញ ជាអ្នកមានគតិស្មើៗ នឹងពួកសាវកក្នុងភពមុខ បើដូច្នោះមានតែអាត្មាអញចម្រើនមេត្តា ឲ្យលើសលុបជាងបឋមជ្ឈានទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ គ្រូឈ្មោះសុនេត្តៈ ចម្រើននូវមេត្តាចិត្តអស់ ៧ ឆ្នាំ លុះចម្រើននូវមេត្តាចិត្តអស់ ៧ ឆ្នាំហើយ ក៏មិនបានមកកាន់លោកនេះទៀតអស់ ៧ សំវដ្តវិវដ្តកប្ប ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា កាលលោកកំពុងវិនាស គ្រូឈ្មោះសុនេត្តៈ ក៏បានទៅកើតក្នុងព្រហ្មលោក ជាន់អាភស្សរៈ កាលលោកកំពុងចម្រើន ក៏ចូលទៅកើតក្នុងសុញ្ញវិមាននៃព្រហ្ម ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា ក្នុងសុញ្ញវិមាននៃព្រហ្មនោះ មានព្រហ្មជាមហាព្រហ្ម គ្របសង្កត់នូវព្រហ្មឯទៀតៗ បាន ព្រហ្មឯទៀតៗ មិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុដោយសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួង ឲ្យលុះនៅក្នុងអំណាចខ្លួន ម្នាលភិក្ខុ

ទាំងឡាយ គ្រូឈ្មោះសុនេត្តៈ បានជាសក្កៈ ជាធំជាងទេវតាទាំងឡាយ ៣៦ លើក បានជាស្តេចចក្រពត្តិប្រកបដោយធម៌ ជាធម្មរាជា ( ជាឥស្សរៈលើផែនដី ) មានមហាសមុទ្ទទាំង ៤ ជាទីបំផុត ព្រះអង្គជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទ ដល់នូវសេចក្តីមាំមួន ប្រកបដោយកែវ ៧ ប្រការ ព្រះរាជបុត្ររបស់ព្រះអង្គ ច្រើនជាងពាន់ សុទ្ធតែជាអ្នកក្លៀវក្លា មានសភាពជាអ្នកមានសេចក្តីព្យាយាម សង្កត់សង្កិននូវសេនារបស់ស្តេចដទៃ បានច្រើនរយលើក ។ ព្រះអង្គទ្រង់ប្រាមប្រាប់ គ្រប់គ្រងផែនដី ដែលមានសាគរជាទីបំផុត ដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធឡើយ ។ ម្នាលភិក្ខុទាំងឡាយ អម្បាលដូចជាគ្រូឈ្មោះសុនេត្តៈនោះ មានអាយុវែងយ៉ាងនេះ ឋិតនៅយូរយ៉ាងនេះ ក៏នៅតែជាអ្នកមិនផុតអំពីជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ចិត្ត តថាគតហៅថា មិនរួចអំពីទុក្ខដូច្នេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះមិនទាន់ត្រាស់ដឹង មិនទាន់ចាក់ធ្លុះចំពោះនូវធម៌ទាំង ៤ ។ ធម៌ទាំង ៤ តើដូចម្តេច ។ គឺមិនទាន់ត្រាស់ដឹង មិនទាន់ចាក់ធ្លុះនូវសីលដ៏ប្រសើរ ១ មិនទាន់ត្រាស់ដឹង មិនទាន់ចាក់ធ្លុះនូវសមាធិដ៏ប្រសើរ ១ មិនទាន់ត្រាស់ដឹង មិនទាន់ចាក់ធ្លុះនូវបញ្ញាដ៏ប្រសើរ ១ មិនទាន់ត្រាស់ដឹង មិនទាន់ចាក់ធ្លុះនូវវិមុត្តិដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ សីលដ៏ប្រសើរនោះឯង ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ សមាធិដ៏ប្រសើរ ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ

បញ្ញាដ៏ប្រសើរ ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ វិមុត្តិដ៏ប្រសើរ ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហា គឺសេចក្តីប្រាថ្នាក្នុងភព ក៏សូន្យទៅ ខែ្សគឺតណ្ហា ដែលអាចនាំសត្វអំពីភពមួយ ទៅភពមួយ ក៏អស់ទៅ ភពថ្មីទៀត ក៏មិនមានក្នុងកាលឥឡូវនេះឡើយ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងដូច្នេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់មានព្រះពុទ្ធដីកាដូច្នេះហើយ ក៏ទ្រង់ត្រាស់ដូច្នេះតទៅទៀតថា

ធម៌ទាំងនេះ គឺសីល សមាធិ បញ្ញា និងវិមុត្តិដ៏ប្រសើរ ព្រះគោតមដ៏មានយស បានត្រាស់ដឹងហើយ ព្រះពុទ្ធទ្រង់ត្រាស់ដឹងយ៉ាងនេះហើយ ទើបសម្តែងធម៌ប្រាប់ ដល់ភិក្ខុទាំងឡាយ ព្រះសាស្តាមានចក្ខុ ទ្រង់ធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ ទ្រង់បរិនិព្វានហើយ ។

# អដ្ឋកថា

## សុរិយសូត្រ

[ ៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុរិយសូត្រទី ២ ដូចតទៅនេះ គប្បីជ្រាបបុរេចារិកកថា នូវពាក្យដែលជាលំនាំដើមនៃព្រះសូត្រនេះសិន ដូចតទៅនេះថា ព្រោះហេតុដែលសត្តសុរិយទេសនា ព្រះអាទិត្យ ៧ ដួង ប្រព្រឹត្តទៅ

ដោយអំណាចសម្តែងថា លោកវិនាសដោយភ្លើងកប្ប ដូច្នោះ ទើបទ្រង់សម្តែងថា សំវដ្តកប្បមាន ៣ សំវដ្តសីមាមាន ៣ សំវដ្តមូលមាន ៣ កោលាហលមាន ៣ ។ បុរេចារិកកថានោះ បានពោលពិស្តារហើយ ក្នុងបុព្វេនិវាសានុស្សតិនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា **ឯតទវោច** សេចក្តីថា ដើម្បីទ្រង់សម្តែងការវិបត្តិនៃសង្ខារទាំងឡាយ ទាំងដែលមានចិត្តគ្រប់គ្រង និងមិនមានចិត្តគ្រប់គ្រង តាមអធ្យាស្រ័យរបស់ភិក្ខុ ៥០០ រូប ដែលចម្រើនអនិច្ចកម្មដ្ឋាន ទើបព្រះមានព្រះភាគត្រាស់សត្តសុរិយោបមសូត្រ មានពាក្យជាដើមថា **អនិច្ចា ភិក្ខវេ សង្ខារា** ដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនិច្ចា** សេចក្តីថា សង្ខារទាំងឡាយ ឈ្មោះថា អនិច្ចា ព្រោះអត្ថថា មានហើយ ត្រឡប់ជាមិនមាន ។ បទថា **សង្ខារា** បានដល់ សង្ខារធម៌ដែលមានចិត្តគ្រប់គ្រងផង មិនមានចិត្តគ្រប់គ្រងផង ។ បទថា **អទ្ធុវា** សេចក្តីថា ឈ្មោះថា មិនស្ថិតស្ថេរ ព្រោះអត្ថថា មិនយូរ ។ បទថា **អនស្សាសិកា** សេចក្តីថា វៀរចាកការស្រោលចិត្ត ព្រោះជារបស់មិនស្ថិតស្ថេរ ។ បទថា **អលមេវ** ប្រែថា សមគួរហើយ ។ បទថា **អជ្ឈោគាឡ្ហា** បានដល់ លិចចុះទៅក្នុងទឹក ។ បទថា **អច្ចុគ្គតោ** បានដល់ ផុសឡើងអំពីទឹក ។ បទថា **ទេវោ ន វស្សតិ** សេចក្តីថា ឈ្មោះថា ភ្លៀងដែលធ្វើទឹកឲ្យកម្រើកជាដំបូង រួមគ្នាជាភ្លៀងក្រុមតែមួយជាមួយគ្នា ធ្លាក់ចុះក្នុងសែនកោដិចក្រវាល ។ ក្នុងកាលនោះ ពូជដែលដុះមកហើយ រមែង

មិនត្រឡប់ចូលទៅកាន់ជម្រកទៀត ។ ធម្មកថាដែលគិតគ្នេរ រមែងកាន់យកជាប្រមាណថា រាប់តាំងអំពីពេលដែលភ្លៀងមិនធ្លាក់នោះ ទឹកខះទៅ ដូចទឹកក្នុងធម្មក្រក ដូច្នោះ ។ ភ្លៀងមិនធ្លាក់ទៀតត្រឹមតែមួយតំណក់ កាលលោកកំពុងវិនាស តាំងអំពីអវិចីមហានរកទៅ ក៏មានតែភាពទទេ សត្វទាំងឡាយកាលឡើងមកអំពីអវិចីមហានរកនោះ ក៏កើតឡើងក្នុងមនុស្សលោក និងក្នុងសត្វតិរច្ឆាន ។ សត្វដែលកើតក្នុងកំណើតតិរច្ឆាន បែរជាបានមេត្តាក្នុងកូន និងបងប្អូន ធ្វើកាលកិរិយាហើយ កើតក្នុងទេវតា និងមនុស្សទាំងឡាយ ។ ទេវតាទាំងឡាយ ត្រាច់ទៅតាមអាកាសស្រែកប្រាប់គ្នាថា ទីនេះ ជាទីត្រាច់ទៅមិនបានផង មិនស្ថិតស្ថេរផង ពួកអ្នកចូរចម្រើនមេត្តា ករុណា មុទិតា ឧបេក្ខាចុះ ដូច្នេះ សត្វទាំងនោះ កាលចម្រើនមេត្តាជាដើមហើយ ចុតិអំពីនោះហើយ រមែងកើតក្នុងព្រហ្មលោក ។

ក្នុងបទថា **ពីជគាម** មានវិនិច្ឆ័យដូចតទៅនេះថា ពូជ ៥ ប្រភេទ ឈ្មោះថា ពីជគាម ពូជពណ៌ខៀវ មានឫស និងស្លឹកដុះជាលប្រភេទណាមួយ ឈ្មោះថា ភូតគាម ។

ក្នុងបទថា **ឱសធតិណវនប្បតយោ** មានវិនិច្ឆ័យដូចតទៅនេះថា ដើមឈើដែលគេប្រើផ្សំជាថ្នាំរក្សារោគ ឈ្មោះថា **ឱសធ** ។ ដើមឈើដែលមានខ្លឹមខាងក្រៅ ដូចជាដើមត្នោត និងដើមដូងជាដើម ឈ្មោះថា **តិណ** គឺស្មៅ ដើមឈើដែលចម្រើនបំផុតក្នុងព្រៃ ឈ្មោះថា **វនប្បតិ** គឺដើមឈើដែលជា

ជាំក្នុងព្រៃ សូម្បីស្ទឹងតូចដ៏សេស វៀរស្ទឹងធំ ៥ ខ្សែ ឈ្មោះថា **កុណ្ណនទី** គឺស្ទឹងតូច ៗ ស្រះតូចៗ មានបឹងជាដើមដ៏សេស វៀរស្រះធំ ៧ ឈ្មោះថា **កុសុព្ភ** គឺអណ្តូងទឹក ។

ក្នុងបទថា **ទុតិយោ សុរិយោ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា ក្នុងគ្រាដែលមានព្រះអាទិត្យទី ២ រះឡើង ព្រះអាទិត្យ ១ ក៏លិចចុះ ។ ក្នុងគ្រាដែលមានព្រះអាទិត្យទី ៣ រះឡើង ព្រះអាទិត្យ ១ លិច ព្រះអាទិត្យ ១ នៅត្រង់កណ្តាល ។ ក្នុងគ្រាដែលមានព្រះអាទិត្យទី ៤ តាំងឡើងរៀងគ្នាលំដាប់ ដូចភិក្ខុ ៤ រូបត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ៤ គ្រួសារ ឈរតាមលំដាប់ទ្វារផ្ទះដូច្នោះ ។ សូម្បីព្រះអាទិត្យជួនទី ៥ ជាដើម ក៏ន័យនេះដូចគ្នា ។

បទថា **បលុជ្ជន្តិ** បានដល់ ដាច់ធ្លាក់ចុះ ។ បទថា **នេវ ឆារិកា បញ្ញាយតិ ន មសិ** សេចក្តីថា កាលមានប្រមាណប៉ុណ្ណេះ គឺមហាប្រឹថពីក្នុងចក្រវាល ស្តេចភ្នំសិនេរុ ភ្នំហិមពាន្ត ភ្នំកណ្តាប់ចក្រវាល កាមាវចរ ៦ ជាន់ និងព្រហ្មលោកជាន់បឋមជ្ឈានភូមិដែលត្រូវភ្លើងឆេះហើយ ផេះ ឬធ្យូងត្រឹមតែចាប់យកដោយម្រាមដៃក៏មិនប្រាកដ ។

បទថា **កោ មន្តា កោ សទ្ធាតា** សេចក្តីថា អ្នកណាអាចឲ្យបុគ្គលដឹង និងឲ្យបុគ្គលជឿនោះ ឬអ្នកណាជាអ្នកជឿរឿងនោះ ។ បទថា **អញ្ញត្រ ទិដ្ឋបទេហិ** សេចក្តីថា វៀរព្រះអរិយសាវកដែលជាសោតាបន្ន ដែលមានបទ គឺព្រះនិព្វានដែលខ្លួនឃើញហើយ អធិប្បាយថា អ្នកណានឹងជឿអ្នកដទៃ

បាន ។ បទថា **វីតរាគោ** សេចក្ដីថា ដែលប្រាសចាករាគៈ ដោយអំណាចវិក្ខម្ភនប្បហាន ។ បទថា **សាសនំ អាជានីសុ** សេចក្ដីថា ព្រះសាវកទាំងឡាយ ដឹងដល់ពាក្យប្រៀនប្រដៅ គឺដើរតាមផ្លូវដើម្បីជាសម្លាញ់អ្នកព្រហ្មលោក ។ បទថា **សមសមគតិយោ** សេចក្ដីថា ដែលមានគតិស្មើគ្នា គឺមានគតិតែមួយដោយអាការដូចគ្នា ក្នុងអត្ថភាពទី ២ ។ បទថា **ឧត្តរិ មេត្តំ ភាវេយ្យុំ** សេចក្ដីថា អាត្មាអញគប្បីចម្រើនមេត្តាឲ្យក្រៃលែងឡើង គឺធ្វើឲ្យប្រណីត ផ្ដើមតាំងអំពីបឋមជ្ឈាន រហូតដល់តិកជ្ឈាន និងចតុក្កជ្ឈាន ។

បទថា **ចក្ខុមា** សេចក្ដីថា ព្រះសាស្ដាទ្រង់មានចក្ខុ ៥ ឈ្មោះថា **ចក្ខុមា** ។ បទថា **បរិនិព្វុតោ** សេចក្ដីថា ទ្រង់បរិនិព្វានដោយកិលេសប្បរិនិព្វាន នាមណ្ឌលពោធិបល្លង្កនោះឯង ។ កាលព្រះសាស្ដាទ្រង់សម្ដែងអនិច្ចលក្ខណៈហើយ ទ្រង់ជាស់ស្មារតីដោយធម្មទេសនាយ៉ាងនេះ ភិក្ខុដែលចម្រើនអនិច្ចកម្មដ្ឋានទាំង ៥០០ នោះ បញ្ជូនញាណទៅតាមក្រសែទេសនា សម្រេចអរហត្តហើយ លើអាសនៈដែលខ្លួនអង្គុយនោះឯង ដូច្នេះ ។

## អដ្ឋកថា សុរិយសូត្រទី ២ ចប់

# សុត្តន្តបិដក

## នគរោបមសូត្រទី ៣

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ កាលណានគរនៃស្តេច ជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរបរិក្ខារ ៧ យ៉ាង ទាំងស្តេចក៏រមែងបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវអាហារ ៤ យ៉ាង ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា នគរនៃស្តេច ជាទីបំផុតនៃដែន ដែលពួកបច្ចាមិត្តជាសត្រូវខាងក្រៅ មិនគប្បីធ្វើបាន ។ នគរដែលរៀបចំល្អហើយ ដោយនគរបរិក្ខារ ៧ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេច ជាទីបំផុតនៃដែន ក្នុងលោកនេះ មានសសរគោល មានរណ្តៅដ៏ជ្រៅ ដែលគេដាំល្អហើយ មិនកម្រើក មិនរញ្ជួយ ។ នគរនៃស្តេចជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរបរិក្ខារទី ១ នេះ ដើម្បីគ្រប់គ្រងនូវពួកជនខាងក្នុង ដើម្បីការពារនូវពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច ជាទីបំផុតនៃដែន មានស្នាមភ្លោះដ៏ជ្រៅផង ធំទូលាយផង ។ នគរនៃស្តេចជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរបរិក្ខារទី ២ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេចជាទីបំផុតនៃដែន មានផ្លូវយាមល្បាតដ៏ខ្ពស់ផង ទូលាយផង ។ នគរនៃស្តេចជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរបរិក្ខារទី ៣ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេច

ជាទីបំផុតនៃដែន មានអាវុធដ៏ច្រើន គឺព្រួញ និងលំពែងផង និងអាវុធមានមុខម្ខាងផង ដែលគេសន្សំទុកហើយ ។ នគរនៃស្តេចជាទីបំផុតនៃដែន ដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារទី ៤ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេចជាទីបំផុតនៃដែន មានពួកពលដ៏ច្រើន តែងនៅអាស្រ័យ គឺទ័ពជិះដំរី ទ័ពជិះសេះ ទ័ពបររថ ខ្មាន់ធ្នូ អ្នកកាន់ទង់ជ័យ ( ដើរមុខ ) អ្នកចាត់កងទ័ព ជាអ្នកឲ្យនូវស្បៀង ( ពួកអ្នកចែកស្បៀងដល់ពួកទាហានក្នុងសង្គ្រាម ) ពួករាជបុត្រ អ្នកពុះពារ ( ចូលទៅក្នុងសង្គ្រាម ) ពួកទាហានអ្នកលុកចូល ពួកទាហានអ្នកអង់អាច ពួកទាហានអ្នកក្លៀវក្លា ដូចជាដំរីដ៏ប្រសើរ ពួកទាហានអ្នកទ្រទ្រង់នូវផែនក្តារ ( សម្រាប់ការពារសរ ) គឺខែល ពួកទាហានអ្នកពាក់អាវក្រោះ ពួកទាហានជាកូននៃជនជាទាសៈ ។ នគរនៃស្តេចជាទីបំផុតនៃដែន ដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារទី ៥ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេចជាទីបំផុតនៃដែន មានឆ្មាំទ្វារជាបណ្ឌិត អ្នកឈ្លាសវៃ មានបញ្ញា ឃាត់ពួកជនដែលមិនស្គាល់ បើកឲ្យពួកជនដែលស្គាល់ចូលទៅ ។ នគរនៃស្តេចជាទីបំផុតនៃដែន ដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារទី ៦ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេចជាទីបំផុតនៃដែន មានកំពែង

ខ្ពស់ផង ក្រាស់ផង បរិបូណ៌ដោយគ្រឿងអប់ និងគ្រឿងលាបផង ។ នគរនៃស្តេចជាទីបំផុតនៃដែន ដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារទី ៧ នេះ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ នគរដែលគេរៀបចំល្អហើយ ដោយនគរបរិក្ខារ ៧ យ៉ាងនេះ ។ ចុះស្តេចដែលបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវអាហារទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ នគរនៃស្តេចជាទីបំផុតនៃដែន មានស្មៅ និងឧស និងទឹកដ៏ច្រើន ដែលគេសន្សំទុកហើយ ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេចជាទីបំផុតនៃដែន មានស្រូវខ្សាយ និងស្រូវដំណើបដ៏ច្រើន ដែលគេសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេចជាទីបំផុតនៃដែន មានល្ង និងសណ្តែក និងអបរណ្ណជាតិដ៏ច្រើន ដែលគេសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត នគរនៃស្តេចជាទីបំផុតនៃដែន មានភេសជ្ជៈច្រើន គឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ និងអំបិលដែលគេសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយដល់ពួកជនខាង

ក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ ។ ស្ដេចរមែងបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវអាហារទាំង ៤ នេះ ។ ម្នាលភិក្ខុទាំងឡាយ កាលណានគរនៃស្ដេចជាទីបំផុតនៃដែន ដែលរៀបចំល្អហើយ ដោយនគរបរិក្ខារទាំង ៧ យ៉ាង ទាំងស្ដេចក៏រមែងបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវអាហារទាំង ៤ យ៉ាង ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា នគរនៃស្ដេចជាទីបំផុតនៃដែន ដែលពួកបច្ចាមិត្តជាសត្រូវខាងក្រៅ មិនគប្បីធ្វើបាន ( យ៉ាងណាមិញ ) ម្នាលភិក្ខុទាំងឡាយ កាលណា អរិយសាវកជាអ្នកប្រកបដោយព្រះសទ្ធម្ម ៧ យ៉ាង បានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ប្រសើរ មានការនៅជាសុខក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អរិយសាវកដែលមារមិនគប្បីធ្វើបាន ដែលមារមានចិត្តបាប មិនគប្បីធ្វើបាន យ៉ាងនោះដែរ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្ម ៧ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្ដេចជាទីបំផុតនៃដែន មានសសរគោល មានរណ្ដៅដ៏ជ្រៅ ដែលគេដាំដោយល្អ មិនកម្រើក មិនរញ្ជួយ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកជាអ្នកមានសទ្ធា រមែងជឿចំពោះពោធិញ្ញាណ របស់តថាគតដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងត្រឡប់មកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក មាន

សទ្ធាទុកជាសសរគោល រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើដែលមានទោស ចម្រើននូវអំពើដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធក៏យ៉ាងនោះដែរ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ១ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានស្នាមភ្លោះដ៏ជ្រៅផង ធំទូលាយផង ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវកជាអ្នកខ្មាសបាប រមែងខ្មាសកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងខ្មាសការជួបប្រសព្វនូវអកុសលធម៌ដ៏លាមកទាំងឡាយ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកមានហិរិទុកជាស្នាមភ្លោះ រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើដែលមានទោស ចម្រើននូវអំពើដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ២ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានផ្លូវចាំយាមល្បាតដ៏ខ្ពស់ផង ធំទូលាយផង ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ជាអ្នកមានសេចក្តីតក់ស្លុតចំពោះបាប រមែងតក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងតក់ស្លុតចំពោះការជួបប្រសព្វ នូវអកុសលធម៌ទាំងឡាយដ៏លាមក ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានឱត្តប្បៈទុកជាផ្លូវយាមល្បាត រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើមានទោស ចម្រើន

នូវអំពើមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៣ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានគ្រឿងអាវុធដ៏ច្រើន គឺព្រួញ និងលំពែងផង និងអាវុធមានមុខម្ខាងផង ដែលគេសន្សំទុក ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវកជាពហុស្សូត ។បេ។ ចាក់ធ្លុះចំពោះដោយទិដ្ឋិ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានការចេះដឹងទុកជាអាវុធ រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើមានទោស ចម្រើននូវអំពើមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៤ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានពួកពលដ៏ច្រើន តែងនៅអាស្រ័យ គឺទ័ពជិះដំរី ទ័ពជិះសេះ ទ័ពបររថ ខ្មាន់ធ្នូ អ្នកកាន់ទង់ជ័យ ( ដើរមុខ ) អ្នកចាត់កងទ័ព អ្នកឲ្យនូវស្បៀង ( ដល់ពួកទាហានក្នុងសង្គ្រាម ) ពួករាជបុត្រអ្នកពុះពារ ( ចូលទៅក្នុងសង្គ្រាម ) ពួកទាហានអ្នកលុកចូលកាន់សង្គ្រាម ពួកទាហានអ្នកអង់អាច ពួកទាហានអ្នកក្លៀវក្លា ដូចជាដំរីដ៏ប្រសើរ ពួកទាហានអ្នកទ្រង់នូវផែនក្តារ ( សម្រាប់ការពារសរ ) គឺខែល ពួកទាហានជាកូននៃជនជាទាសៈ ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក អ្នកប្រារព្ធសេចក្តីព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីចម្រើននូវកុសលធម៌

ទាំងឡាយ ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងដ៏មាំមួន មិនដាក់ធុរៈ បោលក្នុងកុសលធម៌ទាំងឡាយ ក៏យ៉ាងនោះដែរ ។ អរិយសាវក មានសេចក្តីព្យាយាមទុកជាពួកពល រមែងលះបង់នូវអកុសលធម៌ ចម្រើននូវកុសលធម៌ លះបង់នូវអំពើមានទោស ចម្រើននូវអំពើមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៥ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានឆ្មាំទ្វារជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា ឃាត់នូវពួកជនដែលមិនស្គាល់ បើកឲ្យពួកជនដែលស្គាល់ឲ្យចូល ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវកជាអ្នកមានសតិ ប្រកបដោយសតិ និងភាពជាបុគ្គលមានប្រាជ្ញាចាស់ក្លាដ៏ក្រៃលែង ជាអ្នករឭកបានរឿយៗ នូវការងារដែលបានធ្វើយូរហើយក្តី និយាយយូរហើយក្តី ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកមានសតិទុកជាឆ្មាំទ្វារ រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើមានទោស ចម្រើននូវអំពើមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៦ នេះ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានកំពែងដ៏ខ្ពស់ផង ក្រាស់ផង បរិបូណ៌ដោយគ្រឿងអប់ និងគ្រឿងលាបផង ដើម្បីគ្រប់គ្រងពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវកជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា

ជាគ្រឿងចាក់ធ្លុះ យល់នូវសេចក្តីចម្រើន និងសេចក្តីវិនាស មានប្រាជ្ញាជាគ្រឿងចាក់ធ្លុះដ៏ប្រសើរ ដល់នូវសេចក្តីអស់ទៅនៃទុក្ខដោយប្រពៃ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកបរិបូណ៌ដោយប្រាជ្ញា ទុកជាគ្រឿងអប់ និងគ្រឿងលាប រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើដែលមានទោស ចម្រើននូវអំពើដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទី ៧ នេះ ។ អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទាំង ៧ យ៉ាងនេះឯង ។ ( អរិយសាវក ) ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែនមានស្មៅ និងឧស និងទឹកដ៏ច្រើន ដែលសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីឈមចុះកាន់ព្រះនិព្វានចំពោះខ្លួន យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានស្រូវខ្សាយ ស្រូវដំណើបដ៏ច្រើន ដែលគេសន្សំទុក ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាង

ក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ព្រោះរម្ងាប់នូវវិតក្កនិងវិចារៈ ។បេ។ ចូលកាន់ទុតិយជ្ឈាន ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីឈមចុះកាន់ព្រះនិព្វានចំពោះខ្លួន ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានល្ង សណ្តែក និងអបរណ្ណជាតិដ៏ច្រើន ដែលគេសន្សំទុកដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់តតិយជ្ឈាន ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីឈមចុះកាន់ព្រះនិព្វាន ចំពោះខ្លួន ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នគរនៃស្តេចជាទីបំផុតនៃដែន មានភេសជ្ជៈដ៏ច្រើន ដែលគេសន្សំទុក គឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ អំបិល ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដល់ពួកជនខាងក្នុង ដើម្បីការពារពួកសត្រូវខាងក្រៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អរិយ-សាវក ព្រោះលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីឈមចុះកាន់ព្រះនិព្វានចំពោះខ្លួន ក៏យ៉ាងនោះដែរ ។ អរិយសាវក ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលណា

អរិយសាវក ជាអ្នកប្រកបដោយព្រះសទ្ធម្មទាំង ៧ យ៉ាងនេះ ទាំងបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អរិយសាវក ដែលមារមិនគប្បីធ្វើបាន មារមានចិត្តបាបមិនគប្បីធ្វើបានឡើយ ។

# អដ្ឋកថា

## នគរោបមសូត្រ

[ ៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនគរោបមសូត្រទី ៣ ដូចតទៅនេះ បទថា **យតោ** ប្រែថា ក្នុងកាលណា ។ បទថា **បច្ចន្តិមំ** បានដល់ នគរដែលតាំងនៅក្នុងទីបំផុតនៃដែន គឺចុងដែន ។ ការរក្សានគរក្នុងមជ្ឈិមប្រទេសរមែងមិនមាន ព្រោះហេតុនោះ ទើបទ្រង់មិនកាន់យកកិច្ច គឺរក្សានគរនោះ ។ បទថា **នគរបរិក្ខារេហិ បរិក្ខិត្តំ** សេចក្តីថា ប្រដាប់តាក់តែងដោយគ្រឿងប្រដាប់ព្រះនគរ ។ បទថា **អករណីយំ** សេចក្តីថា ដែលសត្រូវខាងក្រៅគប្បីធ្វើមិនបាន គឺយកឈ្នះមិនបាន ។ បទថា **គម្ភីរនេមា** បានដល់ រណ្តៅជ្រៅ ។ បទថា **សុនិខាតា** បានដល់ កប់ទុកល្អហើយ ។ ឯអ្នកនគរ រមែងធ្វើសសរគោលនោះដោយឥដ្ឋខ្លះ ដោយថ្មខ្លះ ដោយឈើមានខ្លឹម មានឈើ

គគីរជាដើមខ្លះ ដើម្បីសាងសសរគោលនោះ ដើម្បីជាប្រយោជន៍ដល់ការរក្សាព្រះនគរ កសាងទុកខាងក្រៅព្រះនគរ កាលសាងដើម្បីប្រយោជន៍ដល់ការគាត់តែង កសាងទុកខាងក្នុងព្រះនគរ ។

កាលធ្វើសសរគោលនោះឲ្យសម្រេចដោយឥដ្ឋ ក៏ជីករណ្តៅធំកប់ខាងលើធ្វើជា ៨ ជ្រុង បូកលាបដោយបាយ-អ កាលណាដំរីយកក្អួកបុស ក៏មិនញាប់ញ័រ កាលនោះ សសរគោលនោះ រមែងឈ្មោះថា បូកលាបល្អហើយ សសរគោលទោះសម្រេចដោយថ្មជាដើម ជាសសរ ៨ ជ្រុងប៉ុណ្ណោះ ។ បើសសរទាំងនោះវែង ៨ ហត្ថសោត ក៏កប់ក្នុងរណ្តៅជម្រៅប្រមាណ ៤ ហត្ថ ខាងលើប្រមាណ ៤ ហត្ថ សូម្បីសសរគោល ១៦ ហត្ថ ឬ ២០ ហត្ថ ក៏ន័យនេះដូចគ្នា ។ សសរគោលទាំងអស់កប់ចូលទៅខាងក្រោមពាក់កណ្តាល ខាងលើពាក់កណ្តាល សសរទាំងនោះរៀបដូចទឹកនោមគោ ព្រោះហេតុនោះ បុគ្គលរមែងអាចធ្វើការផារបាន ដោយប្រើឈើរៀបក្នុងរវាងសសរទាំងនោះម្យ៉ាងទៀត សសរទាំងនោះ គេធ្វើឆ្លូតទុកលើកទង់ផងដែរ ។ បទថា **បរិខា** បានដល់ នគរដែលព័ទ្ធ ។ បទថា **អនុបរិយាយបថោ** បានដល់ ផ្លូវធំដែលប្រទក្សិណខាងក្នុងកំពែង ដែលទាហានទាំងឡាយតាំងនៅ ច្បាំងជាមួយទាហានដែលតាំងនៅខាងក្រៅកំពែង ។ បទថា **សលាកំ** បានដល់ អាវុធប្រយោល មានព្រួញ និងលំពែងសម្រាប់ពួយជាដើម ។ បទថា **ជេវនិកំ** បានដល់ អាវុធដ៏សេស មានអាវុធមានមុខម្ខាងជាដើម ។

បទថា **ហត្ថារោហា** បានដល់ ជនទាំងពួង មានអាចារ្យទូន្មានដំរី ពេទ្យរក្សាដំរី និងអ្នកចិញ្ចឹមដំរីជាដើម ។ បទថា **អស្សារោហា** បានដល់ ជនទាំងពួង មានអាចារ្យបង្ហាត់សេះ ពេទ្យរក្សាសេះ និងអ្នកចិញ្ចឹមសេះ ជាដើម ។ បទថា **ធនុគ្គហា** បានដល់ ទាហានបាញ់ធ្នូ ។ បទថា **ចេលកា** បានដល់ ពួកទាហានដែលកាន់ទង់ជ័យនាំមុខក្នុងសារមភូមិ ។ បទថា **ចលកា** សេចក្ដីថា អ្នកចាត់ចែងក្បួនទ័ពយ៉ាងនេះថា តំណែងព្រះរាជានៅទីនេះ តំណែងមហាមាត្យ ឈ្មោះនោះនៅទីនេះ ។ បទថា **បិណ្ឌទាយកា** បានដល់ ទាហានធ្ងន់ អធិប្បាយថា បានឮថា ទាហានទាំងនោះ ចូលទៅកាន់កងទ័ពនៃសត្រូវ កាត់យកជាកំណាត់ៗ ហើយនាំទៅ ដូចនាំដុំបាយទៅជាដុំៗ ហើយលោតគេចទៅ ន័យម្យ៉ាងទៀត ទាហានពួកណា កាន់យកបាយ និងទឹកចូលទៅឲ្យដល់កងទាហាន កណ្ដាលសង្គ្រាមបាន ពាក្យថា **បិណ្ឌទាយកា** នោះ ជាឈ្មោះរបស់ទាហានទាំងនោះ ។ បទថា **ឧគ្គា រាជបុត្តា** បានដល់ ពួកទាហានដែលជារាជបុត្រ មានត្រកូលខ្ពស់ៗ ជំនាញក្នុងសង្គ្រាម ។ បទថា **បក្ខន្ទិនោ** បានដល់ ពួកទាហានដែលសួរគ្នាថា ពួកយើងទៅនាំយកក្បាល ឬអាវុធរបស់អ្នកណាមក បានពាក្យឆ្លើយថា របស់ទាហានឈ្មោះនោះ ដូច្នេះ ហើយ ក៏ហក់លោតចូលកាន់សង្គ្រាម នាំយកក្បាល និងអាវុធនោះមកបាន ទាហានទាំងនេះ រមែងហក់លោតចូលទៅ ហេតុនោះ ទើបឈ្មោះថា **បក្ខន្ទិ** ទាហានទាំងនោះឈ្មោះថា ជាអ្នកក្លាហានច្រើន ដូចស្ដេចដំរី ដូច្នោះ ។ បទថា

**មហានាគា** នេះ ជាឈ្មោះរបស់ទាហានដែលមិនព្រមថយក្រោយ ក្នុងកាលដំរីជាដើមប្រឈមមុខគ្នា ។

បទថា **សូរា** បានដល់ ពួកទាហានដែលក្លៀវក្លាឯក សូម្បីស្លៀកសំពត់ ក៏អាចឆ្លងសមុទ្រទៅបាន ។ បទថា **ចម្មយោធិនោ** បានដល់ ទាហានដែលពាក់គ្រោះស្បែក ឬខែលស្បែក ធ្វើការច្បាំង ។ បទថា **ទាសកបុត្តា** បានដល់ ទាហានទាសៈដែលមានសេចក្ដីស្រឡាញ់ក្នុងម្ចាស់ក្រៃលែង ។ បទថា **ទោវារិកោ** ប្រែថា ទាហានរក្សាទ្វារ ។ បទថា **វាសធលេបនសម្បន្នោ** សេចក្ដីថា កំពែងដែលប្រកបដោយការកឥដ្ឋ ដោយការបិទប្រហោងទាំងពួង បូកលាបដោយបាយ-អម្យ៉ាងទៀត ប្រកបដោយការកឥដ្ឋពោល គឺកំពែងបិទបន្ទា និងបូកដោយបាយ-អក្រាស់រលោង ធ្វើធ្នូតបង្ហាញរូបក្អមដែលមានទឹកពេញ លើកទង់ឡើង ។ បទថា **តិណកដ្ឋោទកំ** សេចក្ដីថា ស្មៅដែលនាំមករក្សា ក្នុងទីច្រើនកន្លែងដើម្បីប្រយោជន៍របស់សត្វ មានដំរី សេះជាដើម និងដើម្បីជាប្រយោជន៍ដល់ការប្រក់ផ្ទះ ឈើដែលនាំមកគរទុកដើម្បីជាប្រយោជន៍ធ្វើផ្ទះ និងឧសចម្អិនបបរជាដើម ទឹកដែលប្រើសម្រាប់គ្រឿងយន្ត បូមចូលទៅរក្សាទុកក្នុងស្រះបោក្ខរណី ។ បទថា **សន្និចិតំ ហោតិ** សេចក្ដីថា រមែងជាការសន្សំទុកយ៉ាងល្អ ក្នុងទីច្រើនកន្លែងត្រៀមទុកមុន ។ បទថា **អព្ភន្តរានំ រតិយា** សេចក្ដីថា ដើម្បីជាប្រយោជន៍ដល់ភាពកក់ក្ដៅនៃបុគ្គលដែលនៅក្នុងគនរ ។ បទថា **អបរិតស្សាយ** សេចក្ដី

ថា ដើម្បីជាប្រយោជន៍មិនឲ្យក័យខ្វាច ។ បទថា **សាលិយវកំ** បានដល់ស្រូវសាលី និងស្រូវដំណើបផ្សេងៗ ។ បទថា **តិលមុគ្គមាសាបរណ្ណំ** បានដល់ ល្ង សណ្ដែកបាយ សណ្ដែករាជមាស និងអបរណ្ណជាតិដ៏សេស ។

ឥឡូវនេះ ព្រោះហេតុដែលកិត្តិកម្មក្នុងព្រះនគររបស់តថាគតមិនមាន តែឧបមាមកហើយយ៉ាងនេះថា តថាគតនឹងសម្ដែងអរិយសាវកឲ្យដូចជាសត្តម្ម ៧ ដូចគ្រឿងព័ទ្ធព្រះនគរ ឈាន ៤ ដូចអាហារ ៤ ហើយតថាគតនឹងពញ្ញាក់ទេសនា ដាក់អរហត្តចូលក្នុងឋាន: ១១ ដូច្នោះ ដើម្បីប្រកាសទេសនានោះ ទើបទ្រង់ផ្ដើមពាក្យថា **យថា** **ចោ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **សទ្ធម្មេហិ** ប្រែថា ដោយធម៌ដ៏ល្អ ។

បទថា **សទ្ធោ** បានដល់ ប្រកបដោយការជឿស៊ប់ និងការជឿដោយប្រចក្ស ក្នុងការជឿ ២ យ៉ាងនោះ ការជឿផលនៃទាន និងសីលជាដើម ជឿក្នុងការបំពេញបុណ្យ មានទានជាដើម ឈ្មោះថា **ឱកប្បនសទ្ធា** ។ សទ្ធាដែលមកហើយដោយមគ្គ ឈ្មោះថា **បច្ចក្ខសទ្ធា** គឺជឿដោយផលប្រចក្ស ។ ក្នុងបទថា **បសាទសទ្ធា** ក៏មានន័យនេះដូចគ្នា ។ គប្បីចង្អុលលក្ខណ:ជាដើមរបស់សទ្ធានោះឲ្យជាក់ច្បាស់ ការជឿនេះតាមបាលីថា បពិត្រមហារាជ សទ្ធាមានការស្ទុះទៅជាលក្ខណ: មានការផូរផង់ជាលក្ខណ: ឈ្មោះថា លក្ខណ:របស់សទ្ធា តែការជឿដែលត្រាស់ដោយន័យថា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសទ្ធាជ្រះថ្លា បណ្ឌិតត្រូវដឹងដោយហេតុ ៣ យ៉ាង ។ ហេតុ ៣ យ៉ាង

*គឺអ្វីខ្លះ ។ គឺបុគ្គលនោះចង់ឃើញបុគ្គលមានសីល ១ ... ជាដើម នេះឈ្មោះថា និមិត្តរបស់សទ្ធា ។ អាហារ គឺអ្វី អាហាររបស់សទ្ធាមកក្នុងបាលីនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សទ្ធាប្រកបដោយអាហារ មិនបានពោលថា ឥតអាហារទេ ។ ចុះអ្វីជាអាហាររបស់សទ្ធា ។ គប្បីឆ្លើយថា សទ្ធម្មស្សវនៈ ។ នេះឈ្មោះថា អាហាររបស់សទ្ធានោះ ។ បាលីនេះថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តដែលបួសដោយសទ្ធា តែងមានអនុធម៌នេះ គឺតែងនៅច្រើនដោយសេចក្តីនឿយណាយនឹងរូប ។ នេះឈ្មោះថា ធម៌ដែលស្រមតាមសទ្ធានោះ ( អនុធម៌ ) ។ ឯការដែលសទ្ធានោះមានកិច្ចច្រើនយ៉ាង ដោយការៈដែលប្រៀបដូចកញ្ចប់បាយ ដែលចងរួមគ្នាជាដើម ព្រះមានព្រះភាគទ្រង់ប្រកាសហើយ ក្នុងព្រះសូត្រទាំងឡាយថា* **សទ្ធា ពន្ធតិ បាថេយ្យំ សិរិ ភោគានមាសយោ** *សទ្ធារមែងចងនូវស្បៀង គឺកុសលសិរីជាទីនៅអាស្រ័យនៃភោគៈទាំងឡាយ ។* **សទ្ធា ទុតិយា បុរិសស្ស ហោតិ** *សទ្ធាជាទី ២ ( សម្លាញ់ ) របស់បុរស ។* **សទ្ធាយ តរតិ ឱឃំ** *បុគ្គលឆ្លងអន្លង់បានដោយសទ្ធា ។* **សទ្ធា ពីជំ តបោ វុដ្ឋិ** *សទ្ធាជាពូជ តបៈជាភ្លៀង ។* **សទ្ធាហត្ថោ មហានាគោ ឧបេក្ខាសេតទន្តវា** *មហានាគ ( នោះ ) មានសទ្ធាជាប្រមោយ មានឧបេក្ខាជាភ្លុកស ។ តែក្នុងនគរោបមសូត្រនេះ ព្រះមានព្រះភាគទ្រង់សម្តែងសទ្ធានេះ ដូចជាសសរគោល ព្រោះតាំងនៅដោយល្អ មិនញាប់ញ័រ ។ គប្បីធ្វើការជាគ្រឿងប្រកបថ្មីគ្រប់បទដោយន័យ*

ជាដើមថា **សច្ចេសិកោ** សេចក្ដីថា ព្រះអរិយសាវកធ្វើសទ្ធាឲ្យដូចជាសសរគោល រមែងលះអកុសលបាន ។

ម្យ៉ាងទៀត ក្នុងព្រះសូត្រនេះ សំវរៈ គឺការសង្រួមក្នុងទ្វារទាំង ៣ រមែងសម្រេចផលដោយហិរិ និងឱត្តប្បៈ សំវរៈ គឺការសង្រួមនោះ ទើបចាត់ជាបារិសុទ្ធិសីល ៤ ។ ដូច្នោះ ក្នុងព្រះសូត្រនេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់ដាក់អរហត្តទុកក្នុងឋានៈ ១១ ហើយទ្រង់កាន់យកជាកំពូលនៃទេសនា ។

## អដ្ឋកថា នគរោបមសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ធម្មញ្ញូសូត្រទី ៤

[ ៦៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៧ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកដឹងនូវធម៌ ១ ដឹងនូវអត្ថ ( របស់ធម៌ ) ១ ដឹងខ្លួន ១ ដឹងនូវប្រមាណក្នុង ( ភោជន ) ១ ដឹងកាលគួរ ១ ដឹងបរិស័ទ ១ ដឹងបុគ្គលដែលគួរគប់រក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដឹងនូវធម៌ តើដូច

ម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងនូវធម៌គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនគប្បីដឹងនូវធម៌ គឺសុត្តៈ ... វេទល្លៈទេ តថាគតមិនគប្បីហៅថា ជាអ្នកដឹងនូវធម៌ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកឯភិក្ខុដឹងនូវធម៌ គឺសុត្តៈ ... វេទល្លៈ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងនូវធម៌ ភិក្ខុជាអ្នកដឹងនូវធម៌ យ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងនូវអត្ថ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងនូវអត្ថនៃភាសិតនោះៗ ថា នេះជាអត្ថរបស់ភាសិតនេះ នេះជាអត្ថរបស់ភាសិតនេះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនដឹងនូវអត្ថនៃភាសិតនោះៗ ថា នេះជាអត្ថរបស់ភាសិតនេះ នេះជាអត្ថរបស់ភាសិតនេះទេ តថាគតមិនហៅថា អ្នកដឹងនូវអត្ថក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកឯភិក្ខុ ដឹងនូវអត្ថរបស់ភាសិតនោះៗ ថា នេះជាអត្ថរបស់ភាសិតនេះ នេះជាអត្ថរបស់ភាសិតនេះ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងនូវអត្ថ អ្នកដឹងនូវធម៌ ដឹងនូវអត្ថ យ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងខ្លួន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងខ្លួនថា អាត្មាអញជាអ្នកប្រកបដោយសទ្ធា មានសីលៈ សុតៈ ចាគៈ បញ្ញា បដិភាណៈត្រឹមប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនដឹងខ្លួនថា អាត្មាអញជាអ្នកប្រកបដោយសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា បដិភាណៈត្រឹមប៉ុណ្ណេះទេ តថាគតមិនហៅថា អ្នកដឹងខ្លួនក្នុងបទ

នេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុអ្នកដឹងខ្លួនថា អាត្មាអញជាអ្នកប្រកបដោយសទ្ធាសីលៈ សុតៈ ចាគៈ បញ្ញា បដិភាណៈត្រឹមប៉ុណ្ណេះ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងខ្លួន ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួនយ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងប្រមាណ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងប្រមាណក្នុងការទទួលនូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនដឹងប្រមាណក្នុងការទទួលចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទេ តថាគតមិនហៅថា អ្នកដឹងប្រមាណក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុដឹងប្រមាណ ក្នុងការទទួលចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងប្រមាណ ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន ដឹងប្រមាណ យ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងនូវកាល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រកប នេះជាកាលគួរពួនសម្ងំ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រកប នេះជាកាលគួរពួនសម្ងំទេ តថាគតមិនហៅថា អ្នកដឹងកាលក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុអ្នកដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រកប នេះជាកាលគួរពួន

សម្មំ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងនូវកាល ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន ដឹងប្រមាណ ដឹងកាល យ៉ាងនេះឯង ។ ចុះភិក្ខុអ្នកដឹងបរិស័ទ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងបរិស័ទថា នេះជាខត្តិយបរិស័ទ នេះជាព្រាហ្មណបរិស័ទ នេះជាគហបតិបរិស័ទ នេះជាសមណបរិស័ទ អាត្មាអញគួរចូលទៅរកយ៉ាងនេះ គួរឈរយ៉ាងនេះ គួរធ្វើយ៉ាងនេះ គួរអង្គុយយ៉ាងនេះ គួរនិយាយយ៉ាងនេះ គួរស្ងៀមយ៉ាងនេះ ចំពោះបរិស័ទទាំងនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនដឹងបរិស័ទថា នេះជាខត្តិយបរិស័ទ ... គួរស្ងៀមយ៉ាងនេះ តថាគតមិនហៅថា អ្នកដឹងបរិស័ទ ក្នុងបទនេះឡើយ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងភិក្ខុដឹងបរិស័ទថា នេះជាខត្តិយបរិស័ទ ... គួរស្ងៀមយ៉ាងនេះ ព្រោះហេតុនោះ ទើបតថាគតហៅថា អ្នកដឹងបរិស័ទ ភិក្ខុអ្នកដឹងធម៌ ដឹងអត្ថ ដឹងខ្លួន ដឹងប្រមាណ ដឹងកាល ដឹងបរិស័ទយ៉ាងនេះឯង ។ ចុះភិក្ខុដឹងបុគ្គលដែលគួរគប់រក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងដឹងច្បាស់នូវបុគ្គលពីរពួក ឯបុគ្គលពីរពួក គឺមួយពួក ជាអ្នកចង់ជួបប្រទះពួកព្រះអរិយៈ មួយពួក មិនចង់ជួបប្រទះពួកព្រះអរិយៈ ។ បុគ្គលណា មិនចង់ជួបប្រទះពួកព្រះអរិយៈ បុគ្គលនោះគេគប្បីតិះដៀល ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណា ចង់ជួបប្រទះពួកព្រះអរិយៈ បុគ្គលនោះគេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលពីរពួក ចង់ជួបប្រទះពួកព្រះអរិយៈ គឺមួយពួកចង់ស្តាប់ព្រះសទ្ធម្ម មួយ

ពួកមិនចង់ស្តាប់ព្រះសទ្ធម្ម ។ បុគ្គលណាមិនចង់ស្តាប់ព្រះសទ្ធម្ម បុគ្គលនោះគេគប្បីតិះដៀល ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណាចង់ស្តាប់ព្រះសទ្ធម្ម បុគ្គលនោះគេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលពីរពួក ចង់ស្តាប់នូវព្រះសទ្ធម្ម គឺបុគ្គលមួយពួក មានត្រចៀកផ្ទៀងស្តាប់នូវធម៌ បុគ្គលមួយពួក មានត្រចៀកមិនផ្ទៀងស្តាប់នូវធម៌ ។ បុគ្គលណាមានត្រចៀក មិនផ្ទៀងស្តាប់នូវធម៌ បុគ្គលនោះគេគប្បីតិះដៀល ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណាមានត្រចៀក ផ្ទៀងស្តាប់នូវធម៌ បុគ្គលនោះគេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលពីរពួក មានត្រចៀកផ្ទៀងស្តាប់នូវធម៌ គឺមួយពួក ស្តាប់ហើយចាំទុកនូវធម៌ មួយពួក ស្តាប់ហើយមិនចាំទុកនូវធម៌ ។ បុគ្គលណាស្តាប់ហើយ មិនចាំទុកនូវធម៌ បុគ្គលនោះគេគប្បីតិះដៀល ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណា ស្តាប់ហើយចាំទុកនូវធម៌ បុគ្គលនោះគេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលពីរពួក ស្តាប់ហើយចាំទុកនូវធម៌ គឺមួយពួក ពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ មួយពួក មិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយទេ ។ បុគ្គលណាមិនពិចារណា នូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណាពិចារណា នូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនចាំទុកហើយ បុគ្គលនោះគេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលពីរពួក ពិចារណា

នូវអត្ថនៃធម៌ទាំងឡាយដែលខ្លួនចាំទុកហើយ គឺមួយពួកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ មួយពួកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយមិនប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។ បុគ្គលណា ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយមិនប្រតិបត្តធម៌ដ៏សមគួរដល់ធម៌ បុគ្គលនោះ គេគប្បីតិះដៀលដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណា ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ បុគ្គលនោះគេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលពីរពួក ដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ គឺមួយពួកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ មួយពួកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ។ បុគ្គលណាប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ បុគ្គលនោះ គេគប្បីតិះដៀលដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណាប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង បុគ្គលនោះគេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់បុគ្គលពីរពួក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដឹងនូវបុគ្គលដែលគួរគប់រកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះ ជាអ្នកគួរទទួលចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## ធម្មញ្ញូសូត្រ

[ ៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មញ្ញូសូត្រទី ៤ ដូចតទៅនេះ បទថា **កាលំ ជានាតិ** សេចក្តីថា រមែងស្គាល់កាលដែលគួរ ដែលមកដល់ហើយ ។ បទថា **អយំ កាលោ ឧទ្ទេសស្ស** សេចក្តីថា នេះជាពេលរៀនព្រះពុទ្ធវចនៈ ។ បទថា **បរិបុច្ឆាយ** សេចក្តីថា ជាពេលសាកសួរដល់វត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ហេតុ និងមិនមែនហេតុ ។ បទថា **យោគស្ស** សេចក្តីថា ដើម្បីដាក់កិច្ចកម្មក្នុងការប្រកបសេចក្តីព្យាយាម ។ បទថា **បដិសល្លានស្ស** សេចក្តីថា ដើម្បីពួនសម្ងំ ដើម្បីនៅម្នាក់ឯង ។ បទថា **ធម្មានុធម្មប្បដិបន្នោ** សេចក្តីថា ជាអ្នកបដិបត្តិបដិបទាដែលជាចំណែកខាងដើម ដែលជាធម៌សមគួរដល់លោកុត្តរធម៌ ៩ ។ ពាក្យថា **ឯវំ ខោ ភិក្ខវេ ភិក្ខុ បុគ្គលបរោបរញ្ញូ ហោតិ** សេចក្តីថា ភិក្ខុរមែងជាអ្នកអាចស្គាល់ភាពក្រៃលែង និងធូរថយ គឺការខ្លាំងក្លា និងទន់ខ្សោយនៃបុគ្គលទាំងឡាយ ដោយប្រការដូច្នេះ ។

**អដ្ឋកថា ធម្មញ្ញូសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ចារិច្ឆត្តកសូត្រទី ៥

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ សម័យណាដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្សរបស់ពួកទេវតាជាន់តាវត្តិង្ស មានស្លឹកទុំជ្រុះហើយ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស មានស្លឹកទុំជ្រុះហើយ មិនយូរប៉ុន្មានមុខជានឹងមានស្លឹក ៧ ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណាដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្សមានស្លឹក ៧ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្សក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្សរបស់ពួកទេវតាជាន់តាវត្តិង្ស មានស្លឹក ៧ ហើយ មិនយូរប៉ុន្មាន មុខជានឹងមានកញ្ចុំនៃស្លឹក និងផ្កាក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្សរបស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានកញ្ចុំនៃស្លឹក និងផ្កា ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្សក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស មានកញ្ចុំនៃស្លឹក និងផ្កាកើតហើយ មិនយូរប៉ុន្មាន មុខជានឹងមានកញ្ចុំនៃស្លឹក និងផ្កាតាំងឡើងផ្សេងៗ គ្នាក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្សរបស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានកញ្ចុំនៃស្លឹក និងផ្កាតាំងឡើងផ្សេងៗ គ្នា ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្សមានចិត្ត

ត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស មានកញ្ចុំនៃស្លឹក និងផ្កាតាំងឡើងផ្សេងៗ គ្នាកើតហើយ មិនយូរប៉ុន្មាន មុខជានឹងមានផ្កាក្រពុំកើតឡើងក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានផ្កាក្រពុំកើតឡើង ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស មានផ្កាក្រពុំកើតឡើងហើយ មិនយូរប៉ុន្មាន មុខជានឹងមានផ្កាបែកជាមាត់ចាប ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានផ្កាបែកជាមាត់ចាបកើតឡើង ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្សក៏មានចិត្តត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស មានផ្កាបែកជាមាត់ចាបកើតហើយ មិនយូរប៉ុន្មាន មុខជានឹងមានផ្ការីកស្គុសស្គាយ ដោយអាការទាំងពួងក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ដើមរលួសផ្អុង ជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ជាឈើមានផ្ការីកស្គុសស្គាយ ដោយអាការទាំងពួង ម្នាលភិក្ខុទាំងឡាយ សម័យនោះ ពួកទេវតាជាន់តាវត្តិង្សក៏មានចិត្តត្រេកអរ ឆ្អែតស្កប់ស្កល់បរិបូណ៌ ឲ្យគេបម្រើដោយកាមគុណទាំង ៥ ជាទិព្វអស់ ៤ ខែ ទៀបគល់រលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស ។ ម្នាលភិក្ខុទាំងឡាយ ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស មានផ្ការីកស្គុសស្គាយ

ដោយអាការទាំងពួង មានពន្លឺផ្សាយចេញទៅ ៥០ យោជន៍ដោយជុំវិញ ក្លិនផ្សាយទៅបណ្តោយខ្យល់ ១០០ យោជន៍ នេះជាអានុភាពនៃដើមរលួសផ្កុងជាបារិច្ឆត្តកព្រឹក្ស ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកគិតដើម្បីចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្កុង ជាបារិច្ឆត្តកព្រឹក្សរបស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានស្លឹកទុំហើយ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក កោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ហើយចេញចាកផ្ទះចូលទៅកាន់ផ្នួស ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្កុងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានស្លឹក ៧ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវកដូចជាដើមរលួសផ្កុងជាបារិច្ឆត្តកព្រឹក្សរបស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានកញ្ចុំនៃស្លឹក និងផ្កា ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈ ។បេ។ ចូលកាន់ទុតិយជ្ឈាន ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្កុងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្សដែលមានស្លឹកនិងផ្កា តាំងឡើងផ្សេងៗ គ្នា ។ ម្នាលភិក្ខុទាំងឡាយ សម័យណាអរិយសាវក ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់តតិយជ្ឈាន ម្នាលភិក្ខុទាំង-

ឡាយ សម័យនោះ អរិយសាវក ដូចជាដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានផ្កាក្រពុំកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក ព្រោះលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវកដូចជាដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានផ្កាបែកជាមាត់ចាបកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ សម័យនោះ អរិយសាវកដូចជាដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់តាវត្តិង្ស ដែលមានផ្ការីកស្គុសស្គាយ ដោយអាការទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ភុម្មទេវតាទាំងឡាយ ក៏ញ៉ាំងសំឡេងឲ្យលាន់ឮឡើងថា អរិយសាវកដ៏មានអាយុឈ្មោះនេះ ជាសទ្ធិវិហារិករបស់លោកដ៏មានអាយុឈ្មោះនេះ ចេញចាកផ្ទះដែលតាំងនៅក្នុងស្រុក ឬនិគមឯណោះ ហើយចូលមកកាន់ផ្នួស បានធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ។ ពួកទេវតាជាន់ចាតុម្មហារាជិកៈ ឮនូវសំឡេងនៃភុម្មទេវតាទាំងឡាយ ... ពួកទេវតាជាន់តាវត្តិង្ស ... ពួកទេវតាជាន់យាមៈ ... ពួកទេវតាជាន់តុសិត ... ពួកទេវតាជាន់និម្មានរតី ... ពួកទេវតាជាន់បរនិម្មិតវសវត្តី ... ពួកទេវតាជាន់ព្រហ្មកាយិកៈ ញ៉ាំងសំឡេងឲ្យលាន់ឮឡើងថា អរិយសាវកដ៏មានអាយុឈ្មោះនេះ ជាសទ្ធិវិហារិករបស់លោកដ៏មានអាយុ

*ឈ្មោះនេះ ចេញចាកផ្ទះដែលតាំងនៅក្នុងស្រុក ឬនិគមឯណោះ ហើយចូលមកកាន់ផ្នួស បានធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ។ ព្រោះហេតុនោះ សំឡេងក៏ឮផ្សាយឡើងទៅដរាបដល់ព្រហ្មលោកក្នុងខណៈនោះ មួយរំពេចនោះថា នេះជាអានុភាពរបស់ភិក្ខុជាព្រះខីណាស្រព ។*

# អដ្ឋកថា

## ចារិច្ឆត្តកសូត្រ

[ ៦៦ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបារិច្ឆត្តកសូត្រទី ៥ ដូចតទៅនេះ បទថា* **បណ្ឌុបលាសោ** *បានដល់ ស្លឹកឈើទុំដែលជ្រុះ ។ បទថា* **ជាលកជាតោ** *បានដល់ មានពកស្លឹក និងផ្កាកើតព្រមគ្នា ព្រោះថា ពកស្លឹក និងពកផ្កានៃដើមរលួសផុងនោះចេញព្រមគ្នានោះឯង ។ បទថា* **ខារកជាតោ** *សេចក្តីថា ប្រកបហើយដោយពកស្លឹកខ្ចី និងពកផ្កា ដែលបែកស្អាតល្អ តែតាំងនៅបែកគ្នាម្ខាងមួយចំណែក ។ បទថា* **កុឌុមលកជាតោ** *បានដល់ ជាផ្កាក្រពុំ ។ បទថា* **កោរកសកជាតោ** *សេចក្តីថា ប្រកបដោយផ្កាទាំងឡាយ បែកមាត់ចាប មានទងផ្កាធំមិនទាន់រីក ។ បទថា* **សព្វផាលិផុល្លោ** *សេចក្តីថា រីកល្អហើយ ដោយអាការទាំងពួង ។ បទថា* **ទិព្វេ ចត្តារោ មាសេ** *សេចក្តីថា*

អស់ ៤ ខែ ដោយអាយុទិព្វ ។ តែកាលរាប់តាមអាយុមនុស្ស រមែងមាន អាយុ ១២០០០ ឆ្នាំ ។ បទថា **បរិចារេន្តិ** សេចក្តីថា ទេវតាទាំងនោះ រមែងបម្រើឥន្ទ្រិយទាំងឡាយត្រាច់ទៅខាងនោះ និងខាងនេះ អធិប្បាយថា រមែងលេង រមែងត្រេកអរ ។

បទថា **អាភាយ ផុដំ ហោតិ** សេចក្តីថា ស្ថានទីប៉ុណ្ណោះ ឈ្មោះថា រស្មីពាល់ត្រូវហើយ រស្មីរបស់ផ្កាទាំងនោះ ដូចពន្លឺព្រះអាទិត្យចាំងពន្លឺស្រទន់ ស្លឹករបស់ផ្កាទាំងនោះមានទំហំប៉ុនឆត្រស្លឹកឈើ ខាងក្នុងផ្កា មានលម្អងកេសរ មួយនាឡិ ។ តែកាលដើមបារិច្ឆត្តក ផ្ការីកហើយ មិនចាំបាច់មានកិច្ចក្នុងការ ឡើង មិនមានកិច្ចយកឈើថ្កក់ឲ្យចុះមក មិនចាំបាច់យកប្រអប់ដើម្បីនាំផ្កាមក ខ្យល់សម្រាប់កាត់ក៏កើតឡើង កាត់ផ្កាអំពីទង ខ្យល់សម្រាប់ទទួល ក៏ទទួល ផ្កា ខ្យល់សម្រាប់បញ្ជូន ក៏បញ្ជូនកាន់ទេវសភា ឈ្មោះសុធម្មា ខ្យល់ សម្រាប់បោស ក៏នាំផ្កាចាស់ៗ ចេញទៅ ខ្យល់សម្រាប់ក្រាល ក៏ក្រាលត្របក និងកេសរ និងមានធម្មាសនៈសម្តែងធម៌ត្រង់កណ្តាល ។ អាសនៈសម្រាប់ សក្កទេវរាជ ត្រូវក្រាលបន្ទាប់អំពីធម្មាសនៈ មានស្វេតច្ឆត្រទំហំ ៣ យោជន៍ ប៉ាំងនៅខាងលើរតនបល្ល័ង្កទំហំ ១ យោជន៍ បន្ទាប់អំពីនោះ ក៏ជាអាសនៈ របស់ទេវបុត្រ ៣៣ អង្គ បន្ទាប់អំពីនោះ ជាអាសនៈរបស់ទេវតា ដែលមាន សក្តិធំដទៃ បន្ទាប់អំពីនោះ ត្របកផ្កា ជាអាសនៈនៃទេវតាមួយពួក ចំណែក ទេវតានាំគ្នាចូលទៅកាន់ទេវសភា ហើយអង្គុយចុះ ។ លំដាប់នោះ លម្អង

កេសរចេញអំពីផ្កាផ្សាយឡើង ប៉ះត្របកខាងលើធ្លាក់ចុះមក ធ្វើឲ្យអត្តភាពទំហំប្រមាណ ៣ គាវុតរបស់ទេវតាទាំងឡាយ ដូចតាក់តែងដោយទឹកល័ខ ឬដូចរចនាដោយលម្អងមាស ដូច្នោះ ។ តែទេវតាពួកខ្លះ កាន់ផ្កាមួយអង្គមួយផ្កា លេងវាយគ្នានិងគ្នា កាលដែលលេងលម្អងកេសរមួយនាឡិធំ ក៏ខ្ចាយចេញ ធ្វើឲ្យសរីរៈដូចជ្រលក់ដោយមនោសិលា ទឹកកើតឯង ដោយលម្អងកេសរក្រអូប មានរស្មី ការលេងនោះ ៤ ខែ ទើបអស់ដោយអាការយ៉ាងនោះ ។ បទថា **អយមានុភាវោ** សេចក្ដីថា នេះជាអានុភាពដើម្បីផ្សាយទៅតាមលំដាប់ ។

ឥឡូវនេះ ព្រោះហេតុដែលព្រះសាស្ដា មិនមានបំណងដោយដើមបារិច្ឆត្តក តែទ្រង់បំណងសម្ដែងអរិយសាវក ៧ ពួក ប្រៀបធៀបនឹងដើមបារិច្ឆត្តកនោះ ដូច្នោះ ដើម្បីទ្រង់សម្ដែងអរិយសាវកនោះ ទើបត្រាស់ពាក្យជាដើមថា **ឯវមេវ ខោ** ដូច្នេះ ។

បទថា **បព្វជ្ជាយ ចេតេតិ** សេចក្ដីថា ព្រះអរិយសាវកគិតថា អញនឹងបួស ដូច្នេះ ។ បទថា **ទេវានំ** សេចក្ដីថា ដូចរបស់ពួកទេវតា ។ បទថា **យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆតិ** សេចក្ដីថា សំឡេងសាធុការរាប់តាំងអំពីផែនដី រហូតដល់ព្រហ្មលោក ជាសំឡេងតែមួយដូចគ្នាទាំងអស់ ។ បទថា **អយមានុភាវោ** សេចក្ដីថា នេះជាអានុភាពដើម្បីការផ្សាយទៅតាមលំដាប់របស់ភិក្ខុ ដែលជាខីណាស្រព ។ តែក្នុងព្រះសូត្រនេះ ចតុប្បារិសុទ្ធិ-

សីលអាស្រ័យបព្វជ្ជា កសិណបរិកម្មអាស្រ័យបឋមជ្ឈាន មគ្គ ៣ ផល ៣ មួយអន្លើដោយវិបស្សនា អាស្រ័យអរហត្តមគ្គ ។ ទេសនារមែងកំណត់យ៉ាង ទាបខ្លះ យ៉ាងខ្ពស់ខ្លះ ទាំង ២ យ៉ាងខ្លះ ។ តែក្នុងព្រះសូត្រនេះ កំណត់ទាំង ២ យ៉ាង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះ ។ ក្នុងព្រះសូត្រនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់វដ្ដៈផង និងវិវដ្ដៈផង ដោយសង្ខេប ។៚

**អដ្ឋកថា ចារិត្តកសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សគារវសូត្រទី ៦

[ ៦៧ ] គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ នៅក្នុងទីស្ងាត់ពួនសម្ងំ ក៏មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ភិក្ខុកាលធ្វើសក្ការៈ គោរពអាស្រ័យអ្វីហ្ន៎ ទើបលះបង់នូវអកុសល ចម្រើននូវកុសលបាន ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្ដីត្រិះរិះដូច្នេះថា ភិក្ខុកាលធ្វើសក្ការៈ គោរពអាស្រ័យព្រះសាស្ដា ទើបលះបង់នូវអកុសល ចម្រើននូវកុសលបាន ភិក្ខុកាលធ្វើ សក្ការៈគោរពអាស្រ័យព្រះធម៌ ... ព្រះសង្ឃ ... សិក្ខា ... សមាធិ ... អប្បមាទៈ ... បដិសណ្ឋារៈ ទើបលះបង់នូវអកុសល ចម្រើននូវកុសលបាន ។

លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ធម៌ទាំង-ឡាយ របស់អាត្មាអញនេះ ដ៏បរិសុទ្ធផូរផង់ បើដូច្នេះមានតែអាត្មាអញយកធម៌ទាំងនេះទៅ ក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ កាលបើយ៉ាងនេះ ធម៌ទាំងឡាយរបស់អញនេះ នឹងជាធម៌ដ៏បរិសុទ្ធផង ជាធម៌ដែលបច្ច័យតាក់តែងដ៏បរិសុទ្ធក្រៃពេកយ៉ាងនេះផង ។ ដូចជាបុរសមានមាសឆ្តោរដ៏បរិសុទ្ធផូរផង់ បុរសមានសេចក្តីត្រិះរិះយ៉ាងនេះថា មាសឆ្តោររបស់អាត្មាអញនេះ ដ៏បរិសុទ្ធផូរផង់ បើដូច្នោះ មានតែអាត្មាអញយកមាសឆ្តោរនេះទៅបង្ហាញដល់ពួកជាងមាស កាលបើយ៉ាងនេះ មាសឆ្តោររបស់អញនេះ តាំងនៅក្នុងចង្រ្កាននៃជាងមាស នឹងជាមាសដ៏បរិសុទ្ធផង ជាមាសដែលជាងតាក់តែងដ៏បរិសុទ្ធក្រៃពេកផង យ៉ាងណាមិញ ។ ធម៌ទាំងឡាយរបស់អាត្មាអញនេះ បរិសុទ្ធផូរផង់ បើដូច្នោះ មានតែអាត្មាអញយកធម៌ទាំងនេះទៅក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ កាលបើយ៉ាងនេះ ធម៌របស់អញនេះឯង នឹងជាធម៌ដ៏បរិសុទ្ធផង ជាធម៌ដែលបច្ច័យតាក់តែងដ៏បរិសុទ្ធក្រៃពេកផង ក៏យ៉ាងនោះដែរ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ចេញចាកការពួនសម្ងំក្នុងសាយណ្ហសម័យ ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គនៅក្នុង

ទីស្ងាត់ ហើយពួនសម្ងំ ក៏មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ភិក្ខុកាលធ្វើសក្ការៈ គោរព អាស្រ័យអ្វីហ្ន៎ ទើបលះបង់នូវអកុសល ចម្រើននូវកុសលបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុកាលធ្វើសក្ការៈគោរពអាស្រ័យព្រះសាស្តា ទើបលះបង់នូវអកុសល ចម្រើននូវកុសលបាន ភិក្ខុកាលធ្វើសក្ការៈគោរពអាស្រ័យព្រះធម៌ ... ព្រះសង្ឃ ... សិក្ខា ... សមាធិ ... អប្បមាទៈ ... បដិសណ្ឋារៈ ទើបលះបង់នូវអកុសល ចម្រើននូវកុសលបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះដូច្នេះថា ធម៌ទាំងឡាយរបស់អញនេះ ដ៏បរិសុទ្ធផូរផង់ បើដូច្នោះ មានតែអញយកធម៌ទាំងនោះ ទៅក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ កាលបើយ៉ាងនេះ ធម៌ទាំងឡាយរបស់អញនេះ នឹងជាធម៌ដ៏បរិសុទ្ធផង ជាធម៌ដែលបច្ច័យតាក់តែងដ៏បរិសុទ្ធក្រៃពេកផង ។ ដូចបុរសបានមាសត្ពោរ ដ៏បរិសុទ្ធផូរផង់ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា មាសត្ពោររបស់អាត្មាអញនេះដ៏បរិសុទ្ធផូរផង់ បើដូច្នោះ មានតែអាត្មាអញយកមាសត្ពោរនេះទៅបង្ហាញដល់ពួកជាងមាស កាលបើយ៉ាងនេះ មាសត្ពោររបស់អញនេះ តាំងនៅក្នុងចង្រ្កាននៃជាងមាស នឹងជាមាសដ៏បរិសុទ្ធផង ជាមាសដែលជាងតាក់តែងដ៏បរិសុទ្ធក្រៃពេកផង យ៉ាងណាមិញ ។ ធម៌ទាំងឡាយ របស់អាត្មាអញនេះដ៏បរិសុទ្ធផូរផង់ បើដូច្នោះ មានតែអាត្មាអញយកធម៌ទាំងនេះទៅក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ កាលបើយ៉ាងនេះ ធម៌ទាំងឡាយរបស់អញនេះ នឹង

ជាធម៌បរិសុទ្ធផង ជាធម៌ដែលបច្ច័យតាក់តែងដ៏បរិសុទ្ធក្រៃពេកផង ក៏យ៉ាង នោះដែរ ។ ម្នាលសារីបុត្ត ត្រូវហើយៗ ម្នាលសារីបុត្ត ភិក្ខុកាលធ្វើសក្ការៈ គោរពអាស្រ័យនូវព្រះសាស្ដា ទើបលះបង់នូវអកុសល ចម្រើននូវកុសល បាន ។ ម្នាលសារីបុត្ត ភិក្ខុកាលធ្វើសក្ការៈគោរពអាស្រ័យនូវព្រះធម៌ ... ព្រះ សង្ឃ ... សិក្ខា ... សមាធិ ... អប្បមាទៈ ... បដិសណ្ឋារៈ ទើបលះបង់ នូវអកុសល ចម្រើននូវកុសលបាន កាលបើព្រះសាស្ដាទ្រង់ត្រាស់យ៉ាងនេះ ហើយ ព្រះសារីបុត្តដ៏មានអាយុ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងដោយ សង្ខេបនេះ ខ្ញុំព្រះអង្គយល់សេចក្ដីដោយពិស្ដារបានយ៉ាងនេះ ។ បពិត្រព្រះ អង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះមិនគោរពព្រះសាស្ដា ជាអ្នកគោរពក្នុងព្រះ ធម៌ដូច្នេះ ហេតុនុ៎ះមិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាមិនគោរព ព្រះសាស្ដា ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងព្រះធម៌ដែរ ។ បពិត្រព្រះអង្គ ដ៏ចម្រើន ពាក្យថា ភិក្ខុនោះមិនគោរពព្រះសាស្ដា មិនគោរពព្រះធម៌ ជាអ្នក គោរពក្នុងព្រះសង្ឃដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាមិនគោរពព្រះសាស្ដា មិនគោរពព្រះធម៌ ភិក្ខុនោះឈ្មោះថាមិនគោរព ក្នុងព្រះសង្ឃដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះមិនគោរព ព្រះសាស្ដា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ ជាអ្នកគោរពសិក្ខាដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណា មិនគោរពព្រះ

សាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងសិក្ខាដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះមិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា ជាអ្នកគោរពក្នុងសមាធិដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាមិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងសមាធិដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះមិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ ជាអ្នកគោរពក្នុងអប្បមាទដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាមិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងអប្បមាទដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះមិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ មិនគោរពអប្បមាទ ជាអ្នកគោរពក្នុងបដិសណ្ឋារៈដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាមិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ មិនគោរពអប្បមាទ ភិក្ខុនោះឈ្មោះថាមិនគោរពក្នុងបដិសណ្ឋារៈដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះគោរពក្នុងព្រះសាស្តា ជាអ្នកមិនគោរពព្រះធម៌ដូច្នេះ ហេតុនុ៎ះមិនមានឡើយ បពិត្រព្រះអង្គ

ដ៏ចម្រើន ភិក្ខុណាគោរពព្រះសាស្តា ភិក្ខុនោះឈ្មោះថាគោរពក្នុងព្រះធម៌ដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះគោរពព្រះសាស្តា គោរពព្រះធម៌ ជាអ្នកមិនគោរពក្នុងព្រះសង្ឃដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាគោរពព្រះសាស្តា គោរពព្រះធម៌ ភិក្ខុនោះឈ្មោះថាគោរពក្នុងព្រះសង្ឃដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះគោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ ជាអ្នកមិនគោរពក្នុងសិក្ខាដូច្នេះ ហេតុនុ៎ះមិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាគោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ ភិក្ខុនោះឈ្មោះថា គោរពក្នុងសិក្ខាដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះគោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា ជាអ្នកមិនគោរពក្នុងសមាធិដូច្នេះ ហេតុនុ៎ះមិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាគោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា ភិក្ខុនោះឈ្មោះថាគោរពក្នុងសមាធិដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះគោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ ជាអ្នកមិនគោរពក្នុងអប្បមាទដូច្នេះ ហេតុនុ៎ះ មិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាគោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ ភិក្ខុនោះឈ្មោះថាគោរពក្នុងអប្បមាទដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះគោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ គោរពអប្បមាទ

ជាអ្នកមិនគោរពក្នុងបដិសណ្ឋារៈដូច្នេះ ហេតុនុ៎ះមិនមានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យថា ភិក្ខុនោះគោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ គោរពអប្បមាទ ភិក្ខុនោះ ឈ្មោះថាគោរពក្នុងបដិសណ្ឋារៈដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងដោយសង្ខេបនេះ ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារយ៉ាងនេះ ។ ម្នាលសារីបុត្ត ត្រូវហើយៗ ម្នាលសារីបុត្ត ធម៌ដែលតថាគតសម្តែងដោយសង្ខេបនេះ អ្នកយល់សេចក្តីដោយពិស្តារយ៉ាងនេះល្អហើយ ។ ម្នាលសារីបុត្ត ពាក្យថា ភិក្ខុនោះមិនគោរពព្រះសាស្តា ជាអ្នកគោរពក្នុងព្រះធម៌ដូច្នេះ ហេតុនុ៎ះមិនមានឡើយ ម្នាលសារីបុត្ត ភិក្ខុណាមិនគោរពព្រះសាស្តា ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងព្រះធម៌ដែរ ។បេ។ ម្នាលសារីបុត្ត ពាក្យថា ភិក្ខុនោះ មិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ មិនគោរពអប្បមាទ ជាអ្នកគោរពក្នុងបដិសណ្ឋារៈដូច្នេះ ហេតុនុ៎ះ មិនមានឡើយ ម្នាលសារីបុត្ត ភិក្ខុណាមិនគោរពព្រះសាស្តា មិនគោរពព្រះធម៌ មិនគោរពព្រះសង្ឃ មិនគោរពសិក្ខា មិនគោរពសមាធិ មិនគោរពអប្បមាទ ភិក្ខុនោះ ឈ្មោះថា មិនគោរពក្នុងបដិសណ្ឋារៈដែរ ។ ម្នាលសារីបុត្ត ពាក្យថា ភិក្ខុនោះគោរពព្រះសាស្តា ជាអ្នកមិនគោរពក្នុងព្រះធម៌ដូច្នេះ ហេតុនុ៎ះ មិនមានឡើយ ម្នាលសារីបុត្ត ភិក្ខុណាគោរពព្រះសាស្តា ភិក្ខុនោះ ឈ្មោះថា គោរពក្នុងព្រះធម៌ដែរ ។បេ។ ម្នាលសារីបុត្ត ពាក្យថា ភិក្ខុ

នោះ គោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ គោរពអប្បមាទ ជាអ្នកមិនគោរពក្នុងបដិសណ្ឋារៈដូច្នេះ ហេតុនុ៎ះ មិនមែនជាឋានៈឡើយ ម្នាលសារីបុត្ត ភិក្ខុណាគោរពព្រះសាស្តា គោរពព្រះធម៌ គោរពព្រះសង្ឃ គោរពសិក្ខា គោរពសមាធិ គោរពអប្បមាទ ភិក្ខុនោះ ឈ្មោះថា គោរពក្នុងបដិសណ្ឋារៈដែរ ។ ម្នាលសារីបុត្ត ធម៌ដែលតថាគត សម្តែងដោយសង្ខេបនេះ អ្នកយល់សេចក្តីដោយពិស្តារយ៉ាងនេះ ។

# អដ្ឋកថា

## សក្កច្ចសូត្រ

[ ៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសក្កច្ចសូត្រទី ៦ ដូចតទៅនេះ បទថា **បរិសុទ្ធា ច ភវិស្សន្តិ** សេចក្តីថា ធម៌ទាំងនេះ នឹងបរិសុទ្ធឥតមន្ទិលដោយប្រមាណក្រៃលែង ។ **ស** អក្ខរៈ ក្នុងបទថា **សកម្មារគតោ** នេះ ត្រឹមតែជានិបាត អធិប្បាយថា ដល់ជាងមាសហើយ គឺដល់ជើងក្រានរបស់ជាងមាសហើយ ៕

**អដ្ឋកថា សក្កច្ចសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ភាវនាសូត្រទី ៧

[ ៦៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនប្រកបរឿយៗ នូវភាវនា បើទុកជាមានសេចក្ដីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះមិនរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុមិនបានចម្រើន ។ ព្រោះមិនបានចម្រើនអ្វី ។ ព្រោះតែមិនបានចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចពងមាន់ទាំងឡាយ ៨ ក្ដី ១០ ក្ដី ១២ ក្ដី ពងមាន់ទាំងឡាយនោះ ដែលមេមាន់មិនក្រាបដោយប្រពៃ មិនបានធ្វើឲ្យកក់ក្ដៅដោយប្រពៃ មិនបានឲ្យជាប់ក្លិនវាជាមេដោយប្រពៃ បើទុកជាមេមាន់នោះ មានសេចក្ដីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ កូនទាំងឡាយរបស់អញ គប្បីទម្លាយសម្បកពងដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួល ដូច្នេះក៏ដោយ ក៏គង់តែកូនមាន់ទាំងនោះ មិនអាចនឹងទម្លាយនូវសម្បកពងដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពងទាំងនោះ ដែលមេមាន់មិនបានក្រាបដោយប្រពៃ មិនបានធ្វើឲ្យកក់ក្ដៅដោយប្រពៃ មិនបានឲ្យជាប់ក្លិនវាជាមេដោយប្រពៃ យ៉ាង

ណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនបានប្រកបរឿយៗ នូវភាវនា បើទុកជាមានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ មិនផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែមិនបានចម្រើន ។ ព្រោះមិនបានចម្រើនអ្វី ។ ព្រោះមិនបានចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយៗ នូវភាវនា បើទុកជាមិនមានសេចក្តីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ចិត្តរបស់អាត្មាអញគប្បីផុតស្រឡះចាកអាសវៈទាំង-ឡាយ ព្រោះមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចម្រើន ។ ព្រោះបានចម្រើនអ្វី ។ ព្រោះបានចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាពងមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ពងមាន់ទាំងនោះ ដែលមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្តៅដោយប្រពៃហើយ ធ្វើឲ្យជាប់ក្លិនវាជាមេដោយប្រពៃហើយ មេមាន់នោះ បើទុកជាមិនមានសេចក្តីប្រាថ្នាយ៉ាង

នេះថា ធ្វើដូចម្ដេចហ្ន៎ កូនទាំងឡាយរបស់អញ គប្បីទម្លាយសម្បកពងដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួល ដូច្នេះក៏ដោយ ក៏គង់តែកូនមាន់ទាំងនោះ អាចទម្លាយសម្បកពងដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលបាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតែពងទាំងនោះ ដែលមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្ដៅដោយប្រពៃហើយ ឲ្យជាប់ក្លិនវាជាមេដោយប្រពៃហើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបានប្រកបរឿយៗ នូវភាវនា បើទុកជាមិនមានសេចក្ដីប្រាថ្នាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ចិត្តរបស់អាត្មាអញ គប្បីផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំដូច្នេះក៏ដោយ ក៏គង់តែចិត្តរបស់ភិក្ខុនោះ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះតែមិនប្រកាន់មាំបានដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ត្រូវនិយាយថា ព្រោះតែភិក្ខុបានចម្រើន ។ ព្រោះបានចម្រើនអ្វី ។ ព្រោះបានចម្រើនសតិបដ្ឋាន ៤ ។បេ។ អរិយមគ្គប្រកបដោយអង្គ ៨ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាងឈើ ឬកូនសិស្សរបស់ជាងឈើ យកម្រាមដៃ និងមេដៃទៅចាប់កាន់ត្រង់មៀនកាំបិត ប៉ុន្តែជាងឈើ ឬកូនសិស្សរបស់ជាងឈើនោះ មិនដឹងយ៉ាងនេះថា មៀនកាំបិតរបស់អញនោះ ថ្ងៃនេះសឹកអស់ប៉ុណ្ណេះ ឬថ្ងៃម្សិលសឹកអស់ប៉ុណ្ណេះ ឬក៏ម្សិលម្ង៉ៃសឹកអស់ប៉ុណ្ណេះដូច្នេះទេ លុះដល់មៀនកាំបិតនោះសឹកអស់ហើយ ទើបបានដឹង

*ថា អស់ហើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រកប រឿយៗ នូវភាវនា បើទុកជាមិនបានដឹងយ៉ាងនេះថា ថ្ងៃនេះ អាសវៈទាំង-ឡាយរបស់អញ អស់ទៅប៉ុណ្ណោះ ឬថ្ងៃម្សិលអស់ទៅប៉ុណ្ណោះ ឬក៏ម្សិលម៉្ងៃ អស់ទៅប៉ុណ្ណោះ ដូច្នេះទេ លុះអាសវៈនោះអស់ទៅ ទើបដឹងថាអស់ហើយ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពៅសមុទ្ទ ដែលគេចងនឹង ផ្តៅ ត្រាំនៅក្នុងទឹកអស់ ៦ ខែ ដល់ហេមន្តរដូវ គេលើកឡើងដាក់លើគោក ចំណងទាំងឡាយត្រូវខ្យល់ និងកម្តៅថ្ងៃ ចំណងទាំងនោះត្រូវភ្លៀងបង្អុរស្រោច ក៏ខូចពុកផុយបានដោយងាយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុបានប្រកបរឿយៗ នូវភាវនា សញ្ញោជនៈទាំងឡាយ ក៏ស្ងប់រម្ងាប់បាន ដោយងាយ ក៏យ៉ាងនោះដែរ ។*

# អដ្ឋកថា

## ភាវនាសូត្រ

*[ ៦៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភាវនាសូត្រទី ៧ ដូចតទៅនេះ បទថា* **អននុយុត្តស្ស** *សេចក្តីថា កាលភិក្ខុមិនប្រកបរឿយៗ និងមិនប្រកបទូទៅ ហើយ ។ ពាក្យថា* **សេយ្យថាបិ ភិក្ខវេ កុក្កុដិយា អណ្ឌានិ** *សេចក្តីថា ព្រះមានព្រះភាគត្រាស់ឧបមានេះ ឲ្យជា ២ ប្រការ គឺធម៌ចំណែកខ្មៅ និង*

ធម៌ចំណែកស ។

បណ្ដាឧបមា ២ យ៉ាងនោះ ឧបមានៃធម៌ចំណែកខ្មៅ មិនធ្វើប្រយោជន៍ឲ្យសម្រេច ធម៌ចំណែកស ធ្វើប្រយោជន៍ឲ្យសម្រេច ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបប្រយោជន៍ ដោយឧបមា នៃធម៌ចំណែកសនោះឯង ។ សព្ទថា **សេយ្យថា** ជានិបាត ប្រើក្នុងអត្ថនៃឧបមា ។ សព្ទថា **អបិ** ជានិបាត ប្រើក្នុងអត្ថនៃសម្ភាវនៈ លើកតម្កើង ព្រះមានព្រះភាគទ្រង់សម្ដែងថា **សេយ្យថាបិ ឆាម ភិក្ខវេ** ដូច្នេះ ។

ក្នុងព្រះបាលីនេះថា **កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា** មានវិនិច្ឆ័យដូចតទៅនេះថា មេមាន់មានពងខ្វះ ឬលើស ដោយប្រការដែលត្រាស់ហើយក៏ពិត តែទ្រង់ត្រាស់ពាក្យនេះ ដើម្បីឲ្យពាក្យពីរោះ ។ បទថា **តានស្សុ** កាត់បទជា **តានិ អស្សុ** សេចក្ដីថា ពងទាំងនោះគប្បីមាន ។ បទថា **កុក្កុដិយា សម្មាអធិសយិតានិ** សេចក្ដីថា កាលញីដែលជាមេមាន់នោះបើកស្លាប ដេកក្រាបលើពងទាំងនោះ ឈ្មោះថា ក្រាបហើយដោយប្រពៃ ។ បទថា **សម្មា បរិសេទិតានិ** សេចក្ដីថា កាលមេមាន់មានរដូវតាមកំណត់កាល ដែលឈ្មោះថា ឲ្យឆ្អិនហើយដោយជុំវិញដោយល្អ អធិប្បាយថា ធ្វើឲ្យក្ដៅហើយ ។ បទថា **សម្មា បរិភាវិតានិ** សេចក្ដីថា ក្ដៅដោយជុំវិញដោយល្អតាមកំណត់កាល អធិប្បាយថា ពងបានទទួលកម្ដៅរបស់មេមាន់ ។ ពាក្យថា **កិញ្ចាបិ តស្សា កុក្កុដិយា** សេចក្ដីថា ព្រោះមេមាន់នោះធ្វើការមិន

ប្រមាទ ដោយការធ្វើកិរិយា ៣ យ៉ាងនេះ មិនគប្បីកើតការប្រាថ្នាយ៉ាងនោះ ក៏ពិត ។ បទថា **អថខោ ភព្វាវ តេ** សេចក្តីថា ដែលពិត កូនមាន់ទាំងនោះ គួរបោះចេញទៅដោយសួស្តី ដោយន័យដែលពោលហើយ ព្រោះហេតុដែល ពងទាំងនោះ មេមាន់នោះបានគ្រប់គ្រងដោយអាការ ៣ យ៉ាង ទើបមិនស្អុយ ពងទាំងនោះ មានទឹករំអិលស្រស់ ទឹករំអិលនោះជាប់នឹងសម្បកពងក៏ស្តើង ចុងក្រចក និងចុងចំពុះជារបស់រឹង កូនមាន់ទាំងឡាយ រមែងរើបម្រះ ព្រោះ សម្បកពងជារបស់ស្តើង ពន្លឺខាងក្រៅរមែងប្រាកដចូលដល់ខាងក្នុង ដូច្នោះ កូនមាន់ទាំងនោះ នាំគ្នាគិតថា ពួកយើងដេកអង្គុញដៃ-ជើង នៅក្នុងទីចង្អៀត អស់កាលយូរហ្ន៎ ពន្លឺនេះរមែងប្រាកដខាងក្រៅ ឥឡូវនេះ ពួកយើងនឹង នៅជាសុខក្នុងទីនេះ ដូច្នេះ បំណងនឹងចេញទៅ ទើបទម្លាយសម្បក អើត កចេញទៅ ។ បន្ទាប់ពីនោះ សម្បកពងនោះ ក៏បែកចេញជា ២ ចំណែក ។ បន្ទាប់អំពីនោះ កូនមាន់ទាំងនោះ រលាស់ស្លាបបណ្តើរ ស្រែកយំបណ្តើរ ចេញទៅតាមសមគួរដល់កាលនោះ កាលចេញទៅបាន ក៏ធ្វើស្រុកឲ្យស្អាត ។

ពាក្យថា **ឯវមេវ ខោ** នេះ លោកពោលជាពាក្យឧបមា ។ ពាក្យ នោះ គប្បីជ្រាបបានក៏ព្រោះប្រៀបធៀបសេចក្តីយ៉ាងនេះ ។ ពិតហើយ ការ ធ្វើអនុបស្សនា ៣ ថា បញ្ចក្ខន្ធមិនទៀង ជាទុក្ខ ជាអនត្តា ក្នុងចិត្តសន្តាន របស់ខ្លួននៃភិក្ខុនេះ ប្រៀបដូចការធ្វើកិរិយា ៣ មានការដេកក្រាបជាដើមនៃ មេមាន់នោះ ការមិនធ្វើវិបស្សនាញាណឲ្យវិនាស ដោយការធ្វើវិបស្សនា ៣

ឲ្យដល់ព្រមរបស់ភិក្ខុដែលប្រកបរឿយៗ នូវវិបស្សនា ប្រៀបដូចការមិនស្អុយនៃពង ដោយការធ្វើកិរិយា ៣ យ៉ាងឲ្យដល់ព្រមនៃមេមាន់ ។ ការទាញយកទឹករំអិល គឺការប្រាថ្នាដែលជាប់តាមទៅកាន់ភព ៣ ដោយការធ្វើអនុបស្សនា ៣ ឲ្យដល់ព្រមនៃភិក្ខុនោះ ប្រៀបដូចទាញទឹករំអិលស្រស់នៃពងទាំងឡាយ ដោយការធ្វើកិរិយា ៣ នៃមេមាន់នោះ សេចក្ដីថា ត្រង់សម្បកពង គឺអវិជ្ជាជារបស់ស្ដើង ព្រោះការធ្វើអនុបស្សនា ៣ ឲ្យដល់ព្រមរបស់ភិក្ខុ ប្រៀបដូចការដែលសម្បកពងជារបស់ស្ដើង ដោយការធ្វើកិរិយា ៣ របស់មេមាន់ ការដែលវិបស្សនាញាណជាធម្មជាតិរឹងមាំ សម្បកពងនឹងរឹង ព្រោះការធ្វើអនុ-បស្សនា ៣ ឲ្យដល់ព្រមនៃភិក្ខុ ប្រៀបដូចក្រចក ចំពុះរបស់កូនមាន់ជារបស់រឹង ដោយការធ្វើកិរិយា ៣ របស់មេមាន់ កាលដែលផ្លាស់ប្ដូរ កាលចម្រើនលូតលាស់ កាលកាន់យកនូវបន្ទប់នៃវិបស្សនាញាណ ដោយធ្វើអនុបស្សនា ៣ ឲ្យដល់ព្រមរបស់ភិក្ខុ ប្រៀបដូចកូនមាន់វិវឌ្ឍន៍ទៅ ដោយការធ្វើកិរិយា ៣ នៃមេមាន់ ការដែលភិក្ខុនោះឲ្យចិត្តកាន់យកនូវបន្ទប់នៃវិបស្សនាញាណ អង្គុយលើអាសនៈ ត្រាច់ទៅ ៗ រមែងអស់ហើយ ទើបត្រាច់ទៅ ៗ បាននូវឧតុជាទីសប្បាយ ភោជនជាទីសប្បាយ បុគ្គលជាសប្បាយ ធម្មស្សវនៈជាសប្បាយ ដែលសមគួរដល់វិបស្សនាញាណនោះ អង្គុយលើអាសនៈ ១ ចម្រើនវិបស្សនាទម្លាយសម្បក គឺអវិជ្ជា ដោយអរហត្តមគ្គ ដែលខ្លួនសម្រេចហើយ ដោយលំដាប់ ហើយទទះស្លាប គឺអវិជ្ជា ហើយសម្រេចអរហត្តដោយសួស្ដី គប្បី

*ជ្រាបដូចកាលដែលកូនមាន់ទាំងឡាយ ទម្លាយសម្បកដោយចុងក្រចក ឬដោយចំពុះ ហើយទទះស្លាប់ចោះចេញទៅដោយសួស្តី ដោយការធ្វើកិរិយា ៣ ឲ្យដល់ព្រមរបស់មេមាន់ ដូចមេមាន់ដឹងថា កូនមាន់ទាំងឡាយ វិវឌ្ឍន៍ហើយ រមែងទម្លាយសម្បក យ៉ាងណា សូម្បីព្រះសាស្តាក៏ដូច្នោះ ទ្រង់ជ្រាបថា ភិក្ខុបែបនោះ មានញាណចាស់ក្លាហើយ ទ្រង់ផ្សាយរស្មី ទម្លាយសម្បកគឺអវិជ្ជា ដោយគាថា ដោយន័យជាដើមថា*

*អ្នកចូរដកសេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គល*
*ដកផ្កាកុមុទ ដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរ*
*បណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគត*
*សម្តែងទុកហើយ ។*

*ចប់គាថា ភិក្ខុទាំងនោះ ទម្លាយសម្បក គឺអវិជ្ជាហើយ ក៏សម្រេចអរហត្ត ។ តាំងអំពីនោះមក កូនមាន់ទាំងនោះ ក៏ធ្វើដែនឲ្យស្អាត ត្រាច់ទៅក្នុងស្រុកនោះ យ៉ាងណា ព្រះមហាខីណាស្រពនេះ ក៏ដូច្នោះ ចូលផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ហើយធ្វើសង្ឃារាមឲ្យស្អាតត្រាច់ទៅ ។*

*បទថា* **ពលកណ្ឌស្ស** *បានដល់ ដាងឈើៗ នោះ ទ្រទ្រង់ទុកនូវកម្លាំង ពោល គឺកម្លាំងលើកដាក់នាំយកគ្រឿងឈើទៅ ព្រោះហេតុនោះទើបហៅថា ពលកណ្ឌៈ ។ បទថា* **វាសិជដេ** *បានដល់ ក្នុងដងកាំបិត*

សម្រាប់ដៃចាប់ ។ បទថា **ឯត្តកំ វា មេ អជ្ជ អាសវានំ ខីណំ** សេចក្តីថា អាសវៈទាំងឡាយរបស់បព្វជិត រមែងអស់ទៅអស់កាលជានិច្ច ដោយឧទ្ទេស ដោយបរិបុច្ឆា ដោយយោនិសោមនសិការ ដោយវត្តបដិបត្តិ ដោយសង្ខេបថា បព្វជ្ជា អធិប្បាយថា កាលអាសវៈទាំងឡាយអស់ទៅយ៉ាងនេះ ភិក្ខុនោះ រមែងមិនដឹងយ៉ាងនេះថា ថ្ងៃនេះ អាសវៈអស់ទៅប៉ុណ្ណេះ ម្សិលមិញ អាសវៈ អស់ទៅប៉ុណ្ណេះ ដូច្នេះ ។ អានិសង្សនៃវិបស្សនា លោកសម្តែងដោយឧបមា យ៉ាងនេះ ។ បទថា **ហេមន្តិកេន** សេចក្តីថា ដោយហេមន្តសម័យ គឺរដូវរងា ។ បទថា **បដិប្បស្សម្ភន្តិ** បានដល់ រមែងវិនាសទៅយ៉ាងថាវៈ ។

ក្នុងបទថា **ឯវមេវ ខោ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ព្រះសាស្តា គប្បីឃើញដូចមហាសមុទ្រ ព្រះយោគាវចរដូចទូក ការត្រាច់ទៅក្នុងសម្នាក់ របស់អាចារ្យ និងឧបជ្ឈាយ៍ក្នុងពេលដែលខ្លួនមានវស្សាក្រោម ៥ របស់ភិក្ខុ នេះ ដូចទូកអណ្តែតទៅក្នុងមហាសមុទ្រ ។ ភាពដែលសំយោជនៈទាំងឡាយ ស្រាលស្តើង ដោយកិច្ច មានឧទ្ទេស និងបរិបុច្ឆាជាដើមនោះឯងដោយសង្ខេប ថា បព្វជ្ជារបស់ភិក្ខុ ដូចគ្រឿងចងទូកដែលទឹកក្នុងមហាសមុទ្រ កាត់ឲ្យស្តើង ស្តើងទៅ ដូច្នោះ កាលដែលភិក្ខុជានិស្សយមុត្តក កំណត់កម្មដ្ឋានក្នុងព្រៃ ដូចពេលដែលទូកត្រូវគេលើកឡើងទុកលើគោក ជរ គឺតណ្ហារឹងស្ងួតទៅដោយ វិបស្សនាញាណ ដូចខ្សែស្ងួតក្រៀមទៅដោយខ្យល់ និងកម្តៅថ្ងៃក្នុងពេលថ្ងៃ ដូច្នោះ ការធ្វើចិត្តឲ្យសើមដោយបីតិ និងបាមោជ្ជ ដែលអាស្រ័យកម្មដ្ឋានកើត

ឡើង ដូចខ្សែរសើមដោយតំណក់ទឹកសន្សើមក្នុងពេលយប់ ភាពដែលសំយោជនៈទាំងឡាយមានកម្លាំងទន់ ថយចុះយ៉ាងក្រៃលែង ដោយបីតិ និងបាមោជ្ជ ដែលសម្បយុត្តដោយវិបស្សនាញាណ គប្បីឃើញដូចគ្រឿងចងទូក ដែលត្រូវកម្តៅដុតក្នុងពេលថ្ងៃ និងត្រូវតំណក់ទឹកសន្សើមផ្សើមក្នុងពេលយប់ ធ្វើឲ្យវិនាសសភាវៈទៅ អរហត្តមគ្គញ្ញាណ ដូចភ្លៀងដែលធ្លាក់ចុះមក ។ ភិក្ខុដែលប្រារព្ធវិបស្សនា ចម្រើនវិបស្សនាដោយអំណាចនៃអារម្មណ៍ មានរូបសត្តកៈជាដើម កាលកម្មដ្ឋានប្រាកដច្បាស់ បានឧតុជាទីសប្បាយជាដើម ក្នុងថ្ងៃមួយ អង្គុយដោយពត់ភ្នែនក៏សម្រេចអរហត្តផល ដូចទូកដែលពុកខាងក្នុង ព្រោះទឹកភ្លៀង ដែលធ្លាក់ចុះមក និងទឹកក្នុងមហាសមុទ្រ ព្រះអរហន្តដែលអស់សំយោជនៈហើយ អនុគ្រោះមហាជន ធ្វើឲ្យខន្ធតាំងនៅជាបដល់អាយុក្ខ័យ ដូចទូកដែលចំណាងតាំងនៅក្នុងកាលតិចតួច ព្រះខីណាស្រពដែលបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ព្រោះការស្ងួតនៃឧបាទិន្នកក្ខន្ធ សង្ខារដែលមានចិត្តគ្រប់គ្រង ក៏ដល់នូវការមិនមានបញ្ញត្តិ គប្បីឃើញដូចទូកដែលនៅមួយកន្លែង ពុកផុយ ក៏វិនាសទៅដោយលំដាប់ មិនមាននូវការបញ្ញត្តិដូច្នោះ ។ ដោយឧបមានេះ ព្រះមានព្រះភាគ ទ្រង់សម្តែងភាពដែលសំយោជនៈទាំងឡាយ មានកម្លាំងទន់ខ្សោយ ៕

## អដ្ឋកថាភាវនាសូត្រទី ៧ ចប់

# សុត្តន្តបិដក

## អគ្គិក្ខន្ធោបមសូត្រទី ៨

[ ៦៩ ] សម័យមួយ ព្រះដ៏មានព្រះភាគ ត្រាច់ទៅកាន់ចារិកក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ផ្លូវឆ្ងាយ ទ្រង់បានឃើញគំនរភ្លើងធំ ក្នុងប្រទេសមួយកន្លែងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ លុះទតឃើញហើយ ក៏យាងចេញអំពីផ្លូវ ទៅគង់លើអាសនៈដែលគេក្រាលថ្វាយ ប្របគល់ឈើមួយដើម ។ លុះព្រះដ៏មានព្រះភាគគង់រួចហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានឃើញគំនរភ្លើងធំឯណោះ កំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់ហេតុនោះថាដូចម្តេច ភិក្ខុអង្គុយ ឬដេកឱបគំនរភ្លើងធំឯណោះ កំពុងឆេះភ្លឺប្រាលរន្ទាលសន្ធោសន្ធៅ ហើយនឹងភិក្ខុអង្គុយ ឬដេកឱបខត្តិយកញ្ញាក្តី ព្រាហ្មណកញ្ញាក្តី គហបតិកញ្ញាក្តី ដែលមានដៃ និងជើងដ៏ទន់ល្មាសល្មន់ តើរបស់ណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអង្គុយ ឬដេកឱបខត្តិយកញ្ញាក្តី ព្រាហ្មណកញ្ញាក្តី គហបតិកញ្ញាក្តី ដែលមានដៃ និងជើងដ៏ទន់ល្មាសល្មន់នុ៎ះឯងប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ឯភិក្ខុអង្គុយ ឬដេកឱបគំនរភ្លើងធំឯណោះ កំពុងឆេះភ្លឺប្រាលរន្ទាលសន្ធោសន្ធៅ នុ៎ះជាសេចក្តីទុក្ខវិញទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ ភិក្ខុអង្គុយ ឬដេកឱបគំនរភ្លើងធំឯណោះ កំពុងឆេះភ្លឺប្រាល

រន្ទាលសន្ទោសន្ទៅ អំពើនុ៎ះឯង ប្រសើរជាងភិក្ខុទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត ដែលគួររឭកដោយសេចក្តីរង្កៀស បិទបាំងអំពើអាក្រក់ មិនមែនសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនព្រហ្មចារី តែប្តេជ្ញាខ្លួនថាជាព្រហ្មចារី ស្អុយខាងក្នុង មានចិត្តទទឹកដោយរាគៈ ជាបុគ្គលមានចិត្តជ្រោកជ្រាក ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុនោះដល់នូវសេចក្តីស្លាប់ សេចក្តីទុក្ខស្មើរតែនឹងស្លាប់ ព្រោះតែអគ្គិយ ឬដេកឱបគំនរភ្លើងនោះប៉ុណ្ណោះ ដល់បែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះតែអគ្គិយ ឬដេកឱបគំនរភ្លើងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត ដែលគួររឭកដោយសេចក្តីរង្កៀស បិទបាំងអំពើអាក្រក់ មិនមែនជាសមណៈ តែប្តេជ្ញាថាជាសមណៈ មិនមែនជាព្រហ្មចារី តែប្តេជ្ញាថាជាព្រហ្មចារី ស្អុយខាងក្នុង មានចិត្តទទឹកដោយរាគៈ មានចិត្តជ្រោកជ្រាក អគ្គិយ ឬដេកឱបខត្តិយកញ្ញាក្តី ព្រាហ្មណកញ្ញាក្តី គហបតិកញ្ញាក្តី ដែលមានដៃ និងជើងទន់ល្មាសល្មន់ ម្នាលភិក្ខុទាំងឡាយ ហេតុនោះឯង នាំឲ្យភិក្ខុនោះបានសេចក្តីវិនាស និងសេចក្តីទុក្ខអស់កាលយូរ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះដូចម្តេច បុរសមានកម្លាំង រុំក្លួតស្មងទាំងពីរ ដោយខ្សែក្រនុយសត្វយ៉ាងជាប់ ខ្សែនោះក៏មុតស្បែកសម្បុរថ្ងៃ លុះមុត

ស្បែកសម្បុរថ្ងៃហើយ ក៏មុតស្បែកខាងក្នុង លុះមុតស្បែកខាងក្នុងហើយ ក៏មុតសាច់ លុះមុតសាច់ហើយ ក៏មុតសរសៃ លុះមុតសរសៃហើយ ក៏មុតឆ្អឹង លុះមុតឆ្អឹងហើយ ក៏ចុចជាប់ទៅនឹងខួរក្នុងឆ្អឹង ភិក្ខុត្រេកអរនឹងការថ្វាយបង្គំ របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិ-មហាសាលទាំងឡាយ ( ទាំងពីរនេះ ) ឯណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុត្រេកអរនឹងការថ្វាយបង្គំ របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ កាលត្រេកអរនឹងគេថ្វាយបង្គំ នុ៎ះប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសមានកម្លាំង រុំក្ដួតស្មងទាំងពីរ ដោយខ្សែកន្ទុយសត្វយ៉ាងជាប់ ខ្សែនោះ ក៏មុតស្បែកសម្បុរថ្ងៃ ។បេ។ ក៏ចុចជាប់ទៅនឹងខួរក្នុងឆ្អឹង ការមុតនុ៎ះ ជាទុក្ខលំបាកវិញទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំង-ឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសមានកម្លាំង ហើយក្ដួតស្មងទាំងពីរដោយខ្សែកន្ទុយសត្វយ៉ាងជាប់ ខ្សែនោះក៏មុតស្បែកសម្បុរថ្ងៃ ។បេ។ ក៏ចុចជាប់ទៅនឹងខួរក្នុងឆ្អឹង ការមុតនុ៎ះ ប្រសើរជាងបុគ្គលទ្រុស្តសីល ។បេ។ មានចិត្តជ្រោកជ្រាកនោះ។ ដំណើរនោះ ព្រោះហេតុអ្វី។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុរសនោះ ដល់នូវសេចក្ដីស្លាប់ ឬដល់នូវសេចក្ដីទុក្ខស្មើរតែនឹងស្លាប់ ព្រោះហេតុតែរុំហើយក្ដួតនូវស្មងទាំងពីរ ដោយខ្សែកន្ទុយសត្វយ៉ាងជាប់ ( ប៉ុណ្ណោះ) ដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក

ព្រោះតែរុំហើយក្ដួតនូវស្មងទាំងពីរ ដោយខ្សែកន្ទុយសត្វនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។បេ។ មានចិត្តជ្រោកជ្រាក ត្រេកអរចំពោះការថ្វាយបង្គំ របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ ហេតុនោះនាំឲ្យភិក្ខុនោះ បានសេចក្ដីវិនាស សេចក្ដីទុក្ខអស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្ដីនោះថាដូចម្ដេច បើបុរសមានកម្លាំង ពួយនឹងលំពែងដ៏មុត ដែលគេលាបដោយប្រេង ចំដើមទ្រូង ភិក្ខុត្រេកអរនឹងអញ្ជលិកម្ម របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ឯណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុត្រេកអរនឹងអញ្ជលិកម្ម របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ការត្រេកអរនឹងអញ្ជលិកម្ម នុ៎ះប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសមានកម្លាំង ពួយនឹងលំពែងដ៏មុត ដែលគេលាបដោយប្រេង ចំដើមទ្រូង ការពួយចំដើមទ្រូងនោះ ជាទុក្ខលំបាកវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសមានកម្លាំង ពួយនឹងលំពែងដ៏មុត ដែលគេលាបដោយប្រេង ចំដើមទ្រូងដោយហេតុណា ហេតុនោះប្រសើរជាង ភិក្ខុទ្រុស្តសីល ។បេ។

មានចិត្តជ្រោកជ្រាកនោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ ព្រោះហេតុតែពួយនឹងលំពែងដ៏មុត ដែលលាបដោយប្រេង ចំដើមទ្រូងប៉ុណ្ណោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែគេពួយនឹងលំពែងដ៏មុត ដែលលាបដោយប្រេង ចំដើមទ្រូងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។បេ។ មានចិត្តជ្រោកជ្រាក ត្រេកអរនឹងអញ្ជលិកម្ម របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ ហេតុនោះ នាំឲ្យភិក្ខុនោះ បានសេចក្តីវិនាសសេចក្តីទុក្ខអស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះដូចម្តេច បុរសមានកម្លាំង ស្រោបកាយដោយបន្ទះដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ភិក្ខុប្រើប្រាស់ចីវររបស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រើប្រាស់ចីវរ របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ការប្រើប្រាស់ចីវរនោះប្រសើរជាង ។ បពិត្រព្រះអង្គដ៏

ចម្រើន បុរសមានកម្លាំង ស្រោបកាយដោយបន្ទះដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ កាលស្រោបកាយដោយដែកដ៏ក្តៅនុ៎ះ ជាទុក្ខលំបាកវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសមានកម្លាំង ស្រោបកាយដោយបន្ទះដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ដោយហេតុណា ហេតុនុ៎ះប្រសើរជាង ។ ភិក្ខុទ្រុស្តសីល ។បេ។ មានចិត្តជ្រោកជ្រាកនោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុរសនោះដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុកស្មើរតែនឹងស្លាប់ ព្រោះហេតុតែស្រោបកាយ ដោយបន្ទះដែកដ៏ក្តៅនោះប៉ុណ្ណោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែស្រោបកាយដោយបន្ទះដែកដ៏ក្តៅនោះទៀតទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។បេ។ មានចិត្តជ្រោកជ្រាក ប្រើប្រាស់ចីវររបស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ ហេតុនោះនាំឲ្យភិក្ខុនោះ បានសេចក្តីវិនាស សេចក្តីទុក្ខអស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកទៀត ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះដូចម្តេច បុរសមានកម្លាំង បើកមាត់ដោយសណ្តាសដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោ

សន្ធៅ ហើយដាក់ដុំទង់ដែងដ៏ក្ដៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ទៅក្នុងមាត់ ដុំទង់ដែងនោះ រលាកបបូរមាត់បុរសនោះផង រលាកមាត់ផង រលាកអណ្ដាតផង រលាកកផង រលាកទ្រូងផង រលួយទាំងពោះវៀនធំ ពោះវៀនតូច ធ្លាក់រហូតទៅខាងក្រោមផង ភិក្ខុឆាន់ចង្ហាន់បិណ្ឌ-បាត របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឆាន់ចង្ហាន់របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលគេឲ្យដោយសទ្ធា ការឆាន់ចង្ហាន់បិណ្ឌបាតនុ៎ះ ប្រសើជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ឯបុរសមានកម្លាំង បើកមាត់ដោយសណ្ដាសដែកដ៏ក្ដៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ហើយដាក់ដុំទង់ដែងដ៏ក្ដៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ទៅក្នុងមាត់ ដុំទង់ដែងនោះ រលាកបបូរមាត់បុរសនោះផង រលាកមាត់ផង រលាកអណ្ដាតផង រលាកកផង រលាកទ្រូងផង រលាករលួយទាំងពោះវៀនធំ ពោះវៀនតូច ធ្លាក់ទៅខាងក្រោមផង ដោយហេតុណា ហេតុនុ៎ះជាទុក្ខលំបាកវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសមានកម្លាំង បើកមាត់ដោយសណ្ដាសដែកដ៏ក្ដៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ហើយដាក់ដុំទង់ដែងដ៏ក្ដៅ ដែលភ្លើងកំពុងឆេះ ភ្លឺ

ប្រាលរន្ទាល សន្ធោសន្ធៅ ទៅក្នុងមាត់ ដុំទង់ដែងនោះ រលាកបបូរមាត់បុរសនោះផង រលាកមាត់ផង រលាកអណ្តាតផង រលាកកផង រលាកទ្រូងផង រលាករលួយទាំងពោះវៀនធំ ពោះវៀនតូច ធ្លាក់របូតទៅខាងក្រោមផង ដោយហេតុណា ហេតុនុ៎ះប្រសើរជាងភិក្ខុទ្រុស្តសីល ។បេ។ មានចិត្តជ្រោកជ្រោកនោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបុរសនោះ ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ ព្រោះហេតុតែដាក់ដុំទង់ដែងដ៏ក្តៅទៅក្នុងមាត់នោះ លុះបែកធ្លាយរាងកាយស្លាប់ទៅក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកទៀត ព្រោះតែដាក់ដុំទង់ដែងដ៏ក្តៅ ទៅក្នុងមាត់នោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។បេ។ មានចិត្តជ្រោកជ្រោក ឆាន់ចង្ហាន់បិណ្ឌបាត របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំង-ឡាយ ដែលឲ្យដោយសទ្ធា ម្នាលភិក្ខុទាំងឡាយ ការឆាន់ចង្ហាន់បិណ្ឌបាតនោះ នាំឲ្យភិក្ខុនោះ បានសេចក្តីវិនាស សេចក្តីទុក្ខអស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះដូចម្តេច បុរសមានកម្លាំង ចាប់បុរសឯទៀតត្រង់ក្បាល ឬត្រង់ក ហើយទន្និចឲ្យអង្គុយ ឬឲ្យដេកលើគ្រែដែក ឬក៏តាំងដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ភិក្ខុប្រើប្រាស់គ្រែ និងតាំង របស់ខត្តិយមហាសាលទាំងឡាយ

ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលឲ្យដោយសទ្ធា ណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រើប្រាស់គ្រែនិងតាំង របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំង-ឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលឲ្យដោយសទ្ធា ការប្រើប្រាស់គ្រែ និងតាំងនុ៎ះ ប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសមានកម្លាំង ចាប់ ( បុរសឯទៀត ) ត្រង់ក្បាល ឬត្រង់ក ហើយទន្គិចឲ្យអង្គុយ ឬឲ្យដេកលើគ្រែដែក ឬតាំងដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ភ្លឺប្រាលរន្ទាលសន្ធោសន្ធៅ នុ៎ះជាទុក្ខលំបាកវិញទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសដ៏មានកម្លាំង ចាប់ ( បុរសឯទៀត ) ត្រង់ក្បាល ឬត្រង់ក ហើយទន្គិចឲ្យអង្គុយ ឬឲ្យដេកលើគ្រែដែក ឬតាំងដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ភ្លឺប្រាលរន្ទាលសន្ធោសន្ធៅ ការដេកនោះប្រសើរជាង ភិក្ខុទ្រុស្តសីល ។បេ។ មានចិត្តជ្រោកជ្រាកនោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុរសនោះ គ្រាន់តែដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ ព្រោះហេតុតែអង្គុយ ឬដេកលើគ្រែ ឬតាំងដ៏ក្តៅនោះ ( ប៉ុណ្ណោះ ) លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះតែអង្គុយ ឬដេកលើគ្រែ ឬតាំងដ៏ក្តៅនោះទៀតទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។បេ។ មានចិត្តជ្រោកជ្រាក ប្រើប្រាស់គ្រែ និងតាំងរបស់

ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលឲ្យដោយសទ្ធា ម្នាលភិក្ខុទាំងឡាយ ការប្រើប្រាស់នោះ នាំឲ្យភិក្ខុនោះបានសេចក្តីវិនាស សេចក្តីទុក្ខអស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ( ថែមទៀត ) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះដូចម្តេច បុរសមានកម្លាំង ចាប់ ( បុរសឯទៀត ) យួរជើង ( ទាំងពីរ ) ឡើងលើ ឲ្យក្បាលសំយុងចុះក្រោម ហើយបោះទៅក្នុងរណ្តៅរងើកដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ កាលបុរសនោះ កំពុងឆេះពុះផុលក្នុងរណ្តៅនោះ អណ្តែតឡើងលើម្តង លិចចុះក្រោមម្តង ទៅទទឹងម្តង ភិក្ខុប្រើប្រាស់វិហាររបស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលឲ្យដោយសទ្ធា ណាប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រើប្រាស់វិហារ របស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលឲ្យដោយសទ្ធា ការប្រើប្រាស់នុ៎ះប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសមានកម្លាំង ចាប់ ( បុរសឯទៀត ) យួរជើង ( ទាំងពីរ ) ឡើងលើ ឲ្យក្បាលសំយុងចុះក្រោម ហើយបោះទៅក្នុងរណ្តៅរងើកដ៏ក្តៅ ដែលភ្លើងកំពុងឆេះ ភ្លឺប្រាលរន្ទាលសន្ធោសន្ធៅ កាលបុរសនោះ កំពុងឆេះពុះផុល ក្នុងរណ្តៅរងើកនោះ ក៏អណ្តែតឡើងលើម្តង លិចចុះក្រោមម្តង ទៅទទឹងម្តង ការនុ៎ះជាទុក្ខ

លំបាកវិញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ បុរសមានកម្លាំង ចាប់ ( បុរសឯទៀត ) យួរជើង ( ទាំងពីរ ) ឡើងលើ ឲ្យក្បាលសំយុងចុះក្រោម ហើយបោះទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ កាលបុរសនោះ កំពុងឆេះពុះផុលក្នុងខ្ទះទង់ដែងនោះ អណ្តែតឡើងលើម្តង លិចចុះក្រោមម្តង ទៅទទឹងម្តង ការទ្រុះប្រសើរជាងភិក្ខុទ្រុស្តសីល ។បេ។ មានចិត្តជ្រោកជ្រាកនោះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបុរសនោះដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ ព្រោះហេតុតែគេបោះទៅក្នុងខ្ទះទង់ដែងដ៏ក្តៅនោះ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែគេបោះទៅក្នុងខ្ទះទង់ដែងដ៏ក្តៅនោះទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីលនោះ ។បេ។ មានចិត្តជ្រោកជ្រាក ប្រើប្រាស់វិហាររបស់ខត្តិយមហាសាលទាំងឡាយ ឬព្រាហ្មណ-មហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ ដែលឲ្យដោយសទ្ធា ម្នាលភិក្ខុទាំងឡាយ ការប្រើប្រាស់នោះ នាំឲ្យភិក្ខុនោះបានសេចក្តីវិនាស សេចក្តីទុក្ខអស់កាលដ៏វែង លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ( ថែមទៀត ) ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ពួកភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាយ៉ាងនេះថា យើងបរិភោគប្រើប្រាស់ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ របស់ពួកបុគ្គលណា

បច្ច័យទានទាំងនោះ នឹងមានផលច្រើន មានអានិសង្សច្រើន ដល់ពួកបុគ្គលទាំងនោះ ឯបព្វជ្ជារបស់យើងនេះ មានផល មានប្រយោជន៍ ( មិនមែនឥតអំពើទេ ) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ ឃើញប្រយោជន៍របស់ខ្លួនច្បាស់ហើយ គួរដើម្បីញុំាងកិច្ចឲ្យសម្រេច ដោយសេចក្តីមិនប្រមាទផង ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឃើញប្រយោជន៍របស់អ្នកដទៃច្បាស់ហើយ គួរដើម្បីញុំាងកិច្ចឲ្យសម្រេចដោយសេចក្តីមិនប្រមាទផង ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឃើញប្រយោជន៍ទាំងពីរច្បាស់ហើយ គួរដើម្បីញុំាងកិច្ចឲ្យសម្រេច ដោយសេចក្តីមិនប្រមាទផង ។ ព្រះដ៏មានព្រះភាគ បានទ្រង់ត្រាស់ភាសិតនេះហើយ កាលព្រះដ៏មានព្រះភាគ សម្តែងវេយ្យាករណ៍នេះចប់ហើយ ពួកភិក្ខុទាំង ៦០ រូប ក្អួតស្មុទ្ធែតឈាមក្តៅៗ តាមមាត់ ពួកភិក្ខុ ៦០ រូបទៀត លះបង់សិក្ខា ត្រឡប់ទៅកាន់ភេទជាគ្រហស្ថ ព្រោះមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ សម្តែងនូវអំពើដែលគេធ្វើបានដោយក្រ ព្រះដ៏មានព្រះភាគ សម្តែងនូវអំពើ ដែលគេមិនងាយធ្វើកើត ពួកភិក្ខុ ៦០ រូបទៀត មានចិត្តរួចស្រឡះចាកអាសវៈទាំងឡាយព្រោះមិនប្រកាន់មាំ ។

# អដ្ឋកថា

## អគ្គិក្ខន្ធោបមសូត្រ

[ ៦៩ ] *អគ្គិក្ខន្ធោបមសូត្រទី ៨ ព្រះមានព្រះភាគត្រាស់ហើយ ដោយអត្ថុប្បត្តិហេតុ ។ ការកើតឡើងនៃរឿងរបស់សូត្រនេះ ពោលហើយដោយពិស្តារ ក្នុងចុល្លច្ឆរាសង្ឃាតសូត្រខាងដើមនោះឯង ។ បទថា* **បស្សថ នោ** *កាត់បទជា* **បស្សថ នុ** *ប្រែថា អ្នកទាំងឡាយឃើញឬហ្ន៎ ។ បទថា* **អាលិត្តំ** *ប្រែថា ឱបរឹត ។ បទថា* **ឧបនិសីទេយ្យ** *ប្រែថា គប្បីចូលទៅអង្គុយជិត ។ បទថា* **អារោចយាមិ** *ប្រែថា តថាគតនឹងប្រាប់ ។ បទថា* **បដិវេទយាមិ** *សេចក្តីថា តថាគតនឹងពោលប្រកាសជាស់តឿនឲ្យជ្រាប ។ បទថា* **វាលរជ្ជុយា** *សេចក្តីថា ដោយខ្សែដែលបុគ្គលវេញហើយ ដោយរោមកន្ទុយសេះ និងរោមកន្ទុយគោ ។ បទថា* **បច្ចោរស្មឹ** *បានដល់ ត្រង់កណ្តាលដើមទ្រូង ។ បទថា* **ដេណ្ឌុទ្ធមាកំ** *ប្រែថា ញ៉ាំងពពុះឲ្យផុសឡើង អធិប្បាយថា ឲ្យតាំងឡើង ។ បទថា* **អត្ថត្ថំ** *បានដល់ ប្រយោជន៍ដែលជាលោកិយ និងលោកុត្តរ ទាំងដែលប្រព្រឹត្តទៅក្នុងភពនេះ និងភពខាងមុខ ។ ក្នុងប្រយោជន៍ដទៃ និងប្រយោជន៍ទាំង ២ ក៏ន័យនេះដូចគ្នា ។ ពាក្យដ៏សេសក្នុងសូត្រនេះដែលគួរពោលទាំងអស់ បានពោលហើយ ក្នុងហេតុកើតនៃរឿងចុល្លច្ឆរាសង្ឃាតសូត្រនោះឯង ។ ព្រះសាស្តា កាលត្រាស់សូត្រនេះហើយទើបត្រាស់ចុល្លច្ឆរាសង្ឃាតសូត្រ ។៚*

**អដ្ឋកថាអគ្គិក្ខន្ធោបមសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## សុនេត្តអនុសាសនីសូត្រទី ៩

[ ៧០ ] ម្នាលភិក្ខុទាំងឡាយ កាលពីដើម មានគ្រូឈ្មោះសុនេត្តៈ ជាអ្នកធ្វើនូវកំពង់ ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯគ្រូឈ្មោះសុនេត្តៈ មានសាវកច្រើនរយ ។ ក៏គ្រូឈ្មោះសុនេត្តៈ រមែងសម្តែងធម៌ ដើម្បីដឹកនាំសាវកទាំងឡាយ ឲ្យទៅកើតក្នុងព្រហ្មលោក ។ ម្នាលភិក្ខុទាំងឡាយ បើពួកសាវកណា មិនបានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះគ្រូឈ្មោះសុនេត្តៈ ដែលសម្តែងធម៌ ដើម្បីដឹកនាំឲ្យទៅកើតក្នុងព្រហ្មលោកទេ ពួកសាវកនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បើពួកសាវកណា បានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះគ្រូឈ្មោះសុនេត្តៈ ដែលសម្តែងធម៌ ដើម្បីដឹកនាំឲ្យទៅកើតក្នុងព្រហ្មលោកហើយ ពួកសាវកនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ កាលពីដើម មានគ្រូឈ្មោះមូគបក្ខៈ ។បេ។ មានគ្រូឈ្មោះអរនេមិ ។បេ។ មានគ្រូឈ្មោះកុទ្ទាលៈ ។បេ។ មានគ្រូឈ្មោះហត្ថិបាល ។បេ។ មានគ្រូឈ្មោះជោតិបាល ។បេ។ មានគ្រូឈ្មោះអរកៈ ជាអ្នកធ្វើនូវកំពង់ ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯគ្រូឈ្មោះអរកៈ មានសាវកច្រើនរយ ។ គ្រូឈ្មោះអរកៈ តែងសម្តែងធម៌ ដើម្បីដឹកនាំសាវកទាំងឡាយ ឲ្យទៅកើតក្នុងព្រហ្មលោក ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវកណា

មិនបានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះគ្រូឈ្មោះអរកៈ ដែលសម្តែងធម៌ ដើម្បីដឹកនាំឲ្យទៅកើតក្នុងព្រហ្មលោកទេ ពួកសាវកទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ បើពួកសាវកណា បានញុំាងចិត្តឲ្យជ្រះថ្លា ចំពោះគ្រូឈ្មោះអរកៈ ដែលសម្តែងធម៌ ដើម្បីដឹកនាំឲ្យទៅកើតក្នុងព្រហ្មលោកហើយ ពួកសាវកនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុនោះដូចម្តេច អ្នកណាមានចិត្តប្រទូស្ត ជេរប្រទេច ផ្តាសានូវគ្រូទាំង ៧ នេះ ជាអ្នកធ្វើនូវកំពង់ ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេកក្នុងកាមទាំងឡាយ មានបរិវារច្រើនរយ ប្រកបដោយពួកសាវក អ្នកនោះឈ្មោះថា សន្សំនូវបាបច្រើនដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុទាំងឡាយ អ្នកណាមានចិត្តប្រទូស្ត ជេរប្រទេចផ្តាសាគ្រូទាំង ៧ នេះ ជាអ្នកធ្វើនូវកំពង់ ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេកក្នុងកាមទាំងឡាយ មានបរិវារច្រើនរយ ប្រកបដោយពួកសាវក អ្នកនោះឈ្មោះថាសន្សំបាបដ៏ច្រើន អ្នកណាមានចិត្តប្រទូស្ត ជេរប្រទេច ផ្តាសាបុគ្គលម្នាក់ ដែលបរិបូណ៌ដោយទិដ្ឋិ ( សោតាបន្នបុគ្គល ) អ្នកនេះឈ្មោះថា សន្សំនូវបាបដ៏ច្រើនជាងនោះទៅទៀត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគត មិនហៅការជេរប្រទេច ពួកសព្រហ្មចារីបុគ្គលនេះ ថាជាខន្តិមានសភាពយ៉ាងនេះ ខាងក្រៅអំពីខន្តិនេះ

ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាយ៉ាងនេះថា ចិត្តទាំងឡាយរបស់យើង នឹងមិនបានប្រទូស្ត ពួកសព្រហ្មចារីបុគ្គល ដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះ ។

# អដ្ឋកថា

## សុនេត្តអនុសាសនីសូត្រ

[ ៧០ ] ក្នុងសុនេត្តអនុសាសនីសូត្រទី ៩ មានអត្ថងាយហើយ ។

អដ្ឋកថាសុនេត្តអនុសាសនីសូត្រទី ៩ ចប់

# សុត្តន្តបិដក

## អរកានុសាសនីសូត្រទី ១០

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ កាលពីដើមមានគ្រូឈ្មោះអរកៈ ជាអ្នកធ្វើនូវកំពង់ ជាទីទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯគ្រូឈ្មោះអរកៈ មានសាវកច្រើនរយ ។ គ្រូឈ្មោះអរកៈ រមែងសម្តែងធម៌ដល់សាវកទាំងឡាយ យ៉ាងនេះថា ម្នាលព្រាហ្មណ៍ ជីវិតពួក

មនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តនូវព្រហ្មចរិយធម៌ ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលព្រាហ្មណ៍ទាំងឡាយ ប្រៀបដូចតំណក់ទឹកសន្សើមលើចុងស្មៅ ដល់ព្រះអាទិត្យរះឡើង ក៏ត្រឡប់បាត់វិញឆាប់រហ័ស ជារបស់មិនឋិតថេរ នៅយូរយារបានយ៉ាងណា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចតំណក់ទឹកសន្សើម យ៉ាងនោះដែរ ។ អ្នកទាំង-ឡាយត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តនូវព្រហ្មចរិយធម៌ ដោយប្រាជ្ញា សត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលព្រាហ្មណ៍ ប្រៀបដូចភ្លៀង មានតំណក់ដ៏ថ្លោសធ្លាក់ចុះមក ក្រពេញទឹកក៏ត្រឡប់បាត់ទៅវិញឆាប់ មិនឋិតថេរយូរយារបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានសេចក្តីទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាក្រពេញទឹក យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលព្រាហ្មណ៍ ប្រៀបដូចស្នាមគំនូសដំបងលើទឹក តែងត្រឡប់បាត់ទៅវិញឆាប់ មិនឋិតថេរយូរយារបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្ស ជារបស់តិច ខ្លី... ប្រៀបដូចជាស្នាមគំនូសដំបងលើទឹក យ៉ាងនោះដែរ ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ទៅវិញ ។ ម្នាល

ព្រាហ្មណ៍ ប្រៀបដូចស្ទឹងហូរពីភ្នំ ហូរទៅកាន់ទីឆ្ងាយ មានខ្សែទឹករហ័ស អាចនាំទៅនូវរបស់ដែលគួរនាំទៅបាន គ្មានកំណត់កាលកំណត់វេលា កំណត់យាមឡើយ ព្រោះស្ទឹងនោះចេះតែទៅ ចេះតែប្រព្រឹត្តទៅ ចេះតែហូរទៅបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី ប្រៀបដូចជាស្ទឹងហូរពីភ្នំ ... យ៉ាងនោះដែរ ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ទៅវិញ ។ ម្នាលព្រាហ្មណ៍ ប្រៀបដូចបុរសដែលមានកម្លាំង គ្រលៀវដុំទឹកមាត់ដាក់លើចុងអណ្តាត ហើយស្តោះចោលទៅដោយងាយបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី ប្រៀបដូចដុំទឹកមាត់ ... យ៉ាងនោះដែរ ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ទៅវិញ ។ ម្នាលព្រាហ្មណ៍ ដូចជាដុំសាច់ដែលគេយកទៅដាក់ក្នុងខ្ទះដែកដ៏ក្តៅអស់មួយថ្ងៃ រមែងខ្ទាចចង្រុះឆាប់ មិនឋិតថេរ យូរយារបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់ តិច ខ្លី ប្រៀបដូចដុំសាច់... យ៉ាងនោះដែរ ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលព្រាហ្មណ៍ ដូចមេគោដែលត្រូវសម្លាប់ ដែលគេនាំទៅកាន់កន្លែងសម្លាប់ ឈានជំហានណាទៅ ឈ្មោះថា ខិតទៅជិតកន្លែងសម្លាប់ ជិតសេចក្តីស្លាប់ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាមេគោ ដែលត្រូវសម្លាប់ យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយ-

ធម៌ ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង ពួកមនុស្សមានអាយុប្រាំមួយម៉ឺនឆ្នាំ ។ កុមារិកាមានអាយុត្រឹមប្រាំរយឆ្នាំ ទើបល្មមមានប្តី ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង ពួកមនុស្សមានតែអាពាធ ៦ យ៉ាង គឺរងា ១ ក្តៅ ១ ឃ្លាន ១ ស្រេក ១ ឈឺឧច្ចារៈ ១ ឈឺបស្សាវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ គ្រូឈ្មោះអរកៈនោះ អម្បាលពួកមនុស្សមានអាយុវែងយ៉ាងនេះ ឋិតនៅយូរយារយ៉ាងនេះ មានអាពាធតិចយ៉ាងនេះ ម្តេចគង់សម្តែងធម៌ដល់ពួកសាវកយ៉ាងនេះថា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ បើបុគ្គលនិយាយឲ្យត្រូវ ត្រូវនិយាយថា ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។ បុគ្គលត្រូវដឹង ត្រូវធ្វើនូវកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ បុគ្គលរស់នៅយ៉ាងយូរត្រឹមមួយរយឆ្នាំ ឬតិចជាង ឬក៏លើសពីមួយរយឆ្នាំបន្តិចបន្តួច ។ ម្នាលភិក្ខុទាំងឡាយ ក៏បុគ្គលដែលរស់នៅបានមួយរយឆ្នាំ ឈ្មោះថា រស់នៅអស់បីរយរដូវ គឺហេមន្តរដូវមួយរយ គិម្ហរដូវមួយរយ វស្សានរដូវមួយរយ ។ ម្នាលភិក្ខុទាំងឡាយ ក៏បុគ្គលដែលរស់

នៅអស់បីរយរដូវ ឈ្មោះថា រស់នៅមួយពាន់ពីររយខែ គឺហេមន្តរដូវបួនរយខែ គិម្ហរដូវបួនរយខែ វស្សានរដូវបួនរយខែ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលរស់នៅអស់មួយពាន់ពីររយខែហើយ បើរាប់ជាកន្លះៗ ខែ ឈ្មោះថា រស់នៅអស់ពីរពាន់បួនរយកន្លះៗ ខែ គឺហេមន្តរដូវប្រាំបីរយកន្លះខែ គិម្ហរដូវប្រាំបីរយកន្លះខែ វស្សានរដូវប្រាំបីរយកន្លះខែ ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើបុគ្គលរស់នៅអស់ពីរពាន់បួនរយកន្លះៗ ខែហើយ ឈ្មោះថា រស់នៅអស់បីម៉ឺនប្រាំមួយពាន់រាត្រី គឺហេមន្តរដូវ មួយម៉ឺនពីរពាន់រាត្រី គិម្ហ-រដូវ មួយម៉ឺនពីរពាន់រាត្រី វស្សានរដូវ មួយម៉ឺនពីរពាន់រាត្រី ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលរស់នៅអស់បីម៉ឺនប្រាំមួយពាន់រាត្រីហើយ រមែងបរិភោគបាយប្រាំពីរម៉ឺនពីរពាន់ដង គឺហេមន្តរដូវពីរម៉ឺនបួនពាន់ដង គិម្ហរដូវពីរម៉ឺនបួនពាន់ដង វស្សានរដូវពីរម៉ឺនបួនពាន់ដង រាប់ទាំងបៅទឹកដោះម្តាយរាប់ទាំងខានបរិភោគបាយ ។ ក្នុងហេតុទាំងនោះ ការអត់បាយនេះ គឺបុគ្គលខឹងមិនបរិភោគបាយ បុគ្គលព្រួយមិនបរិភោគបាយ បុគ្គលឈឺចាប់មិនបរិភោគបាយ បុគ្គលរក្សាឧបោសថមិនបរិភោគបាយ បុគ្គលមិនបរិភោគបាយព្រោះរកអ្វីមិនបាន ។ ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្ស ដែលមានអាយុមួយរយឆ្នាំ តថាគតបានរាប់ហើយ ប្រមាណនៃអាយុតថាគតបានរាប់ហើយ រដូវទាំងឡាយ តថាគតបានរាប់ហើយ ឆ្នាំទាំងឡាយ តថាគតបានរាប់ហើយ ខែទាំងឡាយ តថាគតបានរាប់ហើយ កន្លះខែទាំងឡាយ តថាគតបានរាប់

ហើយ រាត្រីទាំងឡាយ តថាគតបានរាប់ហើយ ថ្ងៃទាំងឡាយ តថាគតបាន រាប់ហើយ បាយទាំងឡាយ តថាគតបានរាប់ហើយ ការអត់បាយទាំងឡាយ តថាគតបានរាប់ហើយដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ កិច្ចណាដែលសាស្តា ជាអ្នកស្វែងរកប្រយោជន៍ ទំនុកបម្រុង ជាអ្នកឈឺឆ្អាល អាស្រ័យនូវសេចក្តី ឈឺឆ្អាល គួរធ្វើដល់ពួកសាវក កិច្ចនោះតថាគតបានធ្វើហើយដល់អ្នកទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ នុ៎ះជាគល់ឈើទាំងឡាយ នុ៎ះជាផ្ទះស្ងាត់ទាំង-ឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចម្រើនឈានកុំប្រមាទ កុំមាន សេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។ នេះជាពាក្យប្រៀនប្រដៅ របស់តថាគតចំពោះអ្នកទាំងឡាយ ។

**មហាវគ្គទី ២ ចប់**

## ឧទ្ទានក្នុងមហាវគ្គនោះគឺ

និយាយពីហិរិ ( ឱត្តប្បៈ ) ១ ព្រះអាទិត្យ ១ ប្រៀបដូចជានគរ ១ អ្នកដឹងនូវធម៌ ១ ដើមបារិច្ឆត្តកព្រឹក្ស ១ ធ្វើសក្ការៈគោរព ១ ភាវនា ១ គំនរភ្លើង ១ ពាក្យប្រៀនប្រដៅរបស់គ្រូសុនេត្តៈ ១ របស់គ្រូអរកៈ ១ ។

# អដ្ឋកថា

## អរកានុសាសនីសូត្រ

[ ៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអរកានុសាសនីសូត្រទី ១០ ដូចតទៅនេះ បទថា **បរិត្តំ** សេចក្តីថា តិច គឺតិចតួច ។ ពិតហើយ ជីវិតនោះឈ្មោះថា មានតិចតួចប៉ុណ្ណោះ ព្រោះមានកិច្ចបន្តិចបន្តួចខ្លះ ព្រោះមានរយៈកាលតិចតួចខ្លះ ព្រោះតាំងនៅក្នុងរយៈតិចតួចខ្លះ ជីវិតនោះឈ្មោះថា **លហុក** ព្រោះកើតរហ័ស រលត់រហ័ស ។ បទថា **មន្តាយ ផោដ្ឋព្វំ** សេចក្តីថា គប្បីពាល់ត្រូវដោយការដឹង អធិប្បាយថា គប្បីដឹងដោយបញ្ញា ។ បទថា **បព្វតេយ្យា** បានដល់ ដែលកើតអំពីភ្នំ ។ បទថា **ហារហារិនី** សេចក្តីថា អាចក្លួចយកវត្ថុដែលគប្បីក្លួចយកទៅបាន ដូចជាដើមឈើ ដើមបបុស និងឫស្សីជាដើម ។ ពាក្យដ៏សេស ក្នុងបទទាំងពួងងាយយល់ហើយ ៕

**អដ្ឋកថា អរកានុសាសនីសូត្រទី ១០ ចប់**

**មហាវគ្គទី ២ ចប់**

# សុត្តន្តបិដក
# វិនយវគ្គ

## បឋមវិនយធរសូត្រទី ១

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ឈ្មោះថា វិនយធរ ( អ្នកទ្រទ្រង់វិន័យ ) ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួលនូវឈានទាំង ៤ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយដោយខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះថា វិនយធរ ។

# អដ្ឋកថា
# វិនយធរវគ្គទី ៨

## បឋមវិនយធរសូត្រ

[ ៧២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមវិនយធរសូត្រទី ១ នៃវិនយធរវគ្គទី ៨ ដូចតទៅនេះ បទថា **អាបត្តឹ ជានាតិ** សេចក្តីថា រមែងដឹងអាបត្តិនោះឯងថា ជាអាបត្តិ ។ បទដ៏សេសក៏មានន័យដូចគ្នា ៕

**អដ្ឋកថា បឋមវិនយធរសូត្រទី ១ ចប់**

# សុត្តន្តបិដក
## ទុតិយវិនយធរសូត្រទី ២

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ឈ្មោះថា វិនយធរ ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ បាតិមោក្ខទាំងពីរ ក៏ភិក្ខុនោះចេះចាំដោយត្រឹមត្រូវល្អយ៉ាងពិស្តារ បានចែករលែកដោយល្អ បានឲ្យប្រព្រឹត្តទៅដោយប្រពៃ បានវិនិច្ឆ័យដោយត្រឹមត្រូវតាមសុត្តៈ តាមរបៀបនៃព្យញ្ជនៈ ១ ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល

នូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះថា វិនយធរ ។

# អដ្ឋកថា

## ទុតិយវិនយធរសូត្រ

[ ៧៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយវិនយធរសូត្រទី ២ ដូចតទៅនេះ បទថា **ស្វាគតានិ** ប្រែថា មកល្អហើយ គឺស្ទាត់ល្អហើយ ។ បទថា **សុវិភត្តានិ** សេចក្តីថា ចែកជាចំណែកដោយល្អហើយ ។ បទថា **សុប្បវត្តីនិ** សេចក្តីថា ប្រព្រឹត្តទៅដោយល្អ ក្នុងទីដែលនឹកបាន គឺសូធ្យបាន ស្ទាត់ជំនាញ ។ បទថា **សុវិនិច្ឆិតានិ** ប្រែថា វិនិច្ឆ័យល្អហើយ ។ បទថា **សុត្តសោ** បានដល់ ដោយវិភង្គ ។ បទថា **អនុព្យញ្ជនសោ** បានដល់ ដោយខន្ធកៈ និងបរិវារ ។l៚

**អដ្ឋកថា ទុតិយវិនយធរសូត្រទី ២ ចប់**

# សុត្តន្តបិដក

## តតិយវិនយធរសូត្រទី ៣

[ ៧៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ឈ្មោះថាវិនយធរ ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្ដេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកខ្ជាប់ខ្ជួនមិនឃ្លេងឃ្លោងក្នុងវិន័យ ១ ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួលនូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ១ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងនេះ ឈ្មោះថាវិនយធរ ។

[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ឈ្មោះថាវិនយធរ ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្ដេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ រឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ គឺ ១ ជាតិ ២ ជាតិ ។បេ។ រឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការ និងឧទ្ទេស ១ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងផុតចក្ខុជារបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្ម ១ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ

ឈ្មោះថាវិនយធរ ។

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរប្រកបដោយធម៌ ៧ យ៉ាង ទើបរុងរឿង ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកបានដោយស្រួលនូវឈានទាំង ៤ ។បេ។ ១ ធ្វើឲ្យជាក់ច្បាស់សម្រេច ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរប្រកបដោយធម៌ ៧ យ៉ាងនេះ ទើបរុងរឿង ។

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរប្រកបដោយធម៌ ៧ យ៉ាង ទើបរុងរឿង ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ទាំងបាតិមោក្ខទាំងពីរ ភិក្ខុនោះចេះចាំដោយត្រឹមត្រូវល្អយ៉ាងពិស្តារ បានចែករំលែកដោយល្អ ឲ្យប្រព្រឹត្តទៅដោយប្រពៃ បានវិនិច្ឆ័យដោយត្រឹមត្រូវតាមសុត្តៈ តាមរបៀបនៃព្យញ្ជនៈ ១ ជាអ្នកបានដោយស្រួលនូវឈានទាំង ៤ ។បេ។ ១ ធ្វើឲ្យជាក់ច្បាស់សម្រេច ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ទើបរុងរឿងបាន ។

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរប្រកបដោយធម៌ ៧

យ៉ាង ទើបរុងរឿង ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្ដេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកខ្ជាប់ខ្ជួន មិនយោងយោងក្នុងវិន័យ ១ ជាអ្នកបានដោយស្រួលនូវឈានទាំង ៤ ។បេ។ ១ ធ្វើឲ្យជាក់ច្បាស់សម្រេច ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ទើបរុងរឿង ។

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរប្រកបដោយធម៌ ៧ យ៉ាង ទើបរុងរឿង ។ ប្រកបដោយធម៌ ៧ យ៉ាង តើដូចម្ដេចខ្លះ ។ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ រឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការគឺ ១ ជាតិ ២ ជាតិ ។បេ។ រឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការ និងឧទ្ទេស ១ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងផុតចក្ខុជារបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្ម ១ ធ្វើឲ្យជាក់ច្បាស់សម្រេច ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាវិនយធរ ប្រកបដោយធម៌ទាំង ៧ យ៉ាងនេះ ទើបរុងរឿង ។

# អដ្ឋកថា

## តតិយវិនយធរសូត្រ

[ ៧៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយវិនយធរសូត្រទី ៣ ដូចតទៅនេះ បទថា **វិនយេ ខោ បន ឋិតោ ហោតិ** សេចក្ដីថា តាំងនៅហើយក្នុងលក្ខណៈនៃវិន័យ ។ បទថា **អសំហីរោ** សេចក្ដីថា មិនអាចឲ្យលះបង់នូវការប្រកាន់មាំវត្ថុដែលប្រកាន់ហើយ ។ល។

**អដ្ឋកថា តតិយវិនយធរសូត្រទី ៣ ចប់**

*លេខឃ្នាបទី ៧៥ ដល់លេខឃ្នាប ៧៩*

*មិនមានឈ្មោះសូត្រ និងអដ្ឋកថាឡើយ*

# សុត្តន្តបិដក

## សត្ថុសាសនសូត្រទី ៩

[ ៨០ ] គ្រានោះឯង ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះឧបាលិដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្ដែងធម៌ដល់ខ្ញុំព្រះអង្គ ដោយសេចក្ដីសង្ខេបឲ្យទាន ខ្ញុំព្រះអង្គ

បានស្តាប់ធម៌របស់ព្រះដ៏មានព្រះភាគហើយ នៅតែម្នាក់ឯង ចៀសចេញចាកពួកគណៈ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស បញ្ជូនចិត្តទៅក្នុងព្រះនិព្វាន ។ ម្នាលឧបាលិ អ្នកត្រូវដឹងនូវពួកធម៌ណាថា ធម៌ទាំងនេះមិននាំឲ្យនឿយណាយដោយដាច់ខាត មិននាំឲ្យរសាយចិត្ត មិននាំឲ្យរលត់ មិននាំឲ្យស្ងប់ មិននាំឲ្យបានអភិញ្ញា មិននាំឲ្យបានត្រាស់ដឹង មិននាំឲ្យបានព្រះនិព្វាន ម្នាលឧបាលិ អ្នកត្រូវចាំទុកដោយដាច់ខាតថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រដៅរបស់ព្រះសាស្តាឡើយ ។ ម្នាលឧបាលិ អ្នកត្រូវដឹងនូវពួកធម៌ណាថា ធម៌ទាំងឡាយនេះ នាំឲ្យនឿយណាយដោយដាច់ខាត នាំឲ្យរសាយចិត្ត នាំឲ្យរលត់ នាំឲ្យស្ងប់ នាំឲ្យបានអភិញ្ញា នាំឲ្យបានត្រាស់ដឹង នាំឲ្យបានព្រះនិព្វាន ម្នាលឧបាលិ អ្នកត្រូវចាំទុកដោយដាច់ខាតថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា ។

# អដ្ឋកថា

## សត្ថុសាសនសូត្រ

[ ៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្ថុសាសនសូត្រទី ៩ ដូចតទៅនេះ បទថា **ឯកោ** បានដល់ មិនមានសម្លាញ់ជាគម្រប់ ២ ។ បទថា **វូបកដ្ឋោ** សេចក្តីថា ចៀសចេញទៅហើយ គឺស្ងាត់ហើយ នៅឆ្ងាយហើយ ផ្លូវកាយ

ក៏ចាកគណៈ ផ្លូវចិត្តក៏ចាកកិលេសទាំងឡាយ ។ បទថា **អប្បមត្តោ** បាន ដល់ តាំងនៅហើយ ក្នុងការមិននៅប្រាសចាកសតិ ។ បទថា **បហិតត្តោ** ប្រែថា មានខ្លួនបញ្ជូនទៅហើយ ។ បទថា **និព្វិទាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការនឿយណាយក្នុងវដ្តៈ ។ បទថា **វិរាគាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការប្រាសចាកកិលេស មានរាគៈជាដើម ។ បទថា **និរោធាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការធ្វើមិនឲ្យប្រព្រឹត្តទៅបាន ។ បទថា **វូបសមាយ** បានដល់ ដើម្បីការរម្ងាប់កិលេស ដើម្បីមិនបាននៃកិលេស ។ បទថា **អភិញ្ញាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការដឹងក្រៃលែង នូវការលើកឡើងកាន់ត្រៃលក្ខណ៍ ។ បទថា **សម្ពោធាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការត្រាស់ដឹងធម៌ ពោល គឺមគ្គ ។ បទថា **និព្វានាយ** សេចក្តីថា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ៕

## អដ្ឋកថា សត្ថុសាសនសូត្រទី ៩ ចប់

# សុត្តន្តបិដក

## អធិករណសមថសូត្រទី ១០

[ ៨១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៧ នេះ ឈ្មោះថា អធិករណសមថៈ សម្រាប់រម្ងាប់ សម្រាប់ផ្សះផ្សានូវអធិករណៈទាំងឡាយ ដែលកើត

ឡើងហើយ កើតឡើងហើយ ។ ធម៌ទាំង ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺ សង្ឃត្រូវឲ្យសម្មុខាវិន័យ ១ ត្រូវឲ្យសតិវិន័យ ១ ត្រូវឲ្យអមូឡ្ហវិន័យ ១ ត្រូវវិនិច្ឆ័យកាត់ទោសតាមពាក្យប្តេជ្ញារបស់អ្នកឆ្លើយ ១ ត្រូវវិនិច្ឆ័យតាមភាគច្រើនជាប្រមាណ ១ ត្រូវកាត់ទោសតាមកម្មរបស់ភិក្ខុដែលប្រព្រឹត្តលាមក ១ ត្រូវវិនិច្ឆ័យឲ្យពួកភិក្ខុដែលវិវាទទាស់ទែងគ្នា សង្រួបសង្រួម អត់ឱនគ្នាទៅវិញទៅមក ដូចគេគ្របមូត្រលាមកដោយស្មៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះថា អធិករណសមថៈ សម្រាប់រម្ងាប់ សម្រាប់ផ្សះផ្សានូវអធិករណៈទាំងឡាយ ដែលកើតឡើងហើយ កើតឡើងហើយ ។

**វិនយវគ្គទី ៣ ចប់**

## ឧទ្ទាននៃវិនយវគ្គនោះគឺ

បាលី ១០ លើក មានក្នុងអដ្ឋមវគ្គ គឺនិយាយអំពីភិក្ខុជា
វិនយធរ ៤ ពួក ១ ភិក្ខុជាវិនយធរ ដែលរុងរឿង ៤
ពួក ១ ពាក្យប្រដៅ ១ អធិករណសមថៈ ១ ។

# អដ្ឋកថា

## អធិករណសមថសូត្រ

[ ៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអធិករណសមថសូត្រទី ១០ ដូចតទៅនេះ ធម៌ ឈ្មោះថា **អធិករណសមថ** ព្រោះអត្ថថា រម្ងាប់ គឺញុំាងអធិករណ៍ឲ្យចូលទៅស្ងប់រម្ងាប់ ។ បទថា **ឧប្បន្នុប្បន្នានំ** ប្រែថា កើតឡើងហើយកើតឡើងទៀត ។ បទថា **អធិករណានំ** សេចក្ដីថា អធិករណ៍ ៤ គឺវិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ កិច្ចាធិករណ៍ ១ អាបត្តាធិករណ៍ ១ ។ បទថា **សមថាយ វូបសមាយ** សេចក្ដីថា ដើម្បីស្ងប់ និងដើម្បីចូលទៅរម្ងាប់ ។ គប្បីប្រើសមថៈ ៧ នេះ គឺសម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកវិន័យ ១ ។

ន័យក្នុងការវិនិច្ឆ័យសមថៈទាំងនោះ គប្បីកាន់យកពីអដ្ឋកថាព្រះវិន័យម្យ៉ាងទៀត ក្នុងអដ្ឋកថានៃសង្គីតិសូត្រ ក្នុងទីឃនិកាយ ក៏បានពោលពិស្ដារហើយនោះឯង ។ ក្នុងអដ្ឋកថាសាមគាមសូត្រ ក្នុងមជ្ឈិមនិកាយ ក៏បានពោលហើយដូចគ្នា ។ល។

**អដ្ឋកថាអធិករណសមថសូត្រទី ១០ ចប់**

**វិនយធរវគ្គទី ៨ ចប់**

# សុត្តន្តបិដក

## វគ្គាសង្គហិតសុត្តន្ត

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលហៅថា ភិក្ខុ ព្រោះបានទម្លាយនូវធម៌ ៧ យ៉ាង ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកបានទម្លាយសក្កាយទិដ្ឋិ ១ ទម្លាយវិចិកិច្ឆា ១ ទម្លាយសីលព្វតបរាមាសៈ ១ ទម្លាយរាគៈ ១ ទម្លាយទោសៈ ១ ទម្លាយមោហៈ ១ ទម្លាយមានះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលហៅថា ភិក្ខុ ព្រោះបានទម្លាយនូវធម៌ទាំង ៧ យ៉ាងនេះ ។

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលហៅថា សមណៈ ព្រោះបានរម្ងាប់ធម៌ ៧ យ៉ាង ។បេ។ បុគ្គលដែលហៅថា ព្រាហ្មណ៍ ព្រោះបានបន្សាត់ ។បេ។ បុគ្គលដែលហៅថា សោត្ថិកៈ ព្រោះជាអ្នកប្រាសចាក ។បេ។ បុគ្គលដែលហៅថា នហាតកៈ ព្រោះជាអ្នកលាងជម្រះ ។បេ។ បុគ្គលដែលហៅថា វេទគូ ព្រោះជាអ្នកត្រាស់ដឹង ។បេ។ បុគ្គលដែលហៅថា អរហន្ត ព្រោះជាអ្នកឆ្ងាយ ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺឆ្ងាយចាកសក្កាយទិដ្ឋិ ១ ឆ្ងាយចាកវិចិកិច្ឆា ១ ឆ្ងាយចាកសីលព្វតបរាមាសៈ ១ ឆ្ងាយចាករាគៈ ១ ឆ្ងាយចាកទោសៈ ១ ឆ្ងាយចាកមោហៈ ១ ឆ្ងាយចាកមានះ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលហៅថា អរហន្ត ព្រោះឆ្ងាយចាកធម៌ទាំង ៧ យ៉ាងនេះឯង ។

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ អសទ្ធម្មនេះមាន ៧ យ៉ាង ។ អសទ្ធម្ម ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលមិនមានសទ្ធា ១ មិនមានហិរិ ១ មិនមាន

ឱត្តប្បៈ ១ ជាអ្នកចេះដឹងតិច ១ ខ្ជិលច្រអូស ១ ភ្លេចភ្លាំងស្មារតី ១ ឥតប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អសទ្ធម្មមាន ៧ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សទ្ធម្មនេះមាន ៧ យ៉ាង ។ សទ្ធម្ម ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលមានសទ្ធា ១ មានហិរិ ១ មានឱត្តប្បៈ ១ អ្នកចេះដឹងច្រើន ១ ជាអ្នកផ្គងព្យាយាម ១ មានស្មារតី ១ មានប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ សទ្ធម្មមាន ៧ យ៉ាងនេះឯង ។

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ ជាអ្នកគួរទទួលនូវវត្ថុដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេប្រណម្យអញ្ជលី ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ បុគ្គល ៧ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកឃើញរឿយៗ ថា មិនទៀង មានសេចក្តីសម្គាល់ថាមិនទៀង ដឹងច្បាស់ថាមិនទៀង មានចិត្តចុះស៊ប់ ស្កប់ស្កល់ដោយប្រាជ្ញាជាប់រឿយៗ មិនច្រឡូកច្រឡំក្នុងចក្ខុ ។ បុគ្គលនោះបានធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ នេះជាបុគ្គលទី ១ ដែលគួរទទួលនូវវត្ថុដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេប្រណម្យអញ្ជលី ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះជាអ្នកឃើញរឿយៗ

ថាមិនទៀង មានសេចក្ដីសម្គាល់ថាមិនទៀង ដឹងច្បាស់ថាមិនទៀង មានចិត្តចុះស៊ប់ ស្ងប់ដោយប្រាជ្ញាជាប់រឿយៗ មិនច្រឡូកច្រឡំក្នុងចក្ខុ ។ បុគ្គលនោះអស់ទាំងអាសវៈ អស់ទាំងជីវិតដំណាលៗ គ្នា ។ ម្នាលភិក្ខុទាំងឡាយ នេះជាបុគ្គលទី ២ ដែលគួរទទួលនូវវត្ថុដែលគេនាំមកបូជា ... ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកឃើញរឿយៗ ថាមិនទៀង មានសេចក្ដីសម្គាល់ថាមិនទៀង ដឹងច្បាស់ថាមិនទៀង មានចិត្តចុះស៊ប់ ស្ងប់ដោយប្រាជ្ញាជាប់រឿយៗ មិនច្រឡូកច្រឡំក្នុងចក្ខុ ។ បុគ្គលនោះបានឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់សំយោជនៈ ៥ ដែលជាចំណែកខាងក្រោមរលីង ។បេ។ បានឈ្មោះថាឧបហច្ចបរិនិព្វាយី ។បេ។ បានឈ្មោះថាអសង្ខារបរិនិព្វាយី ។បេ។ បានឈ្មោះថាសសង្ខារបរិនិព្វាយី ។បេ។ បានឈ្មោះថាឧទ្ធំសោតអកនិដ្ឋគាមី ។ ម្នាលភិក្ខុទាំងឡាយ នេះជាបុគ្គលទី ៧ ដែលគួរទទួលនូវវត្ថុដែលគេនាំមកបូជា ... ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៧ ពួកនេះ ជាអ្នកគួរទទួលនូវវត្ថុដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេប្រណម្យអញ្ជលី ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ គួរទទួលនូវវត្ថុដែលគេនាំមកបូជា ... ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ បុគ្គល ៧ ពួក

តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកឃើញរឿយៗ ក្នុងចក្ខុថាជាទុក្ខ ... ១ ឃើញរឿយៗ ក្នុងចក្ខុថា មិនមែនជារបស់ខ្លួន ១ ឃើញរឿយៗ ក្នុងចក្ខុថា អស់ទៅ ១ ឃើញរឿយៗ ក្នុងចក្ខុថា សាបសូន្យទៅ ១ ឃើញរឿយៗ ក្នុងចក្ខុថា គួរសោយចិត្ត ១ ឃើញរឿយៗ ក្នុងចក្ខុថា ជារបស់រលត់ ១ ឃើញរឿយៗ ក្នុងចក្ខុថា ជារបស់គួរលះបង់ចេញ ១ ក្នុងសោតៈ ឃានៈ ជិវ្ហា កាយ មនៈ ក្នុងរូបទាំងឡាយ សំឡេងទាំងឡាយ ក្លិនទាំងឡាយ រសទាំងឡាយ ផោដ្ឋព្វៈទាំងឡាយ ធម្មារម្មណ៍ទាំងឡាយ ក្នុងចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ក្នុងចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស ក្នុងវេទនាដែលកើតអំពីចក្ខុ-សម្ផស្ស វេទនាដែលកើតអំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃាន-សម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេទនាដែលកើតអំពីមនោសម្ផស្ស ក្នុងរូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រស-សញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា ក្នុងរូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធ-សញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា ក្នុងរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ក្នុងរូបវិតក្ក សទ្ទវិតក្ក គន្ធវិតក្ក រសវិតក្ក ផោដ្ឋព្វវិតក្ក ធម្មវិតក្ក ក្នុងរូបវិចារៈ សទ្ទ-វិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ ក្នុងរូបក្ខន្ធ វេទនាខន្ធ

សញ្ញាខន្ធ សង្ខារក្ខន្ធ ជាអ្នកឃើញរឿយៗ ក្នុងវិញ្ញាណក្ខន្ធថា ជារបស់មិនទៀង ឃើញរឿយៗ ថាជាទុក្ខ ឃើញរឿយៗ ថាមិនមែនរបស់ខ្លួន ឃើញរឿយៗ ថាអស់ទៅ ឃើញរឿយៗ ថាសាបសូន្យទៅ ឃើញរឿយៗ ថាគួរស្រោយចិត្ត ឃើញរឿយៗ ថារលត់ ឃើញរឿយៗ ថាជារបស់គួរលះបង់ចេញ ។

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងដែលបុគ្គលត្រូវចម្រើនដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៧ យ៉ាងនេះ ដែលបុគ្គលត្រូវចម្រើនដើម្បីដឹងច្បាស់នូវរាគៈ ។

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងដែលបុគ្គលត្រូវចម្រើនដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺអនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះដែលបុគ្គលត្រូវចម្រើនដើម្បីដឹងច្បាស់នូវរាគៈ ។

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ ដែលបុគ្គលត្រូវចម្រើនដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៧ យ៉ាង តើដូចម្តេចខ្លះ ។ គឺអសុភសញ្ញា ១ មរណសញ្ញា ១ អាហារេបដិកូលសញ្ញា ១ សព្វលោកេអនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេទុក្ខសញ្ញា ១ ទុក្ខេអនត្តសញ្ញា ១ ។ ម្នាលភិក្ខុទាំង-

ឡាយ ធម៌ទាំង ៧ យ៉ាងនេះ ដែលបុគ្គលត្រូវចម្រើនដើម្បីដឹងច្បាស់នូវរាគៈ ។

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាង ដែលបុគ្គលត្រូវចម្រើន ដើម្បីកំណត់ដឹង ។បេ។ ដើម្បីឲ្យអស់រលីង ដើម្បីលះ ដើម្បីឲ្យក្ស័យ ដើម្បីឲ្យសាបសូន្យ ដើម្បីរំសាយ ដើម្បីរម្ងត់ ដើម្បីឲ្យដាច់ ដើម្បីបោះបង់នូវរាគៈ ។ ធម៌ ៧ យ៉ាងនេះដែលបុគ្គលត្រូវចម្រើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីឲ្យអស់រលីង ដើម្បីលះ ដើម្បីឲ្យក្ស័យ ដើម្បីឲ្យសាបសូន្យទៅ ដើម្បីរំសាយ ដើម្បីរម្ងត់ ដើម្បីឲ្យដាច់ ដើម្បីបោះបង់នូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។

សត្តកនិបាត ចប់

# អដ្ឋកថា

## សូត្រដែលមិនសង្គ្រោះចូលក្នុងវគ្គ

សូត្រ ៧ បន្ទាប់អំពីនេះ មានអត្ថងាយយល់ទាំងអស់ហើយ ។ ព្រោះក្នុងព្រះសូត្រនេះ សូត្រណាមួយ ឈ្មោះថា មានន័យមិនបានពោលហើយខាងដើមមិនមានឡើយ ដូច្នេះឯង ។

**អដ្ឋកថា សត្តកនិបាត ចប់**

**មនោរថបូរណីអដ្ឋកថាអង្គុត្តរនិកាយ ចប់**

# សុត្តន្តបិដក
# អង្គុត្តរនិកាយ អដ្ឋកនិបាត
# ឆដ្ឋមភាគ

*សូមនមស្ការព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## បណ្ណាសក មេត្តាវគ្គ
### មេត្តាសូត្រទី ១

*[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលធ្វើឲ្យច្រើន ចម្រើនធ្វើឲ្យរឿយៗ ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីនៅ បានតាំងទុករឿយៗ បានសន្សំ បានប្រារព្ធល្អហើយ មានអានិសង្ស ៨ ប្រការជាប្រាកដ ។ អានិសង្ស ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺដេកលក់ជាសុខ ១ ភ្ញាក់ឡើងជាសុខ ១ មិនឃើញនូវសុបិនអាក្រក់ ១ ជាទីស្រឡាញ់នៃពួកមនុស្ស ១ ជាទីស្រឡាញ់នៃពួកអមនុស្ស ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី សស្ត្រាវុធក្តី មិនប៉ះពាល់នូវបុគ្គលនោះ ១*

កាលបើមិនទាន់បានគុណវិសេសដ៏ខ្ពង់ខ្ពស់ទេ រមែងទៅកើតក្នុងព្រហ្មលោក ១ ។ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលធ្វើឲ្យច្បឹក ចម្រើន ធ្វើឲ្យរឿយៗ ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីនៅ បានតាំងទុករឿយៗ បានសន្សំ បានប្រារព្ធល្អហើយ រមែងមានអានិសង្ស ៨ ប្រការនេះឯងជាប្រាកដ ។

បុគ្គលដែលនឹករឭកចំពោះ ចម្រើននូវមេត្តា ប្រមាណ មិនបាន ពិចារណាឃើញនូវការអស់ទៅ នៃឧបធិ-ក្កិលេស សំយោជនៈទាំងឡាយក៏ស្រាលស្តើង ( ចាក ខន្ធសន្តាន ) បើបុគ្គលមានចិត្តមិនបានប្រទូស្តសត្វណា មួយ ឈ្មោះថា ជាប់មេត្តា កុសលក៏រមែងកើតមាន ដោយហេតុនោះ ចំណែកព្រះអរិយៈ មានចិត្តអនុគ្រោះ សត្វទាំងឡាយទាំងពួង តែងធ្វើបុណ្យច្រើន ពួកស្តេច ណាដែលប្រាកដ ដូចជាឥសី បានឈ្នះនូវផែនដីដែល ពាសពេញដោយមនុស្សសត្វ កាលឲ្យទាន ប្រព្រឹត្ត រឿយៗ ( ដោយសង្គហវត្ថុ ៤ ប្រការ ) គឺឈ្លាសវៃ ក្នុងការទំនុកបម្រុងធញ្ញជាតិ ១ ឈ្លាសវៃក្នុងការទំនុក បម្រុងមនុស្ស ១ ការចងចិត្តមនុស្ស ១ ពោលពាក្យ ជាទីស្រឡាញ់ ១ មិនបាច់ប្រើទុកទ្វារផ្ទះឡើយ ការឲ្យ ទានទាំងឡាយនោះ ក៏មិនដល់នូវចំណិតក្នុងចំណែក ១៦

នៃមេត្តាចិត្តដែលបានអប់រំហើយ ដូចជារស្មីព្រះចន្ទ្រ និង ពួកផ្កាយទាំងពួង បុគ្គលណា ជាអ្នកមានចំណែកនៃមេត្តា សមាធិចិត្តចំពោះពួកសត្វទាំងអស់ មិនបៀតបៀន មិន សម្លាប់ មិនធ្វើសេចក្តីវិនាសដល់សត្វដទៃដោយខ្លួនឯង មិនប្រើអ្នកដទៃ ឲ្យធ្វើសេចក្តីវិនាសដល់សត្វដទៃ វេរា របស់បុគ្គលនោះ មិនមានដោយហេតុណាមួយឡើយ ។

# អដ្ឋកថា
# អង្គុត្តរនិកាយ អដ្ឋកនិបាត
# បឋមបណ្ណាសក

## មេត្តាវគ្គទី ១

### មេត្តាសូត្រ

[ ១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងមេត្តាសូត្រទី ១ នៃអដ្ឋកនិបាតដូចតទៅនេះ បទថា* **អាសេវិតាយ** *ប្រែថា សេពដោយអើពើ ។ បទថា* **ភាវិតាយ** *ប្រែថា ចម្រើនហើយ ។ បទថា* **ពហុលីកតាយ** *ប្រែថា ធ្វើរឿយៗ ។ បទថា* **យានីកតាយ** *ប្រែថា ធ្វើឲ្យដូចជាយានដែលទឹមហើយដោយសេះ ។ បទថា* **វត្ថុកតាយ** *ប្រែថា ធ្វើឲ្យដូចជាវត្ថុ ទីតាំង ព្រោះអត្ថថា ជាទីតាំង ។ បទថា* **អនុដ្ឋិតាយ** *ប្រែថា ចូលទៅតាំងទុកចំពោះ គឺប្រាកដ ។ បទថា* **បរិចិតាយ** *ប្រែថា សន្សំ គឺចូលទៅសន្សំដោយប្រពៃ ។ បទថា* **សុសមារទ្ធាយ** *ប្រែថា ផ្ដើមល្អហើយ គឺធ្វើល្អហើយ ។ បទថា* **អានិសំសា** *បានដល់ គុណ គឺសេចក្ដីល្អ ។ ពាក្យដែលគប្បីពោលក្នុងបទថា* **សុខំ សុបតិ** *ដូច្នេះជាដើម ខ្ញុំនឹងពោលក្នុងឯកាទសកនិបាតខាងមុខ ។*

*បទថា* **អប្បមាណំ** *គឺមិនមានប្រមាណដោយការផ្សាយទៅ ។ បទថា* **តនូ សំយោជនា ហោន្តិ បស្សតោ ឧបធិក្ខយំ** *សេចក្ដីថា សំយោជនៈ ១០*

ដែលបុគ្គលសម្រេចអរហត្ត ពោល គឺធម៌ជាទីអស់ទៅនូវឧបធិក្កិលេសដោយលំដាប់ លះបានដោយវិបស្សនា មានមេត្តាជាបទដ្ឋាន ។ ម្យ៉ាងទៀត បទថា **តនុ សំយោជនា ហោន្តិ** សេចក្តីថា បដិឃៈ និងសំយោជនៈដែលសម្បយុត្តដោយបដិឃៈ ជាកិលេសដែលស្រាលស្តើង ។ បទថា **បស្សតោ ឧបធិក្ខយំ** សេចក្តីថា ជាអ្នកឃើញនូវព្រះអរហត្ត ពោល គឺធម៌ជាទីអស់ឧបធិក្កិលេសទាំងនោះឯង ដោយអំណាចចាក់ធ្លុះ ។ បទថា **កុសលំ តេន ហោតិ** ប្រែថា រមែងជាកុសលដោយការចម្រើនមេត្តានោះ ។ បទថា **សត្តសណ្ឌំ** សេចក្តីថា រមែងប្រកបដោយជដៈ គឺពួកសត្វ អធិប្បាយថា ពេញដោយពួកសត្វ ។ បទថា **ជិនិត្វា** បានដល់ ឈ្នះដោយមិនមែនអាជ្ញា មិនប្រើសស្ត្រា ប្រើធម៌តែម្យ៉ាង ។ បទថា **រាជិសយោ** បានដល់ ព្រះរាជាតាំងនៅក្នុងធម៌ ដូចឥសី ។ បទថា **យជមានា** បានដល់ ឲ្យទានទាំងឡាយ ។ បទថា **អនុបរិយគា** ប្រែថា ត្រាច់ទៅហើយ ។

ក្នុងបទថា **សស្សមេធំ** មានវិនិច្ឆ័យដូចតទៅនេះថា បានឮថា កាលព្រះរាជាតាំងនៅក្នុងបុរាណធម៌ មានសង្គហវត្ថុ ៤ ដែលព្រះរាជាទាំងឡាយទ្រង់សង្គ្រោះលោក គឺសស្សមេធ បុរិសមេធ សម្មាបាស វាជបេយ្យ ។

ក្នុងសង្គហវត្ថុ ៤ ប្រការនោះ ការកាន់យកចំណែកទី ១០ អំពីស្រូវដែលបានផលហើយ ឈ្មោះថា **សស្សមេធ** អធិប្បាយថា ភាពជាអ្នកឈ្លាសក្នុងការទំនុកបម្រុងស្រូវ ។ ការបន្ថែមឲ្យអាហារ និងថ្លៃឈ្នួលគ្រប់គ្រាន់ ៦

ខែ ដល់អ្នកចម្បាំងធំទាំងឡាយ ឈ្មោះថា **បុរិសមេធ** អធិប្បាយថា ភាព ជាអ្នកឈ្លាសក្នុងការទាញទឹកចិត្តមនុស្ស ។ ការកត់ចំណាំចំនួនអ្នកក្រ និង អ្នកមាន ហើយឲ្យទ្រព្យប្រមាណ ១០០០-២០០០ ដោយមិនយកការប្រាក់ ក្នុងពេល ៣ ឆ្នាំ ឈ្មោះថា **សម្មាបាស** ការធ្វើបែបនោះ រមែងរក្សាមនុស្ស ទាំងឡាយទុកបានល្អ គឺតាំងនៅដូចចងចិត្តទុក ព្រោះដូច្នោះ ទើបហៅថា **សម្មាបាស** ។ ការពោលវាចាទន់ភ្លន់ ដោយន័យជាដើមថា លោកឪពុក លោកអ៊ំ ឈ្មោះថា **វាជបេយ្យ** អធិប្បាយថា បិយវាចា គឺមានវាចាគួរ ស្រឡាញ់ ។ រដ្ឋដែលសង្គ្រោះដោយសង្គហវត្ថុ ៤ ប្រការយ៉ាងនេះ រមែង ជារដ្ឋដែលចម្រើនមាំទាំ មានបាយ និងទឹកបរិបូណ៌ ទូលាយ ប្រាសចាក ចោរប្រទូស្ត ។ មនុស្សទាំងឡាយត្រេកអរ ឲ្យកូនរាំនៅលើទ្រូង មិនចាំបាច់ បិទទ្វារផ្ទះ នេះហៅថា **និរគ្គឡ** ព្រោះមិនចាំបាច់ខ្ទាស់ទ្វារផ្ទះ នេះជាបុរាណ បវេណី ។

ចំណេរកាលតមក ក្នុងសម័យព្រះបាទឱក្កាករាជ ពួកព្រាហ្មណ៍ផ្លាស់ ប្តូរសង្គហវត្ថុ ៤ ប្រការនេះ និងសម្បត្តិរបស់រដ្ឋនេះចោល ធ្វើឲ្យខុសគន្លង ដើម សូម្បីយញ្ញទាំង ៥ មានអស្សមេធជាដើម ។ ក្នុងយញ្ញ ៥ ប្រការ នោះ យញ្ញ ឈ្មោះថា អស្សមេធ ព្រោះសម្លាប់សេះក្នុងយញ្ញនោះ ។ ពាក្យ ថា **អស្សមេធ** នោះ ជាឈ្មោះនៃយញ្ញដែលគប្បីបូជាដោយយញ្ញជាបរិវារ ២ យ៉ាង មានសសរយញ្ញ ២១ មានការបៀតបៀន ព្រោះការសម្លាប់បសុសត្វ

៥៩៧ ក្បាល ព្រោះក្នុងថ្ងៃចុងក្រោយតែមួយ មានសម្បត្តិទាំងពួងមិនសេសសល់ វៀរដី និងមនុស្សជាទក្ខិណា ។ យញ្ញ ឈ្មោះថា បុរិសមេធ ព្រោះសម្លាប់មនុស្សក្នុងយញ្ញនោះ ។ ពាក្យថា បុរិសមេធនោះ ជាឈ្មោះនៃយញ្ញដែលបូជាដោយយញ្ញដែលជាបរិវារ ៤ យ៉ាង មានសម្បត្តិដូចពោលក្នុងអស្សមេធ មួយអន្លើដោយដីជាទក្ខិណា ។ យញ្ញ ឈ្មោះថា សម្មាបាស ព្រោះមានការស៊កគន្លឹះក្នុងយញ្ញនោះ ។ ពាក្យថា **សម្មាបាស** នេះ ជាឈ្មោះរបស់សត្តយាគ បូជា គឺយញ្ញដែលមានសសរដែលធ្វើច្រើនថ្ងៃ ដែលដាក់គន្លឹះ គឺកំណាត់ឈើស៊កចូលទៅក្នុងប្រហោងនឹមរាល់ៗ ថ្ងៃ ហើយធ្វើភូមិដែលបូជាក្នុងឱកាស ដែលគន្លឹះនោះធ្លាក់ ហើយដើរថយក្រោយ តាំងអំពីឱកាសដែលព្រះរាជាក្នុងកាលមុនមុជចុះក្នុងស្ទឹងសរស្សវតី បូជាដោយសសរយញ្ញជាដើម ដែលឃ្លាតចាកទីបានដោយពាហនៈ ។ ឈ្មោះថា **វាជ-បេយ្យ** ព្រោះផឹកវាជៈ គឺសប្បិ និងទឹកឃ្មុំក្នុងយញ្ញនោះ ។ ពាក្យថា វាជបេយ្យនេះ ជាឈ្មោះរបស់យញ្ញដែលត្រូវបូជាដោយបសុសត្វ ១៧ ដោយយញ្ញបរិវារណាមួយ មានសសរយញ្ញ ដែលធ្វើអំពីដើមព្នៅ ដែលឲ្យប្រេកបដោយរបស់ ១៧ យ៉ាង ជាទក្ខិណា ។ ឈ្មោះថា **និរគ្គឡ** ព្រោះមិនមានគន្លឹះក្នុងយញ្ញនោះ ។ ពាក្យថា និរគ្គឡនេះ ជាឈ្មោះរបស់អស្សមេធមួយទៀត ដែលមានឈ្មោះដោយអមថា **សព្វមេធ** ដែលត្រូវបូជាដោយយញ្ញបរិវារ ១៩ យ៉ាង ឲ្យនូវសម្បត្តិ ដូចពោលក្នុងអស្សមេធ ព្រមដោយដី

*និងមនុស្សដែលជាទក្ខិណា ។*

*បទថា* **កលម្បិ តេ នានុភវន្តិ សោឡសឹ** *សេចក្តីថា ដ្បិតថា មហាយញ្ញទាំងអស់នោះ មានអានិសង្សមិនដល់ចំណែកទី ១៦ អធិប្បាយថា មិនដល់ចំណែកទី ១៦ ព្រោះមេត្តាចិត្ត ១ ដួងដែលមានវិបាក គឺផលច្រើន ។*

*បទថា* **ន ជិនាតិ** *បានដល់ មិនធ្វើនូវសេចក្តីវិនាសដល់អ្នកដទៃដោយខ្លួនឯង ។ បទថា* **ន ជាបយេ** *បានដល់ មិនមែនអ្នកដទៃធ្វើនូវការវិនាសដល់អ្នកដទៃ ។ បទថា* **មេត្តំសោ** *បានដល់ ជាអ្នកមានចំណែកនៃសមាធិចិត្តដែលសម្បយុត្តដោយមេត្តា ។ បទថា* **សព្វភូតានំ** *បានដល់ ក្នុងសព្វសត្វទាំងឡាយ ។ បទថា* **វេរំ តស្ស ន កេនចិ** *សេចក្តីថា បុគ្គលនោះរមែងមិនមានអកុសលវេរ ឬបុគ្គលវេរជាមួយបុគ្គលណាឡើយ ។*

**អដ្ឋកថា មេត្តាសូត្រទី ១ ចប់**

# សុត្តន្តបិដក

## បញ្ញាសូត្រទី ២

[ ២ ] *ម្នាលភិក្ខុទាំងឡាយ ហេតុ ៨ យ៉ាង បច្ច័យ ៨ យ៉ាងនេះប្រព្រឹត្តទៅដើម្បីបាននូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាពដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញាដែលខ្លួនបាន*

ហើយ ។ ហេតុបច្ច័យ ៨ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនៅនឹងគ្រូ ឬសព្រហ្មចារីបុគ្គលណាមួយ ជាគរុដ្ឋានិយបុគ្គល ( បុគ្គលតាំងនៅក្នុងស្ថានដែលគួរគោរព ) ជាអ្នកមាន ហិរិ និងឱត្តប្បៈដ៏ក្លៀវក្លា តម្កល់នូវសេចក្ដីស្រឡាញ់ និងសេចក្ដីគោរពចំពោះ បុគ្គលជាគរុដ្ឋានិយៈ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុ នេះជាបច្ច័យទី ១ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែល ខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញា ដែលខ្លួនបាន ។ បុគ្គលនោះ ចូលទៅអាស្រ័យនៅនឹងគ្រូនោះ ឬសព្រហ្មចារី បុគ្គលណាមួយ ជាគរុដ្ឋានិយៈ ជាអ្នកមានហិរិ និងឱត្តប្បៈដ៏ក្លៀវក្លា តម្កល់ សេចក្ដីស្រឡាញ់ និងសេចក្ដីគោរពចំពោះបុគ្គលគរុដ្ឋានិយៈ ភិក្ខុនោះចូលទៅ រក ( បុគ្គលនោះ ) តាមកាលគួរ ហើយសាកសួរត្រង់ប្រស្នាថា បពិត្រ លោកដ៏ចម្រើន ហេតុនេះដូចម្ដេច សេចក្ដីអធិប្បាយនៃភាសិតនេះដូចម្ដេច ។ លោកដ៏មានអាយុទាំងឡាយនោះ បើកបង្ហាញនូវធម៌ដែលកំបាំងផង ធ្វើធម៌ ដែលមានជម្រៅឲ្យរាក់ផង បន្ទោបង់នូវសេចក្ដីសង្ស័យក្នុងធម៌ដែលគួរសង្ស័យ ច្រើនប្រការផង ដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២ ជាបច្ច័យ ទី ២ ដែលប្រព្រឹត្តទៅដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនធ្លាប់បានដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវ បញ្ញាដែលខ្លួនបាន ។ ភិក្ខុនោះ លុះបានស្ដាប់ធម៌នោះហើយ ទើបញុំាងសេចក្ដី

ស្ងប់រម្ងាប់ ២ ប្រការឲ្យសម្រេច គឺការស្ងប់រម្ងាប់កាយ ១ ស្ងប់រម្ងាប់ចិត្ត ១ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៣ ជាបច្ច័យទី ៣ ដែលប្រព្រឹត្តទៅដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។ ភិក្ខុជាអ្នកមានសីល សង្រួមហើយក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៤ ជាបច្ច័យទី ៤ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញាជាខាងដើម នៃមគ្គព្រហ្មចារ្យដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាពដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។ ភិក្ខុជាអ្នករៀនសូត្រច្រើន ទ្រទ្រង់ព្រះសូត្រ ចេះចាំព្រះសូត្រ ធម៌ទាំងឡាយណា មានពីរោះបទដើម ពីរោះបទកណ្ដាល ពីរោះបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏បរិបូណ៌បរិសុទ្ធទាំងអស់ ធម៌ទាំងឡាយ មានសភាពដូច្នោះ ភិក្ខុនោះ បានរៀនសូត្រច្រើន ទ្រទ្រង់ចាំស្ទាត់ រត់មាត់ ជាក់ច្បាស់ក្នុងចិត្ត យល់ច្បាស់ដោយទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៥ ជាបច្ច័យទី ៥ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាពដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។ ភិក្ខុប្រារព្ធសេចក្ដីព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ហើយបំពេញនូវ

កុសលធម៌ទាំងឡាយ មានកម្លាំង មានសេចក្តីប្រឹងប្រែងដ៏មាំ មិនដាក់ធុរៈក្នុងធម៌ទាំងឡាយជាកុសល ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៦ ជាបច្ច័យទី ៦ ដែលប្រព្រឹត្តទៅដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនធ្លាប់បានដើម្បីជាភិយ្យោភាពដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញា ដែលខ្លួនបាន ។ ភិក្ខុនៅក្នុងសង្ឃ មិនមែននិយាយផ្តេសផ្តាស មិនមែនជាអ្នកនិយាយតិរច្ឆានកថា រមែងសម្តែងធម៌ដោយខ្លួនឯងផង អារាធនាអ្នកឯទៀតឲ្យសម្តែងផង មិនមើលងាយព្រះអរិយៈដែលស្ងប់ស្ងៀមផង ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៧ ជាបច្ច័យទី ៧ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនធ្លាប់បានដើម្បីជាភិយ្យោភាពដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។ ភិក្ខុពិចារណាឃើញរឿយៗ នូវការកើតឡើង និងសូន្យទៅក្នុងឧបាទានក្ខន្ធទាំងឡាយ ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ ការវិនាសនៃរូបដូច្នេះ វេទនាដូច្នេះ សញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ ការវិនាសទៅនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៨ ជាបច្ច័យទី ៨ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាពដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញាដែលខ្លួនបានហើយ ។ ពួកសព្រហ្មចារីបុគ្គលតែងនាំគ្នាសរសើរនូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុ ( នេះ ) បានចូលទៅនៅ

អាស្រ័យនឹងគ្រូ ឬសព្រហ្មចារីបុគ្គលណាមួយ ជាគរុដ្ឋានិយៈជាអ្នកមានហិរិ និងឱត្តប្បៈ តម្កល់សេចក្តីស្រឡាញ់ និងសេចក្តីគោរពចំពោះបុគ្គលជាគរុដ្ឋានិយៈដោយគិតថា លោកដ៏មានអាយុនេះ ដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះ ប្រព្រឹត្តទៅ ដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ ចំណែកលោកដ៏មានអាយុនេះ ចូលទៅនៅអាស្រ័យនឹងគ្រូនោះ ឬសព្រហ្មចារីបុគ្គលណាមួយជាគរុដ្ឋានិយៈ ជាអ្នកមានហិរិ និងឱត្តប្បៈ តម្កល់សេចក្តីស្រឡាញ់ និងសេចក្តីគោរពចំពោះបុគ្គលជាគរុដ្ឋានិយៈ លុះលោកដ៏មានអាយុនោះ ចូលទៅរកគ្រូនោះ តាមកាលដ៏សមគួរហើយ សាកសួរត្រង់ប្រស្នាថា បពិត្រលោកដ៏ចម្រើន ហេតុនេះដូចម្តេច សេចក្តីអធិប្បាយនៃភាសិតនេះដូចម្តេច ។ លោកដ៏មានអាយុទាំងនោះ ក៏បើកបង្ហាញនូវធម៌ដែលកំបាំងផង ធ្វើធម៌ដែលមានជម្រៅឲ្យរាក់ផង បន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលគួរសង្ស័យច្រើនប្រការផង ដោយគិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ឯធម៌នេះ ប្រព្រឹត្តទៅដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ លុះលោកមានអាយុនេះស្តាប់ធម៌នោះហើយ ទើបញ៉ាំងការស្ងប់រម្ងាប់ ២ ប្រការឲ្យសម្រេច គឺការស្ងប់រម្ងាប់កាយ ១ ស្ងប់រម្ងាប់ចិត្ត ១

ដោយគិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯង ប្រព្រឹត្តទៅដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។ ចំណែកខាងលោកដ៏មានអាយុនេះជាអ្នកមានសីល សង្រួមហើយក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរ ឃើញភ័យក្នុងទោសទាំងឡាយបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ក៏គិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯង ប្រព្រឹត្តទៅដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។ ចំណែកលោកដ៏មានអាយុនេះ ជាអ្នករៀនសូត្រច្រើន ទ្រទ្រង់ព្រះសូត្រ ចេះដឹងព្រះសូត្រ ធម៌ទាំងឡាយណា មានពីរោះបទដើម ពីរោះបទកណ្ដាល ពីរោះបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះបានរៀនសូត្រច្រើន ទ្រទ្រង់ ចាំស្ទាត់ រត់មាត់ ជាក់ច្បាស់ក្នុងចិត្ត យល់ច្បាស់ដោយទិដ្ឋិ ក៏គិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯង ប្រព្រឹត្តទៅដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។ ចំណែកខាងលោកដ៏មានអាយុនេះប្រារព្ធ

នូវសេចក្ដីព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីបំពេញនូវកុសលធម៌ទាំងឡាយ ជាអ្នកមានកម្លាំង មានសេចក្ដីប្រឹងប្រែងមាំ មិនដាក់ធុរៈក្នុងធម៌ជាកុសល ក៏គិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯង ប្រព្រឹត្តទៅដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញុំាងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។ ចំណែកខាងលោកដ៏មានអាយុនេះ តាំងនៅក្នុងសង្ឃ មិនមែននិយាយពាក្យផ្ដេសផ្ដាស មិនមែននិយាយតិរច្ឆានកថា តែងសម្ដែងធម៌ដោយខ្លួនឯងផង អារាធនាអ្នកដទៃឲ្យសម្ដែងផង មិនមើលងាយនូវព្រះអរិយៈដែលស្ងប់ស្ងៀមផង ដោយគិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯង ប្រព្រឹត្តទៅដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញុំាងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។ ក៏ឯលោកដ៏មានអាយុនេះ ពិចារណាឃើញរឿយៗ នូវការចម្រើនឡើង និងការសាបសូន្យទៅក្នុងឧបាទានក្ខន្ធទាំងឡាយ ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ ការវិនាសទៅនៃរូបដូច្នេះ វេទនាដូច្នេះ សញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ ការវិនាសនៃវិញ្ញាណដូច្នេះ ក៏គិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯង ប្រព្រឹត្តទៅដើម្បីឲ្យគេស្រឡាញ់ ដើម្បី

ឲ្យគេគោរព ដើម្បីញុំាងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៨ យ៉ាង បច្ច័យទាំង ៨ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញាជាខាងដើម នៃមគ្គព្រហ្មចារ្យដែលខ្លួនមិនធ្លាប់បាន ដើម្បីជាកិរិយាភាពដ៏ធំទូលាយ ចម្រើន បរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។

# អដ្ឋកថា

## បញ្ញាសូត្រ

[ ២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ញាសូត្រទី ២ ដូចតទៅនេះ បទថា **អាទិព្រហ្មចរិយិកាយ** ប្រែថា ជាចំណែកខាងដើមនៃមគ្គព្រហ្មចរិយៈ ។ បទថា **បញ្ញាយ** បានដល់ វិបស្សនា គឺបញ្ញាដែលឃើញច្បាស់ ។ បទថា **គរុដ្ឋានិយំ** បុគ្គលគួរដល់ភាពជាគ្រូដែលជាបច្ច័យឲ្យកើតការគោរព ។ បទថា **តិព្វំ** ប្រែថា ក្រាស់ ។ បទថា **បរិបុច្ឆតិ** បានដល់ សួរដល់ចំណុចខាងដើមខាងចុងនៃអត្ថបាលី ។ បទថា **បរិបញ្ហតិ** បានដល់ តាំងបញ្ហា គឺនឹកថា អញនឹងសួរសេចក្តីនេះ និងសេចក្តីនេះ ។ បទថា **ទ្វយេន** ប្រែថា ២ យ៉ាង ។ បទថា **អនានាកថិកោ** គឺជាអ្នកមិនពោលរឿងផ្សេងៗ ។ បទថា **តិរច្ឆានកថិកោ** គឺមិនពោលតិរច្ឆានកថា មានបែបផ្សេងៗ ។ បទថា

**អរិយំ វា** **តុណ្ហីភាវំ** សេចក្តីថា ចតុត្ថជ្ឈាន ឈ្មោះថា អរិយតុណ្ហីភាព សូម្បីមនសិការកម្មដ្ឋានដ៏សេស ក៏ប្រើបាន ។ បទថា **ជានំ ជានាតិ** ប្រែថា ដឹងវត្ថុដែលគួរដឹង ។ បទថា **បស្សំ បស្សតិ** ប្រែថា ឃើញវត្ថុដែលគួរឃើញ ។ បទថា **បិយតាយ** ប្រែថា ដើម្បីឲ្យគេស្រឡាញ់ ។ បទថា **គរុតាយ** ប្រែថា ដើម្បីឲ្យគេគោរព ។ បទថា **ភាវនាយ** ប្រែថា ដើម្បីជាប្រយោជន៍ឲ្យគេសរសើរ ឬដើម្បីឲ្យគេលើកតម្កើង ។ បទថា **សាមញ្ញាយ** គឺដើម្បីជាប្រយោជន៍ដល់សមណធម៌ ។ បទថា **ឯកីភាវាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការមិនឆ្ងាយគ្នា ។l៚

អដ្ឋកថា បញ្ញាសូត្រទី ២ ចប់

# សុត្តន្តបិដក

## បឋមអប្បិយសូត្រទី ៣

[ ៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសរសើរចំពោះបុគ្គលមិនជាទីស្រឡាញ់ ១ តិះដៀល

នូវជនជាទីស្រឡាញ់ ១ ប្រាថ្នាលាភ ១ ប្រាថ្នាសក្ការៈ ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ ប្រាថ្នាលាមក ១ យល់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ នៃសព្រហ្មចារីបុគ្គលទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនសរសើរ នូវបុគ្គលមិនជាទីស្រឡាញ់ ១ មិនតិះដៀល នូវជនជាទីស្រឡាញ់ ១ មិនប្រាថ្នាលាភ ១ មិនប្រាថ្នាសក្ការៈ ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ ប្រាថ្នាតិច ១ មានសេចក្តីយល់ត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង ទើបជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ។

# អដ្ឋកថា

## បឋមអប្បិយសូត្រ

[ ៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអប្បិយសូត្រទី ៣ ដូចតទៅនេះ បទថា **អប្បិយបសំសី** ប្រែថា ជាបុគ្គលសរសើរ គឺពោលសរសើរបុគ្គល

មិនជាទីស្រឡាញ់ ។ បទថា **បិយគរហី** បានដល់ និន្ទា គឺតិះដៀលបុគ្គលជាទីស្រឡាញ់ ។l៙

## អដ្ឋកថា បឋមអប្បិយសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ទុតិយអប្បិយសូត្រទី ៤

[ ៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាលាភ ១ ប្រាថ្នាសក្ការៈ ១ ប្រាថ្នាមិនឲ្យគេមើលងាយ ១ មិនស្គាល់កាល ១ មិនស្គាល់ប្រមាណ ១ មានការងារមិនស្អាត ១ និយាយច្រើន ១ ជេរប្រទេចផ្តាសាទូវសព្រហ្មចារីបុគ្គលទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង រមែងមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត មិនជាទីគោរព មិនជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព គួរជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាល

ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រាថ្នាលាភ ១ មិនប្រាថ្នាសក្ការៈ ១ មិនមែនជាអ្នកប្រាថ្នាមិនឲ្យអ្នកដទៃមើលងាយ ១ ស្គាល់កាល ១ ស្គាល់ប្រមាណ ១ មានការងារស្អាត ១ មិននិយាយច្រើន ១ មិនជេរប្រទេចផ្តាសានូវសព្រហ្មចារីបុគ្គលទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង ទើបជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ នៃសព្រហ្មចារីបុគ្គលទាំងឡាយ ។

# អដ្ឋកថា

## ទុតិយអប្បិយសូត្រ

[ ៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអប្បិយសូត្រទី ៤ ដូចតទៅនេះ បទថា **អនវញ្ញត្តិកាមោ** សេចក្តីថា មិនបំណងមើលងាយថា ឱហ្ន៎ ! អ្នកដទៃមិនគប្បីមើលងាយអញ ។ បទថា **អកាលញ្ញូ** បានដល់ មិនដឹងកាល ឬមិនមែនកាល គឺពោលក្នុងកាលមិនមែនកាល ។ បទថា **អសុចិ** បានដល់ ដែលប្រកបដោយកាយកម្មមិនស្អាតជាដើម ។

**អដ្ឋកថាទុតិយអប្បិយសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមលោកធម្មសូត្រទី ៥

[ ៥ ] ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំងឡាយ ៨ យ៉ាងនេះ តែងជាប់តាមនូវសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ ដែរ ។ លោកធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺលាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះឯង តែងជាប់តាមសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ យ៉ាងនេះដែរ ។

ធម៌ទាំងឡាយនេះ គឺលាភ ១ អលាភ ១ យស ១
អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ជា
ធម៌មិនទៀង ក្នុងមនុស្សជាតិទាំងឡាយ ជាធម៌មិនឋិត
ថេរ មានសេចក្តីប្រែប្រួលជាធម្មតា ចំណែកបុគ្គលអ្នក
មានប្រាជ្ញា មានស្មារតី លុះដឹងនូវធម៌នេះហើយ រមែង
ពិចារណានូវធម៌ ដែលមានសេចក្តីប្រែប្រួលជាធម្មតា
ឥដ្ឋារម្មណ៍ទាំងឡាយ រមែងមិនញាំញីនូវចិត្តរបស់បុគ្គល
នោះបាន ទាំងអនិដ្ឋារម្មណ៍ ក៏មិនអាចប៉ះទង្គិចបាន
សេចក្តីត្រេកអរ ឬថា សេចក្តីថ្នាំងថ្នាក់ចិត្ត ក៏បុគ្គល
នោះបានកម្ចាត់បង់ហើយ ដល់នូវសេចក្តីវិនាស មិន
មានតទៅទៀតឡើយ បុគ្គលអ្នកដល់នូវត្រើយនៃភព

រមែងដឹងច្បាស់ ដោយប្រពៃ ព្រោះដឹងច្បាស់នូវបទ គឺព្រះនិព្វាន ដែលមិនមានធូលី គឺកិលេស មិនមានសេចក្តីសោក ។

# អដ្ឋកថា

## បឋមលោកធម្មសូត្រ

[ ៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមលោកធម្មសូត្រទី ៥ ដូចតទៅនេះ ឈ្មោះថា លោកធម៌ ព្រោះជាធម៌របស់លោក ។ ឈ្មោះថា បុគ្គលផុតចាកលោកធម៌ទាំងនេះមិនមាន សូម្បីព្រះពុទ្ធទាំងឡាយក៏នៅមាន ព្រោះហេតុនោះឯង ទើបត្រាស់ថា **លោកំ អនុបរិវត្តន្តិ** ការវិលទៅតាមលោក ។ សេចក្តីថា រមែងជាប់តាមទៅមិនលះបង់ បានដល់ មិនត្រឡប់ចាកលោក ។ បទថា **លោកោ ច អដ្ឋ លោកធម្មេ អនុបរិវត្តតិ** សេចក្តីថា លោកនេះតែងជាប់តាម មិនលះលោកធម៌ទាំងនោះ អធិប្បាយថា មិនត្រឡប់ចាកធម៌ទាំងនោះ ។

ក្នុងបទថា **លាភោ អលាភោ** គប្បីជ្រាបថា កាលលាភមកដល់ ការមិនមានលាភក៏មកដល់ដូចគ្នា ។ ក្នុងលោកធម៌ មានការវិនាសយសជាដើមក៏ន័យនេះដូចគ្នា ។ បទថា **អវេក្ខតិ វិបរិណាមធម្មេ** បានដល់ ពិចារណា

យ៉ាងនេះថា ធម៌ទាំងនេះ មានការប្រែប្រួលទៅជាធម្មតា ។ បទថា **វិទ្ធំសិតា** បានដល់ កម្ចាត់ហើយ គឺកម្ចាត់បង់ហើយ ។ បទថា **បទញ្ច ញត្វា** បាន ដល់ ដឹងបទ គឺព្រះនិព្វាន ។ បទថា **សម្មប្បជានាតិ ភវស្ស បារគូ** សេចក្តី ថា កាលដឹងបទ គឺព្រះនិព្វានហើយ រមែងដឹងដោយប្រពៃនូវភាពដែលខ្លួន ដល់ត្រើយនោះហើយ ក្នុងសូត្រនេះ ទ្រង់ត្រាស់វដ្ដៈផង វិវដ្ដៈផង ។ល។

**អដ្ឋកថា បឋមលោកធម្មសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយលោកធម្មសូត្រទី ៦

[ ៦ ] ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះ តែងជាប់ តាមសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ យ៉ាង ដែរ ។ លោកធម៌ ៨ យ៉ាង តើដូចម្ដេចខ្លះ ។ គឺលាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះឯង តែងជាប់តាមសត្វលោក ទាំងសត្វលោកក៏ វិលទៅតាមនូវលោកធម៌ទាំង ៨ យ៉ាងដែរ ។ ម្នាលភិក្ខុទាំងឡាយ លាភក្តី អលាភក្តី យសក្តី អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី តែងកើតឡើង ដល់បុថុជ្ជនអ្នកមិនចេះដឹង ម្នាលភិក្ខុទាំងឡាយ លាភក្តី អលាភក្តី យសក្តី

អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី តែងកើតឡើងដល់អរិយសាវក អ្នកចេះដឹងដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះក្នុងលោកធម៌ទាំងនោះមានសេចក្តីប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច មានហេតុផ្សេងគ្នាដូចម្តេច របស់អរិយសាវកអ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ មានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគជាទីពឹង របស់យើងទាំងឡាយស្រាប់ហើយ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនៃភាសិតនោះ ជាក់ច្បាស់ដល់ព្រះដ៏មានព្រះភាគដោយល្អស្រាប់ហើយ ភិក្ខុទាំងឡាយបានស្តាប់ ( ធម៌ ) របស់ព្រះដ៏មានព្រះភាគនឹងចងចាំទុកបាន ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយប្រុងស្តាប់ធ្វើទុកក្នុងចិត្ត ដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ លាភតែងកើតឡើងដល់បុថុជ្ជនអ្នកមិនចេះដឹង បុថុជ្ជននោះមិនពិចារណា មិនដឹងច្បាស់តាមពិតដូច្នេះថា លាភនេះកើតឡើងដល់អាត្មាអញហើយ លាភនោះឯងមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា អលាភរមែងកើតឡើង យសរមែងកើតឡើង អយសរមែងកើតឡើង និន្ទារមែងកើតឡើង បសំសារមែងកើតឡើង សុខរមែងកើតឡើង ទុក្ខរមែងកើតឡើង ( ដល់បុថុជ្ជនអ្នកមិនចេះដឹង ) បុថុជ្ជននោះ មិនពិចារណា មិនដឹងច្បាស់តាមពិតដូច្នេះថា ទុក្ខនេះ កើតឡើងដល់អាត្មាអញ

ហើយ ទុក្ខនោះឯងមិនទៀង ជារបស់អត់ធន់បានដោយក្រ មានសេចក្ដីប្រែប្រួលជាធម្មតា ។ លាភក្ដីរមែងគ្របសង្កត់ចិត្តរបស់បុថុជ្ជននោះ អលាភក្ដី រមែងគ្របសង្កត់ចិត្ត យសក្ដី រមែងគ្របសង្កត់ចិត្ត អយសក្ដី រមែងគ្របសង្កត់ចិត្ត និន្ទាក្ដី រមែងគ្របសង្កត់ចិត្ត បសំសាក្ដី រមែងគ្របសង្កត់ចិត្ត សុខក្ដី រមែងគ្របសង្កត់ចិត្ត ទុក្ខក្ដី រមែងគ្របសង្កត់ចិត្ត ។ បុថុជ្ជននោះ តែងត្រេកអរនឹងលាភដែលកើតឡើង តូចចិត្តព្រោះអលាភ ត្រេកអរនឹងយសដែលកើតឡើង តូចចិត្តព្រោះអយស ត្រេកអរនឹងបសំសាដែលកើតឡើង តូចចិត្តព្រោះនិន្ទា ត្រេកអរនឹងសុខដែលកើតឡើង តូចចិត្តព្រោះទុក្ខ ។ បុថុជ្ជននោះ ប្រកបនូវសេចក្ដីត្រេកអរ និងសេចក្ដីតូចចិត្តយ៉ាងនេះហើយ រមែងមិនរួចចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស តថាគតពោលថា មិនរួចចាកវដ្ដទុក្ខឡើយ ។ ម្នាលភិក្ខុទាំងឡាយ លាភកើតឡើងដល់អរិយសាវកអ្នកចេះដឹង អរិយសាវកនោះពិចារណាដឹងច្បាស់តាមពិតដូច្នេះថា លាភនេះកើតឡើងដល់អាត្មាអញហើយ លាភនោះឯងមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា អលាភកើតឡើង យសកើតឡើង អយសកើតឡើង និន្ទាកើតឡើង បសំសាកើតឡើង សុខកើតឡើង ទុក្ខកើតឡើង អរិយសាវកនោះពិចារណាដឹងច្បាស់តាមពិតដូច្នេះថា ទុក្ខកើតឡើងដល់អាត្មាអញហើយ ទុក្ខនោះឯង ក៏មិនទៀង អត់ធន់បានដោយក្រ មានសេចក្ដីប្រែប្រួលជាធម្មតា ។ អរិយសាវកដឹងច្បាស់តាមពិតថា នេះជាទុក្ខ ទុក្ខនោះឯង ក៏មិនទៀង អត់ធន់

បានដោយក្រ មានសេចក្ដីប្រែប្រួលជាធម្មតា លាភក្ដី មិនគ្របសង្កត់ចិត្តរបស់អរិយសាវកនោះ អលាភក្ដី ក៏មិនគ្របសង្កត់ចិត្ត យសក្ដី ក៏មិនគ្របសង្កត់ចិត្ត អយសក្ដី ក៏មិនគ្របសង្កត់ចិត្ត និន្ទាក្ដី ក៏មិនគ្របសង្កត់ចិត្ត បសំសាក្ដី ក៏មិនគ្របសង្កត់ចិត្ត សុខក្ដី ក៏មិនគ្របសង្កត់ចិត្ត ទុក្ខក្ដី ក៏មិនគ្របសង្កត់ចិត្តបាន ។ អរិយសាវកនោះ មិនត្រេកអរនឹងលាភដែលកើតឡើង មិនអាក់អន់ព្រោះអលាភ មិនត្រេកអរនឹងយសដែលកើតឡើង មិនអាក់អន់ព្រោះអយស មិនត្រេកអរនឹងបសំសាដែលកើតឡើង មិនអាក់អន់ព្រោះនិន្ទា មិនត្រេអរនឹងសុខដែលកើតឡើង មិនអាក់អន់ព្រោះសេចក្ដីទុក្ខ ។ អរិយសាវកនោះ លះបង់សេចក្ដីត្រេកអរនឹងសេចក្ដីអាក់អន់យ៉ាងនេះហើយ រមែងរួចចាកជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស តថាគតពោលថា រួចស្រឡះចាកវដ្ដទុក្ខ ម្នាលភិក្ខុទាំងឡាយ នេះឯងជាសេចក្ដីប្លែកគ្នា នេះជាអធិប្បាយ នេះជាហេតុផ្សេងៗ គ្នា នៃអរិយសាវកអ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង ។

ធម៌ទាំងឡាយនេះ គឺលាភ ១ អលាភ ១ យស ១
អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ជា
ធម៌មិនទៀងក្នុងមនុស្សជាតិទាំងឡាយ ជាធម៌មិនឋិតថេរ
មានសេចក្ដីប្រែប្រួលជាធម្មតា ចំណែកបុគ្គលអ្នកមាន
ប្រាជ្ញា មានស្មារតី លុះដឹងនូវធម៌ទាំងនេះហើយ រមែង

ពិចារណាឃើញច្បាស់នូវធម៌ ដែលមានសេចក្តីប្រែប្រួលជាធម្មតា ឥដ្ឋារម្មណ៍ រមែងមិនញាំញីចិត្តរបស់បុគ្គលនោះបាន ទាំងអនិដ្ឋារម្មណ៍ ក៏មិនអាចប៉ះទង្គិចបានសេចក្តីត្រេកអរ ឬថា សេចក្តីថ្នាំងថ្នាក់ ក៏បុគ្គលនោះបានកម្ចាត់បង់ហើយ ដល់នូវសេចក្តីវិនាស មិនមានតទៅទៀតឡើយ បុគ្គលអ្នកដល់នូវត្រើយនៃភព រមែងដឹងច្បាស់ដោយប្រពៃ ព្រោះដឹងច្បាស់នូវបទ គឺព្រះនិព្វានដែលមិនមានធូលី គឺកិលេស មិនមានសេចក្តីសោក ។

# អដ្ឋកថា

## ទុតិយលោកធម្មសូត្រ

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយលោកធម្មសូត្រទី ៦ ដូចតទៅនេះ បទថា **កោ វិសេសោ** បានដល់ អ្វីជាហេតុពិសេស ។ បទថា **កោ អធិប្បាយសោ** បានដល់ អ្វីជាការប្រកបក្រៃលែង ។ បទថា **បរិយាទាយ** បានដល់ ប្រកាន់ គឺតាំងទុកដោយជុំវិញ ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់វដ្តៈផង និងវិវដ្តៈផង ៕៚

# សុត្តន្តបិដក

## ទេវទត្តសូត្រទី ៧

[ ៧ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ កាលដែលទេវទត្តភិក្ខុ ចៀសចេញមិនយូរប៉ុន្មាន ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ប្រារព្ធនូវទេវទត្តភិក្ខុ ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិរបស់បុគ្គលដទៃសព្វៗ កាល ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិរបស់បុគ្គលដទៃសព្វៗ កាល ជាការប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្មទាំងឡាយ ៨ ប្រការគ្របសង្កត់ហើយ មានចិត្តត្រូវអសទ្ធម្មរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ អសទ្ធម្ម ៨ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវលាភគ្របសង្កត់ហើយ មានចិត្តដែលលាភរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ត្រូវអលាភ ម្នាលភិក្ខុទាំង-ឡាយ ត្រូវយស ម្នាលភិក្ខុទាំងឡាយ ត្រូវអយស ម្នាលភិក្ខុទាំងឡាយ ត្រូវសក្ការៈ ម្នាលភិក្ខុទាំងឡាយ ត្រូវអសក្ការៈ ម្នាលភិក្ខុទាំងឡាយ ត្រូវសេចក្តីប្រាថ្នាដ៏លាមក ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវបាបមិត្តគ្របសង្កត់ហើយ

មានចិត្តត្រូវបាបមិត្តរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្មទាំង ៨ ប្រការនេះឯងគ្របសង្កត់ មានចិត្តត្រូវអសទ្ធម្មរួបរឹត ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ ញាំញីនូវលាភដែលកើតឡើងហើយ ជាការប្រពៃ នូវអលាភដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមកដែលកើតឡើងហើយ គ្របសង្កត់ ញាំញីនូវបាបមិត្តដែលកើតឡើងហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ ញាំញីនូវលាភ ដែលកើតឡើងហើយ តើព្រោះអាស្រ័យនូវអំណាចប្រយោជន៍ដូចម្តេច ។បេ។ ម្នាលភិក្ខុទាំង-ឡាយ ព្រោះថា អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ក្រោលក្រាលកើតឡើងដល់ភិក្ខុនោះ ព្រោះមិនបានគ្របសង្កត់នូវលាភ ដែលកើតឡើងហើយ អាសវៈទាំងឡាយនោះ ជាសភាវៈចង្អៀតចង្អល់ក្រោលក្រាល រមែងមិនមានដល់ភិក្ខុនោះយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ព្រោះថា អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ ក្រោលក្រាល កើតឡើងដល់ភិក្ខុនោះ កាលមិនបានគ្របសង្កត់នូវអលាភ ដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវ

អសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមក ដែលកើតឡើងហើយ នូវបាបមិត្តដែលកើតឡើងហើយ អាសវៈទាំងឡាយនោះ ជាសភាវៈចង្អៀតចង្អល់ ពេលពល រមែងមិនមានដល់ភិក្ខុ កាលគ្របសង្កត់នូវបាបមិត្តដែលកើតឡើងហើយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ញាំញីនូវលាភ ដែលកើតឡើងហើយ នូវអលាភដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមកដែលកើតឡើងហើយ គ្របសង្កត់ញាំញីនូវបាបមិត្ត ដែលកើតឡើងហើយព្រោះអាស្រ័យនូវអំណាចប្រយោជន៍នេះឯង ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយគួរជាអ្នកគ្របសង្កត់ញាំញីនូវលាភដែលកើតឡើង យើងទាំងឡាយគួរជាអ្នកគ្របសង្កត់ ញាំញីនូវអលាភដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមក ដែលកើតឡើងហើយ នូវបាបមិត្តដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះឯង ។

# អដ្ឋកថា

## ទេវទត្តសូត្រ

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទេវទត្តសូត្រទី ៧ ដូចតទៅនេះ បទថា **អចិរប្បក្កន្តេ** បានដល់ កាលទេវទត្តបំបែកសង្ឃហើយ ចេញទៅមិនយូរ ។ បទថា **អារព្ភ** បានដល់ អាស្រ័យ ឧទ្ទិស ប្រាថ្នា ។

បទថា **អត្តវិបត្តឹ** បានដល់ ការវិបត្តិ គឺអាការដែលវិបត្តិរបស់ខ្លួន ។ ក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា **អភិភុយ្យ** បានដល់ គ្របសង្កត់ ញាំញី ។l៚

**អដ្ឋកថា ទេវទត្តសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ឧត្តរសូត្រទី ៨

[ ៨ ] សម័យមួយ ព្រះឧត្តរដ៏មានអាយុគង់ក្នុងវិហារឈ្មោះវដ្តជាលិកា ទៀបភ្នំឈ្មោះសង្ខេយ្យក: ជិតស្រុកមហិសវត្ថុ ។ ក្នុងទីនោះ ព្រះឧត្តរដ៏មានអាយុហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិរបស់បុគ្គលដទៃសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោ

ទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិរបស់អ្នកដទៃសព្វៗ កាល ជាការប្រពៃ ។

សម័យនោះឯង មហារាជឈ្មោះ វេស្សវ័ណចេញអំពីឧត្តរទិសទៅកាន់ទក្សិណទិស ដោយកិច្ចនីមួយ ។ មហារាជឈ្មោះវេស្សវ័ណ បានឮថេរវាចានៃព្រះឧត្តរដ៏មានអាយុ កំពុងសំដែងធម៌ដល់ភិក្ខុទាំងឡាយ ក្នុងវិហារឈ្មោះវដ្ដជាលិកា ទៀបភ្នំសង្ខេយ្យកៈ ជិតស្រុកមហិសវត្ថុ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណា នូវវិបត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណា នូវវិបត្តិរបស់អ្នកដទៃសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិរបស់អ្នកដទៃសព្វៗ កាល ជាការប្រពៃ ។ លំដាប់នោះ មហារាជឈ្មោះវេស្សវ័ណ ក៏បាត់អំពីវដ្ដជាលិកាវិហារ ទៀបភ្នំសង្ខេយ្យកៈ ជិតស្រុកមហិសវត្ថុ ទៅប្រាកដក្នុងតាវត្តិង្សទេវលោក ដូចបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ យ៉ាងនោះឯង ។ លំដាប់នោះឯង មហារាជវេស្សវ័ណ ចូលទៅគាល់ព្រះឥន្ទ្រជាធំ ជាងពួកទេវតា លុះចូលទៅដល់ហើយ បានទូលពាក្យនេះ នឹងព្រះឥន្ទ្រជាធំជាងពួកទេវតា បពិត្រលោកជាម្ចាស់យើង សូមទ្រង់ជ្រាប ព្រះឧត្តរដ៏មានអាយុនុ៎ះ សំដែងធម៌ដល់ភិក្ខុទាំង

ឡាយ ក្នុងវត្តជាលិកាវិហារ ទៀបក្មុំសង្ខេយ្យកៈ ជិតស្រុកមហិសវត្ថុយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិរបស់ខ្លួនសព្វៗកាល ជាការប្រពៃ ។បេ។ ជាអ្នកពិចារណានូវសម្បត្តិរបស់អ្នកដទៃ ។

គ្រានោះ សក្កៈជាធំជាងពួកទេវតា ក៏បាត់អំពីទេវលោក ទៅប្រាកដក្នុងទីចំពោះមុខព្រះឧត្តរដ៏មានអាយុ ក្នុងវត្តជាលិកាវិហារ ទៀបក្មុំសង្ខេយ្យកៈជិតស្រុកមហិសវត្ថុ ដូចបុរសមានកម្លាំង លាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញយ៉ាងនោះឯង ។ លំដាប់នោះ សក្កៈជាធំជាងពួកទេវតា ចូលទៅរកព្រះឧត្តរដ៏មានអាយុ ត្រង់កន្លែងដែលលោកគង់នៅ លុះចូលទៅហើយ ថ្វាយបង្គំព្រះឧត្តរដ៏មានអាយុ ហើយឋិតនៅក្នុងទីសមគួរ ។ លុះសក្កៈជាធំជាងពួកទេវតា ឋិតនៅក្នុងទីសមគួរហើយ បានតំណាលពាក្យនេះនឹងព្រះឧត្តរដ៏មានអាយុដូច្នេះថា បានឮថា ព្រះឧត្តរដ៏មានអាយុ សម្តែងធម៌ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិនៃខ្លួនជាការប្រពៃ ។បេ។ ជាអ្នកពិចារណានូវសម្បត្តិរបស់អ្នកដទៃ ពិតមែនឬ ។ ថ្វាយព្រះពរ ទេវានមិន្ទ ។ បពិត្រលោកដ៏ចម្រើន ចុះការសម្តែងតាមសេចក្តីយល់របស់ខ្លួនព្រះឧត្តរដ៏មានអាយុឬ ឬក៏សម្តែងតាមព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ថ្វាយព្រះពរទេវានមិន្ទ បើដូច្នោះ អាត្មាភាពនឹងឧបមាថ្វាយមហាបពិត្រ ពួកវិញ្ញូបុរសក្នុងលោកនេះ គង់ដឹងនូវសេចក្តីអធិប្បាយនៃភាសិតដោយសេចក្តីឧបមា ថ្វាយព្រះពរ ទេវានមិន្ទ ដូចជាគំនរ

ស្រូវដ៏ធំ ក្នុងទីជិតស្រុកក្តី និគមក្តី ពួកមហាជននាំយកស្រូវអំពីគំនរនោះ ដោយអង្រែកទាំងឡាយខ្លះ ដោយល្អីទាំងឡាយខ្លះ ដោយថ្នក់ទាំងឡាយខ្លះ ដោយកម្បង់ដៃទាំងឡាយខ្លះ ថ្វាយព្រះពរ ទេវានមិន្ទ ពួកមហាជនណា ដែលមិនបានចូលទៅ ( នឹងគេ ) គប្បីសួរយ៉ាងនេះថា អ្នកទាំងឡាយ នាំយកស្រូវនេះអំពីទីណា ។ ថ្វាយព្រះពរ ទេវានមិន្ទ ពួកមហាជននោះ កាលនឹងឆ្លើយប្រាប់ គប្បីឆ្លើយប្រាប់តាមទំនងដូចម្តេច ។ បពិត្រលោកដ៏ចម្រើន ពួកមហាជននោះ កាលឆ្លើយប្រាប់ គប្បីឆ្លើយប្រាប់តាមទំនងថា យើងទាំងឡាយនាំមកអំពីគំនរស្រូវធំឯណោះដូច្នេះ ។ ថ្វាយព្រះពរ ទេវានមិន្ទ ពាក្យឯណានីមួយជាសុភាសិត សុភាសិតទាំងអស់នោះ ជាព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ យើងទាំងឡាយនាំចេញមកអំពីព្រះពុទ្ធដីកានោះ ទើបសម្តែងដូចជាស្រូវយ៉ាងនោះដែរ ។ បពិត្រលោកដ៏ចម្រើន អស្ចារ្យណាស់ បពិត្រលោកដ៏ចម្រើន ចម្លែកណាស់ ពាក្យនេះ ព្រះឧត្តរដ៏មានអាយុពោលហើយដោយប្រពៃ ( ព្រោះ ) ពាក្យឯណានីមួយជាសុភាសិត ពាក្យទាំងអស់នោះ ជាព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ យើងទាំងឡាយក៏ពោលនូវស្រូវប្រៀបធៀបនឹងព្រះពុទ្ធដីកានោះដែរ បពិត្រព្រះឧត្តរដ៏ចម្រើន សេចក្តីនេះយ៉ាងនេះ សម័យមួយ ព្រះដ៏មានព្រះភាគគង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ កាលដែលព្រះទេវទត្ត ចៀសចេញទៅមិនយូរប៉ុន្មាន ក្នុងទីនោះឯងព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធនូវទេវទត្ត ត្រាស់នឹង

ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិនៃខ្លួន ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិរបស់អ្នកដទៃ នូវសម្បត្តិរបស់ខ្លួន នូវសម្បត្តិរបស់អ្នកដទៃ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្មទាំង ៨ ប្រការគ្របសង្កត់ហើយ មានចិត្តត្រូវអសទ្ធម្មរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ អសទ្ធម្ម ៨ ប្រការ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវលាភគ្របសង្កត់ហើយ មានចិត្តត្រូវលាភរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ត្រូវអលាភ ម្នាលភិក្ខុទាំងឡាយ ត្រូវយស ម្នាលភិក្ខុទាំងឡាយ ត្រូវអយស ម្នាលភិក្ខុទាំងឡាយ ត្រូវសក្ការៈ ម្នាលភិក្ខុទាំងឡាយ ត្រូវអសក្ការៈ ម្នាលភិក្ខុទាំងឡាយ ដែលត្រូវសេចក្ដីប្រាថ្នាលាមក ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវបាបមិត្តគ្របសង្កត់ហើយ មានចិត្តដែលត្រូវបាបមិត្តរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្មទាំងឡាយ ៨ ប្រការនេះឯង គ្របសង្កត់ហើយ មានចិត្តត្រូវអសទ្ធម្មរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ ញាំញីនូវលាភ ដែលកើតឡើងហើយ ជាការប្រពៃ នូវអលាភដែលកើតឡើង

ហើយ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមកដែលកើតឡើងហើយ គ្របសង្កត់ញាំញីនូវបាបមិត្ត ដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ ញាំញីនូវលាភ ដែលកើតឡើងហើយ គ្របសង្កត់ ញាំញីនូវអលាភ ដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមកដែលកើតឡើងហើយ តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ រោលរាល កើតឡើងដល់ភិក្ខុនោះ កាលមិនបានគ្របសង្កត់នូវលាភដែលកើតឡើងហើយ អាសវៈទាំងឡាយនោះ ជាសភាវៈចង្អៀតចង្អល់ រោលរាល រមែងមិនមានដល់ភិក្ខុនោះ កាលគ្របសង្កត់នូវលាភ ដែលកើតឡើងហើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ រោលរាល គប្បីកើតឡើងដល់ភិក្ខុនោះ កាលមិនបានគ្របសង្កត់នូវអលាភដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមកដែលកើតឡើងហើយ នូវបាបមិត្តដែលកើតឡើងហើយ អាសវៈទាំងឡាយនោះ ជា

សភាវៈចង្អៀតចង្អល់ ពេលពល រមែងមិនមានដល់ភិក្ខុនោះ កាលគ្រប សង្កត់នូវបាបមិត្តដែលកើតឡើងបានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ គ្របសង្កត់ ញាំញីនូវលាភដែលកើតឡើងហើយ គ្របសង្កត់ ញាំញីនូវ អលាភដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយសដែល កើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈ ដែលកើត ឡើងហើយ នូវសេចក្ដីប្រាថ្នាលាមកដែលកើតឡើងហើយ នូវបាបមិត្តដែល កើតឡើងហើយ ព្រោះអាស្រ័យនូវអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុ ទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គប្បីសិក្សាយ៉ាងនេះថា យើង ទាំងឡាយ គួរជាអ្នកគ្របសង្កត់ ញាំញីនូវលាភដែលកើតឡើងហើយ យើង ទាំងឡាយ គួរជាអ្នកគ្របសង្កត់ ញាំញីនូវអលាភដែលកើតឡើងហើយ នូវ យសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈ ដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្ដីប្រាថ្នា លាមកដែលកើតឡើងហើយ នូវបាបមិត្តដែលកើតឡើងហើយ ។ ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះឯង ។ បពិត្រព្រះឧត្តមដ៏ ចម្រើន បណ្ដាបរិសទ្យទាំង ៤ ពួក គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ធម្មបរិយាយនេះ មិនទាន់តាំងនៅក្នុងបរិសទ្យណាទេ បពិត្រលោកដ៏ចម្រើន សូមព្រះឧត្តមដ៏មានអាយុ កាន់យកនូវធម្មបរិយាយនេះ បពិត្រលោកដ៏ ចម្រើន សូមព្រះឧត្តមដ៏មានអាយុ រៀនយកនូវធម្មបរិយាយនេះ បពិត្រលោក

*ដ៏ចម្រើន សូមព្រះឧត្តរដ៏មានអាយុ ទទួលទូវធម្មបរិយាយនេះ បពិត្រលោក ដ៏ចម្រើន ធម្មបរិយាយនេះ ប្រកបដោយប្រយោជន៍ជាខាងដើមនៃមគ្គព្រហ្មចរិយធម៌ ។*

# អដ្ឋកថា

## ឧត្តរសូត្រ

*[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧត្តរសូត្រទី ៨ ដូចតទៅនេះ បទថា* **វដ្ដជាលិកាយំ** *គឺក្នុងវិហារដែលមានឈ្មោះយ៉ាងនោះ ។ បានឮថា វិហារនោះ មានឈ្មោះថា វដ្ដជាលិកា ព្រោះតាំងនៅក្នុងព្រៃវដ្ដវ័ន ។ បទថា* **ចាតុរហោសិ** *សេចក្ដីថា ជាអ្នកមកប្រាកដដោយតាំងចិត្តថា នឹងប្រាប់រឿងនេះដល់ស្ដេចទេវរាជ ។ បទថា* **អាទិព្រហ្មចរិយកោ** *ប្រែថា ជាខាងដើមនៃព្រហ្មចរិយៈទាំងមូល ដែលជាទីសង្គ្រោះចូលនូវសិក្ខា ៣ ។*

**អដ្ឋកថាឧត្តរសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ឆដ្ឋសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ អ្នកផងកាលបើពោលតាមត្រឹមត្រូវ គប្បីពោលនូវនន្ទភិក្ខុថា ជាកុលបុត្តដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកផងកាលបើពោលតាមត្រឹមត្រូវ គប្បីពោលនូវនន្ទភិក្ខុថា ជាអ្នកមានកម្លាំងកាយដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកផងកាលបើពោលតាមត្រឹមត្រូវ គប្បីពោលនូវនន្ទភិក្ខុថា ជាអ្នកគួរនាំមកនូវសេចក្តីជ្រះថ្លាដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកផងកាលបើពោលតាមត្រឹមត្រូវ គប្បីពោលនូវនន្ទភិក្ខុថា ជាអ្នកមានរាគៈដ៏ក្លៀវក្លាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ចាំបាច់ពោលទៅថ្វីក្នុងទីដទៃ ថានន្ទភិក្ខុគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ នូវការភ្ញាក់រឭក ប្រកបដោយសតិ និងសម្បជញ្ញៈ ទើបនន្ទភិក្ខុអាចដើម្បីប្រព្រឹត្តនូវព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធបាន ។

ម្នាលភិក្ខុទាំងឡាយ ហេតុដែលនន្ទភិក្ខុមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយនោះយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បើនន្ទភិក្ខុរមិលមើលទៅទិសខាងកើត លុះតែប្រមូលនូវហេតុទាំងអស់ ដោយចិត្ត ទើបនន្ទភិក្ខុរមិលមើលនូវទិសខាងកើត ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្សនឹងមិនជាប់តាមអាត្មាអញ ដែលកំពុងរមិលមើលទិសខាងកើតយ៉ាងនេះ ។ ព្រោះហេតុនោះ ក្នុងសាសនានេះ នន្ទភិក្ខុទើបឈ្មោះថា ជាអ្នកមានសេចក្តីដឹងខ្លួន ក្នុងការគ្រប់គ្រងទ្វារនោះ ។ ម្នាលភិក្ខុទាំងឡាយ បើនន្ទភិក្ខុ

រមិលមើលទិសខាងលិច រមិលមើលទិសខាងជើង រមិលមើលទិសខាងត្បូង ងើយមើលទៅទិសខាងលើ ឱនមើលទិសខាងក្រោម ងាកមើលទៅទិសជាលំដាប់ លុះតែប្រមូលនូវហេតុទាំងអស់ដោយចិត្ត ទើបនទួភិក្ខុងាកមើលនូវទិសជាលំដាប់ ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្សនឹងមិនជាប់តាមអាត្មាអញ ដែលកំពុងងាកមើលទិសជាលំដាប់ ។ ព្រោះហេតុនោះ ក្នុងសាសនានេះ នទួភិក្ខុទើបឈ្មោះថា ជាអ្នកមានសេចក្តីដឹងខ្លួន ក្នុងការគ្រប់គ្រងទ្វារយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលនទួភិក្ខុមានឥន្ទ្រិយគ្រប់គ្រងហើយយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ហេតុដែលនទួភិក្ខុស្គាល់ប្រមាណក្នុងភោជននោះយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ នទួភិក្ខុពិចារណាដោយឧបាយហើយ ទើបបរិភោគនូវអាហារ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីតាក់តែងរាងកាយ មិនមែនដើម្បីផូរផង់ គ្រាន់តែឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យ អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ផង ញ៉ាំងវេទនាថ្មី មិនឲ្យកើតឡើងបានផង ការប្រព្រឹត្តទៅនៃឥរិយាបថក្តី ការមិនមានទោសក្តី ការនៅសប្បាយក្តី នឹងមានដល់អាត្មាអញ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលនទួភិក្ខុស្គាល់ប្រមាណក្នុងភោជន យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ហេតុដែលនទួភិក្ខុប្រកបរឿយៗ ក្នុងការភ្ញាក់រឭក

នោះយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ឧទុភិក្ខុជម្រះចិត្តចាក អាវរណីយធម៌ ដោយការចង្ក្រម ដោយការអង្គុយអស់មួយថ្ងៃ ជម្រះចិត្ត ចាកអាវរណីយធម៌ ដោយការចង្ក្រម ដោយការអង្គុយអស់បឋមយាមនៃរាត្រី សម្រេចនូវសីហសេយ្យ ដោយផ្អៀងទៅខាងស្តាំ តម្រួតជើង ដោយជើង ជាអ្នកមានសតិសម្បជញ្ញៈ ធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា អស់មជ្ឈិមយាមនៃរាត្រី ហើយក្រោកឡើង ជម្រះចិត្តចាកអាវរណីយធម៌ ដោយការចង្ក្រម ដោយការអង្គុយ អស់បច្ឆិមយាមនៃរាត្រី ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែល ឧទុភិក្ខុប្រកបរឿយៗ ក្នុងការភ្ញាក់រឭក យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ហេតុដែលឧទុភិក្ខុ មានសតិសម្បជញ្ញៈនោះយ៉ាង នេះ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ វេទនាកើតឡើងដល់ឧទុភិក្ខុ ក៏ដឹងច្បាស់ វេទនាប្រាកដឡើង ក៏ដឹងច្បាស់ ដល់នូវសេចក្តីវិនាស ក៏ដឹងច្បាស់ សញ្ញាដែលកើតឡើង ក៏ដឹងច្បាស់ សញ្ញាប្រាកដឡើង ក៏ដឹងច្បាស់ សញ្ញា ដល់នូវសេចក្តីវិនាស ក៏ដឹងច្បាស់ វិតក្កដែលកើតឡើង ក៏ដឹងច្បាស់ វិតក្ក ដែលប្រាកដឡើង ក៏ដឹងច្បាស់ វិតក្កដែលដល់នូវសេចក្តីវិនាស ក៏ដឹងច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលឧទុភិក្ខុមានសតិសម្បជញ្ញៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចាំបាច់ពោលទៅថ្វីក្នុងទីដទៃថា ឧទុភិក្ខុគ្រប់គ្រងទ្វារក្នុង ឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ នូវការភ្ញាក់រឭក ប្រកបដោយសតិសម្បជញ្ញៈ ទើបឧទុភិក្ខុអាចប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌

បរិសុទ្ធបាន ។

# អដ្ឋកថា

## នន្ទសូត្រ

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនន្ទសូត្រទី ៩ ដូចតទៅនេះ បទថា **កុលបុត្តោ** បានដល់ កុលបុត្រដោយកំណើត ។ បទថា **ពលវា** ប្រែថា សម្បូរដោយកម្លាំង ។ បទថា **បាសាទិកោ** បានដល់ ធ្វើឲ្យកើតនូវសេចក្តីជ្រះថ្លាដោយរូបសម្បត្តិ ។ បទថា **តិព្វរាគោ** ប្រែថា ជាអ្នកក្រាស់ដោយរាគៈ ។ ក្នុងបទថា **កិមញ្ញត្រ** ជាដើម មានអធិប្បាយដូចតទៅនេះ ប្រយោជន៍អ្វីដោយហេតុដទៃ ដែលតថាគតនឹងពោល នន្ទនេះ គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងភ្ញាក់រឭក ប្រកបដោយសតិសម្បជញ្ញៈ ដែលនន្ទអាចប្រព្រឹត្តព្រហ្មចរិយៈឲ្យបរិសុទ្ធបរិបូណ៌ បើនន្ទមិនប្រកបដោយហេតុនេះសោត លោកក៏មិនអាច ។ បទថា **ឥតិហ តត្រ** ប្រែថា ក្នុងសេចក្តីនោះយ៉ាងនេះ ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់ចំពោះវដ្តៈតែម្យ៉ាង ៗ។

**អដ្ឋកថានន្ទសូត្រទី ៩ ចប់**

# សុត្តន្តបិដក

##ការណ្ឌវសូត្រទី ១០

[ ១០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្បែរឆ្នេរស្រះបោក្ខរណី ឈ្មោះគគ្គរា ជិតក្រុងចម្បា ។ សម័យនោះឯង ភិក្ខុទាំងឡាយចោទភិក្ខុផងគ្នា ដោយអាបត្តិ ។ ភិក្ខុនោះ កាលត្រូវពួកភិក្ខុផងគ្នា ចោទដោយអាបត្តិ ក៏អាង ពាក្យដទៃដោយពាក្យដទៃ បដិសេធពាក្យទៅខាងក្រៅ ធ្វើសេចក្ដីក្រោធផង ទោសផង សេចក្ដីមិនពេញចិត្តផង ឲ្យកើតប្រាកដ ។ លំដាប់នោះ ព្រះដ៏មាន ព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបណ្ដេញនូវបុគ្គលនេះចេញ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបណ្ដេញ នូវបុគ្គលនេះចេញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ( នោះ ) ជាបុគ្គលគួរ បណ្ដេញចេញ បុគ្គលដូចជាកូននៃបុគ្គលដទៃ រមែងបៀតបៀនបានទេដឹង ម្នាលភិក្ខុទាំងឡាយ ការឈានទៅមុខ និងថយក្រោយ ការមើលទូទៅ មើល ផ្សេងៗ ការបត់អវយវៈចូល ការលាអវយវៈចេញ ការទ្រទ្រង់នូវសង្ឃាដិ បាត្រ ចីវរ របស់បុគ្គលពួកខ្លះ ក្នុងសាសនានេះ ប្រាកដដូច្នោះ ដូចដំណើរ នៃពួកភិក្ខុដ៏ចម្រើនដទៃ ពួកភិក្ខុមិនឃើញនូវអាបត្តិរបស់ភិក្ខុនោះ លុះកាល ណាពួកភិក្ខុឃើញនូវអាបត្តិ ភិក្ខុនោះ ក៏ដឹងនូវភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះ ជាអ្នកប្រទូស្តដល់សមណៈ ដូចជាសំដី ឬអង្កាមក្នុងសមណៈ ជាសំរាមក្នុង សមណៈ លុះពួកភិក្ខុដឹងច្បាស់នូវភិក្ខុនោះ ដូច្នេះហើយ ក៏ធ្វើឲ្យវិនាសទៅ ខាងក្រៅ ( ជំនុំសង្ឃ ) ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា អ្នកកុំ

ប្រទូស្តភិក្ខុល្អទាំងឡាយឯទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងស្មៅ ដែលបន្ទូចស្រូវ ជាសំដីក្នុងស្រូវ ជាសំរាមដល់ស្រូវ ផុសឡើងក្នុងស្រែនៃស្រូវដ៏ល្អ គល់ស្មៅនោះក៏ដូច្នោះដែរ ដូចគល់នៃស្រូវដ៏ចម្រើនដទៃ ដើមក៏ដូច្នោះដែរ ដូចជាដើមនៃស្រូវដ៏ចម្រើនដទៃ ស្លឹកក៏ដូច្នោះដែរ ដូចជាស្លឹកនៃស្រូវដ៏ចម្រើនដទៃ កំណត់ត្រឹមក្ឋរនៃស្មៅនោះមិនទាន់កើត លុះកាលណាក្ឋរនៃស្មៅនោះកើតឡើង អ្នកផងទើបដឹងស្មៅនោះយ៉ាងនេះថា នេះជាស្មៅបន្ទូចស្រូវ ជាសំដីក្នុងស្រូវ ជាសំរាមដល់ស្រូវ លុះអ្នកផងដឹងច្បាស់នូវស្មៅនោះយ៉ាងនេះហើយ ក៏ដករម្លើងទាំងឫសចោលទៅខាងក្រៅនៃស្រែស្រូវ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យបន្ទូចស្រូវទាំងឡាយឯទៀតបានឡើយ សេចក្តីនេះយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ការឈានទៅមុខ និងការថយក្រោយ ការមើលទូទៅ ការមើលផ្សេងៗ ការបត់អវយវៈចូល ការលាអវយវៈចេញ ការទ្រទ្រង់នូវសង្ឃាដិ បាត្រ ចីវរ របស់បុគ្គលពួកខ្លះ ក្នុងសាសនានេះ ប្រាកដដូចយ៉ាងដំណើរនៃពួកភិក្ខុល្អដទៃ កំណត់ត្រឹមពួកភិក្ខុ មិនឃើញនូវអាបត្តិរបស់ភិក្ខុនោះ ក្នុងកាលណា ពួកភិក្ខុឃើញនូវអាបត្តិរបស់ភិក្ខុនោះ ក៏ដឹងនូវភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះ ជាអ្នកប្រទូស្តសមណៈ ដូចជាសំដី ឬអង្កាមក្នុងសមណៈ ជាសំរាមដល់សមណៈ លុះពួកភិក្ខុដឹងច្បាស់នូវភិក្ខុនោះ ដូច្នេះហើយ ក៏ធ្វើឲ្យវិនាសទៅខាងក្រៅ ( ជំនុំសង្ឃ ) ក្នុងកាលនោះក៏យ៉ាងនោះឯង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះ

ថា កុំឲ្យប្រទូស្តភិក្ខុល្អទាំងឡាយឯទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងគំនរស្រូវដ៏ធំដែលគេកំពុងរោយ ស្រូវណា ក្នុងគំនរទាំងនោះ ដែលជាស្រូវសុទ្ធ ជាស្រូវមានគ្រាប់ ស្រូវទាំងនោះ ក៏ទៅជាគំនរដោយឡែក ចំណែកស្រូវណា ជាស្រូវមានកម្លាំងថយ ជាសំដីស្រូវ ខ្យល់ក៏បក់ស្រូវទាំងនោះ ទៅជាគំនរដោយឡែក ពួកម្ចាស់ក៏យកអំបោសទៅបោសស្រូវនោះ ( ឲ្យស្អាតចេញ ) ដោយក្រៃលែង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យបន្ទូចស្រូវល្អទាំងឡាយឯទៀតបានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំង-ឡាយ ដំណើរប្រាកដដូច្នោះ គឺការឈានទៅមុខ និងការថយក្រោយ ការមើលទូទៅ ការមើលផ្សេងៗ ការបត់អវយវៈចូល ការលាអវយវៈចេញ ការទ្រទ្រង់នូវសង្ឃាដិ បាត្រ ចីវរ របស់បុគ្គលពួកខ្លះ ក្នុងសាសនានេះ ប្រាកដដូចយ៉ាងដំណើរនៃពួកភិក្ខុល្អដទៃ កំណត់ត្រឹមពួកភិក្ខុ មិនឃើញនូវអាបត្តិរបស់ភិក្ខុនោះ លុះកាលណា ពួកភិក្ខុឃើញអាបត្តិរបស់ភិក្ខុនោះ ក៏ដឹងភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះជាអ្នកប្រទូស្តសមណៈ ដូចជាសំដី ឬអង្កាមក្នុងសមណៈ ជាសំរាមដល់សមណៈ លុះពួកភិក្ខុ ដឹងច្បាស់នូវភិក្ខុនោះ ដូច្នេះហើយ ធ្វើឲ្យវិនាសទៅខាងក្រៅ ( ជំនុំសង្ឃ ) ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យប្រទូស្តពួកភិក្ខុល្អទាំង-ឡាយឯទៀតបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងបុរសត្រូវការថាំងសម្រាប់ដងទឹកអណ្តូង ក៏ត្រូវកាន់យកដឹងដ៏មុតចូលទៅព្រៃ បុរសនោះ គោះ

មើលឈើនោះ ដោយស្លាបជីង ។ ឈើទាំងនោះ ឈើណា ជាឈើមាំមួន មានខ្លឹម ឈើទាំងនោះ កាលត្រូវគេគោះ ដោយស្លាបជីងហើយ ក៏បញ្ចេញសូរបែបរឹងតាន់ ។ ចំណែកឈើទាំងឡាយណា ជាឈើស្អុយក្នុង ជាឈើពុក ជាឈើជ្រោកជ្រាក ឈើទាំងនោះ កាលត្រូវគេគោះ ដោយស្លាបជីងហើយ ក៏បញ្ចេញសូរបែបពុកៗ ។ បុរសនោះ ក៏កាត់យកឈើនោះ ត្រង់គល់ លុះកាត់គល់ហើយ ទើបកាត់ចុង លុះកាត់ចុងហើយ ទើបសម្អាតខាងក្នុងឲ្យស្អាត លុះសម្អាតខាងក្នុង ឲ្យស្អាតហើយ ទើបធ្វើទៅជាថាំងសម្រាប់ដងទឹកអណ្តូង យ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ ការឈានទៅមុខ និងការថយក្រោយ ការមើលទូទៅ ការមើលផ្សេងៗ ការបត់អវយវៈចូល ការលាអវយវៈចេញ ការទ្រទ្រង់នូវសង្ឃាដិ បាត្រ ចីវរ តែងមានដល់បុគ្គលពួកខ្លះក្នុងសាសនានេះ ប្រាកដដូចយ៉ាងដំណើរនៃពួកភិក្ខុល្អដទៃ កំណត់ត្រឹមពួកភិក្ខុមិនទាន់ឃើញនូវអាបត្តិរបស់ភិក្ខុនោះ លុះកាលណា ពួកភិក្ខុឃើញនូវអាបត្តិរបស់ភិក្ខុនោះហើយ ក៏ដឹងនូវភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះ ជាអ្នកប្រទូស្តសមណៈ ដូចជាសំដី ឬអង្កាមក្នុងសមណៈ ជាសំរាមដល់សមណៈ លុះពួកភិក្ខុដឹងច្បាស់នូវភិក្ខុនោះដូច្នេះហើយ ធ្វើឲ្យវិនាសទៅខាងក្រៅ ( ជំនុំសង្ឃ ) ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យប្រទូស្តពួកភិក្ខុល្អឯទៀតបានឡើយ ។

ដោយការនៅរួមគ្នា បុគ្គលគប្បីដឹងថា បុគ្គលមានប្រាជ្ញា

ដ៏លាមក មានសេចក្ដីក្រោធ ជាអ្នកលុបគុណ រឹងត្អឹង លើកខ្លួន ប្រណែន មានសេចក្ដីកំណាញ់ ជាអ្នកអួតអាង មានសម្ដីទន់ភ្លន់ និយាយក្នុងកណ្ដាលប្រជុំជន ដូចជាសមណៈ តែជាអ្នកមានទិដ្ឋិអាក្រក់ មិនអើពើ ( ក្នុងធម៌វិន័យ ) ជាបុគ្គលវង្វេងវង្វាង ពោលនូវពាក្យកុហក តែងធ្វើនូវអំពើ ( អាក្រក់ ) ក្នុងទីស្ងាត់ យ៉ាងណា អ្នកទាំងឡាយទាំងអស់គ្នា លុះដឹងច្បាស់នូវពាក្យនោះយ៉ាងណាហើយ គួរជាអ្នកព្រមព្រៀងគ្នា ចូរបណ្ដេញនូវបុគ្គលនោះចេញ កម្ចាត់បង់នូវបុគ្គលដូចជាសំរាម កម្ចាត់បង់នូវបុគ្គលជ្រោកជ្រាកចេញ លំដាប់អំពីនោះ អ្នកទាំងឡាយចូរបន្សាត់នូវបុគ្គលទាំងឡាយ ដូចជាសំដី ឬអង្កាម មិនមែនជាសមណៈ លើកខ្លួនថាជាសមណៈនោះចេញ លុះអ្នកទាំងឡាយ កម្ចាត់បង់នូវបុគ្គលប្រាថ្នាលាមក មានអាចារៈ និងគោចរដ៏លាមកចេញហើយ ជាអ្នកមានស្មារតី ចូរកំណត់នូវការនៅរួមគ្នា ដោយបុគ្គលបរិសុទ្ធ និងមិនបរិសុទ្ធ គួរជាអ្នកព្រមព្រៀងគ្នា មានប្រាជ្ញាដ៏ខ្ជាប់ខ្ជួន នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

មេត្តាវគ្គទី ១ ចប់

### ឧទ្ទានក្នុងមេត្តាវគ្គនោះ គឺ

និយាយអំពីអានិសង្សមេត្តាចេតោសមាធិ ១ អំពីការបាន បញ្ញាពីរលើក អំពីបុគ្គលជាទីស្រឡាញ់ពីរលើក អំពីបុគ្គល មិនជាទីស្រឡាញ់ពីរលើក អំពីលោកធម៌ និងការប្រាស ចាកលោកធម៌ ១ អំពីទេវទត្ត ១ អំពីព្រះឧត្តរ ១ អំពី ព្រះនន្ទ ១ អំពីសមណៈដូចជាសំរាម ១ ។

# អដ្ឋកថា

## ការណ្ឌវសូត្រ

[ ១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងការណ្ឌវសូត្រទី ១០ ដូចតទៅនេះ បទថា **អញ្ញេនាញ្ញំ បដិចរតិ** សេចក្តីថា យកហេតុ ឬពាក្យដទៃមកលុបលាងហេតុ ឬពាក្យដទៃ ។ បទថា **ធមេថេតំ ភិក្ខវេ** សេចក្តីថា វាចាដែល ជ្រៀតចូលមកដទៃឲ្យចេញក្រៅផ្លូវ ។ បទថា **អបនេយ្យោ** បានដល់ បុគ្គល នេះគប្បីនាំចេញទៅ ។ បទថា **សមណទូសី** បានដល់ អ្នកប្រទូស្តសមណៈ ។ បទថា **សមណបលាបោ** សេចក្តីថា ឈ្មោះថា ជាសមណៈអង្កាម ក្នុង សមណៈទាំងឡាយ ព្រោះមិនមានខ្លឹម ដូចអង្កាមក្នុងស្រូវទាំងឡាយ ។ បទ ថា **សមណការណ្ឌវោ** បានដល់ សមណៈសំរាម ។ បទថា **ធមេថ** **និទ្ធមេថ** ប្រែថា បណ្តេញចេញទៅខាងក្រៅ ។

បទថា **យវការណោ** បានដល់ ក្នុងស្រែស្រូវដំណើប ។ បទថា **ផុសយមានស្ស** បានដល់ ដែលបុគ្គលឈរនៅលើទីខ្ពស់ ហើយបាចទៅក្នុងទីដែលមានខ្យល់ខ្លាំង ។ បទថា **អបសម្មជ្ជន្តិ** សេចក្តីថា បោសចេញរឿយៗ ដើម្បីធ្វើស្រូវដែលល្អទុកម្ខាង ស្រូវដែលអាក្រក់ទុកម្ខាង គឺយកចង្អេរ ឬសំពត់ដែលអាចបក់បាន ឬផ្លិតបក់ទៅ ។ បទថា **ឧន្នំ** បានដល់ មានសំឡេងខ្លាំង ។

បទថា **សំវាសាយ** ប្រែថា ព្រោះនៅរួមគ្នា ។ បទថា **វិជានេថ** ប្រែថា គប្បីដឹងបាន ។ បទថា **សន្តវាចោ** ប្រែថា មានវាចាទន់ផ្អែម ។ បទថា **ជនវតិ** ប្រែថា ក្នុងកណ្តាលជន ។ បទថា **រហោ ករោតិ ការណំ** សេចក្តីថា បាបកម្ម ហៅថា **ការណា** គឺការធ្វើ បានដល់ ជាអ្នកបិទបាំងការធ្វើបាបកម្មក្នុងទីកំបាំង ។ បទថា **សំសប្បី ច មុសាវាទី** សេចក្តីថា ជាបុគ្គលពោលមុសាឡេះឡោះ អធិប្បាយថា និយាយកុហកឡេះឡោះ គឺត្រឡប់ចុះត្រឡប់ឡើង ។ ក្នុងសូត្រនេះ ត្រាស់ចំពោះវដ្តៈតែម្យ៉ាង ឯក្នុងគាថាទាំងឡាយ ទ្រង់ត្រាស់វដ្តៈផង និងវិវដ្តៈផង ។

## អដ្ឋកថា ការណ្ឌវសូត្រទី ១០ ចប់

## មេត្តាវគ្គទី ១ ចប់

# សុត្តន្តបិដក

# មហាវគ្គ

## វេរញ្ជសូត្រទី ១

[ ១១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា ។ គ្រានោះ វេរញ្ជព្រាហ្មណ៍ ចូលសំដៅទៅត្រង់ទីដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ កាលដែលវេរញ្ជព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំបានឮពាក្យថា ព្រះសមណគោតម មិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់ជរា ជាព្រឹទ្ធាចារ្យមានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុជ្រលចូល ក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឲ្យអង្គុយលើអាសនៈ ( ព្រះអង្គក៏មិនធ្វើ ) បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំបានឮមកនោះ ជាប្រាកដថា ព្រះគោតមដ៏ចម្រើន មិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់ជរា ជាព្រឹទ្ធាចារ្យមានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុជ្រលចូលមកក្នុងបច្ឆិមវ័យហើយ ជាសូម្បីត្រឹមតែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ

ដោយអាសនៈ ( ព្រះអង្គក៏មិនធ្វើ ) បពិត្រព្រះគោតមដ៏ចម្រើន កិច្ចមានមិនសំពះជាដើមនោះ ជាទំនងពុំសមគួរឡើយ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញអ្នកណាមួយ ល្មមឲ្យតថាគតសំពះ ឬក្រោកទទួល ឬអញ្ជើញហៅរកឲ្យអង្គុយលើអាសនៈឡើយ ម្នាលព្រាហ្មណ៍ ព្រោះថា បើតថាគតសំពះអ្នកណា ឬក្រោកទទួលអ្នកណា ឬក៏អញ្ជើញហៅរកដោយអាសនៈ ក្បាលរបស់អ្នកនោះ នឹងដាច់ធ្លាក់ចេញចាកក ។ វេរញ្ជព្រាហ្មណ៍ក៏ពោលពាក្យប្រទ្បោះបោះ ទៅរកព្រះសាស្តាថា ព្រះគោតមដ៏ចម្រើន ជាមនុស្សស្រោះកក្រោះ ឥតរសជាតិទេតើ ។ ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សស្រោះកក្រោះ ឥតរសជាតិ ដែលគេថានោះ ត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះរសជាតិ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោតដែលគេគាស់រម្លើង ឲ្យលែងដុះតទៅទៀតហើយ ជាធម៌លែងមានបែបភាពតទៅទៀតហើយ ជាធម៌លែងមានកំណើតតទៅមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សស្រោះកក្រោះ ឥតមានរសជាតិនោះ គឺត្រូវត្រង់ហេតុ

នេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុដែលព្រាហ្មណ៍ឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន គ្មានគ្រឿងប្រើការទេតើ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សប្រើការមិនកើត ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះគ្រឿងប្រើការ គឺរូប សំឡេង ក្លិន រសផោដ្ឋព្វៈទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោតដែលគេគាស់រម្លើងឲ្យលែងដុះតទៅទៀតហើយ ជាធម៌លែងមានបែបភាពតទៅទៀតហើយ ជាធម៌មិនមានកំណើតតទៅខាងមុខទៀតទេ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សប្រើការមិនកើតនោះ គឺជាសម្តីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអកិរិយវាទទេតើ ។ ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអកិរិយវាទ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះតថាគត ប្រកាន់និយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយ ធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតឡើយ តែងនិយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយ ធ្វើនូវធម៌ទាំងឡាយ ជាអកុសលអាក្រក់ច្រើនប្រការនោះឡើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជា

អកិរិយវាទនោះ គឺជាសម្ដីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកនិយាយសំដៅនោះទេ ។

ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាឧច្ឆេទវាទទេតើ ។ ព្រះសាស្ដាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាឧច្ឆេទវាទ ដែលគេថានោះ ត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះតថាគត ប្រកាន់និយាយថា ឲ្យសត្វកាត់ផ្ដាច់ផ្ដិលនូវរាគៈ ទោសៈ មោហៈ តថាគតតែងនិយាយថា ឲ្យសត្វកាត់ផ្ដាច់ផ្ដិលនូវធម៌ទាំងឡាយ ជាអកុសលអាក្រក់ច្រើនយ៉ាងនេះចេញ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាឧច្ឆេទវាទនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកខ្ពើមរអើម ( ណាស់ ) ទេតើ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម ដែលគេថានោះ ត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះតថាគត តែងនិយាយថា គួរខ្ពើមរអើមសេចក្ដីប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត តថាគតតែងនិយាយថា គួរខ្ពើមរអើមសេចក្ដីប្រកបចិត្ត ផ្ដេកផ្ដិតទៅរកអកុសលធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើមនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុដែលអ្នកនិយាយសំដៅនោះ

ទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកបំផ្លាញទេតើ ។ ព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកបំផ្លាញ ដែលគេថានោះ ត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះតថាគតសម្តែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែលបំផ្លាញបង់នូវរាគៈ ទោសៈ មោហៈ តថាគតសម្តែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែលរំលាងបង់នូវអកុសលធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកបំផ្លាញនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកដុតកម្តៅទេតើ ។ ព្រះសព្វញ្ញូទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកដុតកម្តៅ ដែលគេថានោះ ត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះតថាគតប្រកាន់និយាយថា ការប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ជាអកុសលធម៌ដ៏អាក្រក់ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ ( នោះ ) បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោត ដែលគេគាស់រម្លើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា អ្នកដុតកម្តៅ ម្នាលព្រាហ្មណ៍

អកុសលធម៌ទាំងឡាយដ៏អាក្រក់ ជាទីតាំងនៃសេចក្តីក្តៅក្រហាយ តថាគត បានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោត ដែលគេគាស់រម្លើងឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតត ទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកជុតកម្តៅនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុដែលអ្នកនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាមនុស្សឥតកំណើតទេតើ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សឥតកំណើត ដែលគេថានោះ ត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះកិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើត ក្នុងភពតទៅទៀត បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចដើមត្នោត ដែលគេគាស់រម្លើងឲ្យលែងដុះតទៅទៀតហើយ ធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅទៀតហើយ តថាគតហៅអ្នកនោះថា អ្នកឥតកំណើត ម្នាលព្រាហ្មណ៍ កិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើត ក្នុងភពតទៅមុខទៀត តថាគតបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោត ដែលគេគាស់រម្លើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែប

ភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើត ទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សឥតកំណើត នោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកនិយាយ សំដៅនេះទេ ។ ម្នាលព្រាហ្មណ៍ ដូចជាស៊ុតមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ស៊ុតមាន់ទាំងនោះ គឺមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្តៅ ដោយប្រពៃហើយ ឲ្យចាប់ក្លិនមេដោយប្រពៃហើយ ( លុះដល់វេលាញាស់ ) ក៏បណ្តាកូនមាន់ទាំងនោះ កូនមាន់ណា ទម្លាយសម្បកស៊ុត ដោយចុងក្រចក ជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលមុនគេបំផុត បើ ដូច្នេះ តើអ្នកផងគួរហៅកូនមាន់នោះថា កូនច្បង ឬកូនពៅហ្ន៎ ! ព្រាហ្មណ៍ ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ( កូនមាន់នោះ ) គេគួរហៅថា កូន ច្បង បពិត្រព្រះគោតមដ៏ចម្រើន ពីព្រោះវាជាបងគេបំផុត ។ ព្រះសាស្តាទ្រង់ ត្រាស់ថា ម្នាលព្រាហ្មណ៍ កាលបើពពួកសត្វ ដូចជាស៊ុត ( មាន់ ) មាន អវិជ្ជា គឺសេចក្តីល្ងង់ ដូចជាសម្បកស៊ុតកំពុងរួបរឹតក្នុងលោក មានតែតថាគត ម្នាក់ឯង ដែលទម្លាយសម្បកស៊ុត គឺសេចក្តីល្ងង់ ហើយត្រាស់ដឹងខ្លួនឯងដោយ ប្រពៃ នូវសម្មាសម្ពោធិញ្ញាណ ដែលមិនមានគុណជាតឯទៀតប្រសើរជាង ឡើយ ម្នាលព្រាហ្មណ៍ តថាគតឯង ជាច្បង ជាបុគ្គលប្រសើរបំផុតជាង សត្វលោក ម្នាលព្រាហ្មណ៍ ព្យាយាម តថាគតបានតាំងផ្តើមហើយ មិនបន្ធូរ បន្ថយឡើយ ទាំងស្មារតីតថាគតក៏ប្រុងមិនឲ្យមានភ្លាត់ កាយសោត ក៏ស្ងប់

រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏នឹងល្អ ជាចិត្តមានអារម្មណ៍តែមួយ ម្នាលព្រាហ្មណ៍ តថាគតនោះ លុះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ទាំង-ឡាយ ជាអកុសលហើយ ក៏ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្កវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កវិចារៈ តថាគតបានចូលដល់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្ដានចិត្ត ប្រកបដោយសេចក្ដីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈ មានតែបីតិ និងសុខ កើតអំពីសមាធិ ព្រោះលះបង់បីតិចេញហើយ តថាគតជាបុគ្គលព្រងើយផង មានសតិសម្បជញ្ញៈផង សោយសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលអ្នកបានតតិយជ្ឈាន មានចិត្តព្រងើយ មានស្មារតី មានប្រក្រតីនៅជាសុខ ព្រោះតតិយជ្ឈានណា តថាគត ក៏បានដល់នូវតតិយជ្ឈាននោះ ព្រោះលះបង់នូវសេចក្ដីសុខផង ព្រោះលះបង់នូវសេចក្ដីទុក្ខផង ព្រោះរម្ងត់នូវសោមនស្ស និងទោមនស្សអំពីមុនផង តថាគតបានចូលដល់ចតុត្ថជ្ឈាន ដែលឥតទុក្ខ ឥតសុខ មានសតិដ៏ស្អាត ប្រាកដចំពោះត្រង់ឧបេក្ខា កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាងនេះហើយ តថាគតក៏បានបង្អោនចិត្តចូលទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ តថាគតក៏រឭកជាតិដែលបានអាស្រ័យនៅអំពីមុន ជាអនេកជាតិ គឺរឭកបាន ១ ជាតិ ២ ជាតិ

៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន រឭកបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា តថាគតបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគតច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ តថាគតមានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានសោយសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគតច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ។ តថាគតរឭកតាមនូវជាតិ ដែលអាស្រ័យនៅពីមុនបានច្រើនជាតិ ព្រមទាំងអាការព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលព្រាហ្មណ៍ បឋមវិជ្ជានេះហើយ ដែលតថាគតបានក្នុងយាមដំបូងនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើង ដល់តថាគត ដូចជាបុគ្គលដែលមិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តបញ្ជូនទៅ ។ ម្នាលព្រាហ្មណ៍ នេះឯងជាការញាស់ចេញជាដំបូងរបស់តថាគត ដូចជាកូនមាន់ញាស់ចេញចាកសម្បកស៊ុត ។ កាលដែលចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាងនេះហើយ តថាគតទើបបង្អោនចិត្ត ដើម្បីដឹងនូវចុតិ និងបដិសន្ធិនៃសត្វ

ទាំងឡាយ ( ចុតូបបាតញ្ញាណ ) ។ តថាគតពិចារណាមើលនូវសត្វទាំងឡាយ ដែលច្យុត និងចាប់បដិសន្ធិ ថោកទាប និងឧត្តម មានសណ្ឋានល្អ និងអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុ របស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ ! សត្វទាំងឡាយអម្បាលនេះ ប្រកបដោយកិរិយាប្រព្រឹត្តអាក្រក់ ដោយកាយ ដោយវាចា ដោយចិត្ត និយាយតិះដៀលអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះរំលាងខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក មួយសោត ឱហ្ន៎ ! សត្វទាំងឡាយនេះ ប្រកបដោយកិរិយាប្រព្រឹត្តល្អដោយកាយ ដោយវាចា ដោយចិត្ត មិនតិះដៀលអរិយបុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះរំលាងខន្ធបន្ទាប់ពីមរណៈ ក៏ទៅកើតឯឋានសុគតិសួគ៌ទេវលោក ។ តថាគតពិចារណាមើលសត្វទាំងឡាយ ដែលច្យុត និងចាប់បដិសន្ធិ ថោកទាប និងឧត្តម មានសណ្ឋានល្អ និងអាក្រក់ទៅកាន់សុគតិ និងទុគ្គតិដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ២ នេះហើយ ដែលតថាគតបានក្នុងយាមជាកណ្តាលនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដូចជាបុគ្គលមិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មាន

ចិត្តបញ្ជូនទៅ ។ ម្នាលព្រាហ្មណ៍ នេះឯងជាការញាស់ចេញ ជាគម្រប់ ២ របស់តថាគត ដូចជាកូនមាន់ដែលញាស់ចេញចាកសម្បកស៊ុត ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ តថាគតទើបបង្អោនចិត្តទៅ ដើម្បីដឹងនូវធម៌ជាគ្រឿងអស់ទៅ នៃអាសវៈទាំងឡាយ ( អាសវក្ខយញ្ញាណ ) ។ តថាគតដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាឧបាយឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា ធម៌ប៉ុណ្ណេះជាអាសវៈ ដឹងប្រាកដតាមពិតថា ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងប្រាកដតាមពិតថា នេះជាឧបាយឲ្យបានដល់នូវសេចក្តីរលត់នៃអាសវៈ កាលដែលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តនៃតថាគតក៏ផុតចាកគ្រឿងត្រាំ គឺកាមផង គឺភពផង គឺអវិជ្ជាផង កាលបើចិត្តនៃតថាគតបានរួចផុតស្រឡះហើយ សេចក្តីដឹងថា ចិត្តផុតស្រឡះក៏កើតប្រាកដឡើង តថាគតដឹងច្បាស់ថា កំណើតរបស់អញអស់ហើយ ព្រហ្មចរិយធម៌ អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអញក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ៣ នេះហើយ ដែលតថាគតបានក្នុងយាមជាទីបំផុតនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅ

វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដូចជាបុគ្គលមិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តបញ្ជូនទៅ ។ ម្នាលព្រាហ្មណ៍ នេះឯងជាការញាស់ជាគម្រប់ ៣ របស់តថាគតដូចគ្នានឹងការញាស់ចេញរបស់កូនមាន់អំពីសម្បកស៊ុត ។ កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ វេរញ្ជព្រាហ្មណ៍ បានក្រាបទូលព្រះដ៏មានព្រះភាគវិញថា ព្រះគោតមដ៏ចម្រើន ព្រះអង្គជាចម្បងជាងមនុស្ស ព្រះគោតមដ៏ចម្រើន ព្រះអង្គប្រសើរបំផុតជាងមនុស្ស បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន សម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះ ឲ្យផ្ងារឡើង ពុំនោះដូចមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវ ដល់អ្នកវង្វេងទិស ឬក៏ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថាមនុស្សអ្នកមានភ្នែក នឹងឃើញនូវរូបទាំងឡាយបាន ខ្ញុំព្រះអង្គនុ៎ះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់សរណៈស្មើដោយជីវិត ។

# អដ្ឋកថា
# មហាវគ្គទី ២

## វេរញ្ជសូត្រ

[ ១១ ] គប្បីជ្រាបវិនិច្ឆ័យវេរញ្ជសូត្រក្នុងទី ១ នៃមហាវគ្គទី ២ ដូចតទៅនេះ គប្បីប្រកបបទជាដើមយ៉ាងនេះថា **អភិវាទេតិ** ជាមួយនឹង **ន** អក្ខរៈ ដែលបានពោលក្នុងបទនេះថា **ន សមណោ គោតមោ** ហើយជ្រាបដោយសេចក្តីយ៉ាងនេះថា ព្រះសមណគោតមមិនថ្វាយបង្គំ មិនក្រោកឡើងអំពីអាសនៈ ទាំងមិនអញ្ជើញដោយអាសនៈយ៉ាងនេះថា សូមអ្នកអង្គុយត្រង់នេះ ។ **វា** សព្ទ ក្នុងពាក្យថា **អភិវាទេតិ វា** ជាដើម ចុះក្នុងអត្ថឈ្មោះថា **វិភាវន** ធ្វើឲ្យជាក់ច្បាស់ ដូច **វា** សព្ទ ក្នុងប្រយោគជាដើមថា **រូបំ និច្ចំ វា អនិច្ចំ វា** រូប ទៀង ឬមិនទៀង ។ វេរញ្ជព្រាហ្មណ៍កាលពោលយ៉ាងនេះហើយ លុះឃើញព្រះមានព្រះភាគ មិនធ្វើការសំពះខ្លួនជាដើម ទើបពោលថា **តយិទំ ភោ គោតម តថេវ** បពិត្រព្រះគោតម សេចក្តីនោះពិតយ៉ាងនោះ អធិប្បាយថា វត្ថុដែលខ្ញុំបានឮមកនោះ យ៉ាងនោះពិត ។ ការបានឮមក និងការបានឃើញនោះសមគ្នាដោយអត្ថ គឺតែមួយដូចគ្នា ។ ព្រះគោតម ។បេ។ មិនអញ្ជើញដោយអាសនៈ ។ វេរញ្ជព្រាហ្មណ៍ពោលបញ្ជាក់រឿងដែលខ្លួនបានស្តាប់ និងបានឃើញ ទើបពោលតិះដៀលដោយប្រការយ៉ាងនោះ ។ បទថា **តយិទំ ភោ គោតម ន សម្បន្នមេវ**

សេចក្ដីថា ការមិនធ្វើការអភិវាទជាដើមនោះ មិនសមគួរឡើយ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់មិនបានអាស្រ័យទោស គឺការលើកខ្លួនសង្កត់ដល់វេរញ្ជព្រាហ្មណ៍នោះ មានព្រះហឫទ័យត្រជាក់ត្រៀម ដោយព្រះករុណា ទ្រង់បំណងនឹងកម្ចាត់ការមិនដឹងនោះ ហើយទ្រង់សម្ដែងការពាល់ត្រូវ ទើបត្រាស់ពាក្យជាដើមថា **នាហន្តំ ព្រាហ្មណ** ដូច្នេះ ។ ក្នុងព្រះតម្រាស់នោះ មានសេចក្ដីសង្ខេបដូចតទៅនេះ ម្នាលព្រាហ្មណ៍ តថាគតពិនិត្យមើលដោយចក្ខុ គឺសព្វញ្ញុតញ្ញាណដែលមិនទើសទាក់ ក៏មិនឃើញបុគ្គលក្នុងលោកនេះ មានទេវលោកជាដើម ដែលតថាគតគប្បីថ្វាយបង្គំ ក្រោកទទួល ឬអញ្ជើញដោយអាសនៈ ។ ម្យ៉ាងទៀត សេចក្ដីនេះមិនគួរអស្ចារ្យឡើយ តថាគតសម្រេចសព្វញ្ញុតញ្ញាណ គង់មើលមិនឃើញបុគ្គល គួរដល់ការនមស្ការបែបនេះ ក្នុងថ្ងៃនេះ ម្យ៉ាងទៀត ក្នុងកាលណាតថាគតកើតក្នុងឥឡូវនេះ បែរមុខទៅកាន់ទិសឧត្តរ ឈានទៅ ៧ ជំហាន មើលនូវម៉ឺនលោកធាតុទាំងពួង សូម្បីក្នុងកាលនោះ ក្នុងលោកនេះ មានទេវលោកជាដើម តថាគតក៏មើលមិនឃើញបុគ្គល ដែលតថាគតគប្បីធ្វើការថ្វាយបង្គំបែបនោះ ។ គ្រានោះឯង ព្រះខីណាស្រពដែលជាព្រហ្ម មានអាយុ ១៦០០០ កប្ប ផ្គងអញ្ជលីកើតនូវសោមនស្ស រមែងរាប់អានតថាគតថា ព្រះអង្គជាមហាបុរសក្នុងលោក ព្រមទាំងទេវលោក ទ្រង់ជាបុគ្គលប្រសើរ ជាអ្នកចម្រើនបំផុត ជាបុគ្គលប្រសើរបំផុតរបស់លោក ព្រមទាំងទេវលោក មិនមានបុគ្គលដែល

ក្រៃលែងជាងទ្រង់ ។ ក្នុងកាលនោះ តថាគតមើលមិនឃើញ បុគ្គលដែលជាធំជាងតថាគត ទើបបន្លឺអាសភិវាចា គឺវាចាដ៏អង់អាចថា យើងជាកំពូលនៃលោក យើងជាបុគ្គលចម្រើនបំផុតនៃលោក យើងជាបុគ្គលប្រសើរបំផុតនៃលោក ។ តថាគតសូម្បីកើតបានមួយសន្ទុះ ក៏គង់មិនមានបុគ្គលដែលគួរថ្វាយបង្គំយ៉ាងនេះ ឥឡូវនេះ តថាគតសម្រេចសព្វញ្ញុតញ្ញាណហើយ គប្បីថ្វាយបង្គំអ្នកណា ព្រោះដូច្នោះ អ្នកកុំប្រាថ្នាការថ្វាយបង្គំយ៉ាងក្រៃលែងបែបនេះ អំពីតថាគតឡើយ ។ ព្រោះតថាគត គប្បីក្រាបថ្វាយបង្គំបុគ្គលណា ។បេ។ ឬអញ្ជើញបុគ្គលណា ដោយអាសនៈ សូម្បីសីសៈរបស់បុគ្គលនោះ ក៏គប្បីដាច់អំពីកធ្លាក់ចុះត្រង់ផែនដីមួយរំពេច ដូចផ្លែត្នោតរបូតចាកទង ដែលជាប់តិចតួច ព្រោះទុំខ្លាំង របូតចាកទងអស់រាត្រី ដូច្នោះ ។

កាលត្រាស់យ៉ាងហើយ ព្រាហ្មណ៍ក៏កំណត់មិនបានថា ព្រះតថាគតជាបុគ្គលចម្រើនបំផុតក្នុងលោក ព្រោះភាពដែលប្រាជ្ញារាក់ កាលអត់ធន់នឹងព្រះតម្រាស់តែម្យ៉ាងមិនបាន ទើបពោលថា ព្រះគោតមជាអ្នកមិនមានរសជាតិ ។ បានឮថា ព្រាហ្មណ៍នោះ មានបំណងដូច្នេះថា សាមីចិកម្ម គឺការថ្វាយបង្គំ ការក្រោកទទួល និងការធ្វើអញ្ជលីក្នុងលោក ដែលហៅថា សាមគ្គីរស ព្រះគោតមមិនមានឡើយ ព្រោះដូច្នោះ ទើបព្រះគោតមមិនមានរស គឺមិនមានរសជាតិ មិនមានរសជាសភាវៈ ។ លំដាប់នោះ ព្រះមានព្រះភាគកាលទ្រង់ចៀសវាងនូវការជំទាស់ដោយត្រង់ ដើម្បីឲ្យព្រាហ្មណ៍នោះកើតនូវចិត្តទន់

ក្ខន់ កាលនឹងប្រាប់អត្ថនៃពាក្យនោះ ដោយប្រការដទៃក្នុងព្រះអង្គ ទើបត្រាស់ថា **អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អត្ថិ ខ្វេស** កាត់បទជា **អត្ថិ ខោ ឯស ។** បទថា **បរិយាយោ** បានដល់ ហេតុ ។ លោកអធិប្បាយថា ម្នាលព្រាហ្មណ៍ មានហេតុដែលបុគ្គលកាលពោលដល់តថាគត ។ ព្រះគោតមមិនមានរសជាតិ ដូច្នេះ ឈ្មោះថា គប្បីពោលប្រពៃ គឺគប្បីទទួលថា ពោលតាមពិត ហេតុនោះដូចម្ដេច ម្នាលព្រាហ្មណ៍ ការត្រេកអរក្នុងរូប ។បេ។ ការត្រេកអរក្នុងផោដ្ឋព្វៈ តថាគតលះបានហើយ មានអធិប្បាយដូចម្ដេច មានអធិប្បាយថា ការត្រេកអរក្នុងរូប ការត្រេកអរក្នុងសំឡេង ការត្រេកអរក្នុងក្លិន ការត្រេកអរក្នុងរស ការត្រេកអរក្នុងផោដ្ឋព្វៈឯណា ពោល គឺការពេញចិត្តក្នុងកាមសុខ រមែងកើតដល់ពួកបុថុជ្ជន ដែលគេសន្មតថា ជាអ្នកប្រសើរដោយកំណើត ឬដោយការកើតឡើង ជាអ្នកពេញចិត្ត ត្រេកអរ ប្រាសចាកតម្រេកក្នុងរូបារម្មណ៍ជាដើម រសពួកណា រមែងទាញនូវលោកនេះ ដូចចងទុកត្រង់ក ឬហៅថា សាមគ្គីរស ព្រោះកើតឡើងដោយការព្រមព្រៀងរបស់វត្ថុ និងអារម្មណ៍ជាដើម រសទាំងអស់នោះ តថាគតលះបានហើយ សូម្បីកាលគួរនឹងត្រាស់ថា តថាគតលះបង់ហើយ ក៏ទ្រង់មិនលើកព្រះអង្គដោយមមង្ការ សម្ដែងធម៌ជាបែបដទៃ នេះជាទេសនាវិលាស ជាលំនាំរណ្ដំនៃទេសនារបស់ព្រះ-តថាគត ។

ក្នុងបទទាំងនោះ បទថា **បហីនា** ប្រែថា ទៅប្រាស ឬដាច់អំពីចិត្តសន្តាន ក្នុងអត្ថនេះ គប្បីឃើញឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃតតិយាវិភត្តិ ឈ្មោះថា មានឫសកាត់បង់ហើយ ព្រោះឫស គឺតណ្ហា និងអវិជ្ជានៃរសទាំងនោះ តថាគតកាត់ផ្តាច់ហើយដោយសស្ត្រា គឺអរិយមគ្គ ។ ឈ្មោះថា ធ្វើឲ្យដូចវត្ថុដែលជាទីតាំងនៃដើមត្នោត ព្រោះធ្វើឲ្យជាវត្ថុទីតាំងនៃការត្រេកអរក្នុងរូបជាដើមទាំងនោះ ដូចវត្ថុជាទីតាំងនៃដើមត្នោត ។ ប្រៀបដូចកាលកំណាត់ដើមត្នោត ព្រមទាំងឫសធ្វើប្រទេស គឺទីត្រង់នោះ ឲ្យដូចជាទីតាំងរបស់ដើមត្នោតនោះ ដើមត្នោតនោះ រមែងមិនប្រាកដជាកើតឡើងទៀត យ៉ាងណា កាលដកនូវការត្រេកអរក្នុងរូបជាដើម ព្រមទាំងឫសដោយសស្ត្រា គឺអរិយមគ្គ ធ្វើចិត្តសន្តានឲ្យត្រឹមតែជាវត្ថុ ព្រោះការត្រេកអរក្នុងរូបជាដើមទាំងនោះ ធ្លាប់កើតឡើងក្នុងកាលមុន ការត្រេកអរក្នុងរូបជាដើមទាំងអស់នោះ ទើបត្រាស់ហើយថា **តាលាវត្ថុកតា** ធ្វើឲ្យដូចទីតាំងរបស់ដើមត្នោត ដូច្នោះ ។ ម្យ៉ាងទៀត ឈ្មោះថា **តាលាវត្ថុកតា** ព្រោះធ្វើឲ្យដូចត្នោតកំបុតចុង ព្រោះមិនដុះឡើងជាធម្មតា ព្រោះហេតុដែលការត្រេកអរក្នុងរូបជាដើម ត្រូវធ្វើឲ្យដូចជាវត្ថុនៃដើមត្នោតយ៉ាងនេះ គឺរមែងធ្វើមិនឲ្យមានតទៅទៀត ឈ្មោះថា ត្រូវធ្វើដោយប្រការដែលត្រេកអរក្នុងរូបជាដើមនោះ នឹងមិនមានខាងក្រោយដូច្នោះ ទើបត្រាស់ថា **អនភាវំកតា** គឺធ្វើឲ្យមិនមាន ។ បទថា **អាយតឹ អនុប្បាទធម្មា** បានដល់ ដែលមិនកើតឡើងក្នុងអនាគតជាធម្មតា ។

បទថា **នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ** សេចក្តីថា អ្នកពោលហេតុណាសំដៅដល់តថាគត ហេតុនោះ រមែងមិនមាន ។ សួរថា កាលត្រាស់យ៉ាងនេះ រមែងឈ្មោះថា ទ្រង់អនុញ្ញាតថា សាមគ្គីរសដែលព្រាហ្មណ៍ពោលនោះមានក្នុងព្រះអង្គមិនមែនឬ ។ ឆ្លើយថា មិនមែនទ្រង់អនុញ្ញាត ។ ព្រោះបុគ្គលណា ជាបុគ្គលគួរធ្វើសាមគ្គីរសនោះ ហើយមិនធ្វើ បុគ្គលនោះគួរជាបុគ្គលត្រូវពោលថា ជាអ្នកមិនមានរសជារូប ព្រោះមិនមានសាមគ្គីរសនោះ ។ តែព្រះមានព្រះភាគ មិនគួរនោះឯង ដែលនឹងធ្វើសាមគ្គីរសនោះ ព្រោះហេតុនោះ កាលទ្រង់ប្រកាសការមិនគួរក្នុងការធ្វើសាមគ្គីរសនោះ ទើបត្រាស់ថា **នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ** ដូច្នេះ ។ អធិប្បាយថា អ្នកពោលដល់តថាគតថា មិនមានរសជារូប សំដៅយកហេតុណា ហេតុនោះ មិនគួរពោលក្នុងតថាគតឡើយ ។

ព្រាហ្មណ៍មិនអាចលើកយកការមិនមានរសជាតិ ដែលខ្លួនបំណងដោយអាការយ៉ាងនេះ ទើបពោលបរិយាយដទៃតទៅខាងក្រោយថា **និព្ភោគោ ភវំ** ជាដើម ។ ក្នុងបរិយាយទាំងពួង គប្បីជ្រាបលំដាប់ការប្រកបសេចក្តីដោយន័យដូចពោលក្នុងហេតុនេះហើយ ជ្រាបអត្ថពោលយ៉ាងនេះថា ព្រាហ្មណ៍សម្គាល់កម្ម មានសាមីចិកម្មជាដើម នូវបុគ្គលដែលចម្រើនដោយវ័យទាំង-ឡាយនោះប៉ុណ្ណោះថា សាមគ្គីបរិភោគក្នុងលោក និងពោលជាមួយព្រះមានព្រះភាគថា **និព្ភោគ** គឺមិនមានភោគៈ ព្រោះមិនមានសាមគ្គីបរិភោគនោះ ។

ព្រះមានព្រះភាគទ្រង់ឃើញថា ការបរិភោគដោយធន្ទរាគៈក្នុងរូបជាដើមរបស់សត្វទាំងឡាយ មិនមានក្នុងព្រះអង្គ ទើបទ្រង់អនុញ្ញាតបរិយាយដទៃទៀត ។

ព្រាហ្មណ៍ឃើញការមិនធ្វើកម្ម គឺការប្រព្រឹត្តដែលជាកុសល មានការថ្វាយបង្គំជាដើម ដែលបុគ្គលចម្រើនវ័យក្នុងលោក អ្នកស្រុកគប្បីធ្វើ ទើបពោលទោសព្រះមានព្រះភាគទៀតថា ជាអកិរិយវាទ ពោលការមិនធ្វើ ។ តែព្រោះហេតុដែលព្រះមានព្រះភាគ ត្រាស់ការមិនធ្វើកាយទុច្ចរិតជាដើម ដូច្នោះ កាលទ្រង់ឃើញភាពជាអ្នកមានវាទៈថាមិនធ្វើក្នុងព្រះអង្គ ទើបទ្រង់អនុញ្ញាតបរិយាយដទៃទៀត ។ ក្នុងសេចក្តីនោះ វៀរកាយទុច្ចរិតជាដើមចេញ អកុសលធម៌ដ៏សេស គប្បីជ្រាបថា អកុសលបាបធម៌ច្រើនយ៉ាង ។

ព្រាហ្មណ៍មិនឃើញកម្ម មានការថ្វាយបង្គំជាដើមនោះ ក្នុងព្រះមានព្រះភាគទៀត សម្គាល់ថា បែបផែនក្នុងលោក ប្រពៃណីលោកនេះ នឹងដាច់សូន្យ ព្រោះអាស្រ័យសេចក្តីនេះ ទើបពោលទោសព្រះមានព្រះភាគថា ជាឧច្ឆេទវាទ ។ ព្រោះព្រះមានព្រះភាគត្រាស់ការដាច់សូន្យនៃរាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ និងទោសៈ ដែលសម្បយុត្តដោយអកុសលចិត្តទាំង ២ ដោយអនាគាមិមគ្គ ម្យ៉ាងទៀត ត្រាស់ការដាច់សូន្យនៃមោហៈ ដែលជាដែនកើតអកុសលទាំងពួង ដោយអរហត្តមគ្គ ត្រាស់ការដាច់សូន្យនៃអកុសលធម៌ទាំងឡាយ វៀរកិលេស ៣ យ៉ាងនោះ ដោយមគ្គទាំង ៤ តាមសមគួរ ។ ដូច្នោះ កាលទ្រង់ឃើញវាទៈថាដាច់សូន្យនោះ មានក្នុងព្រះអង្គ ទើបទ្រង់

អនុញ្ញាតបរិយាយដទៃទៀត ។ ព្រាហ្មណ៍សម្គាល់ថា សមណគោតមប្រហែល ជាស្អប់កម្ម គឺការប្រព្រឹត្តល្អមានការថ្វាយបង្គំជាដើម នូវបុគ្គលចម្រើនវ័យ នេះ ដោយហេតុនោះ ទើបមិនធ្វើការថ្វាយបង្គំជាដើមនេះ ទើបពោលទោស ព្រះមានព្រះភាគទៀតថាជា **ជេគុច្ឆី** ។ តែព្រោះហេតុដែលព្រះមានព្រះភាគ ទ្រង់ស្អប់ខ្ពើមកាយទុច្ចរិតជាដើម គឺទ្រង់ខ្ពើម ទ្រង់ខ្មាសកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត និងការដល់ព្រម កិរិយាដែលដល់ព្រម ការព្រមព្រៀងនៃ អកុសលបាបធម៌ច្រើនយ៉ាងទាំងអស់ ដូចបុរសស្រឡាញ់ការស្អាត ស្អប់ខ្ពើម លាមក ដូច្នោះ កាលទ្រង់ឃើញការខ្ពើមនោះក្នុងព្រះអង្គ ទើបទ្រង់អនុញ្ញាត ហេតុដទៃទៀត ។ តតិយាវិភត្តិថា **កាយទុច្ចរិតេន** ជាដើម ក្នុងបាលីនោះ គប្បីជ្រាបថា ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ ព្រាហ្មណ៍មិនឃើញកម្ម មានការ ថ្វាយបង្គំជាដើមនោះឯងក្នុងព្រះមានព្រះភាគទៀត សម្គាល់ថា ព្រះសមណ- គោតមនេះកម្ចាត់ គឺធ្វើកម្មរបស់បុគ្គលចម្រើនបំផុតក្នុងលោកនេះឲ្យវិនាសទៅ ម្យ៉ាងទៀត ព្រោះទ្រង់មិនធ្វើសាមីចិកម្មនេះ ដូច្នោះ ព្រះសមណគោតមនេះ គួរកម្ចាត់ គួរសង្កត់សង្កិន ទើបពោលទោសព្រះមានព្រះភាគថា **វេនយិក** គឺអ្នកកម្ចាត់ ។ ក្នុងសេចក្តីនោះ មានវចនត្ថៈ គឺអត្ថរបស់ពាក្យដូចតទៅនេះ ថា ឈ្មោះថា វិន័យ ព្រោះកម្ចាត់ អធិប្បាយថា ធ្វើឲ្យវិនាសអន្តរាយ វិន័យ នោះឯងជា **វេនយិក** ។ ម្យ៉ាងទៀត ឈ្មោះថា **វេនយិក** ព្រោះគួរកម្ចាត់ អធិប្បាយថា គួរសង្កត់សង្កិន ។ តែព្រោះហេតុដែលព្រះមានព្រះភាគទ្រង់

សម្តែងធម៌ដើម្បីកម្ចាត់ ដើម្បីស្ងប់រម្ងាប់រាគៈជាដើម ដូច្នោះ ទើបទ្រង់ជាអ្នកកម្ចាត់ ។ ក្នុងបទថា **វេនយិកោ** នេះ មានអត្ថដូចតទៅនេះថា ឈ្មោះថា **វេនយិក** ព្រោះទ្រង់សម្តែងធម៌ដើម្បីកម្ចាត់ ។ ការប្រព្រឹត្តរបស់តទ្ធិត គឺគោលវេយ្យាករណ៍មួយប្រភេទ មានន័យវិចិត្រសន្ទឹកសន្ធាប់ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាអ្នកកម្ចាត់កិលេសនោះក្នុងព្រះអង្គ ទើបទ្រង់អនុញ្ញាតបរិយាយដទៃទៀត ។

ព្រោះហេតុដែលលោកិយជន កាលធ្វើសាមីចិកម្ម មានការថ្វាយបង្គំជាដើម រមែងធ្វើបុគ្គលដែលចម្រើនដោយវ័យឲ្យត្រេកអរ តែកាលមិនធ្វើរមែងដុតរោល បៀតបៀន ធ្វើនូវទោមនស្សឲ្យកើតឡើង ដល់បុគ្គលដែលចម្រើនដោយវ័យទាំងនោះ ដល់ព្រះមានព្រះភាគ ទ្រង់មិនធ្វើសាមីចិកម្មនោះ ដូច្នោះ ទើបព្រាហ្មណ៍សម្គាល់ថា ព្រះសមណគោតមនេះ ដុតរោលបុគ្គលដែលចម្រើនដោយវ័យ គឺសម្គាល់ថា ព្រះសមណគោតមនេះ ជាមនុស្សកំព្រាឥតមានទីពឹង ព្រោះវៀរចាកការប្រព្រឹត្តល្អ ទើបពោលទោសព្រះមានព្រះភាគទៀតថាជា **តបស្សី** គឺជាអ្នកដុតរោល ។ ក្នុងបទថា **តបស្សី** នោះ អត្ថនៃបទទាំងនោះ ឈ្មោះថា **តប** ព្រោះដុតរោល អធិប្បាយថា បៀតបៀន ។ ពាក្យថា **តប** នេះ ជាឈ្មោះនៃការធ្វើសាមីចិកម្ម ។ ឈ្មោះថា **តបស្សី** ព្រោះមានតបៈជាគ្រឿងដុត ។ ក្នុងអត្ថវិកប្បទី ២ មិនពិចារណាព្យញ្ជនៈ ហៅមនុស្សកំព្រាក្នុងលោកថា **តបស្សី** គឺអ្នកដុតបំផ្លាញ ។ តែព្រោះព្រះ

មានព្រះភាគ ទ្រង់រាប់បានថាជា **តបស្សី** ជាអ្នកដុតកម្ដៅ ព្រោះទ្រង់លះអកុសលធម៌ ដែលហៅថា **តបនីយ** ព្រោះដុតសត្វលោកបាន ដូច្នោះ គ្រាទ្រង់ឃើញភាពជាបុគ្គលដុតបំផ្លាញ មានក្នុងព្រះអង្គ ទើបទ្រង់អនុញ្ញាតបរិយាយដទៃទៀត ។ ក្នុងបទថា **តបស្សី** នោះ មានអត្ថនៃពាក្យដូចតទៅនេះថា អកុសលធម៌ទាំងឡាយ ឈ្មោះថា **តប** ព្រោះដុតរោល ។ ពាក្យនេះជាឈ្មោះរបស់អកុសលធម៌ទាំងឡាយ ។ ឈ្មោះថា **តបស្សី** ព្រោះបន្សាត់ទៅគ្រវែងទៅ លះទៅ កម្ចាត់តបៈ គឺអកុសលធម៌ទាំងនោះ ។

ព្រាហ្មណ៍នៅសម្គាល់នៅឡើយថា កម្ម មានការថ្វាយបង្គំជាដើមនោះរមែងប្រព្រឹត្តទៅដើម្បីគព្ភសម្បត្តិក្នុងទេវលោក គឺដើម្បីបានចំពោះនូវបដិសន្ធិក្នុងទេវលោក និងឃើញថា សាមីចិកម្ម មានការថ្វាយបង្គំជាដើមនោះ មិនមានក្នុងព្រះមានព្រះភាគ ទើបពោលទោសព្រះមានព្រះភាគថា **អបគព្ភ** ជាអ្នកប្រាសចាកគភ៌ ។ម្យ៉ាងទៀត កាលនឹងសម្ដែងទោសក្នុងការបដិសន្ធិក្នុងគភ៌មាតារបស់ព្រះមានព្រះភាគ ដោយអំណាចសេចក្ដីក្រោធ ទើបពោលយ៉ាងនោះ ។ ក្នុងបទថា **អបគព្ភ** នោះ មានអត្ថដូច្នេះថា ឈ្មោះថា **អបគព្ភ** ព្រោះប្រាសចាកគភ៌ អធិប្បាយថា មិនគួរកើតឡើងក្នុងទេវលោក ។ ម្យ៉ាងទៀត ឈ្មោះថា **អបគព្ភ** ព្រោះមានគភ៌ដែលកើតហើយ អធិប្បាយថា ឈ្មោះថា មានចំណែកបានគភ៌ ដែលអាក្រក់តទៅ ព្រោះឆ្ងាយចាកគភ៌ក្នុងទេវលោក ឬថា ព្រះមានព្រះភាគ មានការនៅក្នុងគភ៌ព្រះមាតាតែម្យ៉ាងហើយ

តែព្រោះ គព្ភសេយ្យា គឺការដេកក្នុងគភ៌នៃព្រះមានព្រះភាគ ទៅប្រាសហើយ ដូច្នោះ កាលទ្រង់ឃើញការប្រាសចាកគភ៌នោះក្នុងព្រះអង្គ ទើបទ្រង់អនុញ្ញាត បរិយាយដទៃទៀត ។ ក្នុងព្រះបាលីនេះ បទទាំងនេះថា ម្នាលព្រាហ្មណ៍ ការដេកក្នុងគភ៌ ការកើតក្នុងភពថ្មីតទៅទៀត ដែលបុគ្គលណាលះបានហើយ ដូច្នេះ គប្បីឃើញអត្ថយ៉ាងនេះថា ម្នាលព្រាហ្មណ៍ ការដេកក្នុងគភ៌ និងការកើតក្នុងភព ក្នុងអនាគតកាល ដែលបុគ្គលណាលះបានហើយ ព្រោះមានហេតុដែលអ្នកខាងលើកម្ចាត់ហើយ ។ ក្នុងអធិការនេះ លោកកាន់យកជលាពុជកំណើត ដោយ **គព្ភសេយ្យ** សព្ទ ។ម្យ៉ាងទៀត គប្បីឃើញក្រៅអំពីនេះដោយ **បុនព្ភវាភិនិព្វត្តិ** សព្ទ ។ ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងពាក្យនេះយ៉ាងនេះថា ការដេករបស់សត្វដែលកើតក្នុងគភ៌ ឈ្មោះថា **គព្ភ-សេយ្យា** ការកើត គឺភពថ្មី ឈ្មោះថា **បុនព្ភវាភិនិព្វត្តិ**។ ដូចកាលពោលថា វិញ្ញាណដ្ឋិតិ ទីតាំងដទៃក្រៅអំពីវិញ្ញាណរមែងមិនមាន យ៉ាងណា ក្នុងរឿងនេះក៏ដូច្នោះ មិនគួរយល់ថា ការដេក ជារបស់ដទៃក្រៅអំពីគភ៌ក៏មាន ។ ម្យ៉ាងទៀត ឈ្មោះថា ការកើត ហេតុដែលជាភពថ្មីខ្លះ មិនជាភពថ្មីខ្លះមាន តែក្នុងទីនេះ បំណងយកការកើត ដែលជាភពថ្មី ព្រោះដូច្នោះ ទើបពោលថា ការកើត គឺភពថ្មី ឈ្មោះថា ការកើតថ្មី ដូច្នេះ ។

ព្រាហ្មណ៍ សូម្បីជេរដោយអក្កោសវត្ថុ មានភាពជាអ្នកមិនមានរសជាតិជាដើម តាំងអំពីពេលដែលមកដល់ហើយ ដោយប្រការយ៉ាងនោះ

ព្រះមានព្រះភាគដែលជាធម្មិស្សរ ធម្មរាជា ធម្មសាមី គឺជាម្ចាស់របស់ធម៌ ដ៏ជាតថាគត ទ្រង់ពិចារណាមើលព្រាហ្មណ៍ ដោយចក្ខុដ៏ត្រជាក់ ដោយសេចក្ដីករុណា ទ្រង់សម្រេចធម្មធាតុណាហើយ ឈ្មោះថា ដល់ព្រមដោយការពីរោះរណ្ដំនៃទេសនានោះ ព្រោះធម្មធាតុនោះ ទ្រង់ដឹងច្បាស់ល្អហើយ កាលទ្រង់កម្ចាត់ងងឹតអន្ធការ ក្នុងហទយៈរបស់ព្រាហ្មណ៍ ដូចព្រះចន្ទពេញវង់ អណ្ដែតឰដ៏នភា ប្រាសចាកពពក និងដូចព្រះអាទិត្យក្នុងសរទកាល ទើបទ្រង់សម្ដែងអក្កោសវត្ថុទាំងនោះឯងឲ្យជារបស់ដទៃ ដោយបរិយាយនោះៗ កាលទ្រង់ប្រកាសការផ្សាយទៅនៃព្រះករុណារបស់ព្រះអង្គ គុណលក្ខណៈនៃតាទិបុគ្គល និងភាពជាបុគ្គលមានចិត្តស្មើដោយផែនដី និងជាអ្នកមានអកុប្ប-ធម៌ គឺធម៌ដែលមិនកម្រើក ដែលទ្រង់បានហើយ ព្រោះទ្រង់មិនញាប់ញ័រដោយលោកធម៌ ៨ ដដែលទៀត ទើបទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះរមែងកំណត់ភាពដែលខ្លួនមនុស្សចាស់ ដោយប្រការ មានសក់ស្កូវ ធ្មេញបាក់ស្បែកយុរយារជាដើមតែម្យ៉ាង ទាំងមិនដឹងថា ខ្លួនត្រូវជាតិជាប់តាម ត្រូវជរាកៀនទៅ ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈតាមកម្ចាត់ ស្លាប់ថ្ងៃនេះហើយ ស្អែកឡើងក៏នឹងក្លាយជាទារកដេកផ្ងារទៀត ។ តែព្រាហ្មណ៍នេះ មកកាន់សម្នាក់តថាគត ដោយការខ្មីឃ្មាតដ៏ច្រើន ចូរការមករបស់ព្រាហ្មណ៍នោះប្រកបដោយប្រយោជន៍ចុះ កាលទ្រង់សម្ដែងព្រះអង្គ ថាជាអ្នកកើតមុន មិនមានបុគ្គលប្រៀបផ្ទៀបក្នុងលោកនេះ ទើបទ្រង់បន្ថែមព្រះធម្មទេសនាដល់

ព្រាហ្មណ៍ ដោយន័យថា **សេយ្យថាបិ ព្រាហ្មណ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សេយ្យថាបិ** ជាដើម គប្បីជ្រាបដោយន័យដូចពោលហើយខាងដើមនោះឯង ឯការប្លែកគ្នា មានដូច្នេះថា ដោយន័យដូចពោលខាងដើមនោះឯង កូនមាន់ទាំងនោះ ទទះស្លាប ស្រែកចេញទៅសមគួរដល់ខណៈនោះ ហើយបណ្តាកូនមាន់ទាំងនោះ ដែលចេញទៅយ៉ាងនោះ កូនមាន់ណាចេញមុន កូនមាន់នោះ គេហៅថា បង ព្រោះហេតុនោះ ព្រះមានព្រះភាគ បំណងធ្វើភាពដែលព្រះអង្គជាបង ជាអ្នកចម្រើនបំផុតឲ្យសម្រេចដោយឧបមានោះ ទើបត្រាស់សួរព្រាហ្មណ៍ថា **យោ នុ ខោ តេសំ កុក្កុដច្ឆាបកានំ ។បេ។ កិន្តិ ស្វាស្ស វចនីយោ** បណ្តាកូនមាន់ទាំងនោះ កូនមាន់ណាញាស់មុន ។បេ។ កូនមាន់នោះគួរហៅដូចម្តេច ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **កុក្កុដច្ឆាបកានំ** ប្រែថា បណ្តាកូនមាន់ទាំងឡាយ ។ បទថា **កិន្តិ ស្វាស្ស វចនីយោ** សេចក្តីថា កូនមាន់នោះគួរហៅដូចម្តេច គឺគប្បីហៅយ៉ាងណា ហៅថា បង ឬប្អូន ។

បទថា **ជេដ្ឋោតិស្ស ភោ គោតម វចនីយោ** សេចក្តីថា បពិត្រព្រះគោតម កូនមាន់នោះគួរហៅថា បង ។ បើមានគេសួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះបណ្តាកូនមាន់ទាំងនោះ កូនមាន់នោះ ចាស់ជាងគេទាំងអស់ អធិប្បាយថា ព្រោះកូនមាន់នោះ ចាស់ជាងកូនមាន់ទាំងនោះ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ធ្វើឧបមាឲ្យសម្រេចផលដល់ព្រាហ្មណ៍នោះ ទើប

ត្រាស់ថា **ឯវមេវ ខោ** ដូច្នេះជាដើម អធិប្បាយថា តថាគតក៏ដូចកូនមាន់នោះ ។ បទថា **អវិជ្ជាគតាយ បជាយ** សេចក្តីថា ការមិនដឹង ហៅថា អវិជ្ជា ។ ពួកសត្វដែលធ្លាក់នៅក្នុងអវិជ្ជា គឺការមិនដឹងនោះ ។ បទថា **បជាយ** នេះ ជាឈ្មោះរបស់សត្វ ។ អធិប្បាយថា ក្នុងសត្វទាំងឡាយដែលចូលទៅខាងក្នុងសម្បក គឺអវិជ្ជា ។ បទថា **អណ្ឌភូតាយ** បានដល់ មានហើយ កើតហើយ កើតព្រមហើយក្នុងពង ។ ដូចសត្វពួកខ្លះ កើតក្នុងកំណើតពង ហៅថា អណ្ឌកូត យ៉ាងណា ពួកសត្វទាំងឡាយនេះក៏ដូច្នោះ ហៅថា អណ្ឌកូត ព្រោះកើតក្នុងពង គឺអវិជ្ជា ។ បទថា **បរិយោនទ្ធាយ** បានដល់ ដែលសម្បក គឺអវិជ្ជានោះរិតរុំ គឺចងដោយជុំវិញ ។ បទថា **អវិជ្ជណ្ឌកោសំ បទាលេត្វា** បានដល់ ទម្លាយសម្បកដែលសម្រេចដោយអវិជ្ជានោះ ។ បទថា **ឯកោវ លោកេ** សេចក្តីថា តថាគតប៉ុណ្ណោះជាបុគ្គលឯក មិនមានបុគ្គលជាគម្រប់ ២ ក្នុងលោកសន្និវាសទាំងមូល ។ បទថា **អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ** បានដល់ ព្រះបញ្ញាជាគ្រឿងត្រាស់ដឹងប្រពៃ ដោយព្រះអង្គឯង ប្រាសចាកបុគ្គលក្រៃលែងជាង គឺប្រសើរបំផុតជាងគេបង្អស់ ។ ម្យ៉ាងទៀត ព្រះបញ្ញាជាគ្រឿងត្រាស់ដឹងដ៏ប្រសើរល្អ ។ ពាក្យថា **ពោធិ** នេះ ជាឈ្មោះរបស់អរហត្តមគ្គញ្ញាណផង ជាឈ្មោះរបស់ព្រះសព្វញ្ញុតញ្ញាណផង ។ សូម្បីឈ្មោះទាំង ២ ក៏សម ។ សួរថា អរហត្តមគ្គរបស់បុគ្គលដទៃជាបញ្ញាគ្រឿងត្រាស់ដឹងដ៏កំពូលឬ ។ ឆ្លើយថា មិនដូច្នោះឡើយ សួរថា ព្រោះហេតុអ្វី ព្រោះមិនឲ្យ

នូវគុណគ្រប់យ៉ាង ។ បណ្តាបុគ្គលទាំងនោះ អរហត្តមគ្គ រមែងឲ្យចំពោះអរហត្តផលដល់បុគ្គលខ្លះ ឲ្យវិជ្ជា ៣ ដល់បុគ្គលខ្លះ ឲ្យអភិញ្ញា ៦ ដល់បុគ្គលខ្លះ ឲ្យបដិសម្ភិទា ៤ ដល់បុគ្គលខ្លះ ឲ្យសាវកបារមីញាណដល់បុគ្គលខ្លះ សម្រាប់ព្រះបច្ចេកពុទ្ធទាំងឡាយ ឲ្យចំពោះបច្ចេកពោធិញ្ញាណប៉ុណ្ណោះ ចំណែករបស់ព្រះពុទ្ធទាំងឡាយ ឲ្យនូវគុណសម្បត្តិគ្រប់យ៉ាង ដូចការអភិសេកឲ្យនូវភាពជាធំក្នុងលោកទាំងពួងដល់ព្រះរាជា ព្រោះហេតុនោះ បញ្ញាជាគ្រឿងត្រាស់ដឹងដ៏កំពូល ទើបមិនមានដល់បុគ្គលដទៃ ។ បទថា **អភិសម្ពុទ្ធោ** បានដល់ ដឹងក្រៃលែងហើយ ចាក់ធ្លុះហើយ អធិប្បាយថា សម្រេចហើយ ។

ឥឡូវនេះ គប្បីប្រៀបធៀបសាធក គឺឧបមាដែលព្រះមានព្រះភាគត្រាស់ដោយន័យជាដើមថា **សេយ្យថាបិ** នោះ ដោយអត្ថហើយ ជ្រាបយ៉ាងនេះថា ដូចមេមាន់នោះធ្វើកិរិយា ៣ មានការដេកក្រាបពងរបស់ខ្លួន យ៉ាងណា ការដែលព្រះមានព្រះភាគ កាលនៅជាពោធិសត្វ ប្រថាប់គង់ត្រង់ពោធិបល្ល័ង្ក ធ្វើអនុបស្សនាបញ្ញា ឃើញរឿយៗ ៣ យ៉ាង គឺអនិច្ចំ ទុក្ខំ អនត្តា ក្នុងសន្តានរបស់ព្រះអង្គ ក៏ដូច្នោះ ការមិនធ្វើវិបស្សនាញាណឲ្យវិនាសទៅ ដោយការញុំាងអនុបស្សនា ៣ ប្រការ ឲ្យបរិបូណ៌នៃព្រះមានព្រះភាគ កាលជាព្រះពោធិសត្វ ដូចពងដែលនឹងស្អាប់ ដោយការធ្វើកិរិយា ៣ របស់មេមាន់ឲ្យសម្បូរ ការដែលព្រះមានព្រះភាគ កាលជាព្រះពោធិសត្វ ទម្លាយនូវការជាប់ជំពាក់ដោយអំណាចការប្រាថ្នា ដែលទៅតាមភពទាំង ៣ ដោយការ

ធ្វើអនុបស្សនា ៣ ឲ្យបរិបូណ៌ ដូចមេមាន់ធ្វើដំរំអិលរបស់ពងឲ្យខះទៅ ដោយការធ្វើកិរិយាទាំង ៣ យ៉ាង គឺក្រាប ធ្វើឲ្យកក់ក្តៅ ឲ្យនូវក្លិន ការដែលសម្បកពង គឺអវិជ្ជា ជារបស់ស្តើង ក៏ដោយការដែលព្រះមានព្រះភាគ កាលជាព្រះពោធិសត្វ ទ្រង់ធ្វើអនុបស្សនាទាំង ៣ ឲ្យបរិបូណ៌ ដូចការដែលសម្បកពងជារបស់ស្តើង ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ដូច្នោះ ។ ការដែលវិបស្សនាញាណជាគុណជាតិរឹងមាំ ផូរផង់ និងមុតស្រួច ក៏ព្រោះព្រះមានព្រះភាគ កាលជាព្រះពោធិសត្វ ទ្រង់ធ្វើអនុបស្សនាទាំង ៣ ឲ្យសម្បូរ ប្រៀបដូចក្រចក និងចំពុះរបស់កូនមាន់ជារបស់រឹង ដោយការដែលមេមាន់ធ្វើកិរិយាទាំង ៣ ដូច្នោះ ពេលដែលវិបស្សនាញាណវិវឌ្ឍន៍ទៅ ពេលពង្រីកទៅ ពេលកាន់យកបន្ទប់ ដោយការដែលព្រះមានព្រះភាគ កាលជាព្រះពោធិសត្វ ទ្រង់ធ្វើអនុបស្សនាទាំង ៣ ឲ្យបរិបូណ៌ ប្រៀបដូចកាលដែលកូនមាន់វិវឌ្ឍន៍ទៅ ដោយការដែលមេមាន់ធ្វើកិរិយា ៣ ដូច្នោះ គប្បីជ្រាបពេលដែលធ្វើវិបស្សនាញាណឲ្យកាន់យកបន្ទប់ ទម្លាយសម្បក គឺអវិជ្ជា ដោយអរហត្តមគ្គដែលសម្រេចដោយលំដាប់ ទទះស្លាប គឺអភិញ្ញា ៦ ធ្វើឲ្យជាក់ច្បាស់នូវពុទ្ធគុណទាំងអស់ដោយសួស្តី ដោយការដែលព្រះមានព្រះភាគ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឲ្យបរិបូណ៌ ដូចកាលដែលកូនមាន់ទម្លាយសម្បកដោយចុងក្រចក ឬចំពុះ បើកស្លាបចោះចេញដោយសួស្តី ដោយការធ្វើកិរិយាទាំង ៣ របស់មេមាន់ ដូច្នោះ ។

បទថា **អហញ្ហិ ព្រាហ្មណ ជេដ្ឋោ សេដ្ឋោ លោកស្ស** សេចក្តីថា ម្នាលព្រាហ្មណ៍ បណ្តាកូនមាន់ទាំងនោះ កូនមាន់ដែលទម្លាយសម្បកកើតឡើងមុន ជាកូនមាន់ច្បង យ៉ាងណា បណ្តាពួកសត្វដែលធ្លាក់នៅក្នុងអវិជ្ជា តថាគតនេះឯង ជាអ្នកចម្រើនជាង គឺជាអ្នកចម្រើនបំផុត ព្រោះទម្លាយសម្បកកើតឡើងមុន ជាកូនមាន់ច្បង យ៉ាងណា បណ្តាពួកសត្វដែលធ្លាក់នៅក្នុងអវិជ្ជា តថាគតនេះឯង ឈ្មោះថា ជាអ្នកចម្រើនជាង គឺជាអ្នកចម្រើនបំផុត ព្រោះទម្លាយសម្បក គឺអវិជ្ជានោះ កើតក្នុងអរិយជាតិមុន ដូច្នោះ ម្យ៉ាងទៀត ឈ្មោះថា ប្រសើរបំផុត ព្រោះមិនមានបុគ្គលប្រៀបបានដោយគុណទាំងពួង ។

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសភាពដែលព្រះអង្គ ជាបុគ្គលចម្រើនបំផុត ប្រសើរបំផុត កំពូលបំផុត ដល់ព្រាហ្មណ៍យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងបដិបទា ដែលជាហេតុ ឲ្យទ្រង់សម្រេចដល់ភាពជាបុគ្គលចម្រើនបំផុត និងប្រសើរបំផុតនោះ តាំងអំពីខាងដើម ទើបត្រាស់ពាក្យជាដើមថា **អារទ្ធំ ខោ បន មេ ព្រាហ្មណ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អារទ្ធំ ខោ បន មេ ព្រាហ្មណ វីរិយំ អហោសិ** សេចក្តីថា ម្នាលព្រាហ្មណ៍ ភាពជាបុគ្គលចម្រើនបំផុត និងប្រសើរបំផុត ជាកំពូល ដូច្នេះ សម្រេចដោយការខ្ជិលច្រអូស ដោយការមិនមានស្មារតី ដោយការអណ្តែតអណ្តូង ដោយចិត្តដែលរាយមាយ ក៏មិនមែន ។ ម្យ៉ាងទៀត តថាគតមានសេចក្តីព្យាយាមប្រារព្ធហើយ ដើម្បីសម្រេចភាពជាបុគ្គលចម្រើនបំផុត និងប្រសើរបំផុត ដូច្នោះ ។

តថាគតអង្គុយត្រង់ពោធិមណ្ឌលដ្ឋាន បានប្រារព្ធ ផ្គងសេចក្ដីព្យាយាម មានសម្មប្បធាន ៤ ដែលប្រព្រឹត្តទៅមិនធូរថយ ។ សេចក្ដីព្យាយាមនោះរបស់តថាគត បានជាសេចក្ដីព្យាយាមមិនធូរថយ ព្រោះបានប្រារព្ធហើយនោះឯង និងមានតែសេចក្ដីព្យាយាមតែម្យ៉ាងក៏មិនមែន សូម្បីសតិក៏ឈ្មោះថា តថាគតចូលទៅតម្កល់ទុក មានមុខត្រង់ឆ្ពោះអារម្មណ៍ និងជាសតិ មិនភ្លេចភ្លាំង ព្រោះជាធម្មជាតិចូលទៅតាំងមាំហើយ ។ បទថា **បស្សទ្ធោ កាយោ អសារទ្ធោ** សេចក្ដីថា សូម្បីកាយរបស់តថាគត ក៏ជាសភាវៈស្ងប់ ដោយអំណាចកាយ-បស្សទ្ធិ និងចិត្តបស្សទ្ធិ ។ ក្នុងការស្ងប់នេះ ហេតុដែលមាននាមកាយស្ងប់ សូម្បីរូបកាយ ក៏ឈ្មោះថា ជាការស្ងប់ដូចគ្នា ដូច្នោះ ទើបមិនត្រាស់ឲ្យប្លែកគ្នាថា **នាមកាយោ រូបកាយោ** តែត្រាស់ថា **បស្សទ្ធោកាយោ** ប្រែថា កាយស្ងប់ ។ បទថា **អសារទ្ធោ** សេចក្ដីថា កាយនោះ ឈ្មោះថា ស្ងប់ អធិប្បាយថា ប្រាសចាកការក្រវល់ក្រវាយ ព្រោះជាកាយស្ងប់ពិតនោះឯង ។ បទថា **សមាហិតំ ចិត្តំ ឯកគ្គំ** សេចក្ដីថា សូម្បីចិត្ត តថាគតក៏តាំងទុកដោយប្រពៃ គឺតាំងទុកដោយល្អ ចុះស៊ប់ មានអារម្មណ៍តែមួយ គឺមិនញាប់ញ័រ ជាចិត្តមិនច្រួច្រា ព្រោះជាចិត្តតាំងមាំនោះឯង ។ ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់ត្រាស់បដិបទាជាចំណែកខាងដើមរបស់ឈាន ឥឡូវនេះ កាលទ្រង់សម្ដែងគុណវិសេស ផ្ដើមអំពីបឋមជ្ឈានដែលទ្រង់សម្រេចដោយបដិបទានេះ រហូតដល់វិជ្ជា ៣ ជាទីបំផុត ទើបត្រាស់ពាក្យ

ជាដើមថា **សោ ខោ អហំ** ដូច្នេះ ពាក្យដែលត្រាស់នោះ ជាបឋម មិនបាន លើកឡើងវិនិច្ឆ័យនោះ បានពោលល្អហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គឯណោះ ។

ក្នុងបទថា **អយំ ខោ មេ ព្រាហ្មណ** ដូច្នេះជាដើម មានវិនិច្ឆ័យដូចតទៅនេះថា បទថា **វិជ្ជា** គឺដែលឈ្មោះថា វិជ្ជា ព្រោះអត្ថថា ធ្វើនូវការដឹងច្បាស់ ។ សួរថា ធ្វើនូវការដឹងច្បាស់អ្វី ។ ឆ្លើយថា ដឹងច្បាស់នូវបុព្វេនិវាសញ្ញាណ គឺដឹងខន្ធដែលនៅអាស្រ័យក្នុងកាលមុន ។ បទថា **អវិជ្ជា** បានដល់ មោហៈដែលបិទបាំងវិជ្ជានោះ ព្រោះអត្ថថា ធ្វើនូវការមិនដឹងច្បាស់នូវបុព្វេនិវាសញ្ញាណនោះ ។ បទថា **តមោ** សេចក្តីថា មោហៈនោះឯងឈ្មោះថា **តម** គឺការងងឹត ព្រោះអត្ថថា បិទបាំងវិជ្ជានោះ ។ បទថា **អាលោកោ** សេចក្តីថា វិជ្ជានោះឯង ឈ្មោះថា អាលោក ព្រោះអត្ថថា ធ្វើនូវការភ្លឺស្វាង ។ ក្នុងបទថា **អាលោកោ** នេះ មានអត្ថដូច្នេះថា វិជ្ជា តថាគតសម្រេចហើយ ។ ពាក្យដ៏សេសអំពីអាលោកោ ជាពាក្យសរសើរ ។ ក្នុងសេចក្តីនេះប្រកបដោយអត្ថដូចតទៅនេះថា វិជ្ជានេះឯង តថាគតសម្រេចហើយ កាលតថាគតសម្រេចវិជ្ជាហើយ អវិជ្ជាក៏អន្តរធានទៅ អធិប្បាយថា វិនាសទៅ ។ ព្រោះហេតុអ្វី ព្រោះវិជ្ជាកើតឡើង ។ ក្នុងបទទាំង ២ ក្រៅពីនេះ ក៏មានន័យដូច្នេះ ។ បទថា **តំ** ក្នុងបទថា **យថា តំ** នេះ ត្រឹមតែជានិបាត ឈ្មោះថា បុគ្គលមិនប្រមាទ ព្រោះមិននៅប្រាសចាកសតិ ឈ្មោះថា បុគ្គលមានសេចក្តីព្យាយាម ព្រោះមានព្យាយាមជាគ្រឿងដុតកិលេស ឈ្មោះថា

មានខ្លួនបញ្ជូនទៅ អធិប្បាយថា ជាអ្នកមានចិត្តបញ្ជូនទៅហើយ ព្រោះមិនអាល័យក្នុងកាយ និងជីវិត ។ លោកអធិប្បាយដូចតទៅនេះថា កាលបុគ្គលមិនប្រមាទ មានសេចក្ដីព្យាយាម មានខ្លួនបញ្ជូនទៅ អវិជ្ជា គប្បីត្រូវកម្ចាត់ទៅ វិជ្ជាគប្បីកើតឡើង ងងឹតគប្បីត្រូវកម្ចាត់ទៅ ពន្លឺគប្បីកើតឡើង យ៉ាងណា អវិជ្ជា កាលតថាគតកម្ចាត់ហើយ វិជ្ជាកើតឡើង ងងឹត តថាគតកម្ចាត់ហើយ ពន្លឺកើតឡើង ដូច្នោះដូចគ្នា ។ តថាគតបានផលដ៏សមគួរដល់ការប្រកបសេចក្ដីព្យាយាមនោះឯង ។

បទថា **អយំ ខោ មេ ព្រាហ្មណ បឋមា អភិនិព្ភិទា អហោសិ កុក្កុដច្ឆាបស្សេវ អណ្ឌកោសម្ហា** សេចក្ដីថា ម្នាលព្រាហ្មណ៍ ការទម្លាយសម្បកគឺអវិជ្ជាដែលបិទបាំងខន្ធ ដែលធ្លាប់នៅអាស្រ័យក្នុងកាលមុនដោយចំពោះ គឺបុព្វេនិវាសានុស្សតិញ្ញាណ ការដឹងក្នុងការរឭកជាតិខាងដើម ហើយចាក់ធ្លុះបានគ្រាទី ១ ចេញទៅគ្រាទី ១ កើតជាអរិយៈគ្រាទី ១ នេះឯង មានហើយដល់តថាគត ដូចកូនមាន់ទម្លាយសម្បកដោយចំពុះ ឬចុងក្រចកហើយរំលៀកខ្លួនចេញទៅអំពីសម្បកនោះ ចម្រើនធំធាត់ក្នុងហ្វូងមាន់ ដូច្នោះ ។ ន័យក្នុងបុព្វេនិវាសកថា ពោលដោយការដឹងរឿងខន្ធដែលជាទីនៅអាស្រ័យ ក្នុងកាលមុនត្រឹមនេះប៉ុណ្ណោះសិន ។

ឯក្នុងចុតូបបាតកថា ពោលដោយការដឹងចុតិ និងបដិសន្ធិរបស់សត្វមានវិនិច្ឆ័យដូចតទៅនេះថា បទថា **វិជ្ជា** បានដល់ វិជ្ជា គឺទិព្វចក្ខុញ្ញាណ ។

បទថា **អវិជ្ជា** បានដល់ អវិជ្ជាដែលបិទបាំងចុតូបបាតញ្ញាណ ដូចដែលពោលក្នុងបុព្វេនិវាសកថាថា ទម្លាយសម្បកពង គឺអវិជ្ជាដែលបិទបាំងខន្ធដែលនៅអាស្រ័យក្នុងកាលមុនដោយចំពុះ គឺបុព្វេនិវានុស្សតិញ្ញាណ ដូច្នេះ យ៉ាងណាក្នុងទីនេះ គួរពោលថា ទម្លាយសម្បក គឺអវិជ្ជាដែលបិទបាំងចុតិ និងបដិសន្ធិរបស់សត្វ ដោយចំពុះ គឺចុតូបបាតញ្ញាណដូច្នេះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការសម្រេចអាសវក្ខយញ្ញាណដែលកំណត់យកដោយបច្ចវេក្ខណញ្ញាណដល់ព្រាហ្មណ៍ ទើបត្រាស់ពាក្យជាដើមថា **អយំ ខោ មេ ព្រាហ្មណ តតិយា វិជ្ជា** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **វិជ្ជា** បានដល់ វិជ្ជា គឺអរហត្តមគ្គញ្ញាណ ។ បទថា **អវិជ្ជា** បានដល់ អវិជ្ជាដែលបិទបាំងសច្ចៈទាំង ៤ ។ ក្នុងបទថា **អយំ ខោ មេ ព្រាហ្មណ តតិយា អភិនិព្ភិទា អហោសិ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ម្នាលព្រាហ្មណ៍ ការដែលតថាគតទម្លាយនូវសម្បក គឺអវិជ្ជាដែលបិទបាំងសច្ចៈទាំង ៤ ដោយចំពុះ គឺអាសវក្ខយញ្ញាណ ហើយរើខ្លួនចេញលើកទី ៣ ចេញទៅគ្រាទី ៣ កើតជាអរិយៈគ្រាទី ៣ នេះឯង មានហើយដល់តថាគតដូចកូនមាន់ទម្លាយសម្បកដោយចំពុះ ឬដោយចុងក្រចក ហើយរើខ្លួនចេញចាកសម្បកនោះ កើតមក ធំធាត់ក្នុងពងមាន់ ដូច្នោះ ។ សួរថា ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគទ្រង់សម្តែងអ្វី ។ ឆ្លើយថា ទ្រង់សម្តែងសេចក្តីនេះថា ម្នាលព្រាហ្មណ៍ កូនមាន់នោះទម្លាយសម្បក ហើយចេញចាក

សម្បកនោះ កើតឡើងម្តងប៉ុណ្ណោះ តែតថាគតទម្លាយសម្បក គឺអវិជ្ជាដែលបិទបាំងខន្ធ ធ្លាប់នៅអាស្រ័យក្នុងកាលមុន កើតលើកទី ១ ដោយវិជ្ជា គឺបុព្វេនិវាសានុស្សតិញ្ញាណ បន្ទាប់អំពីនោះ ទម្លាយសម្បក គឺអវិជ្ជាដែលបិទបាំងចុតិ និងបដិសន្ធិ នៃសត្វទាំងឡាយ កើតលើកទី ២ ដោយវិជ្ជា គឺទិព្វ-ចក្ខុញ្ញាណតទៅ ទម្លាយសម្បក គឺអវិជ្ជាដែលបិទបាំងសច្ចៈទាំង ៤ កើតលើកទី ៣ ដោយវិជ្ជា គឺអាសវក្ខយញ្ញាណ តថាគតកើត ៣ ដង ដោយវិជ្ជា ៣ យ៉ាងនេះ ហើយការកើតនៃតថាគតនោះ ជារបស់ប្រសើរ ស្អាតបរិសុទ្ធ ។ កាលទ្រង់សម្តែងយ៉ាងនេះ បានប្រកាសព្រះសព្វញ្ញុគុណទាំងអស់ ដោយវិជ្ជា ៣ យ៉ាងនេះ គឺប្រកាសអតីតំសញ្ញាណ ដោយបុព្វេនិវា-សញ្ញាណ ប្រកាសបច្ចុប្បន្នំសញ្ញាណ និងអនាគតំសញ្ញាណ ដោយទិព្វ-ចក្ខុញ្ញាណ ប្រកាសលោកិយគុណ និងលោកុត្តរគុណទាំងអស់ ដោយអាសវក្ខយញ្ញាណ ទ្រង់សម្តែងភាពដែលព្រះអង្គជាបុគ្គលចម្រើនបំផុត និងប្រសើរបំផុត ដោយអរិយជាតិ គឺការកើតដ៏ប្រសើរដល់ព្រាហ្មណ៍ ។

បទថា **ឯវំ វុត្តេ វេរញ្ជោ ព្រាហ្មណោ** សេចក្តីថា កាលព្រះមានព្រះភាគ ទ្រង់អនុគ្រោះសត្វលោក កាលទ្រង់អនុគ្រោះព្រាហ្មណ៍ ត្រាស់ការៈដែលទ្រង់ជាអ្នកចម្រើនបំផុត និងប្រសើរបំផុតដោយអរិយជាតិ ការកើតដ៏ប្រសើរ ដែលគួរបិទបាំងដោយព្រះធម្មទេសនា ដែលប្រកាសវិជ្ជា ៣ យ៉ាងនេះ វេរញ្ជព្រាហ្មណ៍មានកាយ និងចិត្តជ្រួតជ្រាបដោយបីតិ ដឹងដល់ភាពដែល

ព្រះមានព្រះភាគទ្រង់ចម្រើនបំផុត និងប្រសើរបំផុត ដោយការកើតដ៏ប្រសើរ នោះ បានតិះដៀលខ្លួនថា អញបានពោលទោសព្រះសព្វញ្ញូដែលប្រកបដោយគុណទាំងពួង ចម្រើនបំផុតក្នុងលោកទាំងពួង ដូចជាពាក្យថា មិនធ្វើកម្ម មានការក្រាបថ្វាយបង្គំជាដើមដល់អ្នកដទៃ គួរតិះដៀលពិតហ្ន៎ ព្រាហ្មណ៍ ដោយការមិនដឹង ទើបយល់ថា ឥឡូវនេះ បុគ្គលនេះជាបុគ្គលចម្រើនបំផុត ព្រោះកើតមុនដោយអរិយជាតិ ការកើតដ៏ប្រសើរក្នុងលោក ជាបុគ្គលប្រសើរបំផុត ព្រោះមិនមានបុគ្គលប្រៀបដោយគុណទាំងពួង ហើយបានក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគថា ព្រះគោតមជាបុគ្គលចម្រើនបំផុត ព្រះគោតមជាបុគ្គលប្រសើរបំផុត កាលក្រាបទូលយ៉ាងនេះហើយ កាលនឹងសរសើរព្រះធម្មទេសនារបស់ព្រះមានព្រះភាគនោះតទៅ ទើបពោលពាក្យជាដើមថា **អភិក្កន្តំ ភោ គោតម** ដូច្នេះ ។ ពាក្យនោះ មានអត្ថដូចពោលហើយនោះឯង ។ល។

**អដ្ឋកថា វេរញ្ជសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សីហសូត្រទី ២

[ ១២ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ សម័យនោះឯង ពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ ។ ជួនសម័យនោះឯង សីហសេនាបតីជាសាវ័ករបស់និគណ្ឋ-នាដបុត្រ អង្គុយក្នុងបរិសទ្យនោះដែរ ។ គ្រានោះ សីហសេនាបតី មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាក់ជាអរហន្តសម្មាសម្ពុទ្ធប្រាកដ បានជាពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទាំងនោះ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ បើដូច្នោះ គួរតែអញចូលទៅ ដើម្បីជួបនឹងព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ លំដាប់នោះ សីហសេនាបតី ចូលទៅឯលំនៅនិគណ្ឋនាដបុត្រ លុះចូលទៅដល់ហើយ បានស្នើសេចក្តីនេះនឹងនិគណ្ឋនាដបុត្រថា បពិត្រលោកដ៏ចម្រើន ខ្ញុំចង់ចូលទៅដើម្បីជួបនឹងព្រះសមណគោតម ។ និគណ្ឋនាដបុត្រតបថា ម្នាលសីហៈ អ្នកឯង ជាកិរិយវាទ នឹងចូលទៅជួបព្រះសមណគោតម ជាអកិរិយវាទដូចម្តេចកើត ម្នាលសីហៈ ព្រោះថា សមណគោតមជាអកិរិយវាទ តែងសម្តែងធម៌ ដើម្បីឃាត់កិច្ចការថា មិនត្រូវធ្វើ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ

ដែរ ។ លំដាប់នោះ ការប្រុងប្រៀបដំណើរដើម្បីទៅជួបព្រះដ៏មានព្រះភាគរបស់សីហសេនាបតី ក៏ត្រឡប់ជាអាក់ខានទៅវិញ ។ ពួកលិច្ឆវីជនច្រើននាក់ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ ក្នុងលើកទី ២ ទៀត ។ សីហសេនាបតី មានសេចក្តីត្រិះរិះ ក្នុងលើកទី ២ ទៀតដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាក់ជាព្រះអរហន្តសម្មាសម្ពុទ្ធប្រាកដ បានជាពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទាំងនេះ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ បើដូច្នោះ គួរតែអញចូលទៅ ដើម្បីជួបនឹងព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ លំដាប់នោះ សីហសេនាបតី ក៏ចូលទៅឯលំនៅរបស់និគណ្ឋនាដបុត្រ លុះចូលទៅដល់ហើយ បានស្នើសេចក្តីនេះនឹងនិគណ្ឋនាដបុត្រថា បពិត្រលោកដ៏ចម្រើន ខ្ញុំចង់ចូលទៅដើម្បីជួបព្រះសមណគោតម ។ និគណ្ឋនាដបុត្រតបថា ម្នាលសីហៈ ចំណែកអ្នកឯង ជាកិរិយវាទ នឹងចូលទៅ ដើម្បីជួបព្រះសមណគោតម ជាអកិរិយវាទដូចម្តេចកើត ម្នាលសីហៈ ព្រោះថា សមណគោតម ជាអកិរិយវាទ តែងសម្តែងធម៌ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវ័កដោយធម៌នោះដែរ ។ ការប្រុងប្រៀបដំណើរ ដើម្បីទៅជួបព្រះដ៏មានព្រះភាគ របស់សីហសេនាបតី ក៏ត្រឡប់ជា

អាក់ខានទៅវិញ ក្នុងលើកទី ២ ទៀត ។ ពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេក-បរិយាយ ក្នុងលើកទី ៣ ទៀត ។ សីហសេនាបតី មានសេចក្តីត្រិះរិះក្នុងលើកទី ៣ ដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាក់ជាព្រះអរហន្តសម្មា-សម្ពុទ្ធប្រាកដ បានជាពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទាំងនេះ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ ក៏ឯនិគ្រន្ថទាំងឡាយនេះ ទោះបីអញលាក្តី មិនលាក្តី នឹងហ៊ានធ្វើអ្វី បើដូច្នោះអញមិនបាច់លានិគ្រន្ថនាដបុត្រទេ នឹងចូលទៅដើម្បីជួបព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធនោះតែម្តង ។ លំដាប់នោះ សីហសេនាបតីចេញទៅអំពីក្រុងវេសាលី ពេលជ្រេពីត្រង់ ដោយរថចំនួនប្រាំរយ ដើម្បីជួបព្រះដ៏មានព្រះភាគ ទី ( ទៅ ) ដោយយានបានត្រឹមណា ក៏ទៅដោយយានត្រឹមនោះហើយចុះអំពីយាន ដើរដោយជើងចូលទៅកាន់អារាម ។ លំដាប់នោះ សីហ-សេនាបតី ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះសីហសេនាបតីអង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ព្រះសមណគោតម ជា

អកិរិយវាទ តែងសំដែងធម៌ ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវកដោយធម៌នោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយណាពោលពាក្យយ៉ាងនេះថា ព្រះសមណគោតម ជាអកិរិយវាទ តែងសំដែងធម៌ ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវកដោយធម៌នោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ចុះជនទាំងឡាយនោះ ឈ្មោះថា អ្នកពោលតាមពាក្យដែលព្រះដ៏មានព្រះភាគពោលហើយផង ឈ្មោះថា មិនពោលបង្កាច់ព្រះដ៏មានព្រះភាគដោយពាក្យមិនពិតផង ឈ្មោះថា ព្យាករនូវធម៌សមគួរដល់ធម៌ផង លំអាននៃពាក្យតូចធំ ប្រកបដោយធម៌តិចតួច រមែងមិនមកកាន់ឋានៈគួរតិះដៀលផងទេឬ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះយើងខ្ញុំមិនបានប្រាថ្នាពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ។ ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតម ជាអកិរិយវាទ តែងសំដែងធម៌ ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវក ដោយធម៌នោះដែរ ដែលគេថានោះ ត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណ-គោតមជាកិរិយវាទ តែងសំដែងធម៌ ដើម្បីធ្វើដែរ ទាំងទូន្មានពួកសាវកដោយធម៌នោះ ត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណ-គោតមជាឧច្ឆេទវាទ តែងសំដែងធម៌ដើម្បីកាត់ផ្តាច់ផ្តិលដែរ ទាំងទូន្មានពួកសាវកដោយធម៌នោះ ដែលគេថានោះ ត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតមជាអ្នកខ្ពើមរអើម តែងសំដែងធម៌ ដើម្បីសេចក្តី

ខ្ពើមរអើម ទាំងទូន្មានពួកសាវកដោយធម៌នោះ ត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតមជាអ្នកបំផ្លាញ តែងសម្តែងធម៌ ដើម្បីបំផ្លាញ ទាំងទូន្មានពួកសាវកដោយធម៌នោះ ដែលគេថានោះ ត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតមជាអ្នកដុតកម្តៅ តែងសម្តែងធម៌ ដើម្បីដុតកម្តៅ ទាំងទូន្មានពួកសាវកដោយធម៌នោះ ដែលគេថានោះ ត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតម ជាមនុស្សឥតកំណើត តែងសម្តែងធម៌ ដើម្បីឥតកំណើត ទាំងទូន្មានពួកសាវកដោយធម៌នោះ ដែលគេថានោះ ត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកលួងលោម ទាំងទូន្មានពួកសាវកដោយធម៌នោះ ដែលគេថានោះ ត្រូវហើយ ។ ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតមជាអកិរិយវាទ តែងសម្តែងធម៌ ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវកដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថា តថាគតតែងនិយាយថា មិនគួរធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតទេ តែងនិយាយថា មិនគួរធ្វើអកុសលទាំងឡាយដ៏អាក្រក់ច្រើនប្រការទេ ។ ម្នាលសីហៈ នេះឯង ជាបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអកិរិយវាទ តែងសម្តែងធម៌ ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវកដោយធម៌នោះ ។ ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតមជាកិរិយវាទ តែងសម្តែងធម៌ ដើម្បីធ្វើទាំងទូន្មាន ពួកសាវក

ដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថា តថាគតតែងនិយាយថា គួរធ្វើកាយសុចរិត វចីសុចរិត មនោសុចរិត តែងនិយាយថា គួរធ្វើកុសលធម៌ទាំងឡាយច្រើនប្រការ ។ ម្នាលសីហៈ នេះឯង ជាបរិយាយដែលអ្នកផងថា ព្រះសមណគោតមជាកិរិយវាទ តែងសម្តែងធម៌ ដើម្បីធ្វើទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតមជាឧច្ឆេទវាទ តែងសម្តែងធម៌ ដើម្បីកាត់ផ្តាច់ផ្តិលទាំងទូន្មានពួកសាវ័ក ដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថាតថាគតតែងនិយាយចំពោះការកាត់ផ្តាច់ផ្តិលរាគៈ ទោសៈ មោហៈ តែងនិយាយចំពោះការកាត់ផ្តាច់ផ្តិលនូវអកុសលធម៌ទាំងឡាយ ច្រើនប្រការ ។ ម្នាលសីហៈ នេះឯងជាបរិយាយ ដែលអ្នកផងថា ព្រះសមណគោតម ជាឧច្ឆេទវាទ តែងសម្តែងធម៌ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតមជាអ្នកខ្ពើមរអើម តែងសម្តែងធម៌ ដើម្បីខ្ពើមរអើម ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថា តថាគតខ្ពើមរអើមកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ខ្ពើមរអើមការប្រកបចិត្ត ផ្តេកផ្តិតទៅរកអកុសលធម៌ទាំងឡាយដ៏អាក្រក់ ច្រើនប្រការ ។ ម្នាលសីហៈ នេះឯង ជាបរិយាយដែលអ្នកផងថា ព្រះសមណគោតមជាអ្នកខ្ពើមរអើម តែងសម្តែងធម៌ ដើម្បីខ្ពើមរអើម ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ ចុះ

បរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកបំផ្លាញ តែងសម្ដែងធម៌ ដើម្បីបំផ្លាញ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្ដេច ។ ម្នាលសីហៈ ព្រោះថា តថាគតសម្ដែងធម៌ ដើម្បីបំផ្លាញរាគៈ ទោសៈ មោហៈ សម្ដែងធម៌ ដើម្បីបំផ្លាញអកុសលធម៌ទាំងឡាយដ៏អាក្រក់ ច្រើនប្រការ ។ ម្នាលសីហៈ នេះឯង ជាបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកបំផ្លាញ តែងសម្ដែងធម៌ ដើម្បីបំផ្លាញ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតមជាអ្នកដុតកម្ដៅ តែងសម្ដែងធម៌ ដើម្បីដុតកម្ដៅ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្ដេច ។ ម្នាលសីហៈ តថាគតតែងនិយាយចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ជាអកុសលធម៌ដ៏អាក្រក់ ។ ម្នាលសីហៈ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោត ដែលគេគាស់រម្លើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាព តទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅមុខទៀតហើយ តថាគតហៅអ្នកនោះថា ជាអ្នកដុតកម្ដៅ ។ ម្នាលសីហៈ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ តថាគតបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោតដែលគេគាស់

រមើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅមុខទៀតហើយ ។ ម្នាលសីហៈ នេះឯង ជាបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកដុតកម្តៅ តែងសម្តែងធម៌ដើម្បីដុតកម្តៅ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ បរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាមនុស្សមិនមានកំណើត តែងសម្តែងធម៌ ដើម្បីមិនមានកំណើត ទាំងទូន្មានពួកសាវ័ក ដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ កិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅទៀត បើអ្នកណាបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោត ដែលគេគាស់រមើង ឲ្យលែងដុះតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា ជាអ្នកមិនមានកំណើត ។ ម្នាលសីហៈ កិរិយាដេកនៅក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅទៀត តថាគតបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលអស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោតដែលគេគាស់រមើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ។ ម្នាលសីហៈ នេះឯង ជាបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកមិនមានកំណើត តែងសម្តែងធម៌ ដើម្បីមិនមានកំណើត ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ បរិយាយដែលអ្នកផងថា

ព្រះសមណគោតម ជាអ្នកលួងលោម តែងសម្តែងធម៌ ដើម្បីលួងលោម ទាំងទូន្មានពួកសាវកដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថា តថាគតជាអ្នកលួងលោម តែងសំម្តែងធម៌ ដើម្បីលួងលោម ដោយសេចក្តីលួងលោមយ៉ាងក្រៃលែង ទាំងទូន្មានពួកសាវកដោយធម៌នោះ ។ ម្នាលសីហៈ នេះឯង ជាបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកលួងលោម តែងសម្តែងធម៌ដើម្បីលួងលោម ទាំងទូន្មានពួកសាវកដោយធម៌នោះ ។ កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ សីហសេនាបតីបានក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ពេកណាស់ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះដ៏មានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណៈ ស្មើដោយជីវិត ។ ព្រះសាស្តា ទ្រង់ត្រាស់ថា ម្នាលសីហៈ អ្នកចូរធ្វើនូវការពិចារណា រួចហើយ សឹមធ្វើ ( ព្រោះ ) ការពិចារណារួចហើយសឹមធ្វើ រមែងជាគុណគាប់ប្រសើររបស់ពួកមនុស្សអ្នកចេះដឹង ប្រហែលនឹងអ្នក ។ សីហសេនាបតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីពេញចិត្ត ត្រេកអរលើសលុបហួសប្រមាណ ចំពោះភាសិតរបស់ព្រះអង្គ ដោយហេតុដែលព្រះអង្គសម្តែងនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ អ្នកចូរធ្វើនូវការពិចារណារួចហើយសឹមធ្វើ ( ព្រោះ ) ការពិចារណារួចហើយសឹមធ្វើ រមែងជាគុណគាប់ប្រសើរ

របស់ពួកមនុស្សអ្នកចេះដឹងប្រហែលនឹងអ្នក បពិត្រព្រះអង្គដ៏ចម្រើន ដ្បិត ពួកអន្យតិរ្ថិយ បានខ្ញុំព្រះអង្គជាសាវកហើយ ក៏ដង្ហែទង់ ចូលទៅកាន់ក្រុង វេសាលីទាំងមូល ហើយប្រកាសសេចក្តីថា សីហសេនាបតី បានចុះចូលមក ជាសាវករបស់ពួកយើងហើយ ចំណែកតែព្រះដ៏មានព្រះភាគ ត្រឡប់ជាទ្រង់ ត្រាស់ចំពោះខ្ញុំព្រះអង្គយ៉ាងនេះវិញថា ម្នាលសីហៈ អ្នកចូរធ្វើនូវការពិចារណា រួចហើយសឹមធ្វើ ( ព្រោះ ) ការពិចារណារួចហើយសឹមធ្វើ រមែងជាគុណ គាប់ប្រសើរ របស់មនុស្សអ្នកចេះដឹង ប្រហែលនឹងអ្នក បពិត្រព្រះអង្គដ៏ ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃ ផង ជាទីពឹងទីរឭក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះដ៏មានព្រះភាគ ចាំ ទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត ជាគម្រប់ ពីរដងផង ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសីហៈ ត្រកូលរបស់ អ្នក ដូចជាអណ្តូងទឹក របស់ពួកនិគ្រន្ថ អស់កាលយូរណាស់មកហើយ អ្នក គប្បីសម្គាល់នូវបិណ្ឌបាត ដែលអ្នកគួរឲ្យដល់ពួកនិគ្រន្ថ ដែលចូលមករកនោះ ផង ។ សីហសេនាបតី ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមាន សេចក្តីពេញចិត្ត ត្រេកអរលើសលុបហួសប្រមាណចំពោះភាសិត របស់ព្រះ អង្គ ដោយហេតុដែលព្រះអង្គ បានសម្តែងនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាល សីហៈ ត្រកូលរបស់អ្នក ដូចជាអណ្តូងទឹក របស់ពួកនិគ្រន្ថ អស់កាលយូរ ណាស់មកហើយ អ្នកគប្បីសម្គាល់នូវបិណ្ឌបាត ដែលអ្នកគួរឲ្យដល់ពួកនិគ្រន្ថ

ដែលចូលមករកនោះផង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់ឮពាក្យនេះ ថា ព្រះសមណគោតម ទ្រង់ត្រាស់យ៉ាងនេះថា បុគ្គលត្រូវឲ្យទានដល់តថាគត តែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកសាស្ដាដទៃឡើយ បុគ្គលត្រូវឲ្យទានដល់ពួក សាវករបស់តថាគតតែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកសាវក របស់ពួកសាស្ដា ដទៃឡើយ បុគ្គលឲ្យទានដល់តថាគតតែម្យ៉ាង ទើបមានផលច្រើន ឲ្យដល់ ពួកសាស្ដាដទៃ មិនមានផលច្រើនឡើយ បុគ្គលឲ្យទានដល់ពួកសាវករបស់ តថាគតតែម្យ៉ាង ទើបមានផលច្រើន ឲ្យទានដល់ពួកសាវករបស់ពួកសាស្ដា ដទៃ មិនមានផលច្រើនឡើយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគត្រឡប់ជាបបួល ខ្ញុំព្រះអង្គឲ្យធ្វើទានក្នុងពួកនិគ្រន្ថ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងខ្ញុំព្រះ អង្គគង់នឹងដឹងនូវកាលគួរក្នុងទាននុ៎ះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទី រឭក បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះដ៏មាន ព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈ ស្មើដោយ ជីវិត ជាគម្រប់បីដងផង ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងអនុបុព្វីកថា ចំពោះសីហសេនាបតី គឺទ្រង់ប្រកាសនូវទានកថា សីលកថា សគ្គកថា នូវ ទោសរបស់កាមដ៏លាមក សៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ។ កាលណា ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា សីហសេនាបតី មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់ មានចិត្តជ្រះថ្លាហើយ

ទើបទ្រង់ប្រកាសនូវធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ តែងលើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ។ ធម្មតាសំពត់សស្អាត មិនជិតប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គួរទទួលទឹកជ្រលក់បានដោយល្អ មានឧបមាដូចម្តេចមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់សីហសេនាបតី ក្នុងទីនោះឯងថា ធម្មជាតណាមួយ ដែលកើតឡើង ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ គ្រានោះ សីហសេនាបតី បានឃើញអរិយសច្ចធម៌ហើយ បានលុះអរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានជៀជាក់អរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវភាពជាអ្នកក្លាហាន មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តាហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលនូវភត្តរបស់ខ្ញុំព្រះអង្គ ជាមួយនឹងភិក្ខុសង្ឃ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ សីហសេនាបតី ដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទទួលនិមន្តន៍ហើយ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយដើរចេញទៅ ។ លំដាប់នោះ សីហសេនាបតី បានហៅបុរស ១ នាក់មកថា ម្នាលបុរសដ៏ចម្រើន អ្នកចូរទៅ ចូរដឹងនូវសាច់ ដែលគួរប្រព្រឹត្តទៅតាមប្រក្រតី ( សាច់ទុកលក់ ) ។ លំដាប់នោះ សីហសេនាបតី

ក៏ចាត់ចែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ក្នុងផ្ទះរបស់ខ្លួន ដោយកាលកន្លង ទៅនៃរាត្រីនោះ ទើបប្រើបុរសនោះឲ្យទៅក្រាបទូលនូវកត្តកាល ដល់ព្រះដ៏មាន ព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ កត្តក្នុងផ្ទះរបស់សីហ-សេនាបតី សម្រេចហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅរបស់សីហ-សេនាបតី លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលសីហសេនាបតី ក្រាលបម្រុងទុក ជាមួយនឹងភិក្ខុសង្ឃ ។ ក្នុងសម័យនោះ ពួកនិគ្រន្ថជាច្រើន នាក់ផ្គងនូវដើមដៃស្រែកកន្ទក់កន្ទេញ សព្វច្រកសព្វផ្លូវត្រៀងកែងក្នុងក្រុង វេសាលីថា ថ្ងៃនេះ សីហសេនាបតី សម្លាប់សត្វមានសរីរៈធាត់ធំ ធ្វើកត្តដើម្បី សមណគោតមៗ ទុកជាដឹង គង់ឆាន់នូវសាច់ដែលគេសម្លាប់ចំពោះខ្លួន ( ព្រះ សមណគោតមនេះ ឈ្មោះថា ត្រូវ ) បដិច្ចកម្ម ។ លំដាប់នោះ បុរសម្នាក់ ក៏ចូលទៅឯកន្លែងដែលសីហសេនាបតីនៅ លុះចូលទៅដល់ហើយ ក៏ខ្សឹប ប្រាប់ក្បែរត្រចៀកនៃសីហសេនាបតីថា សូមព្រះតេជព្រះគុណជ្រាប ពួក និគ្រន្ថជាច្រើន ទាំងអម្បាលនេះ ផ្គងដើមដៃកន្ទក់កន្ទេញ សព្វច្រកសព្វផ្លូវ ត្រៀងកែង ជិតក្រុងវេសាលីថា ក្នុងថ្ងៃនេះ សីហសេនាបតី សម្លាប់សត្វ មានសរីរៈធាត់ធំ ធ្វើកត្តដើម្បីព្រះសមណគោតមៗ ទុកជាដឹង ក៏គង់ឆាន់នូវ សាច់ដែលគេសម្លាប់ចំពោះខ្លួន ព្រះសមណគោតមនេះ ឈ្មោះថា ត្រូវបដិច្ច-កម្ម ។ លោកម្ចាស់ទាំងឡាយ មិនគួរសោះ ព្រោះថា លោកដ៏មានអាយុ

ទាំងនោះ ប្រាថ្នារកទោសព្រះពុទ្ធ ប្រាថ្នារកទោសព្រះធម៌ ប្រាថ្នារកទោសព្រះសង្ឃ អស់កាលជាយូរណាស់មកហើយ តែលោកដ៏មានអាយុទាំងនោះ មិនអៀនខ្មាស នៅតែពោលបង្កាច់ព្រះដ៏មានព្រះភាគនោះ ដោយពាក្យមិនមានពាក្យទទេ ជាពាក្យកុហក មិនពិត ទាំងពួកយើងក៏មិនក្លែងផ្តាច់បង់សត្វចាកជីវិត ព្រោះហេតុតែជីវិត ( របស់ខ្លួនឡើយ ) ។ លំដាប់នោះ សីហសេនាបតី ញ៉ាំងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ឧត្តម ដោយដៃខ្លួនឯង ។ កាលដែលព្រះដ៏មានព្រះភាគអង្គនោះឆាន់រួច លែងដាក់ព្រះហស្តទៅក្នុងបាត្រទៀតហើយ សីហសេនាបតីក៏អង្គុយក្នុងទីសមគួរ ។ កាលដែលសីហសេនាបតី អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយក្រោកចាកអាសនៈស្តេចចេញទៅ ។

# អដ្ឋកថា

## សីហសូត្រ

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីហសូត្រទី ២ ដូចតទៅនេះ បទថា **អភិញ្ញាតា** បានដល់ ស្គាល់គ្នាហើយ ប្រាកដហើយ ។ បទថា **សន្ថាគារេ** បានដល់ សណ្ឋាគាររបស់មហាជន គឺផ្ទះដែលសាង ដើម្បីសម្រាករបស់

មហាជន ។ បានឮថា សណ្ឋាគារសាលានោះ មាននៅត្រង់កណ្ដាលក្រុង ប្រាកដដល់មនុស្សទាំង ២ ដែលនៅត្រង់ទ្វារទាំង ៤ ពួកមនុស្សដែលមកអំពីទិសទាំង ៤ សម្រាកត្រង់សណ្ឋាគារនោះសិន ក្រោយមក ទើបទៅកាន់ទីផាសុកដល់ខ្លួន ។ អាចារ្យពួកខ្លះពោលថា ផ្ទះដែលសាងដើម្បីបដិបត្តិរាជកិច្ចនៃរាជត្រកូល ដូច្នេះក៏មាន ។ ពិតហើយ ស្ដេចលិច្ឆវីប្រជាប់គង់ត្រង់សណ្ឋាគារនោះ ផ្ដើមធ្វើរាជកិច្ច ។ បទថា **សន្និសិន្នា** សេចក្ដីថា អង្គុយប្រជុំលើអាសនៈដែលខ្លួនតាក់តែង មានកម្រាលគួរដល់តម្លៃច្រើន លើកស្វេតច្ឆត្រឡើងសម្រាប់ស្ដេចលិច្ឆវីទាំងនោះប្រជាប់គង់ ។

បទថា **អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ** សេចក្ដីថា ស្ដេចលិច្ឆវីទាំងឡាយពិចារណាក្នុងរាជត្រកូល បំពេញប្រយោជន៍ដល់លោកហើយពោលសម្ដែងគុណរបស់ព្រះពុទ្ធ ដោយហេតុមិនមែនតិច ។ ពិតហើយ ស្ដេចទាំងនោះជាបណ្ឌិត មានសទ្ធាជ្រះថ្លា ជាអរិយសាវក ថ្នាក់សោតាបន្នខ្លះ សកទាគាមីខ្លះ អនាគាមីខ្លះ ស្ដេចគ្រប់អង្គនោះកាត់ព្រៃស្លុក ដែលជាលោកិយបានហើយ សរសើរគុណរបស់រតនៈទាំង ៣ មានព្រះពុទ្ធជាដើម ។ បណ្ដារតនៈទាំង ៣ នោះ ឈ្មោះថា ពុទ្ធគុណ មាន ៣ យ៉ាង គឺចរិយគុណ ១ សរីរគុណ ១ គុណគុណ ១ ។ បណ្ដាគុណទាំង ៣ នោះ ស្ដេចទាំងនេះប្រារព្ធព្រះចរិយាគុណ គឺពោលគុណរបស់ព្រះពុទ្ធដោយជាតក ៥៥០ រឿងថា ព្រះសម្មាសម្ពុទ្ធទ្រង់បំពេញបារមី ៣០ គឺបារមី ១០ ឧបបារមី ១០

បរមត្ថបារមី ១០ អស់ ៤ អសង្ខេយ្យកម្រៃមួយសែនកប្ប ទ្រង់ធ្វើញាតត្ថ-ចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយាឲ្យដល់ទីបំផុត ហើយធ្វើបរិច្ចាគនូវមហាបរិច្ចាគ ៥ ប្រការ ទ្រង់ធ្វើកិច្ចកម្មដែលធ្វើលំបាកហ្ន៎ ដូច្នេះ ពណ៌នារហូតដល់តុសិតភព ហើយទើបឈប់ ។

ម្យ៉ាងទៀត កាលពោលគុណរបស់ព្រះធម៌ បានពោលព្រះធម្មគុណជាចំណែកៗ ថា ព្រះធម៌ដែលព្រះមានព្រះភាគអង្គនោះសម្តែងហើយ ពោលដោយនិកាយ មាន ៥ ពោលដោយបិដក មាន ៣ ពោលដោយអង្គ មាន ៩ ពោលដោយខន្ធ មាន ៨៤០០០ ព្រះធម្មក្ខន្ធ ។

កាលពោលគុណរបស់ព្រះសង្ឃ ក៏ពោលគុណដោយសង្ខេបនៃបព្វជ្ជា ថា កុលបុត្រទាំងឡាយបានស្តាប់ធម្មទេសនារបស់ព្រះសាស្តា មាននូវសទ្ធា លះនូវគំនរភោគៈ និងវង្សញាតិ មិនអាឡោះអាល័យដល់ស្វេតច្ឆត្រ តំណែងឧបរាជ តំណែងសេនាបតី សេដ្ឋី និងនាយឃ្លាំងជាដើម ចេញបួសក្នុងសាសនាដ៏ប្រសើរនៃព្រះសាស្តា ក្នុងសម័យពុទ្ធកាល ចំពោះរាជបព្វជិត ដូចជាព្រះបាទកម្ពិយៈ ព្រះមហាកប្បិន និងព្រះបាទបុក្កុសាតិជាដើម ដែលលះស្វេតច្ឆត្រចេញបួស មានចំនួនដល់ទៅ ៨០០០០ អង្គ ។ សម្រាប់កុលបុត្រទាំងឡាយ មានយសកុលបុត្រ សោណសេដ្ឋីបុត្រ និងរដ្ឋបាលកុលបុត្រជាដើម លះនូវទ្រព្យច្រើនកោដិចេញបួសកំណត់មិនបាន កុលបុត្របែបនេះរមែងបួសក្នុងសាសនារបស់ព្រះសាស្តា ។

បទថា **សីហោ សេនាបតិ** បានដល់ មេទ័ពមានឈ្មោះយ៉ាងនោះ ។ ក្នុងក្រុងវេសាលី មានស្តេចដល់ទៅ ៧៧០៧ អង្គ ស្តេចទាំងឡាយនោះប្រជុំគ្នាទាំងអស់ ដើម្បីថែទឹកចិត្តគ្នា ជ្រើសរើសគ្នាថា អ្នកទាំងឡាយ ចូរជ្រើសរើសស្តេចមួយអង្គដែលអាចរក្សារដ្ឋបាន ឃើញសីហរាជកុមារ ក៏សម្រេចគ្នាថា បុគ្គលនេះអាច ទើបបានថ្វាយឆត្រប្រចាំតំណែងសេនាបតី មានពណ៌ដូចត្បូងទទឹម ពាសដោយសំពត់កម្ពលដល់សីហរាជកុមារនោះ ។ ទ្រង់សំដៅយកសីហរាជកុមារនោះ ទើបត្រាស់ថា **សីហោ សេនាបតិ** ដូច្នេះ ។

បទថា **និគ្គណ្ឋសាវកោ** បានដល់ ឧបដ្ឋាកដែលឲ្យបច្ច័យដល់និគណ្ឋនាដបុត្រ ។ ក្នុងផ្ទៃនៃជម្ពូទ្វីប មានជន ៣ នាក់ ដែលជាអគ្គឧបដ្ឋាករបស់ពួកនិគ្រន្ថ គឺក្នុងក្រុងនាលន្ទា មានឧបាលិគហបតី ក្នុងក្រុងកបិលពស្តុ មានវប្បសក្យៈ ក្នុងក្រុងវេសាលី មានសីហសេនាបតី ។

បទថា **និសិន្នោ ហោតិ** សេចក្តីថា ក្រាលអាសនៈតាមជាយៗសម្រាប់បរិស័ទរបស់ស្តេចក្រៅអំពីនោះ ឯសីហសេនាបតី ក្រាលត្រង់កណ្តាលដូច្នោះ ទើបសីហសេនាបតីប្រថាប់គង់លើរាជអាសនៈ ដែលគួរដល់តម្លៃច្រើន ដែលគេក្រាលនោះ ។

បទថា **និស្សំសយំ** បានដល់ មិនសង្ស័យ គឺពិតដោយចំណែកមួយ ព្រោះថា ស្តេចលិច្ឆវីទាំងនេះ មិនពោលគុណរបស់ស្តេច ដែលមានសក្តិតូចអង្គណាមួយ ដោយហេតុច្រើនរយយ៉ាងនេះ ។

បទថា **យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ** សេចក្តីថា បានឮថា និគណ្ឋនាដបុត្រគិតថា បើសីហសេនាបតីនេះ កាលបុគ្គលណាម្នាក់ពោលគុណរបស់ព្រះសមណគោតម បានស្តាប់ហើយ នឹងចូលទៅគាល់ព្រះសមណគោតមសោត អញនឹងវិនាស ទើបបានពោលពាក្យនេះនឹងសីហសេនាបតីថា នែ៎សេនាបតី ក្នុងលោកនេះ មហាជនត្រាច់ពោលថា ខ្ញុំជាព្រះពុទ្ធ ខ្ញុំជាព្រះពុទ្ធ បើអ្នកបំណងចូលទៅជួប បុគ្គលណាម្នាក់សោតគួរសួរខ្ញុំ ដែលសមគួរ ខ្ញុំនឹងបញ្ជូនអ្នកទៅ បើមិនសមគួរ ខ្ញុំនឹងហាមអ្នក ។ សីហសេនាបតីនោះ ឮពាក្យនោះ ទើបគិតថា បើនិគណ្ឋនាដបុត្របញ្ជូនអញទៅសោត អញនឹងទៅ បើមិនបញ្ជូន អញមិនទៅឡើយ ដូច្នេះហើយ ចូលទៅរកនិគណ្ឋនាដបុត្រដល់លំនៅ ។ គ្រានោះ និគ្រន្ថបានស្តាប់ពាក្យសីហសេនាបតីនោះ ត្រូវសេចក្តីសោកដ៏ខ្លាំងក្លា ដូចភ្នំធំសង្កត់ ទោមនស្សថា អញមិនប្រាថ្នាឲ្យចូលទៅក្នុងទីណា សីហសេនាបតីក៏បំណងទៅទីនោះ អញត្រូវគេសម្លាប់ហើយ ទើបគិតថា អញនឹងធ្វើឧបាយហាមឃាត់ ទើបពោលពាក្យជាដើមថា **កឹ បន ត្វំ** ដូច្នេះ ។ និគ្រន្ថកាលពោលយ៉ាងនេះ ធ្វើបីតិដែលកើតឡើងហើយរបស់សីហសេនាបតីឲ្យវិនាសទៅ ដូចយកមាត់បញ្ឈប់គោកំពុងត្រាច់ទៅ ដូចធ្វើប្រទីបដែលឆេះសន្ធោសន្ធៅ ឲ្យរលត់ ដូចផ្កាប់បាត្រដែលពេញដោយភត្តាហារ ដូច្នោះ ។ បទថា **គមិយាភិសង្ខារោ** បានដល់ ការត្រៀមដែលប្រព្រឹត្តទៅ ដោយការឲ្យទឹមដំរី សេះ និងការកាន់

យកមាល័យ គ្រឿងក្រអូបជាដើម ។ បទថា **សោ បដិប្បស្សម្ភិ** បានដល់ការត្រៀមទីងទៅនោះ ត្រូវរម្ងាប់ហើយ ។

បទថា **ទុតិយម្បិ ខោ** គឺសូម្បីវារៈទី ២ ។ ក្នុងវារៈនេះ កាលស្តេចលិច្ឆវីសរសើរគុណរបស់ព្រះពុទ្ធ បានពោលសរសើរគុណ ដោយអំណាចមហាបុរិសលក្ខណៈ ៣២ ប្រការ អនុព្យញ្ជនៈ ៨០ និងព្រះរស្មីនៃព្រះទសពល កំណត់ខាងក្រោម អំពីផ្ទៃព្រះបាទឡើងទៅ ខាងលើ រាប់អំពីចុងព្រះកេសាចុះមក តាំងអំពីសន្ទុសិតពិភព ដល់មហាពោធិបល្ល័ង្ក ។ កាលពោលសរសើរគុណព្រះធម៌ បានពោលគុណរបស់ព្រះធម៌ ដោយអំណាចធម៌ដែលត្រាស់ល្អហើយប៉ុណ្ណោះថា ឈ្មោះថា ការភ្លាំងភ្លាត់ក្នុង ១ បទក្តី ក្នុងព្យញ្ជនៈ ១ តួក្តី មិនមានឡើយ ។ កាលពោលសរសើរគុណរបស់ព្រះសង្ឃ បានពោលគុណរបស់ព្រះសង្ឃ ដោយអំណាចបដិបទាបដិបត្តិថា កុលបុត្រដែលលះយសសិរី និងទ្រព្យសម្បត្តិបែបនេះ បួសក្នុងសាសនារបស់ព្រះសាស្តា ជាអ្នកមិនខ្វិលប្រអូសជាប្រក្រតី ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងធុតង្គគុណ ១៣ ប្រការ ធ្វើកិច្ចកម្មក្នុងអនុបស្សនា ៧ ប្រើការចែកអារម្មណ៍ ៣៨ ។

ក្នុងវារៈទី ៣ កាលពោលសរសើរគុណរបស់ព្រះពុទ្ធ ពោលគុណទាំងឡាយដោយបរិយាយនៃព្រះសូត្រនោះឯងថា **ឥតិបិ សោ ភគវា** ដូច្នេះជាដើម ។ ពោលសរសើរព្រះធម្មគុណទាំងឡាយ ដោយបរិយាយនៃព្រះ

សូត្រនោះឯងថា **ស្វាក្ខាតោ ភគវតា ធម្មោ** ដូច្នេះជាដើម ។ ពោលសរសើរព្រះសង្ឃគុណទាំងឡាយ ដោយបរិយាយនៃព្រះសូត្រនោះឯងថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ដូច្នេះជាដើម ។ លំដាប់នោះ សីហសេនាបតីគិតថា កាលលិច្ឆវីរាជកុមារទាំងនេះពោលពុទ្ធគុណ ធម្មគុណ សង្ឃគុណ ចាប់តាំងអំពីថ្ងៃទី ៣ ព្រះឱស្ឋក៏មិនគ្រប់គ្រាន់ ព្រះមានព្រះភាគអង្គនោះទ្រង់ប្រកបដោយគុណមិនថោកថយពិត ឥឡូវនេះ អញនឹងមិនលះបីតិដែលកើតឡើងហើយនេះជាដាច់ខាត នឹងចូលទៅគាល់ព្រះមានព្រះភាគថ្ងៃនេះ ។ លំដាប់នោះ សីហសេនាបតីកើតវិតក្កឡើងថា ពួកនិគ្រន្ថនឹងធ្វើអ្វីដល់អញ ។ បណ្តាបទទាំងនោះ បទថា **កឹ ហិ មេ ករិស្សន្តិ** សេចក្តីថា និគ្រន្ថទាំងឡាយនឹងធ្វើអ្វីដល់អញ ។ បទថា **អបលោកិតា វា អនបលោកិតា វា** បានដល់ ប្រាប់ហើយ ឬមិនទាន់ប្រាប់ ។ អធិប្បាយថា និគ្រន្ថទាំងនោះ អញប្រាប់ហើយ នឹងឲ្យសម្បត្តិ គឺយាន ពាហនៈ ឥស្សរិយយសដែលវិសេសក៏មិនមែន អញមិនប្រាប់ អញនឹងនាំឥស្សរិយយសទៅក៏មិនមែន ការប្រាប់និគ្រន្ថទាំងនោះ ទើបមិនមានផល ។

បទថា **វេសាលិយា និយ្យាសិ** សេចក្តីថា ឧបមាដូចកាលភ្លៀងធ្លាក់ក្នុងរដូវក្តៅ ទឹកហូរចុះកាន់ស្ទឹង ហូរទៅបានបន្តិចប៉ុណ្ណោះ ក៏ខះអស់មិនហូរយ៉ាងណា កាលបីតិកើតឡើងដល់សីហសេនាបតីក្នុងថ្ងៃដំបូងថា នឹងចូលគាល់ព្រះទសពល ត្រូវនិគ្រន្ថហាមឃាត់ ក៏ដូច្នោះ ដូចកាលភ្លៀងធ្លាក់ក្នុងកាល

ទី ២ ទឹកហូរចុះកាន់ស្ទឹង ហូរទៅបានបន្តិច ជួបនឹងគំនរខ្សាច់ ក៏ឈប់ហូរ យ៉ាងណា កាលបីតិកើតឡើងដល់សីហសេនាបតីក្នុងថ្ងៃទី ២ ថា អញនឹងគាល់ព្រះទសពល ត្រូវនិគ្រន្ថហាមឃាត់ ក៏ដូច្នោះ ។ កាលភ្លៀងធ្លាក់ក្នុងថ្ងៃទី ៣ ទឹកហូរចុះកាន់ស្ទឹង កួចយកស្លឹកឈើចាស់ កំណាត់ឈើស្ងួត ដើមបបុស និងសំរាមជាដើមទៅ ទម្លាយគំនរខ្សាច់ ហូរចុះកាន់មហាសមុទ្រទៅបាន យ៉ាងណា សីហសេនាបតីក៏ដូច្នោះ កាលបីតិបាមោជ្ជកើតឡើង ព្រោះបានស្តាប់កថាពណ៌នាគុណរបស់វត្ថុទាំង ៣ ក្នុងថ្ងៃទី ៣ ទើបគិតថា ពួកនិគ្រន្ថមិនមានផល ពួកនិគ្រន្ថឥតផល ពួកនិគ្រន្ថទាំងនេះនឹងធ្វើអ្វីអញ អញនឹងទៅគាល់ព្រះសាស្តា ទើបត្រៀមដំណើរយាងចេញទៅអំពីក្រុងវេសាលី ។ កាលនឹងចេញទៅ គិតថា អញបំណងនឹងគាល់ព្រះទសពលមកយូរហើយ ការទៅដោយភេទដែលបុគ្គលណាមិនស្គាល់ គឺបន្ទំខ្លួនទៅ មិនគួរដល់អញឡើយ ទើបឲ្យប្រកាសថា ជនឯណាមួយ បំណងនឹងទៅគាល់ព្រះទសពល ជនទាំងអស់ ចូរមក ហើយឲ្យទឹមរថ ៥០០ គ្រឿង និងមហាបរិស័ទចោមរោម កាន់យកផ្កាកម្រង គ្រឿងក្រអូប និងលម្អិតជាដើមចេញទៅ ។

បទថា **ទិវា ទិវស្ស** បានដល់ ក្នុងពេលថ្ងៃ គឺក្នុងពេលប្រមាណហួសថ្ងៃត្រង់ទៅ ។ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា កាលចូលទៅកាន់អារាម បានឃើញព្រះរស្មីមួយព្យាម អនុព្យញ្ជនៈ ៨០ និងបុរិសលក្ខណៈ ៣២ និងព្រះរស្មីដ៏ក្រាស់ មាន ៦ ពណ៌អំពីចម្ងាយនោះឯង ទើប

គិតថា អញមិនបានជួបបុរសបែបនេះ ដែលនៅក្នុងទីជិតយ៉ាងនេះ អស់កាលដល់ម៉្លោះ អញត្រូវបោកបញ្ឆោតហើយហ្ន៎ អញមិនមានលាភហ្ន៎ កើតបីតិបាមោជ្ជ ដូចបុរសទ័លក្រ ជួបនូវកំណប់ទ្រព្យធំ ទើបចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

បទថា **បរមេន អស្សាសេន** សេចក្ដីថា ដោយការត្រេកអរយ៉ាងក្រៃលែង ពោល គឺមគ្គផល ។ បទថា **អស្សាសាយ ធម្មំ ទេសេមិ** សេចក្ដីថា តថាគតនឹងសម្ដែងធម៌ដើម្បីល្ហួងលោមចិត្ត ដើម្បីឧបការៈ ។ ដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្ដែងធម៌ដល់សីហសេនាបតី ដោយអង្គ ៨ ។

បទថា **អនុវិច្ចការំ** សេចក្ដីថា ពិចារណាហើយ អធិប្បាយថា គិតហើយ គឺត្រិះរិះហើយ ទើបធ្វើកិច្ចដែលគួរធ្វើ ។ បទថា **សាធុ ហោតិ** ប្រែថា ជាការល្អ ។ ពិតហើយ កាលបុគ្គលដូចអ្នកឃើញតថាគតហើយ ក៏ដល់នូវតថាគតថាជាទីពឹង ឃើញនិគ្រន្ថហើយ ក៏ដល់នូវនិគ្រន្ថថាជាទីពឹង រមែងកើតនូវការនិន្ទាឡើងថា ហេតុអ្វី ទើបសីហសេនាបតីនេះដល់នូវបុគ្គលដែលខ្លួនឃើញហើយប៉ុណ្ណោះថាជាទីពឹង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្ដែងថា ការពិចារណាមុនហើយសឹមធ្វើ ទើបជាការល្អសម្រាប់បុគ្គលដូចអ្នក ។ បទថា **បដាកំ បរិហរេយ្យុំ** សេចក្ដីថា បានឮថា និគ្រន្ថទាំងនោះ បានបុគ្គលបែបនេះជាសាវ័ក ក៏លើកបដាត្រាច់ប្រកាសទៅក្នុងព្រះនគរថា ព្រះរាជាអង្គនោះ រាជមហាមាត្យនោះ សេដ្ឋីនោះ ដល់យើងជាសរណៈ ។

ព្រោះហេតុអ្វី ព្រោះនិគ្រន្ថទាំងនោះគិតថា កាលបើដូច្នេះ ភាពជាធំរបស់ខ្លួន នឹងប្រាកដច្បាស់ នឹងគិតថា បើសីហសេនាបតីនោះគប្បីកើតការក្តៅក្រហាយចិត្តឡើងថា អញដល់នូវនិគ្រន្ថទាំងនេះជាទីពឹងធ្វើអ្វី នឹងបន្ទោបង់ការក្តៅក្រហាយចិត្តនោះថា ជនជាច្រើនដឹងថា អញដល់និគ្រន្ថទាំងនោះជាទីពឹង ក៏នឹងមិនថយក្រោយ ព្រោះហេតុនោះ ទើបពោលថា **បដាកំ បរិហរេយ្យុំ។**

បទថា **ឱបានភូតំ** បានដល់ ត្រកូលដែលតាំងទៅដូចអណ្តូងទឹកដែលគេរៀបចំ ។ បទថា **កុលំ** បានដល់ និវេសន៍ដែលនៅអាស្រ័យរបស់លោក ។ ដោយបទថា **ទាតព្វំ មញ្ញេយ្យាសិ** នេះ ព្រះមានព្រះភាគទ្រង់ឱវាទថា ក្នុងកាលមុនអ្នកឃើញជន ១០ នាក់ខ្លះ ២០ នាក់ខ្លះ មកដល់ មិនពោលថា មិនមានហើយក៏ឲ្យទៅ ឥឡូវនេះ អ្នកកុំកាត់ទេយ្យធម៌សម្រាប់និគ្រន្ថទាំងនេះ ដោយហេតុត្រឹមតែដល់តថាគតជាទីពឹងប៉ុណ្ណោះឡើយ ការពិត អ្នកគួរឲ្យដល់ពួកនិគ្រន្ថដូចមុន ។ សីហសេនាបតីទូលថា ពាក្យនោះខ្ញុំព្រះអង្គបានស្តាប់មកហើយ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់សួរថា បានស្តាប់មកអំពីណា សីហសេនាបតីទូលថា អំពីសម្នាក់និគ្រន្ថ ព្រះអង្គ ។ បានឮថា និគ្រន្ថទាំងនោះប្រកាសទៅក្នុងក្រុងនៃត្រកូលទាំងឡាយយ៉ាងនេះថា យើងទាំងឡាយពោលថា គួរឲ្យដល់បុគ្គលណាមួយដែលមកដល់ តែព្រះ-សមណគោតមពោលយ៉ាងនេះថា គួរឲ្យទានដល់តថាគតប៉ុណ្ណោះ មិនគួរឲ្យដល់អ្នកដទៃ គួរឲ្យដល់សាវ័ករបស់តថាគតប៉ុណ្ណោះ មិនគួរឲ្យដល់សាវ័កនៃ

សាស្ដាដទៃ ទានដែលឲ្យដល់តថាគតប៉ុណ្ណោះ មានផលច្រើន ទានដែលឲ្យដល់អ្នកដទៃ មិនមានផលច្រើនឡើយ ទានដែលឲ្យដល់សាវកប៉ុណ្ណោះ មានផលច្រើន ដែលឲ្យដល់សាវករបស់សាស្ដាដទៃ មិនមានផលច្រើនឡើយ សីហសេនាបតីពោលថា **សុតមេតំ** សំដៅយកពាក្យនោះ ។

បទថា **អនុបុព្វិកថំ** បានដល់ ពាក្យតាមលំដាប់យ៉ាងនេះថា សីលក្នុងលំដាប់នៃទាន ស្ថានសួគ៌ក្នុងលំដាប់នៃសីល មគ្គក្នុងលំដាប់នៃស្ថានសួគ៌ ។ បណ្ដាបទទាំងនោះ បទថា **ទានកថំ** បានដល់ ពាក្យដែលទាក់ទងដោយគុណរបស់ទាន មានពាក្យថា ឈ្មោះថា ទាននេះ ជាហេតុនៃសេចក្ដីសុខ ជាមូលនៃសម្បត្តិ ជាទីតាំងនៃភោគៈទាំងឡាយ ជាទីពួន ជាទីសម្ងំ ជាគតិ ជាទីពុំនាក់អាស្រ័យនៃបុគ្គលដែលដើរផ្លូវមិនរាបស្មើ ជាទីអាស្រ័យ ជាទីពឹង ជាទីទាញទុក ជាទីពួន ជាទីសម្ងំ ជាទីទៅ ជាទីស្នាក់ ដូចគ្នានឹងទានក្នុងលោកនេះ និងលោកខាងមុខ មិនមាន ។ ពិតហើយ ទាននេះ ដូចគ្នានឹងអាសនៈមាស ដែលសម្រេចដោយរតនៈ ព្រោះអត្ថថា ជាទីពឹងអាស្រ័យ ដូចគ្នានឹងមហាប្រឹថពី ព្រោះអត្ថថា ជាទីតាំងអាស្រ័យ ដូចគ្នានឹងខ្សែសម្រាប់ចងព្រោះអត្ថថា ជាទីចងទាននេះ ដូចជានាវា ព្រោះអត្ថថា ជាទីជួយបំបាត់ទុក្ខ ដូចជាអ្នកចម្បាំងដ៏ក្លៀវក្លាក្នុងសង្គ្រាម ព្រោះអត្ថថា ជាទីល្ហួងចិត្ត ដូចជានគរដែលបានតាក់តែងល្អហើយ ព្រោះអត្ថថា ជាទីពួនអំពីភ័យ ដូចជាផ្កាបទុម ព្រោះអត្ថថា មិនត្រូវមន្ទិល គឺការកំណាញ់ជាដើមទទឹក ដូចភ្លើង ព្រោះ

អត្ថថា ជុតមទ្ទិល គឺការកំណាញ់ជាដើមនោះ ដូចអាសិរពិស ព្រោះអត្ថថា បុគ្គលចូលជិតបានដោយលំបាក ដូចសីហៈ ព្រោះអត្ថថា មិនតក់ស្លុត ដូចដំរី ព្រោះអត្ថថា មានកម្លាំង ដូចគោឧសភៈពណ៌ស ព្រោះអត្ថថា ដែលសត្វលោកសន្មតថាជាមង្គលក្រៃលែង ដូចស្តេចសេះវលាហក ព្រោះអត្ថថា ធ្វើបុគ្គលឲ្យដល់នូវដែនក្សេមផុតភ័យ ។ ធម្មតាទាននេះ ជាផ្លូវដែលតថាគតទៅ នុ៎ះជាវង្សនៃតថាគត តថាគតកាលបំពេញបារមី ១០ បានបដិបត្តិមហាយញ្ញជាអនេក គឺមហាយញ្ញ កាលនៅជាវេលាមព្រាហ្មណ៍ មហាយញ្ញ កាលជាមហាគោវិន្ទព្រាហ្មណ៍ មហាយញ្ញ កាលជាស្តេចចក្រពត្តិ ឈ្មោះថា មហាសុទស្សនៈ មហាយញ្ញកាលជាវេស្សន្តរ កាលជាសត្វទន្សាយ បានប្រគល់ខ្លួនក្នុងគំនរភ្លើងដែលឆេះសន្ធោសន្ធៅ ហើយប្រព្រឹត្តផ្គងនូវចិត្តដ៏អង់អាច ដែលមកដល់បាន ដ្បិតថា ទានក្នុងលោក រមែងឲ្យនូវសក្កសម្បត្តិ មារសម្បត្តិ ព្រហ្មសម្បត្តិ ចក្រពត្តិសម្បត្តិ សាវកបារមីញាណ បច្ចេកពោធិញ្ញាណ ឲ្យអភិសម្ពោធិញ្ញាណ ។

ព្រោះហេតុដែលឲ្យទាន អាចសមាទានសីលបាន ដូច្នោះ ទើបត្រាស់សីលកថាក្នុងលំដាប់ទាន ។ បទថា **សីលកថំ** បានដល់ វាចាដែលទាក់ទងដោយគុណរបស់សីលជាដើមយ៉ាងនេះថា ឈ្មោះថា សីលនេះ ជាទីអាស្រ័យ ជាទីពុំនាក់ ជាទីតោង ជាទីពួន ជាគតិ ជាទីទៅខាងមុខ ធម្មតាសីលនេះ ជាវង្សរបស់តថាគតៗ បំពេញសីលក្នុងអត្តភាពទាំងឡាយ មិនមានទីបំផុត ដូច

កាលនៅជាស្តេចនាគ ឈ្មោះសង្ខបាល កាលជាស្តេចនាគ ឈ្មោះចម្ប្បេយ្យ កាលនៅជាស្តេចនាគ ( ដំរី ) ឈ្មោះសីលវៈ កាលជាស្តេចដំរីដែលជាអ្នកចិញ្ចឹមមាតា កាលជាស្តេចដំរីឈ្មោះឆទ្ទន្ត ព្រោះទីអាស្រ័យ ទីពឹង ទីទាញ ទីពួន ទីសម្ងំ ទីទៅ និងទីពុំនាក់នៃសម្បត្តិក្នុងលោកនេះ និងលោកដទៃដូចសីលមិនមាន ។ គ្រឿងអលង្ការ ដូចគ្នានឹងសីលមិនមាន ។ ផ្កាដូចគ្នានឹងសីលមិនមាន ក្លិនដូចគ្នានឹងក្លិនសីលមិនមាន ព្រោះសត្វលោក និងទេវលោក កាលសម្លឹងមើលបុគ្គលដែលប្រដាប់ដោយគ្រឿងអលង្ការ គឺសីល លាបស្រឡាបដោយក្លិន គឺសីល រមែងមិនឆ្អែតឆ្អន់ ម្យ៉ាងទៀត ដើម្បីសម្តែងថា បុគ្គលអាស្រ័យសីលនេះ រមែងបាននូវសគ្គៈនេះ ទើបត្រាស់សគ្គកថាក្នុងលំដាប់នៃសីល ។

បទថា **សគ្គកថំ** បានដល់ ពាក្យដែលទាក់ទងដោយគុណនៃស្ថានសួគ៌ មានពាក្យថា ធម្មតាស្ថានសួគ៌នេះគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ក្នុងស្ថានសួគ៌នោះ មានការលេងជានិច្ច បានសម្បត្តិជានិច្ច ទេវតាជាន់ចាតុម្មហារាជកា សោយសុខទិព្វសម្បត្តិ ៩ ម៉ឺនឆ្នាំ ទេវតាជាន់តាវត្តិង្សសោយសុខទិព្វសម្បត្តិ ៣ កោដិ ៦ លានឆ្នាំជាដើម ។ ពិតហើយ ព្រះឱស្ឋរបស់ព្រះពុទ្ធទាំងឡាយ មិនល្មមគ្រប់គ្រាន់សម្រាប់ពណ៌នាសគ្គសម្បត្តិ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតគប្បីពោលសគ្គកថា ដោយអនេកបរិយាយ ។ ព្រះមានព្រះភាគ កាលត្រាស់លួង

លោម ដោយសត្តកថាយ៉ាងនេះហើយ ដើម្បីសម្ដែងថា ស្ថានសួគ៌នេះមិនទៀង មិនស្ថិតស្ថេរ មិនគួរធ្វើសេចក្ដីត្រេកអរ ដោយអំណាចការពេញចិត្តក្នុងស្ថានសួគ៌នោះ ដូចបុគ្គលប្រដាប់ដំរីហើយ កាត់ប្រមោយចេញ ទើបទ្រង់សម្ដែងទោសការថោកថយ ការសៅហ្មងនៃកាមទាំងឡាយ ដោយន័យជាដើមថា កាមទាំងឡាយ មានសេចក្ដីរីករាយតិច មានទុក្ខច្រើន មានការចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានច្រើនក្រៃលែង ។ បណ្ដាបទទាំងនោះ បទថា **អាទីនវោ** បានដល់ ទោស ។ បទថា **ឱការោ** ប្រែថា ការថោកថយ បានដល់ ការថោកទាប ។ បទថា **សង្កិលេសោ** បានដល់ ការដែលសត្វទាំង-ឡាយសៅហ្មងក្នុងសង្សារវដ្ដដោយកាមទាំងនោះ ។ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលអ្នកទាំងឡាយ សត្វទាំងឡាយ រមែងសៅហ្មងហ្ន៎ ។

ព្រះមានព្រះភាគ កាលទ្រង់បង្ហាញទោសនៃកាមយ៉ាងនេះហើយ ទ្រង់ប្រកាសអានិសង្សក្នុងនេក្ខម្មៈ គឺការចេញចាកកាម ។ បទថា **កល្លចិត្តំ** បានដល់ ចិត្តមិនខូច ។ បទថា **សាមុក្កំសិកា** បានដល់ ព្រះធម្មទេសនាដែលទ្រង់លើកឡើងឯង គឺចាប់លើកឡើងដោយព្រះអង្គឯង អធិប្បាយថា ព្រះធម្មទេសនាដែលទ្រង់ឃើញដោយព្រះសយម្ភូញាណ មិនសាធារណៈដល់បុគ្គលដទៃ ។ សួរថា ទេសនាដែលលើកឡើងសម្ដែងឯង គឺអ្វី ។ ឆ្លើយថា គឺអរិយសច្ចទេសនា ។ ដោយហេតុនោះឯង ទើបលោកពោលថា **ទុក្ខំ សមុទយំ និរោធំ មគ្គំ**។ បទថា **វិរជំ វីតមលំ** សេចក្ដីថា ធម្មចក្ខុ ឈ្មោះ

ថា ប្រាសចាកធូលី ព្រោះមិនមានធូលី គឺរាគៈជាដើម ។ ឈ្មោះថា ប្រាសចាកមន្ទិល ព្រោះប្រាសចាកមន្ទិល មានមន្ទិល គឺរាគៈជាដើម ។ ក្នុងបទថា **ធម្មចក្ខុំ** នេះ សំដៅដល់សោតាបត្តិមគ្គ ។ ដើម្បីទ្រង់សម្តែងការកើតឡើងនៃសោតាបត្តិមគ្គនោះ ទើបត្រាស់ថា **យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ** ធម្មជាតិណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតិទាំងឡាយនោះ មានការរលត់ទៅជាធម្មតា ។ ធម្មចក្ខុនោះ ធ្វើនិរោធឲ្យជាអារម្មណ៍ ដឹងច្បាស់នូវធម៌ គឺសច្ចៈ ដោយអំណាចកិច្ចនោះឯងកើតឡើង ។

អរិយសច្ចធម៌ដែលសីហសេនាបតីនោះឃើញហើយ ព្រោះដូច្នោះ ទើបឈ្មោះថា ទិដ្ឋធម៌ គឺបុគ្គលមានធម៌ឃើញហើយ ក្នុងបទដ៏សេស ក៏មានន័យដូច្នេះ ។ វិចិកិច្ឆា សីហសេនាបតីនោះឆ្លងបានហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **តិណ្ណវិចិកិច្ឆ** ។ ការងឿងឆ្ងល់របស់សីហសេនាបតីនោះ បានទៅប្រាសហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **វិគតកថំកថ** ។ សីហសេនាបតីនោះដល់នូវភាពជាបុគ្គលក្លៀវក្លា ព្រោះហេតុនោះ ទើបឈ្មោះថា **វេសារជ្ជប្បត្ត** ។ បុគ្គលដទៃមិនជាបច្ច័យនៃសេនាបតីនោះ ក្នុងសាសនារបស់ព្រះសាស្តា គឺប្រព្រឹត្តទៅក្នុងសាសនាដោយមិនចាំបាច់ជឿអ្នកដទៃ ព្រោះហេតុនោះ ទើបឈ្មោះថា **អបរប្បច្ចយ** ។

បទថា **បវត្តមំសំ** បានដល់ សាច់ដែលជាកប្បិយ ដែលប្រព្រឹត្តទៅហើយតាមប្រក្រតី ។ អធិប្បាយថា អ្នកចូររកទិញក្នុងរានផ្សារ ។ បទថា

**សម្ពហុលា និគ្គណ្ឋា** បានដល់ និគ្រន្ថប្រមាណ ៥០០ ។ បទថា **ថូលំ បសុំ** បានដល់ សត្វចិញ្ចឹម ពោល គឺគ្កាន់ ក្របី និងជ្រូកដែលធាត់ គឺមានខ្លួនធំ ។ បទថា **ឧទ្ទិស្សកតំ** សេចក្តីថា សាច់ដែលគេធ្វើ គឺសម្លាប់ចំពោះខ្លួន ។ បទថា **បដិច្ចកម្មំ** សេចក្តីថា ព្រះសមណគោតមនេះ រមែងត្រូវកម្ម គឺការសម្លាប់ជីវិតនោះ ព្រោះអាស្រ័យសាច់នេះ ។ និគ្រន្ថទាំងនោះ មានលទ្ធិយ៉ាងនេះ ពិតហើយ កម្មដែលជាអកុសលនោះមានដល់ទាយកពាក់កណ្តាល មានដល់បដិគ្គាហកពាក់កណ្តាល ។ ម្យ៉ាងទៀត បទថា **បដិច្ចកម្មំ** បានដល់ សាច់ដែលគេអាស្រ័យខ្លួនធ្វើ ។ ម្យ៉ាងទៀត បទថា **បដិច្ចកម្មំ** នេះ ជាឈ្មោះនៃនិមិត្តកម្ម បដិច្ចកម្មមានក្នុងសាច់នេះ ព្រោះហេតុនោះ សូម្បីសាច់ក៏ហៅថា **បដិច្ចកម្ម** ។

បទថា **ឧបកណ្ណកេ** ប្រែថា ត្រង់គុម្ពត្រចៀក ។ ពាក្យថា **អលំ** នេះ ជាពាក្យបដិសេធ អធិប្បាយថា នឹងមានប្រយោជន៍អ្វីដោយសាច់នេះ ។ បទថា **ន ច បនេតេ** សេចក្តីថា លោកទាំងនោះ ជាអ្នកតិះដៀលមកអស់កាលយូរ ។ សូម្បីកាលពោលតិះដៀល ក៏ពោលទោសមិនបណ្តាក់មាត់ អធិប្បាយថា ពោលទោសមិនចេះចប់ ។ ម្យ៉ាងទៀត បទថា **ជីរន្តិ** នេះ គប្បីឃើញដោយអត្ថថា ខ្មាស អធិប្បាយថា រមែងមិនខ្មាស ។

## អដ្ឋកថាសីហសូត្រទី ២ ចប់

# សុត្តន្តបិដក

## អស្សាជានីយសូត្រទី ៣

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ស្តេចដែលប្រកបដោយអង្គ ៨ យ៉ាង ជាសត្វគួរដល់ព្រះរាជា ជារាជបម្រើ ដល់នូវការរាប់ថា ជាអង្គរបស់ព្រះរាជា ។ អង្គ ៨ យ៉ាងដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ សេះអាជានេយ្យដ៏ល្អរបស់ស្តេច ជាសត្វមានកំណើតដ៏ល្អទាំងពីរខាង គឺទាំងខាងមេ និងខាងបា ១ សេះអាជានេយ្យទាំងឡាយដ៏ល្អដទៃទៀត កើតក្នុងទិសណា ក៏កើតក្នុងទិសនោះ ១ ជនទាំងឡាយ ឲ្យស្មៅស្រស់ក្តី ស្មៅស្ងួតក្តីណា ដល់វាៗ ក៏ចេះតែស៊ីស្មៅស្រស់ ឬស្មៅស្ងួតនោះដោយគោរព មិនឲ្យរាត់រាយ ១ ជាសត្វខ្ពើមរអើមនឹងការអង្គុយសង្កត់ នូវឧច្ចារៈ និងបស្សាវៈ ១ វាជាសត្វត្រេកអរ តែងសប្បាយ មិនបៀតបៀននូវពួកសេះដទៃ ១ ការអួតអាង កោង មីតពត់ និងការវៀចទាំងឡាយណារបស់វាៗ ក៏ធ្វើនូវការអួតអាងជាដើមនោះ ឲ្យជាក់ច្បាស់គួរតាមពិត ដល់នាយសារថីៗ ក៏ព្យាយាមដើម្បីញាំញីនូវការអួតអាងជាដើមរបស់វា ១ ជាសត្វតែងនាំទៅ តែងញុំាងចិត្តឲ្យកើតឡើងថា ពួកសេះដទៃ ទោះនាំទៅក៏ដោយ មិននាំទៅក៏ដោយ អញនឹងនាំទៅដោយពិតក្នុងទីនោះ កាលដែលទៅក៏រមែងទៅតាមផ្លូវត្រង់តែម្យ៉ាង ១ ជាសត្វមានកម្លាំងមាំមួន ដែលនឹងជយកម្លាំង ត្រាតែសេចក្តីស្លាប់គ្របសង្កត់ជីវិត ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ស្តេច ប្រកបដោយអង្គ ៨ យ៉ាងនេះឯង ជាសត្វគួរ

ដល់ព្រះរាជា ជារាជបម្រើ ដល់នូវការរាប់ថា ជាអង្គរបស់ព្រះរាជា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក៏យ៉ាងនោះដែរ ជាអ្នកប្រកបដោយធម៌ ៨ យ៉ាង ទើបជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល តែងសង្រួមក្នុងបាតិមោក្ខសំវរសីល ជាអ្នកបរិបូណ៌ដោយអាចារៈ និងគោចរ ១ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីមានប្រមាណតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជនប្រគេននូវភោជនណាមួយ ទោះសៅហ្មងក្តី ឧត្តមក្តី ដល់លោកៗ ក៏ចេះតែឆាន់នូវភោជននោះដោយគោរព មិនរើសអើង ១ ជាអ្នកខ្ពើមរអើមចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ខ្ពើមរអើមចំពោះការជួបប្រសព្វនឹងអកុសលធម៌ទាំងឡាយដ៏លាមក ១ លោកជាអ្នករីករាយ មានការនៅសប្បាយ មិនបៀតបៀនពួកភិក្ខុដទៃ ១ ការអួតអាង កោង មឹតពត់ និងការវៀចទាំងឡាយណារបស់លោកៗ ជាអ្នកធ្វើនូវការអួតអាងជាដើមនោះ ឲ្យជាក់ច្បាស់តាមពិតចំពោះព្រះសាស្តា ឬសព្រហ្មចារីជាវិញ្ញូជន ព្រះសាស្តា ឬសព្រហ្មចារីជាវិញ្ញូជន តែងព្យាយាមដើម្បីញ៉ាំញីនូវការអួតអាងជាដើមនោះរបស់លោក ១ ជាអ្នកសិក្សា ញ៉ាំងចិត្តឲ្យកើតឡើងថា ពួកភិក្ខុដទៃ ទោះសិក្សាក៏ដោយ មិនសិក្សាក៏ដោយ អញនឹងសិក្សាក្នុងធម្មវិន័យនេះ ដោយពិត លោកកាលនឹងទៅ ក៏ទៅតាមផ្លូវត្រង់តែម្យ៉ាង

*បណ្តាផ្លូវត្រង់ទាំងនោះ ផ្លូវត្រង់នេះ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ជាអ្នកមានសេចក្តីព្យាយាមតឹងតែងថា ស្បែក សរសៃ និងឆ្អឹង ចូរស្ងិតក្រៀម ចុះ សាច់ និងឈាម ចូររីងស្ងួតក្នុងសរីរៈចុះ កិច្ចណា ដែលអ្នកផងត្រូវ ដល់ ដោយកម្លាំងនៃបុរស ព្យាយាមនៃបុរស សេចក្តីប្រឹងប្រែងនៃបុរស បើ មិនទាន់ដល់នូវកិច្ចនោះទេ ក៏មិនបញ្ឈប់សេចក្តីព្យាយាម ១ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវ ចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។*

# អដ្ឋកថា

## អស្សាជានីយសូត្រ

*[ ១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអស្សាជានីយសូត្រទី ៣ ដូចតទៅនេះ បទថា* **អង្គេហិ** *បានដល់ ដោយអង្គ គឺគុណ ។ បទថា* **តស្មិំ ទិសាយំ ជាតោ ហោតិ** *សេចក្តីថា សេះសិន្ធពអាជានេយ្យកើតត្រង់ប្រាំងស្ទឹងសិន្ធុ នោះ ។ សេះអាជានេយ្យដែលល្អដទៃ រមែងកើតក្នុងទីនោះឯង ។ បទថា* **អល្លំ វា សុក្ខំ វា** *បានដល់ ស្មៅស្រស់ ឬស្មៅស្ងួត ។ បទថា* **ឆ ៩ អញ្ញេ អស្សេ ឧព្ពេជេតា** *សេចក្តីថា សេះអាជានេយ្យនោះ មិនបៀតបៀន គឺ*

មិនកោងកាច មិនឈ្លោះនឹងសេះដទៃ ។

បទថា **សាដេយ្យានិ** ប្រែថា អួតអាង ។ បទថា **កូដេយ្យានិ** ប្រែថា កោង ។ បទថា **ជិម្ហេយ្យានិ** ប្រែថា បោកបញ្ឆោត ។ បទថា **វង្កេយ្យានិ** ប្រែថា វៀចវេរ ។ ព្រះមានព្រះភាគត្រាស់ថា សេះអាជានេយ្យនោះ មិនទាន់បានសិក្សាដោយបទទាំង ៤ ដោយប្រការដូច្នេះ ។ បទថា **វាហី** បានដល់នាំភារៈទៅជាសភាវៈ គឺតបស្នងនឹងពាក្យប្រើដែលគេឲ្យ ។ បទថា **យាវជីវិតមរណបរិយាទានា** បានដល់ ដរាបដល់អស់ជីវិតដោយការមរណៈ ។ បទថា **សក្កច្ចំ បរិភុញ្ជតិ** សេចក្តីថា ពិចារណាកោជនដូចទឹកអមតៈហើយ ទើបបរិភោគដោយខ្លួនឯងនោះឯង ។ ក្នុងបទថា **បុរិសថាមេន** ជាដើម ព្រះមានព្រះភាគត្រាស់ដល់កម្លាំងញាណជាដើម ។ បទថា **សណ្ឋានំ** បានដល់ ធូរថយ ។៚

**អដ្ឋកថា អស្សាជានីយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## អស្សខឡុង្កសូត្រទី ៤

[ ១៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេះមានពុតត្បុត ៨ យ៉ាង និងទោសនៃសេះ ៨ យ៉ាង បុរសមានពុតត្បុត ៨ យ៉ាង និងទោស

នៃបុរស ៨ យ៉ាង ចូរអ្នកទាំងឡាយ ចាំស្តាប់នូវធម៌នោះចុះ ។បេ។ ម្នាល ភិក្ខុទាំងឡាយ សេះមានពុតត្បុត ៨ យ៉ាង និងទោសនៃសេះ ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ត្រឡប់ថយក្រោយ ញុំាងរថឲ្យត្រឡប់ថយក្រោយ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះបែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ប្រោយជើងខាងក្រោយ ទង្គិចក្បាលទឹងក្បាលក្រពើរថផង បំបាក់ឈើជា ៣ កំណាត់ ( ថែរថ ) ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះបែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថី និយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏លើកនូវជើង ពាក់លើចន្ទោលនៃរថ ញុំាញីនូវចន្ទោលរថ ឲ្យខ្ទេចខ្ទី ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះបែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៣ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ប្រកាន់ខុសផ្លូវ ធ្វើរថឲ្យខុសផ្លូវ

ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះក្នុងលោកនេះបែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៤ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ជាសំតឿន ក៏លោតកញ្ជ្រោលកាយខាងមុខ ផ្គងនូវជើងទាំងពីរខាងមុខ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៥ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ជាសំតឿន ក៏មិនអើពើនឹងជង្ជនញ ខាំផ្តាច់នូវខ្សែបង្ហៀរ ដោយធ្មេញទាំងឡាយ ហើយគេចចេញទៅតាមសេចក្តីប្រាថ្នា ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៦ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ជាសំតឿន ក៏មិនឈានទៅមុខ មិនឈានថយក្រោយ នៅឈរនឹងថ្កល់ដូចជាសសរខឿនក្នុងទីនោះដដែល ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៧ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ជាសំតឿន ក៏កន្ត្រាញជើង

ទាំងពីរខាងមុខ កន្ត្រាញជើងទាំងពីរខាងក្រោយ ហើយក្រាបសន្ធត់នូវជើងទាំង ៤ ក្នុងទីនោះឯង ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៨ ។ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុត ៨ យ៉ាង និងទោសនៃសេះ ៨ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុត ៨ យ៉ាង និងទោសនៃបុរស ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ ដាស់តឿនភិក្ខុផងគ្នា ដោយអាបត្តិ ភិក្ខុនោះ កាលដែលភិក្ខុទាំងឡាយ ដាស់តឿនដោយអាបត្តិ ក៏បណ្តោះបណ្តែអំពីអាបត្តិថា ខ្ញុំនឹកមិនឃើញទេៗ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ត្រឡប់ថយក្រោយ ញុំាងរថឲ្យត្រឡប់ខាងក្រោយ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នា ដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុដាស់តឿនដោយអាបត្តិ ក៏តបតនឹងពាក្យចោទវិញថា ប្រយោជន៍អ្វី អញនឹងនិយាយជាមួយអ្នកឯង ដែលជាមនុស្សពាល មិនឈ្លាសវៃ អម្បាលយ៉ាងអញ អ្នកឯងហ៊ានសម្គាល់ថាជាបុគ្គល គួរគេស្តីថាបានទៅហើយ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ

កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ប្រាយជើងខាងក្រោយទន្ទិចក្បាលនឹងក្បាលក្រពើរថ បំបាក់ឈើជា ៣ កំណាត់ ( ចែរថ ) មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុដាស់តឿនដោយអាបត្តិ ក៏ត្រឡប់លើកទោស ដល់ភិក្ខុអ្នកដាស់តឿនវិញថា អ្នកឯងទេតើ ដែលត្រូវអាបត្តិឈ្មោះនេះ អ្នកឯងចូរសម្ដែងអាបត្តិមុនសិនទៅ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ ដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏លើកនូវជើងពាក់លើចន្ទោលរថ ហើយញាំញីនូវចន្ទោលរថឲ្យខ្ទេចខ្ទី មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៣ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុ ដាស់តឿនដោយអាបត្តិ ក៏បិទបាំងនូវហេតុដទៃ ដោយហេតុដទៃ ទាត់ពាក្យសម្ដីចោលទៅខាងក្រៅ ធ្វើនូវសេចក្ដីក្រោធផង នូវទោសផង នូវសេចក្ដីមិនត្រេកអរផង ឲ្យប្រាកដ ម្នាលភិក្ខុទាំងឡាយ សេះ

មានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ប្រកាន់ខុសផ្លូវ ធ្វើរថឲ្យខុសផ្លូវ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៤ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុដាស់តឿនដោយអាបត្តិ ក៏និយាយច្ចារដៃក្នុងកណ្តាលជំនុំសង្ឃ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏លោតកញ្ជ្រោលកាយខាងមុខ ផ្គងនូវជើងទាំងពីរខាងមុខ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៥ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលដែលភិក្ខុទាំងឡាយដាស់តឿន ដោយអាបត្តិ ក៏មិនអើពើនឹងសង្ឃ មិនអើពើនឹងភិក្ខុអ្នកដាស់តឿន ដើរចេញទៅទាំងអាបត្តិ កាន់ទីតាមសេចក្តីប្រាថ្នា ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ដាស់តឿន ក៏មិនអើពើនឹងជន្លួញ ខាំផ្តាច់នូវខ្សែបង្ហៀរដោយធ្មេញទាំងឡាយ ហើយគេចចេញទៅតាមសេចក្តីប្រាថ្នា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ

តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៦ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នា ដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុដាស់តឿនដោយអាបត្តិ ក៏ប្រកែកថា ខ្ញុំមិនត្រូវអាបត្តិទេៗ ភិក្ខុនោះ រមែងបៀតបៀននូវសង្ឃដោយតុណ្ហីភាព ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏មិនឈានទៅមុខ មិនឈានថយក្រោយ នៅឈរនឹងថ្កល់ ដូចជាសសរខឿនក្នុងទីនោះដដែល មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៧ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុចោទដោយអាបត្តិ ក៏ពោលយ៉ាងនេះថា លោកទាំងឡាយដ៏មានអាយុ ហេតុអ្វី ក៏បានជាខ្វល់ខ្វាយនឹងខ្ញុំខ្លាំងម្ល៉េះ ណ្ហើយចុះ ខ្ញុំនឹងលាសិក្ខា ត្រឡប់មកកាន់ភេទថោកទាបវិញ ក្នុងឥឡូវនេះ ភិក្ខុនោះក៏លាសិក្ខា ហើយត្រឡប់មកកាន់ភេទថោកទាបរួចពោលយ៉ាងនេះថា ឥឡូវនេះ លោកទាំងឡាយដ៏មានអាយុ ចូរមានចិត្តត្រេកអរចុះ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយ

សារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏កន្ទ្រាញជើងទាំងពីរខាងមុខ កន្ទ្រាញជើងទាំងពីរខាងក្រោយ ក្រាបសន្តត់នូវជើងទាំង ៤ ក្នុងទីនោះឯង មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៨ ។ ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុត ៨ យ៉ាង និងទោសនៃបុរស ៨ យ៉ាងនេះឯង ។

# អដ្ឋកថា

## អស្សខឡុង្កសូត្រ

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអស្សខឡុង្កសូត្រទី ៤ ដូចតទៅនេះ បទថា **បេហីតិ វុត្តោ** បានដល់ សេះអាជានេយ្យនោះ ដែលសារថីពោលថា ចូរទៅ ។ បទថា **បដ្ឋិតោ រថំ បវត្តេតិ** សេចក្តីថា យកឆ្អឹងកកៀបនឹមហើយនាំរថថយទៅក្នុងចំណែកទិសខាងក្រោយ ។ បទថា **បច្ឆា លង្ឃិបតិ កុព្វរំ បហារតិ** សេចក្តីថា លើកជើងក្រោយទាំង ២ ឡើង ហើយយកជើងទាំង ២ ប្រាយទម្លាយទូករថ ។ បទថា **តិទណ្ឌំ** សេចក្តីថា ទម្លាយឈើ ៣ កំណាត់ដែលនៅខាងមុខរថ ។ បទថា **រថីសាយ សត្ថឹ ឧស្សជ្ជិត្វា** សេចក្តី

ថា ឱនក្បាលចុះ ទម្លាក់នឹមដល់ផែនដី ប្រើជើងខាកចន្ទោលរថ ។ បទថា **អជ្ឈោមទ្ធតិ** សេចក្ដីថា ប្រើជើងមុខទាំង ២ ជាន់ចន្ទោលរថ ឈរនៅ ។ បទថា **ឧត្តរជមំ វថំ ករោតិ** សេចក្ដីថា លើករថឡើងទួល ឬទីដែលមានបន្លា ។ បទថា **អនាទិយិត្វា** បានដល់ ការមិនដាក់ចិត្ត គឺមិនអើពើ ។ បទថា **មុខាធានំ** បានដល់ បង្ហៀរដែលគេដាក់ក្នុងមាត់ ។ បទថា **ខិលដ្ឋាយី** សេចក្ដីថា សេះឈរជើង ៤ មិនកម្រើក ដូចសសរ នៅឈប់មួយកន្លែង ដូចគ្នានឹងសសរខឿន ព្រះមានព្រះភាគត្រាស់វដ្ដៈតែម្យ៉ាងក្នុងព្រះសូត្រនេះ ។

## អដ្ឋកថា ខឡុង្គសូត្រទី ៤ ចប់

# មលសូត្រទី ៥

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ មន្ទិលនេះមាន ៨ យ៉ាង ។ មន្ទិល ៨ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មន្តទាំងឡាយ មានការមិនស្វាធ្យាយ ជាមន្ទិល ១ ម្នាលភិក្ខុទាំងឡាយ ផ្ទះទាំងឡាយមានការមិនថែទាំ ជាមន្ទិល ១ ម្នាលភិក្ខុទាំងឡាយ ការខ្ជិលច្រអូស ជាមន្ទិលនៃសម្បុរសរីរៈ ១ ម្នាលភិក្ខុទាំងឡាយ ការប្រហែសធ្វេស ជាមន្ទិលនៃអ្នកថែរក្សា ១ ម្នាលភិក្ខុទាំងឡាយ ការប្រព្រឹត្តអាក្រក់ ( ចំពោះប្ដី ) ជាមន្ទិលរបស់ស្ត្រី ១ ម្នាលភិក្ខុទាំងឡាយ សេចក្ដីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ១ ម្នាលភិក្ខុ

ទាំងឡាយ អកុសលធម៌ដ៏លាមក ជាមន្ទិលក្នុងលោកនេះ និងលោកខាងមុខ ១ ម្នាលភិក្ខុទាំងឡាយ មន្ទិលដ៏លើស ជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលយ៉ាងក្រៃលែង ១ ។ ម្នាលភិក្ខុទាំងឡាយ មន្ទិល ៨ យ៉ាងនេះឯង ។

មន្តទាំងឡាយ មានការមិនស្វាធ្យាយ ជាមន្ទិល ផ្ទះ
ទាំងឡាយមានការមិនថែទាំ ជាមន្ទិល ការខ្ជិលច្រអូស
ជាមន្ទិលនៃពណ៌សម្បុរ ការប្រហែសធ្វេស ជាមន្ទិល
នៃអ្នកថែរក្សា ការប្រព្រឹត្តអាក្រក់ ( ចំពោះប្តី ) ជា
មន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នក
ឲ្យ អកុសលធម៌ដ៏លាមក ជាមន្ទិលក្នុងលោកនេះ និង
លោកខាងមុខ មន្ទិលដ៏លើសជាងមន្ទិលទាំងនោះ គឺ
អវិជ្ជា ជាមន្ទិលយ៉ាងក្រៃលែង ។

# អដ្ឋកថា

## មលសូត្រ

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមលសូត្រទី ៥ ដូចតទៅនេះ បទថា **អសជ្ឈាយមលា** សេចក្តីថា ការមិនធ្វើការស្វាធ្យាយមន្តដែលខ្លួនរៀនហើយ ឈ្មោះថា ជាមន្ទិល ។ បទថា **អនុដ្ឋានមលា ឃរា** សេចក្តីថា ការមិន

ឧស្សាហ៍ព្យាយាម ឈ្មោះថា ជាមន្ទិលនៃអ្នកគ្រប់គ្រងផ្ទះ ។ បទថា **វណ្ណស្ស** បានដល់ ពណ៌សម្បុរបស់កាយ ។ បទថា **រក្ខតោ** សេចក្តីថា រក្សាវត្ថុណាមួយ ដែលជាសម្បត្តិរបស់ខ្លួន ។ បទថា **អវិជ្ជា បរមំ មលំ** សេចក្តីថា អវិជ្ជា គឺការងងឹតដ៏ក្រាស់ ពោល គឺមូលនៃវដ្តៈដែលជាការមិនដឹងក្នុងឋានៈ ៨ ជាមន្ទិលក្រៃលែងជាងមន្ទិលទាំងឡាយ គឺអកុសលធម៌ដ៏សេសនោះ មន្ទិលដទៃដែលឈ្មោះថា ក្រៃលែងជាងអវិជ្ជានោះមិនមាន ។ ព្រះមានព្រះភាគ ត្រាស់វដ្តៈតែម្យ៉ាងក្នុងសូត្រនេះ ។៚

**អដ្ឋកថា មលសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទូតសូត្រទី ៦

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង ទើបគួរដើម្បីដល់នូវទូតកម្មបាន ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្តាប់ខ្លួនឯង ១ ជាអ្នកញ៉ាំងបុគ្គលដទៃឲ្យស្តាប់ ១ ជាអ្នករៀនខ្លួនឯង ១ ជាអ្នកយល់ច្បាស់នូវសេចក្តីមានប្រ-យោជន៍ និងមិនមានប្រយោជន៍ ១ ជាអ្នកញ៉ាំងបុគ្គលដទៃឲ្យយល់ច្បាស់នូវ

សេចក្តីមានប្រយោជន៍ និងមិនមានប្រយោជន៍ ១ ជាអ្នកឈ្លាសក្នុងអំពើមានប្រយោជន៍ និងមិនមានប្រយោជន៍ ១ ជាអ្នកមិនធ្វើនូវការឈ្លោះប្រកែក ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះ ទើបគួរដើម្បីដល់នូវទូតកម្មបាន ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌ ៨ យ៉ាង ទើបគួរដើម្បីដល់ទូតកម្មបាន ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ សារីបុត្តជាអ្នកស្តាប់ខ្លួនឯង ១ ជាអ្នកញុំាងបុគ្គលដទៃឲ្យស្តាប់ ១ ជាអ្នករៀនខ្លួនឯង ១ ជាអ្នកចងចាំទុក ១ ជាអ្នកយល់ច្បាស់ ( នូវសេចក្តីមានប្រយោជន៍ និងមិនមានប្រយោជន៍ ) ១ ជាអ្នកញុំាងបុគ្គលដទៃឲ្យយល់ច្បាស់ ( នូវសេចក្តីមានប្រយោជន៍ និងមិនមានប្រយោជន៍ ) ១ ជាអ្នកឈ្លាសក្នុងអំពើមានប្រយោជន៍ និងមិនមានប្រយោជន៍ ១ ជាអ្នកមិនធ្វើនូវការឈ្លោះប្រកែក ១ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយធម៌ ៨ យ៉ាងនេះឯង ទើបគួរដើម្បីដល់នូវទូតកម្មបាន ។

ភិក្ខុណានិយាយទៅរកបរិសទ្យ ដែលជាអ្នកពោលពាក្យ
លើកតម្កើង ក៏មិនតក់ស្លុតផង មិនឲ្យបាត់ពាក្យផង មិន
ឲ្យបាត់ពាក្យបណ្តាំផង ពោលពាក្យមិនឲ្យគេមាន
សេចក្តីសង្ស័យផង គេសួរមិនខឹងផង ភិក្ខុប្រាកដដូច្នោះ
នោះឯង គួរដើម្បីដល់នូវទូតកម្មបាន ។

# អដ្ឋកថា

## ទូតសូត្រ

[ ១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទូតសូត្រទី ៦ ដូចតទៅនេះ បទថា **ទូតេយ្យំ** បានដល់ ទូតកម្ម ។ បទថា **គន្តុមរហតិ** សេចក្តីថា ភិក្ខុគួរទ្រទ្រង់សាសនៈ សម្តែងភាពជាទូតនោះ នាំទៅប្រគល់ឲ្យ ។ បទថា **សោតា** បានដល់ ទទួលស្តាប់បុគ្គលដែលខ្ជួនប្រគល់សាសន៍ឲ្យ ។ បទថា **សាវេតា** បានដល់ ភិក្ខុអានសាសន៍នោះហើយ ប្រាប់ម្តងទៀតថា អ្នកអានសាសន៍ឈ្មោះនេះហើយ ។ បទថា **ឧគ្គហេតា** បានដល់ ទទួលយកដោយល្អ ។ បទថា **ធារេតា** បានដល់ ចាំទុកដោយល្អ ។ បទថា **វិញ្ញាតា** បានដល់ ដឹងអត្ថនៃវត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ។ បទថា **វិញ្ញាបេតា** បានដល់ ឲ្យអ្នកដទៃដឹងច្បាស់ ។ បទថា **សហិតាសហិតស្ស** សេចក្តីថា ជាអ្នកឈ្លាសចំពោះប្រយោជន៍ និងមិនមែនប្រយោជន៍យ៉ាងនេះថា នេះជាប្រយោជន៍ នេះមិនមែនប្រយោជន៍ គឺជាអ្នកមុតស្រួចក្នុងការប្រព្រឹត្តទៅបាន និងប្រយោជន៍ដែលប្រព្រឹត្តទៅមិនបាន កាលនឹងប្រាប់សាសន៍ កំណត់តែវត្ថុដែលមានប្រយោជន៍ ហើយទើបប្រាប់ ។ បទថា **ន ព្យាធតិ** បានដល់ រមែងមិនញាប់ញ័រ មិនភ័យខ្លាច ។ បទថា **អសន្ទិដ្ឋំ** បានដល់ អស់ការងឿងឆ្ងល់ ប្រាសចាកសេចក្តីសង្ស័យ ។ បទថា **បុច្ឆិតោ** សេចក្តីថា ត្រូវគេសាកសួរ ដើម្បីដឹងបញ្ហាថាជាអ្វី ។ល។

**អដ្ឋកថា ទូតសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមពន្ធសូត្រទី ៧ ជាដើម

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ ស្ត្រីតែងចងបុរសដោយអាការ ៨ យ៉ាង ។ អាការ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចងបុរសដោយរូប ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចងបុរសដោយសំណើច ១ ម្នាលភិក្ខុទាំង-ឡាយ ស្ត្រីចងបុរសដោយនិយាយ ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចងបុរសដោយចម្រៀង ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចងបុរសដោយយំ ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចងបុរសដោយការស្អាង ( មានវិធីស្លៀកពាក់ជាដើម ) ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចងបុរសដោយគ្រឿងបណ្ណាការ មានផ្កាឈើ និងផ្លែឈើ ដែលខ្លួនកាច់មកអំពីព្រៃ ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចងបុរស ដោយផស្សៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចងបុរស ដោយអាការ ៨ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលស្ត្រីចងក្រៀក ដោយអាការទាំង ៨ យ៉ាងនេះឯង ឈ្មោះថា ជាប់អន្ទាក់ ។

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ បុរសចងស្ត្រី ដោយអាការ ៨ យ៉ាង ។ អាការ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសចងស្ត្រីដោយរូប ១ ម្នាលភិក្ខុទាំងឡាយ បុរសចងស្ត្រី ដោយសំណើច ១ ម្នាលភិក្ខុទាំង-ឡាយ បុរសចងស្ត្រី ដោយនិយាយ ១ ម្នាលភិក្ខុទាំងឡាយ បុរសចងស្ត្រី ដោយចម្រៀង ១ ម្នាលភិក្ខុទាំងឡាយ បុរសចងស្ត្រី ដោយយំ ១ ម្នាលភិក្ខុទាំងឡាយ បុរសចងស្ត្រី ដោយការស្អាង ១ ម្នាលភិក្ខុទាំងឡាយ បុរសចង

ស្ត្រី ដោយគ្រឿងបណ្ណាការ ដែលខ្ជូនកាច់មកអំពីព្រៃ ១ ម្នាលភិក្ខុទាំងឡាយ បុរសចងស្ត្រី ដោយផស្សៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុរសចងស្ត្រី ដោយអាការ ៨ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលបុរសចងក្រៀក ដោយអាការ ៨ យ៉ាងនោះឯង ឈ្មោះថា ជាប់អន្ទាក់ ។

# អដ្ឋកថា

## បឋមពន្ធសូត្រទី ៧ ជាដើម

[ ១៧-១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមពន្ធសូត្រទី ៧ ជាដើម ដូចតទៅនេះ បទថា **រោណ្ណេន** បានដល់ ដោយការទ្រហោយំ ។ បទថា **អាកប្បេន** បានដល់ ដោយវិធី មានការស្លៀក និងការដណ្តប់ជាដើម ។ បទថា **វនភង្គេន** សេចក្តីថា ដោយគ្រឿងបណ្ណាការ មានផ្កា និងផ្លែឈើព្រៃ ដែលខ្ជូនកាច់បានមកអំពីព្រៃ ។l

**អដ្ឋកថា បឋមពន្ធសូត្រទី ៧ ជាដើម ចប់**

# សុត្តន្តបិដក

## បហារាទសូត្រទី ៩

[ ១៩ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្រោមដើមស្តៅជាលំនៅនៃនឡេរុយក្ខ ទៀបស្រុកវេរញ្ជា ។ គ្រានោះ បហារាទអសុរិន្ទ ( ស្តេចអសុរឈ្មោះបហារាទ ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះបហារាទអសុរិន្ទឋិតនៅក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលបហារាទចុះពួកអសុរ តែងរីករាយ ក្នុងមហាសមុទ្រដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើនពួកអសុរ តែងរីករាយ ក្នុងមហាសមុទ្រដែរ ។ ម្នាលបហារាទ ចុះក្នុងមហាសមុទ្រ មានហេតុជាអស្ចារ្យចម្លែកប៉ុន្មានយ៉ាង បានជាពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងមហា-សមុទ្រ មានហេតុជាអស្ចារ្យ ចម្លែក ៨ យ៉ាង បានជាពួកអសុរឃើញហើយៗតែងរីករាយក្នុងមហាសមុទ្រ ។ ហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង តើដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រ មានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តង ដូចជាអណ្តូងទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រមានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់មិនចោតជ្រៅទៅតែម្តង ដូចជាអណ្តូង ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យទី ១ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញ

ហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត មហាសមុទ្រ មានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបាន ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រ មានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបាន ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ២ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត មហាសមុទ្រ មិនដែលនៅរួមដោយសាកសពស្លាប់ទេ បើសាកសពស្លាប់ណា មានក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះ ទៅរកច្រាំងផាត់ឡើងទៅលើគោកមួយរំពេច ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រមិនដែលនៅរួមដោយសាកសពស្លាប់ បើសាកសពស្លាប់ណា មាននៅក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះ ទៅរកច្រាំងផាត់ឡើងទៅលើគោកមួយរំពេច ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ៣ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ទន្លេធំៗ ទាំងឡាយណាមួយ គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី កាលបើទន្លេទាំងនោះ ហូរទៅដល់មហាសមុទ្រហើយ រមែងលះបង់នាម និងគោត្រដើម ( របស់ខ្លួន ) ហើយដល់នូវកិរិយារាប់បញ្ចូលថា មហាសមុទ្រតែម្យ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន ទន្លេធំៗ ទាំងឡាយណាមួយ គឺទន្លេគង្គា ។បេ។ ដល់នូវកិរិយារាប់ថា មហាសមុទ្រតែម្យ៉ាង

ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យ ចម្លែកទី ៤ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ទឹកទន្លេទាំងឡាយណាមួយក្នុងលោក ដែលហូរស្រោចទៅរកមហាសមុទ្រក្តី ធារទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកអំពីអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រក ឬពេញដោយទឹកទន្លេ និងធារទឹកភ្លៀងនោះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ទឹកទន្លេទាំងឡាយណាមួយក្នុងលោក ដែលហូរស្រោច ទៅរកមហាសមុទ្រក្តី ធារទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកអំពីអាកាសក្តី មហាសមុទ្រ ក៏មិនប្រាកដជាស្រក ឬពេញដោយទឹកទន្លេ និងធារទឹកភ្លៀងនោះ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ៥ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត មហាសមុទ្រ មានរសតែមួយ គឺរសប្រៃ ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រមានរសតែមួយ គឺរសប្រៃដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ៦ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត មហាសមុទ្រ មានរតនៈ ( ទ្រព្យជាគ្រឿងពេញចិត្ត ) ច្រើនយ៉ាង មិនមែនមានតែរតនៈម្យ៉ាងទេ ឯរតនៈទាំងនេះ ដែលមាននៅក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាល ប្រាក់ មាស កែវក្រហម ( ត្បូងទទឹម )

និងកែវមរកត បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រ មានរតនៈច្រើនយ៉ាង មិនមែនមានរតនៈម្យ៉ាងទេ ឯរតនៈទាំងនេះ ដែលមាននៅក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាល ប្រាក់ មាស កែវក្រហម និងកែវមរកត ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ៧ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត មហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនោះ ដែលនៅក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ ដែលមានក្នុងមហាសមុទ្រ មានអត្តភាព ១០០ យោជន៍ខ្លះ មានអត្តភាព ២០០ យោជន៍ខ្លះ មានអត្តភាព ៣០០ យោជន៍ខ្លះ មានអត្តភាព ៤០០ យោជន៍ខ្លះ មានអត្តភាព ៥០០ យោជន៍ខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ដែលនៅអាស្រ័យក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ ដែលមានក្នុងមហាសមុទ្រ មានអត្តភាព ១០០ យោជន៍ខ្លះ ។បេ។ មានអត្តភាព ៣០០ យោជន៍ខ្លះ មានអត្តភាព ៤០០ យោជន៍ខ្លះ មានអត្តភាព ៥០០ យោជន៍ខ្លះ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ៨ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។

បពិត្រព្រះអង្គដ៏ចម្រើន ហេតុជាអស្ចារ្យចម្លែកក្នុងមហាសមុទ្រ មាន ៨ យ៉ាង នេះឯង ដែលពួកអសុរឃើញហើយៗ តែងរីករាយ ក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះពួកភិក្ខុតែងរីករាយ ក្នុងធម្មវិន័យនេះដែរឬ ។ ម្នាលបហារាទ ពួកភិក្ខុតែងរីករាយ ក្នុងធម្មវិន័យនេះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងធម្មវិន័យនេះ មានហេតុជាអស្ចារ្យចម្លែកប៉ុន្មានយ៉ាង ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ ក្នុងធម្មវិន័យនេះ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង តើដូចម្តេច ។ ម្នាលបហារាទ មហាសមុទ្រដែលមានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនចោតជ្រៅទៅតែម្តង ដូចអណ្តូងទេ យ៉ាងណាមិញ ម្នាលបហារាទ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងអរហត្តផលតែម្តងទេ ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើ ដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងអរហត្តផលតែម្តងទេ ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ១ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ មហាសមុទ្រដែលមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង

ឬជាវហួសច្រាំងទៅ យ៉ាងណាមិញ ម្នាលបហារាទ សិក្ខាបទណា ដែលតថាគត បានបញ្ញត្តដល់សាវ័កទាំងឡាយហើយ ពួកសាវ័កតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ សិក្ខាបទណា ដែលតថាគតបានបញ្ញត្តដល់សាវ័កទាំង-ឡាយហើយ ពួកសាវ័កតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះ ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ២ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ មហាសមុទ្រដែលមិននៅរួមដោយសាកសពស្លាប់ បើសាកសពស្លាប់ណា ដែលមានក្នុងមហាសមុទ្រ រលកតែងបទ្សាត់សាកសពនោះទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច យ៉ាងណាមិញ ម្នាលបហារាទ បុគ្គលណាជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត គួរឲ្យគេរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ ប្តេជ្ញាខ្លួនជាសមណៈ ជាអ្នកប្រព្រឹត្តធម៌មិនប្រសើរ ប្តេជ្ញាខ្លួនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ កខ្វក់ដូចសំរាម សង្ឃនៅរួមជាមួយនឹងបុគ្គលនោះមិនបាន សង្ឃតែងប្រជុំគ្នានាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះទុកជាអង្គុយនៅក្នុងកណ្តាលជំនុំសង្ឃ ពិតមែន ប៉ុន្តែបុគ្គលនោះ ឈ្មោះថានៅឆ្ងាយអំពីសង្ឃ ចំណែកខាងសង្ឃ ក៏ឈ្មោះថា នៅឆ្ងាយអំពីបុគ្គលនោះដែរ ។ ម្នាលបហារាទ បុគ្គលណាជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មាន

មារយាទមិនស្អាត គួរឲ្យគេរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ ប្តេជ្ញាខ្លួនថាជាសមណៈ ជាអ្នកប្រព្រឹត្តធម៌មិនប្រសើរ ប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកជោយរាគៈ កខ្វក់ដូចសំរាម សង្ឃនៅរួមជាមួយនឹងបុគ្គលនោះមិនបាន សង្ឃតែងប្រជុំគ្នា នាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះ ទុកជាអង្គុយនៅក្នុងកណ្តាលជំនុំសង្ឃពិតមែន ប៉ុន្តែបុគ្គលនោះឈ្មោះថា នៅឆ្ងាយអំពីសង្ឃ ចំណែកខាងសង្ឃ ក៏ឈ្មោះថា នៅឆ្ងាយអំពីបុគ្គលនោះ ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៣ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ ទន្លេធំៗ ទាំងឡាយណាមួយ គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី កាលបើទន្លេទាំងនោះ ហូរចូលទៅដល់មហាសមុទ្រហើយ តែងលះបង់នាម និងគោត្រដើម ( របស់ខ្លួន ) ហើយដល់នូវកិរិយារាប់ថា ជាមហាសមុទ្រតែម្យ៉ាង យ៉ាងណាមិញ ម្នាលបហារាទ វណ្ណៈ គឺត្រកូល ៤ ពួកនេះ គឺក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បើវណ្ណៈទាំងនោះ ចេញចាកផ្ទះបួស ក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយ រមែងលះបង់នាម និងគោត្រដើម ( របស់ខ្លួន ) ហើយដល់នូវកិរិយារាប់ថាជាសមណសក្យបុត្រតែម្យ៉ាង ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ វណ្ណៈ ៤ ពួកនេះ គឺក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំងនោះចេញចាកផ្ទះបួសក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយ រមែងលះបង់នាម និង

គោត្រដើម ( របស់ខ្លួន ) ដល់នូវកិរិយារាប់ថាជាសមណសក្យបុត្រតែម្យ៉ាង ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៤ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ ទឹកទន្លេទាំងឡាយណាមួយក្នុងលោក ដែលហូរស្រោចចុះទៅ កាន់មហាសមុទ្រក្តី ជារទឹកភ្លៀងទាំងឡាយណា ដែលធ្លាក់ចុះមកអំពីអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រក ឬពេញដោយទឹកនោះ យ៉ាងណាមិញ ម្នាលបហារាទ ទោះបីពួកភិក្ខុច្រើនរូបបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដជាខ្វះ ឬពេញដោយភិក្ខុទាំងនោះ ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ ទោះបីពួកភិក្ខុច្រើនរូបបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដជាខ្វះ ឬពេញដោយភិក្ខុទាំងនោះ ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៥ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ មហាសមុទ្រដែលមានរសតែមួយ គឺរសប្រៃ យ៉ាងណាមិញ ម្នាលបហារាទ ធម្មវិន័យនេះ មានរសតែមួយ គឺវិមុត្តិរស ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ ធម្មវិន័យនេះ មានរសតែមួយ គឺវិមុត្តិរស ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៦ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ ក្នុងមហាសមុទ្រ មានរតនៈច្រើនយ៉ាង មិនមែនមានតែមួយទេ រតនៈទាំងនេះ ក្នុងមហាសមុទ្រនោះ គឺ

កែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាល ប្រាក់ មាស កែវក្រហម ( ត្បូងទទឹម ) កែវមរកត យ៉ាងណាមិញ ម្នាលបហារាទ ធម្ម-វិន័យនេះ មានរតនៈច្រើនយ៉ាង មិនមែនមានត្រឹមតែមួយទេ រតនៈទាំងនេះ ក្នុងធម្មវិន័យនោះ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ ធម្មវិន័យនេះ មានរតនៈច្រើនយ៉ាង មិនមែនមានត្រឹមតែមួយទេ រតនៈទាំងនេះក្នុងធម្មវិន័យនោះ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៧ ក្នុងធម្ម-វិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ មហាសមុទ្រដែលជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ដែលនៅក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ ដែលមានក្នុងមហាសមុទ្រ មានអត្តភាព ១០០ យោជន៍ខ្លះ មានអត្តភាព ២០០ យោជន៍ខ្លះ មានអត្តភាព ៣០០ យោជន៍ខ្លះ មានអត្តភាព ៤០០ យោជន៍ខ្លះ មានអត្តភាព ៥០០ យោជន៍ខ្លះ យ៉ាងណាមិញ ម្នាលបហារាទ ធម្មវិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើន បុគ្គលទាំងនេះ ក្នុងធម្មវិន័យនោះ គឺសោតាបន្នបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវ

សោតាបត្តិផល សកទាគាមិបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល អនាគាមិបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល អរហន្ត និងបុគ្គលដែលកំពុងប្រតិបត្តិដើម្បីភាវៈនៃខ្លួនជាអរហន្ត ក៏យ៉ាងនេះដែរ ។ ម្នាលបហារាទ ធម្មវិន័យនេះជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើន បុគ្គលទាំងនេះ ក្នុងធម្មវិន័យនោះ គឺសោតាបន្នបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល សកទាគាមិបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល អនាគាមិបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល អរហន្ត និងបុគ្គលដែលកំពុងប្រតិបត្តិដើម្បីភាវៈនៃខ្លួនជាអរហន្ត ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៨ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ ក្នុងធម្មវិន័យនេះ មានហេតុជាអស្ចារ្យចម្លែកទាំង ៨ យ៉ាងនេះឯង ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។

# អដ្ឋកថា

## បហារាទសូត្រ

[ ១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបហារាទសូត្រទី ៩ ដូចតទៅនេះ បទថា **បហារាទោ** បានដល់ មានឈ្មោះយ៉ាងនេះ ។ បទថា **អសុរិន្ទោ** ប្រែថា ប្រធានអសុរ ពិតហើយ បណ្តាអសុរទាំងឡាយ អសុរដែលជាប្រធាន មាន ៣ គឺវេបចិត្តិ ១ រាហូ ១ បហារាទៈ ១ ។ បទថា **យេន ភគវា តេនុ-បសង្កមិ** សេចក្តីថា រាប់តាំងអំពីថ្ងៃដែលព្រះទសពលត្រាស់ដឹងហើយ បហារាទៈប្រធានអសុរគិតថា ថ្ងៃនេះ អញនឹងទៅគាល់ ស្អែកនេះ អញនឹងទៅគាល់រហូតកន្លងទៅ ១១ ឆ្នាំ កាលដល់ឆ្នាំទី ១២ ក្នុងពេលដែលព្រះសាស្តាប្រថាប់នៅក្នុងក្រុងវេរញ្ជា ទើបការគិតឡើងថា អញនឹងទៅគាល់ព្រះសម្មាសម្ពុទ្ធ ទើបគិតបន្តទៀតថា អញរវល់បង្អន់ថា នឹងទៅថ្ងៃនេះ នឹងទៅស្អែកនេះ កន្លងទៅអស់ ១២ ឆ្នាំ ណ្ហើយចុះ អញនឹងទៅ ឥឡូវនេះឯង ខណៈនោះឯង ដែលពួកអសុរចោមរោមហើយ ចេញអំពីអសុរភព ទាំងកណ្តាលថ្ងៃ ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។ បទថា **ឯកមន្តំ អដ្ឋាសិ** សេចក្តីថា បានឮថា បហារាទស្តេចអសុរនោះមកដោយគិតថា នឹងសួរបញ្ហាជាមួយនឹងព្រះតថាគត ហើយនឹងស្តាប់ធម្មកថា តាំងអំពីពេលដែលបានគាល់ព្រះតថាគតហើយ កាលមិនអាចសួរ ព្រោះសេចក្តីគោរពក្នុងព្រះសម្ពុទ្ធ ក៏បានថ្វាយបង្គំព្រះសាស្តា ហើយឈរក្នុងទីដ៏សមគួរ នាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្ដាទ្រង់ព្រះតម្រិះថា បើតថាគតមិនពោលបហារាទៈក៏មិនអាចពោលមុនបាន តថាគតនឹងសួរបញ្ហាត្រឹមតែមួយ ដើម្បីឲ្យការសន្ទនាកើតឡើង ក្នុងឋានៈដែលបហារាទៈនេះ មានវសីសន្សំហើយនោះឯង កាលទ្រង់ត្រាស់សួរបញ្ហា ទើបត្រាស់ពាក្យជាដើមថា **អបិ បន បហារាទ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **អភិរមន្តិ** សេចក្ដីថា រមែងជួបនូវការត្រេកអរ អធិប្បាយថា មិនទៀយណាយ ។ លោកមានចិត្តត្រេកអរថា ក្នុងឋានៈដែលអញស្និទ្ធស្នាលនោះឯង ទើបព្រះមានព្រះភាគត្រាស់សួរអញ ទើបក្រាបទូលថា **អភិរមន្តិ ភន្តេ។**

បទថា **អនុបុព្វនិន្នោ** ជាដើម ជាវេវចនៈនៃការជ្រៅទៅតាមលំដាប់ ។ ដោយបទថា **ន អាយតកេនេវ បបាតោ** ព្រះមានព្រះភាគ ទ្រង់សម្ដែងថា មហាសមុទ្រ មិនដូចជ្រោះ តាំងមកអំពីខាងដើម ដូចបឹងធំដែលមានច្រាំងតាំងអំពីទីដែលរាបទៅ មហាសមុទ្រនឹងជ្រៅទៅតាមលំដាប់ ដោយអំណាចនៃការជ្រៅចុះទៅ ១ ធ្នាប់ ២ ធ្នាប់ ១ ចំអាម ១ ហត្ថ ១ ឧសភៈ កន្លះគាវុត ១ គាវុត កន្លះយោជន៍ និង ១ យោជន៍ ជ្រៅទៅៗ រហូត ៨៤០០០ យោជន៍ ក្នុងទីជិតជើងភ្នំសិនេរុ ។

បទថា **ឋិតធម្មោ** សេចក្ដីថា តាំងនៅហើយជាសភាវៈ គឺតាំងនៅចំពោះជាសភាវៈ ។ បទថា **កុណបេន** សេចក្ដីថា ដោយសាកសពណាមួយ មានសាកសពដំរី និងសេះជាដើម ។ បទថា **ថលំ ឧស្សារេតិ** សេចក្ដី

ថា រមែងបក់ឡើងលើគោក ដោយរលករុញមកនោះឯង ដូចមនុស្សយកដៃប្រាលទៅ ដូច្នោះ ។

ក្នុងបទថា **គង្គា យមុនា** គួរពោលដល់ហេតុកើតនៃស្ទឹងទាំងនេះព្រោះតាំងនៅក្នុងទីនេះ ។ ជាបឋមជម្ពូទ្វីបនេះ ដែលមានផ្ទៃប្រមាណ ១ ម៉ឺនយោជន៍ ក្នុងចំនួននោះ ៤០០០ យោជន៍ ជាភូមិបទេសដែលត្រូវទឹកលិច រាប់បានថា ជាមហាសមុទ្រ ៣០០០ យោជន៍ ពួកមនុស្សអាស្រ័យនៅ ៣០០០ យោជន៍ ភ្នំហិមពាន្តតាំងនៅ ដែលមានកម្ពស់ ៥០០ យោជន៍ ប្រដាប់ដោយកំពូល ៨៤០០០ លម្អដោយស្ទឹង ៥ ខ្សែ ហូរមកដោយជុំវិញ ជាទីដែលស្រះធំ ៧ តាំងនៅ គឺអនោតត្តស្រះ ១ កណ្ណមុណ្ឌ ១ រថកាឡ ១ ឆទ្ទន្ត ១ កុណាល ១ មន្ទាកិនី ១ សីហប្បាទ ១ បណ្តោយ ទទឹង និងជម្រៅ ៥០ យោជន៍ដូចគ្នា មានបរិមណ្ឌល ១៥០ យោជន៍ ។ បណ្តាស្រះទាំងនោះ អនោតត្តស្រះ ព័ទ្ធដោយភ្នំ ៥ គឺសុទស្សនកូដ ១ ចិត្តកូដ ១ កាឡកូដ ១ គន្ធមាទនកូដ ១ កៃលាសកូដ ១ ។ ភ្នំ ៥ នោះ សុទស្សនកូដជាវិការនៃមាស កម្ពស់ ២០០ យោជន៍ ខាងក្នុងកោង មានសណ្ឋានដូចចំពុះក្អែក ព័ទ្ធអនោតត្តស្រះនោះឯង ភ្នំចិត្តកូដវិចិត្រដោយរតនៈទាំងពួង ភ្នំកាឡកូដសម្រេចដោយពេជ្រ ភ្នំគន្ធមាទនកូដវិចិត្រដោយទីរាបស្មើ ខាងក្នុងមានពណ៌ដូចសណ្តែកបាយ ដេរដាសទៅដោយគន្ធជាតិ ១០ យ៉ាង គឺឈើឫសក្រអូប ឈើខ្លឹមក្រអូប ឈើក្រមរក្រអូប ឈើស្លឹកក្រអូប ឈើសម្បកក្រអូប ឈើ

ស្រាយក្រអូប ឈើរសក្រអូប ឈើផ្កាក្រអូប ឈើផ្លែក្រអូប ឈើដើមក្រអូប គ្របដណ្ដប់ទៅដោយឱសថ មានប្រការផ្សេងៗ មានពន្លឺរុងរឿងតាំងនៅ ដូចដើងក្រានភ្លើង ក្នុងថ្ងៃឧបោសថ ក្នុងខែរនោច ។ ភ្នំកៃលាសកូដ សម្រេចដោយប្រាក់ ។ ភ្នំទាំងអស់មានសណ្ឋាន និងកម្ពស់ស្មើគ្នានឹងសុទស្សនកូដ ព័ទ្ធអនោតត្តស្រះ ។ ភ្នំទាំងអស់នោះ ភ្លៀងធ្លាក់ស្រោចដោយអានុភាពរបស់ទេវតា និងនាគ ។ ទឹកទាំងឡាយ រមែងហូរចុះអំពីភ្នំនោះ ទឹកទាំងអស់នោះក៏ហូរចូលទៅកាន់អនោតត្តស្រះតែមួយ ព្រះចន្ទ និងព្រះអាទិត្យ កាលគោចរធ្វេងខាងទិសទក្សិណ ឬទិសឧត្តរ ក៏គោចរធ្វេងទៅចន្លោះភ្នំ បញ្ចេញពន្លឺទៅក្នុងទីនោះ តែបើគោចរទៅត្រង់ៗ ក៏មិនបញ្ចេញពន្លឺ ព្រោះហេតុនោះឯង ទើបស្រះនោះកើតនូវនាមបញ្ញត្តិថា អនោតត្តស្រះ ប្រែថា ពន្លឺចាំងទៅមិនដល់ ។ ត្រង់អនោតត្តស្រះនោះ មានកំពង់សម្រាប់ងូត មានថ្មាំងថ្មរាបស្មើ គួរត្រេកអរនៃចិត្ត មិនមានត្រី ឬអណ្ដើក មានទឹកថ្លាដូចកែវផលិក ជារបស់ដែលធម្មជាតិតាក់តែងទុកល្អហើយ ជាទីដែលព្រះពុទ្ធទាំងឡាយ ព្រះខីណាស្រព ព្រះ-បច្ចេកពុទ្ធ និងឥសីអ្នកមានឫទ្ធិទាំងឡាយស្រពស្រង់ ទេវតា និងយក្ខជាដើម ក៏នាំគ្នាលេងទឹកទាំង ៤ ទិស ក្នុងស្រះនោះមានមុខ ៤ គឺសីហមុខ ហត្ថិមុខ អស្សមុខ ឧសភមុខ ដែលជាផ្លូវទឹកទាំង ៤ ហូរទៅ ត្រង់ច្រាំងដែលហូរចេញទៅតាមសីហមុខ មានរាជសីហ៍នៅច្រើន ត្រង់ឆ្នេរដែលហូរចេញទៅត្រង់ហត្ថិមុខជាដើម មានដំរី សេះ និងគោឧសភៈនៅច្រើន ។ ផ្លូវទឹកដែល

ហូរចេញនាទិសខាងកើត ហូរព័ទ្ធអនោតត្តស្រះ ៣ ជុំ មិនជួបនឹងផ្លូវទឹក ៣ ខ្សែទៀត ធ្លងកាត់ទឹកដីអមនុស្ស កាត់តាមព្រៃហិមពាន្តទិសខាងកើត និងព្រៃហិមពាន្តទិសខាងជើង ហូរឆ្ពោះទៅមហាសមុទ្រ មេទឹកដែលហូរចេញក្នុងទិសខាងលិច និងទិសខាងជើង ក៏ប្រទក្សិណស្រះនោះដូចគ្នា ធ្លងកាត់ទឹកដីអមនុស្ស កាត់តាមព្រៃហិមពាន្តទិសខាងលិច និងព្រៃហិមពាន្តទិសខាងជើង ហូរទៅកាន់មហាសមុទ្រ ។

ប្រភពទឹកដែលហូរចេញតាមទិសខាងត្បូង ប្រទក្សិណអនោតត្តស្រះ ៣ ជុំ ហើយក៏ហូរឆ្ពោះទៅទិសខាងជើង ចម្ងាយ ៦០ យោជន៍ លើផ្ទាំងថ្មនោះឯង ប៉ះនូវភ្នំ ១ ទឹកក៏បាញ់ឡើងទៅលើដោយជុំវិញ ប្រមាណ ៣ គាវុត បាញ់ទៅតាមអាកាស ចម្ងាយ ៦០ យោជន៍ ហើយធ្លាក់ចុះត្រង់ផ្ទាំងថ្ម ឈ្មោះតិយគ្គឡៈ ផ្ទាំងថ្មក៏បែកទៅ ព្រោះកម្លាំងនៃខ្សែទឹក ក្នុងទីនោះកើតជាស្រះធំឈ្មោះថា តិយគ្គឡៈ ទំហំ ៥០ យោជន៍ ។ ក្រសែទឹកទម្លុះប្រាំងស្រះ រួចហូរខាងក្រោមផ្ទាំងថ្មទៅចម្ងាយ ៦០ យោជន៍ ។ បន្ទាប់អំពីនោះ ក៏ទ្រោះផែនដីជាឧម្មង្គទៅ ៦០ យោជន៍ ហើយក៏ជួបនឹងតិរច្ឆានបព៌ត ឈ្មោះវិជ្ឈៈ ហើយក៏បែកជា ៥ ខ្សែ ដូចម្រាមដៃ ៥ ដូច្នោះ ។ ក្នុងទីដែលទឹកនោះហូរប្រទក្សិណអនោតត្តស្រះ ៣ ជុំ ហើយហូរទៅ ហៅថា អាវដ្តគង្គា ។ ក្នុងទីដែលហូរទៅ ៦០ យោជន៍ លើផ្ទាំងថ្ម ហៅថា កណ្ហគង្គា ក្នុងទីដែលបាញ់ទៅតាមអាកាស ៦០ យោជន៍ ហៅថា អាកាសគង្គា ។ ក្នុងទីដែលឈប់

នៅក្នុងអាកាស ៦០ យោជន៍ លើផ្ទាំងថ្មឈ្មោះតិយគ្គឡៈ ហៅថា តិយគ្គ-ឡបោក្ខរណី ក្នុងទីដែលប្រោះថ្ម ហូរទៅ ៦០ យោជន៍ ហៅថា ពហលគង្គា ក្នុងទី ៦០ យោជន៍ ដែលហូរទៅក្រោមដី ហៅថា ឧម្មង្គគង្គា ។ ក្នុងទីដែលខ្សែទឹកជួបទូវតិរច្ឆានបព៌តឈ្មោះវិជ្ឈៈ ហើយហូរទៅ ជាខ្សែទឹក ៥ ខ្សែ ក៏កាន់យកថា ជាស្ទឹងទាំង ៥ គឺគង្គា យមុនា អចិរវតី សរភូ មហី ។ គប្បីជ្រាបថា ស្ទឹង ៥ ខ្សែនេះ ហូរមកអំពីព្រៃហិមពាន្ត ដោយប្រការដូច្នេះ ។

បទថា **សវន្តិយោ** បានដល់ ស្ទឹងប្រភេទណាមួយ ទោះជាស្ទឹងធំ ឬស្ទឹងតូចក៏ដោយ ដែលកំពុងហូរទៅ ។ បទថា **អប្បេន្តិ** ប្រែថា ហូរទៅរួមគ្នា គឺហូរចុះ ។ បទថា **ធារា** បានដល់ ខ្សែទឹកភ្លៀង ។ បទថា **បូរត្តំ** ប្រែថា ភាវៈដែលពេញ ។ សេចក្ដីពិត មហាសមុទ្រមានធម្មតាដូច្នេះថា បុគ្គលណាមួយ មិនអាចពោលថា ពេលនេះ ភ្លៀងធ្លាក់តិច ពួកយើងនាំគ្នាយកសំណាញ់និងលបជាដើម ទៅចាប់ត្រី និងអណ្ដើក ឬថា ពេលនេះ ភ្លៀងធ្លាក់ច្រើនយើងនឹងបានអាស្រ័យក្នុងទីដែលមានផ្ទាំងថ្ម ។ តាំងអំពីបឋមកប្បមក ទឹកត្រឹមតែមួយធ្នាប់អំពីទឹកដែលដក់នៅ ទល់គ្នានឹងភ្នំសិនេរុ ក៏មិនស្រកចុះក្រោម ឬមិនតាំងឡើងខាងលើ ។

បទថា **ឯករសោ** ប្រែថា មានរសមិនលាយឡំ ។ បទថា **មុត្តា** សេចក្ដីថា កែវមុក្តាមានច្រើនប្រភេទ មានតូច ធំ មូល និងវែងជាដើម ។ បទថា **មណិ** សេចក្ដីថា មណីមានច្រើនប្រភេទ មានពណ៌ក្រហម ខៀវជាដើម ។

បទថា **វេឡុរិយោ** សេចក្តីថា កែវពៃទូរ្យមានច្រើនប្រភេទ គឺកែវខ្លះ មានពណ៌ដូចដើមឫស្សី និងផ្កាច្រេស ។ បទថា **សង្ខោ** សេចក្តីថា ស័ង្ខមានច្រើនប្រភេទ មានស័ង្ខទក្ខិណាវដ្ត ស័ង្ខទង់ដែង និងស័ង្ខសម្រាប់ផ្លុំជាដើម ។ បទថា **សិលា** សេចក្តីថា សិលាមានច្រើនយ៉ាង មានពណ៌ស ខ្មៅ និងពណ៌ដូចគ្រាប់សណ្តែកបាយជាដើម ។ បទថា **បវាឡំ** សេចក្តីថា កែវប្រវាលមានច្រើនយ៉ាង មានតូច ធំ ក្រហម និងក្រហមចាស់ជាដើម ។ បទថា **មសារគល្លំ** បានដល់ កែវឆ្មូត ។ បទថា **នាគា** បានដល់ នាគដែលនៅលើរលកក៏មាន នាគដែលនៅក្នុងវិមានក៏មាន ។ បទថា **អដ្ឋបហារាទ** សេចក្តីថា ព្រះសាស្តាទ្រង់អាចត្រាស់ធម៌ ៨ ប្រការខ្លះ ១៦ ប្រការខ្លះ ៣២ ប្រការខ្លះ ៦៤ ប្រការខ្លះ ១០០ ខ្លះ ១០០០ ខ្លះ តែទ្រង់ត្រិះរិះថា បហារាទៈពោល ៨ ប្រការ តថាគតនឹងពោលឲ្យឃើញសមគ្នានឹងធម៌ ៨ ដែលបហារាទៈពោលនោះឯង ទើបបានត្រាស់យ៉ាងនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អនុបុព្វសិក្ខា** ជាដើម ដូចតទៅនេះ ។ ព្រះមានព្រះភាគ ទ្រង់កាន់យកសិក្ខា ៣ ដោយអនុបុព្វសិក្ខា ទ្រង់កាន់យកធុតង្គ ១៣ ដោយអនុបុព្វកិរិយា ទ្រង់កាន់យកអនុបស្សនា ៧ មហាវិបស្សនា ១៨ កាលចែកអារម្មណ៍ ៣៨ ពោធិបក្ខិយធម៌ ៣៧ ដោយអនុបុព្វបដិបទា ។ បទថា **ន អាយតកេនេវ អញ្ញាបដិវេធោ** សេចក្តីថា ឈ្មោះថា ភិក្ខុដែលមិនធ្វើឲ្យបរិបូណ៌ក្នុងសីលជាដើម តាំងអំពីដើម ហើយសម្រេចអរហត្ត ដូច

កន្លែបលោតទៅមិនមាន ព្រោះហេតុនោះ ទើបអធិប្បាយថា ភិក្ខុបំពេញសីល សមាធិ និងបញ្ញាតាមលំដាប់ប៉ុណ្ណោះ ទើបអាចសម្រេចអរហត្តបាន ។

បទថា **អារកាវ** ប្រែថា ក្នុងទីឆ្ងាយនោះឯង ។ បទថា **ន តេន និព្វានធាតុយា ឩនត្តំ វា បូរត្តំ វា** សេចក្តីថា កាលព្រះពុទ្ធទាំងឡាយ ទ្រង់មិនទាន់កើតឡើងអស់មួយអសង្ខេយ្យកប្ប សូម្បីសត្វតែមួយ ក៏មិន អាចបរិនិព្វានបាន ក្នុងកាលនោះ ក៏មិនអាចពោលបានថា និព្វានធាតុទទេ តែក្នុងពុទ្ធកាល ក្នុងសមាគមនីមួយៗ សត្វទាំងឡាយត្រេកអរ ត្រាស់ដឹង ក្នុងអមតធម៌រាប់មិនអស់ សូម្បីក្នុងកាលនោះ ក៏មិនអាចពោលបានថា និព្វានធាតុពេញ ។៚

អដ្ឋកថា បហារាទសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ឧបោសថសូត្រទី ១០

[ ២០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងមិគារមាតុ-ប្រាសាទ ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះដ៏មានព្រះ ភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងឧបោសថថ្ងៃនោះ ។ លុះវេលា រាត្រីអស់ហើយ បឋមយាមកន្លងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រោក

ចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យ ចំពោះព្រះដ៏មានព្រះភាគ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីអស់ហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សំដែងបាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ។ កាលដែលព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគក៏គង់ស្ងៀម ។ កាលបើវេលារាត្រីអស់ហើយ មជ្ឈិមយាមកន្លងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យ ចំពោះព្រះដ៏មានព្រះភាគ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ អស់វារៈជាគម្រប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីអស់ហើយ មជ្ឈិមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សំដែងបាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ។ ព្រះដ៏មានព្រះភាគ ទ្រង់គង់ស្ងៀមអស់វារៈជាគម្រប់ពីរដង ។ កាលបើវេលារាត្រីអស់ហើយ បច្ឆិមយាមកន្លងទៅហើយ រាត្រីប្រាកដដូចជាមានមុខស្រស់ ( បំព្រង ) ក្នុងពេលដែលអរុណរះឡើង ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យ ចំពោះព្រះដ៏មានព្រះភាគ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ អស់វារៈជាគម្រប់ ៣ ដងទៀតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ រាត្រីអស់ហើយ បច្ឆិមយាមកន្លងទៅហើយ អរុណក៏រះហើយ

រាត្រីក៏ប្រាកដដូចជាមុខស្រស់ហើយ ភិក្ខុសង្ឃក៏អង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្តែងបាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មានបរិសទ្យមិនបរិសុទ្ធទេ ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់ដៅយកបុគ្គលណាហ្ន៎ បានជាទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិសទ្យមិនបរិសុទ្ធទេយ៉ាងនេះ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ សួន់មើលចិត្ត ( របស់ភិក្ខុសង្ឃ ) ដោយចិត្ត ( របស់លោក ) ហើយធ្វើទុកក្នុងចិត្តចំពោះភិក្ខុសង្ឃទាំងអស់នោះ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញបុគ្គលនោះទ្រុស្តសីល មានធម៌លាមក មានមារយាទមិនស្អាត គួរឲ្យរង្កៀស មានអំពើអាក្រក់បិទបាំងទុក មិនមែនជាសមណៈ ប្តេជ្ញាខ្លួនថាជាសមណៈ ប្រព្រឹត្តធម៌មិនប្រសើរ ប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ កខ្វក់ដូចសំរាម អង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃ លុះឃើញហើយ ក៏ក្រោកចាកអាសនៈ ចូលទៅរកបុគ្គលនោះ លុះចូលទៅជិតហើយ ក៏ពោលចំពោះទៅបុគ្គលនោះ ដូច្នេះថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះដ៏មានព្រះភាគទ្រង់បានឃើញអ្នកច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ ។ កាលដែលព្រះមហាមោគ្គល្លានពោលយ៉ាងនេះហើយ បុគ្គលនោះក៏នៅស្ងៀម ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយនឹងបុគ្គលនោះ ជាគម្រប់ពីរដង

ទៀតដូច្នេះថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះដ៏មានព្រះភាគទ្រង់បានឃើញអ្នកច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ ។ បុគ្គលនោះក៏នៅស្ងៀម អស់វារៈពីរដងទៀត ។ ព្រះមហាមោគ្គល្លានដ៏មានអាយុបាននិយាយនឹងបុគ្គលនោះ ជាគម្រប់បីដងទៀតដូច្នេះថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះដ៏មានព្រះភាគទ្រង់បានឃើញអ្នកច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយភិក្ខុទាំងឡាយទៀតហើយ ។ បុគ្គលនោះ ក៏នៅស្ងៀម អស់វារៈជាគម្រប់បីដងទៀត ។ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុ ចាប់ដើមដៃបុគ្គលនោះទាញចេញទៅខាងក្រៅស៊ុមទ្វារ ហើយខ្ទាស់គន្លឹះនឹងរនុកទ្វាររួចចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គល ( ទ្រុស្តសីល ) នោះ ខ្ញុំព្រះអង្គបានបណ្តេញឲ្យដើរចេញហើយ ឥឡូវនេះ បរិសទ្យបរិសុទ្ធហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់សំដែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ហេតុនេះ អស្ចារ្យណាស់ ម្នាលមោគ្គល្លាន ហេតុនេះ ចម្លែកណាស់ មោឃបុរសនោះ មិនសមបើនឹងបង្អង់ទាល់តែចាប់ទាញដៃចេញសោះ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយ គប្បីធ្វើឧបោសថ គប្បីសំដែងបាតិមោក្ខចុះ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតឈប់សំដែងបាតិមោក្ខ ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតគប្បីសម្តែងនូវបាតិមោក្ខ ដល់បរិសទ្យមិនបរិសុទ្ធ ដោយហេតុណា ហេតុនុ៎ះមិនមែនជាឋានៈ មិនមែនជាបច្ច័យឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាងនេះ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ ហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ មានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅតែម្តង ដូចជាអណ្តូងទេ ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ មានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តង ដូចជាអណ្តូង ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ១ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ សេចក្តីពិស្តារដូចពាក្យខាងដើមដែរ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ដែលនៅក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១០០ យោជន៍ខ្លះ ។បេ។ មានអត្តភាព ៥០០ យោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ដែលនៅក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះ

តិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ មានអត្តភាព ១០០ យោជន៍ខ្លះ ។បេ។ មានអត្តភាព ៥០០ យោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៨ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាងនេះឯង ដែលពួកអសុរឃើញហើយៗ តែងរីករាយ ក្នុងមហាសមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាងនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ដែលមានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនចោតជ្រៅទៅតែម្តង ដូចជាអណ្តូង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងនូវអរហត្តផលតែម្តងទេ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងនូវអរហត្តផលតែម្តងទេ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ១ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មហា-

សមុទ្រ ជាទីអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ដែលនៅក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១០០ យោជន៍ខ្លះ ។បេ។ មានអត្តភាព ៥០០ យោជន៍ខ្លះ ដែលនៅក្នុងមហាសមុទ្រ យ៉ាងណាមិញ ។បេ។ ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើន ពួកបុគ្គលទាំងនេះ ក្នុងធម្មវិន័យនោះ គឺសោតាបន្នបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។បេ។ អរហន្ត និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីភាវៈនៃខ្លួនជាអរហន្ត ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើន បុគ្គលទាំងនេះក្នុងធម្មវិន័យនោះ គឺសោតាបន្នបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។បេ។ អរហន្ត និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីភាវៈនៃខ្លួនជាអរហន្ត ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៨ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាងនេះឯង ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។

មហាវគ្គទី ២ ចប់

### ឧទ្ទាននៃមហាវគ្គនោះ គឺ

និយាយអំពីវេរញ្ជព្រាហ្មណ៍ ១ អំពីសីហសេនាបតី ១
អំពីសេះអាជានេយ្យ ១ អំពីពុតត្បុតរបស់សេះ ១ អំពី
មទ្ទិល ១ អំពីភិក្ខុដែលគួរធ្វើជាទូត ១ អំពីចំណងមាន
២ លើក អំពីបហារាទអសុរ ១ អំពីឧបោសថ ១ ។

# អដ្ឋកថា

## ឧបោសថសូត្រ

[ ២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបោសថសូត្រទី ១០ ដូចតទៅនេះ បទថា **និសិន្នោ ហោតិ** សេចក្តីថា ព្រះសាស្តាប្រថាប់គង់លើរតនប្រាសាទរបស់ឧបាសិកាដើម្បីធ្វើឧបោសថ ។ ព្រះសាស្តា កាលប្រថាប់គង់ហើយ ទ្រង់សម្លឹងមើលចិត្តរបស់ភិក្ខុទាំងឡាយ ទ្រង់ឃើញបុគ្គលទ្រុស្តសីលមួយរូប ទ្រង់ព្រះតម្រិះថា បើតថាគតសម្តែងបាតិមោក្ខ ទាំងដែលបុគ្គលនេះនៅអង្គុយនោះឯង ក្បាលរបស់បុគ្គលនោះ នឹងបែកជា ៧ ភាគ ដូច្នេះហើយ ទើបទ្រង់តុណ្ហីភាព ដើម្បីទ្រង់អនុគ្រោះបុគ្គលនោះ ។ បទថា **អភិក្កន្តា**

ប្រែថា កន្លងទៅហើយ អស់ទៅហើយ ។ បទថា **ឧទ្ធស្តេ អរុណេ** បានដល់ កាលអរុណក៏រះឡើង ។ បទថា **ឆន្ទិមុខិយា** បានដល់ រាត្រីភ្លឺស្វាងហើយ ។ បទថា **អបរិសុទ្ធា អានន្ទ បរិសា** សេចក្ដីថា ព្រះមានព្រះភាគមិនត្រាស់ថា បុគ្គលមិនបរិសុទ្ធ តែត្រាស់ថា បរិស័ទមិនបរិសុទ្ធ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា ឧបោសថសូត្រទី ១០ ចប់**

**មហាវគ្គទី ២ ចប់**

# សុត្តន្តបិដក
# គហបតិវគ្គ

## បឋមឧគ្គសូត្រទី ១

[ ២១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកវេសាលី ថាជាអ្នកប្រកបដោយធម៌ អស្ចារ្យ ចម្លែក ៨ យ៉ាង ។ ព្រះដ៏មានព្រះភាគ បានត្រាស់នូវពាក្យនេះ លុះព្រះសុគតទ្រង់ត្រាស់នូវពាក្យនោះរួចហើយ ទើបក្រោកចាកអាសនៈ ហើយទ្រង់ស្តេចចូលទៅកាន់វិហារ ។ គ្រានោះ មានភិក្ខុ ១ រូប ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់លំនៅរបស់ឧគ្គគហបតី អ្នកស្រុកវេសាលី លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈ ដែលគេក្រាលទុក ។ ទើបឧគ្គគហបតី អ្នកស្រុកវេសាលី ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ ថ្វាយបង្គំភិក្ខុនោះដោយគោរព ហើយអង្គុយក្នុងទីសមគួរ ។ លុះឧគ្គគហបតី អ្នកស្រុកវេសាលី អង្គុយក្នុងទីសមគួរហើយ ភិក្ខុនោះក៏បានពោលដូច្នេះថា ម្នាលគហបតី អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាង ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ។ ម្នាលគហបតី អ្នកប្រកបដោយធម៌អស្ចារ្យ ចម្លែកទាំងឡាយណា ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ធម៌អស្ចារ្យចម្លែកទាំង

៨ នោះ តើដូចម្តេច ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមិនដឹងសោះ ថា ខ្ញុំព្រះករុណាប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាងដូចម្តេចខ្លះ ដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ប៉ុន្តែធម៌អស្ចារ្យចម្លែក ៨ យ៉ាងណា ដែលមានដល់ខ្ញុំករុណា លោកម្ចាស់ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ខ្ញុំព្រះករុណានឹងសម្តែងនូវធម៌អស្ចារ្យចម្លែកទាំងនោះ ។ ភិក្ខុនោះ ទទួលស្តាប់ពាក្យឧគ្គគហបតី អ្នកស្រុកវេសាលីថា ចម្រើនពរគហបតី ។ ឧគ្គគហបតីអ្នកស្រុកវេសាលី បានពោលដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលណាបើខ្ញុំករុណា បានឃើញព្រះដ៏មានព្រះភាគ អំពីចម្ងាយជាដំបូងហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ចិត្តខ្ញុំករុណា ក៏ជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគ ដោយគ្រាន់តែបានឃើញប៉ុណ្ណោះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នោះជាធម៌អស្ចារ្យចម្លែកទី ១ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លុះខ្ញុំករុណា មានចិត្តជ្រះថ្លាហើយ ក៏ចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងនូវអនុបុព្វីកថាដល់ខ្ញុំករុណា គឺទ្រង់សម្តែងទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយដ៏លាមក សៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ខ្ញុំព្រះករុណាមានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ ព្រះដ៏មានព្រះភាគក៏ទ្រង់សម្តែងធម៌ទេសនា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើក

ឡើងសម្តែងដោយព្រះអង្គឯង គឺទ្រង់សម្តែងទុក្ខសច្ច សមុទយសច្ច និរោធ-សច្ច មគ្គសច្ច ក្នុងកាលនោះ ។ សំពត់ស្អាត មិនប្រឡាក់ពណ៌ខ្មៅ គួរទទួលទឹកជ្រលក់បានដោយប្រពៃ យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ខ្ញុំករុណា លើអាសនៈនោះឯងថា ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ក៏យ៉ាងនោះដែរ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាបានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានដឹងច្បាស់អរិយ-សច្ចធម៌ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ បានឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លាហើយ មិនបានជឿស្តាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បានដល់ព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងក្នុងទីនោះ ទាំងបានសមាទាននូវសិក្ខាបទទាំងឡាយ មានព្រហ្មចរិយៈជាគម្រប់ ៥ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ២ តែងមានដល់ខ្ញុំព្រះករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមាននាងកុមារីជាប្រពន្ធ ៤ នាក់ បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះករុណាចូលទៅរកប្រពន្ធទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលទៅនឹងប្រពន្ធទាំងនោះ ដូច្នេះថា ម្នាលនាងទាំងឡាយ យើងសមាទានសិក្ខាបទទាំងឡាយមានព្រហ្មចរិយៈជាគម្រប់ ៥ ហើយ ( បើ ) នាងណាប្រាថ្នា នាងនោះ ចូរប្រើប្រាស់នូវភោគៈទាំងឡាយនេះផង ចូរធ្វើបុណ្យទាំងឡាយផងចុះ ឬថាទៅ

កាន់ត្រកូលញាតិ ជារបស់ខ្លួនក៏បាន ពុំនោះសោត នាងទាំងឡាយ ត្រូវការបុរសណា យើងនឹងឲ្យនាងទាំងឡាយទៅបុរសនោះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំករុណានិយាយយ៉ាងនេះហើយ នាងដែលជាប្រពន្ធច្បងនោះ និយាយនឹងខ្ញុំករុណាថា បពិត្រអយ្យបុត្ត ចូរអ្នកឲ្យខ្ញុំទៅបុរសឈ្មោះនេះចុះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ឯខ្ញុំករុណាក៏ឲ្យគេហៅបុរសនោះមកហើយដៃឆ្វេងកាន់ប្រពន្ធ ដៃស្តាំកាន់កុណ្ឌី ( ប្រួចទឹក ) ប្រគល់ឲ្យដល់បុរសនោះ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំករុណា លះបង់នូវនាងកុមារីឲ្យទៅជាទានហើយ ក៏មិនដឹងធ្វើចិត្តឲ្យប្រែប្រួលឡើយ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៣ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ភោគៈទាំងឡាយ មានច្រើនក្នុងត្រកូលរបស់ខ្ញុំករុណាតែភោគៈទាំងនោះ មិនបានចែកមុខ អំពីលោកអ្នកមានសីល មានកល្យាណធម៌ទាំងឡាយទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៤ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើខ្ញុំករុណាចូលទៅអង្គុយជិតភិក្ខុណា តែងចូលទៅអង្គុយជិតដោយគោរព មិនមែនចូលទៅអង្គុយជិតដោយមិនគោរពទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៥ តែងមានដល់ខ្ញុំករុណា ។ បើលោកដ៏មានអាយុនោះសម្តែងធម៌ដល់ខ្ញុំករុណា ខ្ញុំករុណាតែងស្តាប់ដោយគោរព មិនមែនស្តាប់ដោយមិនគោរពទេ បើលោកដ៏មានអាយុមិនសម្តែងធម៌ដល់ខ្ញុំករុណាទេ ខ្ញុំ

ករុណាតែងសម្តែងធម៌ដល់លោកដ៏មានអាយុនោះវិញ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៦ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកទេវតាតែងចូលមករកខ្ញុំករុណា ហើយប្រាប់ថា ម្នាលគហបតី ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយប្រពៃដូច្នេះ មិនជាទីអស្ចារ្យទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលទេវតានិយាយយ៉ាងនេះហើយ ខ្ញុំករុណាក៏និយាយទៅរកពួកទេវតាទាំងនោះ យ៉ាងនេះថា ម្នាលទេវតាទាំងឡាយ អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះក្តី មិនគប្បីពោលយ៉ាងនេះក្តី ឯធម៌ពិត ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយប្រពៃមែន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមិនដឹងថា ចិត្តដែលប៉ោងឡើងព្រោះរឿងនោះជាហេតុទេ ពួកទេវតាតែងចូលមករកខ្ញុំករុណាក៏មាន ខ្ញុំករុណាតែងចរចាជាមួយនឹងពួកទេវតាក៏មាន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៧ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន សញ្ញោជនធម៌ទាំងឡាយ ជាចំណែកខាងក្រោម ៥ យ៉ាងណា ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ បណ្តាសញ្ញោជនៈទាំងនោះ ខ្ញុំករុណាពិចារណារកសញ្ញោជនធម៌ បន្តិចបន្តួច ដែលមិនទាន់លះបង់ក្នុងខ្លួនមិនឃើញឡើយ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៨ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌អស្ចារ្យចម្លែកទាំង ៨ នេះឯង តែងមាន ( ដល់ខ្ញុំករុណា ) ចំណែកខ្ញុំករុណាមិនដឹងសោះថា ខ្ញុំករុណា

ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាង ដូចម្ដេចខ្លះ ដែលព្រះដ៏មានព្រះភាគទ្រង់បានព្យាករហើយ ។ គ្រានោះ ភិក្ខុនោះទទួលចង្ហាន់បិណ្ឌបាត ក្នុងលំនៅរបស់ឧគ្គគហបតី អ្នកស្រុកវេសាលី ហើយក៏ក្រោកចាកអាសនៈ ចៀសចេញទៅ ។ លុះភិក្ខុនោះ ត្រឡប់ពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ក៏ថ្វាយបង្គំទូលនូវរឿងរ៉ាវទាំងអស់នោះ ដែលខ្លួនចរចាទាំងប៉ុន្មាន ជាមួយនឹងឧគ្គ-គហបតី អ្នកស្រុកវេសាលី ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ ឧគ្គគហបតី អ្នកស្រុកវេសាលី កាលបើព្យាករឲ្យសមហេតុ ឈ្មោះថាព្យាករតាមពិត ម្នាលភិក្ខុ ឧគ្គគហបតី អ្នកស្រុកវេសាលី ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាងនេះឯង ដែលតថាគតបានព្យាករហើយ ម្នាលភិក្ខុ មួយទៀត អ្នកទាំងឡាយ ចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកវេសាលី ថាប្រកបដោយធម៌អស្ចារ្យចម្លែកទាំង ៨ យ៉ាងនេះចុះ ។

# អដ្ឋកថា
# គហបតិវគ្គទី ៣

## បឋមឧគ្គសូត្រ

[ ២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមឧគ្គសូត្រទី ១ នៃគហបតិវគ្គទី ៣ ដូចតទៅនេះ បទថា **បញ្ញត្តេ អាសនេ និសីទិ** សេចក្ដីថា បានឮថា ក្នុងផ្ទះរបស់ឧគ្គគហបតីនេះ គេតាក់តែងអាសនៈ ៥០០ សម្រាប់ ទុកសម្រាប់ភិក្ខុ ៥០០ រូប ជាប្រចាំនោះឯង ភិក្ខុនោះអង្គុយលើអាសនៈទាំងនោះណាមួយ ។ បទថា **តេ សុណោហិ** សេចក្ដីថា អ្នកចូរស្ដាប់ធម៌ទាំងនោះ ឬចូរស្ដាប់ធម៌ដែលគួរអស្ចារ្យមិនធ្លាប់មាន ៨ ប្រការនោះ ។ បទថា **ចិត្តំ បសីទតិ** សេចក្ដីថា ត្រឹមតែការត្រិះរិះថា លោកជាព្រះពុទ្ធ ឬមិនមែនហ្ន៎ ដូច្នេះ ក៏មិនកើតឡើង ចិត្តុប្បាទកើតឡើងថា បុគ្គលនេះឯងជាព្រះពុទ្ធ ជាអាការផូរផង់មិនល្អក់កករ ។ បទថា **សកានិ វា ញាតិកុលានិ** សេចក្ដីថា ចូរកាន់យកទ្រព្យល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅសម្រាប់ខ្លួន ហើយទៅផ្ទះរបស់ពួកញាតិ ។ បទថា **តស្ស វោ ទម្មិ** សេចក្ដីថា ខ្ញុំនឹងលើកនាងទាំងឡាយឲ្យដល់បុរសណាម្នាក់ ពួកនាងចូរប្រាប់បំណងរបស់ខ្លួនដល់ខ្ញុំ ។

បទថា **អប្បដិវិភត្តា** សេចក្ដីថា ឈ្មោះថា បុគ្គលកើតចិត្តគិតថា អញនឹងឲ្យប៉ុណ្ណេះ នឹងមិនឲ្យប៉ុណ្ណេះ នឹងឲ្យវត្ថុនេះ មិនឲ្យវត្ថុនេះ ដូច្នេះហើយ ចែកចាយទៅ រមែងមាន តែសម្រាប់ខ្ញុំ មិនដូច្នោះឡើយ ។ ដោយ

ពិត ភោគទ្រព្យទាំងនោះ ជារបស់សាធារណៈដល់អ្នកមានសីលទាំងឡាយ ដូចជារបស់សង្ឃ ដូចរបស់ពួកគណៈ ។ បទថា **សក្កច្ចំយេវ បយិរុបាសាមិ** សេចក្តីថា ខ្ញុំឧបដ្ឋាកដោយដៃរបស់ខ្លួន គឺចូលទៅរកដោយអាការគោរពក្រែង ។ ដោយពាក្យថា **អនច្ឆរិយំ ខោ បន មំ ភន្តេ** នេះ គហបតីពោលថា បពិត្រលោកម្ចាស់ ការដែលទេវតាចូលទៅរកខ្ញុំ ហើយប្រាប់យ៉ាងនោះ មិនជាការអស្ចារ្យឡើយ តែការដែលខ្ញុំមិនដឹងក្ខមិរបស់ចិត្ត មានការដែលទេវតាចូលទៅប្រាប់រឿងនោះជាហេតុ ទុំះគួរអស្ចារ្យ ។ ក្នុងពាក្យថា **សាធុ សាធុ ភិក្ខុ** នេះ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុក៏ពិត តែគប្បីជ្រាបថា នេះជាការប្រទានសាធុការក្នុងការក្លៀវក្លា ដែលកើតអំពីការខ្វល់ខ្វាយរបស់ឧបាសកប៉ុណ្ណោះ ។ល។

**អដ្ឋកថា បឋមឧគ្គសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយឧគ្គសូត្រទី ២

[ ២២ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងហត្ថិគ្រាម ក្នុងដែនវជ្ជី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកហត្ថិ-

គ្រាម ថាជាអ្នកប្រកបដោយធម៌ អស្ចារ្យចម្លែក ៨ ប្រការ ។ ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនេះ លុះព្រះសុគត ទ្រង់ត្រាស់ពាក្យនេះរួចហើយ ក៏ក្រោកចាកអាសនៈ ស្តេចចូលទៅកាន់វិហារ ។ គ្រានោះ ភិក្ខុ ១ រូបស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់លំនៅរបស់ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះ ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ ថ្វាយបង្គំភិក្ខុនោះ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម អង្គុយក្នុងទីសមគួរហើយ ភិក្ខុនោះពោលដូច្នេះថា ម្នាលគហបតី អ្នកប្រកបដោយធម៌ អស្ចារ្យចម្លែក ៨ យ៉ាង ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ម្នាលគហបតី អ្នកប្រកបដោយធម៌ អស្ចារ្យ ៨ យ៉ាងណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយ ធម៌អស្ចារ្យចម្លែក ៨ យ៉ាងនោះ តើដូចម្តេច ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនដឹងសោះថា ខ្ញុំករុណាប្រកបដោយធម៌ អស្ចារ្យ ចម្លែក ៨ យ៉ាង ដូចម្តេចខ្លះដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយទេ បពិត្រលោកម្ចាស់ដ៏ចម្រើន ក៏ប៉ុន្តែ ធម៌អស្ចារ្យចម្លែក ៨ យ៉ាងណា ដែលមានដល់ខ្ញុំករុណា សូមលោកម្ចាស់ស្តាប់នូវធម៌អស្ចារ្យ ចម្លែកទាំងនោះ សូមធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ខ្ញុំករុណានឹងសម្តែង ភិក្ខុនោះទទួលស្តាប់ពាក្យឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាមថា ចម្រើនពរ គហបតី ។ ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម បានពោលដូច្នេះ

ថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលណាខ្ញុំករុណា កំពុងត្រាច់ទៅក្នុងនាគវ័ន បានឃើញព្រះដ៏មានព្រះភាគជាដំបូងអំពីចម្ងាយ បពិត្រលោកដ៏ចម្រើន ចិត្តខ្ញុំករុណាក៏ជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគ ដោយគ្រាន់តែឃើញប៉ុណ្ណោះ ទាំងការស្រវឹងសុរា ក៏ស្វាងទៅ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ១ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លុះខ្ញុំករុណាមានចិត្តជ្រះថ្លាហើយ ក៏ចូលទៅអង្គុយជិតព្រះមានព្រះភាគ ព្រះអង្គទ្រង់សម្តែងអនុបុព្វីកថាដល់ខ្ញុំករុណា គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គ-កថា ទោសរបស់កាមដ៏លាមកសៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ខ្ញុំករុណាមានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ព្រះអង្គក៏ទ្រង់សម្តែងធម៌ទេសនា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង គឺទ្រង់សម្តែងទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ក្នុងកាលនោះ ។ សំពត់សស្អាត មិនប្រឡាក់ពណ៌ខ្មៅ គួរទទួលទឹកជ្រលក់បានដោយប្រពៃ យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ខ្ញុំករុណា លើអាសនៈនោះឯងថា ធម្មជាតណាមួយ ដែលកើតឡើងហើយជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ក៏យ៉ាងនោះដែរ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាបានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានដឹងច្បាស់អរិយ-

សច្ចធម៌ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ បានឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បានដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងក្នុងទីនោះ ទាំងបានសមាទាននូវសិក្ខាបទទាំងឡាយ មានព្រហ្មចរិយៈជាគម្រប់ ៥ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ២ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមាននាងកុមារីជាប្រពន្ធ ៤ នាក់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ខ្ញុំករុណាចូលទៅរកប្រពន្ធទាំងនោះ លុះចូលទៅដល់ហើយ បាននិយាយទៅនឹងប្រពន្ធទាំងនោះដូច្នេះថា ម្នាលនាងទាំងឡាយ យើងបានសមាទានសិក្ខាបទទាំងឡាយ មានព្រហ្មចរិយៈជាគម្រប់ ៥ ហើយ បើនាងណាប្រាថ្នា នាងនោះចូរប្រើប្រាស់នូវភោគសម្បត្តិទាំងនេះផង ចូរធ្វើបុណ្យទាំងឡាយផងចុះ ឬថា ទៅកាន់ត្រកូលញាតិរបស់ខ្លួនក៏បាន ពុំនោះសោត នាងទាំងឡាយត្រូវការបុរសណា យើងនឹងឲ្យនាងទាំងឡាយទៅបុរសនោះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំករុណានិយាយយ៉ាងនេះហើយ នាងដែលជាប្រពន្ធច្បងនោះ ក៏និយាយនឹងខ្ញុំករុណាដូច្នេះថា បពិត្រអយ្យបុត្ត សូមអ្នកឲ្យខ្ញុំទៅបុរសឈ្មោះនេះចុះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ទើបខ្ញុំករុណាក៏ឲ្យគេហៅបុរសនោះមកហើយ ដៃឆ្វេងកាន់ប្រពន្ធ ដៃស្តាំកាន់កុណ្ឌី ( ប្រួចទឹក ) ប្រគល់ឲ្យទៅបុរសនោះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំករុណាលះបង់នាងកុមារីឲ្យទៅជាទាន

ហើយ ក៏មិនដឹងធ្វើចិត្តឲ្យប្រែប្រួលឡើយ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៣ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ភោគសម្បត្តិទាំងឡាយ មានច្រើន ក្នុងត្រកូលរបស់ខ្ញុំករុណា តែភោគសម្បត្តិទាំងនោះ មិនទាន់បានបែកមុខអំពីអ្នកមានសីល មានកល្យាណ-ធម៌ទាំងឡាយទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៤ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើខ្ញុំករុណាចូលទៅអង្គុយជិតភិក្ខុណា តែងចូលទៅអង្គុយជិតដោយគោរព មិនបានចូលទៅអង្គុយជិតដោយមិនគោរពទេ បើលោកដ៏មានអាយុនោះ សម្តែងធម៌ដល់ខ្ញុំករុណា ខ្ញុំករុណាតែងស្តាប់ដោយគោរព មិនបានស្តាប់ដោយមិនគោរពទេ ប្រសិនបើលោកដ៏មានអាយុ មិនសម្តែងធម៌ដល់ខ្ញុំករុណាទេ ខ្ញុំករុណាតែងសម្តែងធម៌ដល់លោកដ៏មានអាយុនោះវិញ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៥ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំករុណា និមន្តព្រះសង្ឃមកហើយ ពួកទេវតាចូលទៅប្រាប់ថា ម្នាលគហបតី ភិក្ខុឯណោះជាឧភតោភាគវិមុត្ត ភិក្ខុឯណោះជាបញ្ញាវិមុត្ត ភិក្ខុឯណោះជាកាយសក្ខី ភិក្ខុឯណោះជាទិដ្ឋិប្បត្តៈ ភិក្ខុឯណោះជាសទ្ធាវិមុត្ត ភិក្ខុឯណោះជាធម្មានុសារី ភិក្ខុឯណោះជាសទ្ធានុសារី ភិក្ខុឯណោះជាអ្នកមានសីល មានកល្យាណធម៌ ភិក្ខុឯណោះជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ហេតុនេះ មិនជាអស្ចារ្យទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំករុណា

កំពុងអង្គាសព្រះសង្ឃ មិនដឹងធ្វើចិត្តឲ្យកើតឡើងយ៉ាងនេះថា អាត្មាអញឲ្យវត្ថុតិចដល់ភិក្ខុនេះផង ឲ្យវត្ថុច្រើនដល់ភិក្ខុនេះផងទេ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាឲ្យទាន មានចិត្តស្មើដោយពិត ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៦ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកទេវតាតែងចូលមករកខ្ញុំករុណា ហើយប្រាប់ថា ម្នាលគហបតី ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយប្រពៃ មិនជាអស្ចារ្យទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលពួកទេវតាពោលយ៉ាងនេះហើយ ខ្ញុំករុណាក៏និយាយទៅរកទេវតា ទាំងនោះយ៉ាងនេះថា ម្នាលទេវតា អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះក្តី មិនគប្បីពោលយ៉ាងនេះក្តី ឯធម៌ពិត ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយប្រពៃមែន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនដឹងថាចិត្តដែលប៉ោងឡើង ព្រោះរឿងនោះជាហេតុទេ ទោះពួកទេវតាចូលមករកខ្ញុំករុណាក្តី ខ្ញុំករុណាចរចាជាមួយនឹងពួកទេវតាក្តី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៧ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើខ្ញុំករុណា គប្បីធ្វើមរណកាលមុនព្រះដ៏មានព្រះភាគ ព្រះអង្គគប្បីព្យាករយ៉ាងនេះ ចំពោះខ្ញុំករុណាថា ឧគ្គគហបតីអ្នកស្រុកហត្ថិគ្រាម ប្រកបដោយសំយោជនៈណាហើយ គប្បីមកកាន់មនុស្សលោកនេះម្តងទៀត សំយោជនៈនោះគ្មានទេ ហេតុនុ៎ះ មិនជាអស្ចារ្យទេ ។ បពិត្រលោកម្ចាស់ដ៏

ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៨ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌ជាទីអស្ចារ្យចម្លែកទាំង ៨ នេះ តែងមាន ( ដល់ខ្ញុំករុណា ) តែថា ខ្ញុំករុណាមិនដឹងសោះថា ខ្ញុំករុណាប្រកបដោយធម៌ ជាអស្ចារ្យចម្លែក ៨ យ៉ាង ដូចម្តេចខ្លះ ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយទេ ។ លំដាប់នោះ ភិក្ខុនោះទទួលចង្ហាន់បិណ្ឌបាត ក្នុងលំនៅរបស់ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម រួចក្រោកចាកអាសនៈ ចៀសចេញទៅ ។ លុះភិក្ខុនោះត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃភត្ត ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយក៏ក្រាបបង្គំទូលនូវហេតុទាំងអស់នោះ ដែលខ្លួនចរចាទាំងប៉ុន្មាន ជាមួយនឹងឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម កាលបើព្យាករឲ្យសមហេតុ ឈ្មោះថា ព្យាករតាមពិត ម្នាលភិក្ខុ ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការនេះឯង ដែលតថាគតព្យាករហើយ ម្នាលភិក្ខុ អ្នកចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាមថា ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការនេះចុះ ។

# អដ្ឋកថា

## ទុតិយឧគ្គសូត្រ

[ ២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយឧគ្គសូត្រទី ២ ដូចតទៅនេះ បទថា **នាគវនេ** សេចក្ដីថា បានឮថា សេដ្ឋីនោះមានចម្ការ ឈ្មោះថា នាគវន សេដ្ឋីនោះឲ្យមនុស្សកាន់យកគ្រឿងក្រអូប និងកម្រងផ្កាជាដើម ក្នុងពេលមុនអាហារ បំណងនឹងលេងកីឡាក្នុងសួននោះ ដែលបរិវារចោមរោមទៅ បានឃើញព្រះមានព្រះភាគ គាត់កើតជ្រះថ្លាដោយន័យមុននោះឯង មួយអន្លើដោយការឃើញ ការស្រវឹងដែលកើតឡើង ព្រោះការផឹកសុរាក៏ស្វាងទៅក្នុងខណៈនោះឯង ។ ឧគ្គសេដ្ឋីពោលយ៉ាងនោះ សំដៅយកសេចក្ដីនោះ ។ បទថា **ឱណោជេសិ** សេចក្ដីថា ប្រួចទឹកត្រង់ព្រះហស្ដថ្វាយ ។ បទថា **អសោកោ** កែជា **អមុកោ** ។ បទថា **សមចិត្តោវ ទេមិ** សេចក្ដីថា មិនធ្វើការគិតផ្សេងៗ យ៉ាងនេះថា ឲ្យដល់បុគ្គលនេះតិច ឲ្យដល់បុគ្គលនេះច្រើន ដោយពាក្យនេះ ឧគ្គសេដ្ឋីសម្ដែងថា អញនឹងមិនធ្វើគុណរបស់ភិក្ខុទាំងនោះឲ្យដូចគ្នា តែអញធ្វើទេយ្យធម៌ឲ្យដូចគ្នា ។ បទថា **អារោចេន្តិ** សេចក្ដីថា ទេវតាទាំងឡាយ ឈរប្រាប់ក្នុងអាកាស ។ ឧបាសកបានព្យាករអនាគាមិផលរបស់ខ្លួនដោយ ពាក្យនេះថា **នត្ថិ តំ សំយោជនំ** ដូច្នេះ ។ ៚

**អដ្ឋកថា ទុតិយឧគ្គសូត្រទី ២ ចប់**

# សុត្តន្តបិដក

## បឋមហត្ថកសូត្រទី ៣

[ ២៣ ] សម័យមួយ ព្រះមានព្រះភាគកាលគង់ក្នុងអគ្គាឡវចេតិយ ជិតស្រុកអាឡវី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវហត្ថកអាឡវកថាជាអ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការ ។ ហត្ថកអាឡវកប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសទ្ធា ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសីល ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសេចក្តីខ្មាសបាប ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសេចក្តីខ្លាចបាប ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក ជាពហុស្សូត ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានចាគៈ ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវហត្ថកអាឡវកថា ជាអ្នកប្រកបដោយធម៌ អស្ចារ្យចម្លែក ៧ ប្រការនេះឯង ។ ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនេះ លុះព្រះសុគតទ្រង់ត្រាស់ពាក្យនេះរួចហើយ ទ្រង់ក្រោកចាកអាសនៈ ស្តេចចូលទៅកាន់វិហារ ។ គ្រានោះ ភិក្ខុ ១ រូបស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅរបស់ហត្ថកអាឡវក លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះ ហត្ថកអាឡវក ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ថ្វាយបង្គំភិក្ខុនោះ ហើយអង្គុយ

ក្នុងទីសមគួរ ។ លុះហត្ថកអាឡវក អង្គុយក្នុងទីសមគួរហើយ ភិក្ខុនោះបាន ពោលថា ម្នាលអាវុសោ អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការ ដែល ព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ។ ប្រកបដោយធម៌អស្ចារ្យ ចម្លែក ៧ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសទ្ធា ១ មាន សីល ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ ជាពហុស្សូត ១ មានចាគៈ ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានបញ្ញា ១ ។ ម្នាល អាវុសោ អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការនេះ ដែលព្រះដ៏មាន ព្រះភាគ ទ្រង់ព្យាករហើយ ។ ហត្ថកអាឡវក សួរតបថា បពិត្រលោកម្ចាស់ ដ៏ចម្រើន ចុះគ្រហស្ថទីមួយ អ្នកស្លៀកស មិនមានក្នុងហេតុដែលព្យាករនេះ ទេឬ ។ ម្នាលអាវុសោ គ្រហស្ថទីមួយអ្នកស្លៀកស មិនមានក្នុងហេតុព្យាករ នេះទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើគ្រហស្ថទីមួយអ្នកស្លៀកស មិន មានក្នុងហេតុព្យាករនេះទេ នុ៎ះជាការប្រពៃហើយ ។ លំដាប់នោះ ភិក្ខុនោះ ទទួលបិណ្ឌបាតក្នុងលំនៅហត្ថកអាឡវកហើយ ក៏ក្រោកចាកអាសនៈចៀស ចេញទៅ ។ លុះភិក្ខុនោះត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃភត្ត ហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទី សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងវេលា

បុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅរបស់ហត្ថកអាឡវក លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ហត្ថកអាឡវកចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំខ្ញុំព្រះអង្គ ហើយអង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះហត្ថកអាឡវក អង្គុយក្នុងទីសមគួរហើយ ខ្ញុំព្រះអង្គបានពោលដូច្នេះថា ម្នាលអាវុសោ អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការ ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ។ ប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសទ្ធា ១ មានសីល ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ ជាពហុស្សូត ១ មានចាគៈ ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានបញ្ញា ១ ។ ម្នាលអាវុសោ អ្នកប្រកបដោយធម៌អស្ចារ្យ ចម្លែក ៧ ប្រការនេះឯង ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គពោលយ៉ាងនេះហើយ ហត្ថកអាឡវកនិយាយនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន គ្រហស្ថនីមួយអ្នកស្លៀកស មិនមានក្នុងហេតុព្យាករនេះទេឬ ។ ម្នាលអាវុសោ គ្រហស្ថនីមួយ អ្នកស្លៀកស មិនមានក្នុងហេតុព្យាករនេះទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើគ្រហស្ថនីមួយ អ្នកស្លៀកស មិនមានក្នុងហេតុព្យាករនេះទេ នុ៎ះជាការប្រពៃហើយ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ កុលបុត្រនោះជាអ្នកប្រាថ្នា

*តិច កាលបើកុសលធម៌មាននៅក្នុងខ្លួនហើយ រមែងមិនប្រាថ្នាឲ្យអ្នកដទៃដឹងទេ ។ ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរចាំទុកនូវហត្ថកអាឡវក ថាជាអ្នកប្រកបដោយធម៌អស្ចារ្យចម្លែកនេះ គឺ ។បេ។ កាលជាអ្នកប្រាថ្នាតិច ។*

# អដ្ឋកថា

## បឋមហត្ថកសូត្រ

*[ ២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមហត្ថកសូត្រទី ៣ ដូចតទៅនេះ បទថា* **ហត្ថកោ អាឡវកោ** *សេចក្តីថា ព្រះរាជកុមារដែលបានឈ្មោះថា ហត្ថកៈ ព្រោះព្រះមានព្រះភាគ ទ្រង់ទទួលអំពីដៃរបស់អាឡវកយក្ខ ដោយព្រះហស្ត ។ បទថា* **សីលវា** *បានដល់ ជាអ្នកមានសីល ដោយសីល ៥ និងសីល ១០ ។ បទថា* **ចាគវា** *ប្រែថា ដល់ព្រមដោយបរិច្ចាគ ។ បទថា* **កច្චិត្ថ ភន្តេ** *សេចក្តីថា ក្នុងទីដែលព្រះមានព្រះភាគទ្រង់ព្យាករនេះឯងឬ ។ បទថា* **អប្បិច្ឆោ** *បានដល់ បុគ្គលឈ្មោះថា ប្រាថ្នាតិច ព្រោះប្រាថ្នាតិចក្នុងអធិគម ។*

**អដ្ឋកថា បឋមហត្ថកសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ទុតិយហត្ថកសូត្រទី ៤

[ ២៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងអគ្គាឡវចេតិយ ជិតស្រុកអាឡវី ។ គ្រានោះ ហត្ថកអាឡវក មានឧបាសកចំនួន ៥០០ នាក់ ចោមរោម ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះហត្ថកអាឡវកអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលហត្ថកៈ ពួកបរិសទ្យរបស់អ្នកច្រើនណាស់ ម្នាលហត្ថកៈ ចុះអ្នកសង្គ្រោះបរិសទ្យច្រើននេះដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន សង្គហវត្ថុទាំងឡាយ ៤ ប្រការណា ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ខ្ញុំព្រះអង្គរមែងសង្គ្រោះបរិសទ្យច្រើននេះ ដោយសង្គហវត្ថុទាំងឡាយនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ដឹងនូវបុគ្គលណាថា បុគ្គលនេះ គួរសង្គ្រោះដោយការឲ្យ ខ្ញុំព្រះអង្គក៏សង្គ្រោះបុគ្គលនោះ ដោយការឲ្យ ខ្ញុំព្រះអង្គដឹងនូវបុគ្គលណាថា បុគ្គលនេះ គួរសង្គ្រោះដោយសម្តី ជាទីស្រឡាញ់ ខ្ញុំព្រះអង្គក៏សង្គ្រោះបុគ្គលនោះដោយសម្តីជាទីស្រឡាញ់ ខ្ញុំព្រះអង្គដឹងនូវបុគ្គលណាថា បុគ្គលនេះ គួរសង្គ្រោះដោយការប្រព្រឹត្តនូវប្រយោជន៍ ខ្ញុំព្រះអង្គ ក៏សង្គ្រោះបុគ្គលនោះ ដោយការប្រព្រឹត្តនូវប្រយោជន៍ ខ្ញុំព្រះអង្គដឹងនូវបុគ្គលណាថា បុគ្គលនេះ គួរសង្គ្រោះដោយការតាំងខ្លួនឲ្យស្មើៗ ខ្ញុំព្រះអង្គក៏សង្គ្រោះបុគ្គលនោះ ដោយការតាំងខ្លួនឲ្យស្មើៗ ។ បពិត្រព្រះអង្គដ៏ចម្រើន ភោគសម្បត្តិក្នុងត្រកូលរបស់ខ្ញុំព្រះអង្គ

មានច្រើន ពួកមហាជន រមែងមិនសម្គាល់នូវពាក្យរបស់ជនអ្នកកម្សត់ ថាជាពាក្យគួរស្តាប់ ដូចជាពាក្យរបស់ខ្ញុំព្រះអង្គទេ ។ ម្នាលហត្ថកៈ ប្រពៃហើយ ប្រពៃហើយ ម្នាលហត្ថកៈ នេះជាឧបាយរបស់អ្នក ដើម្បីសង្គ្រោះនូវបរិសទ្យច្រើន ។ ម្នាលហត្ថកៈ ព្រោះថា ពួកជនណាមួយ បានសង្គ្រោះបរិសទ្យច្រើន ក្នុងកាលកន្លងទៅហើយ ជនទាំងអស់នោះ បានសង្គ្រោះនូវបរិសទ្យច្រើន ដោយសង្គហវត្ថុទាំង ៤ នេះឯង ។ ម្នាលហត្ថកៈ ពួកជនណាមួយ នឹងសង្គ្រោះបរិសទ្យច្រើន ក្នុងកាលជាអនាគត ជនទាំងអស់នោះនឹងសង្គ្រោះនូវបរិសទ្យច្រើន ដោយសង្គហវត្ថុទាំង ៤ នេះឯង ។ ម្នាលហត្ថកៈ ពួកជនណាមួយ សង្គ្រោះបរិសទ្យច្រើន ក្នុងកាលឥឡូវនេះ ជនទាំងអស់នោះ តែងសង្គ្រោះនូវបរិសទ្យច្រើន ដោយសង្គហវត្ថុទាំង ៤ នេះឯង ។ លំដាប់នោះ ហត្ថកអាឡវក កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ណែនាំ ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ លុះហត្ថកអាឡវក ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវហត្ថកអាឡវក ថាជាអ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការ ។ ហត្ថកអាឡវក ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសទ្ធា ១ មានសីល ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ ជាពហុស្សូត ១ មាន

បាត: ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានបញ្ញា ១ ម្នាលភិក្ខុទាំង-ឡាយ ហត្ថកអាឡវក មានសេចក្តីប្រាថ្នាតិច ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវហត្ថកអាឡវក ថាជាអ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការនេះចុះ ។

# អដ្ឋកថា

## ទុតិយហត្ថកសូត្រ

[ ២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយហត្ថកសូត្រទី ៤ ដូចតទៅនេះ បទថា **បញ្ចមត្តេហិ ឧបាសកសតេហិ** សេចក្តីថា ហត្ថកឧបាសកដែលអរិយសាវកឧបាសក ជាសោតាបន្ន សកទាគាមី និងអនាគាមីប៉ុណ្ណោះ ចោមរោមហើយ បរិភោគអាហារព្រឹកហើយ កាន់យកគ្រឿងក្រអូប ផ្កា និងលម្អិត សម្រាប់លាបជាដើម ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។ បទថា **សង្គហវត្ថូនិ** បានដល់ ហេតុនៃការសង្គ្រោះ ។ បទថា **តេហាហំ** កាត់បទជា **តេហិ អហំ**។

បទថា **តំ ទានេន សង្គណ្ហាមិ** សេចក្តីថា ខ្ញុំនឹងឲ្យទន្ត័ល គោបម្រើ អាហារ និងពូជជាដើម និងគ្រឿងក្រអូប កម្រងផ្កា និងលម្អិតសម្រាប់លាបជាដើម ឲ្យសង្គ្រោះ ។ បទថា **បេយ្យវាចេន** សេចក្តីថា ខ្ញុំសង្គ្រោះដោយ

បិយវាចាដ៏ពីរោះ ចូលត្រចៀក មានពាក្យជាដើមថា លោកឪពុក អ្នកម្ដាយ បងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី ។ បទថា **អត្ថចរិយាយ** សេចក្ដីថា ខ្ញុំសង្គ្រោះដោយការប្រព្រឹត្តប្រយោជន៍ ពោល គឺដឹងថា បុគ្គលនេះមិនមានកិច្ចដោយការឲ្យ ឬដោយបិយវាចា បុគ្គលនេះគប្បីសង្គ្រោះ ដោយការប្រព្រឹត្តប្រយោជន៍ ដូច្នេះហើយ ទើបជួយកិច្ចដែលកើតឡើង ។ បទថា **សមានត្តតាយ** សេចក្ដីថា ខ្ញុំសង្គ្រោះ ដោយធ្វើឲ្យស្មើនឹងខ្លួន ដោយការបរិភោគ ការផឹក និងការអង្គុយជាដើមរួមគ្នា ព្រោះដឹងថា បុគ្គលនេះមិនមានកិច្ច ដោយការឲ្យជាដើម បុគ្គលនេះគួរសង្គ្រោះដោយភាពជាបុគ្គលមានខ្លួនស្មើគ្នា ។ បទថា **ទលិទ្ទស្ស ខោ នោ តថា សោតព្វំ មញ្ញន្តិ** សេចក្ដីថា កាលបុគ្គលក្រីក្រ មិនអាចឲ្យ ឬធ្វើអ្វីមួយបាន ជនទាំងឡាយរមែងមិនសម្គាល់ថា នឹងត្រូវស្ដាប់ ដូចពាក្យរបស់បុគ្គលក្រីក្រ តែពាក្យរបស់ខ្ញុំ ជនទាំងឡាយ រមែងសម្គាល់ថា គួរស្ដាប់ គឺរមែងតាំងនៅក្នុងឱវាទដែលឲ្យអធិប្បាយថា រមែងមិនសម្គាល់ ដែលនឹងកន្លងល្មើសអនុសាសនីរបស់ខ្ញុំព្រះអង្គ ។ បទថា **យោនិ ខោ ត្យាយំ** កែជា **ឧបាយោ ខោ តេ អយំ** ប្រែថា នេះជាឧបាយរបស់អ្នក ។ ក្នុងសូត្រទី ២ នេះ គប្បីជ្រាបថា ត្រាស់សទ្ធា សីល ចាគៈ និងបញ្ញាលាយឡំគ្នា ។

## អដ្ឋកថា ទុតិយហត្ថកសូត្រទី ៤ ចប់

# សុត្តន្តបិដក

## មហានាមសូត្រទី ៥

[ ២៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ សក្យមហានាមចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះសក្យមហានាម គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលបានជាឧបាសក តើដោយហេតុដូចម្តេច ។ បពិត្រមហានាម បុគ្គលអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ដោយហេតុណា បពិត្រមហានាម បុគ្គលបានជាឧបាសក ដោយហេតុប៉ុណ្ណោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកមានសីល តើដោយហេតុដូចម្តេច ។ បពិត្រមហានាម ឧបាសក ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ដោយហេតុណា បពិត្រមហានាម ឧបាសកអ្នកមានសីល ដោយហេតុប៉ុណ្ណោះឯង ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃទេ តើដោយហេតុដូចម្តេច ។ បពិត្រមហានាម ឧបាសកអ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯង

មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបានស្តាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់ធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១ អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា បពិត្រមហានាម ឧបាសក អ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសក អ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង តើដោយហេតុដូចម្តេច ។ បពិត្រមហានាម ឧបាសក អ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីលដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបានជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់

ព្រះសទ្ធម្មដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបានស្តាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលបានស្តាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្តាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១ អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា បពិត្រមហានាម ឧបាសក អ្នកប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

# អដ្ឋកថា

## មហានាមសូត្រ

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហានាមសូត្រទី ៥ ដូចតទៅនេះ បទថា **អត្ថូបបរិក្ខី ហោតិ** សេចក្តីថា រមែងជាអ្នកពិចារណាដល់ប្រយោជន៍ និងមិនមែនប្រយោជន៍ គឺហេតុ និងមិនមែនហេតុ ៗ។

**អដ្ឋកថា មហានាមសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ជីវកសូត្រទី ៦

[ ២៦ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងជីវកម្ពវ័ន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ជីវកកោមារភត្យ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះជីវកកោមារភត្យ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលបានជាឧបាសក តើដោយហេតុដូចម្តេច ។ ម្នាលជីវក បុគ្គលអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ដោយហេតុណា ម្នាលជីវក បុគ្គលនោះ បានជាឧបាសក ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកមានសីល តើដោយហេតុដូចម្តេច ។ ម្នាលជីវក ឧបាសកជាអ្នកវៀរចាកបាណាតិបាត ។បេ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ដោយហេតុណា ម្នាលជីវក ឧបាសកជាអ្នកមានសីល ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសក អ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ តើដោយហេតុដូចម្តេច ។ ម្នាលជីវក ឧបាសក អ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង តែមិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ ។បេ។ អ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង តែមិនបបួលបុគ្គល

ដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា ម្នាលជីវក ឧបាសក អ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង តើដោយហេតុដូចម្តេច ។ ម្នាលជីវក ឧបាសក អ្នកបរិបូណ៌ដោយសទ្ធាដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីលដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបានស្តាប់នូវព្រះសទ្ធម្ម ១ ជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលបានស្តាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១ អ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា ម្នាលជីវក ឧបាសក អ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

# អដ្ឋកថា

## ជីវកសូត្រ

[ ២៦ ] ក្នុងជីវកសូត្រទី ៦ ព្រះមានព្រះភាគត្រាស់សទ្ធា សីល និង ចាគៈលាយគ្នា ។ល។

អដ្ឋកថាជីវកសូត្រទី ៦ ចប់

# សុត្តន្តបិដក

## បឋមពលសូត្រទី ៧

[ ២៧ ] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៨ យ៉ាង ។ កម្លាំង ៨ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកក្មេងមានការយំ ជាកម្លាំង ១ ពួកមាតុគ្រាមមានសេចក្ដីក្រោធ ជាកម្លាំង ១ ពួកចោរមានគ្រឿងអាវុធ ជាកម្លាំង ១ ពួកព្រះរាជាមានឥស្សរិយៈ ជាកម្លាំង ១ ពួកជនពាលមានការលើកទោស ជាកម្លាំង ១ ពួកបណ្ឌិតមានការរំពឹងគិត ជាកម្លាំង ១ ពួកពហុស្សុតមានការពិចារណា ជាកម្លាំង ១ ពួកសមណព្រាហ្មណ៍មានការអត់ធន់ ជាកម្លាំង ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៨ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមពលសូត្រ

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមពលសូត្រទី ៧ ដូចតទៅនេះ បទថា **ឧជ្ឈត្តិពលា** ប្រែថា មានការសម្លឹងទោសជាកម្លាំង ។ ពិតហើយ ពួកបុគ្គលពាល មានកម្លាំងចំពោះតែការសម្លឹងទោសយ៉ាងនេះថា បុគ្គលនោះប្រាប់រឿងនេះៗ នឹងអ្នកណា បុគ្គលនោះបានប្រាប់ដល់អញ មិនប្រាប់ដល់អញ ។ បទថា **និជ្ឈត្តិពលា** សេចក្ដីថា មានការមិនសម្លឹងប្រយោជន៍ប៉ុណ្ណោះថា នេះមិនមែន នេះឈ្មោះថា យ៉ាងនេះជាកម្លាំង ។ បទថា **បដិសង្ខានពលា** ប្រែថា មានការពិចារណាជាកម្លាំង ។ បទថា **ខន្តិពលា** បានដល់ មានការអត់ធន់ ដោយការឈប់ស្កាត់ជាកម្លាំង ៕

អដ្ឋកថា បឋមពលសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ទុតិយពលសូត្រទី ៨

[ ២៨ ] គ្រានោះ ព្រះសារីបុត្រដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះ

ដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលសារីបុត្ត ភិក្ខុជាខីណាស្រព ប្រកប ដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយ ថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ កម្លាំងទាំងនោះ របស់ ភិក្ខុជាខីណាស្រព តើមានប៉ុន្មានយ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជា ខីណាស្រព ប្រកបដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅនៃ អាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ កម្លាំង ទាំងនោះ របស់ភិក្ខុជាខីណាស្រពមាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ក្នុងសាសនានេះ ឃើញច្បាស់នូវ សង្ខារទាំងពួងថា មិនទៀង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ។ បពិត្រព្រះ អង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ឃើញច្បាស់នូវសង្ខារទាំងពួងថា មិនទៀង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ដោយកម្លាំងណា បពិត្រព្រះអង្គដ៏ចម្រើន (ម្យ៉ាងទៀត ) ភិក្ខុជាខីណាស្រព ប្តេជ្ញានូវកិរិយាអស់ទៅនៃអាសវៈទាំងឡាយ ថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន មួយ ទៀត ភិក្ខុជាខីណាស្រព ឃើញច្បាស់នូវកាមទាំងឡាយ មានឧបមាដូចជា រណ្តៅ ដ៏ពេញដោយរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ។ បពិត្រ ព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រពឃើញច្បាស់នូវកាមទាំងឡាយ ដែលមាន ឧបមាដូចជារណ្តៅដ៏ពេញដោយរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត

ដោយកម្លាំងណា បពិត្រព្រះអង្គដ៏ចម្រើន ( ម្យ៉ាងទៀត ) ភិក្ខុជាខីណាស្រព ប្តេជ្ញានូវកិរិយាអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ចិត្តរបស់ភិក្ខុជាខីណាស្រព តែងឱនទៅរកវិវេក ឈានទៅរកវិវេក បែរទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈដោយប្រការទាំងពួង ។ បពិត្រព្រះអង្គដ៏ចម្រើន ចិត្តរបស់ភិក្ខុជាខីណាស្រព តែងឱនទៅរកវិវេក ឈានទៅរកវិវេក បែរទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ដោយកម្លាំងណា បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព ប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុ ជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព បានចម្រើន អប់រំល្អហើយ នូវសតិប្បដ្ឋានទាំង ៤ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព បានចម្រើន អប់រំល្អហើយ នូវសតិប្បដ្ឋាន ៤ ដោយកម្លាំងណា បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព ប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យ

កម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុ ជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព បានចម្រើន អប់រំល្អហើយនូវឥទ្ធិបាទ ៤ ។បេ។ បានចម្រើន អប់រំល្អហើយ នូវឥន្ទ្រិយ ៥ បានចម្រើន អប់រំល្អហើយ នូវពោជ្ឈង្គ ៧ បានចម្រើន អប់រំល្អហើយ នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព បានចម្រើន អប់រំល្អហើយនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដោយកម្លាំងណា បពិត្រព្រះអង្គដ៏ចម្រើន ( ម្យ៉ាងទៀត ) ភិក្ខុជាខីណាស្រព ប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុ ជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រពប្រកបដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ កម្លាំងទាំងនោះ របស់ភិក្ខុជាខីណាស្រព មាន ៨ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយពលសូត្រ

[ ២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយពលសូត្រទី ៨ ដូចតទៅនេះ បទថា **ពលានិ** បានដល់ កម្លាំង គឺព្រះញាណ ។ បទថា **អាសវានំ ខយំ បដិជានាតិ** សេចក្តីថា រមែងប្តេជ្ញានូវអរហត្ត ។ បទថា **អនិច្ចតោ** ប្រែថា ដោយអាការមានហើយ បែរជាមិនមាន ។ បទថា **យថាភូតំ** ប្រែថា តាមសេចក្តីពិត ។ បទថា **សម្មប្បញ្ញាយ** បានដល់ ដោយសម្មាវិបស្សនា និងមគ្គប្បញ្ញា ។ បទថា **អង្គារកាសូបមា** សេចក្តីថា កាមទាំងនេះ លោកប្រៀបដូចរងើកភ្លើង ព្រោះអត្ថថា ធ្វើឲ្យក្តៅក្រហាយ ។ បទថា **វិវេកនិន្នំ** បានដល់ បង្អោនទៅក្នុងព្រះនិព្វាន ដោយអំណាចផលសមាបត្តិ ។ បទថា **វិវេកដ្ឋំ** បានដល់ វៀរ ឬឆ្ងាយចាកកិលេសទាំងឡាយ ។ បទថា **នេក្ខម្មាភិរតំ** បានដល់ ត្រេកអរក្រៃលែងក្នុងបព្វជ្ជា ។ បទថា **ព្យន្តីភូតំ** ប្រែថា មានទីបំផុត គឺតណ្ហាទៅប្រាសហើយ គឺដោយឯកទេស ក៏មិនជាប់ មិនប្រកប មិនពាក់ព័ន្ធ ។ បទថា **អាសវដ្ឋានិយេហិ** បានដល់ ចាកធម៌ដែលជាហេតុនៃអាសវៈទាំងឡាយ ដោយអំណាចការប្រកប អធិប្បាយថា ចាកកិលេសធម៌ទាំងឡាយ ។ ម្យ៉ាងទៀត បទថា **ព្យន្តីភូតំ** ប្រែថា ប្រាសចាកតណ្ហាដែលឈ្មោះថា តន្តី អធិប្បាយថា ប្រាសចាកតណ្ហា ។ បទថា **សព្វសោ អាសវដ្ឋានិយេហិ ធម្មេហិ** សេចក្តីថា ប្រាសចាកធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ។ ក្នុងសូត្រនេះ លោកពោលដល់អរិយមគ្គជាលោកិយផង ជា

លោកុត្តរផល ។ល។

## អដ្ឋកថា ទុតិយពលសូត្រទី ៨ ចប់

# សុត្តន្តបិដក

## អក្ខណសូត្រទី ៩

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនមិនមានការចេះដឹង រមែងនិយាយថា សត្វលោកមានកិច្ចក្នុងខណៈ សត្វលោកមានកិច្ចក្នុងខណៈ តែបុថុជ្ជននោះមិនដឹងនូវខណៈ ឬអក្ខណៈទេ ។ ម្នាលភិក្ខុទាំងឡាយ អក្ខណៈ អសម័យនៃការនៅប្រព្រឹត្តព្រហ្មចារ្យនេះ មាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណឥតមានបុគ្គលណាស្មើ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ដូចនាយសារថី ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរារិយសច្ច ទ្រង់មានដំណើរទៅកាន់ត្រៃកពង្ខាក់ចោលហើយ បានកើតឡើងក្នុងលោកនេះ ទាំងធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គក៏បានសម្តែង

ហើយ តែទាស់បុគ្គលនេះ ទៅកើតក្នុងនរក ។ ម្នាលភិក្ខុទាំងឡាយ នេះជា អក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យទី ១ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ព្រះតថាគត ។បេ។ ជាសាស្តានៃទេវតា និងមនុស្សទាំង-ឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរារិយសច្ច ទ្រង់មានដំណើរទៅកាន់ត្រៃគកពខ្ចាក់ចោលហើយ រមែងកើតឡើងក្នុងលោក ទាំងធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គបានសម្តែងហើយ តែទាស់បុគ្គលនេះ ទៅកើតក្នុងកំណើតតិរច្ឆាន ។បេ។ តែទាស់បុគ្គលនេះ ទៅកើតក្នុងបិត្តិវិស័យ ។បេ។ តែទាស់បុគ្គលនេះ ទៅកើតក្នុងពួកទេវតាណាមួយ មានអាយុវែង ។បេ។ តែទាស់បុគ្គលនេះ ជាអ្នកមកកើតក្នុងពួកបច្ចន្តិមជនបទ ទាំងជាអ្នកបានទៅកើតក្នុងពួកមិលក្ខជន ដែលមិនដឹងការខុសត្រូវច្បាស់លាស់ ដែលជាប្រទេសគ្មានភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាទៅដល់ ។បេ។ បុគ្គលនេះ បានមកកើតក្នុងពួកមជ្ឈិមជនបទហើយ ទាស់តែបុគ្គលនោះ ជាមិច្ឆាទិដ្ឋិ មានសេចក្តីឃើញវិបរិតថា ទានដែលបុគ្គលឲ្យហើយគ្មានផល ការបូជាធំគ្មានផល ការបូជាតូចគ្មានផល ផល និងវិបាករបស់កម្ម ដែលសត្វធ្វើល្អ និងធ្វើអាក្រក់ មិនមានលោកនេះក៏មិនមាន លោកដទៃ ក៏មិនមាន មាតាក៏មិនមាន បិតាក៏មិនមានពួកសត្វជាឱបបាតិកៈក៏មិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិដោយល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ

ព្រោះដឹងច្បាស់ដោយខ្លួនឯង ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង ក៏មិនមាន ។បេ។ បុគ្គលនេះ បានមកកើតក្នុងពួកមជ្ឈិមជនបទហើយ ទាស់តែបុគ្គលនោះ ជាអ្នកអប្បឥតប្រាជ្ញា ល្ងង់ខ្លៅ ជាមនុស្សគ្រ មិនអង់អាច ដើម្បីដឹងសេចក្តីនៃ សុភាសិត និងទុព្ភាសិតបាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាអក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យទី ៧ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ចំពោះព្រះអង្គ ។បេ។ ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច មាន ដំណើរទៅកាន់ត្រៃកពន្លាក់ចោលហើយ មិនកើតឡើងក្នុងលោក ទាំងធម៌ដែល ធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គក៏មិនបានសម្តែង បុគ្គល នេះ បានកើតក្នុងមជ្ឈិមជនបទ ក៏ឯបុគ្គលនោះ ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនជាមនុស្សគ្រ អង់អាចដើម្បីដឹងសេចក្តីនៃសុភាសិត និងទុព្ភាសិតបាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាអក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យ ទី ៨ ។ ម្នាលភិក្ខុទាំងឡាយ អក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យ មាន ៨ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ខណៈ និងសម័យនៃការនៅ ប្រព្រឹត្តព្រហ្មចារ្យ មានតែមួយ ។ មួយតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយ ប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ

ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ដូចនាយសារថី ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរារិយសច្ច ទ្រង់មានដំណើរទៅកាន់ត្រៃកពខ្ចាក់ចោលហើយ បានកើតឡើងក្នុងលោកនេះ ទាំងធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គក៏បានសម្តែងហើយ ទាំងបុគ្គលនេះបានកើតក្នុងពួកមជ្ឈិមជនបទ ថែមទាំងបុគ្គលនោះ ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនជាមនុស្សគ អង់អាច ដើម្បីដឹងសេចក្តីនៃសុភាសិត និងទុព្ភាសិតបាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាខណៈ និងសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យតែមួយ ។

ពួកជនណា បាននូវមនុស្សលោកហើយ ( បានកើតជាមនុស្ស ) តែមិនជួបប្រទះនូវខណៈ ក្នុងព្រះសទ្ធម្ម ដែលព្រះតថាគតទ្រង់សម្តែងដោយល្អ ជនទាំងនោះ ឈ្មោះថា កន្លងបង់នូវខណៈ អក្ខណៈទាំងឡាយ ដែលអ្នកប្រាជ្ញទាំងឡាយជាច្រើន បានពោលហើយថា ធ្វើនូវសេចក្តីអន្តរាយដល់បុគ្គល ព្រះតថាគតទាំងឡាយ ទ្រង់កើតឡើង ក្នុងលោកម្តងៗ ការកើតឡើងនៃព្រះតថាគតទាំងឡាយណា ដែលសត្វបានដោយកម្រក្រៃពេក ក្នុង

លោក ការកើតឡើងនៃព្រះតថាគតទាំងឡាយនោះ ក៏កើតចំពោះមុខហើយ ការបានអត្តភាពជាមនុស្សផង ការសម្តែងនូវព្រះសទ្ធម្មផង ( ក៏បានកើតចំពោះមុខហើយ ) ជនអ្នកមានសេចក្តីប្រាថ្នា នូវប្រយោជន៍ គួរព្យាយាមក្នុងព្រះសទ្ធម្មនោះ ។ បុគ្គលគប្បីដឹងច្បាស់ នូវព្រះសទ្ធម្ម ដោយហេតុដូចម្តេច ខណៈកុំកន្លងនូវអ្នកទាំងឡាយឡើយ ព្រោះថា ពួកជនដែលខណៈកន្លងហើយ រមែងសោកស្រែងសង្រែង ក្នុងនរកត្រៀបត្រា ។ បើបុគ្គលណា ក្នុងលោកនេះ ញុំាងសេចក្តីកំណត់នូវព្រះសទ្ធម្ម គឺអរិយមគ្គ មិនឲ្យសម្រេចទេ បុគ្គលនោះជាអ្នកកន្លងបង់នូវប្រយោជន៍ រមែងសោកស្រែងសង្រែង អស់រាត្រីយូរ ដូចជាពាណិជ ដែលកន្លងបង់នូវប្រយោជន៍ ដូច្នោះដែរ សត្វដែលអវិជ្ជា រួបរឹតហើយ មិនញុំាងព្រះសទ្ធម្មឲ្យសម្រេចបាន គង់នឹងត្រឡប់មកកាន់សង្សារ គឺការកើតនិងការស្លាប់ អស់កាលដ៏យូរ មួយទៀត ពួកជនណា បាននូវអត្តភាពជាមនុស្ស ក្នុងព្រះសទ្ធម្ម ដែលព្រះតថាគត សម្តែងល្អហើយ បានធ្វើហើយ នឹងធ្វើ ឬកំពុងធ្វើ តាមពាក្យនៃព្រះសាស្តា ពួកជនណា ដើរ

ទៅកាន់ផ្លូវ ដែលព្រះតថាគត សម្តែងទុកហើយ ពួក
ជននោះ ឈ្មោះថា ត្រាស់ដឹងនូវខណៈ និងព្រហ្មចារ្យ
ដ៏ប្រសើរក្នុងលោក សេចក្តីសង្រួមណា ដែលព្រះពុទ្ធ
ជាអាទិច្ចពន្ធុ ព្រះអង្គមានចក្ខុ បានសម្តែងហើយ
បុគ្គលមានចិត្តមិនទទឹក ដោយកិលេស ជាអ្នកមាន
ស្មារតីគ្រប់កាល គប្បីគ្រប់គ្រងក្នុងសេចក្តីសង្រួមទាំង
នោះ ពួកជនណា បានដល់នូវការអស់ទៅនៃអាសវៈ
ជនទាំងនោះ បានកាត់នូវអនុស័យទាំងពួង ដែលទៅ
កាន់សង្សារ ជាលំនៅនៃមារហើយ ដល់នូវត្រើយ គឺ
ព្រះនិព្វាន ក្នុងលោក ។

# អដ្ឋកថា

## អក្ខណាសូត្រ

[ ២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអក្ខណាសូត្រទី ៩ ដូចតទៅនេះ សត្វលោក រមែងធ្វើកិច្ចទាំងឡាយក្នុងខណៈ ព្រោះដូច្នោះ សត្វលោកនោះ ឈ្មោះថា **ខណកិច្ចា** អធិប្បាយថា ល្មមបានឱកាសធ្វើកិច្ចទាំងឡាយ ។ បទថា **ធម្មោ** បានដល់ ធម៌ គឺសច្ចៈទាំង ៤ ។ បទថា **ឧបសមិកោ** បានដល់ នាំ

នូវការស្ងប់កិលេសមកឲ្យ ។ បទថា **បរិនិព្វានិកោ** បានដល់ ធ្វើនូវការរលត់កិលេសបានដោយឥតសេសសល់ ។ ឈ្មោះថា **សម្ពោធគាមី** ព្រោះដល់ គឺសម្រេចសម្ពោធិញាណ ពោល គឺមគ្គញាណ ៤ ។ ពាក្យថា **ទីឃាយុកំ ទេវនិកាយំ** នេះ ព្រះមានព្រះភាគត្រាស់សំដៅដល់អសញ្ញីទេវតា ។ បទថា **អវិញ្ញាតារេសុ** សេចក្តីថា ក្នុងពួកមិលក្ខៈ អ្នកមិនចេះដឹង ។

បទថា **សុប្បវេទិតេ** សេចក្តីថា ដែលព្រះមានព្រះភាគ ត្រាស់ល្អហើយ ។ បទថា **អន្តរាយិកា** ប្រែថា ដែលធ្វើអន្តរាយ ។ បទថា **ខណោ វោ មា ឧបជ្ឈគា** សេចក្តីថា ខណៈដែលអ្នកបានហើយនេះ កុំកន្លងអ្នកទាំងឡាយទៅឡើយ ។ បទថា **ឥធ ចេ ន វិរាធេតិ** សេចក្តីថា បើបុគ្គលណាម្នាក់ មានប្រក្រតីប្រព្រឹត្តប្រមាទ សូម្បីបានខណៈនេះក្នុងលោកនេះហើយ ក៏មិនសម្រេច គឺមិនសម្រេចនូវភាពដែលព្រះសទ្ធម្មជារបស់ទៀងទាត់ គឺអរិយមគ្គ ។ បទថា **អតីតត្ថោ** បានដល់ ជាអ្នកវិនាសប្រយោជន៍ហើយ ។ បទថា **ចិរត្តនុតបិស្សតិ** សេចក្តីថា នឹងសោកស្តាយអស់កាលយូរ ។ ដូចឈ្មួញម្នាក់ បានឮថា ក្នុងទីឈ្មោះនោះ ទំនិញមានតម្លៃស្មើគ្នា ក៏មិនទៅ ឈ្មួញដទៃទិញយកមក ទំនិញនោះក៏មានតម្លៃកើនឡើង ៨ ដង ១០ ដងខ្លះ កាលបើដូច្នោះ ឈ្មួញម្នាក់ទៀត គប្បីក្តៅក្រហាយគិតថា ប្រយោជន៍របស់អញកន្លងទៅហើយ ដូច្នេះ យ៉ាងណា បុគ្គលណាបានខណៈក្នុងលោកហើយ មិនបដិបត្តិ មិនត្រេកអរ ក្នុងការកំណត់ពិតប្រាកដនៃព្រះសទ្ធម្ម បុគ្គលនោះ

ឈ្មោះថា មានប្រយោជន៍កន្លងហើយ ដូចឈ្នួញនេះ នឹងក្តៅក្រហាយ នឹងសោកស្តាយអស់កាលយូរជាងបុគ្គលណាៗ ដូច្នោះ ។ បទថា **អភិដ្ឋា-ឆិវុតោ** គប្បីជ្រាបសេចក្តីយ៉ាងនោះ ។ បទថា **បច្ចភិដ្ឋំ** ប្រែថា បានត្រាស់ដឹងហើយ ។ បទថា **សំវកា** បានដល់ ដែលសង្រួមក្នុងសីល ។ បទថា **មារធេយ្យសានុគេ** សេចក្តីថា ដែលរសាត់តាមសង្សារវដ្ត គឺជាចំណីមារ ។ បទថា **ធារគតា** បានដល់ ដល់នូវព្រះនិព្វាន ។ បទថា **យេ បត្តា អាសវក្ខយំ** សេចក្តីថា ជនទាំងឡាយណា សម្រេចអរហត្តហើយ ។ ព្រះមានព្រះភាគត្រាស់វដ្តៈ និងវិវដ្តៈ ក្នុងព្រះគាថាទាំងឡាយ ក្នុងព្រះសូត្រនេះដោយប្រការដូច្នេះ ៕

**អដ្ឋកថា អក្ខណាសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## អនុរុទ្ធសូត្រទី ១០

[ ៣០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់សត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ ក្នុងសម័យនោះ ព្រះអនុរុទ្ធដ៏មានអាយុ គង់នៅក្នុងបាចីនវង្សទាយវ័ន ក្នុងដែន

ចេតី ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ នៅក្នុងទីស្ងាត់ពួនសម្ងំ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើន នេះជាធម៌របស់អ្នកសន្ដោស នេះមិនមែនជាធម៌របស់អ្នកមិនសន្ដោស នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរ ក្នុងការប្រឡូកប្រឡំដោយពួក នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតី នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញា ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត របស់ព្រះអនុរុទ្ធដ៏មានអាយុ ដោយព្រះហឫទ័យនៃព្រះអង្គហើយ ក៏បាត់អំពីភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់សត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ស្រាប់តែមកប្រាកដ ក្នុងទីចំពោះមុខនៃព្រះអនុរុទ្ធដ៏មានអាយុ ក្នុងបាចីនវំសទាយវ័ន ក្នុងដែនចេតី ព្រះអង្គទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ដូចជាបុរសមានកម្លាំង លានូវដៃដែលខ្ជួនបត់ចូល ឬបត់ចូលនូវដៃ ដែលខ្ជួនលាចេញ ដូច្នោះឯង ។ ព្រះអនុរុទ្ធដ៏មានអាយុថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលអនុរុទ្ធ ប្រពៃហើយៗ ម្នាលអនុរុទ្ធ អ្នកបានត្រិះរិះ នូវមហា-

បុរិសវិតក្កប្រពៃហើយថា នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើន នេះជាធម៌របស់អ្នកសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនសន្តោស នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរក្នុងការនៅច្រឡូកច្រឡំដោយពួក នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតី នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌ របស់អ្នកឥតប្រាជ្ញា ។ ម្នាលអនុរុទ្ធ បើដូច្នោះ អ្នកត្រិះរិះនូវមហាបុរិសវិតក្កទី ៨ នេះថា នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ គឺព្រះនិព្វាន ជាទីត្រេកអរ អ្នកត្រេកអរក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរក្នុងបបញ្ចធម៌ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងប្រាថ្នាដរាបណា អ្នកនឹងស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុ-សលធម៌ទាំងឡាយ ដល់បឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារៈ មានបីតិនិងសុខ កើតអំពីសេចក្ដីស្ងប់ស្ងាត់ ដរាបនោះ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងប្រាថ្នាដរាបណា ព្រោះរម្ងាប់នូវវិតក្ក និងវិចារៈ អ្នកនឹងដល់នូវទុតិយជ្ឈានជាធម្មជាតកើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធាមាន

សភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ( ដរាបនោះ ) ។ ម្នាលអនុរុទ្ធ កាលណា អ្នកត្រិះរិះនូវមហាបុរិសវិតក្កទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹង ប្រាថ្នាដរាបណា អ្នកនឹងប្រកបដោយឧបេក្ខា ព្រោះមានចិត្តនឿយណាយ ចាកបីតិ មានស្មារតីដឹងខ្លួន សោយនូវសេចក្ដីសុខ ដោយនាមកាយ ព្រះ អរិយៈទាំងឡាយ តែងសរសើរនូវបុគ្គល ដែលបានតតិយជ្ឈាននោះថា បុគ្គល នេះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះ តតិយជ្ឈានណា អ្នកនឹងដល់នូវតតិយជ្ឈាននោះ ( ដរាបនោះ ) ។ ម្នាល អនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងប្រាថ្នា ដរាបណា អ្នកនឹងដល់នូវចតុត្ថជ្ឈាន ជាធម្មជាត មានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺឧបេក្ខា មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង អស់ទៅនៃ សោមនស្ស និងទោមនស្សផង ( ដរាបនោះ ) ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បាន មិនលំបាក បានដោយងាយ នូវឈានទាំង ៤ នេះ ប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាទូសម្រាប់ដាក់ សំពត់ដ៏ពេញដោយសំពត់ទាំងឡាយ ដែលគេជ្រលក់ដោយពណ៌ផ្សេងៗ របស់ គហបតី ឬគហបតិបុត្ត យ៉ាងណាមិញ បំសុកូលចីវរ ក៏នឹងប្រាកដដល់អ្នក

ដែលសន្ដោស ដើម្បីសេចក្ដីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះ ប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាបាយនៃស្រូវសាលីរបស់គហបតី ឬគហបតិបុត្តដែលប្រាសចាកពណ៌ខ្មៅ មានសម្លច្រើនមុខ មានម្ហូបគ្រៀមច្រើនមុខ យ៉ាងណាមិញ ភោជនជាដុំ ជាពំនូតនឹងប្រាកដដល់អ្នកដែលសន្ដោស ដើម្បីសេចក្ដីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាផ្ទះកំពូលរបស់គហបតី ឬគហបតិបុត្ត ដែលគេលាបខាងក្នុងនិងខាងក្រៅ មិនមានខ្យល់ ( ចេញចូល ) មានគន្លឹះដ៏ជិតស្និទ្ធ មានបង្អួចបិទហើយ យ៉ាងណាមិញ រុក្ខមូលសេនាសនៈ ក៏នឹងប្រាកដដល់អ្នកដែលសន្ដោស ដើម្បីសេចក្ដីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បាន

មិនលំបាក បានដោយងាយ នូវឈានទាំង ៤ នេះ ដែលប្រព្រឹត្តទៅក្នុងចិត្ត ដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាបល្ល័ង្ក ( គ្រែដែលមានជើងខ្ពស់វិចិត្រដោយរូបសត្វសាហាវ ) របស់គហបតី ឬគហបតិបុត្ត ដែលក្រាលដោយព្រំ មានរោមវែងជាង ៤ ធ្នាប់ ដែលក្រាលដោយកម្រាលមានពណ៌ស ដែលធ្វើដោយរោមសត្វ ដែលក្រាលដោយកម្រាលធ្វើដោយរោមសត្វជាផ្កាចង្កោម មានកម្រាលដ៏ឧត្តម ដែលគេធ្វើដោយស្បែកសត្វឈ្មុស មានខ្នើយមានពណ៌ក្រហមទាំងពីរខាង គឺខ្នើយក្បាល និងខ្នើយជើង ព្រមទាំងពិតាន មានពណ៌ក្រហមពីខាងលើ យ៉ាងណាមិញ ទីដេក និងទីអង្គុយដែលធ្វើដោយកម្រាលស្មៅ ក៏នឹងប្រាកដដល់អ្នកដែលសន្តោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយ នូវឈានទាំង ៤ នេះ ប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាភេសជ្ជៈផ្សេងៗ គឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅរបស់គហបតី ឬគហបតិបុត្ត យ៉ាងណាមិញ ថ្នាំដែលត្រាំដោយទឹកមូត្រស្អុយ នឹងប្រាកដដល់អ្នកដែលសន្តោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ បើ

ដូច្នោះ អ្នកគប្បីនៅចាំវស្សាតទៅទៀត ក្នុងបាចីនវំសទាយវ័ន ជិតដែនចេតីនេះចុះ ។ ព្រះអនុរុទ្ធដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ទូន្មាន ព្រះអនុរុទ្ធដ៏មានអាយុដោយឱវាទនេះ ហើយក៏បាត់អំពីបាចីនវំសទាយវ័ន ក្នុងដែនចេតី មកប្រាកដក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ពួកសត្វម្រឹគ ជិតក្រុងសុំសុមារគិរៈក្នុងភគ្គជនបទ ព្រះអង្គគង់លើអាសនៈដែលគេក្រាលថ្វាយ ដូចជាបុរសមានកម្លាំងលាដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលាចេញដូច្នោះឯង ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវមហាបុរិសវិតក្ក ៨ យ៉ាងដល់អ្នកទាំង-ឡាយ អ្នកទាំងឡាយចូរស្តាប់នូវពាក្យនោះចុះ ។បេ។ ម្នាលភិក្ខុទាំងឡាយចុះមហាបុរិសវិតក្ក ៨ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើន ១ ម្នាលភិក្ខុទាំង-ឡាយ នេះជាធម៌របស់អ្នកមានសេចក្តីសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនមានសេចក្តីសន្តោស ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរដោយពួក ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រារព្ធសេចក្តីព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតី ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាន

ចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំ ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញា ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ គឺព្រះនិព្វាន ជាទីត្រេកអរ អ្នកត្រេកអរក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរក្នុងបបញ្ចធម៌ ១ ។

ឯពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើនដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះដែលតថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាតិច រមែងមិនប្រាថ្នាថា ពួកជនគប្បីដឹងនូវអាត្មាអញថាជាអ្នកប្រាថ្នាតិច ដូច្នេះ ជាអ្នកមានសេចក្តីសន្តោស រមែងមិនប្រាថ្នាថា ពួកជនគប្បីដឹងនូវអាត្មាអញ ថាជាអ្នកមានសេចក្តីសន្តោស ដូច្នេះ ជាអ្នកស្ងាត់ រមែងមិនប្រាថ្នាថា ពួកជនគប្បីដឹងនូវអាត្មាអញថាជាអ្នកស្ងាត់ដូច្នេះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញ ថាជាអ្នកប្រារព្ធសេចក្តីព្យាយាម ដូច្នេះ ជាអ្នកមានស្មារតីខ្ជាប់ខ្ជួន រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមានស្មារតីខ្ជាប់ខ្ជួន ដូច្នេះ ជាអ្នកមានចិត្តតាំងមាំ រមែងមិនប្រាថ្នាថា ពួកជនគប្បីដឹងនូវអាត្មាអញថាជាអ្នកមានចិត្តតាំងមាំ ដូច្នេះ ជាអ្នកមានប្រាជ្ញា រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញ ថាជាអ្នកមានប្រាជ្ញា ដូច្នេះ ជាអ្នកមាន

និប្បបញ្ចធម៌ ជាទីត្រេកអរ រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញ ថាជាអ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរដូច្នេះ ។ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើន ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានសេចក្ដីសន្ដោស នេះមិនមែនជាធម៌របស់អ្នកមិនមានសេចក្ដីសន្ដោស ដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្ដោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារតាមមាន តាមបាន ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានសេចក្ដីសន្ដោស នេះមិនមែនជាធម៌របស់អ្នកមិនមានសេចក្ដីសន្ដោស ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរ ដោយពួកដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងប់ស្ងាត់នៅមានពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា មហាមាត្យរបស់ព្រះរាជា តិរ្ថិយ និងសាវករបស់តិរ្ថិយ

រមែងចូលទៅរកភិក្ខុនោះ ។ ក្នុងទីនោះ ភិក្ខុមានចិត្តឱនទៅរកវិវេក ឈានទៅរកវិវេក បែរទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាអ្នកធ្វើតាមនូវពាក្យ ដែលប្រកបចំពោះដោយពាក្យ ដែលគួរបញ្ចូនទៅដោយពិត ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌ របស់អ្នកត្រេកអរដោយពួក ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស ដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ ដើម្បីញ៉ាំងពួកអកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំ មិនទម្លាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតីដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំង-

ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងភាព ជាអ្នកមានប្រាជ្ញាចាស់ក្លាដ៏ខ្ពង់ខ្ពស់ នឹកឃើញ រឭកបានរឿយៗ នូវអំពើដែល ធ្វើរួចយូរហើយផង នូវសម្ដីដែលនិយាយរួចយូរហើយផង ពាក្យណាថា ម្នាល ភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់ អ្នកភ្លេចស្មារតីដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោល ហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះ មិនមែនជាធម៌ របស់អ្នកមានចិត្តមិនតាំងមាំ ដូច្នេះនេះ ដែលតថាគតពោល ហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្ដេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ដល់នូវចតុត្ថជ្ឈាន ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់ អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំដូច្នេះ ដែល តថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុ នេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិន មែនជាធម៌របស់អ្នកឥតប្រាជ្ញាដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាដំណើរទៅកាន់

សេចក្តីចម្រើន និងសេចក្តីវិនាស ជាប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងគ្រាស់ដឹង ជាដំណើរទៅកាន់ការអស់ទៅនៃទុក្ខដោយប្រពៃ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញាដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងបបញ្ចធម៌ដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់ភិក្ខុក្នុងសាសនានេះ រមែងស្ទុះទៅ រមែងជ្រះថ្លា រមែងតាំងនៅ រមែងបង្អោនទៅ ក្នុងកិរិយារលត់នៃបបញ្ចធម៌ គឺព្រះនិព្វាន ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងបបញ្ចធម៌ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ ក៏នៅចាំវស្សាតទៅ ក្នុងបាចីនវំសទាយវ័ន ក្នុងដែនចេតីនោះឯង ។ លំដាប់នោះ ព្រះអនុរុទ្ធដ៏មានអាយុតែម្នាក់ឯង ចៀសចេញចាកពួក មិនមានសេចក្តីប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះបួលកាន់ផ្នួសដោយ

ប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌ ដែលមានព្រហ្មចរិយៈជាទីបំផុតនោះ ដោយបញ្ញាដ៏ឧត្តមរបស់ខ្លួនក្នុងបច្ចុប្បន្ន ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅរួចហើយ សោឡសកិច្ច បានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះ មិនមានទៀតឡើយ មានសេចក្ដីសរសើរថា បណ្ដាព្រះអរហន្តទាំងឡាយ ព្រះអនុរុទ្ធដ៏មានអាយុ ជាព្រះអរហន្តមួយអង្គដែរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុ បានដល់ព្រះអរហត្តហើយ បានពោលគាថាទាំងឡាយនេះ ក្នុងវេលានោះថា

ព្រះសាស្ដា ជាបុគ្គលប្រសើរក្នុងលោក ព្រះអង្គទ្រង់
ជ្រាបច្បាស់នូវសេចក្ដីត្រិះរិះ របស់អាត្មាអញ ទ្រង់មាន
កាយសម្រេចដោយចិត្ត ទ្រង់ស្ដេចចូលមក ដោយឫទ្ធិ
តម្រិះរបស់អាត្មាអញ កើតមានយ៉ាងណា ព្រះអង្គក៏
ទ្រង់សម្ដែងនូវធម៌ដ៏លើសលុបយ៉ាងនោះ ព្រះពុទ្ធទ្រង់
ត្រេកអរក្នុងនិប្បបញ្ចធម៌ ក៏ទ្រង់សម្ដែងនូវនិប្បបញ្ចធម៌
អាត្មាអញបានដឹងច្បាស់នូវធម៌ របស់ព្រះអង្គ ក៏ត្រេកអរ
ក្នុងសាសនា វិជ្ជាទាំង ៣ អាត្មាអញក៏បានសម្រេចហើយ
សាសនារបស់ព្រះពុទ្ធ អាត្មាអញក៏បានធ្វើហើយ ។

**គហបតិវគ្គទី ៣ ចប់**

### *ឧទ្ទាននៃគហបតិវគ្គនោះ គឺ*

*និយាយអំពីឧគ្គគហបតី ពីរលើក ហត្ថកអាឡវក ពីរលើក សក្កមហានាម ១ ជីវកកោមារភច្ច ១ កម្លាំងពីរលើក អក្ខណៈ ១ ជាគម្រប់ ១០ និងព្រះអនុរុទ្ធ ។*

## អដ្ឋកថា

## អនុរុទ្ធសូត្រទី ១០

[ ៣០ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងអនុរុទ្ធសូត្រទី ១០ ដូចតទៅនេះ បទថា* **ចេតីសុ** *សេចក្ដីថា ក្នុងរដ្ឋដែលមានឈ្មោះយ៉ាងនោះ ព្រោះរដ្ឋនោះ ជាទីប្រថាប់នៅនៃស្ដេចទាំងឡាយ ឈ្មោះថា ចេតី ។ បទថា* **ចាចីនវំសទាយេ** *សេចក្ដីថា ត្រង់ព្រៃវង្សទាយ ដែលតាំងនៅទិសខាងកើត អំពីទីប្រថាប់របស់ព្រះទសពល ដែលជាដងព្រៃដេរដាសទៅដោយដើមឫស្សីមានពណ៌ខៀវ ។*

*បទថា* **ឯវំ ចេតសោ បរិវិតក្កោ ឧទចាទិ** *សេចក្ដីថា បានឮថា ព្រះថេរៈបួសហើយ ជាអ្នកបានសមាបត្តិខាងក្នុងវស្សាមុនគេបង្អស់ ឲ្យកើតទិព្វចក្ខុដែលអាចឲ្យឃើញលោកធាតុទាំង ១០០០ បាន លោកបានទៅកាន់សម្នាក់នៃព្រះសារីបុត្រ ហើយពោលយ៉ាងនេះថា លោកម្ចាស់សារីបុត្រ ក្នុងទីនេះ ខ្ញុំឃើញលោកធាតុ ១០០០ ដោយទិព្វចក្ខុដ៏បរិសុទ្ធកន្លងបង់ចក្ខុ*

មនុស្ស ។ សេចក្តីព្យាយាមខ្ញុំប្រារព្ធហើយ មិនធូរថយ សតិខ្ញុំតាំងមាំហើយ មិនភ្លេចភ្លាំងកាយ ស្ងប់មិនក្រវល់ក្រវាយ ចិត្តតាំងមាំ មានអារម្មណ៍ ១ កាលបើដូច្នោះ ចិត្តរបស់ខ្ញុំមិនទាន់រួចផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំនេះ ។ គ្រានោះ ព្រះសារីបុត្រពោលនឹងលោកថា អាវុសោអនុរុទ្ធ ការគិតឯណាមានដល់លោកយ៉ាងនេះថា ខ្ញុំមើលឃើញ ។បេ។ ដោយទិព្វចក្ខុ ដូច្នេះ ការគិតរបស់លោកនេះ ជាមានះ អាវុសោអនុរុទ្ធ ការគិតណារបស់លោក ដែលមានយ៉ាងនេះថា សេចក្តីព្យាយាមដែលខ្ញុំប្រារព្ធហើយ ។បេ។ មានអារម្មណ៍តែមួយ ការគិតនេះរបស់លោកជាឧទ្ធច្ចៈ ការគិតណារបស់លោក ដែលមានយ៉ាងនេះថា កាលបើដូច្នោះ ចិត្តរបស់ខ្ញុំមិនទាន់រួចផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ការគិតរបស់លោក ក៏ជាកុក្កុច្ចៈ សាធុ អាវុសោអនុរុទ្ធ លោកចូរលះធម៌ ៣ ប្រការនេះចេញ កុំដាក់ចិត្តក្នុងធម៌ ៣ ប្រការនេះ បង្អោនចិត្តចូលទៅដើម្បីអមតធាតុ ដូច្នេះ ព្រះថេរៈប្រាប់កម្មដ្ឋានដល់ព្រះអនុរុទ្ធ ដោយប្រការដូច្នេះ ព្រះអនុរុទ្ធទទួលកម្មដ្ឋានហើយ ទូលលាព្រះសាស្តា ទៅកាន់ចេតិយរដ្ឋ ធ្វើសមណធម៌ ឈប់បង្អង់ដោយការចង្រ្កមអស់កាលកន្លះខែ លោកលំបាកកាយ ព្រោះកម្លាំងនៃសេចក្តីព្យាយាម អង្គុយខាងក្រោមគុម្ពឫស្សីមួយ ។ បទថា **អថស្សាយំ ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ** សេចក្តីថា មហាបុរិសវិតក្កនេះកើតឡើង ។

បទថា **អប្បិច្ឆស្ស** នេះ មានវិនិច្ឆ័យដូចតទៅនេះថា បុគ្គលដែលប្រាថ្នា

តិច ៤ ពួក គឺប្រាថ្នាតិចក្នុងបច្ច័យ ប្រាថ្នាតិចក្នុងអធិគម ប្រាថ្នាតិចក្នុងបរិយត្តិ ប្រាថ្នាតិចក្នុងធុតង្គ ក្នុងបណ្តាអ្នកប្រាថ្នាតិច ៤ ពួកនោះ ភិក្ខុដែលប្រាថ្នាតិចក្នុងបច្ច័យ កាលគេឲ្យច្រើន រមែងទទួលតែបន្តិច ឬកាលគេឲ្យតិច រមែងទទួលកាន់តែតិច មិនរឹតយកដរាបដល់អស់ អ្នកប្រាថ្នាតិចក្នុងអធិគម រមែងមិនឲ្យអ្នកដទៃដឹងមគ្គផលដែលខ្លួនសម្រេច ដូចព្រះមជ្ឈន្តិកត្ថេរ ដូច្នោះ អ្នកប្រាថ្នាក្នុងបរិយត្តិ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ក៏មិនប្រាថ្នាឲ្យអ្នកដទៃដឹងនូវភាពដែលខ្លួនជាពហុស្សុត ដូចព្រះសាកេតកត្ថេរ ។ អ្នកប្រាថ្នាតិចក្នុងធុតង្គ រមែងមិនឲ្យអ្នកដទៃដឹងថា ខ្លួនរក្សាធុតង្គ ដូចព្រះថេរៈដែលជាបងប្រុសក្នុងព្រះថេរៈ ២ នាក់បងប្អូន ដូច្នោះ ។ រឿងបានពោលហើយក្នុងវិសុទ្ធិមគ្គ ។

បទថា **អយំ ធម្មោ** សេចក្តីថា ធម៌នេះ គឺលោកុត្តរធម៌ ៩ រមែងកើតដល់បុគ្គល ឈ្មោះថា មានការប្រាថ្នាតិច ព្រោះបិទបាំងគុណ ដែលខ្លួនបានយ៉ាងនេះ និងព្រោះស្គាល់ប្រមាណក្នុងការទទួល មិនកើតដល់បុគ្គលដែលប្រាថ្នាច្រើន ។ ក្នុងបទគ្រប់បទ គប្បីប្រកបសេចក្តីយ៉ាងនេះ ។ បទថា **សន្តុដ្ឋស្ស** បានដល់ សន្តោសដោយសន្តោស ៣ យ៉ាង ក្នុងបច្ច័យ ៤ ។

បទថា **បវិវិត្តស្ស** បានដល់ ដែលស្ងាត់ដោយកាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។ ក្នុងវិវេក ៣ យ៉ាងនោះ ការបន្ទោបង់នូវការច្រឡូកច្រឡំដោយពួកគណៈ ហើយជាអ្នកមានកាយឯក ដោយអំណាចអារព្ភវត្ថុដែលជាគ្រឿងប្រារព្ធព្យាយាម ឈ្មោះថា កាយវិវេក ។ តែកម្មដ្ឋានរមែងមិនសម្រេច

ដោយអាការត្រឹមតែនៅម្នាក់ឯង ព្រោះដូច្នោះ ព្រះយោគីធ្វើបរិកម្មកសិណហើយ ញុំាងសមាបត្តិ ៨ ឲ្យកើតឡើង នេះឈ្មោះថា ចិត្តវិវេក កម្មដ្ឋានរមែងសម្រេចដោយហេតុត្រឹមសមាបត្តិប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះយោគីធ្វើឈានឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយ ហើយសម្រេចអរហត្ត ព្រមដោយបដិសម្ភិទា នេះឈ្មោះថា ឧបធិវិវេក ស្ងាត់ចាកកិលេស ដោយអាការទាំងពួង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា កាយវិវេកសម្រាប់បុគ្គលដែលមានកាយស្ងាត់ ដែលត្រេកអរក្រៃលែងក្នុងនេក្ខម្មៈ ចិត្ត-វិវេកសម្រាប់បុគ្គលដែលមានចិត្តបរិសុទ្ធ ដែលដល់នូវការផូរផង់ហើយយ៉ាងក្រៃលែង និងឧបធិវិវេកសម្រាប់បុគ្គលដែលប្រាសចាកឧបធិក្កិលេស ដល់នូវព្រះនិព្វានដែលប្រាសចាកសង្ខារ ដូច្នេះ ។

បទថា **សង្គណិការាមស្ស** បានដល់ ដែលត្រេកអរដោយការប្រឡូកប្រឡុំក្នុងពួក និងប្រឡូកប្រឡំដោយកិលេស ។ បទថា **អារទ្ធវីរិយស្ស** បានដល់ ដែលប្រារព្ធសេចក្តីព្យាយាម ដោយអំណាចសេចក្តីព្យាយាមតាមកាយនិងចិត្ត ។ បទថា **ឧបដ្ឋិតស្សតិស្ស** បានដល់ ដែលមានសតិតាំងមាំដោយអំណាចសតិប្បដ្ឋាន ៤ ។ បទថា **សមាហិតស្ស** បានដល់ បុគ្គលមានចិត្តមានអារម្មណ៍តែ ១ ។ បទថា **បញ្ញវតោ** បានដល់ ដែលមានបញ្ញា ដោយបញ្ញាជាហេតុដឹងថា សត្វមានកម្មជារបស់ខ្លួន ។ បទថា **សាធុ សាធុ** សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់ញុំាងចិត្តនៃព្រះថេរៈឲ្យអង់អាច ឲ្យក្លៀវក្លា

ទើបត្រាស់យ៉ាងនេះ ។ បទថា **ឥមំ អដ្ឋមំ** សេចក្តីថា កាលត្រាស់ប្រាប់មហាបុរិសវិតក្កទី ៨ ដល់ព្រះអនុរុទ្ធ ដែលត្រិះរិះមហាបុរិសវិតក្ក ៧ ប្រការទើបត្រាស់យ៉ាងនោះ ដូចឲ្យកំណាប់ទ្រព្យទី ៨ ដល់បុរសដែលបានកំណាប់ទ្រព្យ ៧ និងដូចឲ្យកំណាប់ទ្រព្យទី ៨ ដល់បុរសដែលបានកែវមណី ៧ ហត្ថីរតនៈ ៧ អស្សរតនៈ ៧ ដូច្នោះ ។ បទថា **និប្បបញ្ចារាមស្ស** សេចក្តីថា បុគ្គលដែលត្រេកអរក្រៃលែងក្នុងបទ គឺព្រះនិព្វាន ពោល គឺធម៌ដែលប្រាសចាកការយឺតយូរ ព្រោះវៀរចាកធម៌ជាគ្រឿងយឺតយូរ គឺតណ្ហា មានះ និងទិដ្ឋិ ។ ពាក្យក្រៅអំពីនេះ ជាវេវចនៈនៃបទថា **និប្បបញ្ចារាមស្ស** នោះឯង ។ បទថា **បបញ្ចារាមស្ស** បានដល់ ដែលត្រេកអរក្រៃលែង ក្នុងធម៌ជាគ្រឿងយឺតយូរតាមដែលពោលហើយ ។ ពាក្យក្រៅអំពីនេះ ជាវេវចនៈនៃបទថា **បបញ្ចារាមស្ស** នោះឯង ។

បទថា **យតោ** ប្រែថា ក្នុងកាលណា ។ បទថា **តតោ** ប្រែថា ក្នុងកាលនោះ ។ បទថា **នានារត្តានំ** សេចក្តីថា ជ្រលក់ហើយដោយគ្រឿងជ្រលក់ផ្សេងៗ មានពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម និងពណ៌សជាដើម ។ បទថា **បំសុកូលចីវរំ** បានដល់ សំពត់បង្សុកូលដែលតាំងនៅក្នុងខេត្ត ២៣ ។ បទថា **ខាយិស្សតិ** សេចក្តីថា កាលគហបតីនោះដណ្តប់សំពត់ដែលខ្ចីនប្រាជ្ញាក្នុងសម័យ មានពេលព្រឹកជាដើម ហិបដាក់សំពត់នោះរមែងប្រាកដជារបស់គួរពេញចិត្ត យ៉ាងណា កាលលោកត្រេកអរ ដោយ

មហាអរិយវង្ស គឺសន្តោសដោយចីវរ សំពត់បង្សុកូលចីវរ នឹងប្រាកដ គឺនឹងចូលទៅប្រាកដ ដូច្នោះ ។ បទថា **រតិយា** ប្រែថា ដើម្បីជាប្រយោជន៍ដល់ការត្រេកអរ ។ បទថា **អបរិតស្សាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការមិនតក់ស្លុត ព្រោះតណ្ហា និងទិដ្ឋិ ។ បទថា **ផាសុវិហារាយ** បានដល់ ដើម្បីការនៅជាសុខ ។ បទថា **ឱក្កមនាយ និព្វានស្ស** បានដល់ ដើម្បីឈមចុះកាន់អមតមហានិព្វាន ។

បទថា **បិណ្ឌិយាលោបភោជនំ** បានដល់ ភោជន គឺបាយដែលខ្លួនអាស្រ័យកម្លាំងស្នែង ត្រាច់ទៅតាមលំដាប់ផ្ទះ ក្នុងគាម និគម និងរាជធានីបានមក ។ បទថា **ខាយិស្សតិ** សេចក្តីថា នឹងប្រាកដ ដូចភោជនមានរសដ៏លើសផ្សេងៗ របស់គហបតីនោះ ។ បទថា **សន្តុដ្ឋស្ស វិហរតោ** សេចក្តីថា បុគ្គលសន្តោសនៅដោយមហាអរិយវង្ស គឺការសន្តោសដោយបិណ្ឌបាត ។ បទថា **រុក្ខមូលសេនាសនំ ខាយិស្សតិ** សេចក្តីថា សេនាសនៈ គឺគល់ឈើរមែងប្រាកដ ដូចផ្ទះកំពូលដ៏ក្រអូបឈ្ងុយឈ្ងប់ទៅដោយធូមគន្ធ និងគ្រឿងអប់ មានផ្កាជាដើម លើប្រាសាទ ៣ ជាន់របស់គហបតីនោះ ។ បទថា **សន្តុដ្ឋស្ស** បានដល់ សន្តោសដោយមហាអរិយវង្ស គឺសន្តោសដោយសេនាសនៈ ។ បទថា **តិណសន្ថរកោ** បានដល់ កម្រាលដែលក្រាលដោយស្មៅ ឬស្លឹកឈើត្រង់ផែនដី ឬត្រង់បន្ទះក្តារ និងផ្ទាំងថ្មណាមួយ ។ បទថា **បូតិមុត្តំ** សេចក្តីថា ទឹកមូត្រណាមួយដែលកាន់យកក្នុងខណៈនោះ

លោកក៏ហៅថា ទឹកមូត្រស្អុយដូចគ្នា ព្រោះមានក្លិនស្អុយ ។ បទថា **សន្តុដ្ឋស្ស វិហារតោ** បានដល់ ដែលសន្តោសដោយគិលានប្បច្ចយភេសជ្ជ-បរិក្ខារ ។ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ត្រាស់កម្មដ្ឋានទុកក្នុងអរហត្ត ក្នុងឋានៈ ៤ កាលទ្រង់រំពឹងថា កម្មដ្ឋានជាសប្បាយដល់អនុរុទ្ធដែលនៅក្នុងសេនាសនៈណាហ្ន៎ ទ្រង់ជ្រាបថា នៅក្នុងទីនោះឯង ទើបត្រាស់ពាក្យជាដើមថា **តេនហិ ត្វំ អនុរុទ្ធ** ដូច្នេះ ។

បទថា **បវិវិត្តស្ស វិហារតោ** សេចក្តីថា អ្នកស្ងាត់ដោយវិវេក ៣ ។ បទថា **ឧយ្យោជនិកប្បដិសំយុត្តំ** សេចក្តីថា ដែលទាក់ទងដោយវាចាសមគួរដល់ការត្រឡប់បញ្ជូនទៅ ។ អធិប្បាយថា កិរិយាដែលក្រោកឡើង និងកិរិយាដែលដើរទៅរបស់ខ្ជួនទាំងនោះៗ ឯង ។ បទថា **បបញ្ចនិរោធេ** បានដល់ ក្នុងបទ គឺព្រះនិព្វាន ។ បទថា **បក្ខន្ទតិ** សេចក្តីថា រមែងស្ទុះទៅដោយអំណាចនៃការធ្វើឲ្យជាអារម្មណ៍ ។ ក្នុងបទថា **បសីទតិ** ជាដើម គប្បីជ្រាបសេចក្តីជ្រះថ្លា ការតាំងមាំ និងការរួចផុតដោយអំណាចនៃអារម្មណ៍នោះឯង ដូច្នោះ ព្រះមានព្រះភាគ កាលត្រាស់មហាបុរិសវិតក្ក ៨ ដល់ព្រះអនុរុទ្ធក្នុងបាចីនវំសទាយវ័ន ក្នុងចេតិយរដ្ឋ ប្រថាប់គង់ត្រង់ភេសកឡាវ័នមហាវិហារ ទើបត្រាស់ដោយពិស្តារដល់ភិក្ខុសង្ឃទៀត ។

បទថា **មនោមយេន** សេចក្តីថា កាយដែលកើតឡើងដោយចិត្តក្តី ដែលទៅដោយចិត្តក្តី ហៅថា **មនោមយ** គឺសម្រេចដោយចិត្ត ។ តែក្នុងទីនេះ

ទ្រង់សំដៅយកកាយដែលទៅដោយចិត្ត ទើបត្រាស់យ៉ាងនេះ ។ បទថា **យថា មេ អហុ សង្កប្បោ** សេចក្តីថា តថាគតមានសេចក្តីត្រិះរិះ ដោយប្រការណា ។ បទថា **តតោ ឧត្តរិ** សេចក្តីថា ព្រះសាស្តាកាលទ្រង់សម្តែងមហាបុរិសវិតក្ក ៨ ប្រការ ទើបសម្តែងឲ្យក្រៃលែងជាងនេះ ។ ពាក្យដ៏សេសទាំងអស់ មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាអនុរុទ្ធសូត្រទី ១០ ចប់**
**គហបតិវគ្គទី ៣ ចប់**

# សុត្តន្តបិដក

## ទានវគ្គ

### បឋមទានសូត្រទី ១

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ ទាននេះមាន ៨ យ៉ាង ។ ទាន ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យទាន ព្រោះបានចាត់ចែងទុកស្រេច ១ ឲ្យទាន ព្រោះភ័យ ១ ឲ្យទានដោយគិតថា គេបានឲ្យដល់អញ ១ ឲ្យទានដោយគិតថា គេនឹងឲ្យដល់អញវិញ ១ ឲ្យទានដោយគិតថា ទានជាការប្រពៃ ១ ឲ្យទានដោយគិតថា អញចម្អិន បុគ្គលទាំងឡាយនេះ មិនទាន់ចម្អិន អញកាលចម្អិន មិនគួរដើម្បីមិនឲ្យទានដល់បុគ្គលមិនទាន់ចម្អិន ១ ឲ្យទាន ដោយគិតថា កាលបើអញឲ្យនូវទាននេះ កិត្តិសព្ទដ៏ពីរោះ រមែងខ្ចរខ្ចាយទៅ ១ ឲ្យទានដើម្បីជាគ្រឿងប្រដាប់នៃចិត្ត និងជាបរិក្ខារនៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ទានមាន ៨ យ៉ាងនេះឯង ។

# អដ្ឋកថា
# ទានវគ្គទី ៤

## បឋមទានសូត្រ

[ ៣១ ] គប្បីជ្រាបវិនិច្ឆ័យបឋមទានសូត្រក្នុងទី ១ នៃទានវគ្គទី ៤ ដូចតទៅនេះ បទថា **អាសជ្ជ ទានំ ទេតិ** សេចក្តីថា បុគ្គលពួកខ្លះឲ្យទាន ព្រោះជួប គឺគ្រាន់តែឃើញបដិគ្គាហកមកដល់ និមន្តឲ្យគង់មួយស្របក់ ធ្វើសក្ការៈ ហើយទើបឲ្យទាន រមែងមិនលំបាកចិត្តថា នឹងឲ្យ ។ បទថា **ភយា** បានដល់ ព្រោះខ្លាចនិន្ទាកើតឡើងថា បុគ្គលនេះជាអ្នកមិនឲ្យ ជាអ្នកមិនធ្វើ ឬព្រោះខ្លាចអបាយភូមិ ។ បទថា **អទាសិ មេ** សេចក្តីថា ឲ្យដោយគិតថា បុគ្គលនេះបានឲ្យវត្ថុឈ្មោះនេះដល់អញក្នុងកាលមុន ។ បទថា **ទស្សតិ មេ** សេចក្តីថា ឲ្យដោយគិតថា បុគ្គលនេះនឹងឲ្យវត្ថុឈ្មោះនេះ ដល់អញក្នុងអនាគត ។ បទថា **សាហុ ទានំ** សេចក្តីថា ឲ្យដោយគិតថា ឈ្មោះថាទាន ញុំាងនូវប្រយោជន៍ឲ្យសម្រេច គឺល្អ បានដល់ បណ្ឌិត មានព្រះពុទ្ធជាដើមសរសើរហើយ ។ បទថា **ចិត្តាលង្ការចិត្តបរិក្ខារត្ថំ ទានំ ទេតិ** សេចក្តីថា ឲ្យដើម្បីប្រដាប់ និងតាក់តែងចិត្ត ក្នុងសមថៈ និងវិបស្សនា ។ ព្រោះថា ទាន រមែងធ្វើចិត្តឲ្យទន់ភ្លន់ បុគ្គលបានទទួលទាន រមែងមានចិត្តទន់ភ្លន់ថា អញបានហើយ បុគ្គលដែលឲ្យទាននោះ ក៏រមែងមានចិត្តទន់ភ្លន់ថា អញឲ្យទានហើយ ព្រោះដូច្នោះ ទាននោះ ឈ្មោះថា រមែងធ្វើចិត្តរបស់បុគ្គល

ទាំង ២ ចំណែកឲ្យទន់ភ្លន់ ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ថា **អទន្ត-ទមនំ** ប្រែថា ការទូន្មានចិត្តដែលមិនទាន់បានទូន្មាន ដូចព្រះមានព្រះភាគត្រាស់ទុកថា

**អទន្តទមនំ ទានំ អទានំ ទន្តទូសកំ**
**អទេន បិយវាចេន ឱណមន្តិ នមន្តិ ច ។**

ការឲ្យទាន ជាគ្រឿងទូន្មានចិត្ត ដែលមិនទាន់បានទូន្មាន
ការមិនឲ្យទាន ជាគ្រឿងប្រទូស្តចិត្ត ដែលទូន្មានហើយ ជន
ទាំងឡាយមានចិត្តទន់ភ្លន់ និងទោរទន់ដោយបិយវាចានេះ ។

បណ្តាការឲ្យទាន ៨ ប្រការនេះ ការឲ្យដើម្បីប្រដាប់ចិត្តប៉ុណ្ណោះប្រសើរជាងគេ ។ល។

**អដ្ឋកថាបឋមទានសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយទានសូត្រទី ២

[ ៣២ ] សទ្ធាទាន ហិរិទាន កុសលទាន ធម៌ទាំងនេះ
ជាធម៌តាំងនៅក្នុងពួកសប្បុរស សប្បុរសទាំងឡាយ

តែងពោលនូវធម៌នេះ ថាជាផ្លូវទៅកាន់ទេវលោក ព្រោះថា បុគ្គលតែងទៅកាន់ទេវលោកបានដោយធម៌នេះ ។

# អដ្ឋកថា

## ទុតិយទានសូត្រ

[ ៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយទានសូត្រទី ២ ដូចតទៅនេះ បុគ្គលរមែងឲ្យទានដោយសទ្ធាណា សទ្ធានោះលោកបំណងថា សទ្ធា ។ បុគ្គលរមែងឲ្យទានដោយហិរិណា ហិរិនោះ លោកបំណងយកថា ហិរិ ។ បទថា **កុសលញ្ច ទានំ** បានដល់ ទានដែលមិនមានទោស ។ បទថា **ទិវិយំ** បានដល់ ជាផ្លូវទៅកាន់ស្ថានសួគ៌ ។ល។

**អដ្ឋកថា ទុតិយទានសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ទានវត្ថុសូត្រទី ៣

[ ៣៣ ] ម្នាលភិក្ខុទាំងឡាយ ទានវត្ថុនេះមាន ៨ យ៉ាង ។ ទានវត្ថុ ៨

យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យទាន ព្រោះសេចក្តីស្រឡាញ់ ១ ឲ្យទានព្រោះសេចក្តីខឹង ១ ឲ្យទានព្រោះសេចក្តីល្ងង់ ១ ឲ្យទានព្រោះសេចក្តីភ័យ ១ ឲ្យទានព្រោះគិតថា ជីដូនជីតាទាំងឡាយ ( របស់អញ ) ធ្លាប់ឲ្យ ធ្លាប់ធ្វើមក អញមិនគួរញុំាងវង្សត្រកូលពីបុរាណនុ៎ះឲ្យវិនាស ១ ឲ្យទានព្រោះគិតថា អញបានឲ្យទាននេះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ១ ឲ្យទានព្រោះគិតថា កាលអញឲ្យទាននេះ ចិត្តរមែងជ្រះថ្លា ទាំងសេចក្តីពេញចិត្ត និងសោមនស្ស ក៏រមែងកើតឡើង ១ ឲ្យទានដើម្បីជាគ្រឿងប្រដាប់នៃចិត្ត និងជាបរិក្ខារនៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ទានវត្ថុមាន ៨ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទានវត្ថុសូត្រ

[ ៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទានវត្ថុសូត្រទី ៣ ដូចតទៅនេះ បទថា **ទានវត្ថូនិ** បានដល់ ហេតុនៃការឲ្យទាន ។ បទថា **ឆន្ទា ទានំ ទេតិ** សេចក្តីថា បុគ្គលឲ្យទាន ព្រោះសេចក្តីស្រឡាញ់ ។ បទថា **ទោសា** សេចក្តីថា ជាអ្នកក្រោធហើយ វត្ថុណាមាន ប្រញាប់យកវត្ថុនោះឲ្យទៅព្រោះទោសៈ ។ បទថា **មោហា** សេចក្តីថា ជាអ្នកវង្វេង ឲ្យទៅ ព្រោះ

មោហៈ ។ បទថា **ភយា** សេចក្ដីថា ព្រោះខ្លាចនូវពាក្យនិន្ទា ឬព្រោះខ្លាចអបាយភូមិ ឬថា ព្រោះខ្លាចនូវពាក្យនិន្ទា និងអបាយភូមិនោះឯង ទើបឲ្យ ។ បទថា **កុលវំសំ** បានដល់ ជាប្រពៃណីរបស់ត្រកូល ។l៙ssss

អដ្ឋកថា ទានវត្ថុសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ខេត្តសូត្រទី ៨

[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ ពូជដែលបុគ្គលសាបព្រោះក្នុងស្រែ ប្រកបដោយអង្គ ៨ ជាពូជមិនមានផលច្រើន មិនមានសេចក្ដីត្រេកអរច្រើន មិនចម្រើន ។ ស្រែប្រកបដោយអង្គ ៨ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ស្រែក្នុងលោកនេះ ជាស្រែមានទីទួលខ្ពស់ ទីទំនាបខ្ពស់ ១ មានថ្ម និងក្រួស ១ មានទឹកប្រៃ ១ គន្លងនង្គ័លមិនជ្រៅ ១ មិនបរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចូល ១ មិនបរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចេញ ១ មិនបរិបូណ៌ដោយប្រឡាយទឹក ១ មិនបរិបូណ៌ដោយភ្លឺ ១ ។ ម្នាលភិក្ខុទាំងឡាយ ពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ យ៉ាងនេះ ជាពូជមិនមានផលច្រើន មិនមានសេចក្ដីត្រេកអរច្រើន មិនចម្រើនទេ ។ ម្នាលភិក្ខុទាំងឡាយ ទានដែល

បុគ្គលឲ្យ ចំពោះពួកសមណព្រាហ្មណ៍ ដែលប្រកបដោយអង្គ ៨ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយទៅច្រើន ក៏យ៉ាងនោះដែរ ។ សមណព្រាហ្មណ៍ ដែលប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ ក្នុងលោកនេះ ជាអ្នកយល់ឃើញខុស ១ ត្រិះរិះខុស ១ និយាយខុស ១ ធ្វើការងារខុស ១ ចិញ្ចឹមជីវិតខុស ១ ព្យាយាមខុស ១ នឹករឭកខុស ១ តាំងចិត្តខុស ១ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យ ចំពោះសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ យ៉ាងនេះ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយទៅច្រើន ។

ម្នាលភិក្ខុទាំងឡាយ ចំណែកខាងពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ ទើបជាពូជមានផលច្រើន មានសេចក្តីត្រេកអរច្រើន មានសេចក្តីចម្រើន ។ ស្រែប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ស្រែក្នុងលោកនេះ មិនមានទីទួលខ្ពស់ ឬទីទំនាបខ្លះ ១ មិនមានថ្ម និងក្រួស ១ មិនមានទឹកប្រៃ ១ មានគន្លងនង្គ័លជ្រៅ ១ បរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចូល ១ បរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចេញ ១ បរិបូណ៌ដោយប្រឡាយទឹក ១ បរិបូណ៌ដោយភ្លឺ ១ ។ ម្នាលភិក្ខុទាំងឡាយ ពូជដែលបុគ្គលសាបព្រោះក្នុងស្រែប្រកបដោយអង្គ ៨ យ៉ាងនេះ ជាពូជមានផលច្រើន មានសេចក្តីត្រេកអរច្រើន មានសេចក្តីចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ទាន

ដែលបុគ្គលឲ្យហើយ ចំពោះសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ ជាទានមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ក៏យ៉ាងនោះដែរ ។ សមណព្រាហ្មណ៍ប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ ក្នុងលោកនេះ ជាអ្នកយល់ឃើញត្រូវ ១ ត្រិះរិះត្រូវ ១ និយាយត្រូវ ១ ធ្វើការងារត្រូវ ១ ចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ នឹករឭកត្រូវ ១ តាំងចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យហើយ ចំពោះពួកសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ យ៉ាងនេះ ទើបជាទានមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។

ពូជដ៏បរិបូណ៌ ដែលគេសាបព្រោះ ក្នុងស្រែដ៏ល្អ កាលបើមានភ្លៀងស្រួល ការបរិបូណ៌ ដោយគ្រាប់ស្រូវ ក៏រមែងមាន គឺបរិបូណ៌ដោយការមិនអន្តរាយ ១ ការចម្រើនឡើងបរិបូណ៌ ១ ការលូតលាស់បរិបូណ៌ ១ ផ្លែហ្នឹងឯងបរិបូណ៌ ១ មានឧបមាយ៉ាងណាមិញ ។ ភោជនដ៏បរិបូណ៌ដែលបុគ្គលឲ្យហើយ ចំពោះពួកបុគ្គលមានសីលបរិបូណ៌ រមែងញុំាងចំណែកកុសលឲ្យកើតឡើង កុសលកម្មដែលបុគ្គលនោះធ្វើហើយ ឈ្មោះថា កម្មដ៏

បរិបូណ៌ មានឧបមេយ្យយ៉ាងនោះដែរ ព្រោះហេតុនោះ បុគ្គលក្នុងលោកនេះ ជាអ្នកបរិបូណ៌ មានប្រាថ្នានូវសេចក្តីបរិបូណ៌ គួរសេពគប់នូវបុគ្គល ដែលមានបញ្ញាដ៏បរិបូណ៌ ការបរិបូណ៌រមែងសម្រេច យ៉ាងនេះឯង ។ បុគ្គលអ្នកបរិបូណ៌ដោយវិជ្ជា និងចរណៈ បាននូវសេចក្តីបរិបូណ៌នៃចិត្ត រមែងធ្វើនូវកម្មដ៏បរិបូណ៌ផង បាននូវប្រយោជន៍ក៏បរិបូណ៌ ។ បុគ្គលដឹងច្បាស់នូវសត្វលោកតាមសេចក្តីពិត រមែងសម្រេចនូវវិបស្សនាសម្មាទិដ្ឋិដ៏បរិបូណ៌ បុគ្គលអាស្រ័យនូវមគ្គដ៏បរិបូណ៌ មានចិត្តដ៏បរិបូណ៌ រមែងដល់នូវ ( ព្រះអរហត្ត ) ។ បុគ្គលកម្ចាត់បង់នូវមន្ទិលទាំងពួង ដល់នូវព្រះនិព្វានដ៏បរិបូណ៌ រមែងរួចចាកទុក្ខទាំងពួង ការរួចចាកទុក្ខនោះឯង ទើបឈ្មោះថា សេចក្តីបរិបូណ៌គ្រប់យ៉ាង ។

# អដ្ឋកថា

## ខេត្តសូត្រ

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងខេត្តសូត្រទី ៤ ដូចតទៅនេះ បទថា **ន មហប្ផលំ ហោតិ** សេចក្តីថា មិនមានផលច្រើន ដោយផលនៃពូជ ។ បទថា **ន មហស្សាទំ** សេចក្តីថា ការត្រេកអរចំពោះផលនៃពូជនោះ មិនមានច្រើន គឺមានការត្រេកអរតិច មិនច្ងាញ់ ។ បទថា **ន ផាតិសេយ្យំ** សេចក្តីថា ពូជនោះ រមែងមិនដុះដាល អធិប្បាយថា ពូជនោះ នឹងចម្រើន គឺមានដើមធំធាត់ល្អក៏មិនមែន ។ បទថា **ឧន្នាមិនិន្នាមិ** បានដល់ ដីដែលមិនស្មើ ព្រោះទួល និងទំនាប ។ ក្នុងទីទាំងនោះ ទីទួលមិនមានទឹកដក់ ទីទាបមានទឹកដក់ច្រើនពេក ។ បទថា **បាសាណសក្ខរិលំ** សេចក្តីថា ប្រកបដោយថ្មតាំងនៅ និងក្រួសតូចធំ ។ បទថា "**សរំ** បានដល់ ទឹកប្រៃ ។ បទថា **ន ច គម្ភីរសិតំ** សេចក្តីថា មិនអាចភ្ជួរឲ្យនង្គ័លមុតជ្រៅបាន ព្រោះដីរឹង នង្គ័លក៏មុតរាក់ៗ ប៉ុណ្ណោះ ។ បទថា **ន អាយសម្បន្នំ** បានដល់ មិនសម្បូរដោយផ្លូវទឹក ហូរចេញទៅតាមក្រោយ ។ បទថា **ន មាតិកាសម្បន្នំ** សេចក្តីថា មិនសម្បូរដោយប្រឡាយតូចធំ ។ បទថា **ន មរិយាទសម្បន្នំ** សេចក្តីថា មិនសម្បូរដោយភ្លឺស្រែ ។ បទទាំងអស់មាន បទថា **ន មហប្ផលំ** ជាដើម គប្បីជ្រាបដោយអំណាចការឲ្យផលនោះឯង ។

បទថា **សម្បន្នេ** បានដល់ បរិបូណ៌ គឺប្រកបដោយគុណសម្បត្តិ ។ បទថា **បវុត្តា ពីជសម្បទា** បានដល់ ពូជដែលដាំសម្បូរ ។ បទថា **ទេវេ**

**សម្បាទយន្តម្ហិ** សេចក្តីថា កាលភ្លៀងធ្លាក់ត្រូវតាមរដូវកាល ។ បទថា **អធីតិសម្បទា ហោតិ** សេចក្តីថា ការមិនមានភ័យអំពីសត្វល្អិត មានកណ្តូប និងដង្កូវជាដើម ជាការសម្បូរដ៏ក្រៃលែង ។ បទថា **វិរុឡ្ហិ** សេចក្តីថា ដុះដាល សម្បូរលំដាប់ទី ២ ។ បទថា **វេបុល្លំ** សេចក្តីថា ការបរិបូណ៌ ជាការសម្បូរលំដាប់ទី ៣ ។ បទថា **ផលំ** សេចក្តីថា ផលនៃពូជដែលបរិបូណ៌ ជាការសម្បូរលំដាប់ទី ៤ ។

បទថា **សម្បន្នសីលេសុ** បានដល់ សមណព្រាហ្មណ៍ដែលមានសីលបរិបូណ៌ ។ បទថា **ភោជនសម្បទា** បានដល់ ភោជន ៥ យ៉ាង ដែលសម្បូរ ។ បទថា **សម្បទានំ** បានដល់ កុសលសម្បទា ៣ យ៉ាង ។ បទថា **ឧបនេតិ** បានដល់ ភោជនសម្បទានោះនាំចូលទៅ ។ ព្រោះហេតុអ្វី ព្រោះកិច្ចកម្មដែលបុគ្គលនោះធ្វើហើយសម្បូរ អធិប្បាយថា ព្រោះកិច្ចកម្មដែលបុគ្គលនោះ ធ្វើហើយសម្បូរ គឺបរិបូណ៌ ។ បទថា **សម្បន្នត្ថូធ** កាត់បទជា **សម្បន្នោ អត្ថុ ឥធ** ប្រែថា ចូរជាបុគ្គលសម្បូរក្នុងកុសលសម្បទានេះ ។ បទថា **វិជ្ជាចរណសម្បន្នោ** សេចក្តីថា ប្រកបដោយវិជ្ជា ៣ និងចរណៈ ១៥ ។ បទថា **លទ្ធា** សេចក្តីថា បុគ្គលបែបនេះ បាននូវការសម្បូរ គឺការមិនខ្វះខាត បានដល់ ការបរិបូណ៌នៃចិត្ត ។ បទថា **ករោតិ កម្មសម្បទំ** បានដល់ ធ្វើកម្មឲ្យបរិបូណ៌ ។ បទថា **លភតិ ចត្ថសម្បទំ** បានដល់ ប្រយោជន៍បរិបូណ៌ ។ បទថា **ទិដ្ឋិសម្បទំ** បានដល់ ទិដ្ឋិក្នុង

វិបស្សនា ។ បទថា **មគ្គសម្បទំ** បានដល់ សោតាបត្តិមគ្គ ។ បទថា **យាតិ សម្បន្នមានសោ** សេចក្តីថា ជាបុគ្គលមានចិត្តបរិបូណ៌ដល់អរហត្ត ។ បទថា **សា ហោតិ សព្វសម្បទា** សេចក្តីថា ការរួបផុតចាកទុក្ខទាំងពួងនោះ ឈ្មោះថា ជាការដល់ព្រមគ្រប់យ៉ាង ៕

**អដ្ឋកថា ខេត្តសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ទានូបបត្តិសូត្រទី ៥

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃទាននេះ មាន ៨ យ៉ាង ។ ការកើតឡើងនៃទាន ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទាន គឺបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យនូវវត្ថុណា ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ ឃើញពួកខត្តិយមហាសាលក្តី ព្រាហ្មណមហាសាលក្តី គហបតិ-មហាសាលក្តី ដែលកំពុងឆ្អែតស្កប់ស្កល់ មូលមិត្រ បម្រើដោយកាមគុណទាំង ៥ ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អញលុះបែកធ្លាយ

រាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងខត្តិយមហាសាលក្តី ព្រាហ្មណ-មហាសាលក្តី គហបតិមហាសាលក្តី បុគ្គលនោះ ក៏តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកខត្តិយមហាសាលខ្លះ ព្រាហ្មណមហា-សាលខ្លះ គហបតិមហាសាលខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេចព្រោះចិត្តដ៏បរិសុទ្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ឲ្យទាន គឺបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យវត្ថុណា ក៏ប្រាថ្នាវត្ថុនោះ បុគ្គលនោះ បានឮថា ពួកទេវតាចាតុម្មហារាជិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញ លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ បុគ្គលនោះ តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនចម្រើនគុណធម៌ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ ម្នាលភិក្ខុទាំងឡាយ

តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេច ព្រោះចិត្តបរិសុទ្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ឲ្យទាន គឺបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យវត្ថុណា ក៏ប្រាថ្នាវត្ថុនោះ បុគ្គលនោះបានឮថា ពួកទេវតាតាវត្តិង្ស ។បេ។ ពួកទេវតាយាមៈ ... ពួកទេវតាតុសិត ... ពួកទេវតានិម្មានរតី ... ពួកទេវតាបរនិម្មិតវសវត្តី មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎អាត្មាអញ លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី បុគ្គលនោះ តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅក៏រមែងទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី ម្នាលភិក្ខុទាំងឡាយ តថា-គត ពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្ត របស់បុគ្គលមានសីល រមែងសម្រេច ព្រោះចិត្តបរិសុទ្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ឲ្យទាន គឺបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿង

គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ ប្រទីប ជាទាន ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យវត្ថុណា ក៏ប្រាថ្នាវត្ថុនោះ បុគ្គលនោះបានឮថា ពួកទេវតាព្រហ្មកាយិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញលុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតា ព្រហ្មកាយិកៈ បុគ្គលនោះ តម្កល់ចិត្តនោះ តាំងចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនចម្រើនគុណធម៌ ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាព្រហ្មកាយិកៈ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលទេ ទានចំពោះបុគ្គលប្រាសចាករាគៈ មិនចំពោះបុគ្គលប្រកបដោយរាគៈទេ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេចព្រោះប្រាសចាករាគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃទានមាន ៨ ប្រការនេះឯង ។

# អដ្ឋកថា

## ទានូបបត្តិសូត្រ

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទានូបបត្តិសូត្រទី ៥ ដូចតទៅនេះ បទថា **ទានូបបត្តិយោ** បានដល់ ឧបបត្តិ មានទានជាបច្ច័យ ។ បទថា **បទហតិ** ប្រែថា តាំងទុក ។ បទថា **អធិដ្ឋាតិ** ជាវេវចនៈនៃពាក្យថា **បទហតិ** នោះឯង ។ បទថា **ភាវេតិ** ប្រែថា ឲ្យចម្រើន ។ បទថា **ហីនេធិមុត្តំ** បានដល់ បង្អោនទៅក្នុងចំណែកថោកទាប គឺកាមគុណ ៥ ។ បទថា **ឧត្តរឹ អភាវិតំ** បានដល់ មិនបានអប់រំដើម្បីជាប្រយោជន៍ដល់មគ្គ និងផលជាន់ខ្ពស់ជាងនោះ ។ បទថា **តត្រូបបត្តិយា សំវត្តតិ** សេចក្ដីថា រមែងប្រព្រឹត្តទៅដើម្បីកើតឡើងក្នុងឋានៈដែលខ្លួនប្រាថ្នា ហើយធ្វើកុសល ។

បទថា **វីតរាគស្ស** បានដល់ ដែលដករាគៈដោយមគ្គ ឬដែលសង្កត់រាគៈដោយសមាបត្តិ ។ ពិតហើយ ត្រឹមតែទានប៉ុណ្ណោះមិនអាចនឹងកើតក្នុងព្រហ្មលោកបានឡើយ តែទានរមែងជាគ្រឿងប្រដាប់ហែហមរបស់ចិត្ត ដែលប្រកបដោយសមាធិ និងវិបស្សនា បន្ទាប់អំពីនោះ បុគ្គលដែលមានចិត្តទន់ដោយការឲ្យទាន ចម្រើនព្រហ្មវិហារ កើតក្នុងព្រហ្មលោក ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **វីតរាគស្ស នោ សរាគស្ស** ដូច្នេះ ។

**អដ្ឋកថា ទានូបបត្តិសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## បុញ្ញកិរិយាវត្ថុសូត្រទី ៦

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុនេះ មាន ៣ យ៉ាង ។ បុញ្ញកិរិយាវត្ថុ ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺទានមយបុញ្ញកិរិយាវត្ថុ ( វត្ថុជាទីតាំងនៃការបំពេញបុណ្យសម្រេចអំពីការឲ្យ ) ១ សីលមយបុញ្ញកិរិយាវត្ថុ ( វត្ថុជាទីតាំងនៃការបំពេញបុណ្យសម្រេចអំពីការរក្សាសីល ) ១ ភាវនាមយបុញ្ញកិរិយាវត្ថុ ( វត្ថុជាទីតាំងនៃការបំពេញបុណ្យសម្រេចអំពីការចម្រើន ) ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុ មានប្រមាណតិច ធ្វើសីលមយបុញ្ញកិរិយាវត្ថុ មានប្រមាណតិច ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងត្រកូលមនុស្សថោកទាប ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុ ល្មមប្រមាណ ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ក៏ល្មមប្រមាណ ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងត្រកូលមនុស្សដ៏ខ្ពង់ខ្ពស់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ មហារាជ

ទាំង ៤ អង្គ បានធ្វើទានមយបុញ្ញកិរិយាវត្ថុ ច្រើនក្រៃពេក ធ្វើសីលមយ-បុញ្ញកិរិយាវត្ថុ ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្លងនូវពួកទេវតាចាតុម្មហារាជិកៈ ដោយស្ថាន ១០ យ៉ាង គឺអាយុជាទិព្យ ១ ពណ៌ជាទិព្យ ១ សុខជាទិព្យ ១ យសជាទិព្យ ១ អធិបតីជាទិព្យ ១ រូបជាទិព្យ ១ សំឡេងជាទិព្យ ១ ក្លិនជាទិព្យ ១ រសជាទិព្យ ១ ផោដ្ឋព្វៈជាទិព្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែង ធ្វើសីលមយបុញ្ញ-កិរិយាវត្ថុច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាតាវត្តិង្ស ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សក្កទេវរាជ ជាធំជាងទេវតា បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក ធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្លងទេវតាជាន់តាវត្តិង្ស ដោយស្ថាន ១០ យ៉ាង គឺអាយុជាទិព្យ ១ ។បេ។ ផោដ្ឋព្វៈជាទិព្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញ-កិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាជាន់យាមៈ ។ ម្នាលភិក្ខុទាំង-ឡាយ បណ្តាទេវតាទាំងនោះ សុយាមទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់

កន្ទងនូវពួកទេវតាជាន់យាមៈ ដោយស្ថាន ១០ យ៉ាង គឺអាយុជាទិព្វ ១ ។បេ។ ផោដ្ឋព្វៈជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុ ច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាជាន់តុសិត ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សន្តុសិត-ទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក បានធ្វើសីលមយ-បុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្ទងនូវពួកទេវតា ជាន់តុសិត ដោយស្ថាន ១០ យ៉ាង គឺអាយុជាទិព្វ ១ ។បេ។ ផោដ្ឋព្វៈជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុ ច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែង ប៉ុន្តែភាវនាមយ-បុញ្ញកិរិយាវត្ថុមិនសម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយ នឹងពួកទេវតានិម្មានរតី ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សុនិម្មិតទេវបុត្រ បានធ្វើទានមយបុញ្ញ-កិរិយាវត្ថុដ៏ច្រើនក្រៃពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់ កន្ទងពួកទេវតានិម្មានរតីដោយស្ថាន ១០ យ៉ាង គឺអាយុជាទិព្វ ១ ។បេ។ ផោដ្ឋព្វៈជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុ

ដ៏ច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ បរនិម្មិតវសវត្តីទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្លងនូវពួកទេវតាបរនិម្មិតវសវត្តី ដោយស្ថាន ១០ យ៉ាង គឺអាយុជាទិព្វ ១ ពណ៌ជាទិព្វ ១ សុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុ មាន ៣ យ៉ាងនេះឯង ។

# អដ្ឋកថា

## បុញ្ញកិរិយាវត្ថុសូត្រ

[ ៣៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុញ្ញកិរិយាវត្ថុសូត្រទី ៦ ដូចតទៅនេះ ការធ្វើបុណ្យនោះផង ជាទីតាំងនៃអានិសង្សនោះផង ព្រោះដូច្នោះ ទើបឈ្មោះថា **បុញ្ញកិរិយាវត្ថុ** ។ ពិតហើយ សត្វទាំងឡាយតាំងចិត្តទុកក្នុងលក្ខណៈនៃទានជាដើម ហើយគិតថា ឈ្មោះថា ទានបែបនេះ ពួកយើងគួរឲ្យ គួររក្សាសីល គួរចម្រើនភាវនា ដូច្នេះហើយ ទើបធ្វើបុណ្យ ។ ទាននោះឯង

ឈ្មោះថា **ឆានមយ** ។ ម្យ៉ាងទៀត បណ្តាទានចេតនា សន្និដ្ឋានបកចេតនាដែលសម្រេចមកអំពីចេតនាដែលដាក់ចិត្ត ចេតនាដំបូង ឈ្មោះថា **ឆានមយ** ដូចវត្ថុដែលសម្រេចមកអំពីម្សៅជាដើម ក៏សម្រេចដោយម្សៅជាដើម ដូច្នោះ ក្នុងពីរបទដ៏សេសក៏មានន័យដូចគ្នា ។

បទថា **បរិត្តំ កតំ ហោតិ** សេចក្តីថា ឈ្មោះថា បុគ្គលនោះធ្វើតិច គឺតិចតួច ។ បទថា **ឆាភិសម្ភោតិ** ប្រែថា រមែងមិនសម្រេចផល ។ បទថា **អកតំ ហោតិ** សេចក្តីថា មិនបានផ្តើមសេចក្តីព្យាយាមក្នុងការនោះសោះ ។ បទថា **មនុស្សទោភគ្យំ** បានដល់ ត្រកូលទាប ៥ ដែលវៀរចាកសម្បត្តិក្នុងមនុស្សទាំងឡាយ ។ បទថា **ឧបបជ្ជតិ** បានដល់ រមែងចូលដល់ដោយអំណាចបដិសន្ធិ អធិប្បាយថា កើតក្នុងត្រកូលទាបនោះ ។ បទថា **មត្តសោកតំ** បានដល់ ធ្វើ គឺមិនតិច មិនច្រើន ។ បទថា **មនុស្សសោភគ្យំ** បានដល់ សម្បត្តិនៃត្រកូល ៣ ដែលប្រសើរក្នុងមនុស្ស ។ បទថា **អធិមត្តំ** បានដល់ ឲ្យមានប្រមាណក្រៃលែង ឬឲ្យរឹងមាំ ។ បទថា **អធិគ្គណ្ហាតិ** បានដល់ ប្រកាន់ អធិប្បាយថា ជាបុគ្គលប្រសើរជាង គឺចម្រើនជាង ។ល។

**អដ្ឋកថា បុញ្ញកិរិយាវត្ថុសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សប្បុរិសទានសូត្រទី ៧

[ ៣៧ ] ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះ មាន ៨ យ៉ាង ។ សប្បុរិសទាន ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យវត្ថុស្អាត ១ ឲ្យវត្ថុថ្លៃថ្លា ១ ឲ្យតាមកាល ១ ឲ្យវត្ថុគួរ ១ ជ្រើសរើសហើយទើបឲ្យ ១ ឲ្យទានរឿយៗ ១ កំពុងឲ្យញ៉ាំងចិត្តឲ្យជ្រះថ្លា ១ លុះឲ្យផុតហើយ រមែងមានសេចក្តីពេញចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាន ៨ យ៉ាងនេះឯង ។

បុគ្គល រមែងឲ្យនូវទានទាំងឡាយ គឺទឹក និងភោជនដ៏
ស្អាត ថ្លៃថ្លា តាមកាល វត្ថុដ៏គួររឿយៗ ចំពោះ
ព្រហ្មចារីបុគ្គលទាំងឡាយ ដូចជាស្រែដ៏ល្អ ពួកអ្នក
ប្រាជ្ញ រមែងសរសើរ នូវទានទាំងឡាយ ដែលបុគ្គល
លះបង់នូវអាមិសៈជាច្រើន ដែលមិនគួរឲ្យកើតសេចក្តី
ក្តៅក្រហាយ ហើយឲ្យយ៉ាងនេះ អ្នកប្រាជ្ញមានបញ្ញា
ជាអ្នកមានសទ្ធា បានបូជាយ៉ាងនេះហើយ មានចិត្តរួច
ស្រឡះ រមែងចូលទៅកាន់ទេវលោក ដែលមិនមាន
សេចក្តីទុក្ខ មានតែសេចក្តីសុខ ។

# អដ្ឋកថា

## សប្បុរិសទានសូត្រ

[ ៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសប្បុរិសទានសូត្រទី ៧ ដូចតទៅនេះ បទថា **សុចឹ** បានដល់ ឲ្យរបស់ដែលស្អាត គឺបរិសុទ្ធ ។ បទថា **បណីតំ** បានដល់ សម្បូរល្អ ។ បទថា **កាលេន** បានដល់ សមគួរដល់ការប្រកបខ្វល់ខ្វាយ ។ បទថា **កប្បិយំ** បានដល់ ឲ្យតែរបស់ដែលជាកប្បិយ ។ បទថា **វិចេយ្យ ទេតិ** សេចក្តីថា ជ្រើសរើសបដិគ្គាហក ឬទាន ដោយតាំងចិត្តឲ្យយ៉ាងនេះថា ទានដែលឲ្យហើយដល់បុគ្គលនេះ នឹងមានផលច្រើន ដែលឲ្យដល់បុគ្គលនេះមិនមានផលច្រើន ដូច្នេះហើយ ឲ្យ ។ល។

**អដ្ឋកថា សប្បុរិសទានសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សប្បុរិសសូត្រទី ៨

[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ សប្បុរស កាលកើតក្នុងត្រកូល រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់មាតាបិតា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តី

សុខដល់បុត្តភរិយា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់បុរសជាទាសកម្មករ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់មិត្ត និងអាមាត្យទាំងឡាយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ពួកញាតិ ដែលចែកឋានទៅកាន់បរលោក ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ព្រះរាជា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ពួកទេវតា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់សមណព្រាហ្មណ៍ទាំងឡាយ ។ ម្នាលភិក្ខុទាំង-ឡាយ មហាមេឃ កាលញុំាំងសម្ទូទាំងអស់ ឲ្យសម្រេចព្រម រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើនដល់ជនច្រើន ។បេ។ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ សប្បុរស កាលកើតក្នុងត្រកូល រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់មាតា និងបិតាទាំងឡាយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់បុត្តភរិយា ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់បុរសជាទាសកម្មករ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់មិត្ត និងអាមាត្យទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ពួកញាតិ

ដែលចែកឋានទៅកាន់បរលោក ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ព្រះរាជា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់ពួកទេវតា ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់សមណព្រាហ្មណ៍ទាំងឡាយ ក៏មានឧបមេយ្យដូច្នោះដែរ ។

បុគ្គលប្រកបដោយបញ្ញា កាលនៅគ្រប់គ្រងផ្ទះ រមែង
ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ពួកជនច្រើន ជាអ្នក
មិនខ្ជិលច្រអូស ក្នុងវេលាយប់ និងថ្ងៃ កាលនឹករឭក
ដល់បុព្វការគុណដែលមាតា និងបិតាធ្វើហើយ រមែង
បូជាមាតាបិតាជាមុន ដោយហេតុប្រកបដោយធម៌ រមែង
កោតក្រែងចំពោះបព្វជិតជាអនាគារិកបុគ្គល ជាព្រហ្ម-
ចារីបុគ្គលមានសទ្ធាតម្កល់មាំ មានសីលជាទីស្រឡាញ់
លុះដឹងច្បាស់នូវធម៌ទាំងឡាយហើយ រមែងបូជាបុគ្គល
ណាដែលមានប្រយោជន៍ដល់ព្រះរាជា មានប្រយោជន៍
ដល់ទេវតា មានប្រយោជន៍ដល់ពួកញាតិ ដល់មិត្ត
សម្លាញ់ តម្កល់ស៊ប់ក្នុងព្រះសទ្ធម្ម បុគ្គលនោះឈ្មោះ
ថាមានប្រយោជន៍ដល់បុគ្គលទាំងអស់ បុគ្គលណាកម្ចាត់
បង់នូវមន្ទិល គឺសេចក្តីកំណាញ់ បុគ្គលនោះ រមែង
ជួបប្រទះនូវលោកក្សេមក្សាន្ត ។

# អដ្ឋកថា

## សប្បុរិសសូត្រ

[ ៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសប្បុរិសសូត្រទី ៨ ដូចតទៅនេះ បទថា **អត្ថាយ** បានដល់ ដើម្បីជាប្រយោជន៍ ។ បទថា **ហិតាយ សុខាយ** បានដល់ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ បទថា **បុព្វបេ្បតានំ** បានដល់ ពួកញាតិដែលទៅកាន់បរលោក ។ ក្នុងព្រះសូត្រនេះ កាលព្រះសម្ពុទ្ធមិនទាន់កើតឡើងក្នុងលោក រមែងបានដល់ស្តេចចក្រពត្តិ ព្រះពោធិសត្វ ព្រះបច្ចេកពុទ្ធ ក្នុងសម័យពុទ្ធកាល រមែងបានដល់ព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធ ។ លោកទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ញាតិទាំងនោះ តាមដែលពោលហើយ ។ បទថា **ពហុន្នំ វត អត្ថាយ សប្បញ្ញោ ឃរមាវសំ** បានដល់ បុគ្គលមានបញ្ញាកាលនៅគ្រប់គ្រងផ្ទះ រមែងនៅដើម្បីប្រយោជន៍ដល់ជនច្រើនប៉ុណ្ណោះ ។ បទថា **បុព្វេ** ប្រែថា ក្នុងកាលមុន ។ បទថា **បុព្វេកតមនុស្សរំ** បានដល់ រឭកដល់ឧបការគុណ ដែលធ្វើទុកមុនរបស់មាតាបិតា ។ បទថា **សហធម្មេន** សេចក្តីថា បូជាដោយការបូជាបច្ច័យ ព្រមទាំងហេតុ ។ បទថា **អបចេ ព្រហ្មចារិនោ** សេចក្តីថា នមស្ការ គឺដល់នូវការប្រព្រឹត្តឱនលំទោនដល់លោកទាំងនោះ ។ បទថា **បេសលោ** ប្រែថា មានសីលជាទីស្រឡាញ់ ។ល។

**អដ្ឋកថា សប្បុរិសសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បុញ្ញាភិសន្ទសូត្រទី ៩

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ ៨ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ៨ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ទី ១ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវកជាអ្នកដល់នូវព្រះធម៌ជាទីពឹង ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យទី ២ ។បេ។ រមែងប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវកជាអ្នកដល់នូវព្រះសង្ឃជាទីពឹង នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ទី ៣ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តី

សុខ ។ ម្នាលភិក្ខុទាំងឡាយ ទានទាំង ៥ យ៉ាងនេះ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថា ជារបស់ប្រសើរ ដឹងថាជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថាជាវង្សនៃ ( កល្យាណជន ) ជារបស់មានមកក្នុងកាលមុន ជារបស់មិនរោយរាយ ជារបស់មិនធ្លាប់រោយរាយហើយ រមែងមិនខ្ចាត់ខ្ចាយ ( ក្នុងកាលឥឡូវនេះ ) នឹងមិនខ្ចាត់ខ្ចាយ ( ក្នុងអនាគត ) ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដែលតិះដៀលឡើយ ។ ទាន ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ លះបង់បាណាតិបាត វៀរចាកបាណាតិបាត ម្នាលភិក្ខុទាំងឡាយ អរិយសាវក ជាអ្នកវៀរចាកបាណាតិបាត ឈ្មោះថា ឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែក នៃសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានទុក្ខ មានប្រមាណមិនបានវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះជាទានទី ១ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថា ជារបស់ប្រសើរ ដឹងថាជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថាជាវង្សនៃ ( កល្យាណជន ) ជារបស់មានមកក្នុងកាលមុន ជារបស់មិនរោយរាយ មិនធ្លាប់រោយរាយហើយ រមែងមិនខ្ចាត់ខ្ចាយ នឹងមិនខ្ចាត់ខ្ចាយ ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដែលតិះដៀលឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារ

នៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខប្រព្រឹត្តទៅ ដើម្បីសួគ៌ទី ៤ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ។បេ។ លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ ។បេ។ លះបង់មុសាវាទ វៀរចាកមុសាវាទ ។បេ។ លះបង់សុរាមេរយមជ្ជប្បមាទដ្ឋាន វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ម្នាលភិក្ខុទាំងឡាយ អរិយសាវក វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ឈ្មោះថា ឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំង-ឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែក នៃសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានទុក្ខ មានប្រមាណមិនបានវិញ ម្នាលភិក្ខុទាំង-ឡាយ នេះជាទានទី ៥ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថាជារបស់ប្រសើរ ដឹងថា ជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថាជាវង្សនៃ ( កល្យាណជន ) ជារបស់មានមកក្នុងកាលមុន មិនរោយរាយ មិនធ្លាប់រោយរាយហើយ រមែងមិនខ្វាត់ខ្វាយ នឹងមិនខ្វាត់ខ្វាយ ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដែលតិះដៀលឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផល

នៃសេចក្ដីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ទី ៨ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីត្រេកអរ ដើម្បីសេចក្ដីរីករាយ ដើម្បីសេចក្ដីពេញចិត្ត ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្ដីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្ដីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ ៨ ប្រការនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីត្រេកអរ ដើម្បីសេចក្ដីរីករាយ ដើម្បីសេចក្ដីពេញចិត្ត ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខ ។

# អដ្ឋកថា

## បុញ្ញាភិសន្ទសូត្រទី ៩

[ ៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុញ្ញាភិសន្ទសូត្រទី ៩ ដូចតទៅនេះ បទថា **ឆាឆាធិ** បានដល់ ចេតនាទាន ។ អត្ថនៃបទជាដើមថា **អគ្គញ្ញាធិ** ដូច្នេះ បានពោលហើយខាងដើមនោះឯង ៕

**អដ្ឋកថា បុញ្ញាភិសន្ទសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## សព្វលហុសសូត្រទី ១០

[ ៤០ ] ម្នាលភិក្ខុទាំងឡាយ បាណាតិបាត ដែលបុគ្គលសេពថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃបាណាតិបាត ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីមានអាយុខ្លី ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ អទិន្នាទាន ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃអទិន្នាទាន ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីវិនាសនៃភោគៈ ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ កាមេសុមិច្ឆាចារ ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃកាមេសុមិច្ឆាចារ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីសត្រូវ និងពៀរដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ មុសាវាទ ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃមុសាវាទ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីគេពោលបង្កាច់ ដោយពាក្យមិនពិត ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ បិសុណាវាចា ដែលបុគ្គលថ្នឹកហើយ ចម្រើន

ហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើត តិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃបិសុណាវាចា ដែលស្រាល ជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីបែកបាក់ចាកមិត្រ ដល់កើតជា មនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ផរុសវាចា ដែលបុគ្គលថ្មីកហើយ ចម្រើន ហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើត តិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃផរុសវាចា ដែលស្រាលជាង ផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីសំឡេងមិនជាទីគាប់ចិត្ត ដល់កើតជា មនុស្ស ។ ម្នាលភិក្ខុទាំងឡាយ សម្ផប្បលាបៈដែលបុគ្គលថ្មីកហើយ ចម្រើន ហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើត តិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃសម្ផប្បលាបៈ ដែលស្រាល ជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីពាក្យដែលមិនគួរកាន់យក ដល់ កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ការផឹកនូវសុរា និងមេរ័យដែលបុគ្គល ថ្មីកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្ត ទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃការផឹកនូវ សុរាមេរ័យ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីភាពជា ឆ្កួត ដល់កើតជាមនុស្ស ។

ទានវគ្គទី ៤ ចប់

**ឧទ្ទានក្នុងវគ្គនោះ គឺ**

*និយាយអំពីទានពីរលើក អំពីទានវត្ថុ ១ អំពីបុញ្ញក្ខេត្ត ១ អំពីការកើតឡើងនៃទាន ១ អំពីបុញ្ញកិរិយាវត្ថុ ១ អំពីសប្បុរសពីរលើក អំពីផលដ៏ស្រោលជាងផលទាំងអស់ ១ អំពីអានិសង្ស ១ ។*

# អដ្ឋកថា

## សព្វលហុសសូត្រ

*[ ៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសព្វលហុសសូត្រទី ១០ ដូចតទៅនេះ បទថា* **បាណាតិបាតោ** *បានដល់ ចេតនាជាហេតុ ធ្វើសត្វមានជីវិតឲ្យកន្លង គឺសម្លាប់សត្វ ។ បទថា* **សព្វលហុសោ** *ប្រែថា ទន់ខ្សោយជាងវិបាកទាំងអស់ ។ បទថា* **អប្បាយុកសំវត្តនិកោ** *សេចក្តីថា ជាបុគ្គលមានអាយុខ្លី ព្រោះកម្មវិបាកតិចតួចនោះ ឬកាលឲ្យបដិសន្ធិ សត្វដែលនៅក្នុងផ្ទៃមាតា ឬសត្វដែលចេញអំពីផ្ទៃមាតាហើយ រមែងលំបាក សេចក្តីពិតវិបាកបែបនេះ មិនមែនជាវិបាកជាគ្រឿងហូរចេញអំពីកម្មណាដទៃ នេះជាផ្លូវទៅចំពោះបាណាតិបាតប៉ុណ្ណោះ ។ បទថា* **ភោគព្យសនសំវត្តនិកោ** *សេចក្តីថា ទ្រព្យត្រឹមតែមួយកាកណិក មិនតាំងនៅក្នុងដៃដោយប្រការណា អទិន្នាទានរមែងញុំាងការវិកវរនៃភោគសម្បត្តិឲ្យប្រព្រឹត្តទៅ ដោយប្រការនោះ ។ បទ*

ថា **សបត្តបរសំវត្តនិកោ ហោតិ** សេចក្តីថា រមែងសាងពៀរ និងសត្រូវ ។ ពិតហើយ បុគ្គលនោះ មានសត្រូវច្រើន ម្យ៉ាងទៀត បុគ្គលណាឃើញបុគ្គលនោះ រមែងញុំាងពៀរឲ្យកើតក្នុងបុគ្គលនោះ មិនរលត់ទៅ ដ្បិតថា វិបាកបែបនេះ ជាវិបាកហូរចេញអំពីការខុសក្នុងកណ្ឌៈរបស់អ្នកដទៃ ដែលគេគ្រប់គ្រងរក្សា ។ បទថា **អព្ភក្ខានសំវត្តនិកោ ហោតិ** សេចក្តីថា ធ្វើនូវការពោលទោសដោយរឿងដែលមិនពិត ឲ្យប្រព្រឹត្តទៅ ។ កម្មដែលបុគ្គលណាម្នាក់ធ្វើហើយ រមែងធ្លាក់លើអំបែងក្បាល របស់បុគ្គលនោះឯង ។ បទថា **មិត្តេហិ ភេទនសំវត្តនិកោ** សេចក្តីថា រមែងញុំាងការបែកចាកមិត្រ ឲ្យប្រព្រឹត្តទៅ ។ បុគ្គលធ្វើបុណ្យណាមួយឲ្យជាមិត្រ បុគ្គលនោះ រមែងព្រាត់ទៅ ។ បទថា **អមនាបសទ្ទសំវត្តនិកោ** សេចក្តីថា រមែងញុំាងសំឡេងដែលមិនពេញចិត្តឲ្យប្រព្រឹត្តទៅ វាចាណាមួយ ជាពាក្យចាក់ដោត គ្រោតគ្រាត ក្តៅក្រហាយ នាំមកនូវការអាក់អន់ កាត់បង់នូវសេចក្តីស្រឡាញ់ បុគ្គលនោះបានឮតែវាចានោះ ក្នុងទីនោះៗ ដែលខ្លួនទៅហើយ ។ មិនបានស្តាប់សំឡេងដែលជាទីពេញចិត្ត ព្រោះវិបាកបែបនេះ ឈ្មោះថា ជាផ្លូវទៅនៃផរុសវាចា ។ បទថា **អនាទេយ្យវាចាសំវត្តនិកោ** សេចក្តីថា រមែងញុំាងពាក្យដែលមិនគួរ ទាញយកមកដាក់ក្នុងចិត្តឲ្យប្រព្រឹត្តទៅ សម្បីភាពជា

បុគ្គលដែលត្រូវជំទាស់ថា ហេតុអ្វី ទើបអ្នកពោល អ្នកណានឹងជឿ ពាក្យអ្នកនេះ ឈ្មោះថា ជាផ្លូវទៅនៃសម្ផប្បលាប ។ បទថា **ឧម្មត្តកសំវត្តនិកោ ហោតិ** សេចក្តីថា រមែងញុំាងនូវភាពជាមនុស្សឆ្កួតឲ្យប្រព្រឹត្តទៅ ពិតហើយ មនុស្សឆ្កួតមានចិត្តរាយមាយ ឬជាមនុស្សគ ព្រោះការផឹកសុរានោះ នេះជាវិបាក គ្រឿងហូរចេញនៃសុរាបាន ។ សូត្រនេះ ទ្រង់ត្រាស់ចំពោះវដ្តៈតែម្យ៉ាងប៉ុណ្ណោះឯង ៕

**អដ្ឋកថាសព្វលហុសសូត្រទី ១០ ចប់**

**ទានវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## ឧបោសថវគ្គ

### សង្ខិត្តសូត្រទី ១

[ ៤១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ឧបោសថ ប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ ម្នាលភិក្ខុទាំងឡាយ ចុះឧបោសថ ប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ ជាអ្នកមានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្លួនអញ លះបង់នូវបាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញា

ដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្ដីខ្មាសបាប មានសេចក្ដីអាណិត មានសេចក្ដីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ១ នេះឯង ។បេ។ ព្រះអរហន្តទាំងឡាយ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ប្រាថ្នាចំពោះវត្ថុដែលគេឲ្យ មានខ្លួនដ៏ស្អាត មិនមែនជាអ្នកលួច ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ប្រាថ្នាចំពោះតែវត្ថុដែលគេឲ្យ មានខ្លួនដ៏ស្អាត មិនមែនជាអ្នកលួច អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថ ប្រកបដោយអង្គទី ២ នេះឯង ។បេ។ ព្រះអរហន្តទាំងឡាយ លះបង់អព្រហ្មចរិយៈ ជាអ្នកមានព្រហ្មចារ្យ ប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ដែលជាធម៌របស់អ្នកស្រុក ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំលះបង់អព្រហ្មចរិយៈ ជាអ្នកមានព្រហ្មចារ្យ ប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ដែលជាធម៌របស់អ្នកស្រុក អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំង-ឡាយផង ខ្ញុំនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៣ នេះឯង ។បេ។ ព្រះអរហន្តទាំងឡាយ លះបង់មុសាវាទ វៀរចាកមុសាវាទ អ្នកពោលពាក្យពិត ទ្រទ្រង់ពាក្យពិត ពោលពាក្យខ្ជាប់ខ្ជួន

គួរឲ្យគេជឿបាន មិនបានពោលពាក្យបង្អាច់លោក ក្នុងថ្ងៃនេះ ចំណែកខ្ញុំអញ លះបង់មុសាវាទ វៀរចាកមុសាវាទ ជាអ្នកពោលពាក្យពិត ទ្រទ្រង់ពាក្យពិត ពោលពាក្យខ្ជាប់ខ្ជួន គួរឲ្យគេជឿបាន មិនបានពោលពាក្យបង្អាច់លោក អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៤ នេះឯង ។បេ។ ព្រះអរហន្តទាំងឡាយ លះបង់ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកគ្រឿងស្រវឹង គឺសុរា និងមេរ័យ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកគ្រឿងស្រវឹង គឺសុរា និងមេរ័យដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំអញ លះបង់ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកគ្រឿងស្រវឹង គឺសុរា និងមេរ័យ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកគ្រឿងស្រវឹង គឺសុរា និងមេរ័យ អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៥ នេះឯង ។បេ។ ព្រះអរហន្តទាំងឡាយ បរិភោគបាយតែម្តង វៀរបរិភោគ ក្នុងវេលាយប់ វៀរចាកភោជន ក្នុងវេលាវិកាល ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំអញ បរិភោគបាយតែម្តង វៀរបរិភោគ ក្នុងវេលាយប់ វៀរចាកភោជន ក្នុងវេលាវិកាល អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៦ នេះឯង ។បេ។ ព្រះអរហន្តទាំង-

ឡាយ លះបង់ការរាំ ច្រៀង ប្រគំ មើលល្បែង ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ ប្រដាប់តាក់តែង ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ វៀរចាកការរាំ ច្រៀង ប្រគំ មើលល្បែងដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាង រាងកាយដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំអញ លះបង់ការរាំ ច្រៀង ប្រគំ មើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ វៀរចាកការរាំ ច្រៀង ប្រគំ មើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាង រាងកាយដោយផ្កាកម្រងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៧ នេះឯង ។បេ។ ព្រះអរហន្តទាំងឡាយ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែតូច លើកម្រាល ដែលគេធ្វើដោយស្មៅក្តី ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំអញ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែតូច លើ

កម្រាលដែលគេធ្វើដោយស្មៅក្តី អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ជួនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៨ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាយ៉ាងនេះឯង រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយច្រើន ។

# អដ្ឋកថា

## ឧបោសថវគ្គទី ៤

### សង្ខិត្តសូត្រ

[ ៤១ ] សង្ខិត្តសូត្រទី ១ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសង្ខិត្តសូត្រទី ១ ចប់

# សុត្តន្តបិដក

## វិត្ថតសូត្រទី ២

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មាន

សេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វ ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្លួនអញលះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វ អស់យប់នេះ និងថ្ងៃនេះ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្លួនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ១ នេះឯង ។ ( សេចក្តីពិស្តារដូចអង្គទី ១ ) ព្រះអរហន្តទាំងឡាយ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែតូច លើកម្រាលដែលគេធ្វើដោយស្មៅក្តី ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្លួនអញ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏

ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែក្ដី លើកម្រាលដែលធ្វើដោយស្មៅក្ដី អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង អញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៨ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាយ៉ាងនេះឯង រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្ដីរុងរឿងច្រើន មានសេចក្ដីផ្សាយទៅច្រើន ។

ឧបោសថ មានផលច្រើន ដូចម្ដេច មានអានិសង្សច្រើន ដូចម្ដេច មានសេចក្ដីរុងរឿងច្រើន ដូចម្ដេច មានសេចក្ដីផ្សាយទៅច្រើន ដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គលសោយរាជ្យ ជាឥស្សរាធិបតីនៃមហាជនបទទាំង ១៦ នេះ ដែលជាជនបទ សម្បូរដោយកែវ ៧ ប្រការ គឺមហាជនបទឈ្មោះគង្គៈ ១ មគធៈ ១ កាសី ១ កោសលៈ ១ វជ្ជី ១ មល្លៈ ១ ចេតី ១ វង្សៈ ១ កុរុ ១ បញ្ចាលៈ ១ មច្ឆៈ ១ សូរសេនៈ ១ អស្សកៈ ១ អវន្តី ១ គន្ធារៈ ១ កម្ពោជៈ ១ រាជសម្បត្តិនៃមហាជនបទទាំងនុ៎ះ មិនដល់នូវចំណិត ១ ក្នុងចំណិតទី ១៦ៗ លើកនៃឧបោសថប្រកបដោយអង្គ ៨ ប្រការឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សជារបស់ស្ដួចស្ដើង ហើយយកទៅប្រៀបធៀបនឹងសេចក្ដីសុខជារបស់ទិព្យ ។ ម្នាលភិក្ខុទាំងឡាយ ៥០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ចាតុម្មហារាជិកទេវតា រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែ

នោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៥០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុ របស់ចាតុម្មហារាជិកទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថ ដែលប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ជាមួយនឹងពួកចាតុម្មហារាជិកទេវតា ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្យ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ១០០ ឆ្នាំ របស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃ របស់តាវត្តិង្សទេវតា រាប់រាត្រីនោះបាន ៣០ ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១០០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុរបស់តាវត្តិង្សទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកតាវត្តិង្សទេវតា ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្យ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ២០០ ឆ្នាំ របស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកយាមទេវតា រាប់រាត្រីនោះបាន ៣០ រាត្រីត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១

ឆ្នាំ រាប់ឆ្នាំនោះបាន ២០០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុរបស់យាមទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកយាមទេវតា ។ ម្នាលភិក្ខុទាំង-ឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្ដួចស្ដើង ហើយយកទៅប្រៀបធៀបនឹងសេចក្ដីសុខជារបស់ទិព្យ ដែលតថាគតសម្ដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ៤០០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកតុសិតទេវតា រាប់រាត្រីនោះបាន ៣០ រាត្រីត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៤០០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុរបស់ពួកតុសិតទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមានត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកតុសិតទេវតា ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្ដួចស្ដើង ហើយយកទៅប្រៀបធៀបនឹងសេចក្ដីសុខជារបស់ទិព្យ ដែលតថាគតសម្ដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ៨០០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកនិម្មានរតីទេវតា រាប់រាត្រីនោះបាន ៣០ ត្រូវជា ១ ខែ រាប់ខែនោះ បាន ១២ ខែត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៨០០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃ

អាយុរបស់ពួកនិម្មានរតីទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកនិម្មានរតីទេវតា ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្វ ដែលតថាគតសំដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ១៦០០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកបរនិម្មិតវសវត្តីទេវតា រាប់រាត្រីនោះបាន ៣០ ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១៦០០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមានត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ដែលតថាគតសំដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។

បុគ្គលមិនគប្បីសម្លាប់សត្វ ១ មិនគប្បីកាន់យកវត្ថុដែល
គេមិនបានឲ្យ ១ មិនគប្បីពោលពាក្យកុហក ១ មិន
គប្បីផឹកទឹកស្រវឹង១ គប្បីវៀរចាកការប្រព្រឹត្តមិនប្រសើរ

គឺមេថុន ១ មិនគប្បីបរិភោគភោជន ក្នុងវេលារាត្រី និង ក្នុងវេលាវិកាល ១ មិនគប្បីទ្រទ្រង់ផ្កាកម្រង មិនគប្បីប្រោះព្រំដោយគ្រឿងក្រអូប ១ គប្បីដេកលើគ្រែ លើផែនដី ឬលើកម្រាល ១ ព្រះពុទ្ធព្រះអង្គ ដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសហើយ នូវឧបោសថដែលប្រកបដោយអង្គ ៨ ប្រការនេះឯង សភាវៈទាំងឡាយពីរ គឺព្រះចន្ទ ១ ព្រះអាទិត្យ ១ ជាសភាវៈល្អមើល កាលបំភ្លឺលោក រមែងចរទៅអស់ទីត្រឹមណា ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ ដែលកម្ចាត់បង់នូវងងឹត ចរទៅក្នុងអាកាស ញុំាងទិសឲ្យរុងរឿងភ្លឺច្បាស់ ក្នុងអាកាសអស់ទីត្រឹមនោះ ទ្រព្យណា មានក្នុងចន្លោះនេះ គឺកែវមុក្តាក្តី កែវមណីក្តី កែវពិទូរ្យដ៏ល្អក្តី មាសឈ្មោះសិង្គីក្តី ឈ្មោះសុវណ្ណក្តី ឬមាសឈ្មោះកាញ្ចនៈក្តី ឈ្មោះជាតរូបក្តី ឈ្មោះហដកៈក្តី ទ្រព្យទាំងអម្បាលនោះ មិនដល់នូវចំណិតមួយ ក្នុងចំណែក ១៦ៗ លើកនៃឧបោសថដែលប្រកបដោយអង្គ ៨ ប្រការឡើយ ដូចជាពួកផ្កាយទាំងអស់ មិនដល់នូវពន្លឺនៃព្រះចន្ទ ហេតុដូច្នោះ ស្ត្រីក្តី បុរសក្តី ជាអ្នកមានសីល គួរចាំរក្សានូវ

ឧបោសថប្រកបដោយអង្គ ៨ ប្រការ ពួកជនដែលមិន
មានគេនិន្ទា បំពេញនូវបុណ្យទាំងឡាយ ដែលមាន
សេចក្តីសុខជាកម្រៃ រមែងចូលទៅកាន់ឋានសួគ៌បាន ។

# អដ្ឋកថា

## វិត្ថតសូត្រ

[ ៤២ ] វិត្ថតសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវិត្ថតសូត្រទី ២ ចប់

# សុត្តន្តបិដក

## វិសាខសូត្រទី ៣

[ ៤៣ ] សម័យមួយ ព្រះដ៏មានព្រះភាគកាលគង់នៅនាប្រាសាទមិគារ-មាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះ នាងវិសាខា ជាមិគារមាតា ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះវិសាខា ជាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូចនេះថា ម្នាលវិសាខា

ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ ម្នាលវិសាខា ចុះឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលវិសាខា អរិយសាវកក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយលះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ ដរាបអស់ជីវិត ក្នុងថ្ងៃនេះចំណែកខ្លួនអញលះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វ អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្លួនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ១ នេះឯង ។បេ។ ព្រះអរហន្តទាំងឡាយ លះបង់នូវសេនាសនៈដ៏ខ្ពស់ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់ និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាបលើគ្រែតូច លើកម្រាលដែលគេធ្វើដោយស្មៅក្តី ដរាបអស់ជីវិត ក្នុងថ្ងៃនេះចំណែកខ្លួនអញ លះបង់សេនាសនៈដ៏ខ្ពស់ និងសេនាសនៈដ៏ប្រសើរ វៀរចាក

សេនាសនៈដ៏ខ្ពស់ និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែក្តី លើកម្រាលដែលគេធ្វើដោយស្មៅក្តី អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៨ នេះឯង ។ ម្នាលវិសាខា ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាយ៉ាងនេះហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។

ឧបោសថ មានផលច្រើន ដូចម្តេច មានអានិសង្សច្រើន ដូចម្តេច មានសេចក្តីរុងរឿងច្រើន ដូចម្តេច មានសេចក្តីផ្សាយទៅច្រើន ដូចម្តេច ។ ម្នាលវិសាខា ប្រៀបដូចបុគ្គលសោយរាជ្យ ជាឥស្សរាធិបតីនៃមហាជនបទទាំង ១៦ នេះ ដែលជាជនបទ សម្បូរដោយកែវ ៧ ប្រការ គឺមហាជនបទឈ្មោះអង្គៈ ១ មគធៈ ១ កាសី ១ កោសលៈ ១ វជ្ជី ១ មល្លៈ ១ ចេតី ១ វំសៈ ១ កុរុ ១ បញ្ចាលៈ ១ មច្ឆៈ ១ សូរសេនៈ ១ អស្សកៈ ១ អវន្តី ១ គន្ធារៈ ១ កម្ពោជៈ ១ រាជសម្បត្តិ នៃមហាជនបទទាំងនុ៎ះ មិនដល់នូវចំណិត ១ ក្នុងចំណិតទី ១៦ៗ លើកនៃឧបោសថ ដែលប្រកបដោយអង្គ ៨ ប្រការឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលវិសាខា រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ។ ម្នាលវិសាខា ៥០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ចាតុម្មហារាជិក-

ទេវតា រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៥០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកចាតុម្មហារាជិកទេវតា ។ ម្នាលវិសាខា ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកចាតុម្មហារាជិកទេវតា ។ ម្នាលវិសាខា រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ម្នាលវិសាខា ១០០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកតាវត្តិង្សទេវតា រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១០០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់តាវត្តិង្សទេវតា ។ ម្នាលវិសាខា ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកើតជាមួយនឹងពួកតាវត្តិង្សទេវតា ។ ម្នាលវិសាខា រាជសម្បត្តិ របស់មនុស្សនេះឯង ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ម្នាលវិសាខា ២០០ ឆ្នាំរបស់មនុស្ស ។បេ។ ៤០០ ឆ្នាំ ។បេ។ ៨០០ ឆ្នាំ ។បេ។ ១៦០០ ឆ្នាំ ត្រូវជា ១ យប់ ១ ថ្ងៃរបស់ពួកបរនិម្មិតវស-

វត្តីទេវតា រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១៦០០០ ( មួយហ្មឺនប្រាំមួយពាន់ ) ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលវិសាខា ហេតុនេះ រមែងមាន គ្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលវិសាខា រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្វ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។

បុគ្គលមិនគប្បីសម្លាប់សត្វ ១ មិនគប្បីកាន់យកវត្ថុ ដែលគេមិនបានឲ្យ ១ មិនគប្បីពោលពាក្យកុហក ១ មិនគប្បីផឹកទឹកស្រវឹង ១ គប្បីវៀរចាកការប្រព្រឹត្តមិនប្រសើរ គឺមេថុន ១ មិនគប្បីបរិភោគភោជន ក្នុងវេលារាត្រី និងក្នុងវេលាវិកាល ១ មិនគប្បីទ្រទ្រង់នូវផ្កាកម្រង មិនគប្បីប្រោះព្រំ ដោយគ្រឿងក្រអូប ១ គប្បីដេកលើគ្រែលើផែនដី ឬលើកម្រាល ១ ព្រះពុទ្ធ ព្រះអង្គដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសហើយ នូវឧបោសថប្រកបដោយអង្គ ៨ ប្រការនេះឯង សភាវៈទាំងឡាយពីរ គឺព្រះចន្ទ ១ ព្រះអាទិត្យ ១ ជាសភាវៈល្អមើល កាល

បំភ្លឺលោក រមែងចរទៅ អស់ទីត្រឹមណា ព្រះចន្ទ និង ព្រះអាទិត្យទាំងនោះ ដែលកម្ចាត់បង់នូវងងឹត ចរទៅ ក្នុងអាកាស ញុំាងទិសឲ្យរុងរឿងភ្លឺច្បាស់ ក្នុងអាកាស អស់ទីត្រឹមនោះ ទ្រព្យណា មានក្នុងចន្លោះនេះ គឺកែវ មុក្តាក្តី កែវមណីក្តី កែវពិទូរ្យដ៏ល្អក្តី មាសឈ្មោះសិង្គី ក្តី ឈ្មោះសុវណ្ណក្តី ឬមាសឈ្មោះកាញ្ចនៈក្តី ឈ្មោះ ជាតរូបក្តី ឈ្មោះហដកៈក្តី ទ្រព្យទាំងអម្បាលនោះ មិន ដល់នូវចំណិត ១ ក្នុងចំណែក ១៦ៗ លើក នៃ ឧបោសថ ដែលប្រកបដោយអង្គ ៨ ប្រការឡើយ ដូច ជាពួកផ្កាយទាំងអស់ មិនដល់នូវពន្លឺ នៃព្រះចន្ទ ហេតុ ដូច្នោះ ស្ត្រីក្តី បុរសក្តី ជាអ្នកមានសីល គួរចាំរក្សានូវ ឧបោសថប្រកបដោយអង្គ ៨ ប្រការ ពួកជនដែលមិន មានគេនិន្ទា បំពេញនូវបុណ្យ ដែលមានសេចក្តីសុខជា កម្រៃ រមែងចូលទៅកាន់ឋានសួគ៌បាន ៗ

# អដ្ឋកថា

## វិសាខសូត្រ

[ ៤៣ ] វិសាខសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវិសាខសូត្រទី ៣ ចប់

# សុត្តន្តបិដក

## វាសេដ្ឋសូត្រទី ៤

[ ៤៤ ] សម័យមួយ ព្រះដ៏មានព្រះភាគកាលគង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ វាសេដ្ឋឧបាសក ( ឧបាសកឈ្មោះវាសេដ្ឋ ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះវាសេដ្ឋឧបាសកអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលវាសេដ្ឋ ឧបោសថប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន ។បេ។ ពួកជនដែលគេមិននិន្ទា តែងទៅកាន់ឋានសួគ៌ ។ កាលដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ វាសេដ្ឋឧបាសក បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកញាតិសាលោហិត ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ គប្បីរក្សាឧបោសថប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកញាតិសា-

លោហិត ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ អស់កាលយូរ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកក្សត្រិយ៍ទាំងពួង គប្បីចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកក្សត្រិយ៍ទាំងពួង អស់កាលយូរ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកព្រាហ្មណ៍ទាំងពួង ។បេ។ ពួកវេស្សៈ សុទ្ទៈ គប្បីចាំរក្សាឧបោ-សថប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកសុទ្ទៈទាំងពួង អស់កាលយូរ ។ ម្នាលវាសេដ្ឋ ប្រសិនបើពួកក្សត្រិយ៍ទាំងពួង គប្បីចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកក្សត្រិយ៍ទាំងពួង អស់កាលយូរ ។ ម្នាលវាសេដ្ឋ ប្រសិនបើពួកព្រាហ្មណ៍ទាំងពួង ។បេ។ ពួកវេស្សៈ សុទ្ទៈ គប្បីចាំរក្សាឧបោសថ ប្រកបដោយអង្គ ៨ ហើយ ការរក្សាឧបោសថនោះគប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកសុទ្ទៈទាំងពួង អស់កាលយូរ ។ ម្នាលវាសេដ្ឋ ប្រសិនបើលោក ( នេះ ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស គប្បីចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដល់ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជា

សម្មតិទេព និងមនុស្សដ៏សេស អស់កាលយូរ ។ ម្នាលវាសេដ្ឋ ប្រសិនបើ ដើមមហាសាលព្រឹក្សទាំងនេះ គប្បីចាំរក្សាឧបោសថ ប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ដើមមហាសាលព្រឹក្សទាំងនេះ អស់កាលយូរ ប្រសិនបើឈើទាំងនេះ ចេះគិត ចាំបាច់ទៅនិយាយថ្វី ដល់មនុស្ស ។

# អដ្ឋកថា

## វាសេដ្ឋសូត្រ

[ ៤៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវាសេដ្ឋសូត្រទី ៤ នៃឧបោសថវគ្គទី ៥ ដូច្នេះ បទថា **ឥមេ ចេបិ វាសេដ្ឋ មហាសាលា** នេះ ព្រះមានព្រះភាគកាលទ្រង់សម្តែងដើមសាលព្រឹក្ស ២ ដើម ដែលឈរនៅចំពោះព្រះភក្ត្រ ទើបត្រាស់ប្រៀបធៀបដោយបរិកប្ប លោកអធិប្បាយដូច្នេះថា ជាបឋម ដើមសាលព្រឹក្សទាំងនេះ មិនមានចិត្ត បើដើមឈើទាំងនេះមានចិត្ត គប្បីរក្សាឧបោសថប្រកបដោយអង្គ ៨ បានសោត ការរក្សាឧបោសថនោះរបស់ដើមមហាសាលទាំងនោះ ក៏គប្បីមានដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលយូរ នឹងពោលទៅថ្វី ក្នុងពួកមនុស្ស ។

**អដ្ឋកថា វាសេដ្ឋសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ពោជ្ឈាសូត្រទី ៩

[ ៤៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ នាងពោជ្ឈាឧបាសិកា ( ឧបាសិកាឈ្មោះពោជ្ឈា ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះនាងពោជ្ឈា-ឧបាសិកា អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលនាងពោជ្ឈា ឧបោសថប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានការរុងរឿងច្រើន មានគុណផ្សាយទៅច្រើន ។ ម្នាលនាងពោជ្ឈា ចុះឧបោសថប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានការរុងរឿងច្រើន មានការផ្សាយទៅច្រើន តើដូចម្តេច ។ ម្នាលនាងពោជ្ឈា អរិយ-សាវក ក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណា-តិបាត វៀរចាកបាណាតិបាត ដាក់ចុះនូវអាជ្ញា ដាក់ចុះនូវគ្រឿងសស្ត្រា មានសេចក្តីអៀនខ្មាស ដល់នូវការអាណិត អនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងអស់ ដរាបដល់អស់ជីវិត ក្នុងថ្ងៃនេះ ចំណែកអាត្មាអញ បានលះបង់បាណាតិបាត វៀរចាកបាណាតិបាត ដាក់ចុះនូវអាជ្ញា ដាក់ចុះនូវគ្រឿងសស្ត្រា មានសេចក្តីអៀនខ្មាស ដល់នូវការអាណិត អនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងអស់ អស់យប់នេះ និងថ្ងៃនេះដែរ ធ្វើតាមព្រះអរហន្តទាំងឡាយផង

ឧបោសថអាត្មាអញនឹងចាំរក្សាហើយផង ដោយអង្គនេះ ។ អរិយសាវកប្រកប ដោយអង្គទី ១ នេះ ។បេ។ ព្រះអរហន្តទាំងឡាយ លះបង់ទីដេក ទីអង្គុយដ៏ខ្ពស់ហួសប្រមាណ និងទីដេកទីអង្គុយដ៏ប្រសើរ វៀរចាកទីដេក ទីអង្គុយដ៏ខ្ពស់ហួសប្រមាណ និងទីដេកទីអង្គុយដ៏ប្រសើរ សម្រេចការដេកលើអាសនៈទាប គឺលើគ្រែ ឬលើកម្រាលស្មៅ ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកអាត្មាអញ បានលះបង់ទីដេកទីអង្គុយដ៏ខ្ពស់ហួសប្រមាណ និងទីដេក ទីអង្គុយដ៏ប្រសើរ វៀរចាកទីដេកទីអង្គុយខ្ពស់ហួសប្រមាណ និងទីដេកទីអង្គុយដ៏ប្រសើរ សម្រេចការដេកលើអាសនៈទាប គឺលើគ្រែ ឬលើកម្រាលស្មៅ អស់យប់នេះ និងថ្ងៃនេះដែរ ធ្វើតាមព្រះអរហន្តទាំងឡាយនេះផង ឧបោសថ អាត្មាអញ នឹងចាំរក្សាហើយផង ដោយអង្គនេះឯង ។ អរិយសាវកប្រកបដោយអង្គទី ៨ នេះ ។ ម្នាលនាងពោជ្ឈា ឧបោសថប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាយ៉ាងនេះហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានការរុងរឿងច្រើន មានគុណផ្សាយទៅច្រើន ។ ឧបោសថមានផលច្រើនប៉ុនណា មានអានិសង្សច្រើនប៉ុនណា មានការរុងរឿងច្រើនប៉ុនណា មានគុណផ្សាយទៅច្រើនប៉ុនណា ។ ម្នាលនាងពោជ្ឈា ប្រៀបដូចជាបុគ្គលណាសោយរាជ្យ ជាឥស្សរាធិបតីលើមហាជនបទទាំង ១៦ នេះ ដែលសម្បូណ៌ដោយរតនៈ ( ទ្រព្យជាគ្រឿងរីករាយ ) ទាំង ៧ ប្រការ គឺមហាជនបទឈ្មោះអង្គៈ ១ មគធៈ ១ កាសី ១ កោសលៈ ១ វជ្ជី ១ មល្លៈ ១ ចេតី ១ វង្សៈ ១ កុរុ ១ បញ្ចាលៈ ១

មច្ឆៈ ១ សូរសេនៈ ១ អស្សកៈ ១ អវន្តី ១ គន្ធារៈ ១ កម្ពោជៈ ១ ឯ ភោគសម្បទទាំងនុ៎ះ មិនដល់នូវចំណិតនៃចំណែក ១៦ៗ លើកនៃឧបោសថដែលប្រកបដោយអង្គ ៨ ឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលនាងពោជ្ឈា ( ព្រោះថា ) រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ហើយប្រៀបផ្ទឹមនឹងសុខជាទិព្វ ។ ម្នាលនាងពោជ្ឈា ព្រោះថា ៥០ ឆ្នាំរបស់មនុស្ស ជា ១ យប់ ១ ថ្ងៃរបស់ពួកទេវតាជាន់ចាតុម្មហារាជិកៈ រាប់រាត្រីនោះ បាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៥០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់ចាតុម្មហា-រាជិកៈ ។ ម្នាលនាងពោជ្ឈា ហេតុនេះរមែងមានប្រាកដ ត្រង់ដែលស្រ្តី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ លុះទម្លាយរាងកាយស្លាប់ទៅ គប្បីទៅកើតជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈ ។ ម្នាលនាងពោជ្ឈា ពាក្យដែលតថាគត សម្តែងហើយថា រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ប្រៀបផ្ទឹមដោយសុខជាទិព្វនេះ ព្រោះសំដៅនូវហេតុនុ៎ះ ។ ម្នាលនាងពោជ្ឈា ១០០ ឆ្នាំរបស់មនុស្ស ។បេ។ ម្នាលនាងពោជ្ឈា ២០០ ឆ្នាំរបស់មនុស្ស ។បេ។ ៤០០ ឆ្នាំ ។បេ។ ៨០០ ឆ្នាំ ។បេ។ ១៦០០ ឆ្នាំ ( របស់មនុស្ស ) ត្រូវជា ១ យប់ ១ ថ្ងៃរបស់ពួកទេវតាជាន់បរនិម្មិតវសវត្តី រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១៦០០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់

បរនិម្មិតវសវត្តី ។ ម្នាលនាងពោជ្ឈា ហេតុនេះ រមែងមានពិតប្រាកដ ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ លុះទម្លាយរាងកាយស្លាប់ទៅ គប្បីទៅកើត ជាមួយនឹងពួកទេវតាជាន់បរនិម្មិតវសវត្តី ។ ម្នាលនាងពោជ្ឈា ពាក្យដែលតថាគតសម្តែងហើយថា រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ប្រៀបផ្ទឹមដោយសុខជាទិព្វនេះ ព្រោះសំដៅនូវហេតុនុ៎ះ ។

បុគ្គលកុំគប្បីសម្លាប់សត្វ ១ កុំគប្បីកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ កុំគប្បីពោលពាក្យកុហក ១ កុំគប្បីផឹកទឹកស្រវឹង ១ គប្បីវៀរចាកអព្រហ្មចរិយៈ គឺមេថុន ១ កុំគប្បីបរិភោគភោជន ក្នុងវេលារាត្រី និងវេលាវិកាល ១ កុំគប្បីទ្រទ្រង់ផ្កាកម្រង កុំគប្បីលាបគ្រឿងក្រអូប ១ គប្បីដេកលើគ្រែលើផែនដី ឬលើកម្រាល ១ ព្រោះថា ឧបោសថប្រកបដោយអង្គ ៨ នេះ ព្រះពុទ្ធទ្រង់ដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសហើយ ព្រះចន្ទនិងព្រះអាទិត្យទាំង ២ ជារបស់ល្អមើល កាលចរទៅបំភ្លឺត្រឹមណា ព្រះចន្ទ និងព្រះអាទិត្យទាំងពីរនោះ តែងកម្ចាត់បង់នូវងងឹត ត្រាច់ទៅក្នុងអាកាស ភ្លឺក្នុងអាកាស រុងរឿងសព្វទិស ទ្រព្យណា ដែលមានក្នុងចន្លោះនុ៎ះ គឺ

កែវមុក្តា កែវមណី កែវពិទូរ្យដ៏ល្អ ម្យ៉ាងទៀត មាស ឈ្មោះសិង្គី ឈ្មោះសុវណ្ណ ឬមាសឈ្មោះកាញ្ចនៈ ឈ្មោះ ជាតរូប ឈ្មោះហដកៈ របស់ទាំងអស់នោះ ក៏មិនដល់ នូវ ១ ចំណិតនៃចំណែក ១៦ៗ លើកនៃឧបោសថ ប្រកបដោយអង្គ ៨ ដូចជាពួកផ្កាយទាំងអស់មិនដល់ នូវពន្លឺនៃព្រះចន្ទ ព្រោះហេតុនោះ ជនស្រីប្រុសអ្នកមាន សីល គួររក្សាឧបោសថ ប្រកបដោយអង្គ ៨ ពួកជន ដែលគេមិននិន្ទាហើយ បំពេញបុណ្យដែលជាកម្រៃនៃ សេចក្តីសុខ រមែងចូលទៅកាន់ឋានសួគ៌បាន ។

# អដ្ឋកថា

## ពោជ្ឈាសូត្រ

[ ៤៥ ] ក្នុងពោជ្ឈាសូត្រទី ៥ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាពោជ្ឈាសូត្រទី ៥ ចប់

# សុត្តន្តបិដក

## អនុរុទ្ធសូត្រទី ៦

[ ៤៦ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅឃោសិតារាម ទៀបក្រុងកោសម្ពី ។ សម័យនោះឯង ព្រះអនុរុទ្ធដ៏មានអាយុ ចូលទៅកាន់ទីនៅក្នុងវេលាថ្ងៃ សម្ងំនៅ ។ គ្រានោះ ពួកទេវតាឈ្មោះមនាបកាយិកាជាច្រើន អង្គនាំគ្នាចូលទៅរកព្រះអនុរុទ្ធ លុះចូលទៅដល់ ថ្វាយបង្គំព្រះអនុរុទ្ធ ហើយឋិតនៅក្នុងទីសមគួរ ។ លុះទេវតាទាំងនោះ ឋិតនៅក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះអនុរុទ្ធដ៏មានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំជាពួកទេវតា ឈ្មោះមនាបកាយិកា ធ្វើឥស្សរិយភាព ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងហេតុទាំង ៣ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំប្រាថ្នានូវវណ្ណៈបែបណា ក៏បាននូវវណ្ណៈបែបនោះមួយរំពេច ១ ប្រាថ្នានូវសំឡេងបែបណា ក៏បាននូវសំឡេងបែបនោះមួយរំពេច ១ ប្រាថ្នានូវសុខបែបណា ក៏បាននូវសុខបែបនោះមួយរំពេច ១ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំជាពួកទេវតា ឈ្មោះមនាបកាយិកា ធ្វើនូវឥស្សរិយភាព ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងហេតុទាំង ៣ នេះ ។ លំដាប់នោះ ព្រះអនុរុទ្ធដ៏មានអាយុ មានសេចក្តីត្រិះរិះថា ធ្វើដូចម្តេចហ្ន៎ នឹងបានទេវតាទាំងនេះ ទៅជាខៀវទាំងអស់ គឺមានសម្បុរ ក៏ខៀវ មានសំពត់ ក៏ខៀវ មានគ្រឿងអលង្ការ ក៏ខៀវ ។ វេលានោះ ទេវតាទាំងនោះ បានដឹងចិត្តនៃព្រះអនុរុទ្ធដ៏មានអាយុ ហើយក៏ទៅជាខៀវទាំងអស់ គឺមានសម្បុរ ក៏ខៀវ មានសំពត់ ក៏ខៀវ មានគ្រឿងអលង្ការ ក៏ខៀវ ។ លំដាប់នោះ ព្រះ

អនុរុទ្ធដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ធ្វើដូចម្តេចហ្ន៎ នឹងបានទេវតាទាំងនេះ ទៅជាលឿងទាំងអស់ ។បេ។ ទៅជាក្រហមទាំងអស់ ទៅជាសទាំងអស់ គឺមានសម្បុរ ក៏ស មានសំពត់ ក៏ស មានគ្រឿងអលង្ការ ក៏ស ។ វេលានោះ ទេវតាទាំងនោះ បានដឹងចិត្តនៃព្រះអនុរុទ្ធដ៏មានអាយុហើយ ក៏ទៅជាស ទាំងអស់ គឺមានសម្បុរ ក៏ស មានសំពត់ ក៏ស មានគ្រឿងអលង្ការ ក៏ស ។ លំដាប់នោះ ទេវតាទាំងនោះ ១ អង្គច្រៀង ១ អង្គរាំ ១ អង្គទះដៃ ។ ប្រៀបដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែលបុគ្គលអ្នកឈ្លាសវៃ បានសិក្សាស្ទាត់ប្រគំដោយប្រពៃ ដេញដំដោយប្រពៃ មានសំឡេងពីរោះផង គួរត្រេកអរផង គួរប្រាថ្នាផង គួរស្រឡាញ់ផង គួររីករាយផង យ៉ាងណាមិញ សំឡេងនៃគ្រឿងអលង្ការ របស់ពួកទេវតាទាំងនោះ ពីរោះផង គួរត្រេកអរផង គួរប្រាថ្នាផង គួរស្រឡាញ់ផង គួររីករាយផង ក៏យ៉ាងនោះដែរ ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ ដាក់ចុះនូវឥន្ទ្រិយទាំងឡាយ គឺធ្វើព្រងើយ ។ លំដាប់នោះ ទេវតាទាំងនោះដឹងថា ព្រះអនុរុទ្ធជាម្ចាស់ មិនត្រេកអរហើយបាត់ក្នុងទីនោះទៅ ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ ចេញចាកទីសម្ងំនៅ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គចូលទៅកាន់ទីនៅ ក្នុងវេលាថ្ងៃ ហើយសម្ងំ

នៅ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ពួកទេវតាឈ្មោះមនាបកាយិកា ជាច្រើនអង្គ ចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ ថ្វាយបង្គំខ្ញុំព្រះអង្គ ហើយ ឋិតនៅក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះទេវតាទាំងនោះ ឋិតនៅ ក្នុងទីសមគួរហើយ ក៏ពោលទៅនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំជាពួកទេវតាឈ្មោះមនាបកាយិកា ធ្វើនូវឥស្សរិយភាពញុំាងអំណាចឲ្យ ប្រព្រឹត្តទៅក្នុងហេតុ ៣ យ៉ាង បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំប្រាថ្នានូវ វណ្ណៈបែបណា ក៏បាននូវវណ្ណៈបែបនោះមួយរំពេច ១ ប្រាថ្នានូវសំឡេងបែប ណា ក៏បាននូវសំឡេងបែបនោះមួយរំពេច ១ ប្រាថ្នានូវសុខបែបណា ក៏បាន នូវសុខបែបនោះមួយរំពេច ១ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំជាពួកទេវតា ឈ្មោះមនាបកាយិកា ធ្វើនូវឥស្សរិយភាព ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ក្នុង ហេតុទាំង ៣ នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះដូច្នេះ ថា ធ្វើដូចម្តេចហ្ន៎ នឹងបានទេវតាទាំងនេះ ទៅជាខៀវទាំងអស់ គឺមានសម្បុរ ក៏ខៀវ មានសំពត់ ក៏ខៀវ មានគ្រឿងអលង្ការ ក៏ខៀវ ។ បពិត្រព្រះអង្គដ៏ ចម្រើន វេលានោះ ទេវតាទាំងនោះ បានដឹងចិត្តខ្ញុំព្រះអង្គហើយ ក៏ទៅជាខៀវ ទាំងអស់ គឺមានសម្បុរ ក៏ខៀវ មានសំពត់ ក៏ខៀវ មានគ្រឿងអលង្ការ ក៏ ខៀវ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះដូច្នេះថា ធ្វើដូចម្តេច ហ្ន៎ នឹងបានទេវតាទាំងនេះ ទៅជាលឿងទាំងអស់ ។បេ។ ទៅជាក្រហមទាំង អស់ ។បេ។ ទៅជាសទាំងអស់ គឺមានសម្បុរ ក៏ស មានសំពត់ ក៏ស មាន

គ្រឿងអលង្ការ ក៏ស ។ បពិត្រព្រះអង្គដ៏ចម្រើន លុះទេវតាទាំងនោះ បានដឹងចិត្តខ្ញុំព្រះអង្គហើយ ក៏ទៅជាសទាំងអស់ គឺមានសម្បុរ ក៏ស មានសំពត់ ក៏ស មានគ្រឿងអលង្ការ ក៏ស ។ បពិត្រព្រះអង្គដ៏ចម្រើន វេលានោះ ទេវតាទាំងនោះ ១ អង្គច្រៀង ១ អង្គរាំ ១ អង្គទះដៃ ។ ប្រៀបដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ដែលគេរៀបចំល្អហើយ បុគ្គលឈ្លាសវៃ បានប្រគំដោយប្រពៃ បានដេញដំដោយប្រពៃ មានសំឡេងពីរោះផង គួរត្រេកអរផង គួរប្រាថ្នាផង គួរស្រឡាញ់ផង គួររីករាយផង យ៉ាងណាមិញ សំឡេងគ្រឿងអលង្ការរបស់ទេវតាទាំងនោះ ក៏ពីរោះផង គួរត្រេកអរផង គួរប្រាថ្នាផង គួរស្រឡាញ់ផង គួររីករាយផង ក៏យ៉ាងនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គក៏ដាក់ចុះនូវឥន្ទ្រិយទាំងឡាយ គឺធ្វើព្រងើយ ។ បពិត្រព្រះអង្គដ៏ចម្រើន វេលានោះ ទេវតាទាំងនោះ គិតគ្នាថា ព្រះអនុរុទ្ធជាម្ចាស់ មិនត្រេកអរហើយ ក៏បាត់ក្នុងទីនោះទៅ បពិត្រព្រះអង្គដ៏ចម្រើន ចុះមាតុគ្រាម ប្រកបដោយធម៌ប៉ុន្មានយ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតជាមួយនឹងពួកទេវតា ឈ្មោះមនាបកាយិកា ។ ព្រះអង្គត្រាស់ថា ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតា ឈ្មោះមនាបកាយិកា ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលអនុរុទ្ធ មាតុគ្រាមក្នុងលោកនេះ ដែលមាតាបិតា ប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ បានរៀបចំឲ្យ

ដល់ស្វាមីណាហើយ ជាស្រីក្រោកមុន ដេកក្រោយ ទទួលស្តាប់កិច្ចការអ្វីៗ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ចំពោះស្វាមីនោះ ១ ពួកជនណាជាទីគោរព របស់ស្វាមី ទោះមាតាក្តី បិតាក្តី សមណព្រាហ្មណ៍ក្តី មាតុគ្រាម តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចំពោះជនទាំងនោះផង តែងបូជាពួកជន ដែលទើបមកដល់ថ្មី ដោយអាសនៈ និងទឹកផង ១ ការងារទាំងឡាយណា ជាបន្ទុករបស់ស្វាមី ទោះជារោមសត្វក្តី កប្បាសក្តី ជាស្រីប៉ិនប្រសប់ក្នុងការងារទាំងនោះ មិនខ្ជិលច្រអូស ប្រកបដោយការពិចារណាដោយឧបាយក្នុងកិច្ចទាំងនោះថា គួរធ្វើ គួរចាត់ចែង ១ ពួកជនណានៅខាងក្នុង ជាបន្ទុករបស់ស្វាមី ទោះជាខ្ញុំក្តី ជាអ្នកបម្រើក្តី ជាកម្មករក្តី មាតុគ្រាម តែងដឹងនូវអំពើដែលជនទាំងនោះធ្វើថា ធ្វើ ដឹងនូវអំពើដែលជនទាំងនោះមិនបានធ្វើថា មិនបានធ្វើ ដឹងនូវកម្លាំងតិច និងកម្លាំងច្រើនរបស់អ្នកឈឺ ទាំងចេះចាត់ចែងនូវខាទនីយភោជនីយាហារ តាមចំណែកដែលគួរដល់ជនជាខាងក្នុងបន្ទុកនោះ ១ ស្វាមីបាននាំមក នូវទ្រព្យណាក្តី ស្រូវណាក្តី ប្រាក់ណាក្តី មាសណាក្តី មាតុគ្រាមនោះ តែងសម្រេចដោយការរក្សា គ្រប់គ្រងនូវទ្រព្យជាដើមនោះនឹងជាអ្នកមិនលេង មិនលួច មិនខិលខូច មិនធ្វើសម្បត្តិទាំងនោះ ឲ្យវិនាស ១ ជាឧបាសិកាដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ១ ជាស្ត្រីមានសីល វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកការផឹកទឹកស្រវឹង គឺសុរា

និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ជាស្ត្រីមានចាគៈ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរក្នុងការចែករំលែកនូវទាន ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាម ប្រកបដោយធម៌ទាំង ៨ នេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងពួកទេវតាឈ្មោះមនាបកាយិកា ។

មាតុគ្រាមណា មានព្យាយាម ខ្វល់ខ្វាយចិញ្ចឹមស្វាមី
នោះសព្វកាលជានិច្ច មិនមើលងាយបុរសជាស្វាមី ដែល
នាំមកនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងនោះ ជាស្ត្រីល្អមិនធ្វើ
ស្វាមីឲ្យក្តៅក្រហាយ ដោយពាក្យប្រចណែន ជាស្ត្រីមាន
បញ្ញា តែងបូជាស្វាមី និងបុគ្គល ដែលជាទីគោរពទាំង
អស់ ជាស្ត្រីមានសេចក្តីខ្នះខ្នែង មិនខ្ជិលច្រអូស សង្គ្រោះ
ជនជាបរិសទ្យ តែងប្រព្រឹត្តនូវអំពើ ជាទីគាប់ចិត្តនៃ
ស្វាមី ថែទាំសម្បត្តិដែលស្វាមីរកបានមក នារីណាជា
ស្ត្រី លុះក្នុងអំណាចសេចក្តីប្រាថ្នារបស់ស្វាមី ហើយ
ប្រព្រឹត្តយ៉ាងនេះ នារីនោះ រមែងទៅកើតក្នុងពួកទេវតា
ឈ្មោះមនាបកាយិកា ។

# អដ្ឋកថា

## អនុរុទ្ធសូត្រ

[ ៤៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុរុទ្ធសូត្រទី ៦ ដូចតទៅនេះ បទថា **យេនាយស្មា អនុរុទ្ធោ** សេចក្តីថា បានឮថា ទេវតាទាំងនោះ សម្លឹងមើលសម្បត្តិរបស់ខ្លួនហើយ អាវជ្ជនះថា អញបានសម្បត្តិនេះ ព្រោះអាស្រ័យអ្វីហ្ន៎ ដូច្នេះ ឃើញព្រះថេរៈ គិតថា យើងជាអ្នកប្រណិប័តន៍លោកម្ចាស់របស់ពួកយើង ដែលគ្រងរាជសម្បត្តិជាស្តេចចក្រពត្តិក្នុងកាលមុន បានទូវសម្បត្តិនេះ ក៏ព្រោះតាំងនៅក្នុងឱវាទដែលលោកប្រទាន ទើបបានទូវសម្បត្តិនេះ ពួកយើងទៅជាមួយគ្នា រកព្រះថេរៈមកសោយសម្បត្តិនេះ ដូច្នេះហើយ ក្នុងពេលថ្ងៃនោះឯង ទើបចូលទៅរកព្រះអនុរុទ្ធ ។

បទថា **តីសុ ឋានេសុ** បានដល់ ក្នុងហេតុ ៣ យ៉ាង ។ បទថា **ឋានសោបដិលភាម** បានដល់ រមែងបានរំពេចនោះឯង ។ បទថា **សទ្ទំ** បានដល់ សំឡេងពោល សំឡេងប្រគំ ឬសំឡេងគ្រឿងអលង្ការ ។ លំដាប់នេះ នឹងពោលបទថា **បីតា អស្ស** ជាដើម ។ ព្រះអនុរុទ្ធគិតត្រិះរិះដោយន័យជាដើមថា ដំបូង ទេវតាដែលមានពណ៌ខៀវ មិនអាចជាអ្នកមាន ពណ៌លឿងបានដូច្នេះ ។ ទេវតាទាំងនោះដឹងថា ឥឡូវនេះ លោកម្ចាស់ប្រាថ្នាឲ្យពួកយើងមានពណ៌លឿង ឥឡូវនេះ ប្រាថ្នាឲ្យពួកយើង មានពណ៌ក្រហម ទើបបានជាយ៉ាងនោះ ។ បទថា **មច្ចរិកំ វាទេសិ** សេចក្តីថា ទះដៃហើយ ។

បទថា **បញ្ចង្គិកស្ស** សេចក្តីថា តន្ត្រីប្រកបដោយអង្គ ៥ គឺអាតតៈ

១ វិតតៈ ១ អាតតវិតតៈ ១ សុសិរៈ ១ ឃនៈ ១ ។ បណ្ដាគ្រឿងតន្ត្រីទាំងនោះ តន្ត្រីដែលពាសស្បែកតែម្ខាង ក្នុងពពួកស្គរជាដើមដែលពាសស្បែក ឈ្មោះថា **អាតត** ។ តន្ត្រីដែលពាសស្បែកសងខាង ឈ្មោះថា **វិតត** ។ តន្ត្រីដែលស្រោបស្បែកទាំងអស់ ឈ្មោះថា **អាតតវិតត** ។ តន្ត្រីមានបីជាដើម ឈ្មោះថា **សុសិរ** ។ តន្ត្រីមានជង ឬស្នូក ធ្វើដោយដើមត្នោតជាដើម ឈ្មោះថា **ឃន** ។ បទថា **សុវិនីតស្ស** បានដល់ ដែលបន្ទឺល្អហើយ ដើម្បីឲ្យដឹងថា សំឡេងស្មើល្អហើយ ។ បទថា **កុសលេហិ សុសមន្នាហតស្ស** បានដល់ ដែលអ្នកតន្ត្រីដ៏ឈ្លាស ជំនាញ លេងហើយ ។ បទថា **វគ្គូ** បានដល់ ពីរោះ គឺពីរោះល្អ ។ បទថា **រជនីយោ** ប្រែថា អាចធ្វើឲ្យកើតស្រឡាញ់ ។ បទថា **កមនីយោ** ប្រែថា ដឹកនាំឲ្យគួរស្រឡាញ់ ។ បាឋៈថា **ខមនីយោ** ដូច្នេះក៏មាន អធិប្បាយថា កាលបុគ្គលស្ដាប់អស់មួយថ្ងៃក៏ពេញចិត្ត មិននឿយណាយ ។ បទថា **មទនីយោ** បានដល់ ឲ្យកើតសេចក្ដីស្រវឹងដោយមានះ និងបុរិសមទៈ ។

បទថា **ឥន្ទ្រិយានិ ឱក្ខិបិ** សេចក្ដីថា ព្រះថេរៈគិតថា ទេវតាទាំងនេះធ្វើវត្ថុដែលមិនសមគួរ ទើបដាក់ឥន្ទ្រិយចុះខាងក្រោម គឺបិទភ្នែក មិនសម្លឹងមើល ។ បទថា **ន ខ្វយ្យោ អនុរុទ្ធោ សាធិយតិ** សេចក្ដីថា ទេវតាគិតថា អញរាំ អញច្រៀង តែលោកម្ចាស់អនុរុទ្ធមិនត្រេកអរ បិទភ្នែកមិនសម្លឹងមើល អញនៅរាំ នៅច្រៀងធ្វើអ្វី ដូច្នេះហើយ ក៏អន្តរធានទៅក្នុងទីនោះឯង ។

បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា ព្រះថេរៈកាលឃើញអានុភាពរបស់ទេវតាទាំងនោះហើយ ចូលទៅសួរសេចក្តីនេះថា ស្រីប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបមកកើតក្នុងទេវលោក មានសរីរៈគួរពេញចិត្ត ។

**អដ្ឋកថា អនុរុទ្ធសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## វិសាខសូត្រទី ៧

[ ៤៧ ] សម័យមួយ ព្រះដ៏មានព្រះភាគកាលគង់នៅក្នុងមិគារមាតុប្រាសាទ ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះ នាងវិសាខាមិគារមាតា ។បេ។ អង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលនាងវិសាខា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលនាងវិសាខា មាតុគ្រាមក្នុងលោកនេះ ដែលមាតាបិតា មានប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ បានរៀបចំឲ្យដល់ស្វាមីណាហើយ ជាស្ត្រីក្រោកមុន ដេកក្រោយ ទទួលស្តាប់កិច្ចការអ្វីៗ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់

ចំពោះស្វាមីនោះ ១ ។បេ។ ជាស្ត្រីមានចាគៈ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកសូម ត្រេកអរក្នុងការចែករំលែកនូវទាន ១ ។ ម្នាលនាងវិសាខា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការនេះឯង លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។

មាតុគ្រាមណា មានព្យាយាម ខ្វល់ខ្វាយចិញ្ចឹមស្វាមី
នោះសព្វកាល ជានិច្ច មិនមើលងាយបុរស ជាស្វាមី
ដែលនាំមកនូវសេចក្តីប្រាថ្នា គ្រប់យ៉ាងនោះ ជាស្ត្រីល្អ
មិនបានធ្វើស្វាមីឲ្យក្តៅក្រហាយ ដោយពាក្យប្រចណែន
ជាស្ត្រីមានបញ្ញា តែងបូជាស្វាមី និងបុគ្គល ដែលជាទី
គោរពទាំងអស់ ជាស្ត្រីមានសេចក្តីខ្នះខ្នែង មិនខ្ជិល
ច្រអូស សង្គ្រោះជនជាបរិសទ្យ តែងប្រព្រឹត្តនូវអំពើ
ជាទីគាប់ចិត្តនៃស្វាមី ថែទាំសម្បត្តិ ដែលស្វាមីរកបាន
មក នារីណា ជាស្ត្រី លុះក្នុងអំណាចសេចក្តីប្រាថ្នារបស់
ស្វាមី ប្រព្រឹត្តយ៉ាងនេះ នារីនោះ រមែងទៅកើតក្នុងពួក
ទេវតា ឈ្មោះមនាបកាយិកា ។

# អដ្ឋកថា

## វិសាខសូត្រ

[ ៤៧ ] ក្នុងវិសាខសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវិសាខសូត្រទី ៧ ចប់

# សុត្តន្តបិដក

## នកុលសូត្រទី ៨

[ ៤៨ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុំសុមារគិរៈ ក្នុងដែនភគ្គៈ ។ គ្រានោះ នកុលមាតាគហបតី ( នាងគហបតានីឈ្មោះនកុលមាតា ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ។បេ។ ក៏អង្គុយនៅ ។ លុះនកុលមាតាគហបតានី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលនកុលមាតា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលនកុលមាតា មាតុគ្រាមក្នុងលោកនេះ ដែលមាតាបិតា មានប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ បានរៀបចំឲ្យដល់ស្វាមីណាហើយ ជាស្រ្តីក្រោកមុន ដេកក្រោយ ទទួលស្តាប់កិច្ចការអ្វីៗ ប្រព្រឹត្តនូវអំពើជាទីគាប់

ចិត្ត ពោលពាក្យជាទីស្រឡាញ់ ចំពោះស្វាមីនោះ ១ ។បេ។ ជាស្រ្តីមានចាគៈ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរក្នុងការចែករំលែកនូវទាន ១ ។ ម្នាលនកុលមាតា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។

មាតុគ្រាមណា មានព្យាយាម ខ្វល់ខ្វាយចិញ្ចឹមស្វាមី
នោះសព្វកាលជានិច្ច មិនមើលងាយបុរសជាស្វាមី ដែល
នាំមកនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងនោះ ជាស្រ្តីល្អ មិន
បានធ្វើស្វាមីឲ្យក្តៅក្រហាយ ដោយពាក្យប្រណែន ជា
ស្រ្តីមានបញ្ញា តែងបូជាស្វាមី និងបុគ្គលដែលជាទីគោរព
ទាំងអស់ ជាស្រ្តីមានសេចក្តីខ្នះខ្នែង មិនខ្ជិលប្រអូស
សង្គ្រោះជនជាបរិសទ្យ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃ
ស្វាមី ថែទាំសម្បត្តិដែលស្វាមីរកបានមក នារីណា ជា
ស្រ្តីលុះក្នុងអំណាចសេចក្តីប្រាថ្នា របស់ស្វាមី ប្រព្រឹត្ត
យ៉ាងនេះ នារីនោះ រមែងទៅកើតក្នុងពួកទេវតាឈ្មោះ
មនាបកាយិកា ។

# អដ្ឋកថា

## នកុលសូត្រ

[ ៤៨ ] ក្នុងនកុលសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថានកុលសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បឋមឥធលោកសូត្រទី ៩

[ ៤៩ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តបុព្វារាម ជាប្រាសាទរបស់មិគារមាតា ជិតក្រុងសាវត្ថី ។ គ្រានោះ នាងវិសាខាមិគារ-មាតា ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ។បេ។ ក៏អង្គុយនៅ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលវិសាខា មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថា ប្រតិបត្តិដើម្បីឈ្នះនូវលោកនេះ លោកនេះ ក៏ឈ្មោះថា មាតុគ្រាមនោះ ប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលវិសាខា មាតុគ្រាម ក្នុងលោកនេះ ជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃ ១ ចេះសង្គ្រោះពួកជនជាបរិសទ្យ ១ ចេះប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តរបស់ស្វាមី ១ ចេះថែទាំសម្បត្តិដែលស្វាមីរកបានមក ១ ។ ម្នាលវិសាខា ចុះមាតុគ្រាមជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃ តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាម

ក្នុងលោកនេះ ការទាំងឡាយណា ជាបន្ទុករបស់ស្វាមី ទោះរោមសត្វក្តី កប្បាសក្តី ជាស្ត្រីឆ្ងៀវឆ្លាស មិនខ្ជិលច្រអូស ក្នុងការងារទាំងនោះ ប្រកបដោយការពិចារណា ដោយឧបាយក្នុងការងារនោះថា គួរធ្វើ គួរចាត់ចែង ។ ម្នាលវិសាខា មាតុគ្រាម ជាស្ត្រីចេះចាត់ចែងការងារ ដោយប្រពៃយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម ជាស្ត្រីចេះសង្គ្រោះពួកជនជាបរិសទ្យ តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាមក្នុងលោកនេះ ពួកជនណា ជាខាងក្នុង ជាបន្ទុករបស់ស្វាមី ទោះខ្ញុំក្តី អ្នកបម្រើក្តី កម្មករក្តី តែងដឹងនូវអំពើដែលជនទាំងនោះធ្វើថាធ្វើ ដឹងនូវអំពើដែលជនទាំងនោះមិនបានធ្វើថា មិនបានធ្វើ ដឹងនូវកម្លាំងតិច និងកម្លាំងច្រើននៃពួកជនអ្នកឈឺ ចេះចាត់ចែងខាទនីយភោជនីយាហារ តាមចំណែកដែលគួរដល់ពួកជនខាងក្នុងបន្ទុកនោះ ។ ម្នាលវិសាខា មាតុគ្រាម ជាស្ត្រីចេះសង្គ្រោះពួកជន ជាបរិសទ្យយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម ចេះប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាមក្នុងលោកនេះ អំពើណា មិនជាទីគាប់ចិត្តរបស់ស្វាមី បើទុកជាមានហេតុដល់ជីវិត ក៏មិនប្រព្រឹត្តកន្លងនូវអំពើនោះ ។ ម្នាលវិសាខា មាតុគ្រាមចេះប្រព្រឹត្តអំពើ ជាទីគាប់ចិត្តនៃស្វាមីយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម ចេះថែទាំសម្បត្តិ ដែលស្វាមីរកបានមក តើដូចម្តេច ។ ម្នាលវិសាខា ទ្រព្យណាក្តី ស្រូវណាក្តី ប្រាក់ណាក្តី មាសណាក្តី ដែលស្វាមីរកបានមក មាតុគ្រាមក្នុងលោកនេះ តែងសម្រេច ដោយការរក្សា គ្រប់គ្រងនូវទ្រព្យជាដើមនោះ

ទាំងជាស្ត្រីអ្នកមិនលេង មិនលួច មិនវិលវូច មិនធ្វើសម្បត្តិទាំងនោះ ឲ្យវិនាស ។ ម្នាលវិសាខា មាតុគ្រាម រេះថែទាំសម្បត្តិ ដែលស្វាមី រកបានមកយ៉ាងនេះឯង ។ ម្នាលវិសាខា មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការនេះឯង ឈ្មោះថា ប្រតិបត្តិដើម្បីឈ្នះនូវលោកនេះ លោកនេះ ក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រារព្ធហើយ ។ ម្នាលវិសាខា មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការឈ្មោះថា ប្រតិបត្តិ ដើម្បីឈ្នះនូវលោកខាងមុខ លោកខាងមុខ ក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលវិសាខា មាតុគ្រាម ក្នុងលោកនេះ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយសីល ១ បរិបូណ៌ដោយចាគៈ ១ បរិបូណ៌ដោយបញ្ញា ១ ។ ម្នាលវិសាខា ចុះមាតុគ្រាម បរិបូណ៌ដោយសទ្ធា តើដូចម្តេច ។ ម្នាលវិសាខា មាតុ-គ្រាម ក្នុងលោកនេះ ជាស្ត្រីមានសទ្ធា ជឿការត្រាស់ដឹងរបស់ព្រះតថាគតថាព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរបំផុត ទ្រង់ទូន្មាននូវបុរស ដែលគួរទូន្មានបាន ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព គឺលែងវិលត្រឡប់មកកើតទៀតហើយ ។ ម្នាលវិសាខា មាតុគ្រាម បរិបូណ៌ដោយសទ្ធាយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម បរិបូណ៌ដោយសីល តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាមក្នុងលោកនេះ ជាស្ត្រីវៀរចាកបាណាតិបាត ។បេ។ វៀរចាក

ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។ ម្នាលវិសាខា មាតុគ្រាម បរិបូណ៌ដោយសីលយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម បរិបូណ៌ដោយចាគៈ តើដូចម្ដេច ។ ម្នាលវិសាខា មាតុគ្រាម ក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្ដីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគរួចស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរក្នុងការចែករំលែកនូវទាន ។ ម្នាលវិសាខា មាតុគ្រាម បរិបូណ៌ដោយចាគៈ យ៉ាងនេះឯង ។ ម្នាលវិសាខា មាតុគ្រាមបរិបូណ៌ដោយបញ្ញា តើដូចម្ដេច ។ ម្នាលវិសាខា ចុះមាតុគ្រាមក្នុងលោកនេះ ជាស្ត្រីមានបញ្ញា ប្រកបដោយបញ្ញា ជាដំណើរទៅកាន់សេចក្ដីចម្រើន និងសេចក្ដីវិនាស ជាបញ្ញាដ៏ប្រសើរមុះមុត ដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលវិសាខា មាតុគ្រាមបរិបូណ៌ដោយបញ្ញាយ៉ាងនេះឯង ។ ម្នាលវិសាខា មាតុគ្រាមបរិបូណ៌ដោយធម៌ ៤ ប្រការនេះ ឈ្មោះថា ប្រតិបត្តិដើម្បីឈ្នះនូវលោកខាងមុខ លោកខាងមុខ ក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រារព្ធហើយ ។

មាតុគ្រាមចាត់ចែងការងារដោយប្រពៃ ១ សង្គ្រោះពួក
ជនជាបរិសទ្យ ១ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី
១ ថែទាំសម្បត្តិដែលស្វាមីរកបានមក ១ បរិបូណ៌ដោយ
សទ្ធា ១ សីល ១ ដឹងនូវពាក្យពោល ១ ប្រាសចាក
សេចក្ដីកំណាញ់ ១ ជម្រះផ្លូវជាទីទៅកាន់បរលោក ឲ្យ

ស្អាតជានិច្ច ១ ធម៌ទាំង ៨ នេះ មានដល់នារីណា អ្នកប្រាជ្ញពោលថា នារីនោះមានសីល ឋិតនៅក្នុងធម៌ ពោលនូវពាក្យពិត ជាឧបាសិកា ដែលបរិបូណ៌ដោយអាការ ១៦ ប្រកបដោយអង្គទាំង ៨ ប្រការ មានសីលបែបនោះ រមែងទៅកើត ក្នុងទេវលោក ឈ្មោះមនាបកាយិកា ។

# អដ្ឋកថា

## បឋមឥធលោកសូត្រ

[ ៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមឥធលោកសូត្រទី ៩ ដូចតទៅនេះ បទថា **អយំស លោកោ អារទ្ធោ ហោតិ** សេចក្តីថា លោកនេះ ឈ្មោះថាដែលគេប្រារព្ធហើយ គឺបរិបូណ៌ហើយ ព្រោះប្រារព្ធសេចក្តីព្យាយាម គឺដល់ព្រមដោយសេចក្តីព្យាយាម ដើម្បីជាប្រយោជន៍ដល់កម្ម ដែលធ្វើក្នុងលោកនេះ ។ បទថា **សោឡសាការសម្បន្នា** សេចក្តីថា ប្រកបដោយអាការ ១៦ គឺអាការ ៨ ពោលក្នុងសូត្រនេះ និងអាការ ៨ ទៀត ពោលក្នុងអដ្ឋកថា ។ ម្យ៉ាងទៀត អាចារ្យមួយពួកពោលថា ប្រកបដោយអាការ ១៦ យ៉ាងនេះថា អង្គ ៨ ទាំងឡាយណាមាន បុគ្គលដឹកនាំអ្នកដទៃក្នុងអង្គ ៨ នោះ ។ សទ្ធា សីល ចាគៈ និងបញ្ញា ព្រះមានព្រះភាគត្រាស់លាយឡំគ្នា ក្នុងសូត្រនេះ ៕

# សុត្តន្តបិដក

## ទុតិយឥធលោកសូត្រទី ១០

[ ៥០ ] ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថា ប្រតិបត្តិដើម្បីឈ្នះនូវលោកនេះ លោកនេះ ក៏ឈ្មោះថាមាតុគ្រាមនោះ បានប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ ជាស្ត្រីចេះចាត់ចែងការងារ ដោយប្រពៃ ១ ចេះសង្គ្រោះពួកជនជាបរិសទ្យ ១ ចេះប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី ១ ចេះថែទាំសម្បត្តិដែលស្វាមីរកបានមក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ ការងារទាំងឡាយណា ជាបន្ទុករបស់ស្វាមី ។បេ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ជាស្ត្រីចេះចាត់ចែង ការងារដោយប្រពៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាមចេះសង្គ្រោះពួកជនជាបរិសទ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ ពួកជនណាជាខាងក្នុង ជាបន្ទុករបស់ស្វាមី ។បេ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមចេះសង្គ្រោះពួកជនជាបរិសទ្យយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ចេះប្រព្រឹត្តអំពើជាទីគាប់ចិត្តរបស់ស្វាមី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ អំពើណាដែលមិនជាទីគាប់ចិត្តនៃស្វាមី បើទុកជាមានហេតុដល់ជីវិត ក៏មិនប្រព្រឹត្តកន្លងនូវអំពើនោះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រព្រឹត្តអំពើជាទីគាប់ចិត្តនៃស្វាមី យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ចេះថែទាំសម្បត្តិ ដែលស្វាមីរកបានមក តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ ស្វាមីនាំមកនូវទ្រព្យណា ។បេ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ចេះថែទាំសម្បត្តិដែលស្វាមីរកបានមកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការនេះឯង ឈ្មោះថា ប្រតិបត្តិដើម្បីឈ្នះលោកនេះ លោកនេះក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រារព្ធហើយ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថា ប្រតិបត្តិដើម្បីឈ្នះលោកខាងមុខ លោកខាងមុខ ក៏ឈ្មោះថាមាតុគ្រាមនោះ បានប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយសីល ១ បរិបូណ៌ដោយចាគៈ ១ បរិបូណ៌ដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាមបរិបូណ៌ដោយសទ្ធា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ មានសទ្ធា ។បេ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បរិបូណ៌ដោយសទ្ធាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះមាតុគ្រាម បរិបូណ៌ដោយសីល តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ វៀរចាកបាណាតិបាត ។បេ។ វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមបរិបូណ៌ដោយសីលយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុ-គ្រាមបរិបូណ៌ដោយចាគៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុង

លោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បរិបូណ៌ដោយចាគៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម បរិបូណ៌ដោយបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ ជាស្រ្តីមានបញ្ញា ។បេ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បរិបូណ៌ដោយបញ្ញាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការនេះឯង ឈ្មោះថា ប្រតិបត្តិដើម្បីឈ្នះលោកខាងមុខ លោកខាងមុខ ក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រារព្ធហើយ ។

មាតុគ្រាមចាត់ចែងការងារដោយប្រពៃ ១ សង្គ្រោះពួក
ជនជាបរិសទ្យ ១ ប្រព្រឹត្តអំពើ ជាទីគាប់ចិត្តនៃស្វាមី ១
ថែទាំសម្បត្តិដែលស្វាមីរកបានមក ១ បរិបូណ៌ដោយ
សទ្ធា ១ សីល ១ ដឹងនូវពាក្យពោល ១ ប្រាសចាក
សេចក្តីកំណាញ់ ជម្រះផ្លូវជាទីទៅកាន់បរលោកឲ្យស្អាត
ជានិច្ច ១ ធម៌ទាំង ៨ នេះ មានដល់នារីណា អ្នកប្រាជ្ញ
ពោលថា នារីនោះ មានសីល ឋិតនៅក្នុងធម៌ ពោល
នូវពាក្យពិត ឧបាសិកាដែលបរិបូណ៌ដោយអាការ ១៦
ប្រកបដោយអង្គទាំង ៨ មានសីល បែបនោះ រមែង
ទៅកើតក្នុងទេវលោក ឈ្មោះមនាបកាយិកា ។

ឧបោសថវគ្គទី ៤ ចប់

## ឧទ្ទានក្នុងឧបោសថវគ្គនោះគឺ

និយាយអំពីការរក្សាឧបោសថយ៉ាងសង្ខេប ១ ពិស្តារ ១ អំពីនាងវិសាខា ១ អំពីវាសេដ្ឋព្រាហ្មណ៍ ១ ជាគម្រប់ ៥ និងនាងពោជ្ឈា អំពីព្រះអនុរុទ្ធ ១ អំពីនាងវិសាខា ១ អំពីនកុលមាតា ១ អំពីការឈ្នះលោកនេះមានពីរលើក ។

បណ្ណាសក ចប់

# អដ្ឋកថា

## ទុតិយសំជលោកសូត្រ

[ ៥០ ] ក្នុងទុតិយសំជលោកសូត្រទី ១០ ត្រាស់ដល់ភិក្ខុសង្ឃ ។ ពាក្យដែលមិនបានត្រាស់ទុកក្នុងព្រះសូត្រទាំងអស់ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយ ខាងដើមនោះឯង ៕

**អដ្ឋកថាទុតិយសំជលោកសូត្រទី ១០ ចប់**

**ឧបោសថវគ្គទី ៤ ចប់**

**បឋមបណ្ណាសក ចប់**

# សុត្តន្តបិដក
# បណ្ណាសកាសង្គហិតវគ្គ

## សក្កវគ្គ
### គោតមីសូត្រទី ១

[ ៥១ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងនិគ្រោធារាម ក្បែរក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី ឋិតនៅក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាម គួរចេញចាកផ្ទះ បានបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់សម្តែងហើយ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ឃាត់ថា ម្នាលនាងគោតមី ណ្ហើយនាង កុំគាប់ចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ ហើយបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតបានសម្តែងឡើយ ។ ព្រះនាងមហាបជាបតិគោតមី ក្រាបថ្វាយបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ ជាគម្រប់ពីរដងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាម គួរចេញចាកផ្ទះ បានបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់សម្តែងហើយ ។

ម្នាលនាងគោតមី ណ្ហើយនាង កុំគាប់ចិត្តឲ្យមាតុគ្រាម ចេញចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យដែលតថាគតបានសម្តែងឡើយ ។ ព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះ ជាគម្រប់ បីដងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាមគួរចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតសម្តែង ហើយ ។ ម្នាលនាងគោតមី ណ្ហើយនាង កុំគាប់ចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតបានសម្តែង ឡើយ ។ លំដាប់នោះឯង ព្រះនាងមហាបជាបតិគោតមី បានជ្រាបថា ព្រះដ៏ មានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាម ចេញចាកផ្ទះ បព្វជ្ជាមិនមាន ប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយ ក៏កើត ទុក្ខ តូចព្រះហឫទ័យ ស្រក់ទឹកព្រះនេត្រទ្រង់ព្រះកន្សែងហើយ ថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណរួចចៀសចេញទៅ ។ គ្រានោះឯង ព្រះដ៏ មានព្រះភាគទ្រង់គង់សម្រេចសម្រាន្ត ក្នុងក្រុងកបិលពស្តុ តាមគួរដល់ពុទ្ធ-អធ្យាស្រ័យហើយ ស្តេចចៀសចេញទៅកាន់ចារិកក្រុងវេសាលី កាលទ្រង់ ស្តេចទៅកាន់ចារិកតាមលំដាប់ ក៏បានទៅដល់ក្រុងវេសាលីនោះឯង ។ មាន សេចក្តីតំណាលថា ព្រះដ៏មានព្រះភាគ ទ្រង់គង់សម្រេចសម្រាន្ត ក្នុងកូដា-គារសាលា នាមហាវ័ន ទៀបក្រុងវេសាលីនោះ ។ លំដាប់នោះឯង ព្រះនាង មហាបជាបតិគោតមី ឲ្យគេកោរព្រះកេសា ហើយស្លៀកសំពត់ជ្រលក់ដោយ

ទឹកអម្ចត់ ទ្រង់យាងសំដៅទៅក្រុងវេសាលី ជាមួយនឹងពួកនាងសាកិយានី ជាច្រើន យាងចូលទៅកាន់កូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលី នោះ តាមលំដាប់ ។ វេលានោះ ព្រះនាងមហាបជាបតិគោតមី មានព្រះបាទ ទាំងគូពុះពង មានព្រះអង្គប្រឡាក់ដោយធូលី កើតទុក្ខតូចព្រះហឫទ័យ ស្រក់ ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែង ទៀបខ្លោងទ្វារខាងក្រៅ ។ ព្រះអានន្ទ ដ៏មានអាយុ បានឃើញព្រះនាងមហាបជាបតិគោតមី មានព្រះបាទទាំងគូ ពុះពង មានព្រះអង្គប្រឡាក់ដោយធូលី កើតទុក្ខតូចព្រះហឫទ័យ ស្រក់ទឹក ព្រះនេត្រ កំពុងតែឈរទ្រង់ព្រះកន្សែង ទៀបខ្លោងទ្វារខាងក្រៅ លុះបាន ឃើញហើយ ក៏ពោលទៅនឹងព្រះនាងមហាបជាបតិគោតមីដូច្នេះថា បពិត្រ ព្រះនាងគោតមី ហេតុអ្វីបានជាព្រះនាងមានព្រះបាទទាំងគូពុះពង មានព្រះ អង្គប្រឡាក់ដោយធូលី កើតទុក្ខតូចព្រះហឫទ័យ ស្រក់ទឹកព្រះនេត្រ ឈរ ទ្រង់ព្រះកន្សែង ទៀបខ្លោងទ្វារខាងក្រៅដូច្នេះ ។ បពិត្រព្រះអានន្ទដ៏ចម្រើន បានជាដូច្នោះ ព្រោះតែព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាត ឲ្យមាតុគ្រាមចេញ ចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះ តថាគត ទ្រង់សម្ដែងហើយផងសោះ ។ បពិត្រព្រះនាងគោតមី បើដូច្នោះ សូមព្រះនាងទ្រង់រង់ចាំក្នុងទីនេះសិនចុះ ទម្រាំអាត្មាភាពទៅក្រាបបង្គំទូលសុំ ព្រះដ៏មានព្រះភាគ ឲ្យមាតុគ្រាមបានចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្ដែងហើយ ។ លំដាប់នោះ

ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមីនុ៎ះ មានព្រះបាទទាំងគូពុះពង មានព្រះអង្គប្រឡាក់ធូលី កើតទុក្ខតូចព្រះហឫទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែង ទៀបខ្លោងទ្វារខាងក្រៅ ដោយជ្រាបថា ព្រះដ៏មានព្រះភាគមិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមចេញចាកផ្ទះ បានបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយ ។ ម្នាលអានន្ទ ណ្ហើយអ្នក កុំគាប់ចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសំដែងឡើយ ។ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូល ជាគម្រប់ពីរដងផង ។បេ។ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ ជាគម្រប់ ៣ ដងផងថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យដែលព្រះតថាគតទ្រង់សំដែងហើយផង ។ ម្នាលអានន្ទ ណ្ហើយ អ្នកកុំគាប់ចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យដែលតថាគតសំដែង

ឡើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្ដីត្រិះរិះដូច្នេះថា ឥឡូវនេះ ព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាត ឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់សម្ដែងហើយទេ បើដូច្នោះ គួរតែអាត្មាអញក្រាបបង្គំទូលសុំព្រះដ៏មានព្រះភាគ ដោយបរិយាយដទៃទៀត ដើម្បីឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យដែលព្រះតថាគត ទ្រង់សម្ដែងហើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មាតុគ្រាម បើចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្ដែងហើយ គួរធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលក្ដី សកទាគាមិផលក្ដី អនាគាមិផលក្ដី អរហត្តផលក្ដី បានដែរឬ ។ ម្នាលអានន្ទ មាតុគ្រាម បើចេញចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសម្ដែងហើយ ក៏គួរធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង ។ បពិត្រព្រះអង្គដ៏ចម្រើន បើមាតុគ្រាម ចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតសម្ដែងហើយ គួរធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលផង ។បេ។ អរហត្តផលផង បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី មានឧបការៈច្រើន ជាព្រះមាតុច្ឆារបស់ព្រះដ៏មានព្រះភាគ បានបីបាច់ចិញ្ចឹម កាលព្រះមាតាទ្រង់

ទិវង្គតទៅ បានបំបៅព្រះដ៏មានព្រះភាគតរៀងមក ។ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាម ចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយផង ។ ម្នាលអានន្ទ បើព្រះនាងមហាបជាបតិគោតមី ទទួលប្រតិបត្តិតាមគរុធម៌ ៨ ប្រការបាន ឧបសម្បទានោះ ចូរសម្រេចដល់ព្រះនាងចុះ ។ ( ឯគរុធម៌ ៨ ប្រការនោះ គឺ ) ភិក្ខុនីសូម្បីឧបសម្បទាបានមួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះភិក្ខុដែលទើបនឹងឧបសម្បទាក្នុងថ្ងៃនោះ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ ភិក្ខុនី មិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុឡើយ នេះជាធម៌ដែលភិក្ខុនី ត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ ភិក្ខុនី ត្រូវស្វែងរកសួរឧបោសថផង ចូលទៅស្តាប់ឱវាទផង អំពីសម្នាក់ភិក្ខុសង្ឃរាល់កន្លះខែ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ ភិក្ខុនី នៅចាំវស្សារួចហើយ ត្រូវបវារណាក្នុងសម្នាក់សង្ឃទាំង ២ ពួក ( គឺភិក្ខុសង្ឃ ១ ភិក្ខុនីសង្ឃ ១ ) ដោយឋាន ៣ យ៉ាង គឺឃើញ ឮ រង្កៀស នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ ភិក្ខុនី ត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្តក្នុងសម្នាក់សង្ឃទាំង ២ ពួក នេះជាធម៌ដែល

ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ ភិក្ខុនី ត្រូវជួយស្វែងរកឧបសម្បទាក្នុងសម្នាក់សង្ឃទាំង ២ ពួក ដល់សិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌ ៦ ប្រការគ្រប់ ២ ឆ្នាំហើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ ភិក្ខុនី មិនត្រូវជេរ មិនត្រូវប្រទេចភិក្ខុ ដោយបរិយាយណាមួយឡើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ តាំងពីថ្ងៃដែលបានឧបសម្បទានេះទៅ ភិក្ខុនីត្រូវតែស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញឡើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ ម្នាលអានន្ទ បើព្រះនាងមហាបជាបតិគោតមី ទទួលប្រព្រឹត្តតាមគរុធម៌ទាំង ៨ នេះបាន ឧបសម្បទានោះ ចូរសម្រេចដល់ព្រះនាងចុះ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានរៀនគរុធម៌ ៨ ប្រការ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ( ចាំស្ទាត់ហើយ ) ក៏ចូលទៅរកព្រះនាងមហា-បជាបតិគោតមី លុះចូលទៅដល់ហើយ ក៏ពោលទៅនឹងព្រះនាងមហាបជាបតិគោតមីដូច្នេះថា បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រតិបត្តិតាមគរុធម៌ ៨ ប្រការបាន ឧបសម្បទានោះ នឹងសម្រេចដល់ព្រះនាង ។ ( ឯគរុធម៌ ៨ ប្រការនោះ គឺ ) ភិក្ខុនី សូម្បីឧបសម្បទាបានមួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះភិក្ខុដែលទើបនឹង

បួសហើយក្នុងថ្ងៃនោះ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។បេ។ ចាប់ដើមតាំងពីថ្ងៃ ( ដែលបានឧបសម្បទា ) នេះទៅ ភិក្ខុនី ត្រូវតែស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញឡើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។ បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រតិបត្តិគរុធម៌ ៨ ប្រការនេះបាន ។ ឧបសម្បទានោះ នឹងសម្រេចដល់ព្រះនាងបាន ។ ព្រះនាងមហាបជាបតិគោតមី ឆ្លើយតបថា បពិត្រព្រះអានន្ទដ៏ចម្រើន ស្រ្តី ឬបុរស នៅក្រមុំកំលោះ ប្រកបដោយជាតិជាអ្នកស្អិតស្អាងខ្លួន មានក្បាលលុបលាងហើយ មានកម្រងផ្កាឧប្បលក្តី កម្រងផ្កាម្លិះក្តី កម្រងផ្កាដែលមានក្លិនក្រអូបណាស់ក្តី ហើយទទួលយកដោយដៃទាំងពីរ តម្កល់ទុកលើអវយវៈដ៏ឧត្តម គឺក្បាល យ៉ាងណាមិញ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំនឹងទទួលប្រតិបត្តិតាមគរុធម៌ ៨ ប្រការនេះ មិនប្រព្រឹត្តកន្លងដរាបអស់ជីវិត ក៏យ៉ាងនោះដែរ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គរុធម៌ទាំង ៨ ប្រការ ព្រះនាងមហាបជាបតិគោតមី ព្រមទទួលហើយ មិនប្រព្រឹត្តឲ្យកន្លងដរាបអស់ជីវិតទេ ។

ម្នាលអានន្ទ ប្រសិនបើមាតុគ្រាម មិនបានចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយទេ ម្នាលអានន្ទ ព្រហ្មចរិយធម៌នឹងបានតាំងនៅជាអង្វែង ព្រះសទ្ធម្ម គឺអរហត្តផលនឹងបានតាំងនៅអស់ ១ ពាន់ឆ្នាំ ។ ម្នាលអានន្ទ តែកាលណា មាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយ ម្នាលអានន្ទ ឥឡូវនេះ ព្រហ្មចរិយធម៌ នឹងមិនតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ឥឡូវនេះ ព្រះសទ្ធម្មនឹងឋិតនៅ បានត្រឹមតែប្រាំរយឆ្នាំវិញ ម្នាលអានន្ទ ត្រកូលទាំងឡាយណាមួយ ដែលមានស្រីច្រើន មានប្រុសតិច ត្រកូលទាំងនោះ ពួកចោរលួចអុជប្រទីបក្នុងក្អមឆ្នាំង ហើយគន់មើលទ្រព្យក្នុងផ្ទះអ្នកដទៃដោយពន្លឺនោះ អាចចូលមកបំផ្លាញបានដោយងាយ យ៉ាងណាមិញ ម្នាលអានន្ទ មាតុគ្រាមចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ គឺព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ មិនបានតាំងនៅយូរអង្វែងទេ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ រោគជាតិឈ្មោះសេតដ្ឋិកា ( ក្រា-ស ) ធ្លាក់ចុះក្នុងស្រែស្រូវណា ដែលកំពុងតែលូតលាស់ល្អ ស្រែស្រូវនោះ មិនបានតាំងនៅយូរអង្វែង ដោយប្រការយ៉ាងនេះ យ៉ាងណាមិញ ម្នាលអានន្ទ មាតុគ្រាម ចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ គឺព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ មិនបានតាំងនៅយូរអង្វែងទេ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ រោគជាតិឈ្មោះមញ្ជេដ្ឋិកា ( ក្រាក្រហម ) ធ្លាក់

ចុះក្នុងច្បារអំពៅណា ដែលកំពុងលូតលាស់ល្អ ច្បារអំពៅនោះ មិនបានតាំងនៅយូរអង្វែង ដោយប្រការយ៉ាងនេះ យ៉ាងណាមិញ ម្នាលអានន្ទ មាតុគ្រាមចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ គឺព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ មិនបានតាំងនៅយូរអង្វែងទេ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ បុរសប្រញាប់លើកទំនប់ទប់ទឹកស្រះដ៏ធំជាមុន ដើម្បីមិនឲ្យទឹកហូរចេញទៅជាកំណត់ យ៉ាងណាមិញ ម្នាលអានន្ទ គរុធម៌ ៨ ប្រការ ដែលតថាគត បានបញ្ញត្តហើយ ចំពោះភិក្ខុនីជាដំបូង ដើម្បីមិនឲ្យ ( ភិក្ខុនី ) ប្រព្រឹត្តកន្លង ដរាបដល់អស់ជីវិត ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា
# វគ្គដែលមិនសង្គ្រោះចូលក្នុងបណ្ណាសកៈ

## សទ្ធានវគ្គទី ១

### គោតមីសូត្រ

[ ៥១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងគោតមីសូត្រទី ១ ដូចតទៅនេះ បទថា* **សក្កេសុ វិហរតិ** *សេចក្តីថា ព្រះមានព្រះភាគយាងទៅប្រថាប់ នៅដោយការយាងគ្រាដំបូង ។ បទថា* **មហាបជាបតី** *បានដល់ មានព្រះនាមយ៉ាងនេះ ព្រោះជាធំ បជា គឺឱរស និងក្នុងបជា គឺធីតា ។ បទថា* **យេន ភគវា តេនុបសង្កមិ** *សេចក្តីថា ព្រះមានព្រះភាគយាងទៅកាន់ក្រុងកបិលពស្តុ ឲ្យនន្ទកុមារបួសមុននោះឯង ក្នុងថ្ងៃទី ៧ ទើបឲ្យរាហុលកុមារបួស កាលអ្នកនគរទាំង ២ ចំណែកចេញទៅដើម្បីត្រៀមច្បាំង ព្រោះហេតុឈ្លោះគ្នាក្នុងរឿងទឹក ព្រះសាស្តាយាងទៅ ធ្វើស្តេចទាំងនោះឲ្យស្រុះស្រួលគ្នា ហើយត្រាស់អត្តទណ្ឌសូត្រ ។ ស្តេចទាំងឡាយទ្រង់ជ្រះថ្លាហើយ បានប្រគេនរាជ-កុមារមួយចំណែក ២៥០ អង្គ ។ រាជកុមារ ៥០០ អង្គនោះបួសក្នុងសម្នាក់ព្រះសាស្តាហើយ ។ លំដាប់នោះ ព្រះជាយារបស់លោកទាំងនោះ បញ្ជូនដំណឹងទៅ ធ្វើឲ្យកើតការមិនត្រេកអរក្នុងការបួស ។ ព្រះសាស្តាទ្រង់ជ្រាបថា ភិក្ខុទាំងនោះកើតនូវការមិនត្រេកអរ ទើបនាំភិក្ខុកំលោះ ៥០០ រូបនោះ*

ទៅកាន់ស្រះឈ្មោះកុណាល ប្រថាប់គង់លើផ្ទាំងថ្ម ដែលទ្រង់ធ្លាប់អាស្រ័យប្រថាប់គង់ក្នុងកាលដែលព្រះអង្គ សោយព្រះជាតិជាសត្វតាវៅ ។ បន្ទោបង់នូវការមិនត្រេកអររបស់ភិក្ខុទាំងនោះ ដោយកុណាលជាតក ហើយឲ្យភិក្ខុទាំងឡាយនោះ តាំងនៅក្នុងសោតាបត្តិផល ហើយនាំត្រឡប់មកកាន់ព្រៃមហាវ័នម្តងទៀត ឲ្យតាំងនៅក្នុងអរហត្តផល ដូច្នេះ ដើម្បីជ្រាបចិត្តនៃភិក្ខុទាំងនោះ ទើបព្រះជាយាទាំងឡាយ បញ្ជូនដំណឹងទៅម្តងទៀត ភិក្ខុទាំងនោះបញ្ជូនសាសន៍តបទៅថា ពួកអាត្មាមិនគួរនៅគ្រប់គ្រងផ្ទះទេ ។ ព្រះនាងទាំងនោះត្រិះរិះថា ឥឡូវនេះ ពួកយើងមិនគួរត្រឡប់ទៅកាន់ផ្ទះឡើយ យើងនឹងទៅកាន់សម្នាក់ព្រះនាងមហាបជាបតិ អនុញ្ញាតបព្វជ្ជា ហើយនឹងបួស ។ ស្ត្រីទាំង ៥០០ ចូលទៅគាល់ព្រះនាងមហាបជាបតិទូលថា បពិត្រព្រះនាង សូមព្រះនាងអនុញ្ញាតឲ្យខ្ញុំម្ចាស់ទាំងឡាយបួសចុះ ។ ព្រះនាងមហាបជាបតិនាំស្រីទាំងនោះទៅគាល់ព្រះមានព្រះភាគ ។ អាចារ្យពួកខ្លះពោលថា ចូលទៅគាល់ក្នុងកាលដែលព្រះរាជាបរិនិព្វានខាងក្រោមស្វេតច្ឆត្រ ដូច្នេះក៏មាន ។ សួរថា ហេតុអ្វី ព្រះមានព្រះភាគឃាត់ថា ម្នាលនាងគោតមី នាងកុំគាប់ចិត្តទៅឡើយ ព្រះពុទ្ធគ្រប់អង្គ រមែងមានបរិស័ទ ៤ មិនមែនឬ ។ ថ្វីដ្បិតមានក៏ពិត តែទ្រង់មានបំណងធ្វើឲ្យធ្ងន់ ហើយសឹមអនុញ្ញាត ទើបទ្រង់ហាម ដោយទ្រង់ព្រះតម្រិះថា ស្រីទាំងនោះនឹងរក្សាដោយប្រពៃនូវបព្វជ្ជា ដែលតថាគតត្រូវនាងអង្វរច្រើនដង កាលអនុញ្ញាត ត្រូវអនុញ្ញាតដោយសេចក្តីលំបាក ឲ្យ

នាងគិតថា អញបានបួសដោយសេចក្ដីលំបាក ។ បទថា **បក្កាមិ** សេចក្ដីថា ទ្រង់ចូលទៅកាន់ក្រុងកបិលពស្តុនោះឯងម្ដងទៀត ។ បទថា **យថាភិរន្តំ វិហរិត្វា** សេចក្ដីថា ទ្រង់ប្រមើលមើលឧបនិស្ស័យនៃសត្វដែលអាចត្រាស់ដឹង ទើបនៅប្រថាប់តាមព្រះអធ្យាស្រ័យ ។ បទថា **ចារិកំ បក្កាមិ** សេចក្ដីថា កាលទ្រង់ធ្វើការសង្គ្រោះមហាជន ទើបយាងចារិកដោយមិនប្រញាប់ ប្រកបដោយពុទ្ធសិរីដ៏ប្រសើរ ដោយពុទ្ធវិលាស ដែលគ្មានអ្វីប្រៀបបាន ។

បទថា **សម្ពហុលាហិ សាកិយានីហិ សទ្ធឹ** សេចក្ដីថា ព្រះនាងមហាបជាបតីកាន់យកភេទបព្វជ្ជា ឧទ្ទិសចំពោះព្រះទសពល ខាងក្នុងព្រះរាជនិវេសន៍នោះឯង ហើយធ្វើសាកិយានីទាំង ៥០០ នោះ ឲ្យកាន់យកភេទបព្វជ្ជាដូចគ្នា ហើយចៀសចេញទៅ មួយអន្លើជាមួយសាកិយានីទាំងនោះ ។ បទថា **បក្កាមិ** បានដល់ ព្រះនាងយាងទៅ ។ ក្នុងពេលដែលព្រះនាងមហាបជាបតីនោះទ្រង់យាងទៅ ម្ចាស់ក្សត្រិយជាសុខុមាលជាតិ មិនអាចយាងទៅដោយព្រះបាទបាន ព្រោះហេតុនោះ ទើបស្ដេចសក្យៈ និងស្ដេចកោលិយៈ រៀបចំវមាសបញ្ជូនទៅ ។ សាកិយានីទាំងនោះគិតថា បើអញឡើងយានទៅ ឈ្មោះថា មិនគោរពក្នុងព្រះសាស្ដា ដូច្នេះហើយ ទើបប្រើព្រះបាទយាងទៅ អស់ចម្ងាយផ្លូវ ៥១ យោជន៍ ។ ចំណែកព្រះអង្គម្ចាស់ទាំងឡាយ បានរៀបចំការរក្សាតាមក្រោយ ផ្ទុកអង្ករ សប្បិ និងប្រេងជាដើមពេញរទេះ ហើយបញ្ជូនបុរសទាំងឡាយទៅ ដោយប្រាប់ថា ពួកអ្នកចូររៀបចំអាហារក្នុងទីដែល

សាកិយានីទាំងនោះទៅ ។ បទថា **សូនេហិ ចាទេហិ** សេចក្តីថា ព្រោះសាកិយានីទាំងនោះ ជាសុខុមាលជាតិ ពងបែកត្រង់បាទាទាំង ២ គ្រាប់ ១ បែកទៅ គ្រាប់ ១ ក៏ផុសឡើងមក ព្រះបាទាទាំងពីរពុះពង ដូចគ្រាប់នៃផ្លែល្ហុង ។ ព្រោះហេតុនោះ ទើបព្រះអានន្ទក្រាបទូលថា **សូនេហិ ចាទេហិ** ដូច្នេះ ។ បទថា **ពហិទ្វារកោដ្ឋកេ** បានដល់ ខាងក្រៅខ្លោងទ្វារ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះនាងមហាបជាបតិនៅឈរយ៉ាងនោះ ។ ឆ្លើយថា បានឮថា ព្រះនាងមហាបជាបតិមានការគិតយ៉ាងនេះថា អាត្មាអញ ព្រះតថាគតមិនអនុញ្ញាត ហើយកាន់យកភេទបព្វជ្ជាដោយខ្លួនឯង ការដែលអញកាន់យកភេទបព្វជ្ជាយ៉ាងនេះ កើតប្រាកដទូទៅពេញជម្ពូទ្វីប បើព្រះសាស្តាទ្រង់អនុញ្ញាតឲ្យអញបួសសោត សេចក្តីនោះជាការល្អ បើទ្រង់មិនអនុញ្ញាតទេ នឹងមានការនិន្ទាដ៏ធំ ទើបមិនអាចចូលទៅកាន់វិហារ ឈរយំនៅខាងក្រៅ ។

បទថា **កឹ នុ ត្វំ គោតមិ** សេចក្តីថា ការវិបត្តិនៃរាជត្រកូលកើតឡើងហើយឬហ្ន៎ ព្រោះហេតុអ្វី ទើបទ្រទ្រង់ភាវៈប្លែកយ៉ាងនេះ គឺមានជើងហើម ។បេ។ ប្រឡាក់ឈរហើយ ។បេ។ បទថា **អញ្ញេនបិ បរិយាយេន** បានដល់ ដោយហេតុដទៃ ។ ព្រះអានន្ទពោលព្រះគុណរបស់ព្រះនាងមហាបជាបតិនោះ ដោយពាក្យជាដើមថា ព្រះនាងមហាបជាបតិមានឧបការៈច្រើនព្រះអង្គ ដូច្នេះ ។ កាលនឹងទូលសូមបព្វជ្ជាម្តងទៀត ទើបបានទូលយ៉ាងនោះ ។ ព្រះសាស្តា កាលទ្រង់ព្រះតម្រិះថា ធម្មតាស្រីទាំងឡាយ មានបញ្ញាតិច បើ

*តថាគតអនុញ្ញាតការបួស ដោយហេតុត្រឹមតែការទូលសូមម្តងប៉ុណ្ណោះ ក៏មិនកាន់យកពាក្យប្រៀនប្រដៅរបស់តថាគតឲ្យស៊ប់សួនបាន ដូច្នេះហើយ ទើបទ្រង់ឃាត់ដល់ទៅ ៣ ដង ឥឡូវនេះ ព្រោះនាងបំណងនឹងកាន់យកពាក្យប្រៀនប្រដៅរបស់តថាគតឲ្យស៊ប់សួន ទើបត្រាស់ពាក្យជាដើមថា ម្នាលអានន្ទ បើមហាបជាបតិគោតមីព្រមទទួលគរុធម៌ ៨ ប្រការសោត ការទទួលគរុធម៌នោះឯង ចូរជាឧបសម្បទារបស់នាង ។ បណ្តាបទទាំងនោះ បទថា* **សាវស្សា** *សេចក្តីថា ការទទួលគរុធម៌នោះឯង ជាបព្វជ្ជាផង ជាឧបសម្បទាផងរបស់នាង ។*

*បទថា* **តទហុបសម្បន្នស្ស** *ប្រែថា ដែលឧបសម្បទាក្នុងថ្ងៃនោះ ។ បទថា* **អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កាតព្វំ** *សេចក្តីថា ភិក្ខុនី មិនធ្វើការមើលងាយខ្លួនឯង និងមើលងាយអ្នកដទៃ ធ្វើការថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ធ្វើការក្រោកឡើង ដោយអំណាចក្រោកឡើងចាកអាសនៈ ចេញទៅទទួល ប្រគំប្រមាមទាំង ១០ ហើយសំពះ ។ ការធ្វើសាមីចិកម្ម ពោល គឺកម្មដ៏សមគួរ មានការក្រាលអាសនៈ និងការបក់ផ្លិតជាដើម ។ បទថា* **អភិក្ខុកេ អាវាសេ** *សេចក្តីថា មិនមានអាចារ្យអ្នកឲ្យឱវាទ ដោយមិនមានអន្តរាយ សម្រាប់ភិក្ខុនីដែលនៅក្នុងអាវាសណា អាវាសនេះឈ្មោះថា អាវាសមិនមានភិក្ខុ ។ ភិក្ខុនីមិនគួរចាំវស្សាក្នុងអាវាសបែបនេះ ។ បទថា* **អន្វឌ្ឍមាសំ** *ប្រែថា គ្រប់ឧបោសថ ។ បទថា* **ឱវាទូបសង្កមនំ** *ប្រែថា ចូល*

ទៅដើម្បីឱវាទ ។ បទថា **ទិដ្ឋេន** ប្រែថា ឃើញដោយភ្នែក ។ បទថា **សុតេន** ប្រែថា ដោយឮនឹងត្រចៀក ។ បទថា **បរិសង្កាយ** ប្រែថា ដោយរង្កៀស ព្រោះការឃើញ និងការឮ ។ បទថា **គរុធម្មំ** បានដល់ អាបត្តិធ្ងន់ គឺអាបត្តិសង្ឃាទិសេស ។ បទថា **បក្ខមានត្តំ** បានដល់ ភិក្ខុនី គប្បីប្រព្រឹត្តមានត្តពេញ ១៥ ថ្ងៃ ។ បទថា **ឆសុ ធម្មេសុ** បានដល់ ក្នុងសិក្ខាបទទាំងឡាយ មានវិកាលភោជនសិក្ខាបទ ជាគម្រប់ ៦ ។ បទថា **សិក្ខិតសិក្ខាយ** បានដល់ បំពេញសិក្ខាដោយមិនឲ្យដាច់ សូម្បីតែសិក្ខាបទ ១ ។ បទថា **អក្កោសិតព្វោ បរិភាសិតព្វោ** សេចក្តីថា ភិក្ខុនីមិនគប្បីជេរ ភិក្ខុដោយអក្កោសវត្ថុ ១០ ប្រការណាមួយ មិនគប្បីបរិភាស ដោយការ បរិភាសណាមួយ អាងដល់វត្ថុដែលគួរខ្លាច ។ បទថា **ឱវដោ ភិក្ខុនីនំ ភិក្ខូសុ វចនបថោ** សេចក្តីថា គន្លងនៃពាក្យ គឺឱវាទ អនុសាសនី និង ធម្មកថា ដែលភិក្ខុនីមិនគួរប្រៀនប្រដៅក្នុងភិក្ខុទាំងឡាយ គឺភិក្ខុនីមិនគួរឲ្យ ឱវាទ មិនគួរឲ្យអនុសាសន៍ភិក្ខុណាមួយឡើយ តែភិក្ខុនីគួរពោលតាម ប្រពៃណីយ៉ាងនេះថា បពិត្រលោកម្ចាស់ ព្រះថេរៈក្នុងកាលមុន បានបំពេញ វត្ត ដូច្នេះៗ មក ។

បទថា **អនោវដោ ភិក្ខូនំ ភិក្ខុនីសុ វចនបថោ** សេចក្តីថា ភិក្ខុទាំង-ឡាយមិនហាមពាក្យដែលជាគន្លងក្នុងភិក្ខុនីទាំងឡាយ គឺភិក្ខុទាំងឡាយចូរឲ្យ ឱវាទ ចូរឲ្យអនុសាសន៍ ចូរពោលធម្មកថាតាមគាប់ចិត្ត ដោយសង្ខេប ក្នុង

សេចក្ដីនេះ មានដូចពោលមកនេះ ។ តែកាលពោលដោយពិស្ដារ គប្បីពោលដោយគរុធម៌នោះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងអដ្ឋកថាព្រះវិន័យ ឈ្មោះថា សមន្តប្បាសាទិកានោះឯង ។

ទោមនស្សដ៏ធំរបស់ព្រះនាងបជាបតិស្ងប់មួយរំពេច ព្រោះបានស្ដាប់គរុធម៌ ៨ ប្រការនេះ ដែលព្រះថេរៈរៀនក្នុងសម្នាក់ព្រះសាស្ដា ហើយមកទូលដល់ព្រះនាង ព្រះនាងប្រាសចាកសេចក្ដីក្រវល់ក្រវាយ មានចិត្តត្រេកអរហាក់ដូចស្រោចចុះលើព្រះសិរសាដោយទឹក ១០០ ក្អម ដែលនាំមកអំពីអនោតត្តស្រះ កាលនឹងធ្វើឲ្យជាក់ច្បាស់នូវបីតិ និងបាមោជ្ជដែលកើតឡើងព្រោះទទួលគរុធម៌ ទើបបន្លឺឧទានជាដើមថា **សេយ្យថាបិ ភន្តេ** ដូច្នេះ ។

បទថា **កុម្ភត្ថេនកេហិ** សេចក្ដីថា ដែលចោរដុតភ្លើងក្នុងថ្នាំង ហើយជ្រើសរើសយករបស់ក្នុងផ្ទះរបស់បុគ្គល ដែលភ្លឺដោយពន្លឺនោះ លួចទៅ ។ បទថា **សេតដ្ឋិកា នាម រោគជាតិ** សេចក្ដីថា ក្អួរស្រូវសូម្បីចេញអំពីដើមស្រូវ ដែលត្រូវដង្កូវតូចៗ ចោះដល់កណ្ដាលទង ក៏មិនអាចមានទឹកដោះបាន ។ បទថា **មញ្ជេដ្ឋិកា នាម រោគជាតិ** បានដល់ ខាងក្នុងដើមអំពៅដែលមានពណ៌ក្រហម ។

ដោយបទថា **មហតោ តឡាកស្ស បដិកច្ចេវ ទាឡឹ** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងសេចក្ដីនេះថា ឧបមាដូចកាលចូលទៅលើកទំនប់ធ្វើស្រះធំ ទឹកតិចតួចក៏មិនដក់នៅឡើយ តែកាលបិទគ្រាដំបូងនោះឯង ទឹកណា

ដែលមិនដក់ ព្រោះមិនបិទដោយបច្ច័យ ទឹកនោះក៏គប្បីដក់បាន យ៉ាងណា គរុធម៌ទាំងនេះ ក៏ដូច្នោះដូចគ្នា តថាគតបញ្ញត្តមុន ដើម្បីជាប្រយោជន៍មិនឲ្យភិក្ខុនីគិតល្មើសក្នុងរឿងដែលមិនទាន់កើតឡើង ព្រោះកាលតថាគតមិនបញ្ញត្តគរុធម៌ទាំងនោះ ព្រោះមាតុគ្រាមបួស ព្រះសទ្ធម្មគប្បីតាំងនៅបាន ៥០០ ឆ្នាំ តែគរុធម៌នេះ ដែលតថាគតបញ្ញត្តមុន ព្រះសទ្ធម្មនឹងតាំងនៅបាន ៥០០ ឆ្នាំទៀត រួមសេចក្តីថា ព្រះសទ្ធម្មនឹងតាំងនៅបានដល់ទៅ ១០០០ ឆ្នាំ ទើបបានត្រាស់ទុកមុន ដូចពោលមកនេះឯង ។

ពាក្យថា **វស្សសហស្សំ** នេះ ត្រាស់ដោយបំណងដល់ព្រះខីណាស្រពដែលសម្រេចបដិសម្ភិទាប៉ុណ្ណោះ តែកាលពោលឲ្យក្រៃលែងទៅជាងនោះ ១ ពាន់ឆ្នាំ ដោយបំណងដល់ព្រះខីណាស្រព ដែលជាសុក្ខវិបស្សក: ១ ពាន់ឆ្នាំ ដោយបំណងដល់ព្រះអនាគាមី ១ ពាន់ឆ្នាំ ដោយបំណងដល់ព្រះសកទាគាមី ១ ពាន់ឆ្នាំ ដោយបំណងដល់ព្រះសោតាបន្ន បដិវេធសទ្ធម្មនឹងតាំងនៅបាន ៥០០០ ឆ្នាំដោយអាការដូចពោលមកនេះ សូម្បីព្រះបរិយត្តិធម៌ ក៏តាំងនៅបាន ៥០០០ ឆ្នាំនោះដូចគ្នា ។ ព្រោះកាលបរិយត្តិធម៌មិនមាន បដិវេធនឹងមានមកអំពីណា កាលបរិយត្តិធម៌មិនមាន បដិវេធធម៌ក៏មិនមាន កាលបរិយត្តិធម៌អន្តរធានទៅហើយ ភេទក៏នឹងប្រែប្រួលអស់ទៅ ។ល។

**អដ្ឋកថាគោតមីសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ឱវាទសូត្រ ២

[ ៥២ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារសាលា នាមហាវ័ន ក្បែរក្រុងវេសាលី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រកបដោយធម៌ប៉ុន្មាន ដែលសង្ឃគួរសន្មត ជាអ្នកឲ្យឱវាទដល់នាងភិក្ខុនីបាន ។ ម្នាលអានន្ទ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ ទើបសង្ឃគួរសន្មត ជាអ្នកឲ្យឱវាទដល់នាងភិក្ខុនីបាន ។ ប្រកបដោយធម៌ទាំង ៨ ប្រការ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកចេះចាំច្រើន ។បេ។ យល់ត្រឹមត្រូវដោយទិដ្ឋិ ១ បាតិមោក្ខទាំងពីរ ភិក្ខុនោះក៏ចេះចាំដោយសេចក្តីពិស្តារ ចែកចេញដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីបានដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈ ១ ជាអ្នកមានវាចាពីរោះ ពោលពាក្យពីរោះ ប្រកបដោយវាចាអ្នកក្រុង ជាវាចាក្បោះក្បាយមិនមានទោស អាចញ៉ាំងអ្នកផងឲ្យដឹងច្បាស់សេចក្តី ១ ជាអ្នកអង់អាច ដើម្បីញ៉ាំងភិក្ខុនីសង្ឃ ឲ្យយល់ ឲ្យប្រតិបត្តិតាម ឲ្យក្លាហាន ឲ្យជ្រះថ្លាដោយធម្មីកថា ១ ជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃនាងភិក្ខុនីទាំងឡាយដោយច្រើន ១ ជាអ្នកមិនធ្លាប់ត្រូវគរុកាបត្តិ ដោយនាងភិក្ខុនី ដែលស្លៀក

សំពត់ជ្រលក់ដោយទឹកអម្ចត់ បួសចំពោះព្រះដ៏មានព្រះភាគអង្គនុ៎ះ ១ ជាអ្នកមានវស្សា ២០ ឬមានវស្សាច្រើនជាង ២០ ឡើងទៅ ។ ម្នាលអានន្ទ ភិក្ខុប្រកបដោយធម៌ទាំង ៨ ប្រការនេះឯង ទើបសង្ឃគួរសន្មតជាអ្នកឲ្យឱវាទដល់នាងភិក្ខុនីបាន ។

# អដ្ឋកថា

## ឱវាទសូត្រ

[ ៥២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឱវាទសូត្រទី ២ ដូចតទៅនេះ ក្នុងបទថា **ពហុស្សុតោ** នេះ គប្បីជ្រាបភាពដែលភិក្ខុជាពហូស្សូត ដោយអំណាចពុទ្ធវចនៈទាំងអស់ ។ បទថា **គរុធម្មំ** បានដល់ កាយសំសគ្គៈ គឺការចាប់ពាល់កាយ សេចក្តីសង្ខេបក្នុងសូត្រនេះ មានប្រមាណប៉ុណ្ណេះ ឯវិនិច្ឆ័យដល់ភិក្ខុដែលឲ្យឱវាទដល់ភិក្ខុនី គប្បីជ្រាបដោយន័យដែលពោលក្នុងអដ្ឋកថាវិន័យ ឈ្មោះសមន្តប្បាសាទិកានោះឯង ។

**អដ្ឋកថា ឱវាទសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សង្ខិត្តសូត្រទី ៣

[ ៥៣ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារសាលា នាមហាវ័ន ក្បែរក្រុងវេសាលី ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមីចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគរួចហើយ ក៏ឋិតនៅក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី ឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សំដែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ព្រោះថា ខ្ញុំព្រះអង្គបានស្តាប់ធម៌ព្រះដ៏មានព្រះភាគហើយ គប្បីចៀសចេញទៅតែម្នាក់ឯង មិនប្រមាទ មានសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ( មិនខាន ) ។ ម្នាលនាងគោតមី នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅ ដើម្បីប្រកបដោយតម្រេក មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក ប្រព្រឹត្តទៅ ដើម្បីប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកការប្រកបក្នុងវដ្តៈ ប្រព្រឹត្តទៅ ដើម្បីការសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីមិនមានការសន្សំកិលេសវដ្តៈ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាតិច ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសន្តោស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសន្តោស ប្រព្រឹត្តទៅ ដើម្បីច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅ ដើម្បីស្ងាត់ចាកពួក ប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅ ដើម្បីប្រារព្ធសេចក្តីព្យាយាម ប្រព្រឹត្ត

ទៅ ដើម្បីឲ្យគេចិញ្ចឹមក្រ មិនប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមងាយ ។ ម្នាលនាងគោតមី នាងគប្បីចាំទុកដោយពិតចុះថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាទេ ។ ម្នាលនាងគោតមី មួយទៀត នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីប្រកបដោយតម្រេក ប្រព្រឹត្តទៅ ដើម្បីប្រាសចាកការប្រកបក្នុងវដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីការប្រកបក្នុងវដ្ដៈ ប្រព្រឹត្តទៅ ដើម្បីមិនមានការសន្សំកិលេសវដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីការសន្សំកិលេសវដ្ដៈ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាតិច មិនប្រព្រឹត្តទៅ ដើម្បីប្រាថ្នាច្រើន ប្រព្រឹត្តទៅ ដើម្បីសេចក្តីសន្តោស មិនប្រព្រឹត្តទៅ ដើម្បីមិនសន្តោស ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងាត់ចាកពួក មិនប្រព្រឹត្តទៅ ដើម្បីប្រឡូកប្រឡំដោយពួក ប្រព្រឹត្តទៅ ដើម្បីប្រារព្ធសេចក្តីព្យាយាម មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស ប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមងាយ មិនប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមក្រ ។ ម្នាលនាងគោតមី នាងគប្បីចាំទុក ដោយពិតចុះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាហើយ ។

# អដ្ឋកថា

## សន្ធិត្តសូត្រ

[ ៥៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសន្និត្តសូត្រទី ៣ ដូចតទៅនេះ បទថា **សភាគាយ** ប្រែថា ដើម្បីប្រកបដោយតម្រេក ។ បទថា **វិភាគាយ** ប្រែថា ដើម្បីប្រាសចាកតម្រេក ។ បទថា **សំយោគាយ** បានដល់ ដើម្បីប្រកបសត្វក្នុងវដ្ដៈ ។ បទថា **វិសំយោគាយ** សេចក្ដីថា ដើម្បីការមិនប្រកបសត្វក្នុងវដ្ដៈ ។ បទថា **អាចយាយ** បានដល់ ដើម្បីធ្វើវដ្ដៈឲ្យវែងឆ្ងាយ ។ បទថា **នោ អបចយាយ** បានដល់ មិនមែនដើម្បីការពង្រីកវដ្ដៈ ។ បទថា **ទុក្ខរតាយ** ប្រែថា ដើម្បីការចិញ្ចឹមក្រ ។ បទថា **នោ សុភរតាយ** ប្រែថា មិនមែនដើម្បីចិញ្ចឹមងាយ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់វដ្ដៈដោយបឋមវារៈ តែក្នុងទុតិយវារៈត្រាស់វិវដ្ដៈ ។ ឯព្រះនាងគោតមីសម្រេចអរហត្ត ដោយព្រះឱវាទនេះឯង ។

**អដ្ឋកថា សន្ធិត្តសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ទីឃជាណុសូត្រទី ៤

[ ៥៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងនិគម ឈ្មោះកក្ករបត្តៈ របស់កោឡិយក្សត្រ ក្នុងដែនកោឡិយៈ ។ គ្រានោះ ទីឃជាណុ-

កោឡិយបុត្រ ( កោឡិយបុត្រឈ្មោះទីឃជាណុ ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំ ព្រះដ៏មានព្រះភាគរួចហើយ អង្គុយក្នុងទីសមគួរ ។ លុះទីឃជាណុកោឡិយបុត្រ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គជាគ្រហស្ថ បរិភោគកាម តែងគ្រប់គ្រងទីដំណេកចង្អៀតចង្អល់ដោយកូនប្រពន្ធ ប្រោះព្រំនូវលម្អិតនៃខ្លឹមចន្ទន៍ ពីដែនកាសី ទ្រទ្រង់ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ត្រេកអរនូវមាស និងប្រាក់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម៌បែបនោះ ដល់យើងខ្ញុំទាំងឡាយនោះ ជាធម៌ប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ដើម្បីសេចក្ដីសុខក្នុងបច្ចុប្បន្ន ដើម្បីប្រយោជន៍ក្នុងបរលោក ដើម្បីសេចក្ដីសុខក្នុងបរលោក ដល់យើងខ្ញុំព្រះអង្គ ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំងឡាយ ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ដើម្បីសេចក្ដីសុខក្នុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្ដេច ។ គឺឧដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ ។ ម្នាលព្យគ្ឃបជ្ជៈ ចុះឧដ្ឋានសម្បទា តើដូចម្ដេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រ ក្នុងលោកនេះ ចិញ្ចឹមជីវិត ដោយការប្រឹងប្រែង ក្នុងការងារណា ទោះគួរកសិកម្មក្ដី ជួញប្រែក្ដី រក្សាគោក្ដី ការងាររបស់ខ្មាន់ធ្នូក្ដី ការងាររបស់រាជបុរសក្ដី សិល្បៈណាមួយក្ដី ជាអ្នកប៉ិនប្រសប់ ក្នុងការងារទាំងនោះ មិនខ្ជិលច្រអូស ប្រកបដោយឧបាយ ជាគ្រឿងពិចារណាក្នុងការងារទាំង

នោះថា គួរធ្វើ គួរចាត់ចែង ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា ឧដ្ឋានសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះអារក្ខសម្បទា តើដូចម្ដេច ។ ម្នាលព្យគ្ឃបជ្ជៈ ភោគៈទាំងឡាយ ដែលកុលបុត្រក្នុងលោកនេះ បានមកដោយកម្លាំងព្យាយាម ប្រឹងប្រែង សន្សំដោយកម្លាំងដៃ បែកញើសហូរញើស ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ កុលបុត្រនោះ បានញុំាងភោគៈទាំងនោះ ឲ្យសម្រេចដោយការរក្សាគ្រប់គ្រង ដោយគិតថា ធ្វើដូចម្ដេច កុំឲ្យស្ដេចទាំងឡាយ នាំយកភោគៈទាំងនេះ របស់អាត្មាអញទៅបាន កុំឲ្យពួកចោរលួចទៅបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកបន្សាត់ទៅបាន កុំឲ្យពួកទាយាទ មិនជាទីស្រឡាញ់ ដណ្ដើមយកទៅបាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា អារក្ខសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះកល្យាណមិត្តតា តើដូចម្ដេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ នៅអាស្រ័យក្នុងស្រុក ឬនិគមណា ពួកជនណា ទោះគហបតីក្ដី គហបតិ-បុត្រក្ដី ក្មេងតែចម្រើនដោយសីលក្ដី ចាស់ហើយ តែចម្រើនដោយសីលក្ដី បរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយសីល បរិបូណ៌ដោយចាគៈ បរិបូណ៌ដោយបញ្ញា ដែលនៅក្នុងស្រុក ឬនិគមនោះ កុលបុត្រនោះតែងឈរ ចរចា សាកច្ឆាជាមួយនឹងពួកជនទាំងនោះ តែងសិក្សានូវសទ្ធាសម្បទា នឹងពួកជនអ្នកបរិបូណ៌ដោយសទ្ធាតាមសមគួរ សិក្សានូវសីលសម្បទា នឹងពួកជនអ្នកបរិបូណ៌ដោយសីល តាមសមគួរ សិក្សានូវចាគសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយចាគៈ តាមសមគួរ សិក្សានូវបញ្ញាសម្បទា នឹងពួកជនអ្នកបរិបូណ៌ដោយ

បញ្ញា តាមសមគួរ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា កល្យាណមិត្តតា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះសមជីវិតា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ ដឹងច្បាស់នូវការចម្រើននៃភោគៈទាំងឡាយផង ដឹងច្បាស់នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ។ ម្នាលព្យគ្ឃបជ្ជៈ ប្រៀបដូចជនអ្នកថ្លឹងជញ្ជីងក្តី កូនសិស្សនៃជនអ្នកថ្លឹងជញ្ជីងក្តី លើកនូវជញ្ជីង ថ្លឹងហើយក៏ដឹងថា ទន់ទៅខាងម្ខាងផង បះឡើងខាងម្ខាងផង យ៉ាងណាមិញ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រអ្នកដឹងច្បាស់នូវការចម្រើន នៃភោគៈទាំងឡាយផង ដឹងច្បាស់នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់អាត្មាអញនឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្យគ្ឃបជ្ជៈ ប្រសិនបើកុលបុត្រនេះមានសេចក្តីចម្រើនតិច ហើយចិញ្ចឹមជីវិតច្រើនលើសលុប អ្នកផងតែងនិយាយ ដល់កុលបុត្រនោះថា កុលបុត្រនេះ បរិភោគនូវភោគៈទាំងឡាយ ដូចជាគេស៊ីផ្លែល្វា ។ ម្នាលព្យគ្ឃបជ្ជៈ ប្រសិនបើកុលបុត្រនេះ មានសេចក្តីចម្រើនធំ ហើយចិញ្ចឹមជីវិតដោយក្បិតក្បៀត អ្នកផងទាំងឡាយ រមែងនិយាយដល់កុលបុត្រ

នោះថា កុលបុត្រនេះ មុខជានឹងស្លាប់ៗ ដោយឥតទីពឹង ។ ម្នាលព្យគ្ឃបជ្ជៈ កាលណា កុលបុត្រនេះដឹងច្បាស់នូវសេចក្តីចម្រើន នៃភោគៈទាំងឡាយផង ដឹងច្បាស់នូវសេចក្តីវិនាសនៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់អាត្មាអញនឹងគ្របសង្កត់នូវសេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា សមជីវិតា ។ ម្នាលព្យគ្ឃបជ្ជៈ កាលដែលភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីវិនាស ៤ យ៉ាង គឺជាអ្នកលេងស្រី ១ លេងសុរា ១ លេងល្បែងភ្នាល់ ១ មានមិត្រដ៏លាមក មានសម្លាញ់ដ៏លាមក សមគប់នឹងបុគ្គលដ៏លាមក ១ ។ ម្នាលព្យគ្ឃបជ្ជៈ ដូចស្រះទឹកដ៏ធំ មានផ្លូវនៃសេចក្តីចម្រើន ៤ យ៉ាងផង មានប្រធាននៃសេចក្តីវិនាស ៤ យ៉ាងផង បុរសគប្បីបិទខ្ទប់នូវផ្លូវនៃសេចក្តីវិនាសទាំងនោះ របស់ស្រះនោះក្តី គប្បីបើកបង្ហូរនូវផ្លូវនៃសេចក្តីវិនាសទាំងនោះ របស់ស្រះនោះក្តី ទាំងភ្លៀង ក៏មិនបង្អុរនូវធារទឹក ដោយប្រពៃក្តី ម្នាលព្យគ្ឃបជ្ជៈ កាលបើយ៉ាងនេះហើយ ស្រះដ៏ធំនោះនឹងមានសេចក្តីសាបសូន្យជាប្រាកដ មិនមានសេចក្តីចម្រើនឡើយ យ៉ាងណាមិញ ម្នាលព្យគ្ឃបជ្ជៈ កាលភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីវិនាស ៤ យ៉ាង គឺជាអ្នកលេងស្រី ១ លេងសុរា ១ លេងល្បែងភ្នាល់ ១ មានមិត្រដ៏លាមក មានសម្លាញ់ដ៏លាមក សមគប់នឹង

បុគ្គលដ៏លាមក ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្យគ្ឃបជ្ជៈ កាលបើភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ ប្រធាននៃសេចក្តីចម្រើន ៤ យ៉ាង គឺជាអ្នកមិនលេងស្រី ១ មិនលេងសុរា ១ មិនលេងល្បែងភ្នាល់ ១ មានមិត្រល្អ មានសម្លាញ់ល្អ សមគប់នឹងបុគ្គលល្អ ១ ក៏មានឡើង ។ ម្នាលព្យគ្ឃបជ្ជៈ ដូចស្រះដ៏ធំ មានផ្លូវនៃសេចក្តីចម្រើន ៤ យ៉ាងផង មានប្រធាននៃសេចក្តីវិនាស ៤ យ៉ាងផង បុរសគប្បីបើកបង្ហូរនូវផ្លូវនៃសេចក្តីចម្រើនទាំងនោះ របស់ស្រះនោះផង គប្បីបិទនូវផ្លូវនៃសេចក្តីវិនាសទាំងនោះ របស់ស្រះនោះផង ទាំងភ្លៀង ក៏បង្អុរចុះនូវធារទឹក ដោយប្រពៃផង ម្នាលព្យគ្ឃបជ្ជៈ កាលបើយ៉ាងនេះហើយ សេចក្តីចម្រើនរបស់ស្រះនោះនឹងមានប្រាកដ មិនមានសេចក្តីសាបសូន្យឡើយ យ៉ាងណាមិញ ម្នាលព្យគ្ឃបជ្ជៈ កាលបើភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីចម្រើន ៤ យ៉ាង គឺអ្នកមិនលេងស្រី ១ មិនលេងសុរា ១ មិនលេងល្បែងភ្នាល់ ១ មានមិត្រល្អ មានសម្លាញ់ល្អ សមគប់នឹងបុគ្គលដ៏ល្អ ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំង-ឡាយ ៤ ប្រការនេះឯង ប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខក្នុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំងឡាយ ៤ ប្រការនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងបរលោក ដើម្បីសេចក្តីសុខក្នុងបរលោក ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្តេច ។ គឺសទ្ធាសម្បទា ១ សីល-សម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលព្យគ្ឃបជ្ជៈ ចុះសទ្ធា-

សម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ ជាអ្នកមាន សទ្ធា ជឿការត្រាស់ដឹងនៃព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់ លែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា សទ្ធា-សម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ វៀរចាកសុរា-មេរយមជ្ជប្បមាទដ្ឋាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា សីលសម្បទា ។ ម្នាល ព្យគ្ឃបជ្ជៈ ចុះចាគសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុង លោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មាន ទានបរិច្ចាគរួចស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរ ដល់សូម ត្រេកអរក្នុងការចែករំលែកនូវទាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា ចាគសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះបញ្ញាសម្បទា តើដូចម្តេច ។ ម្នាល ព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ មានប្រាជ្ញាប្រកបដោយប្រាជ្ញា ជាដំណើរ យល់ការសេចក្តីចម្រើន និងសេចក្តីវិនាស ជាប្រាជ្ញាដ៏ប្រសើរ មុះមុត ជា ដំណើរយល់ការដែលអស់ទៅនៃទុក្ខដោយប្រពៃ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា បញ្ញាសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំង ៤ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបរលោក ដើម្បីសេចក្តីសុខក្នុងបរលោក ដល់កុលបុត្រ ។

កុលបុត្រ អ្នកមានព្យាយាមប្រឹងប្រែង ក្នុងទីនៃការងារ

ទាំងឡាយ ១ មិនប្រហែសធ្វេសមានការចាត់ចែង ១ ចិញ្ចឹមជីវិតស្មើ ១ ចេះថែរក្សាទ្រព្យ ដែលរកបានមក ១ មានសទ្ធា ១ បរិបូណ៌ដោយសីល ១ ដឹងនូវពាក្យពេចន៍ ១ ប្រាសចាកសេចក្តីកំណាញ់ រមែងជម្រះនូវផ្លូវមានសួស្តី ជាផ្លូវទៅកាន់បរលោកជានិច្ច ១ ធម៌ទាំង ៨ ប្រការនេះ តែងនាំមកនូវសេចក្តីសុខក្នុងលោកទាំងពីរ ដែលព្រះដ៏មានព្រះភាគព្រះអង្គ ជាសច្ចនាមទ្រង់សម្តែងហើយ ដល់កុលបុត្រអ្នកមានសទ្ធា ស្វែងរកផ្ទះ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខ ក្នុងបរលោកផង ដោយប្រការដូច្នេះ ការបរិច្ចាគនិងបុណ្យនេះ តែងចម្រើន ដល់គ្រហស្ថទាំងឡាយយ៉ាងនេះឯង ។

# អដ្ឋកថា

## ទីឃជាណុសូត្រ

[ ៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទីឃជាណុសូត្រទី ៤ ដូចតទៅនេះ ពាក្យថា **ព្យគ្ឃបជ្ជ** នេះ ជាពាក្យហៅកោលិយបុត្រឈ្មោះទីឃជាណុនោះ ដោយ

អំណាចប្រពៃណីសម្រាប់ដាក់ឈ្មោះ ។ ពិតហើយ បុព្វបុរសលោកិយ-បុត្រឈ្មោះទីឃជាណុនោះ កើតក្នុងផ្លូវខ្វាច្នងកាត់ ព្រោះដូច្នោះ ទើបមនុស្សក្នុងត្រកូលនោះ គេហៅថា **ព្យគ្ឃបជ្ជ** ។ បទថា **ឥស្សរត្តេន** ប្រែថា ដោយការងាររបស់អ្នកចម្បាំងដែលជំនាញក្នុងធ្នូ ។ បទថា **តត្រុបាយាយ** សេចក្តីថា ដែលជាឧបាយក្នុងការងារនោះ ព្រោះដឹងថា ពេលនេះ គួរធ្វើវត្ថុនេះ ។ បទថា **វុឌ្ឍសីលិនោ** ប្រែថា ជាអ្នកមានសីលសម្បូរ ជាអ្នកមានសមាចារបរិសុទ្ធ ។ បទថា **អាយំ** ប្រែថា ការមក ។ បទថា **នាច្ចោគាឡ្ហំ** ប្រែថា ខ្ជះខ្ជាយពេក ។ បទថា **បរិយាទាយ** បានដល់ ទទួលមកហើយចាយវាយទៅ ក្នុងសេចក្តីនោះ បុគ្គលណាមានចំណូលបន្ថែមឡើងជាងចំណាយ ២ ចំណែក ការចំណាយរបស់បុគ្គលនោះ មិនអាចធ្វើចំណូលឲ្យអស់ទៅសមដូចព្រះតម្រាស់ ក្នុងសិង្គាលកសូត្រថា

**ចតុធា វិភជេ ភោគេ សវេ មិត្តានិ គន្ថតិ ឯកេន**
**ភោគេ ភុញ្ជេយ្យ ទ្វីហិ កម្មំ បយោជយេ ចតុត្ថញ្ច**
**និធាបេយ្យ អាបទាសុ ភវិស្សតិ។**

គ្រហស្ថក្នុងត្រកូល បានសន្សំភោគៈទាំងឡាយយ៉ាងនេះហើយ ទើបអាង ( តាំងខ្លួន ) កុលបុត្រដែលចែកភោគៈទាំងឡាយជា ៤ ចំណែក គឺបរិភោគភោគៈទាំងឡាយ ១ ចំណែក ប្រកបការងារ ២

ចំណែក ទាំងតម្កល់ទុកនូវចំណែកទី ៤ ដោយគ្រែង
មានអន្តរាយទាំងឡាយ ( ទៅខាងមុខ ) កុលបុត្រ
នោះ ទើបឈ្មោះថា ចងបាច់មិត្តទាំងឡាយបាន ។

កាលបុគ្គលបដិបត្តិយ៉ាងនេះ ចំណាយរមែងមិនអាចអស់ទៅបាន ។ បទថា **ឧទុម្ពរខាទិកំ** សេចក្ដីថា កាលបុគ្គលបំណងនឹងស៊ីផ្លែល្វា អង្រួនដើមល្វាដែលមានផ្លែទុំ ផ្លែជាច្រើនជ្រុះមក ដោយការអង្រួនម្ដងប៉ុណ្ណោះ បុគ្គលនោះបរិភោគផ្លែដែលគួរបរិភោគ ចោលផ្លែជាច្រើន ក្រៅអំពីនេះ យ៉ាងណា បុគ្គលណាខ្ជះខ្ជាយ ធ្វើនូវចំណាយឲ្យច្រើនជាងចំណូល បរិភោគភោគៈ បុគ្គលនោះ គេហៅថា ស៊ីចោល ស៊ីគ្រវែង ដូចកុលបុត្រស៊ីផ្លែល្វានេះដូចគ្នា ។ បទថា **អនុមារិកំ** ប្រែថា ស្លាប់យ៉ាងអនាថា ។ បទថា **សមជីវិកំ កប្បេតិ** ប្រែថា ចិញ្ចឹមជីវិតយ៉ាងល្អ ។ បទថា **សមជីវិតា** សេចក្ដីថា ជាអ្នកនៅដោយការនៅសមគួរ ។ បទថា **អបាយមុខានិ** បានដល់ ឋានៈជាទីតាំងនៃសេចក្ដីវិនាស ។

បទថា **ឧដ្ឋាតា កម្មធេយ្យេសុ** បានដល់ ដែលសម្បូរឧស្សាហ៍ព្យាយាមក្នុងឋានៈដែលធ្វើការងារ ។ បទថា **វិធានវា** ប្រែថា អ្នកចាត់ចែងការងារ ។ បទថា **សោត្ថានំ សម្បរាយិកំ** បានដល់ សួស្ដីដែលប្រព្រឹត្តទៅក្នុងចំណែកខាងមុខ ។ បទថា **សច្ចនាមេន** សេចក្ដីថា ដោយព្រះនាមដែលពិតយ៉ាងនេះថា ជាពុទ្ធៈ ព្រោះត្រាស់ដឹងនោះឯង ។ បទថា **ចាគោ**

**បុញ្ញំ បវឌ្ឍតិ** សេចក្តីថា ចាគៈ និងបុណ្យដ៏សេស រមែងចម្រើន ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់សទ្ធាជាដើមលាយឡំគ្នា ។

## អដ្ឋកថា ទីឃជាណុសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ឧជ្ជយសូត្រទី ៥

[ ៥៥ ] លំដាប់នោះ ឧជ្ជយព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏និយាយរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧជ្ជយព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំមានប្រាថ្នា ដើម្បីទៅឃ្លាតចេញអំពីស្រុក ធម៌ទាំងឡាយណា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខ ក្នុងបច្ចុប្បន្ន ដើម្បីប្រយោជន៍ ក្នុងបរលោក ដើម្បីសេចក្តីសុខ ក្នុងបរលោក គប្បីមានដល់ពួកយើងខ្ញុំ សូមព្រះគោតមដ៏ចម្រើនទ្រង់សម្តែងនូវធម៌នោះដល់យើងខ្ញុំ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយ ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្ន ដើម្បី

សេចក្តីសុខ ក្នុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្តេច ។ គឺឧដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ ។ ម្នាលព្រាហ្មណ៍ ចុះឧដ្ឋានសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ចិញ្ចឹមជីវិតដោយការប្រឹងប្រែង ក្នុងការងារណា ទោះភ្ជួរក្តី ជួញប្រែក្តី រក្សាគោក្តី ការងាររបស់ខ្មាន់ធ្នូក្តី ការងាររបស់រាជបុរសក្តី សិល្បៈណាមួយក្តី ជាអ្នកប៉ិនប្រសប់ក្នុងការងារទាំងនោះ មិនខ្ជិលច្រអូស ប្រកបដោយឧបាយជាគ្រឿងពិចារណា ក្នុងការងារទាំងនោះថា គួរធ្វើ គួរចាត់ចែង ម្នាលព្រាហ្មណ៍ នេះហៅថា ឧដ្ឋានសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះអារក្ខសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ ភោគៈទាំងឡាយ ដែលកុលបុត្រក្នុងលោកនេះ បានមកដោយកម្លាំងព្យាយាម ប្រឹងប្រែង សន្សំដោយកម្លាំងដៃ បែកញើស ហូរញើស ជាភោគៈ ប្រកបដោយធម៌ កុលបុត្រនោះរមែងញុំាងភោគៈទាំងនោះ ឲ្យសម្រេចដោយការរក្សាគ្រប់គ្រង ដោយគិតថា ធ្វើដូចម្តេច កុំឲ្យស្តេចទាំងឡាយ នាំយកភោគៈទាំងនេះ របស់អាត្មាអញទៅបាន កុំឲ្យពួកចោរលួចយកទៅបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកបន្សាត់ទៅបាន កុំឲ្យពួកទាយាទ មិនជាទីស្រឡាញ់ ដណ្តើមយកទៅបាន ម្នាលព្រាហ្មណ៍ នេះហៅថា អារក្ខសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះកល្យាណមិត្តតា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ នៅអាស្រ័យក្នុងស្រុក ឬនិគមណា ពួកជនណា ទោះគហបតីក្តី គហបតិបុត្រក្តី ក្មេងតែចម្រើនដោយសីល ចាស់

ហើយតែចម្រើនដោយសីល បរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយសីល បរិ-បូណ៌ដោយចាគៈ បរិបូណ៌ដោយបញ្ញា មាននៅក្នុងស្រុក ឬនិគមនោះ ( កុល-បុត្រនោះ ) រមែងឈរចរចា សាកច្ឆាជាមួយនឹងពួកជនទាំងនោះ តែងសិក្សានូវសទ្ធាសម្បទា និងពួកជនអ្នកបរិបូណ៌ដោយសទ្ធា តាមសមគួរ សិក្សានូវសីលសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយសីល តាមសមគួរ សិក្សានូវចាគសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយចាគៈ តាមសមគួរ សិក្សានូវបញ្ញាសម្បទា និងពួកជនអ្នកបរិបូណ៌ដោយបញ្ញា តាមសមគួរ ម្នាលព្រាហ្មណ៍នេះហៅថា កល្យាណមិត្តតា ។ ម្នាលព្រាហ្មណ៍ ចុះសមជីវិតា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ដឹងច្បាស់នូវការចម្រើន នៃភោគៈទាំងឡាយផង ដឹងច្បាស់នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ។ ម្នាលព្រាហ្មណ៍ប្រៀបដូចជនអ្នកថ្លឹងជញ្ជីងក្តី កូនសិស្សនៃជនអ្នកថ្លឹងជញ្ជីងក្តី លើកនូវជញ្ជីងថ្លឹងហើយ ក៏ដឹងថា ទន់ទៅខាងម្ខាង បះឡើងខាងម្ខាងផង យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ កុលបុត្រអ្នកដឹងច្បាស់នូវការចម្រើន នៃភោគៈទាំងឡាយផង ដឹងច្បាស់នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើមិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់អាត្មាអញ

នឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ ប្រសិនបើ កុលបុត្រនេះមានសេចក្តីចម្រើនតិច តែចិញ្ចឹមជីវិតច្រើនលើសលុប អ្នកផងទាំងឡាយ តែងនិយាយដល់កុលបុត្រនោះថា កុលបុត្រនេះ បរិភោគនូវភោគៈទាំងឡាយ ដូចជាគេស៊ីផ្លែល្វា ។ ម្នាលព្រាហ្មណ៍ ប្រសិនបើកុលបុត្រនេះ មានសេចក្តីចម្រើនធំ តែចិញ្ចឹមជីវិតដោយក្បិតក្បៀត អ្នកផងទាំងឡាយរមែងនិយាយដល់កុលបុត្រនោះថា កុលបុត្រនេះ មុខជានឹងស្លាប់ៗ ដោយឥតទីពឹង ។ ម្នាលព្រាហ្មណ៍ កាលណាកុលបុត្រនេះ ដឹងច្បាស់នូវការចម្រើន នៃភោគៈទាំងឡាយផង ដឹងច្បាស់នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់នូវសេចក្តីវិនាស យ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ម្នាលព្រាហ្មណ៍ នេះហៅថា សមជីវិតា ។ ម្នាលព្រាហ្មណ៍ កាលដែលភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីវិនាស ៤ ប្រការ គឺជាអ្នកលេងស្រី ១ លេងសុរា ១ លេងល្បែងភ្នាល់ ១ មានមិត្រលាមក មានសម្លាញ់លាមក សមគប់នឹងបុគ្គលលាមក ១ ។ ម្នាលព្រាហ្មណ៍ ដូចស្រះធំមានផ្លូវនៃសេចក្តីចម្រើន ៤ ផង មានផ្លូវនៃសេចក្តីវិនាស ៤ ផង បុរសគប្បីបិទខ្ទប់នូវផ្លូវនៃសេចក្តីចម្រើនទាំងនោះ របស់ស្រះនោះផង គប្បីបើកបង្ហូរ នូវផ្លូវនៃ

សេចក្ដីវិនាសទាំងនោះ របស់ស្រះនោះផង ទាំងភ្លៀងសោត ក៏មិនបង្អុរនូវធារទឹក ដោយប្រពៃផង ម្នាលព្រាហ្មណ៍ កាលបើយ៉ាងនេះ ស្រះដ៏ធំនោះនឹងមានសេចក្ដីសាបសូន្យជាប្រាកដ មិនមានសេចក្ដីចម្រើនឡើយ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ កាលដែលភោគៈទាំងឡាយ ចម្រើនឡើង យ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្ដីវិនាស ៤ យ៉ាង គឺជាអ្នកលេងស្រី ១ លេងសុរា ១ លេងល្បែងភ្នាល់ ១ មានមិត្រលាមក មានសម្លាញ់លាមក សមគប់នឹងបុគ្គលលាមក ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ កាលដែលភោគៈទាំងឡាយ ចម្រើនឡើង យ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្ដីចម្រើន ៤ ប្រការ គឺជាអ្នកមិនលេងស្រី ១ មិនលេងសុរា ១ មិនលេងល្បែងភ្នាល់ ១ មានមិត្រល្អ មានសម្លាញ់ល្អ សមគប់នឹងបុគ្គលល្អ ១ ។ ម្នាលព្រាហ្មណ៍ ស្រះធំមានផ្លូវនៃសេចក្ដីចម្រើន ៤ ផង មានផ្លូវនៃសេចក្ដីវិនាស ៤ ផង បុរសគប្បីបើកបង្ហូរនូវផ្លូវនៃសេចក្ដីចម្រើនទាំងនោះ របស់ស្រះនោះផង គប្បីបិទនូវផ្លូវនៃសេចក្ដីវិនាសទាំងនោះ របស់ស្រះនោះផង ទាំងភ្លៀងសោត ក៏បង្អុរចុះនូវធារទឹកដោយប្រពៃផង ម្នាលព្រាហ្មណ៍ កាលបើយ៉ាងនេះហើយ សេចក្ដីចម្រើនរបស់ស្រះនោះនឹងមានប្រាកដ មិនមានសេចក្ដីសាបសូន្យឡើយ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ កាលបើភោគៈទាំងឡាយ ចម្រើនឡើង យ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្ដីចម្រើន ៤ ប្រការ គឺជាអ្នកមិនលេងស្ត្រី ១ ។បេ។ សមគប់នឹងបុគ្គលល្អ ១ យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ ធម៌ទាំង-

ឡាយ ៤ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខ ក្នុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយ ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបរលោក ដើម្បីសេចក្តីសុខ ក្នុងបរលោក ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្តេច ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលព្រាហ្មណ៍ ចុះសទ្ធាសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ជាអ្នកមានសទ្ធា ជឿនូវការត្រាស់ដឹងនៃព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ម្នាលព្រាហ្មណ៍ នេះហៅថា សទ្ធាសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ម្នាលព្រាហ្មណ៍ នេះហៅថា សីលសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះចាគសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគរួចស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ ជាអ្នកគួរដល់ស្មូម ត្រេកអរក្នុងការចែករំលែកនូវទាន ម្នាលព្រាហ្មណ៍ នេះហៅថាចាគសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះបញ្ញាសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ជាអ្នកមានប្រាជ្ញា ។បេ។ ជាដំណើរ

យល់ការដែលអស់ទៅនៃទុក្ខដោយប្រពៃ ម្នាលព្រាហ្មណ៍ នេះហៅថា បញ្ញាសម្បទា ។ ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយ ៤ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបរលោក ដើម្បីសេចក្ដីសុខ ក្នុងបរលោក ដល់កុលបុត្រ ។

កុលបុត្រអ្នកមានព្យាយាម ប្រឹងប្រែង ក្នុងទីនៃការងារទាំងឡាយ ១ មិនប្រហែសធ្វេសមានការចាត់ចែង ១ ចិញ្ចឹមជីវិតស្មើ ១ ចេះថែរក្សាទ្រព្យដែលរកបានមក ១ មានសទ្ធា ១ បរិបូណ៌ដោយសីល ១ ដឹងនូវពាក្យពេចន៍ ១ ប្រាសចាកសេចក្ដីកំណាញ់ ជម្រះនូវផ្លូវមានសួស្ដី ជាផ្លូវទៅកាន់បរលោកជានិច្ច ១ ធម៌ទាំង ៨ ប្រការនេះ តែងនាំមកនូវសេចក្ដីសុខ ក្នុងលោកទាំងពីរ ដែលព្រះដ៏មានព្រះភាគ ព្រះអង្គជាសច្ចនាម ទ្រង់សម្ដែងដល់កុលបុត្រអ្នកមានសទ្ធា ស្វែងរកផ្ទះ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្ដីសុខ ក្នុងបរលោកផង ដោយប្រការដូច្នេះ ការបរិច្ចាគ និងបុណ្យនេះ តែងចម្រើន ដល់គ្រហស្ថទាំងឡាយ យ៉ាងនេះឯង ។

# អដ្ឋកថា

## ឧជ្ជយសូត្រ

[ ៥៥ ] ក្នុងឧជ្ជយសូត្រទី ៥ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាឧជ្ជយសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ភយសូត្រទី៦

[ ៥៦ ] ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ទុក្ខនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំង-ឡាយ ពាក្យថា រោគនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ពកនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រួញនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ជាប់ជំពាក់នេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភក់នេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា គភ៌នេះ ជាឈ្មោះរបស់កាម ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេច បានជាពាក្យថា ភ័យនេះ ជាឈ្មោះរបស់កាម ។ ម្នាលភិក្ខុទាំង-ឡាយ កុលបុត្រនេះត្រេកអរដោយអំណាចកាមរាគ ជាប់ជំពាក់ដោយឆន្ទរាគ រមែងមិនរួចចាកភ័យក្នុងបច្ចុប្បន្នផង មិនរួចចាកភ័យក្នុងបរលោកផង ហេតុនោះបានជាពាក្យថា ភ័យនេះ ជាឈ្មោះរបស់កាម ។ ម្នាលភិក្ខុទាំងឡាយ

ហេតុដូចម្តេច បានជាពាក្យថា ទុក្ខ ។បេ។ ថា រោគ ថា ពក ថា ព្រួញ ថា ជាប់ជំពាក់ ថា ភក់ ( នេះជាឈ្មោះរបស់កាម ) ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេច បានជាពាក្យថា គភ៌នេះ ជាឈ្មោះរបស់កាម ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រនេះ ត្រេកអរដោយអំណាចកាមរាគ ជាប់ជំពាក់ដោយឆន្ទរាគ រមែងមិនរួចចាកគភ៌ ក្នុងបច្ចុប្បន្នផង មិនរួចចាកគភ៌ ក្នុងបរលោកផង ហេតុនោះបានជាពាក្យថា គភ៌នេះ ជាឈ្មោះរបស់កាម ។

បុថុជ្ជនជាប់ជំពាក់ក្នុងកាមណា កាមទាំងពីរនុ៎ះ លោក
ហៅថា ភ័យ ថាទុក្ខ ថារោគ ថាពក ថាព្រួញ ថាការ
ជាប់ជំពាក់ ថាភក់ ថាគភ៌ បុថុជ្ជនត្រូវសេចក្តីសុខ ក្នុង
កាមគ្របសង្កត់ហើយ រមែងទៅកាន់គភ៌ទៀត លុះតែ
ភិក្ខុ មានព្យាយាមដុតកម្តៅកិលេស ត្រេកអរដោយ
សម្បជញ្ញៈក្នុងវេលាណា ភិក្ខុនោះបែបនោះ កន្លងនូវ
ផ្លូវវាង គឺវដ្ដៈនេះ ដែលគេឆ្លងបានដោយក្រ រមែងមើល
ឃើញនូវពួកសត្វ ដែលចូលទៅកាន់ជាតិ និងជរា កំពុង
តែញាប់ញ័រ ( ក្នុងភពទាំង ៣ ក្នុងវេលានោះ ) ។

# អដ្ឋកថា

## ភយសូត្រ

[ ៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភយសូត្រទី ៦ ដូចតទៅនេះ បទថា **គព្ភោ** បានដល់ ការនៅក្នុងគភ៌ ។ បទថា **ទិដ្ឋធម្មិកាបិ** បានដល់ រមែងមិនរួចផុតអំពីគភ៌មនុស្សទៀត ដូចការនៅក្នុងគភ៌ដែលឃើញក្នុងបច្ចុប្បន្ន ។ បទថា **សម្បរាយិកាបិ** បានដល់ ចាកគភ៌ដ៏សេស វៀរគភ៌នៃពួកមនុស្ស ។

បទថា **ឧភយំ ឯតេ កាមា បវុច្ចន្តិ** សេចក្តីថា លោកពោលកាមទាំងនេះ ជាគូគ្នាយ៉ាងនេះ គឺភ័យ និងទុក្ខ ១ ភ័យ និងរោគ ១ ភ័យ និងបូស ១ ភ័យ និងព្រួញ-ស ១ ភ័យ និងការជាប់ជំពាក់ ១ ភ័យ និងភក់ ១ ភ័យ និងការនៅក្នុងគភ៌ ១ ។ បទថា **សាតរូបេន** បានដល់ កាមសុខ ។ បទថា **បលិបថំ** បានដល់ ឈានកន្ទង់ផ្លូវវិលវល់ គឺវដ្ដៈ ។ ក្នុងឋានៈនេះ ព្រះមានព្រះភាគត្រាស់វិបស្សនា ទ្រង់កាន់យកថា ភិក្ខុនោះសម្រេចអរហត្ត ។ ពិតហើយ ទ្រង់ពិចារណាពួកសត្វបែបនេះ ដែលជាបុគ្គលចូលដល់ជាតិ និងជរា អន្ទះអន្ទែងនៅក្នុងភពទាំង ៣ នោះឯង ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់វដ្ដៈទុកក្នុងព្រះសូត្រ និងត្រាស់វដ្ដៈទុកក្នុងគាថាទាំងឡាយ ៕

**អដ្ឋកថា ភយសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមអាហុនេយ្យសូត្រទី ៧

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវចតុប្បច្ច័យដែលគេតាក់តែង ដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ ប្រកបដោយធម៌ទាំង ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកចេះចាំច្រើន ១ ។បេ។ យល់ត្រឹមត្រូវ ដោយទិដ្ឋិ ១ ជាអ្នកមានមិត្រល្អ មានសម្លាញ់ល្អ សមគប់នឹងបុគ្គលល្អ ១ ជាអ្នកសម្មាទិដ្ឋិ ប្រកបដោយសម្មាទស្សនៈ ១ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយទូលាយនូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន ១ តែងរឭកឃើញនូវបុព្វេនិវាស គឺការនៅក្នុងភពមុន មានប្រការដ៏ច្រើន គឺរឭកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកឃើញនូវបុព្វេ-និវាស ព្រមទាំងអាការ ព្រមទាំងឧទ្ទេស មានប្រការដ៏ច្រើន ដោយប្រការដូច្នេះ ១ បានដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ។បេ។ ទិព្វចក្ខុដ៏ស្អាត កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ១ បានធ្វើឲ្យជាក់ច្បាស់ បានដល់ ។បេ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៨

យ៉ាងនេះឯង ជាអ្នកគួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

# អដ្ឋកថា

## បឋមអាហុនេយ្យសូត្រ

[ ៥៧ ] ក្នុងបឋមអាហុនេយ្យសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមអាហុនេយ្យសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ទុតិយអាហុនេយ្យសូត្រទី ៨

[ ៥៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង ជាអ្នកគួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ ប្រកបដោយធម៌ទាំង ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកចេះចាំច្រើន ១ ។បេ។ យល់ត្រឹមត្រូវដោយទិដ្ឋិ ១ ជាអ្នកប្រារព្ធសេចក្តីព្យាយាម មានកម្លាំងប្រឹងប្រែងដ៏មាំ មិន

ដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកនៅក្នុងព្រៃ មានទីសេនាសនៈស្ងាត់ ១ អត់ទ្រាំនូវសេចក្ដីអផ្សុក និងសេចក្ដីត្រេកអរ តែងគ្របសង្កត់នូវសេចក្ដីអផ្សុកដែលកើតឡើងហើយ ១ ជាអ្នកអត់ទ្រាំនូវភ័យគួរស្ញប់ស្ញែង តែងគ្របសង្កត់នូវភ័យ គួរស្ញប់ស្ញែង ដែលកើតឡើងហើយ ១ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយទូលាយ នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ បានធ្វើឲ្យជាក់ច្បាស់ បានដល់ ។បេ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៨ យ៉ាងនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

# អដ្ឋកថា

## ទុតិយអាហុនេយ្យសូត្រ

[ ៥៨ ] ក្នុងទុតិយអាហុនេយ្យសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយអាហុនេយ្យសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បឋមអដ្ឋបុគ្គលសូត្រទី ៩

[ ៥៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៨ ពួកនេះ ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវចតុប្បច្ច័យដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃ ក្រៃលែងជាងគ្មាន ។ បុគ្គលទាំង ៨ ពួក តើដូចម្តេច ។ គឺបុគ្គលជាសោតាបន្ន ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល ១ បុគ្គលជាសកទាគាមី ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សកទាគាមិផល ១ បុគ្គលជាអនាគាមី ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់អនាគាមិផល ១ បុគ្គលជាអរហន្ត ១ បុគ្គលជាអ្នកប្រតិបត្តិ ដើម្បីអរហត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៨ ពួកនេះឯង ជាអ្នកគួរទទួលនូវចតុបច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

បុគ្គល ៤ ពួក ជាអ្នកប្រតិបត្តិផង ៤ ពួក តាំងនៅក្នុងផលផងនេះ ជាសង្ឃមានសភាពដ៏ត្រង់ ប្រកបដោយបញ្ញា និងសីល រមែងធ្វើនូវបុណ្យដ៏ក្រៃលែង ដល់ពួកសត្វ គឺមនុស្ស កាលស្វែងរកនូវបុណ្យហើយបូជា ព្រោះទានដែលបុគ្គលឲ្យហើយ ចំពោះសង្ឃ រមែងមានផលច្រើន ។

# អដ្ឋកថា

## បឋមអដ្ឋបុគ្គលសូត្រ

[ ៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអដ្ឋបុគ្គលសូត្រទី ៩ ដូចតទៅនេះ បទថា **ឧជុភូតោ** សេចក្តីថា ឈ្មោះថា ត្រង់ ព្រោះមិនមានការកោងតាមកាយជាដើម ។ បទថា **បញ្ញាសីលសមាហិតោ** បានដល់ ប្រកបដោយបញ្ញា និងសីល ។ បទថា **យជមានានំ** បានដល់ អ្នកឲ្យទាន ។ បទថា **បុញ្ញបេក្ខានំ** បានដល់ ពិនិត្យមើល គឺស្វែងរកបុណ្យ ។ បទថា **ឱបធិកំ** បានដល់ មានឧបធិជាវិបាកដ៏ក្រៃលែង ឬប្រមាណមិនបាន ៕

**អដ្ឋកថា បឋមអដ្ឋបុគ្គលសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយអដ្ឋបុគ្គលសូត្រទី ១០

[ ៦០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៨ ពួកនេះ ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ បុគ្គលទាំង ៨ ពួក តើដូចម្តេច ។ គឺបុគ្គលជាសោតាបន្ន ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល ១ បុគ្គលជាសកទាគាមី ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សកទាគាមិផល

១ បុគ្គលជាអនាគាមី ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ បុគ្គលជាអរហន្ត ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីអរហត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៨ ពួកនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

បុគ្គល ៤ ពួក ជាអ្នកប្រតិបត្តិផង ៤ ពួកជាអ្នកតាំង
នៅក្នុងផលផង នេះជាសង្ឃដ៏ឧត្តម ជាងសត្វទាំង-
ឡាយ បុគ្គល ៨ ពួក រមែងធ្វើបុណ្យដ៏ក្រៃលែង
ដល់ពួកសត្វ គឺមនុស្ស កាលស្វែងរកនូវបុណ្យហើយ
បូជា ព្រោះទានដែលបុគ្គលឲ្យហើយ ចំពោះសង្ឃនុ៎ះ
រមែងមានផលច្រើន ។

សទ្ធានវគ្គទី ១ ចប់

## ឧទ្ទាននៃសទ្ធានវគ្គនោះ គឺ

និយាយអំពីរឿងនាងមហាបជាបតិគោតមី ១ អំពីភិក្ខុគួរឲ្យឱវាទដល់ភិក្ខុនី ១ អំពីធម៌ដ៏សង្ខេប ១ អំពីទីឃជាណុកោឡិយបុត្ត ១ អំពីឧជ្ជយព្រាហ្មណ៍ ១ អំពីភ័យ ១ អំពីអាហុនេយ្យបុគ្គលមាន ២ លើក អំពីបុគ្គល ៨ ពួកមាន ២ លើក ។

# អដ្ឋកថា

## ទុតិយអដ្ឋបុគ្គលសូត្រ

[ ៦០ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអដ្ឋបុគ្គលសូត្រទី ១០ ដូចតទៅនេះ បទថា* **សមុក្កដ្ឋោ** *ប្រែថា គឺឧត្តមខ្ពង់ខ្ពស់ ។ បទថា* **សត្តានំ** *បានដល់នៃសត្វទាំងពួង ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ ងាយយល់ហើយ ។*

**អដ្ឋកថាទុតិយអដ្ឋបុគ្គលសូត្រទី ១០ ចប់**

**សទ្ធានវគ្គទី ១ ចប់**

# សុត្តន្តបិដក
# អង្គុត្តរនិកាយ អដ្ឋកនិបាត
# នវមភាគ

## ទានវគ្គ
## ឥច្ឆាសូត្រទី ១

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៨ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៨ ពួក តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភក៏កើតឡើង ។ ភិក្ខុនោះ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ។ កាលភិក្ខុនោះ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ លាភក៏មិនកើតឡើង ។ ភិក្ខុនោះ រមែងសោកស្តាយ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង ព្រោះមិនមានលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ប៉ុន្តែជាអ្នកមិនមានលាភផង សោកស្តាយផង ខ្សឹកខ្សួលផង ឃ្លាតចាកព្រះសទ្ធម្មផង ( ១ ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នា ដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុ

នោះខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ។ កាលភិក្ខុនោះ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ លាភក៏កើតឡើង ។ ភិក្ខុនោះ ស្រវឹងជ្រុលជ្រប់ដល់នូវសេចក្តីប្រមាទ ព្រោះលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នាដើម្បីលាភ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង ស្រវឹងផង ប្រមាទផង ឃ្លាតចាកព្រះសទ្ធម្មផង ( ២ ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នា ដើម្បីលាភក៏កើតឡើង ។ ភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ។ កាលភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ លាភក៏មិនកើតដែរ ។ ភិក្ខុនោះ រមែងសោកស្តាយ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង ព្រោះមិនមានលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នាដើម្បីលាភ តែមិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភ ប៉ុន្តែជាអ្នកមិនមានលាភផង សោកស្តាយផង ខ្សឹកខ្សួលផង ឃ្លាតចាកព្រះសទ្ធម្មផង ( ៣ ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ។ កាលភិក្ខុនោះ មិនសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ប៉ុន្តែលាភក៏កើតឡើងបាន ។ ភិក្ខុនោះ ស្រវឹងជ្រុលជ្រប់ ដល់នូវសេចក្តីប្រមាទ ព្រោះលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ

នេះហៅថា ភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ មិនខំសង្វាត មិនខ្នីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ប៉ុន្តែជាអ្នកមានលាភផង ស្រវឹងផង ប្រមាទផង ឃ្លាតចាកព្រះសទ្ធម្មផង ( ៤ ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នា ដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះ ខំសង្វាត ខ្នីឃ្មាត ព្យាយាម ដើម្បីលាភ ប៉ុន្តែលាភមិនកើតឡើង ។ ភិក្ខុនោះ មិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេង ព្រោះមិនមានលាភនោះទេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ ខំសង្វាត ខ្នីឃ្មាត ព្យាយាម ដើម្បីលាភ ប៉ុន្តែជាអ្នកមិនមានលាភផង មិនសោកស្តាយផង មិនខ្សឹកខ្សួលផង មិនឃ្លាតចាកព្រះសទ្ធម្មផង ( ៥ ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នា ដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះខំសង្វាត ខ្នីឃ្មាត ព្យាយាម ដើម្បីលាភ ។ កាលភិក្ខុនោះ ខំសង្វាត ព្យាយាម ដើម្បីលាភ លាភក៏កើតឡើង ។ ភិក្ខុនោះមិនស្រវឹង មិនជ្រុលជ្រប់ មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ ខំសង្វាត ខ្នីឃ្មាត ព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង មិនស្រវឹងផង មិនប្រមាទផង មិនឃ្លាតចាកព្រះសទ្ធម្មផង ( ៦ ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នា ដើម្បីលាភ

ក៏កើតឡើង ។ ភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ។ កាលភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ លាភក៏មិនកើតឡើងដែរ ។ ភិក្ខុនោះ រមែងមិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេង ព្រោះមិនមានលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នាដើម្បីលាភ មិនខំសង្វាត មិនខ្មីឃាត មិនព្យាយាម ដើម្បីលាភ ទាំងជាអ្នកមិនមានលាភផង មិនសោកស្តាយផង មិនខ្សឹកខ្សួលផង មិនឃ្លាតចាកព្រះសទ្ធម្មផង ( ៧ ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នា ដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ។ កាលភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ប៉ុន្តែលាភកើតឡើងបាន ។ ភិក្ខុនោះ មិនស្រវឹង មិនជ្រុលជ្រប់ មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភ ក៏ជាអ្នកមានលាភផង មិនស្រវឹងផង មិនប្រមាទផង មិនឃ្លាតចាកព្រះសទ្ធម្មផង ( ៨ ) ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៨ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា

# ចាលវគ្គទី ២

## ឥច្ឆាសូត្រ

[ ៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឥច្ឆាសូត្រទី ១ នៃចាលវគ្គទី ២ ដូច្នេះ បទថា **បវិវិត្តស្ស** បានដល់ ស្ងាត់ហើយដោយកាយវិវេក ។ បទថា **និរា-យត្តវុត្តិនោ** បានដល់ អ្នកមានវិបស្សនាកម្ម មិនប្រព្រឹត្តទៅ ទាក់ទងគ្នាក្នុងអារម្មណ៍ណាមួយ ។ បទថា **លាភាយ** បានដល់ ដើម្បីបានបច្ច័យ ៤ ។ បទថា **សោចិ ច បរិទេវិ ច** ប្រែថា ការសោយសោក និងការខ្សឹកខ្សួល បាលីថា **សោចិច្ច បរិទេវិច្ច** ដូច្នេះក៏មាន ។ បទថា **ចុតោ ច សទ្ធម្មា** បានដល់ ឃ្លាតចាកព្រះសទ្ធម្ម គឺវិបស្សនាក្នុងខណៈនោះឯង ។ ក្នុងព្រះសូត្រនេះ ត្រាស់វដ្តៈផង វិវដ្តៈផង ៕

**អដ្ឋកថា ឥច្ឆាសូត្រទី ១ ចប់**

# សុត្តន្តបិដក

## បឋមអលំសូត្រទី ២

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ទើបគួរដល់ខ្លួន គួរដល់ពួកជនដទៃ ។ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះដឹងចាប់ ក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកទ្រទ្រង់ធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ ១ ជាអ្នកពិចារណា នូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ១ ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ១ ជាអ្នកមានវាចាល្អ មានពាក្យពីរោះ ប្រកបដោយវាចាអ្នកក្រុង ជាវាចាច្បាស់លាស់ ជាវាចាឥតទោស ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញុំាងពួកសព្រហ្មចារីឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរដល់ខ្លួន គួរដល់ពួកជនដទៃ ។

## ទុតិយអលំសូត្រទី ៣

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបគួរដល់ខ្លួន គួរដល់ពួកជនដទៃ ។ ៥ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចេះដឹងចាប់ ក្នុងកុសលធម៌ទាំងឡាយទេ តែជាអ្នកទ្រទ្រង់ធម៌ទាំងឡាយ ដែលខ្លួនស្តាប់ ១ ជាអ្នកពិចារណានូវអត្ថនៃធម៌ដែលខ្លួនទ្រទ្រង់ ១ ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ១ ជាអ្នកមានវាចាល្អ ។បេ។ ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញុំាងពួកសព្រហ្មចារីឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរដល់ខ្លួន គួរដល់ពួកជនដទៃ ។

# តតិយអលំសូត្រទី ៨

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃទេ ។ ៤ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះដឹងឆាប់ក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកទ្រទ្រង់ធម៌ទាំងឡាយ ដែលខ្លួនបានស្តាប់ហើយ ១ ជាអ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ១ ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ហើយ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ តែជាអ្នកមានវាចាមិនល្អ ជាអ្នកមានពាក្យមិនពីរោះ ជាអ្នកមិនប្រកបដោយវាចាអ្នកក្រុង ដែលជាវាចាច្បាស់លាស់ ជាវាចាឥតទោស ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ទាំងជាអ្នកមិនញុំាងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះឯង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃឡើយ ។

# ចតុត្ថអលំសូត្រទី ៩

[ ៦៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាង រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនទេ ។ ៤ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ តែជាអ្នកមិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ទាំងជាអ្នកមិនដឹងនូវអត្ថ មិនដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ជាអ្នកមានវាចាល្អ ជា

អ្នកមានពាក្យពីរោះ ។បេ។ ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញុំាងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ១ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះឯង រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឡើយ ។

## បញ្ចមអលំសុត្រទី ៦

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃទេ ។ ៣ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ មិនចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយទេ តែជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ ១ ជាអ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ១ ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ តែជាអ្នកមានវាចាមិនល្អ ជាអ្នកមានពាក្យមិនពីរោះ ជាអ្នកមិនប្រកបដោយវាចាអ្នកក្រុង ដែលជាវាចាច្បាស់លាស់ជាវាចាឥតទោស ជាគ្រឿងញុំាងជន ឲ្យដឹងច្បាស់នូវសេចក្តី ទាំងមិនញុំាងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះ រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃឡើយ ។

## ឆដ្ឋអលំសុត្រទី ៧

[ ៦៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង រមែងគួរ

ដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនទេ ។ ៣ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយទេ តែជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ ១ ជាអ្នកមិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ទាំងជាអ្នកមិនដឹងនូវអត្ថ មិនដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ តែជាអ្នកមានវាចាល្អ ។បេ។ ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញុំាងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះ រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឡើយ ។

## សត្តមអលំសូត្រទី ៨

[ ៦៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ យ៉ាង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃទេ ។ ២ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយថែមទាំងមិនជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយផង តែជាអ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ១ ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ តែជាអ្នកមានវាចាមិនល្អ ។បេ។ ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ជាអ្នកមិនញុំាងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ១ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយ

ធម៌ ២ យ៉ាងនេះឯង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃឡើយ ។

## អដ្ឋអលំសូត្រទី ៩

[ ៦៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ យ៉ាង រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនទេ ។ ២ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយ ថែមទាំងជាអ្នកមិនទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ ទាំងជាអ្នកមិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ជាអ្នកមិនដឹងនូវអត្ថ មិនដឹងនូវធម៌ ហើយមិនប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង តែជាអ្នកមានវាចាល្អ ជាអ្នកមានពាក្យពីរោះ ប្រកបដោយវាចាអ្នកក្រុង ដែលជាវាចាច្បាស់លាស់ ជាវាចាឥតទោស ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញុំាងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ យ៉ាងនេះឯង រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឡើយ ។

# អដ្ឋកថា

## បឋមអលំសូត្រទី ២ ជាដើម

[ ៦២-៦៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអលំសូត្រទី ២ ដូចតទៅនេះ បទថា **អលំ អត្តនោ អលំ បរេសំ** សេចក្តីថា ភិក្ខុជាអ្នកអាច គឺអាចបានដល់ សមគួរក្នុងកិច្ចបដិបត្តិប្រយោជន៍ និងសេចក្តីចម្រើនដល់ខ្លួន និងអ្នកដទៃ ។ បទថា **ខិប្បនិសន្តិ** សេចក្តីថា ភិក្ខុរមែងទ្រទ្រង់ចាំរហ័ស អធិប្បាយថា កាលបុគ្គលនោះពោលដល់ខន្ធ ធាតុ និងអាយតនៈជាដើម រមែងដឹងធម៌ទាំងនោះបានឆាប់រហ័ស ។ ក្នុងព្រះសូត្រនេះ ត្រាស់សមថៈ និងវិបស្សនា តែពាក្យនេះ ត្រាស់តាំងអំពីខ្ពស់មកទាប ដោយអជ្ឈាស្រ័យរបស់បុគ្គល និងដោយលីលានៃទេសនា ។៚

**អដ្ឋកថា បឋមអលំសូត្រទី ២ ជាដើមចប់**

# សុត្តន្តបិដក

## សង្ខិត្តសូត្រទី ៧០

[ ៧០ ] គ្រានោះ ភិក្ខុមួយរូប បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ។បេ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌

ដល់ខ្ញុំព្រះអង្គ ដោយសេចក្ដីបង្រួញឲ្យទាន ដែលខ្ញុំព្រះអង្គបានស្ដាប់ធម៌របស់ព្រះដ៏មានព្រះភាគហើយ ជាបុគ្គលម្នាក់ឯង ចៀសចេញទៅ ជាអ្នកមិនធ្វេសប្រហែស មានព្យាយាមដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ មោឃបុរសពួកខ្លះ ក្នុងលោកនេះ គ្រាន់តែអារាធនាតថាគតយ៉ាងនេះ កាលធម៌ដែលតថាគតសម្ដែងហើយ សម្គាល់តែត្រង់ដើម តាមតថាគតប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងធម៌ដល់ខ្ញុំព្រះអង្គ ដោយសេចក្ដីបង្រួញឲ្យទាន សូមព្រះសុគតទ្រង់សម្ដែងធម៌ ដោយសេចក្ដីបង្រួញឲ្យទាន គិតធ្វើដូចម្ដេច សូមឲ្យខ្ញុំព្រះអង្គ បានយល់នូវអត្ថនៃភាសិតរបស់ព្រះដ៏មានព្រះភាគ គិតធ្វើដូចម្ដេច សូមឲ្យខ្ញុំព្រះអង្គបានទទួលនូវភាសិតរបស់ព្រះដ៏មានព្រះភាគ ។ ម្នាលភិក្ខុ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញ នឹងតាំងនៅក្នុងសន្ដាន តាំងនៅដោយល្អ ទាំងពួកអកុសលធម៌ដ៏លាមក ក៏មិនកើតឡើង គ្របសង្កត់ចិត្តបានឡើយ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។ ម្នាលភិក្ខុ កាលណា ចិត្តរបស់អ្នកតាំងនៅក្នុងសន្ដាន តាំងនៅល្អហើយ ទាំងពួកអកុសលធម៌ដ៏លាមក ក៏មិនកើតឡើង គ្របសង្កត់ចិត្តបាន ម្នាលភិក្ខុ កាលនោះ អ្នកគប្បីសិក្សាយ៉ាងនេះថា ចេតោវិមុត្តិ ប្រកបដោយមេត្តា អាត្មាអញ បានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។

ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ យ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគួរចម្រើននូវសមាធិនេះ ដែលប្រកបដោយ វិតក្ក និងវិចារផង គួរចម្រើននូវសមាធិដែលមិនមានវិតក្កផង មានតែវិចារ ប៉ុណ្ណោះ គួរចម្រើននូវសមាធិ ដែលមិនមានវិតក្ក មិនមានវិចារផង គួរចម្រើន នូវសមាធិ ដែលប្រកបដោយបីតិផង គួរចម្រើននូវសមាធិ ដែលមិនមានបីតិ ផង គួរចម្រើននូវសមាធិ ដែលប្រកបដោយសេចក្តីសប្បាយផង គួរចម្រើន នូវសមាធិដែលប្រកបដោយឧបេក្ខាផង ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានចម្រើនល្អហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នក គប្បីសិក្សាយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយករុណា អាត្មាអញ ។បេ។ ចេតោវិមុត្តិ ប្រកបដោយមុទិតា អាត្មាអញ ។បេ។ ចេតោវិមុត្តិ ប្រកបដោយ ឧបេក្ខា អាត្មាអញបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជា យាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ ធ្វើឲ្យច្រើនហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នក គួរចម្រើននូវសមាធិនេះ ដែលប្រកបដោយវិតក្កវិចារផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្កមានតែវិចារផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្ក មិនមានវិចារផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយបីតិផង អ្នកគួរចម្រើន សមាធិ ដែលមិនមានបីតិផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយសេចក្តី

សប្បាយផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយឧបេក្ខាផង ។ ម្នាល ភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានចម្រើនល្អហើយយ៉ាង នេះ ម្នាលភិក្ខុ កាលនោះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញនឹងពិចារណា នូវកាយក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នក ដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ យ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគួរចម្រើនសមាធិនេះ ដែលប្រកបដោយវិតក្កវិចារផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្ក មានតែវិចារផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្ក មិនមានវិចារផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយបីតិផង អ្នកគួរ ចម្រើនសមាធិ ដែលមិនមានបីតិផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយ សេចក្តីសប្បាយផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយឧបេក្ខាផង ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានចម្រើនល្អហើយ យ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគប្បីសិក្សាយ៉ាងនេះថា ក្នុងវេទនាទាំង- ឡាយ ។បេ។ ក្នុងចិត្ត ។បេ។ អាត្មាអញនឹងពិចារណាឃើញ នូវធម៌ក្នុងធម៌ ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបាន

ចម្រើនហើយ បានធ្វើឲ្យច្រើនហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគួរចម្រើនសមាធិនេះ ដែលប្រកបដោយវិតក្កវិចារផង អ្នកគួរចម្រើនសមាធិដែលមិនមានវិតក្ក មានតែវិចារផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្ក មិនមានវិចារផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយបីតិផង អ្នកគួរចម្រើនសមាធិ ដែលមិនមានបីតិផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយសេចក្តីសប្បាយផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយឧបេក្ខាផង ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានចម្រើនល្អហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកនឹងទៅក្នុងទីណាៗ អ្នកនឹងទៅសប្បាយ ក្នុងទីនោះៗ អ្នកនឹងឈរនៅ ក្នុងទីណាៗ អ្នកនឹងឈរនៅសប្បាយ ក្នុងទីនោះៗ អ្នកនឹងអង្គុយ ក្នុងទីណាៗ អ្នកនឹងអង្គុយសប្បាយ ក្នុងទីនោះៗ អ្នកនឹងសម្រេចការដេក ក្នុងទីណាៗ អ្នកនឹងសម្រេចការដេកសប្បាយ ក្នុងទីនោះៗ ។

គ្រានោះ ភិក្ខុនោះ ដែលព្រះដ៏មានព្រះភាគ ទូន្មានដោយឱវាទនេះហើយ ក៏ក្រោកចាកអាសនៈ ហើយក្រាបថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ ។ លំដាប់នោះ ភិក្ខុនោះ តែម្នាក់ឯងចៀសចេញទៅ មិនធ្វេសប្រហែស មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្តចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏ធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌ដែលមានព្រហ្មចរិយៈជាទីបំផុតនោះ ដោយប្រាជ្ញាដ៏ប្រសើររបស់ខ្លួនក្នុងបច្ចុប្បន្ននេះ

ដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាន ប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គ-ភាវនាកិច្ចដទៃទៀត ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះ មិនមានឡើយ ។ មានសេចក្តីសរសើរថា បណ្តាព្រះអរហន្តទាំងឡាយ ភិក្ខុនោះ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

# អដ្ឋកថា

## សន្ទិត្តសូត្រ

[ ៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសន្ទិត្តសូត្រទី ១០ ដូចតទៅនេះ បទថា **ឯវមេវ** បានដល់ ដោយមិនមានហេតុ ។ ម្យ៉ាងទៀត ដោយប្រការដែលភិក្ខុនោះអង្វរនោះឯង ។ បទថា **មោឃបុរិសា** បានដល់ បុរសវង្វេងបុរសទទេ ។ បទថា **អជ្ឈេសន្តិ** ប្រែថា រមែងអង្វរ ។ បទថា **អនុពន្ធិតព្វំ** បានដល់ គប្បីជាប់តាម ដោយការជាប់តាមឥរិយាបថ ។ បទថា **មញ្ញន្តិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់សង្កត់សង្កិនដើម្បីឲ្យកើតការអើពើ ទើបត្រាស់យ៉ាងនោះ ។

បានឮថា ភិក្ខុនោះ កាលប្រទានឱវាទឲ្យហើយ ក៏ប្រកបរឿយៗ ដល់សេចក្តីប្រមាទប៉ុណ្ណោះ ស្តាប់ធម៌ហើយ ក៏នៅក្នុងទីនោះឯង មិនប្រាថ្នាបំពេញ

សមណធម៌ ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់តិះដៀលយ៉ាងនេះហើយ តែព្រោះលោកសម្បូរដោយឧបនិស្ស័យនៃអរហត្ត ដូច្នោះ កាលទ្រង់ឱវាទទៀត ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុ ព្រោះហេតុនោះឯង អ្នកគប្បីសិក្សាយ៉ាងនេះ ដូច្នេះ ។ ក្នុងពាក្យនោះ ទ្រង់ត្រាស់មូលសមាធិដែលល្មមធ្វើចិត្តឲ្យជាឯកគ្គតា ដោយអំណាចចិត្ត ដែលប្រព្រឹត្តទៅក្នុងខាងក្នុងរបស់លោក ដោយព្រះឱវាទនេះជាបឋមថា ចិត្តរបស់អាត្មាអញតាំងមាំហើយក្នុងខាងក្នុង និងជាចិត្តតាំងមាំដោយល្អ និងអកុសលបាបធម៌ដែលកើតឡើងហើយ នឹងមិនគ្របសង្កត់ចិត្តតាំងនៅ បន្ទាប់អំពីនោះ ដើម្បីទ្រង់សម្តែងថា អ្នកមិនគួរពេញចិត្តដោយហេតុត្រឹមប៉ុណ្ណេះ គប្បីចម្រើនសមាធិនោះយ៉ាងនេះ ទើបឲ្យភិក្ខុនោះចម្រើនភាវនា ដោយអំណាចមេត្តាយ៉ាងនេះថា ម្នាលភិក្ខុ កាលណាចិត្តរបស់អ្នកតាំងមាំហើយក្នុងខាងក្នុង ជាចិត្តតាំងមាំដោយល្អហើយ អកុសលបាបធម៌ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តតាំងនៅ គ្រានោះ ភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះថា មេត្តាចេតោវិមុត្តិ ឈ្មោះថា អាត្មាអញអប់រំហើយ ។បេ។ ប្រារព្ធល្អហើយ ដូច្នេះហើយ ទើបត្រាស់ទៀតថា ម្នាលភិក្ខុ កាលណាសមាធិនេះ ឈ្មោះថា អ្នកអប់រំហើយ ធ្វើឲ្យច្រើនហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគប្បីចម្រើនសមាធិនេះ ដែលមានវិតក្កផង មានវិចារៈផង ។ គប្បីជ្រាបអត្ថនៃពាក្យនោះដូចតទៅនេះថា ម្នាលភិក្ខុ កាលណា មូលសមាធិនេះ អ្នកអប់រំហើយដោយអំណាចមេត្តាយ៉ាងនេះ កាលនោះ

អ្នកកាលមិនត្រេកអរដោយហេតុមានប្រមាណប៉ុណ្ណោះ កាលធ្វើមូលសមាធិនោះ ឲ្យដល់ឈានពួក ៤ ឈានពួក ៥ ក្នុងអារម្មណ៍ដទៃ គប្បីចម្រើនដោយន័យជាដើមថា **សវិតក្កំ សវិចារំ** ដូច្នេះ ។

កាលត្រាស់យ៉ាងនេះហើយ កាលទ្រង់សម្តែងព្រហ្មវិហារដ៏សេសជាខាងមុខដល់លោកថា អ្នកគប្បីធ្វើការអប់រំឈានពួក ៤ ឈានពួក ៥ ក្នុងអារម្មណ៍ដទៃ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុ កាលណាសមាធិនេះ អ្នកអប់រំហើយ យ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគប្បីសិក្សាយ៉ាងនេះថា ករុណាចេតោវិមុត្តិ ឈ្មោះថា អាត្មាអញចម្រើនហើយ ។ កាលទ្រង់សម្តែងការចម្រើនឈានពួក ៤ ពួក ៥ មានមេត្តាជាដើម ជាប្រធានយ៉ាងនេះហើយ ដើម្បីសម្តែងកាយានុបស្សនាជាដើមឲ្យជាប្រធានទៀត ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុ កាលណាសមាធិនេះ អ្នកអប់រំហើយ អប់រំល្អហើយយ៉ាងនេះ ម្នាលភិក្ខុ គ្រានោះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញពិចារណារឿយៗ ឃើញកាយក្នុងកាយ ដូច្នេះហើយ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុ កាលណាសមាធិនេះ អ្នកអប់រំហើយ អប់រំល្អហើយយ៉ាងនេះ ម្នាលភិក្ខុ អ្នកនឹងប្រព្រឹត្តទៅ ដោយឥរិយាបថណាមួយ អ្នកក៏នឹងប្រព្រឹត្តទៅយ៉ាងផាសុក ក្នុងឥរិយាបថនោះឯង ។ បណ្តាបទទាំងនោះ បទថា **គញ្ឆសិ** ប្រែថា នឹងទៅ ។ ដោយបទថា **ផាសុយេវ** នេះ ទ្រង់សម្តែងដល់អរហត្ត ។ ពិតហើយ បុគ្គលសម្រេចអរហត្ត ឈ្មោះថា នៅដោយផាសុកក្នុងឥរិយាបថ ។

# សុត្តន្តបិដក

## គយាសីសសូត្រទី ១១

[ ៧១ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងគយាសីស-ប្រទេស ទៀបស្រុកគយា ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ កាលមុនអំពីការត្រាស់ដឹង តថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ ស្គាល់នូវពន្លឺដោយច្បាស់លាស់ តែមិនឃើញនូវរូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា ប្រសិនបើតថាគតស្គាល់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ញាណទស្សនៈរបស់តថាគតនេះ គប្បីបរិសុទ្ធយ៉ាងក្រៃលែងយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម័យដទៃទៀត តថាគតនោះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង តែមិនឋិតនៅជាមួយ មិនចរចាជាមួយ មិនដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងឡាយនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ប្រសិនបើតថាគតស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំង-ឡាយផង គប្បីឋិតនៅជាមួយ គប្បីចរចាជាមួយ គប្បីដល់នូវការសាកច្ឆាជាមួយនឹងទេវតាទាំងឡាយផង ញាណទស្សនៈរបស់តថាគតនេះ គប្បីបរិសុទ្ធក្រៃលែង យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម័យមួយទៀត តថាគត

នោះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ក៏ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងឡាយនោះផង តែមិនស្គាល់នូវទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណោះៗ ដូច្នេះផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើតថាគតស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ក៏ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងឡាយនោះផង តថាគតស្គាល់នូវទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណោះៗ ដូច្នេះផង ញាណទស្សនៈរបស់តថាគតនោះ គប្បីបរិសុទ្ធក្រៃលែងយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សម័យខាងក្រោយមក តថាគតនោះឯង ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ក៏ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងនោះផង ស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណោះៗ ដូច្នេះផង តែមិនស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ ដោយផលកម្មនេះ ដូច្នេះផង ស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ ដោយ

ផលកម្មនេះដូច្នេះផង តែមិនស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង តែមិនស្គាល់ទេវតាទាំងនោះថា ទេវតាទាំងនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង តែមិនស្គាល់ទេវតាទាំងនោះថា អាត្មាអញ ធ្លាប់នៅជាមួយនឹងទេវតាទាំង-ឡាយនេះ ឬថា មិនធ្លាប់នៅជាមួយ ដូច្នេះផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើអាត្មាអញស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងនោះផង គប្បីស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណោះៗ ដូច្នេះផង គប្បីស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ ដោយផលកម្មនេះដូច្នេះផង គប្បីស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង គប្បីស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង គប្បីស្គាល់នូវទេវតាទាំងនោះថា អាត្មាអញធ្លាប់នៅជាមួយនឹងទេវតាទាំងឡាយ ឬថា មិនធ្លាប់នៅជាមួយទេ ដូច្នេះផង ញាណ-

ទស្សនៈរបស់តថាគតនេះ គប្បីបរិសុទ្ធក្រៃលែងយ៉ាងនេះ ។ ម្នាលភិក្ខុទាំង-ឡាយ សម័យដទៃទៀត តថាគតនោះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆាជាមួយនឹងទេវតាទាំងឡាយនោះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណោះៗ ដូច្នេះផង ស្គាល់ទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ ដោយផលកម្មនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា អាត្មាអញធ្លាប់នៅជាមួយនឹងទេវតាទាំងឡាយនោះ ឬថា មិនធ្លាប់នៅជាមួយទេ ដូច្នេះផង ។ ម្នាលភិក្ខុទាំងឡាយ អធិទេ-វញ្ញាណទស្សនៈ ( ការដឹងនិងការឃើញនូវទេវតាដ៏ក្រៃលែង ) របស់តថាគតមានបរិវដ្ដ ៨ ប្រការយ៉ាងនេះ មិនបរិសុទ្ធដរាបណា ម្នាលភិក្ខុទាំងឡាយតថាគត ក៏មិនទាន់ប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក និងព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្សដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយមួយទៀត កាលណា អធិទេវញ្ញាណទស្សនៈ របស់តថាគតមានបរិវដ្ដ ៨

ប្រការយ៉ាងនេះ បរិសុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតប្តេជ្ញាខ្លួន ថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្ស ។ មិនតែប៉ុណ្ណោះសោត ញាណទស្សនៈក៏កើតឡើងដល់តថាគតថា ចេតោវិមុត្តិរបស់តថាគតមិនកម្រើក ជាតិនេះជាជាតិទីបំផុត ក្នុងកាលឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។

# អដ្ឋកថា

## គយាសីសសូត្រ

[ ៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគយាសីសសូត្រទី ១១ ដូចតទៅនេះ បទថា **ឯតទវោច** សេចក្តីថា កាលត្រាស់ប្រាប់វិតក្កដែលកើតឡើង ក្នុងទីដែលធ្វើសេចក្តីព្យាយាមរបស់ខ្លួនដល់ភិក្ខុសង្ឃ ទើបត្រាស់ពាក្យជាដើមថា **បុព្វាហំ ភិក្ខវេ ។** បទថា **ឱភាសំ** បានដល់ ពន្លឺនៃទិព្វចក្ខុញាណ ។ បទថា **ញាណទស្សនំ** បានដល់ ទស្សនៈ ពោល គឺញាណដែលជាតួទិព្វចក្ខុ ។ បទថា **សន្និវុត្ថបុព្វំ** ប្រែថា ធ្លាប់នៅរួមគ្នា ។ តែក្នុងព្រះសូត្រនេះ ញាណ ៨ ប៉ុណ្ណោះ មកដោយចំពោះក្នុងបាលីជាបឋម ។ គឺទិព្វចក្ខុញាណ ឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ យថាកម្មុបគញ្ញាណ អនាគតំសញ្ញាណ

បច្ចុប្បន្នំសញ្ញាណ អតីតំសញ្ញាណ បុព្វេនិវាសញ្ញាណ ។ តែត្រាស់សរុបញាណទាំងនេះ គឺវិបស្សនាញាណ ៩ មគ្គញ្ញាណ ៤ ផលញ្ញាណ ៤ បច្ចវេក្ខណាញ្ញាណ ៤ បដិសម្ភិទាញាណ ៤ អសាធារណាញ្ញាណ ៦ និងញាណ ៨ នោះ រមែងឈ្មោះថា ត្រាស់ព្រះសូត្រនេះ ដោយប្រការដូច្នេះ ។

**អដ្ឋកថា គយាសីសសូត្រទី ១១ ចប់**

# សុត្តន្តបិដក

## អភិភាយតនសូត្រទី ១២

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ អភិភាយតនៈ ( ហេតុជាគ្រឿងគ្របសង្កត់នូវធម៌ជាសត្រូវផង នូវអារម្មណ៍ផង ) នេះមាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណច្រើន មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តី

សម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិ-កាយតនៈទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណច្រើន មានសម្បុរល្អ ឬសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបខៀវ មានសម្បុរខៀវ ជាទីចង្អុលប្រាប់ថា នេះមានសម្បុរខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៥ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបលឿង មានសម្បុរលឿង ជាទីចង្អុលប្រាប់ថា នេះមានសម្បុរលឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបក្រហម មានសម្បុរក្រហម ជាទីចង្អុល

ប្រាប់ថា នេះមានសម្បុរក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៧ ។ បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបស មានសម្បុរស ជាទីចង្អុលប្រាប់ថា នេះមានសម្បុរស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៨ ។ ម្នាលភិក្ខុទាំងឡាយ អភិភាយតនៈមាន ៨ យ៉ាងនេះឯង ។

# អដ្ឋកថា

## អភិភាយតនសូត្រ

[ ៧២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអភិភាយតនសូត្រទី ១២ ដូចតទៅនេះ បទថា **អភិភាយតនានិ** ប្រែថា ហេតុនៃការគ្របសង្កត់ ។ គ្របសង្កត់អ្វី គ្របសង្កត់ធម៌ដែលជាសត្រូវខ្លះ អារម្មណ៍ខ្លះ ។ ពិតហើយ ហេតុនៃការគ្របសង្កត់ទាំងនោះ រមែងគ្របសង្កត់ធម៌ដែលជាសត្រូវ ដោយភាវៈជាបដិបក្ខ គ្របសង្កត់អារម្មណ៍ដោយភាវៈ ដែលបុគ្គលមានញាណខ្ពស់ក្រៃលែងឡើងទៅ ។ ក្នុងពាក្យថា **អជ្ឈត្តំ រូបសញ្ញី** ដូច្នេះជាដើម រមែងឈ្មោះថា ជាអ្នកកំណត់រូបខាងក្នុង ដោយអំណាចបរិកម្មរូបខាងក្នុង ។ ពិតហើយ ភិក្ខុកាល

ធ្វើបរិកម្មនីលកសិណខាងក្នុង រមែងធ្វើត្រង់សក់ ត្រង់ប្រមាត់ ត្រង់ភ្នែក ។ កាលធ្វើបរិកម្មបីតកសិណ រមែងធ្វើត្រង់ខ្លាញ់ខាប់ ត្រង់ស្បែក បាតដៃ និងបាតជើង ឬត្រង់ផ្នែកដែលមានពណ៌លឿងនៃភ្នែក ។ ការធ្វើបរិកម្មលោហិត-កសិណ រមែងធ្វើត្រង់សាច់ ត្រង់ឈាម ត្រង់អណ្តាត ឬត្រង់ផ្នែកពណ៌ក្រហមរបស់ភ្នែក ។ កាលធ្វើបរិកម្មឱទាតកសិណ រមែងធ្វើត្រង់ឆ្អឹង ត្រង់ធ្មេញ ត្រង់ក្រចក ឬផ្នែកពណ៌សនៃភ្នែក ពណ៌នោះខៀវសុទ្ធ លឿងសុទ្ធ ក្រហមសុទ្ធ សសុទ្ធ ក៏មិនមែន ជាពណ៌មិនបរិសុទ្ធទាំងអស់ ។

បទថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** សេចក្តីថា បរិកម្មឯណាមួយនៃភិក្ខុណាកើតឡើងខាងក្នុង តែនិមិត្តកើតឡើងខាងក្រៅ ភិក្ខុនោះឈ្មោះថា កំណត់រូបខាងក្នុង ដោយអំណាចបរិកម្មខាងក្នុង និងអប្បនាខាងក្រៅ ហៅថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** ប្រែថា រូបីបុគ្គល គឺបុគ្គលដែលបានរូបជ្ឈានណាមួយ រមែងឃើញរូបខាងក្រៅ ។ បទថា **បរិត្តានិ** បានដល់ មិនពង្រីក ។ បទថា **សុវណ្ណទុព្វណ្ណានិ** ប្រែថា មានពណ៌ល្អ ឬពណ៌អាក្រក់ ។ គប្បីជ្រាបថា ត្រាស់អភិកាយតនៈនេះ ដោយអំណាចបរិត្តារម្មណ៍នោះឯង ។ បទថា **តានិ អភិភុយ្យ** សេចក្តីថា បុគ្គលដែលមានភ្លើងធាតុល្អ បានអាហារត្រឹមតែមួយវែក គិតថា នឹងមានប្រយោជន៍អ្វីដែលគប្បីបរិភោគក្នុងអាហារនេះ ទើបបួមមក ធ្វើឲ្យជាពុំនូតតែមួយ យ៉ាងណា បុគ្គលមានញាណខ្ពស់ មានញាណចាស់ក្លា ក៏ដូច្នោះដូចគ្នា គ្របសង្កត់

រូបទាំងនោះ ដោយគិតថា នឹងមានប្រយោជន៍អ្វី ដែលអញគប្បីចូលសមាបត្តិក្នុងបរិត្តារម្មណ៍នេះ នេះមិនជាការផ្ចង់ចិត្ត សម្រាប់អាត្មាអញឡើយ ដូច្នេះហើយ ទើបចូលសមាបត្តិ អធិប្បាយថា ភិក្ខុនោះ រមែងដល់អប្បនាក្នុងអារម្មណ៍នេះ ព្រមគ្នានឹងការធ្វើនិមិត្តឲ្យកើតឡើងនោះឯង ។ បទថា **ជានាមិ បស្សាមិ** នេះ ព្រះមានព្រះភាគត្រាស់ដល់ការបង្វែរចិត្តនៃភិក្ខុនោះ ឯការបង្វែរចិត្តនោះឯង តែងមានដល់ភិក្ខុដែលចេញអំពីសមាបត្តិ មិនមែនមានក្នុងសមាបត្តិ ។ បទថា **ឯវំសញ្ញី ហោតិ** សេចក្តីថា ជាអ្នកមានសេចក្តីសម្គាល់យ៉ាងនេះ ដោយអាភោគសញ្ញាខ្លះ ដោយឈានសញ្ញាខ្លះ ។ ព្រោះអភិភវនសញ្ញា គឺសញ្ញាក្នុងការគ្របសង្កត់ រមែងមានដល់លោកសូម្បីក្នុងសមាបត្តិ តែអាភោគសញ្ញា គឺសញ្ញាក្នុងការបង្វែរចិត្ត រមែងមានដល់លោកដែលចេញអំពីសមាបត្តិប៉ុណ្ណោះ ។

បទថា **អប្បមាណានិ** បានដល់ ពង្រីកទំហំចេញទៅមិនកំណត់ អធិប្បាយថា ធំ ក្នុងពាក្យថា **អភិភុយ្យ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា បុគ្គលស៊ីច្រើន បានអាហារបន្ថែមឡើងណាមួយ ទើបពោលថា សូម្បីវត្ថុដទៃៗ ក៏យកមកចុះ នុ៎ះ នឹងធ្វើអ្វីដល់អញបាន មិនឃើញអាហារនោះជារបស់ច្រើន យ៉ាងណា បុគ្គលមានញាណខ្ពស់ មានញាណចាស់ក្លា ក៏ដូច្នោះដូចគ្នា គ្របសង្កត់រូបទាំងនោះ ដោយគិតថា ប្រយោជន៍អ្វីដែលអញគប្បីចូលសមាបត្តិក្នុងអារម្មណ៍នេះ នេះមិនជាប្រមាណក្នុងការធ្វើចិត្តឲ្យជាឯកគ្គតា

មិនធ្ងន់ចិត្តដល់អាត្មាអញឡើយ ដូច្នេះហើយ ទើបចូលសមាបត្តិ អធិប្បាយថា ធ្វើចិត្តឲ្យដល់អប្បនាក្នុងអារម្មណ៍នេះ មួយអន្លើដោយធ្វើនិមិត្តឲ្យកើតឡើងនោះឯង ។ បទថា **អជ្ឈត្តំ អរូបសញ្ញី** សេចក្តីថា វៀរចាកការបរិកម្មសញ្ញាក្នុងរូបខាងក្នុង ព្រោះមិនបានរូប ឬព្រោះមិនត្រូវការរូប ។

បទថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** សេចក្តីថា បរិកម្មក្តី និមិត្តក្តី នៃបុគ្គលណាកើតខាងក្រៅ បុគ្គលនោះមានការកំណត់រូបខាងក្នុង ដោយអំណាចបរិកម្ម និងអប្បនាខាងក្រៅយ៉ាងនេះ ត្រាស់ហៅថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានន័យដូចពោលហើយក្នុងអភិភាយតនៈទី ៤ នោះឯង ។ ក្នុងអារម្មណ៍ទាំង ៤ នេះ បរិត្តារម្មណ៍មកហើយដោយអំណាចវិតក្កចរិត អប្បមាណារម្មណ៍មកហើយ ដោយអំណាចមោហចរិត អារម្មណ៍ដែលមានពណ៌ល្អមកហើយ ដោយអំណាចទោសចរិត អារម្មណ៍មានពណ៌គ្រោតគ្រាតមកហើយដោយអំណាចរាគចិត្ត ។ ព្រោះអារម្មណ៍ទាំងនេះ ជាសប្បាយរបស់ចរិតទាំងនោះ ។ ព្រោះអារម្មណ៍ទាំងនេះ ដែលជាសប្បាយនោះ បានពោលហើយក្នុងចរិយនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ក្នុងអភិភាយតនៈទី ៥ ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា

បទថា **នីលានិ** នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចការរួមយកពណ៌ទាំងអស់ ។ បទថា **នីលវណ្ណានិ** ត្រាស់ដោយអំណាចវណ្ណៈ គឺពណ៌ ។ បទថា **នីលនិទស្សនានិ** ត្រាស់ដោយអំណាចឃើញរូបពណ៌ខៀវ ។ លោក

អធិប្បាយថា រូបដែលមានពណ៌មិនលាយគ្នា មិនប្រាកដឱកាស ប្រាកដ មានពណ៌ខៀវជាដើមដូចគ្នា ។ បទថា **នីលនិភាសានិ** នេះ ត្រាស់ដោយឱកាស អធិប្បាយថា ពន្លឺ មានពណ៌ខៀវ គឺប្រកបដោយពន្លឺពណ៌ខៀវ ។ ដោយពាក្យនេះ ព្រះមានព្រះភាគទ្រង់សម្តែងថា ពណ៌ទាំងនោះជាពណ៌បរិសុទ្ធដោយល្អ ។ ពិតហើយ ព្រះមានព្រះភាគ ត្រាស់អភិភាយតនៈទាំង ៤ នេះ ដោយអំណាចពណ៌ដែលបរិសុទ្ធប៉ុណ្ណោះ ។ ក្នុងកសិណទាំងនេះ ការធ្វើកសិណ ការបរិកម្ម និងអប្បនាវិធី មានជាដើមថា ព្រះយោគីកាលកំណត់នីលកសិណ រមែងកំណត់និមិត្តក្នុងពណ៌ខៀវ ត្រង់ផ្កា ត្រង់សំពត់ ឬត្រង់វណ្ណធាតុ ពណ៌ទាំងនេះបានពោលពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គឯណោះ ។ល។

**អដ្ឋកថា អភិភាយតនសូត្រទី ១២ ចប់**

# សុត្តន្តបិដក

## វិមោក្ខសូត្រទី ១៣

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ វិមោក្ខនេះមាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលមានរូបជ្ឈាន រមែងឃើញនូវរូប គឺកសិណទាំងឡាយ

( មាននីលកសិណជាដើម ) នេះជាវិមោក្ខទី ១ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ( មានសក់ជាដើម ) រមែងឃើញនូវរូបខាងក្រៅទាំងឡាយ គឺកសិណ ( មាននីលកសិណជាដើម ) នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់ថា វណ្ណកសិណដ៏បរិសុទ្ធ នេះជាវិមោក្ខទី ៣ ។ ព្រោះកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវវិញ្ញាណ-ញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវសញ្ញាវេទយិតនិរោធ ( សេចក្តីរលត់នៃសញ្ញា និងវេទនា ) នេះជាវិមោក្ខទី ៨ ។ ម្នាលភិក្ខុទាំងឡាយ វិមោក្ខមាន ៨ យ៉ាងនេះឯង ។

# អដ្ឋកថា

## វិមោក្ខសូត្រ

[ ៧៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិមោក្ខសូត្រទី ១៣ ដូចតទៅនេះ បទថា **វិមោក្ខា** សេចក្តីថា ឈ្មោះថា វិមោក្ខ ព្រោះសភាវៈដូចម្តេច ។ ព្រោះសភាវៈដែលរួចផុតក្រៃលែងដោយល្អ ។ ឈ្មោះថា សភាវៈរួចផុតក្រៃលែងនោះដូចម្តេច គឺសភាវៈដែលរួចផុតក្រៃលែងចាកធម៌ដែលជាសត្រូវ និងសភាវៈដែលផុតក្រៃលែងដោយល្អចាកអំណាចការត្រេកអរក្រៃលែងក្នុងអារម្មណ៍ ។ លោកអធិប្បាយថា ការប្រព្រឹត្តទៅក្នុងអារម្មណ៍ ព្រោះភាវៈដែលប្រាសចាកការសង្ស័យ ដោយការមិនប្រកាន់មាំ ដូចទារកដេកបណ្តោយខ្លួនលើភ្លៅឪពុក ដូច្នោះ ។ តែអត្ថនេះមិនមានក្នុងវិមោក្ខក្រោយ មានក្នុងវិមោក្ខមុនប៉ុណ្ណោះ ។

ក្នុងបទថា **រូបី រូបានិ បស្សតិ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា រូប គឺរូបជ្ឈានដែលឲ្យកើតឡើងហើយ ដោយអំណាចនីលកសិណជាដើម ក្នុងអារម្មណ៍ទាំងឡាយ មានសក់ជាដើមក្នុងខាងក្នុង ។ រូបជ្ឈាននោះ មានដល់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះឈ្មោះថា **រូបី** គឺអ្នកមានរូបជ្ឈាន ។ បទថា **ពហិទ្ធា រូបានិ បស្សតិ** សេចក្តីថា ភិក្ខុបានរូបជ្ឈាន រមែងឃើញរូប មាននីលកសិណជាដើម សូម្បីមានខាងក្រៅដោយឈានចក្ខុ ដោយពាក្យនេះ ព្រះមានព្រះភាគទ្រង់សម្តែងរូបាវចរជ្ឈានទាំង ៤ នៃបុគ្គលដែលឲ្យឈានកើតក្នុងកសិណទាំងឡាយ ដែលមានទាំងខាងក្នុង និងខាងក្រៅ ។ បទថា **អជ្ឈត្តំ**

**អរូបសញ្ញី** សេចក្តីថា បុគ្គលមិនកំណត់រូបខាងក្នុង អធិប្បាយថា បុគ្គលមិនឲ្យរូបាវចរជ្ឈានកើតឡើងក្នុងអារម្មណ៍ មានសក់ជាដើមរបស់ខ្លួន ។ ដោយពាក្យនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងរូបាវចរជ្ឈាននៃបុគ្គលដែលធ្វើបរិកម្មខាងក្រៅ ហើយឲ្យឈានកើតឡើងខាងក្រៅនោះឯង ដោយពាក្យថា **សុភន្តេវ អធិមុត្តោ ហោតិ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងឈានក្នុងវណ្ណកសិណ មាននីលកសិណជាដើម ដែលបរិសុទ្ធដោយល្អ ។ ក្នុងពាក្យថា **សុភន្តេវ** ប្រែថា ស្អាត ការចងចិត្តថាស្អាត រមែងមិនមានខាងក្នុងអប្បនាក៏ពិត តែភិក្ខុណា ធ្វើសុភកសិណដែលបរិសុទ្ធល្អឲ្យជាអារម្មណ៍ ព្រោះហេតុដែលភិក្ខុនោះពាល់ត្រូវ លោកពោលថា ជាអ្នកបង្អោនចិត្តទៅថា ស្អាត ដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើទេសនាយ៉ាងនោះ ។

តែក្នុងបដិសម្ភិទាមគ្គ ពោលថា **សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខ** តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ។បេ។ សត្វទាំងឡាយ ដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនមេត្តា ភិក្ខុមានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិសទី ១ ។បេ។ សត្វទាំងឡាយ ដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនករុណា ភិក្ខុមានចិត្តប្រកបដោយមុទិតា ។បេ។ សត្វទាំងឡាយដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនមុទិតា ភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ។បេ។ សត្វទាំងឡាយដែលគេមិនគួរខ្ពើមរអើម ព្រោះ

បានចម្រើនឧបេក្ខា យ៉ាងនេះឯង ឈ្មោះថា **សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខ** ។ ពាក្យណាដែលគប្បីពោលក្នុងពាក្យថា **សព្វសោ រូបសញ្ញានំ** ដូច្នេះជាដើម ពាក្យទាំងអស់នោះបានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។ បទថា **អយំ អដ្ឋមោ វិមោក្ខោ** សេចក្តីថា នេះឈ្មោះថា វិមោក្ខទី ៨ ព្រោះលះ គឺព្រោះលែងចោលនូវខន្ធទាំង ៤ ដោយប្រការទាំងពួង ៕

**អដ្ឋកថា វិមោក្ខសូត្រទី ១៣ ចប់**

# សុត្តន្តបិដក

## បឋមវោហារសូត្រទី ១៤ ជាដើម

[ ៧៤ ] ម្នាលភិក្ខុទាំងឡាយ អនរិយវោហារ ( វោហារមិនប្រសើរ ) នេះមាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺមិនឃើញ និយាយថា ឃើញ ១ មិនឮ និយាយថា ឮ ១ មិនបានហិតភ្លក្ស និយាយថា បានហិតភ្លក្ស ១ មិនដឹងនិយាយថា ដឹង ១ ឃើញនិយាយថា មិនឃើញ ១ ឮ និយាយថា មិនឮ ១ បានហិតភ្លក្ស និយាយថា មិនបានហិតភ្លក្ស ១ ដឹង និយាយថាមិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ អនរិយវោហារ មាន ៨ យ៉ាងនេះឯង ។

[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ អរិយវោហារ ( វោហារដ៏ប្រសើរ ) នេះមាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺមិនឃើញ និយាយថា មិនឃើញ

១ មិនឮ និយាយថា មិនឮ ១ មិនបានហិតក្លិន និយាយថា មិនបានហិតក្លិន ១ មិនដឹង និយាយថា មិនដឹង ១ ឃើញ និយាយថា ឃើញ ១ ឮ និយាយថា ឮ ១ បានហិតក្លិន និយាយថា បានហិតក្លិន ១ ដឹង និយាយថា ដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយវោហារ មាន ៨ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមវោហារសូត្រទី ១៤ ជាដើម

[ ៧៤-៧៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមវោហារសូត្រទី ១៤ ជាដើម ដូច្នេះ បទថា **អនរិយវោហារា** បានដល់ ពាក្យដែលមិនមែនរបស់ព្រះអរិយៈ គឺពាក្យដែលមានទោស ។ បុគ្គលរមែងពោលវោហារទាំងនោះ ដោយចេតនាណា ពាក្យថា **អនរិយវោហារា** នោះ ជាឈ្មោះនៃចេតនាទាំងនោះ ។

សូត្រទី ១៥ គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។

**អដ្ឋកថា បឋមវោហារសូត្រទី ១៤ ជាដើមចប់**

# សុត្តន្តបិដក

## បរិសសូត្រទី ១៦

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ បរិសទ្យមាន ៨ ពួក ។ ៨ ពួក តើអ្វីខ្លះ ។ គឺខត្តិយបរិសទ្យ ១ ព្រាហ្មណបរិសទ្យ ១ គហបតិបរិសទ្យ ១ សមណបរិសទ្យ ១ ចាតុម្មហារាជិកបរិសទ្យ ១ តាវត្តិង្សបរិសទ្យ ១ មារបរិសទ្យ ១ ព្រហ្មបរិសទ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតធ្លាប់បានចូលទៅរកខត្តិយបរិសទ្យ ជាច្រើនរយ ។ ក្នុងបរិសទ្យនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ដល់នូវការសាកច្ឆាជាមួយផង សម្បុររបស់ជនទាំងនោះក្នុងបរិសទ្យនោះ យ៉ាងណា សម្បុររបស់តថាគតក៏យ៉ាងនោះដែរ សំឡេងរបស់ជនទាំងនោះ យ៉ាងណា សំឡេងរបស់តថាគត ក៏យ៉ាងនោះដែរ មួយទៀត តថាគត បានញុំាងជនទាំងនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា កាលដែលតថាគតកំពុងនិយាយ ជនទាំងនោះ មិនស្គាល់ថា ជនដែលកំពុងនិយាយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬមនុស្សដូច្នេះឡើយ លុះតថាគតញុំាងជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បាត់ទៅ កាលដែលតថាគតបាត់ទៅហើយ ចំណែកជនទាំងនោះ នៅតែមិនស្គាល់ថា ជនដែលបាត់ទៅហើយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្ស ដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ធ្លាប់ចូលទៅរកព្រាហ្មណបរិសទ្យ ជាច្រើនរយ ។បេ។ បានចូលទៅរក គហបតិបរិសទ្យ សមណបរិសទ្យ ចាតុម្មហារាជិកបរិសទ្យ តាវត្តិង្សបរិសទ្យ មារបរិសទ្យ

*ព្រហ្មបរិសទ្យ ។ ក្នុងព្រហ្មបរិសទ្យនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ដល់នូវការសាកច្ឆាជាមួយផង សម្បុររបស់ព្រហ្មទាំងនោះ ក្នុងបរិសទ្យនោះយ៉ាងណា សម្បុររបស់តថាគត ក៏យ៉ាងនោះដែរ សំឡេងរបស់ព្រហ្មទាំងនោះយ៉ាងណា សំឡេងរបស់តថាគត ក៏យ៉ាងនោះដែរ មួយទៀត តថាគតបានញុំាំងព្រហ្មទាំងនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា កាលដែលតថាគតកំពុងនិយាយ ចំណែកព្រហ្មទាំងនោះមិនស្គាល់ថា ជនដែលកំពុងនិយាយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្ស ដូច្នេះឡើយ ។ លុះតថាគតញុំាំងព្រហ្មទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏បាត់ទៅ កាលដែលតថាគត បាត់ទៅហើយ ចំណែកព្រហ្មទាំងនោះ នៅតែមិនស្គាល់ថា ជនដែលបាត់ទៅហើយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ បរិសទ្យ ៨ ពួកនេះឯង ។*

# អដ្ឋកថា

## បរិសសូត្រ

*[ ៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិសសូត្រទី ១៦ ដូចតទៅនេះ បទថា* **ខត្តិយបរិសា** *បានដល់ ប្រជុំ គឺសមាគមនៃខត្តិយបរិស័ទ ។ ក្នុងបទទាំង*

ពួនក៏ន័យនេះ ។ បទថា **អនេកសតំ ខត្តិយបរិសំ** សេចក្តីថា ខត្តិយបរិស័ទ ដូចជាសមាគមនៃព្រះបាទពិម្ពិសារ សមាគមនៃព្រះញាតិ និងសមាគមនៃស្តេចលិច្ឆវីជាដើម ការដែលព្រះសាស្តាទ្រង់យាងចូលរកខត្តិយបរិស័ទជាដើម ក្នុងចក្រវាលដទៃ ក៏រមែងមានដូចគ្នា ។ បទថា **សល្លបិតបុព្វំ** បានជល់ធ្លាប់ធ្វើការប្រាស្រ័យចរចា ។ បទថា **សាកច្ឆា** សេចក្តីថា សូម្បីសាកច្ឆាតថាគតក៏ធ្លាប់ចូលទៅសន្ទនា ។ បទថា **យាទិសកោ តេសំ វណ្ណោ** សេចក្តីថា បរិស័ទទាំងនោះ មានសម្បុរសក៏មាន សម្បុរខ្មៅក៏មាន សម្បុរ ២ ក៏មាន ព្រះសាស្តាមានព្រះឆវីវណ្ណដូចមាសតែម្យ៉ាង ។ តែពាក្យនោះ ត្រាស់អាស្រ័យទ្រង់ទ្រាយ ។ ម្យ៉ាងទៀត ជនទាំងនោះ រមែងស្គាល់ថា ជាក្សត្រព្រាហ្មណ៍ជាដើម ត្រង់ទ្រង់ទ្រាយរបស់ជនទាំងនោះតែម្យ៉ាងប៉ុណ្ណោះ តែព្រះមានព្រះភាគមិនមែនដូចគ្នានឹងពួកមិលក្ខៈផង មិនបានទ្រទ្រង់កុណ្ឌលកែវមណីប្រដាប់គង់ដោយភេទជាព្រះពុទ្ធនោះឯង ។ តែជនទាំងនោះ រមែងឃើញទ្រង់ទ្រាយថាដូចខ្លួន ។ បទថា **យាទិសកោ តេសំ សរោ** សេចក្តីថា ជនទាំងនោះ ជាអ្នកមានសំឡេងដាច់ៗ ក៏មាន ជាអ្នកមានសំឡេងដូចសំឡេងក្អាក៏មាន ជាអ្នកមានសំឡេងដូចសំឡេងក្អែកក៏មាន តែព្រះសាស្តាមានព្រះសូរសៀងដូចព្រហ្មតែម្យ៉ាង ។ ពាក្យនេះត្រាស់សំដៅយកភាសាដទៃ ។ បើព្រះសាស្តាប្រថាប់ត្រាស់លើរាជអាសនៈ ក្នុងខត្តិយបរិស័ទនោះសោត ក្សត្រទាំងនោះ ក៏មានការគិតថា ថ្ងៃនេះ ព្រះរាជាត្រាស់ដោយព្រះសូរសៀងដ៏ពីរោះ

តែព្រះមានព្រះភាគត្រាស់ហើយ ទ្រង់ចៀសចេញទៅ ក្សត្រទាំងនោះឃើញព្រះរាជាយាងមកទៀត ទើបកើតការពិចារណាថា បុគ្គលនេះជានរណាហ្ន៎ ។ បណ្ដាបទទាំងនោះ បទថា **កោ នុ ខោ អយំ** សេចក្ដីថា ក្សត្រទាំងនោះសូម្បីពិចារណាយ៉ាងនេះថា ព្រះរាជាអង្គនេះ គឺនរណាហ្ន៎ កាលត្រាស់ដោយអាការក្រាងក្រអៅ ដោយមគធភាសា សីហឡភាសា ក្នុងទីនេះ ក្នុងឥឡូវនេះឯង ក៏បាត់ខ្លួនទៅហើយ ព្រះរាជាអង្គនេះ ជាទេវតា ឬមនុស្ស ដូច្នេះ ក៏មិនស្គាល់ ។ សួរថា ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ដល់បុគ្គលមិនស្គាល់យ៉ាងនេះ ដើម្បីប្រយោជន៍អ្វី ។ ឆ្លើយថា ដើម្បីឲ្យជាវាសនា គឺការអប់រំបារមី ព្រះមានព្រះភាគទ្រង់សម្ដែងដោយសង្ឃឹមផលអនាគតយ៉ាងនេះថា ធម៌ដែលបុគ្គលនោះស្ដាប់ហើយយ៉ាងនេះ រមែងជាបច្ច័យក្នុងអនាគតនោះឯង គប្បីជ្រាបកំណើតនៃពាក្យជាដើមថា **អនេកសតំ ព្រាហ្មណបរិសំ** ដូច្នេះ ដោយអំណាចសមាគមនៃសោណទណ្ឌព្រាហ្មណ៍ជាដើម និងដោយអំណាចចក្រវាលដទៃ ៕ល៚

## អដ្ឋកថា បរិសសូត្រទី ១៦ ចប់

# សុត្តន្តបិដក

## ភូមិចាលសូត្រទី ១៧

[ ៧៧ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ លុះទ្រង់ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងវេសាលីហើយ ត្រឡប់ អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មាន អាយុថា ម្នាលអានន្ទ ចូរអ្នកកាន់យកនិសីទនៈទៅ យើងនឹងចូលទៅសម្រាក ក្នុងវេលាថ្ងៃឯបាវាលចេតិយ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏កាន់និសីទនៈ ទៅតាមខាងក្រោយៗ ព្រះដ៏មានព្រះភាគទៅ ។

គ្រានោះ ព្រះដ៏មានព្រះភាគ កាលស្តេចចូលទៅកាន់បាវាលចេតិយ លុះ ចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះ ដ៏មានព្រះភាគគង់ហើយ ក៏ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយ ជាទីគួរត្រេកអរ គោតមកចេតិយ ជាទីគួរត្រេកអរ ពហុបុត្តកចេតិយ ជាទីគួរត្រេកអរ សត្តម្ពចេតិយ ជាទីគួរ ត្រេកអរ សារន្ទទចេតិយ ជាទីគួរត្រេកអរ បាវាលចេតិយ ជាទីគួរត្រេកអរ ។ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើឲ្យ ច្រើន បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ

ទុក បានប្រារព្ធល្អហើយ ម្នាលអានន្ទ បុគ្គលនោះ ទោះបីប្រាថ្នា នឹងគប្បីឋិត នៅអស់ ១ អាយុកល្ប ឬលើសជាង ១ អាយុកល្បក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជា យាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ ម្នាលអានន្ទ តថាគត បើប្រាថ្នាគប្បីឋិតនៅអស់ ១ អាយុកល្ប ឬលើស ជាង ១ អាយុកល្បក៏បាន ។ ឯព្រះអានន្ទដ៏មានអាយុ ទុកជាព្រះដ៏មានព្រះ ភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱកាសជាឱឡារិកយ៉ាងនេះហើយ ក៏មិន អាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនបានអារាធនាព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ឋិតនៅអស់ ១ អាយុកល្ប បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះសុគត ឋិតនៅអស់ ១ អាយុកល្ប ដើម្បី ប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ ពួកទេវតា និងមនុស្សដូច្នេះសោះ ព្រោះមារបូលមកជ្រែកគំនិត ។ ព្រះដ៏មាន ព្រះភាគទ្រង់មានព្រះពុទ្ធដីកា ជាគម្រប់ពីរដងផង ។ ព្រះដ៏មានព្រះភាគ ទ្រង់ មានព្រះពុទ្ធដីកានឹងព្រះអានន្ទដ៏មានអាយុ ជាគម្រប់ ៣ ដងផងថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយ ជាទីគួរត្រេកអរ គោតមកចេតិយ ជាទីគួរត្រេកអរ ពហុបុត្តកចេតិយ ជាទីគួរត្រេកអរ សត្តម្ពចេតិយ ជាទីគួរ ត្រេកអរ សារន្ទទចេតិយ ជាទីគួរត្រេកអរ បាវាលចេតិយ ជាទីគួរត្រេកអរ ។

ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ ។បេ។ ម្នាលអានន្ទ តថាគតបើប្រាថ្នា គប្បីឋិតនៅអស់ ១ អាយុកល្ប ឬលើសជាង ១ អាយុកល្បក៏បាន ។ ឯព្រះអានន្ទដ៏មានអាយុ ទុកជាព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិកយ៉ាងនេះហើយ ក៏នៅតែមិនអាចយល់សេចក្តីច្បាស់លាស់បានឡើយ ហើយមិនបានអារាធនាព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ឋិតនៅអស់ ១ អាយុកល្ប បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះសុគត ឋិតនៅអស់ ១ អាយុកល្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយដូច្នេះសោះឡើយ ព្រោះមារចូលមកជ្រែកគំនិត ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅចុះ អ្នកចូរសម្គាល់នូវកាលដែលគួរនឹងទៅក្នុងកាលឥឡូវនេះចុះ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ រួចក៏ក្រោកចាកអាសនៈ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ រួចអង្គុយទៀបគល់ឈើមួយជិតព្រះដ៏មានព្រះភាគ ។

គ្រានោះ កាលបើព្រះអានន្ទដ៏មានអាយុ ចៀសចេញទៅ មិនយូរប៉ុន្មាន

មារមានចិត្តបាប ក៏បានពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគបរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះដ៏មានព្រះភាគបានត្រាស់វាចានេះហើយថា នែមារមានចិត្តបាប ពួកភិក្ខុ ជាសាវ័ករបស់តថាគត ដែលឈ្លាសវៃ ក្លៀវក្លា ដល់នូវការក្រេមចាកយោគៈ ជាពហូសូតទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ បានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួនហើយ ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបាន បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនបានសង្កត់សង្កិនដោយល្អតាមពាក្យ ដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យ នៅមិនទាន់មានដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុជាសាវ័ករបស់ព្រះដ៏មានព្រះភាគ បានឈ្លាសវៃ ក្លៀវក្លា ដល់នូវការក្រេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកប

ដោយបាដិហារ្យបានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះដ៏មានព្រះភាគ ត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកភិក្ខុនី ជាសាវិកាបស់តថាគត មិនទាន់មានដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ។បេ។ ពួកឧបាសក ជាសាវក របស់តថាគត មិនទាន់មានដរាបណា ។បេ។ ពួកឧបាសិកា ជាសាវិការបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ដល់នូវការក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ បានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្តតាំងទុក បើក ចែក ធ្វើឲ្យងាយបាន បានសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ សម្តែងធម៌ប្រកបដោយបាដិហារ្យ នៅមិនទាន់មានដរាបណាទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឧបាសិកា ជាសាវិកា របស់ព្រះដ៏មានព្រះភាគដែលឈ្លាសវាងវៃ ក្លៀវក្លា ដល់នូវការក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ ហើយ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្តតាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិននូវបរប្បវាទ

ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យបានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា នឹងមិនទាន់ពេញបរិបូណ៌ដរាបណា មួយទៀត ពួកទេវតា និងមនុស្ស មិនទាន់ចេះសម្តែងបានដោយប្រពៃដរាបណា តថាគតនឹងមិនបរិនិព្វានដរាបនោះ ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រហ្មចារ្យរបស់ព្រះដ៏មានព្រះភាគនេះ បានខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតា និងមនុស្ស ចេះសម្តែងបានដោយល្អហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ ។ ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់មាន

សតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារ ឰដ៏បាវាលចេតិយ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ ក៏កើតការកក្រើកផែនដីយ៉ាងធំ គួរឲ្យភ្ញាក់ភ្ញើកព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្ដីនេះហើយ ក៏បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វាន
ដែលមានគុណប្រឹងមិនបានផង នូវភពផង ទ្រង់លះបង់
នូវសង្ខារ ដែលនាំសត្វទៅកាន់ភព ទ្រង់ត្រេកអរនូវ
អារម្មណ៍ខាងក្នុង ( ដោយអំណាចវិបស្សនា ) មាន
ព្រះហឫទ័យតាំងមាំហើយ ( ដោយអំណាចសមថៈ )
ទ្រង់បានទម្លាយនូវបណ្ដាញ គឺកិលេស ដែលកើត
មាននៅក្នុងព្រះអង្គដូចជាក្រោះ ។

លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្ដីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ការកក្រើកផែនដីនេះជាយ៉ាងធំ ការកក្រើកផែនដីនេះធំណាស់តើ គួរឲ្យភ្ញាក់ភ្ញើក ឲ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ ហេតុដូចម្ដេច បច្ច័យដូចម្ដេចហ្ន៎ ដែលនាំឲ្យការកក្រើកផែនដី ជាយ៉ាងធំម៉្លេះ ។ ទើបព្រះអានន្ទដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏

ចម្រើន ការកក្រើកផែនដីនេះជាយ៉ាងធំ បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះ ធំពេកណាស់តើ គួរឲ្យភ្ញាក់ភ្ញើក គួរឲ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំម្ល៉េះ ។

ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ហេតុប្បច្ច័យដែលនាំឲ្យកើតការកក្រើកផែនដីនេះមាន ៨ យ៉ាង ។ ហេតុប្បច្ច័យទាំង ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ មហាប្រឹថពីនេះ ប្រតិស្ឋានទៅលើទឹក ឯទឹកប្រតិស្ឋានទៅលើខ្យល់ ខ្យល់ប្រតិស្ឋានទៅលើអាកាស ម្នាលអានន្ទ សម័យដែលមានខ្យល់បក់ ខ្យល់ធំដែលបក់នោះ រមែងធ្វើទឹកឲ្យកក្រើក ឯទឹកដែលកក្រើកមកហើយ ក៏ធ្វើផែនដី ឲ្យកក្រើកដែរ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ១ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត សមណៈក្តី ព្រាហ្មណ៍ក្តី ដែលមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញ ក្នុងចិត្ត ឬទេវតាដែលមានឫទ្ធិធំ មានអានុភាពធំ បុគ្គលនោះ បានចម្រើនបឋវីសញ្ញា ឲ្យមានកម្លាំងតិច ចម្រើនអាបោសញ្ញាឲ្យមានកម្លាំងច្រើន បុគ្គលនោះ រមែងធ្វើផែនដីនេះ ឲ្យកក្រើករំភើប ញាប់ញ័របាន ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ២ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វ ច្យុតចាកពួកទេវតា ដែលឋិតនៅក្នុងឋានតុសិតមានសតិ និងសម្បជញ្ញៈ យាងចុះកាន់ព្រះមាតុឧទរ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំភើប ញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៣ ដែលនាំឲ្យកក្រើក

ផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលពោធិសត្វមានសតិ និងសម្បជញ្ញៈ ទ្រង់ប្រសូតចាកព្រះមាតុឧទរ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៤ ដែលនាំឲ្យកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលព្រះតថាគត ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៥ ដែលនាំឲ្យកើតការកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលព្រះតថាគត ញ៉ាំងអនុត្តរធម្មចក្រ ឲ្យប្រព្រឹត្តទៅ កាលនោះ ផែនដីនេះតែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៦ ដែលនាំឲ្យកើតការកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលព្រះតថាគតមានសតិ និងសម្បជញ្ញៈ ដាក់ចុះនូវអាយុសង្ខារ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៧ ដែលនាំឲ្យកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលព្រះតថាគត បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៨ ដែលនាំឲ្យការកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ ហេតុប្បច្ច័យដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ មាន ៨ យ៉ាងនេះឯង ។

**ចាលវគ្គទី ២ ចប់**

### ឧទ្ទានក្នុងបាលវគ្គនោះ គឺ

និយាយអំពីសេចក្តីប្រាថ្នា ១ កិក្ខុដែលគួរ ១ ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ ដោយសង្ខេប ១ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងគយាសីសប្រទេស ១ អភិ-កាយតនៈ ១ វិមោក្ខ ១ វោហារ ២ លើក បរិសទ្ធ ១ ផែនដីកម្រើក ១ ។

---

## អដ្ឋកថា

## ភូមិចាលសូត្រ

[ ៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភូមិចាលសូត្រទី ១៧ ដូចតទៅនេះ ក្នុងបទថា **និសីទនំ** នេះ លោកបំណងយកកំណាត់ស្បែក ។ បទថា **ឧទេន-ចេតិយំ** លោកពោលដល់វិហារ ដែលគេសាងក្នុងលំនៅរបស់ឧទេនយក្ខ ។ ក្នុងគោតមចេតិយជាដើម ក៏មានន័យដូចគ្នា ។ បទថា **ភាវិតា** ប្រែថា ចម្រើនហើយ ។ បទថា **ពហុលីកតា** ប្រែថា ធ្វើឲ្យច្រើន ។ បទថា **យានីកតា** ប្រែថា ធ្វើឲ្យដូចជាយានដែលទឹមហើយ ។ បទថា **វត្ថុកតា** ប្រែថា ធ្វើឲ្យដូចជាវត្ថុ គឺទីតាំង ព្រោះអត្ថថា ជាទីពឹងអាស្រ័យ ។ បទថា **អនុដ្ឋិតា** ប្រែថា តាំងទុកហើយ ។ បទថា **បរិចិតា** ប្រែថា សន្សំហើយដោយជុំវិញ គឺចម្រើនល្អហើយ ។ បទថា **សុសមារទ្ធា** ប្រែថា ផ្តើមទុកល្អ

ហើយ ។

ព្រះមានព្រះភាគ កាលត្រាស់ដោយមិនបានកំណត់យ៉ាងនេះហើយ កាលទ្រង់សម្តែងដោយកំណត់ពិតប្រាកដទៀត ទើបត្រាស់ពាក្យជាដើមថា **តថាគតស្ស ខោ** ដូច្នេះ ។ ក្នុងទីនេះ បទថា **កប្បំ** បានដល់ អាយុកប្ប គឺកំណត់អាយុយ៉ាងច្រើនរបស់មនុស្សក្នុងយុគនោះៗ ។ ព្រះមានព្រះភាគ គប្បីតាំងព្រះជន្មនៅអស់កំណត់អាយុ របស់មនុស្សទាំងឡាយ ក្នុងសម័យនោះៗ ។ បទថា **កប្បាវសេសំ វា** បានដល់ ឬច្រើនជាង ១០០ ឆ្នាំ ដែលបានត្រាស់ទុកថា តិច ឬក្រៃលែងជាង តែព្រះមហាសិវត្ថេរពោលថា ធម្មតាព្រះពុទ្ធទាំងឡាយទ្រង់មិនបន្ទឹក្នុងទីដែលមិនមែនឋានៈ ព្រះមានព្រះភាគទ្រង់ចូលសមាបត្តិរឿយៗ ទ្រង់សង្កត់វេទនាទៀបបរិនិព្វានបាន គប្បីតាំងនៅបានអស់មួយភទ្ទកប្ប ។ សួរថា ព្រោះហេតុអ្វី ទើបទ្រង់មិនតាំងនៅអស់មួយភទ្ទកប្ប ។ ឆ្លើយថា ឈ្មោះថា សរីរៈដែលមានចិត្តគ្រប់គ្រង ត្រូវជរាលក្ខណៈ មានធ្មេញបាក់ជាដើមគ្របសង្កត់ តែព្រះពុទ្ធទាំងឡាយ មិនមានធ្មេញបាក់ជាដើមឡើយ តែងបរិនិព្វានក្នុងអាយុចំណែកទី ៥ គឺ ២០ ឆ្នាំ ៥ ដង ក្នុងកាលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មហាជននោះឯង ។ បណ្តាមហាសាវក ដែលត្រាស់ដឹងតាមព្រះសម្ពុទ្ធ ព្រះមហាសាវកមួយអង្គបរិ-និព្វានហើយ រមែងតាំងនៅដូចដង្គត់ឈើ ឬតាំងនៅដោយមានភិក្ខុកំលោះនិងសាមណេរចោមរោម បន្ទាប់អំពីនោះ ក៏គប្បីត្រូវមើលងាយថា ពុទ្ធោ

បរិស័ទរបស់ព្រះពុទ្ធទាំងឡាយ ព្រោះដូច្នោះ ទើបទ្រង់មិនតាំងទៅ កាល ពោលយ៉ាងនេះ ការហៅកាលថា អាយុកប្បនេះឯង ក៏កំណត់ទុកក្នុង អដ្ឋកថាហើយ ។

បទថា **តំ** ក្នុងពាក្យថា **យថាតំ មារេន បរិយុដ្ឋិចិត្តោ** នេះ ត្រឹម តែជានិបាត អធិប្បាយថា បុថុជ្ជនពួកខ្លះ មានចិត្តត្រូវមារបណ្តាល មានចិត្ត ត្រូវមារគ្របសង្កត់ មិនអាចដឹងច្បាស់បាន យ៉ាងណា ព្រះអានន្ទក៏មិនអាច ដឹងច្បាស់បាន ដូច្នោះដូចគ្នា ។ ព្រោះមាររមែងគ្របសង្កត់ចិត្តរបស់លោក ដែលមិនទាន់លះវិបល្លាស ១២ បាន ដោយប្រការទាំងពួង ។ ព្រះថេរៈលះ វិបល្លាសទាំង ៤ មិនបាន ដោយហេតុនោះ ទើបមារគ្របសង្កត់ចិត្តរបស់ លោក ។ សួរថា មារនោះ កាលធ្វើការបណ្តាលចិត្ត តើធ្វើដូចម្តេច ។ ឆ្លើយ ថា រមែងសម្តែងរូបារម្មណ៍ដែលគួរខ្លាចខ្លះ ឲ្យបានឮសទ្ទារម្មណ៍ដែលគួរ ខ្លាចខ្លះ បន្ទាប់អំពីនោះ សត្វទាំងឡាយបានឃើញភាពដូច្នោះ ឬបានស្តាប់ សំឡេងដូច្នោះ ក៏អស់សតិ ហាមាត់ មារក៏ស៊កដៃចូលទៅតាមមាត់របស់ សត្វទាំងនោះ ហើយច្របាច់បេះដូង បន្ទាប់អំពីនោះ សត្វទាំងឡាយ ក៏អស់ ការដឹងខ្លួន តាំងនៅ តែមារនេះ មិនអាចស៊កដៃចូលតាមមាត់របស់ព្រះថេរៈ ក៏បានសម្តែងតែអារម្មណ៍ដែលគួរខ្លាច ព្រះថេរៈបានឃើញអារម្មណ៍នោះ ទើបមិនដឹងច្បាស់នូវនិមិត្តឱភាស ។ សួរថា ព្រះមានព្រះភាគ ទាំងដែល ទ្រង់ជ្រាប ព្រោះហេតុអ្វី ទើបត្រាស់ដល់ ៣ ដង ។ ឆ្លើយថា ព្រោះទ្រង់ធ្វើ

ឲ្យសេចក្តីសោកជូរស្បើយ ដោយការលើកទោសឡើងថា នុ៎ះជាការធ្វើមិនល្អរបស់លោក នុ៎ះជាការខុសរបស់លោក ក្នុងកាលព្រះអានន្ទទូលអារាធនាថា សូមព្រះមានព្រះភាគ ទ្រង់តាំងជន្មាយុសិនចុះ ។

ក្នុងបទថា **មារោ បាបិមា** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ឈ្មោះថាមារ ព្រោះប្រកបសត្វទុកក្នុងសេចក្តីវិនាសឲ្យស្លាប់ទៅ ។ បទថា **បាបិមា** នេះ ជាវេវចនៈនៃបទថា **មារោ** នោះឯង ។ ពិតហើយ មារនោះ គេហៅថា **បាបិមា** ព្រោះប្រកបដោយបាបធម៌ ។ បទថា **ភាសិតា ខោ បនេសា** សេចក្តីថា ពិតហើយ មារនេះមកត្រង់ពោធិមណ្ឌលដ្ឋានក្នុងសប្តាហ៍ទី ៨ ក្នុងកាលព្រះមានព្រះភាគត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ហើយទូលថា បពិត្រព្រះមានព្រះភាគ ទ្រង់បំពេញបារមីទាំងឡាយ ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ ទ្រង់សម្រេចតាមគោលបំណងហើយ សព្វញ្ញុតញ្ញាណ ទ្រង់ត្រាស់ដឹងហើយ ប្រយោជន៍អ្វី ដែលទ្រង់ត្រូវប្រមើលមើលសត្វលោក ហើយទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់បរិនិព្វានក្នុងកាលឥឡូវនេះ ដូចក្នុងថ្ងៃនេះ ។ ព្រះមានព្រះភាគ ទ្រង់ឃាត់មារនោះថា **ន តាវាហំ** តថាគតមិនបរិនិព្វានមុនឡើយ ដូច្នេះជាដើម ។ មារពោលពាក្យជាដើមថា **ភាសិតា ខោ បនេសា ភន្តេ** ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយ ដូច្នេះ សំដៅយកពាក្យថា **ន តាវាហំ** នោះ ។

ក្នុងបទទាំងនេះ បទថា **វិយត្តា** បានដល់ ជាអ្នកឈ្លាសដោយ

អំណាចមគ្គ ។ ជាបុគ្គលដែលលោកដឹកនាំហើយយ៉ាងនោះ ។ ជាបុគ្គលក្លៀវក្លាយ៉ាងនោះ ។ បទថា **ពហុស្សុតា** បានដល់ ឈ្មោះថា ជាពហូសូតព្រោះមានពុទ្ធវចនៈដែលស្តាប់ហើយច្រើន ដោយអំណាចបិដក ៣ ។ ឈ្មោះថា ធម្មធរ ព្រោះទ្រទ្រង់ធម៌នោះឯង ។ ម្យ៉ាងទៀត គប្បីឃើញសេចក្តីក្នុងទីនេះយ៉ាងនេះថា ជាពហូសូតខាងបរិយត្តិ និងជាពហូសូតខាងបដិវេធ ឈ្មោះថា ទ្រទ្រង់ធម៌ ព្រោះទ្រទ្រង់បរិយត្តិធម៌ និងបដិវេធធម៌នោះឯង ។ បទថា **ធម្មានុធម្មប្បដិបន្នា** បានដល់ បដិបត្តិខាងវិបស្សនា ដែលសមគួរដល់អរិយធម៌ ។ បទថា **សាមីចិប្បដិបន្នា** បានដល់ បដិបត្តិបដិបទាដ៏សមគួរ ។ បទថា **អនុធម្មចារិនោ** ប្រែថា ជាអ្នកមានប្រក្រតីប្រព្រឹត្តធម៌សមគួរដល់ធម៌ ។ បទថា **សកំ អាចរិយកំ** បានដល់ វាទៈអាចារ្យរបស់ខ្លួន ។ បទថា **អាចិក្ខិស្សន្តិ** ជាដើម ជាវេវចនៈនៃគ្នានិងគ្នា ។ បទថា **សហធម្មេន** បានដល់ ដោយពាក្យដែលមានហេតុ គឺមានការណ៍ ។ បទថា **សប្បាដិហារិយំ** សេចក្តីថា ព្រះអរិយសាវកទាំងនោះ រមែងសម្តែងធម៌ឲ្យជាធម៌នាំសត្វចេញចាកទុក្ខ ។

បទថា **ព្រហ្មចរិយំ** បានដល់ សាសនព្រហ្មចរិយៈទាំងមូលដែលសង្គ្រោះដោយសិក្ខាទាំង ៣ ។ បទថា **ឥទ្ធំ** បានដល់ សម្រេចដោយអំណាចត្រេកអរក្នុងឈាន ។ បទថា **ផីតំ** បានដល់ ដល់នូវការចម្រើនដោយអំណាចអភិញ្ញា សមាបត្តិ ដូចផ្ការីកពេញកម្លាំង ។ បទថា **វិត្ថារិកំ**

បានដល់ ផ្សាយទៅដោយអំណាចប្រតិស្ឋាននៅក្នុងទិសាភាគនោះៗ ។ បទថា **ពាហុជញ្ញំ** បានដល់ ជនជាច្រើនដឹងហើយ គឺចាក់ធ្លុះហើយ ដោយអំណាចការត្រាស់ដឹងនៃជនច្រើន ។ បទថា **បុថុភូតំ** ប្រែថា ដល់នូវការក្រាស់ដោយអាការទាំងពួង ដល់នូវភាពក្រាស់ដូចម្តេច ដល់នូវភាពក្រាស់ដរាបទាល់តែទេវតា និងមនុស្ស ទាំងឡាយប្រកាសល្អហើយ ។ អធិប្បាយថា ទេវតា និងមនុស្សទាំងឡាយ ដែលជាវិញ្ញូជនមានប្រមាណប៉ុនណា ទេវតា និងមនុស្សទាំងអស់ មានប្រមាណប៉ុណ្ណោះ ប្រកាសដោយល្អហើយ ។

បទថា **អប្បោស្សុក្កោ** បានដល់ ជាអ្នកមិនមានសេចក្តីអាល័យ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលមារមានចិត្តបាប តាំងអំពីសប្តាហ៍ទី ៨ អ្នកកាលត្រាច់ស្រែកថា សូមព្រះមានព្រះភាគទ្រង់បរិនិព្វានឥឡូវនេះចុះ សូមព្រះសុគតបរិនិព្វាន ឥឡូវនេះចុះ ដូច្នេះ ឥឡូវនេះ តាំងអំពីថ្ងៃនេះទៅ ចូរអ្នកវៀរនូវការឧស្សាហ៍ចុះ កុំធ្វើនូវការព្យាយាមឲ្យតថាគតបរិនិព្វានឡើយ ។ បទថា **សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់តាំងសតិមាំ កំណត់ដោយញាណ ទ្រង់ដាក់ គឺលះអាយុសង្ខារ ក្នុងការដាក់អាយុសង្ខារនោះ ព្រះមានព្រះភាគ ទ្រង់មិនបានដាក់អាយុសង្ខារដូចយកដៃលែងដុំដីក៏មិនមែន តែព្រះមានព្រះភាគទ្រង់កើតព្រះតម្រិះឡើងថា តថាគតនឹងចូលសមាបត្តិត្រឹម ៣ ខែប៉ុណ្ណោះ បន្ទាប់អំពីនោះ មិនចូលទៀតឡើយ ។ បទថា **ឱស្សជ្ជិ** ត្រាស់សំដៅយកពាក្យនោះ ។ បាឋៈថា **អវស្សជ្ជិ**

ដូច្នេះក៏មាន ។

បទថា **មហាភូមិចាលោ** បានដល់ ផែនដីធំកម្រើក ។ បានឮថា ក្នុងកាលនោះ លោកធាតុទាំង ១០០០០ កម្រើកហើយ ។ បទថា **ភឹសនកោ** ប្រែថា គប្បីខ្លាច ។ បទថា **ទេវទុន្ទុភិយោ ច ផលឹសុ** បានដល់ ស្គរទិព្វក៏លាន់ឮឡើង ភ្លៀងគ្រហឹមគំរាម ផ្គរបន្ទោរវៀសខុសរដូវកាល លោកអធិប្បាយថា ភ្លៀងពុំដូកាល ។ បទថា **ឧទានំ ឧទានេសិ** សេចក្តីថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់បន្លឺឧទាន ព្រោះទ្រង់ព្រះតម្រិះថា ឈ្មោះថា បុគ្គលណាម្នាក់ គប្បីពោលថា ព្រះមានព្រះភាគត្រូវមារជាប់តាមអំពីខាងក្រោយ ពោលរំខានថា សូមព្រះអង្គបរិនិព្វានចុះ ទើបទ្រង់ដាក់អាយុសង្ខារព្រោះការខ្លាច ព្រោះហេតុនោះ បុគ្គលនោះ ចូរកុំមានឱកាសឡើយ ដូច្នេះហើយ ទើបទ្រង់បន្លឺព្រះឧទានដែលហៀរចេញមកដោយកម្លាំងព្រះបីតិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឧទាននោះ ដូចតទៅនេះថា គ្រឿងផ្សំសម្រាប់ធ្វើការផ្ទារ ឈ្មោះថា **តុល** ព្រោះបុគ្គលថ្លឹងបាន គឺកំណត់បាន ព្រោះជារបស់ប្រាកដដល់សត្វទាំងពួង មានខ្លែស្រែក និងខ្លែចចកជាដើម ។ ឈ្មោះថា **តុល** នោះ គឺអ្វី គឺកម្មចំណែកកាមាវចរ ។ គ្រឿងតាក់តែងភពដែលថ្លឹងបានមិនមានឬដែលថ្លឹងបាននៃបុគ្គលនោះមិនមាន គឺមិនមានលោកិយកម្មដទៃដែលដូចគ្នាព្រោះហេតុនោះ ទើបឈ្មោះថា **អតុល** ។ គ្រឿងតាក់តែងភព ដែលឈ្មោះថា **អតុល** នោះ គឺអ្វី គឺកម្មចំណែកមហគ្គតៈ ។ ម្យ៉ាងទៀត កាមាវចរកម្ម

រូបាវចរកម្ម ឈ្មោះថា **តុល** ។ អរូបាវចរកម្ម ឈ្មោះថា **អតុល** ។ ម្យ៉ាងទៀត វិបាកតិច ឈ្មោះថា **តុល** វិបាកច្រើន ឈ្មោះថា **អតុល** ។ បទថា **សម្ភវំ** បានដល់ ជាហេតុនៃភព ។ បទថា **ភវសង្ខារំ** បានដល់ គ្រឿងតាក់តែងថ្មី អធិប្បាយថា កម្មដែលធ្វើឲ្យជាគំនរ ធ្វើឲ្យជាដុំ ។ បទថា **អវស្សជ្ជិ** ប្រែថា ដាក់ហើយ ។ បទថា **មុនិ** បានដល់ មុនី គឺព្រះពុទ្ធ ។ បទថា **អជ្ឈត្តរតោ** បានដល់ ត្រេកអរហើយខាងក្នុងខ្លួន ។ បទថា **សមាហិតោ** បានដល់ មានចិត្តតាំងមាំហើយដោយឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា **អភិន្ទិ កវចមិវ** បានដល់ ទម្លាយហើយ ដូចអ្នកចម្បាំងទម្លាយក្រោះ ។ បទថា **អត្តសម្ភវំ** បានដល់ កិលេសដែលកើតក្នុងខ្លួន លោកពោលអធិប្បាយដូច្នេះថា មុនីលះបង់លោកិយកម្ម ពោល គឺ **តុល** និង **អតុល** ដែលបានឈ្មោះថា **សម្ភវ** ព្រោះអត្ថថា មានវិបាក និងបានឈ្មោះថា **ភវ-សង្ខារ** ព្រោះអត្ថថា តាក់តែងភព និងជាបុគ្គលត្រេកអរខាងក្នុងខ្លួន មានចិត្តតាំងមាំ ទម្លាយបង់នូវកិលេសដែលកើតក្នុងខ្លួន ដូចអ្នកចម្បាំងធំក្នុងសង្គ្រាមទម្លាយក្រោះ ដូច្នោះ ។ ម្យ៉ាងទៀត បទថា **តុលំ** បានដល់ កាលថ្លឹង កាលពិចារណា ។ បទថា **អតុលញ្ចសម្ភវំ** បានដល់ ព្រះនិព្វាន និងភព ។ បទថា **ភវសង្ខារំ** បានដល់ កម្មដែលនាំសត្វទៅកាន់ភព ។ បទថា **អវស្សជ្ជិ មុនិ** សេចក្ដីថា ព្រះមុនី គឺព្រះពុទ្ធ ទ្រង់ពិចារណាដោយន័យជាដើមថា ខន្ធ ៥ មិនទៀង ការរលត់ខន្ធ ៥ គឺនិព្វានទៀង ទ្រង់ឃើញជាទោសក្នុងភព

និងអានិសង្សក្នុងព្រះនិព្វានហើយ ទ្រង់លះបង់កម្មជាគ្រឿងតាក់តែងភព ដែលជាមូលនៃខន្ធទាំងឡាយនោះ ដោយអរិយមគ្គដែលធ្វើនូវការអស់នៃកម្ម ដូចពោលយ៉ាងនេះថា រមែងប្រព្រឹត្តទៅដើម្បីការអស់កម្ម ដូច្នេះ ព្រះអង្គទ្រង់ត្រេកអរខាងក្នុង មានព្រះហឫទ័យតាំងមាំ ទម្លាយដែនកើតនៃខ្លួន ដូចក្រោះបានដូចម្ដេច សេចក្ដីពិត ព្រះអង្គទ្រង់ត្រេកអរក្នុងខាងក្នុង ដោយអំណាចវិបស្សនា មានព្រះហឫទ័យតាំងមាំ ដោយអំណាចសមថៈ ទ្រង់ទម្លាយកិលេសជាតិទាំងអស់ ដែលបានឈ្មោះថា **អត្តសម្ភវ** ព្រោះកើតក្នុងខ្លួនដែលស្រោបអត្តភាព តាំងនៅដូចក្រោះ ដោយកម្លាំងសមថៈ និងវិបស្សនា ចាប់តាំងអំពីខាងដើម ដោយអាការយ៉ាងនេះ និងកម្ម ដែលទ្រង់ធ្វើដោយមិនមានកិលេស ឈ្មោះថា ទ្រង់លះបង់ហើយ ព្រោះមិនមានបដិសន្ធិ ទ្រង់លះកម្ម ដោយលះកិលេសបាន ដូចពោលមកដូច្នេះ ធម្មតាបុគ្គលលះកិលេសបានហើយ រមែងមិនមានការខ្លាច ព្រោះដូច្នោះ គប្បីជ្រាបថា ទ្រង់មិនខ្លាច ទ្រង់ដាក់អាយុសង្ខារ ទ្រង់បន្លឺឧទានដើម្បីឲ្យសត្វលោកដឹងថា ទ្រង់មិនខ្លាច ។

បទថា **យំ មហាវាតា** សេចក្ដីថា ដោយសម័យណា ឬក្នុងសម័យណា ខ្យល់ព្យុះ ឈ្មោះឧក្ខេបកវាតក៏តាំងឡើង ។ ឧក្ខេបកវាតនោះ ក៏បក់ផ្ដាច់ខ្យល់ដែលទ្រទឹកដែលមានកម្រាស់ ៩ សែន ៦ ម៉ឺនយោជន៍ បន្ទាប់អំពីនោះ ទឹកក្នុងអាកាសក៏ធ្លាក់ កាលទឹកធ្លាក់ ផែនដីក៏ធ្លាក់ ខ្យល់ដែលទ្រទឹកក៏ទ្រទឹកទុកទៀតដោយកម្លាំងរបស់ខ្លួន ដូចទ្រទឹកទុកក្នុងធម្មក្រក ដូច្នោះ ។

បន្ទាប់អំពីនោះ ទឹកក៏ខ្ពស់ឡើង កាលទឹកខ្ពស់ឡើង ផែនដីក៏ខ្ពស់ឡើង ។ ទឹកហូរទៅហើយយ៉ាងនេះ ក៏ធ្វើឲ្យផែនដីកម្រើក ។ ការកម្រើកយ៉ាងនេះ រមែងមានមកដល់សព្វថ្ងៃនេះ ។ ការស្រុតចុះ និងការប៉ោងឡើង រមែងមិនប្រាកដ ព្រោះផែនដីច្រើន ។ បទថា **មហិទ្ធិកោ មហានុភាវោ** សេចក្តីថា ឈ្មោះថា មានឫទ្ធិច្រើន ព្រោះមានការសម្រេចច្រើន ឈ្មោះថា មានអានុភាព ច្រើន ព្រោះមានវត្ថុដែលគប្បីសោយច្រើន ។ បទថា **បរិត្តា** បានដល់ មានកម្លាំងតិច ។ បទថា **អប្បមាណា** បានដល់ មានកម្លាំង ។ បទថា **សោ ឥមំ បឋវឹ កម្បេតិ** សេចក្តីថា សមណៈ ឬព្រាហ្មណ៍នោះ ធ្វើឫទ្ធិឲ្យកើតហើយ កាលនឹងឲ្យសង្វេគ ទើបធ្វើផែនដីឲ្យកម្រើក ដូចព្រះមហា-មោគ្គល្លាន កាលល្បងនូវឫទ្ធិ ក៏ធ្វើផែនដីឲ្យកម្រើក ដូចសង្ឃរក្ខិតសាមណេរជាក្មួយរបស់ព្រះមហានាគ ។ បទថា **សង្កម្បេតិ** បានដល់ កម្រើកដោយជុំវិញ ។ បទថា **សម្បកម្បេតិ** នេះ ជាវេវចនៈនៃបទថា **សង្កម្បេតិ** នោះឯង ដូច្នោះ បណ្តាហេតុប្បច្ច័យដែលធ្វើឲ្យផែនដីកម្រើក ៨ ប្រការនេះ ១ ព្រោះធាតុកម្រើក ២ ព្រោះអានុភាពរបស់អ្នកមានឫទ្ធិ ៣-៤ ព្រោះតេជះនៃបុណ្យ ៥ ព្រោះតេជះនៃញាណ ៦ ព្រោះអំណាចឲ្យសាធុការ ៧ ព្រោះសេចក្តីករុណាជាសភាវៈ ៨ ព្រោះសំឡេងទ្រហោយំ ។ កាលព្រះមហាសត្វចុះកាន់គភ៌ព្រះមាតា និងប្រសូតចាកគភ៌ព្រះមាតា ផែនដីកម្រើកព្រោះតេជះនៃបុណ្យរបស់ព្រះមហាសត្វនោះ ។ ក្នុងសម័យត្រាស់ដឹងអភិសម្ពោធិញ្ញាណ

ផែនដីត្រូវតេជះនៃព្រះញាណពាល់ត្រូវហើយ ទើបញាប់ញ័រ ។ ក្នុងសម័យប្រកាសព្រះធម្មចក្រ ផែនដីនៅស្ងៀម ក្នុងភាវៈនៃសាធុការ កាលឲ្យសាធុការក៏កម្រើក ។ ក្នុងសម័យទ្រង់ដាក់អាយុសង្ខារ ផែនដីនៅស្ងៀម ក្នុងភាពជាអ្នកមានករុណាជាសភាវៈ តែអត់ធន់នឹងចិត្តសង្ខារមិនបាន ក៏ញាប់ញ័រ ។ ក្នុងសម័យបរិនិព្វាន ផែនដីទុក្ខសោកដោយកម្លាំងនៃការទ្រហោយំ ទើបកម្រើក ។

សេចក្តីនេះ គប្បីជ្រាបដោយអំណាចទេវតារក្សាផែនដី ការឲ្យសាធុការជាដើម រមែងមិនមានដល់ផែនដីជាមហាភូត ព្រោះផែនដីជាមហាភូត មិនមានចេតនា ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ហើយ ។

## អដ្ឋកថាភូមិចាលសូត្រទី ១៧ ចប់

## ចាលវគ្គទី ២ ចប់

# សុត្តន្តបិដក

# យមកវគ្គ

## បឋមបដិបទាសូត្រទី ១

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធា តែមិនមានសីលទេ យ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនបរិបូរដោយអង្គនោះ ភិក្ខុនោះ គួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង តែមិនមែនជាពហុស្សូតទេ យ៉ាងនេះ ភិក្ខុនោះ ឈ្មោះថា មិនបរិបូរដោយអង្គនោះ ភិក្ខុនោះគួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផងហើយ យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង តែមិនមែនធម្មកថិកទេ ។បេ។ ជាធម្មកថិកផង តែមិនមែនជាអ្នកចូលទៅកាន់បរិសទ្យទេ ។បេ។ ជាអ្នកចូលទៅកាន់បរិសទ្យផង តែមិនមែនជាអ្នកក្លៀវក្លា ខាងសម្តែងធម៌កណ្តាលបរិសទ្យទេ ។បេ។ ជាអ្នកក្លៀវក្លា ខាងសម្តែងធម៌កណ្តាលបរិសទ្យផង តែជាអ្នក

មិនបានតាមប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវឈានទាំង ៤ ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នទេ ។បេ។ ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល នូវឈានទាំង ៤ ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង តែមិនធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នទេ យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា មិនបរិបូរដោយអង្គនោះ ភិក្ខុនោះ គួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យផង ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល នូវឈានទាំង ៤ ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ហើយធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង ម្នាលភិក្ខុទាំងឡាយ កាលណា

ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកក្លៀវក្លាខាងសម្ដែងធម៌កណ្ដាលបរិសទ្យផង ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល នូវឈានទាំង ៤ ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ហើយបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូរដោយធម៌ទាំង ៨ យ៉ាងនេះ ឈ្មោះថា ជាអ្នកបណ្ដុះសេចក្ដីជ្រះថ្លា ឲ្យកើតដោយគ្រប់គ្រាន់ផង ឈ្មោះថា ជាអ្នកបរិបូរដោយអាការ គឺចំណែកនៃសមណធម៌សព្វគ្រប់ផង ។

# អដ្ឋកថា

## យមកវគ្គទី ៣

## បឋមបដិបទាសូត្រ

[ ៧៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមបដិបទាសូត្រទី ១ នៃយមកវគ្គទី ៣ ដូចតទៅនេះ បទថា **នោ ច សីលវា** បានដល់ ដែលមិនធ្វើឲ្យបរិបូណ៌ក្នុងសីល ។ បទថា **សមន្តបាសាទិកោ** ប្រែថា ឲ្យកើតសេចក្តីជ្រះថ្លាដោយជុំវិញ ។ បទថា **សព្វាការបរិបូរោ** បានដល់ បរិបូណ៌ដោយអាការរបស់សមណៈ គឺដោយចំណែកនៃសមណធម៌គ្រប់យ៉ាង ។៚

**អដ្ឋកថា បឋមបដិបទាសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយបដិបទាសូត្រទី ២

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធា តែមិនមានសីលទេ យ៉ាងនេះ ភិក្ខុនោះ ឈ្មោះថា មិនបរិបូរដោយអង្គនោះ ភិក្ខុនោះគួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរដោយអង្គនោះ ។ ម្នាល

ភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង តែមិនមែនជាពហុស្សូតទេ ។បេ។ ជាពហុស្សូតផង តែមិនមែនជាធម្មកថិកទេ ។បេ។ ជាធម្មកថិកផង តែមិនមែនជាអ្នកចូលទៅកាន់បរិសទ្យទេ ។បេ។ ជាអ្នកចូលទៅកាន់បរិសទ្យផង តែមិនមែនជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យទេ ។បេ។ ជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យផង ជាអ្នកពាល់ត្រូវនូវពួកវិមោក្ខដ៏ល្អិត ជាអរូបជ្ឈានដែលកន្លងផុតនូវរូបជ្ឈាន ដោយនាមកាយផង តែមិនទាន់ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននៅឡើយ យ៉ាងនេះ ភិក្ខុនោះ ឈ្មោះថា មិនទាន់បរិបូរដោយអង្គនោះ ភិក្ខុនោះគួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យផង ជាអ្នកពាល់ត្រូវនូវពួកវិមោក្ខដ៏ល្អិត ជាអរូបជ្ឈានដែលកន្លងផុតរូបជ្ឈាន ដោយនាមកាយផង បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យផង ជាអ្នកពាល់ត្រូវនូវ

ពួកវិមោក្ខដ៏ល្អិត ជាអរូបជ្ឈាន ដែលកន្លងផុតនូវរូបជ្ឈាន ដោយនាមកាយផង បានធ្វើឲ្យជាក់ច្បាស់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយ យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូរដោយធម៌ទាំង ៨ យ៉ាងនេះ ឈ្មោះថា ជាអ្នកបណ្តុះសេចក្តីជ្រះថ្លា ឲ្យកើតដោយគ្រប់គ្រាន់ផង ឈ្មោះថា ជាអ្នកបរិបូរដោយអាការ គឺចំណែកនៃសមណធម៌សព្វគ្រប់ផង ។

# អដ្ឋកថា
## ទុតិយបដិបទាសូត្រ

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយបដិបទាសូត្រទី ២ ដូចតទៅនេះ បទថា **សន្តា** សេចក្តីថា ឈ្មោះថា ស្ងប់ ព្រោះស្ងប់ចាកធម៌ដែលជាសត្រូវ ។ បទថា **វិមោក្ខា** សេចក្តីថា ឈ្មោះថា វិមោក្ខ ព្រោះរួចផុតចាកធម៌ដែលជាសត្រូវ ។ល។

### អដ្ឋកថា ទុតិយបដិបទាសូត្រទី ២ ចប់

# សុត្តន្តបិដក

## តតិយបដិបទាសូត្រទី ៣

[ ៨០ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងគិញ្ជកាវសថៈ ( ប្រាសាទឥដ្ឋ ) ជិតនាទិកគ្រាម ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មរណស្សតិ ដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ បានចម្រើនមរណស្សតិឬទេ ។

កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅ អស់យប់ និងថ្ងៃ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការ ឲ្យបានច្រើន ( ក្នុងសាសនារបស់ព្រះអង្គ ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិ យ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រ

ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅអស់ ១ ថ្ងៃ អាត្មាអញ ធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះចម្រើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅអស់កន្លះថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតម្តង អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ

របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅបានត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតពាក់កណ្តាល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើននូវមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅបានត្រឹមខណៈ ដែលទំពាពំនូតបាយ ៤ ឬ ៥ ពំនូត លេបចូលទៅ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រ

ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះខ្ញុំព្រះអង្គ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅត្រឹមខណៈ ទំពាលេបអស់ ១ ពំនូត អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈដែលដកដង្ហើមចូល ហើយចេញ ឬដកដង្ហើមចេញ ហើយចូល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិយ៉ាងនេះ ។

កាលបើពួកភិក្ខុទាំងនោះ ក្រាបទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងពួកភិក្ខុទាំងនោះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះ យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញគប្បីរស់នៅ អស់យប់ និងថ្ងៃ អាត្មាអញគប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀន

ប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិដោយសេចក្ដីត្រិះរិះ យ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅអស់ ១ ថ្ងៃ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិដោយសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ អាត្មាអញគប្បីរស់នៅ អស់កន្លះថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យ ប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញគប្បីរស់នៅ ត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតម្ដង អាត្មាអញគប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិដោយសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតពាក់កណ្ដាល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិ ដោយសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅត្រឹមខណៈទំពាពំនូតបាយ ៤ ឬ ៥ ពំនូត លេបចូលទៅ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀន

ប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនេះ ហៅថា មានសេចក្ដីប្រមាទនៅឡើយ ចម្រើនមរណស្សតិ ដើម្បីធ្វើឲ្យអស់អាសវៈទាំងឡាយយឺតយូរទេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិ ដោយសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅត្រឹមខណៈទំពាលេបបាយ ១ ពំនូត អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិ ដោយសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈ ដែលដកដង្ហើមចូល ហើយចេញ ឬដកដង្ហើមចេញ ហើយចូល អាត្មាអញគប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនេះ ហៅថាមិនមានសេចក្ដីប្រមាទ ចម្រើនមរណស្សតិ ដើម្បីឲ្យអស់អាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាយ៉ាងនេះថា ពួកយើងនឹងមិនមានសេចក្ដីប្រមាទ នឹងចម្រើនមរណស្សតិ ដើម្បីធ្វើឲ្យអស់អាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សា យ៉ាងនេះណា៎ ។

# អដ្ឋកថា

## តតិយបដិបទាសូត្រ

[ ៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយបដិបទាសូត្រទី ៣ ដូចតទៅនេះ បទថា **ភាវេថ នោ** កែជា **ភាវេថ នុ** ប្រែថា អ្នកចូរចម្រើនមរណស្សតិហ្ន៎ ។ បទថា **សាសនំ** បានដល់ ការប្រៀនប្រដៅ ។ បទថា **អាសវានំ ខយាយ** បានដល់ ដើម្បីអរហត្តផល ។ល។

**អដ្ឋកថា តតិយបដិបទាសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ចតុត្ថបដិបទាសូត្រទី ៤

[ ៨១ ] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងគិញ្ជកាវសថៈ ជិតនាទិកគ្រាម ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ។បេ។ ម្នាលភិក្ខុទាំងឡាយ មរណស្សតិ ដែលភិក្ខុចម្រើនហើយ សន្សំរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ចុះមរណស្សតិ ដែលភិក្ខុចម្រើនហើយ តើដូចម្តេច សន្សំរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ

ក្នុងសាសនានេះ កាលបើថ្ងៃកន្លងទៅហើយ យប់មកដល់វិញ តែងពិចារណាដូច្នេះថា ហេតុនៃសេចក្ដីស្លាប់ របស់អាត្មាអញ មានច្រើនណាស់តើ ( ដូចជា ) ពស់ចឹកអាត្មាអញក្ដី ខ្ទួយទិចអាត្មាអញក្ដី ក្អែកខាំអាត្មាអញក្ដី អាត្មាអញនឹងស្លាប់ អន្តរាយនោះនឹងមានដល់អាត្មាអញ ព្រោះហេតុតែពស់ចឹកជាដើមនោះ អាត្មាអញភ្លាត់ជួលក្ដី កត្តដែលអាត្មាអញបរិភោគហើយ ហល់ក្ដី ប្រមាត់របស់អាត្មាអញកម្រើកក្ដី ស្លេស្មរបស់អាត្មាអញកម្រើកក្ដី កងខ្យល់ដូចសស្ត្រាវុធរបស់អាត្មាអញកម្រើកក្ដី ពួកមនុស្សព្យាយាមសម្លាប់អាត្មាអញក្ដី ពួកអមនុស្សព្យាយាមសម្លាប់អាត្មាអញក្ដី អាត្មាអញនឹងស្លាប់ អន្តរាយនោះ នឹងមានដល់អាត្មាអញ ព្រោះហេតុតែភ្លាត់ជួលជាដើមនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវពិចារណាថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាលក្នុងរាត្រី អកុសល-ធម៌ដ៏លាមកនោះ អាត្មាអញ មិនទាន់បានលះបង់នៅឡើយ មានដែរឬទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាលក្នុងរាត្រី អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះបង់ហើយនៅមានមែន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវធ្វើឆន្ទៈផង សេចក្ដីព្យាយាមផង ឧស្សាហៈផង សេចក្ដីខ្នះខ្នែងផង សេចក្ដីមិនរួញរាផង សតិផង សម្ប-ជញ្ញៈផង ឲ្យខ្លាំង ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញឲ្យដាច់

ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលមានសំពត់ឆេះក្តី មានក្បាលឆេះក្តី ត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផងឲ្យខ្លាំង ដើម្បីនឹងលត់សំពត់នោះផង លត់ក្បាលនោះផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលះអកុសលធម៌ដ៏លាមកទាំងនោះចេញឲ្យដាច់យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយ ដល់អាត្មាអញដែលធ្វើមរណកាល ក្នុងរាត្រី អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះហើយ មិនមានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីជាអ្នកសិក្សារឿយៗ ទាំងថ្ងៃទាំងយប់ ក្នុងកុសលធម៌ទាំងឡាយ ដោយបីតិ និងបាមោជ្ជនោះចុះ ។

មួយទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើយប់កន្លងទៅហើយ ថ្ងៃមកដល់វិញ តែងពិចារណាដូច្នេះថា ហេតុនៃសេចក្តីស្លាប់របស់អាត្មាអញមានច្រើនណាស់តើ ( ដូនជា ) ពស់ចឹកអាត្មាអញក្តី ខ្ទួយទិចអាត្មាអញក្តី ក្អែបខាំអាត្មាអញក្តី អាត្មាអញនឹងស្លាប់ អន្តរាយនោះ នឹងមានដល់អាត្មាអញ ព្រោះហេតុតែពស់ចឹកជាដើមនោះ ( ឬមួយ ) អាត្មាអញភ្លាត់ដួលក្តី កត្តដែលអាត្មាអញ បរិភោគហើយហល់ក្តី ប្រមាត់របស់អាត្មាអញកម្រើក

ក្តី ស្នេហ្មរបស់អាត្មាអញកម្រើកក្តី កងខ្យល់ដូចសស្ត្រាវុធរបស់អាត្មាអញកម្រើកក្តី ពួកមនុស្សព្យាយាមសម្លាប់អាត្មាអញក្តី ពួកអមនុស្សព្យាយាមសម្លាប់អាត្មាអញក្តី អាត្មាអញនឹងស្លាប់ អន្តរាយនោះនឹងមានដល់អាត្មាអញ ព្រោះហេតុតែភ្ជាត់ជួលជាដើមនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវពិចារណាថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាលក្នុងវេលាថ្ងៃ អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះបង់ហើយ មានដែរឬទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាលក្នុងវេលាថ្ងៃ អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះនៅឡើយ នៅមានមែន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលះអកុសលធម៌ដ៏លាមកទាំងនោះចេញ ឲ្យដាច់ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលមានសំពត់ឆេះក្តី មានក្បាលឆេះក្តី ត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលត់សំពត់ ឬក្បាលនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង

ដើម្បីនឹងលះអកុសលធម៌ដ៏លាមកទាំងនោះចេញ ឲ្យដាច់ យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាលក្នុងវេលាថ្ងៃ អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញ មិនទាន់បានលះហើយ មិនមានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីជាអ្នកសិក្សារឿយៗ ទាំងថ្ងៃទាំងយប់ ក្នុងកុសលធម៌ទាំងឡាយ ដោយបីតិ និងបាមោជ្ជនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ មរណស្សតិ ដែលភិក្ខុចម្រើនហើយយ៉ាងនេះ សន្សំរឿយៗ ហើយយ៉ាងនេះ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត ។

## បឋមបដិបទាសូត្រទី ៥

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៨ យ៉ាង ។ ៨ យ៉ាង គឺអ្វីខ្លះ ។ គឺឧដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ សទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះសម្បទា ៨ យ៉ាង ។

បុគ្គលអ្នកប្រឹងប្រែង មានវិធានការ មិនបណ្តែតបណ្តោយ
ក្នុងការងារទាំងឡាយ តែងចិញ្ចឹមជីវិតស្មើ រក្សាទ្រព្យ
ដែលខ្លួនរកបានមក មានសទ្ធា បរិបូណ៌ ដោយសីល
ឈ្លាសក្នុងសម្តី លះបោលសេចក្តីកំណាញ់ ជម្រះនូវ

ផ្លូវ សម្រាប់ទៅកាន់លោកខាងមុខ ឲ្យមានសួស្តីជានិច្ច ធម៌ទាំង ៨ យ៉ាងនេះ នាំមកនូវសេចក្តីសុខ ក្នុងលោកទាំងពីរ ដែលព្រះសម្ពុទ្ធទ្រង់ព្រះនាមថាសច្ចៈ ទ្រង់សម្តែងហើយ ដល់កុលបុត្តអ្នកមានសទ្ធា នៅគ្រប់គ្រងផ្ទះ មួយទៀត ការបរិច្ចាគ និងបុណ្យដ៏សេសនេះ តែងចម្រើនដល់ពួកគ្រហស្ថ ដើម្បីសេចក្តីចម្រើន និងប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខ ក្នុងលោកខាងមុខផង យ៉ាងនេះ ។

## ឧជ្ជយបឋមសូត្រទី ៦

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៨ យ៉ាង ។ ៨ យ៉ាងគឺអ្វីខ្លះ ។ គឺឧដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ សទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។

ម្នាលភិក្ខុទាំងឡាយ ចុះឧដ្ឋានសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយខំធ្វើការងារ ទោះបីធ្វើស្រែចម្ការក្តី ជំនួញក្តី រក្សាគោក្តី ធ្វើសេនាយោធាក្តី ធ្វើជារាជបុរសក្តី ចេះសិល្បៈណាមួយក្តី ជាអ្នកឈ្លាស ក្នុងអំពីនោះៗ មិនខ្ជិលច្រអូស បរិបូណ៌ដោយការល្បែងក មានល្បិចក្នុងការនោះថា គួរធ្វើ គួរចាត់ចែង ម្នាលភិក្ខុទាំងឡាយ នេះហៅថាឧដ្ឋានសម្បទា ។

ម្នាលភិក្ខុទាំងឡាយ ចុះអារក្ខសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ កុលបុត្តក្នុងលោកនេះ មានភោគៈច្រើនដែលខ្លួនរកបានមក ដោយការប្រឹងប្រែង ព្យាយាម សន្សំដោយកម្លាំងដៃ បែកញើស ហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ហើយថែទាំភោគៈទាំងនោះ ដោយការរក្សា គ្រប់គ្រង ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ កុំឲ្យព្រះរាជាទាំងឡាយ រឹបជាន់យក កុំឲ្យពួកចោរលួចយក កុំឲ្យភ្លើងឆេះ កុំឲ្យទឹកលិច កុំឲ្យពួកទាយាទ មិនជាទីគាប់ចិត្តយកទៅបាន ម្នាលភិក្ខុទាំងឡាយ នេះហៅថា អារក្ខសម្បទា ។

ម្នាលភិក្ខុទាំងឡាយ ចុះកល្យាណមិត្តតា តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ កុលបុត្តក្នុងលោកនេះ នៅក្នុងស្រុកណាក្តី និគមណាក្តី ក្នុងស្រុក ឬនិគមនោះ មានពួកគហបតី ឬពួកគហបតិបុត្ត ទោះបីនៅក្មេងតែជាអ្នកចម្រើនដោយសីល ទោះបីចាស់ក៏ចម្រើនដោយសីល មានសទ្ធាបរិបូណ៌ មានសីលបរិបូណ៌ មានចាគៈបរិបូណ៌ មានបញ្ញាបរិបូណ៌ កុលបុត្តតែងឋិតនៅចរចាសាកសួរ ជាមួយនឹងពួកគហបតីទាំងនោះ ហើយសិក្សារឿយៗ នូវសទ្ធា-សម្បទា នឹងពួកបុគ្គលដែលជាអ្នកមានសទ្ធាបរិបូណ៌ តាមសមគួរ សិក្សារឿយៗ នូវសីលសម្បទា នឹងពួកបុគ្គល ជាអ្នកមានសីលបរិបូណ៌តាមសមគួរ សិក្សារឿយៗ នូវចាគសម្បទា នឹងពួកអ្នកមានចាគៈបរិបូណ៌ តាមសមគួរ សិក្សារឿយៗនូវបញ្ញាសម្បទា នឹងពួកបុគ្គលអ្នកមានបញ្ញាបរិបូណ៌តាមសមគួរ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កល្យាណមិត្តតា ។

ម្នាលភិក្ខុទាំងឡាយ ចុះសមជីវិតា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ស្គាល់សេចក្តីចម្រើនភោគៈទាំងឡាយផង ស្គាល់សេចក្តីសាបសូន្យភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតតាមសមគួរមិនទូលាយពេក មិនក្បិតក្បៀតពេក ដោយបំណងយ៉ាងនេះថា សេចក្តីចម្រើនរបស់អាត្មាអញនឹងគ្របសង្កត់សេចក្តីវិនាសបាន ឯសេចក្តីវិនាសរបស់អាត្មាអញនឹងមិនគ្របសង្កត់ សេចក្តីចម្រើនយ៉ាងនេះបានទេ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអ្នកថ្លឹងក្តី សិស្សរបស់អ្នកថ្លឹងក្តី លើកជញ្ជីងឡើងហើយដឹងថា ស្រាល ព្រោះ ( ខ្វះ ) ប៉ុណ្ណេះ ឬធ្ងន់ព្រោះ ( លើស ) ប៉ុណ្ណេះយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កុលបុត្តស្គាល់សេចក្តីចម្រើន នូវភោគៈទាំងឡាយផង ស្គាល់សេចក្តីសាបសូន្យភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតតាមសមគួរ មិនទូលាយដែពេក មិនក្បិតក្បៀតពេក ដោយបំណងយ៉ាងនេះថា សេចក្តីចម្រើនរបស់អាត្មាអញនឹងគ្របសង្កត់សេចក្តីវិនាសបាន ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងមិនអាចគ្របសង្កត់សេចក្តីចម្រើនយ៉ាងនេះបានទេ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ប្រសិនបើកុលបុត្តនេះ មានសេចក្តីចម្រើនតិច គឺខ្វះទ្រព្យ ហើយចិញ្ចឹមជីវិតលើសលុប អ្នកផងតែងតិះដៀលកុលបុត្រនោះថា កុលបុត្តនេះស៊ីភោគៈ ដូចគេស៊ីផ្លែល្វា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ កុលបុត្តនេះមានសេចក្តីចម្រើនច្រើន គឺមានទ្រព្យ ហើយចិញ្ចឹមជីវិតរលីបរលាប អ្នកផងតែងតិះដៀលកុលបុត្តនោះថា កុលបុត្តនេះ មុខតែនឹងស្លាប់ឥតមានទីពឹង ។ ម្នាល

ភិក្ខុទាំងឡាយ កាលណា បើកុលបុត្តនេះ ស្គាល់សេចក្តីចម្រើនភោគៈទាំង-ឡាយផង ស្គាល់សេចក្តីវិនាសភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនទូលាយដៃពេក មិនក្បិតក្បៀតពេក ដោយបំណងថា សេចក្តីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់សេចក្តីវិនាសបាន ឯសេចក្តីវិនាសរបស់អាត្មាអញនឹងមិនអាចគ្របសង្កត់សេចក្តីចម្រើន យ៉ាងនេះបានទេ ម្នាលភិក្ខុទាំងឡាយនេះហៅថា សមជីវិតា ។

ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធាសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយកុលបុត្ត ក្នុងលោកនេះ ជាអ្នកមានសទ្ធា ជឿការត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយត្រាស់ដឹងនូវសច្ចៈទាំង ៤ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថា សទ្ធាសម្បទា ។

ម្នាលភិក្ខុទាំងឡាយ ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយកុលបុត្តក្នុងលោកនេះ ជាអ្នកវៀរចាកកិរិយាសម្លាប់សត្វ ។បេ។ ជាអ្នកវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង បានខាងឯសុរានិងមេរ័យ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលសម្បទា ។

ម្នាលភិក្ខុទាំងឡាយ ចុះចាគសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយកុលបុត្ត ក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ ហើយនៅគ្រប់គ្រងផ្ទះ ។បេ។ ជាអ្នកគួរឲ្យគេសូមបាន ត្រេកអរ ក្នុងការឲ្យ និងការ

ចែករំលែក ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចាគសម្បទា ។

ម្នាលភិក្ខុទាំងឡាយ ចុះបញ្ញាសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ កុលបុត្ត ក្នុងលោកនេះ ជាអ្នកមានបញ្ញា ។បេ។ ជាដំណើរអាចយល់សេចក្តីអស់ទៅ នៃទុក្ខដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បញ្ញា-សម្បទា ។ ម្នាលភិក្ខុទាំងឡាយ នេះសម្បទា ទាំង ៨ យ៉ាង ។

បុគ្គលអ្នកប្រឹងប្រែង មានវិធានការ មិនបណ្តែតបណ្តោយ
ក្នុងការងារទាំងឡាយ តែងចិញ្ចឹមជីវិតស្មើ រក្សាទ្រព្យ
ដែលខ្លួនរកបានមក មានសទ្ធា បរិបូណ៌ដោយសីល
ឈ្លាសក្នុងសម្តី លះបោលសេចក្តីកំណាញ់ ជម្រះនូវ
ផ្លូវ សម្រាប់ទៅកាន់លោកខាងមុខ ឲ្យមានសួស្តីជានិច្ច
ធម៌ទាំង ៨ យ៉ាងនេះ នាំមកនូវសេចក្តីសុខ ក្នុងលោក
ទាំងពីរ ដែលព្រះសម្ពុទ្ធទ្រង់ព្រះនាមថាសច្ចៈ ទ្រង់សម្តែង
ហើយ ដល់កុលបុត្តអ្នកមានសទ្ធា នៅគ្រប់គ្រងផ្ទះ មួយ
ទៀត ការបរិច្ចាគ និងបុណ្យដ៏សេសនេះ តែងចម្រើន
ដល់ពួកគ្រហស្ថ ដើម្បីសេចក្តីចម្រើន និងប្រយោជន៍
ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខ ក្នុងលោកខាងមុខ
ផង យ៉ាងនេះ ។

# អដ្ឋកថា

## ចតុត្ថបដិបទាសូត្រទី ៤ ជាដើម

[ ៨១-៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចតុត្ថបដិបទាសូត្រទី ៤ ជាដើម ដូចតទៅនេះ បទថា **បដិហិតាយ** បានដល់ កាលរាត្រីប្រព្រឹត្តទៅ ។ បទថា **សោ មមស្សន្តរាយោ** សេចក្តីថា អន្តរាយនៃជីវិតនោះ គប្បីមានដល់អញ គឺអន្តរាយចំពោះសួគ៌ផង អន្តរាយចំពោះមគ្គផង គប្បីមានដល់អញដែលធ្វើកាលកិរិយាទាំងនៅជាបុថុជ្ជន ។ បទថា **សត្ថកា វា មេ វាតា** សេចក្តីថា ខ្យល់ ឈ្មោះថា មានពិសដូចសស្ត្រា ព្រោះកាត់អវយវៈតូចធំដូចសស្ត្រា ។ សូត្រទី ៥ ជាដើម មានន័យដូចពោលហើយនោះឯង ៕

**អដ្ឋកថា ចតុត្ថបដិបទាសូត្រ ៤ ជាដើមចប់**

# សុត្តន្តបិដក

## សញ្ញាសូត្រទី ៧

[ ៨៤ ] ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ដ៏មានអាយុ ។ ពួកភិក្ខុទាំងនោះ ទទួលថេរវាចារបស់ព្រះសារីបុត្តដ៏មានអាយុថា បពិត្រលោកដ៏មានអាយុ ។ ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចាដូច្នេះថា ម្នាលលោកដ៏មានអាយុទាំងឡាយ បុគ្គល ៨

ពួកនេះ មានពាសក្នុងលោក ។ ៨ ពួក តើដូចម្តេចខ្លះ ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភកើតឡើង ភិក្ខុនោះប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាមដើម្បីលាភ កាលភិក្ខុនោះ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភហើយ លាភក៏មិនកើតឡើង ភិក្ខុនោះ ក៏ក្រៀមក្រំ លំបាក ខ្សឹកខ្សួល គក់ទ្រូង យំ កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង ព្រោះតែឥតលាភនោះ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ តែជាអ្នកឥតលាភផង ក្រៀមក្រំផង ខ្សឹកខ្សួលផង ឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភកើតឡើង ភិក្ខុនោះប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ កាលភិក្ខុនោះ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភហើយ លាភក៏កើតឡើង ភិក្ខុនោះក៏ស្រវឹងងើងឆ្ងោង ដល់នូវសេចក្តីប្រមាទ ព្រោះតែលាភនោះ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង ស្រវឹងផង ងើងឆ្ងោងផង ឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់

កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្ដីប្រាថ្នាដើម្បីលាភកើតឡើង ភិក្ខុនោះ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ កាលភិក្ខុនោះ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភហើយ លាភក៏មិនកើតឡើង ភិក្ខុនោះក៏ក្រៀមក្រំ លំបាក ខ្សឹកខ្សួល គក់ទ្រូង យំ កន្ទក់កន្ទេញ ដល់នូវសេចក្ដីវង្វេង ព្រោះតែឥតលាភនោះ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្ដីប្រាថ្នា ដើម្បីលាភ តែមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ ជាអ្នកឥតលាភផង ក្រៀមក្រំផង ខ្សឹកខ្សួលផង ឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្ដីប្រាថ្នាដើម្បីលាភកើតឡើង ភិក្ខុនោះ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ ភិក្ខុនោះ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភហើយ លាភក៏កើតឡើង ភិក្ខុនោះក៏ស្រវឹង ងេងងោង ដល់នូវសេចក្ដីប្រមាទ ព្រោះតែលាភនោះ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្ដីប្រាថ្នា ដើម្បីលាភ តែមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង ស្រវឹងផង ងេងងោងផង ឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្ដីប្រាថ្នាដើម្បីលាភ កើតឡើង ភិក្ខុនោះ

ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ កាលភិក្ខុនោះ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភហើយ លាភក៏មិនកើតឡើង ភិក្ខុនោះ ក៏មិនក្រៀមក្រំ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង យំ កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេង ព្រោះតែឥតលាភនោះទេ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាមដើម្បីលាភ ជាអ្នកឥតលាភផង មិនក្រៀមក្រំផង មិនខ្សឹកខ្សួលផង មិនឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភ កើតឡើង ភិក្ខុនោះប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ កាលភិក្ខុនោះ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភហើយ លាភក៏កើតឡើង តែភិក្ខុនោះ មិនស្រវឹងមិនធ្វេសធ្វោង មិនដល់នូវសេចក្តីប្រមាទ ព្រោះតែលាភនោះទេ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង ជាអ្នកមិនស្រវឹងផង មិនធ្វេសធ្វោងផង មិនឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភកើតឡើង ភិក្ខុនោះមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ កាលភិក្ខុនោះមិន

ប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភហើយ លាភក៏មិនកើតឡើងដែរ ភិក្ខុនោះមិនក្រៀមក្រំ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង យំកន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេង ព្រោះតែឥតលាភនោះឡើយ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្ដីប្រាថ្នា ដើម្បីលាភ តែមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភ ជាអ្នកមិនមានលាភផង មិនក្រៀមក្រំផង មិនខ្សឹកខ្សួលផង មិនឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្ដីប្រាថ្នាដើម្បីលាភ កើតឡើង ភិក្ខុនោះមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ កាលភិក្ខុនោះ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភហើយ លាភក៏កើតឡើង តែភិក្ខុនោះ មិនស្រវឹង មិនភ្លេងភ្លោង មិនដល់នូវសេចក្ដីប្រមាទ ព្រោះតែលាភនោះទេ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្ដីប្រាថ្នា ដើម្បីលាភ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង មិនស្រវឹងផង មិនភ្លេងភ្លោងផង មិនឃ្លាតចាកព្រះសទ្ធម្មផង ។ ម្នាលលោកដ៏មានអាយុទាំងឡាយ បុគ្គលទាំង ៨ ពួកនេះ មានពាសក្នុងលោក ។

# អដ្ឋកថា

## ឥច្ឆាសូត្រ

[ ៨៤ ] ក្នុងឥច្ឆាសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាឥច្ឆាសូត្រទី ៧ ចប់

# សុត្តន្តបិដក

## បឋមលច្ឆាសូត្រទី ៨

[ ៨៥ ] ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុថា ។បេ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៦ យ៉ាង គួរដល់ខ្លួន ( ផង ) គួរដល់ពួកជនដទៃ ( ផង ) ។ ៦ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចុះចិត្តក្នុងកងធម៌ ជាកុសលដោយឆាប់ ១ ជាអ្នកចាំកងធម៌ ដែលខ្លួនស្ដាប់ហើយ ១ ជាអ្នករំពឹងនូវសេចក្ដីនៃកងធម៌ ដែលខ្លួនចាំហើយ ១ ជាអ្នកយល់អត្ថ យល់ធម៌ ហើយប្រតិបត្តិធម៌សមគួរតាមធម៌ ១ ជាអ្នកមានសម្ដីពីរោះ មានសំឡេងពីរោះ ប្រកបដោយវាចារបស់អ្នកក្រុង ជាវាចាក្បោះក្បាយ មិនរអាក់រអួល អាចបំភ្លឺសេចក្ដីឲ្យបុគ្គលដទៃដឹងច្បាស់ ១ ជាអ្នកសម្ដែងធម៌ ពន្យល់ ណែនាំ ឲ្យពួកសព្រហ្មចារីយល់ប្រយោជន៍ ក្នុងបច្ចុប្បន្ន និងបរលោក ឲ្យជឿជាក់ក្នុងកុសលធម៌ ឲ្យរីករាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ទាំង ៦

យ៉ាងនេះ គួរដល់ខ្លួនឯង ( ផង ) គួរដល់ពួកជនដទៃ ( ផង ) ។

## ទុតិយលច្ឆាសូត្រទី ៩

[ ៨៦ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៥ យ៉ាង គួរដល់ខ្លួនឯង ( ផង ) គួរដល់ពួកជនដទៃ ( ផង ) ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនជាអ្នកចុះចិត្ត ក្នុងកងកុសល-ធម៌ដោយឆាប់ តែជាអ្នកចាំកងធម៌ ដែលខ្លួនស្តាប់ហើយ ១ ជាអ្នករំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយ ១ ជាអ្នកយល់អត្ថ យល់ធម៌ ហើយប្រតិបត្តិធម៌សមគួរតាមធម៌ ១ ជាអ្នកមានសម្តីពីរោះ ១ ។បេ។ ជាអ្នកសម្តែងធម៌ពន្យល់ណែនាំឲ្យពួក ។បេ។ របស់សព្រហ្មចារីទាំងឡាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ ដោយធម៌ទាំង ៥ យ៉ាងនេះ គួរដល់ខ្លួនឯង ( ផង ) គួរដល់ពួកជនដទៃ ( ផង ) ។

## តតិយលច្ឆាសូត្រទី ១០

[ ៨៧ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៤ យ៉ាង គួរដល់ខ្លួនឯង តែមិនគួរដល់ពួកជនដទៃឡើយ ។ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចុះចិត្តក្នុងកងកុសលធម៌ដោយឆាប់ផង ចាំកងធម៌ដែលខ្លួនស្តាប់ហើយផង ១ ជាអ្នករំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ហើយ ប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ តែជាអ្នកមិនមានសម្តីពីរោះ ១ ។បេ។ ជាអ្នកមិន

សម្តែងធម៌ ពន្យល់ ណែនាំ ។បេ។ របស់សព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៤ យ៉ាងនេះ គួរដល់ខ្លួនឯង តែមិនគួរដល់ជនដទៃឡើយ ។

# ចតុត្ថលប្ជាសូត្រទី ១១

[ ៨៨ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៤ យ៉ាង គួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចុះចិត្តក្នុងកងកុសលធម៌ដោយឆាប់ផង ចាំកងធម៌ដែលខ្លួនស្តាប់ហើយផង ១ មិនរំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ ហើយមិនប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ មានសម្តីពីរោះ ១ ។បេ។ សម្តែងធម៌ ពន្យល់ ណែនាំ ។បេ។ របស់ពួកសព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ទាំង ៤ យ៉ាងនេះ គួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។

# បញ្ចមលប្ជាសូត្រទី ១២

[ ៨៩ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ ដោយធម៌ ៣ យ៉ាង គួរដល់ខ្លួនឯង តែមិនគួរដល់ពួកជនដទៃឡើយ ។ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចុះចិត្តក្នុងកងកុសល-ធម៌ ដោយឆាប់ផង ជាអ្នកចាំកងធម៌ ដែលខ្លួនស្តាប់ហើយផង ជាអ្នករំពឹង

សេចក្តីកងធម៌ ដែលខ្លួនចាំហើយផង ជាអ្នកយល់អត្ថ យល់ធម៌ ហើយប្រតិបត្តិធម៌ សមគួរតាមធម៌ផង ១ ជាអ្នកមិនមានសម្តីពីរោះ ១ ។បេ។ ជាអ្នកមិនសម្តែងធម៌ ពន្យល់ ណែនាំ ។បេ។ របស់ពួកសព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ទាំង ៣ យ៉ាងនេះ គួរដល់ខ្លួនឯងតែមិនគួរដល់ពួកជនដទៃឡើយ ។

# ជដ្ឋលប្បាសូត្រទី ១៣

[ ៩០ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ ដោយធម៌ ៣ យ៉ាង គួរដល់ជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចុះចិត្តក្នុងកងកុសលធម៌ ដោយឆាប់ផង ជាអ្នកចាំកងធម៌ ដែលខ្លួនស្តាប់ហើយផង តែជាអ្នកមិនរំពឹងនូវសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ហើយ មិនប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ ជាអ្នកមានសម្តីពីរោះ ។បេ។ ជាវាចាបំភ្លឺនូវសេចក្តីឲ្យអ្នកដទៃដឹងច្បាស់ ១ ជាអ្នកសម្តែងធម៌ ពន្យល់ ណែនាំ ។បេ។ របស់ពួកសព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ ដោយធម៌ ៣ យ៉ាងនេះ គួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។

# សត្ថុមលប្បាសូត្រទី ១៤

[ ៩១ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ពីរយ៉ាង គួរដល់ខ្លួនឯង តែមិនគួរដល់ពួកជនដទៃឡើយ ។ ២ យ៉ាង តើដូចម្តេចខ្លះ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនទាន់ចុះចិត្តក្នុងកុសល-ធម៌ដោយឆាប់ផង ជាអ្នកចាំកងធម៌ដែលខ្លួនស្តាប់ហើយផង រំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ ហើយប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ ជាអ្នកមិនមានសម្តីពីរោះ ។បេ។ ផង ជាអ្នកមិនសម្តែងធម៌ ពន្យល់ ណែនាំ ។បេ។ របស់ពួកសព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូរដោយធម៌ទាំងពីរយ៉ាងនេះ គួរដល់ខ្លួនឯង តែមិនគួរដល់ពួកជនដទៃឡើយ ។

# អដ្ឋមលច្ឆាសូត្រទី ១៨

[ ៩២ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូរដោយធម៌ពីរយ៉ាងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។ ២ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនទាន់ចុះចិត្តក្នុងកងកុសល-ធម៌ដោយឆាប់ផង មិនចាំកងធម៌ដែលខ្លួនស្តាប់ហើយផង មិនបានរំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ ហើយមិនប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ ជាអ្នកមានសម្តីពីរោះ មានសំឡេងពីរោះ ប្រកបដោយវាចារបស់អ្នកក្រុង ជាវាចាក្បោះក្បាយ មិនរអាក់រអួល ជាវាចាបំភ្លឺសេចក្តីឲ្យអ្នកដទៃដឹងច្បាស់ផង ជាអ្នកពន្យល់ ណែនាំ ពួកសព្រហ្មចារី ឲ្យជឿជាក់ក្នុងកុសលធម៌ ឲ្យរីករាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូរដោយធម៌ទាំងពីរយ៉ាងនេះ គួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។

# អដ្ឋកថា

## បឋមលច្ឆាសូត្រ

[ ៨៥-៩២ ] ក្នុងបឋមលច្ឆាសូត្រទី ៨ មានអត្ថងាយយល់ហើយ ។
អដ្ឋកថាបឋមលច្ឆាសូត្រទី ៨ ជាដើមចប់

# សុត្តន្តបិដក

## បរិហានសូត្រទី ១៦

[ ៩៣ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ យ៉ាងនេះ តែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដល់សេក្ខភិក្ខុ ។ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរក្នុងតិរច្ឆានកថា ១ សេចក្តីត្រេកអរក្នុងការដេក ១ សេចក្តីត្រេកអរក្នុងពួក ១ សេចក្តីមិនគ្រប់គ្រងទ្វារក្នុងពួកឥន្រ្ទិយ ១ សេចក្តីមិនស្គាល់ប្រមាណក្នុងភោជន ១ សេចក្តីត្រេកអរក្នុងការជាប់ជំពាក់ ១ សេចក្តីត្រេកអរក្នុងធម៌ជាគ្រឿងយឺតយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់សេក្ខភិក្ខុ ។

# អដ្ឋកថា

## បរិហានសូត្រ

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិហានសូត្រទី ១៦ ដូចតទៅនេះ បទថា **សំសគ្គារាមតា** បានដល់ ភាពជាអ្នកត្រេកអរក្នុងធម៌ជាគ្រឿងជាប់ជំពាក់ ៥ ប្រការ ។ល។

**អដ្ឋកថា បរិហានសូត្រទី ១៦ ចប់**

## អបរិហានសូត្រទី ១៧

[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ យ៉ាងនេះ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសាបសូន្យ ដល់សេក្ខភិក្ខុ ។ ៨ យ៉ាង តើដូចម្ដេចខ្លះ ។ គឺសេចក្ដីមិនត្រេកអរ ក្នុងការងារ ១ សេចក្ដីមិនត្រេកអរ ក្នុងតិរច្ឆានកថា ១ សេចក្ដីមិនត្រេកអរ ក្នុងការដេក ១ សេចក្ដីមិនត្រេកអរ ក្នុងពួកគណៈ ១ សេចក្ដីគ្រប់គ្រងទ្វារ ក្នុងពួកឥន្ទ្រិយ ១ សេចក្ដីស្គាល់ប្រមាណ ក្នុងភោជន ១ សេចក្ដីមិនត្រេកអរ ក្នុងការជាប់ជំពាក់ ១ សេចក្ដីមិនត្រេកអរក្នុងធម៌ជាគ្រឿងយឺតយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីមិនសាបសូន្យ ដល់សេក្ខភិក្ខុ ។

# អដ្ឋកថា

## អបរិហានសូត្រ

[ ៩៤ ] ក្នុងអបរិហានសូត្រទី ១៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអបរិហានសូត្រទី ១៧ ចប់

# សុត្តន្តបិដក

## កុសីតវត្ថុសូត្រទី ១៨ ជាដើម

[ ៩៥ ] ម្នាលភិក្ខុទាំងឡាយ កុសីតវត្ថុនេះ មាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អំពើ គឺការលៃលកវាស់ កាត់ចីវរជាដើម ដែលភិក្ខុក្នុងសាសនានេះ គួរធ្វើក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អំពើដែលអាត្មាអញ គួរធ្វើ គង់នឹងមាន តែបើអាត្មាអញធ្វើអំពើ ( នោះហើយ ) កាយក៏នឹងលំបាក បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះ ក៏ដេក មិនផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ គឺឈាន វិបស្សនា មគ្គ ផលដែលខ្លួនមិនទាន់ដល់ ដើម្បីដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់ នូវគុណដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ១ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើដែលភិក្ខុធ្វើរួចហើយក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានធ្វើអំពើ ( នោះ ) រួចហើយ

តែកាលដែលអាត្មាអញ ធ្វើអំពើនោះ រាងកាយលំបាកហើយ បើដូច្នោះអាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ២ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុគួរដើរទៅក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ផ្លូវដែលអាត្មាអញ គួរដើរទៅ គង់នឹងមាន តែថាកាលបើអាត្មាអញ ដើរទៅកាន់ផ្លូវ ( នោះហើយ ) រាងកាយនឹងលំបាក បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៣ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុដើរទៅហើយក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានដើរទៅកាន់ផ្លូវ ( នោះ ) រួចហើយ តែថា កាលអាត្មាអញ ដើរទៅកាន់ផ្លូវ រាងកាយលំបាកហើយ បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ

ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៤ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬថ្លៃថ្លា គ្រាន់តែ ១ ចម្អែត ឡើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញត្រាច់ទៅកាន់ ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបានភោជនថោកទាប ឬថ្លៃថ្លា គ្រាន់ តែ ១ ចម្អែតសោះ អាត្មាអញនោះ មានរាងកាយលំបាកហើយ មិនគួរដល់ សមណកម្ម បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៥ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែត ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញ ត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ហើយបានភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែតដែរ អាត្មាអញនោះ មានកាយធ្ងន់ ដូចសណ្តែករាជមាសទទឹក មិនគួរដល់ សមណកម្ម បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៦ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានអាពាធតិចតួចកើតឡើង ភិក្ខុ នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ មានអាពាធតិចតួចនេះ កើត ឡើងហើយ គួរតែដេកសិន បើដូច្នោះអាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិន

ផ្គងព្យាយាមឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៧ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ អាត្មាអញនោះ មានរាងកាយ ថមថយកម្លាំង មិនគួរដល់សមណកម្ម បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាមដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងកុសីតវត្ថុ ៨ យ៉ាង ។

## អារព្ភវត្ថុសូត្រទី៩

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ អារព្ភវត្ថុនេះ មាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អំពើដែលភិក្ខុក្នុងសាសនានេះ គួរធ្វើក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អំពើដែលអាត្មាអញ គួរធ្វើគង់នឹងមាន តែថា កាលអាត្មាអញធ្វើអំពើ ( នោះហើយ ) មិនងាយនឹងធ្វើពុទ្ធ-សាសនាឲ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះ អាត្មាអញ ផ្គងព្យាយាមមុនសិន ដើម្បីឲ្យដល់នូវគុណ គឺឈាន វិបស្សនា មគ្គ ផលដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលអាត្មាអញមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យច្បាស់លាស់ ភិក្ខុ

នោះក៏ផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ១ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើដែលភិក្ខុធ្វើរួចហើយក៏មាន ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានធ្វើអំពើរួចហើយ តែថាកាលអាត្មាអញ ធ្វើអំពើ ( នោះ ) មិនអាចនឹងធ្វើពុទ្ធសាសនា ឲ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះ អាត្មាអញផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យច្បាស់លាស់ ភិក្ខុនោះ ក៏ផ្គងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ២ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុ គួរដើរទៅក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ផ្លូវដែលអាត្មាអញ គួរដើរទៅគង់នឹងមាន តែថា អាត្មាអញដើរទៅកាន់ផ្លូវ ( នោះ ) មិនងាយនឹងធ្វើពុទ្ធសាសនា ឲ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះ អាត្មាអញផ្គងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៣ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុដើរទៅហើយក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានដើរទៅកាន់ផ្លូវហើយ តែ

ថា កាលណា អាត្មាអញដើរទៅកាន់ផ្លូវ មិនអាចធ្វើពុទ្ធសាសនាឲ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះ អាត្មាអញផ្គងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៤ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែតទេ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែតឡើយ អាត្មាអញនោះ មានរាងកាយស្រាល គួរដល់សមណកម្ម បើដូច្នោះ អាត្មាអញផ្គងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៥ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែត ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញ ត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែតហើយ អាត្មាអញនោះមានរាងកាយស្រាល គួរដល់សមណកម្ម បើដូច្នោះ អាត្មាអញផ្គងព្យាយាម ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៦ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានអាពាធតិចតួចកើតឡើង ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ កើតអាពាធតិចតួចនេះហើយ អាពាធចម្រើនដល់អាត្មាអញ ដោយហេតុណា ហេតុនុ៎ះ ជាហេតុតែងមាន

ជាធម្មតាទេ បើដូច្នោះ អាត្មាអញ ផ្គងព្យាយាមឲ្យបានមុនសិន ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៧ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ អាពាធរបស់អាត្មាអញ កើតឡើងវិញ ដោយហេតុណា ហេតុនុ៎ះ ជាហេតុតែងមាន ជាធម្មតាទេ បើដូច្នោះ អាត្មាអញផ្គងព្យាយាមឲ្យបានមុន ដើម្បីឲ្យដល់នូវគុណ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលអាត្មាអញមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យច្បាស់លាស់សិន ភិក្ខុនោះក៏ផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអារព្ភវត្ថុទាំង ៨ យ៉ាង ។

### យមកវគ្គទី ៣ ចប់

## ឧទ្ទានក្នុងយមកវគ្គនោះ គឺ

និយាយពីភិក្ខុបរិបូរដោយអង្គ ២ លើក សម្បទា ១ ភិក្ខុ
ចម្រើនមរណស្សតិដទៃទៀត ១ សេចក្តីប្រាថ្នាលាភ ១
គួរដល់ខ្លួននិងអ្នកដទៃ ១ សេចក្តីសាបសូន្យ របស់

សេក្ខភិក្ខុ ១ កុសីតវត្ថុ ១ អារព្ភវត្ថុ ១ ។

# អដ្ឋកថា

## កុសីតវត្ថុសូត្រទី ១៨ ជាដើម

[ ៩៥-៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុសីតវត្ថុសូត្រទី ១៨ ជាដើម ដូចតទៅនេះ បទថា **កុសីតវត្ថូនិ** បានដល់ វត្ថុ គឺទីតាំងនៃការខ្ជិលច្រអូស គឺបុគ្គលខ្ជិលច្រអូស អធិប្បាយថា ហេតុនៃការខ្ជិលច្រអូស ។ បទថា **កម្មំ កត្តព្វំ ហោតិ** បានដល់ ត្រូវធ្វើការងារ មានការបោកចីវរជាដើម ។ បទថា **ន វីរិយំ អារភតិ** បានដល់ មិនប្រារព្ធសេចក្ដីព្យាយាមទាំង ២ យ៉ាង ។ បទថា **អប្បត្តស្ស** បានដល់ ដើម្បីដល់នូវធម៌ គឺឈាន វិបស្សនា មគ្គ និងផល ដែលមិនទាន់ដល់ ។ បទថា **អនធិគតស្ស** បានដល់ ដើម្បីសម្រេចនូវធម៌ គឺឈានជាដើមនោះឯង ដែលមិនទាន់សម្រេច ។ បទថា **អសច្ឆិកតស្ស** បានដល់ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ គឺឈានជាដើមនោះឯង ដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ បទថា **ឥទំ បឋមំ** សេចក្ដីថា ការរួញរាយ៉ាងនេះថា ណ្ហើយចុះ អញដេកសិន នេះជាកុសីតវត្ថុ គឺហេតុនៃការខ្ជិលច្រអូសប្រការទី ១ ។ គប្បីជ្រាបក្នុងបទទាំងអស់ដោយន័យនេះឯង ។ ក្នុងបទថា **មាសាចិតំ មញ្ញេ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ឈ្មោះថា

ចិត្តដែលវង្វេង ប្រៀបដូចសណ្តែកភជមាសដែលសើមដោយទឹក អធិប្បាយថា សណ្តែកភជមាសដែលសើមដោយទឹក ជារបស់ធ្ងន់ យ៉ាងណា ភិក្ខុក៏ជារបស់ធ្ងន់យ៉ាងនោះ ។ បទថា **គិលានោ វុដ្ឋិតោ ហោតិ** សេចក្តីថា ភិក្ខុមានជំងឺ ខាងក្រោយជាហើយ ។

បទថា **អារព្ភវត្ថូនិ** បានដល់ ហេតុនៃការព្យាយាម ។ គប្បីជ្រាបសេចក្តី ក្នុងហេតុនៃការព្យាយាមនោះ ដោយន័យនេះឯង ។ ពាក្យដ៏សេសក្នុងបទទាំងពួងមានអត្ថងាយយល់ហើយ ។

**អដ្ឋកថា កុសីតវត្ថុសូត្រទី ១៨ ជាដើមចប់**

**យមកវគ្គទី ៣ ចប់**

# សុត្តន្តបិដក

## សតិវគ្គ

### សតិសូត្រទី ១

[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ កាលបើសតិ និងសម្បជញ្ញៈ មិនមាន ហិរិ និងឱត្តប្បៈ របស់បុគ្គលវិបត្តិចាកសតិ និងសម្បជញ្ញៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើហិរិ និងឱត្តប្បៈ មិនមាន ឥន្ទ្រិយសំវរៈរបស់បុគ្គលវិបត្តិចាកហិរិ និងឱត្តប្បៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើឥន្ទ្រិយសំវរៈមិនមាន សីលរបស់បុគ្គលវិបត្តិចាកឥន្ទ្រិយសំវរៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើសីលមិនមាន សម្មាសមាធិ របស់បុគ្គលវិបត្តិចាកសីល ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើសម្មា-សមាធិមិនមាន យថាភូតញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិចាកសម្មាសមាធិ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើយថាភូតញ្ញាណទស្សនៈ មិនមាន និព្វិទាវិរាគៈ របស់បុគ្គលវិបត្តិចាកយថាភូតញ្ញាណទស្សនៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើនិព្វិទាវិរាគៈមិនមាន វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិចាកនិព្វិទាវិរាគៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើដែលមិនមានមែក និងស្លឹកហើយ ក្រមរឈើនោះក្តី មិនដល់នូវការពេញលេញទេ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនដល់នូវការពេញលេញ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើ

សតិ និងសម្បជញ្ញៈមិនមាន ហិរិ និងឱត្តប្បៈរបស់បុគ្គលវិបត្តិចាកសតិ និងសម្បជញ្ញៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើហិរិ និងឱត្តប្បៈមិនមាន ( ឥន្ទ្រិយសំវរៈ ) របស់បុគ្គលវិបត្តិចាកហិរិ និងឱត្តប្បៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ ។បេ។ វិមុត្តិញាណទស្សនៈ មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលបើសតិ និងសម្បជញ្ញៈមាន ហិរិ និងឱត្តប្បៈរបស់បុគ្គលបរិបូណ៌ដោយសតិ និងសម្បជញ្ញៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើហិរិ និងឱត្តប្បៈមាន ឥន្ទ្រិយសំវរៈរបស់បុគ្គលបរិបូណ៌ដោយហិរិ និងឱត្តប្បៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើឥន្ទ្រិយសំវរៈមាន សីលរបស់បុគ្គលបរិបូណ៌ដោយឥន្ទ្រិយសំវរៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើសីលមាន សម្មាសមាធិរបស់បុគ្គលបរិបូណ៌ដោយសីល ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើសម្មាសមាធិមាន យថាភូតញ្ញាណទស្សនៈរបស់បុគ្គលបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើយថាភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគៈរបស់បុគ្គលបរិបូណ៌ ដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើនិព្វិទាវិរាគៈមាន វិមុត្តិញាណទស្សនៈរបស់បុគ្គលបរិបូណ៌ដោយនិព្វិទាវិរាគៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើដែលបរិបូណ៌ដោយមែក និងស្លឹកហើយ ក្រមរឈើនោះ ក៏ដល់នូវការពេញលេញ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ( របស់ឈើ

នោះ ) ក៏ដល់នូវការពេញលេញ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំង-ឡាយ កាលបើសតិ និងសម្បជញ្ញៈមាន ហិរិ និងឱត្តប្បៈ របស់បុគ្គលបរិបូណ៌ដោយសតិ និងសម្បជញ្ញៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើហិរិ និងឱត្តប្បៈមាន ( ឥន្ទ្រិយសំវរៈ ) របស់បុគ្គលបរិបូណ៌ដោយហិរិ និងឱត្តប្បៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ ។បេ។ វិមុត្តិញាណទស្សនៈ មានឧបមេយ្យយ៉ាងនោះដែរ ។

# អដ្ឋកថា
## សតិវគ្គទី ៤

### សតិសូត្រ

[ ៩៧ ] ក្នុងសតិសូត្រទី ១ នៃសតិវគ្គទី ៤ មានវិនិច្ឆ័យដូចពោល ហើយខាងដើមនោះឯង ។

**អដ្ឋកថា សតិសូត្រទី ១ ចប់**

# សុត្តន្តបិដក
## បុណ្ណិយសូត្រទី ២

[ ៩៨ ] គ្រានោះ ព្រះបុណ្ណិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះបុណ្ណិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វីបច្ច័យអ្វី បានជាក្នុងកាលខ្លះ ព្រះតថាគតទ្រង់សម្តែងធម្មទេសនា ក្នុងកាលខ្លះក៏មិនសម្តែង ។ ព្រះអង្គត្រាស់តបថា ម្នាលបុណ្ណិយៈ ភិក្ខុមានសទ្ធាហើយ តែមិនចូលមករកទេ តថាគតក៏មិនទាន់សម្តែងធម្មទេសនា ម្នាលបុណ្ណិយៈ កាល

បើភិក្ខុមានសទ្ធាផង បានចូលមករកផង យ៉ាងនេះ ទើបតថាគតសម្តែងធម្មទេសនា ម្នាលបុណ្ណិយៈ ភិក្ខុមានសទ្ធាផង បានចូលមករកផង តែមិនបានចូលមកអង្គុយជិត ។បេ។ បានចូលមកអង្គុយជិតហើយ តែមិនបានសាកសួរ បានសាកសួរហើយ តែមិនបានផ្ទៀងត្រចៀកស្តាប់ធម៌ ផ្ទៀងត្រចៀកស្តាប់ហើយ តែមិនស្តាប់ឲ្យចាំធម៌ ស្តាប់ចាំធម៌ហើយ តែមិនពិចារណានូវសេចក្តីនៃធម៌ ដែលខ្លួនចងចាំហើយ ពិចារណានូវសេចក្តីនៃធម៌ដែលខ្លួនចងចាំហើយ តែមិនដឹងនូវអត្ថមិនដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ទេ តថាគតក៏មិនសម្តែងធម្មទេសនាឡើយ ។ ម្នាលបុណ្ណិយៈ កាលបើភិក្ខុមានសទ្ធាផង បានចូលមករកផង បានចូលមកអង្គុយជិតផង បានសាកសួរផង បានផ្ទៀងត្រចៀកស្តាប់ធម៌ផង ស្តាប់ឲ្យចាំធម៌ផង ពិចារណានូវសេចក្តីនៃធម៌ដែលខ្លួនចងចាំផង ដឹងនូវអត្ថដឹងនូវធម៌ហើយ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ផង យ៉ាងនេះ ទើបតថាគតសម្តែងធម្មទេសនា ។ ម្នាលបុណ្ណិយៈ ភិក្ខុប្រកបដោយធម៌ ( ៨ យ៉ាង ) នេះឯង ទើបតថាគតសម្តែងនូវធម្មទេសនា យ៉ាងច្បាស់លាស់ ។

# អដ្ឋកថា

## បុណ្ណិយសូត្រ

[ ៩៨ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបុណ្ណិយសូត្រទី ២ ដូចតទៅនេះ បទថា* **សទ្ធោ** *បានដល់ ដែលប្រកបដោយសទ្ធា ២ យ៉ាង ។ បទថា* **នោ ច បយិរុបាសិតា** *ប្រែថា មិនចូលទៅបម្រើ ។ បទថា* **នោ ច បរិបុច្ឆិតា** *ប្រែថា មិនសាកសួរប្រយោជន៍ និងមិនមែនប្រយោជន៍ ហេតុ និងមិនមែនហេតុ ។ បទថា* **សមន្នាគតោ** *ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ អធិប្បាយថា* **សមន្នាគតស្ស** *ប្រែថា ដែលប្រកបហើយ ។ បទថា* **ឯកន្តប្បដិភាណំ តថាគតំ ធម្មទេសនា ហោតិ** *សេចក្តីថា ធម្មទេសនា គឺការសម្តែងធម៌នៃព្រះតថាគត ជាក់ច្បាស់ដោយចំណែកមួយ អធិប្បាយថា រមែងជាក់ច្បាស់ រមែងប្រាកដ ដោយចំណែកមួយ ។*

អដ្ឋកថា បុណ្ណិយសូត្រទី ២ ចប់

# សុត្តន្តបិដក

## មូលសូត្រទី ៣

[ ៩៩ ] *ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជក ជាអន្យតិរ្ថិយសួរយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងអស់ គឺបញ្ចក្ខន្ធ មានអ្វីជាមូល ធម៌ទាំងអស់*

កើតអំពីអ្វី ធម៌ទាំងអស់ប្រជុំកើតអំពីអ្វី ធម៌ទាំងអស់ប្រជុំចុះក្នុងអ្វី ធម៌ទាំងអស់មានអ្វីជាប្រធាន ធម៌ទាំងអស់មានអ្វីជាអធិបតី ធម៌ទាំងអស់ មានអ្វីជាវិសេស ធម៌ទាំងអស់មានអ្វីជាខ្លឹម ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាអន្យតិរ្ថិយ សួរយ៉ាងនេះ តើអ្នកទាំងឡាយ គប្បីដោះស្រាយដូចម្ដេចដល់ពួកបរិព្វាជក ជាអន្យតិរ្ថិយនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ មានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគជាទីពឹង របស់យើងខ្ញុំព្រះអង្គស្រាប់ហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្ដែងនូវសេចក្ដីនៃភាសិតនេះឲ្យទាន ពួកភិក្ខុបានស្ដាប់ភាសិតរបស់ព្រះអង្គហើយ នឹងចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្ដាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្ដែង ។ ភិក្ខុទាំងនោះ បានទទួលតបថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជក ជាអន្យ-តិរ្ថិយ សួរយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងអស់មានអ្វីជាមូល ធម៌ទាំងអស់កើតអំពីអ្វី ធម៌ទាំងអស់ប្រជុំកើតអំពីអ្វី ធម៌ទាំងអស់ប្រជុំចុះក្នុងអ្វី ធម៌ទាំងអស់មានអ្វីជាប្រធាន ធម៌ទាំងអស់មានអ្វីជាអធិបតី ធម៌ទាំងអស់មានអ្វីជាវិសេស ធម៌ទាំងអស់មានអ្វីជាខ្លឹម ម្នាលភិក្ខុទាំងឡាយ កាលបើពួកបរិ-ព្វាជកអន្យតិរ្ថិយសួរយ៉ាងនេះ អ្នកទាំងឡាយ គប្បីដោះស្រាយដល់បរិព្វាជកអន្យតិរ្ថិយទាំងនោះយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងអស់មានឆន្ទៈជាមូល ធម៌

ទាំងអស់ កើតអំពីមនសិការ ធម៌ទាំងអស់ប្រជុំកើតអំពីផស្សៈ ធម៌ទាំងអស់ប្រជុំចុះក្នុងវេទនា ធម៌ទាំងអស់មានសមាធិជាប្រធាន ធម៌ទាំងអស់មានសតិជាអធិបតី ធម៌ទាំងអស់មានបញ្ញាជាវិសេស ធម៌ទាំងអស់មានវិមុត្តិជាខ្លឹម ម្នាលភិក្ខុទាំងឡាយ កាលបើពួកបរិព្វាជកអន្យតិ្ថយ សួរយ៉ាងនេះហើយ អ្នកទាំងឡាយ គប្បីដោះស្រាយដល់បរិព្វាជកអន្យតិ្ថយទាំងនោះយ៉ាងនេះឯង ។

# អដ្ឋកថា

## មូលសូត្រ

[ ៩៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមូលសូត្រទី ៣ ដូចតទៅនេះ បទថា **សព្វេ ធម្មា** បានដល់ ខន្ធ ៥ ។ បទថា **ឆន្ទមូលកា** សេចក្ដីថា ឈ្មោះថា មានឆន្ទៈជាមូល ព្រោះមានឆន្ទៈ គឺអជ្ឈាស្រ័យ និងឆន្ទៈ គឺភាពជាអ្នកប្រាថ្នានឹងធ្វើ ជាមូលនៃខន្ធ ៥ នោះ ។ ឈ្មោះថា មានមនសិការជាដែនកើត ព្រោះកើតអំពីមនសិការ ។ ឈ្មោះថា មានផស្សៈជាសមុទយៈ ព្រោះកើត គឺរួមជាកលាបៈ តែផស្សៈ ឈ្មោះថា មានវេទនាជាទីប្រជុំចុះ ព្រោះប្រជុំចុះក្នុងវេទនា ។ ឈ្មោះថា មានសមាធិជាប្រធាន ព្រោះមានសមាធិជាប្រធាន ។ ឈ្មោះថា មានសតិជាធំ ព្រោះមានសតិជាអធិបតី ដោយអត្ថថា

ចម្រើនបំផុត អធិប្បាយថា មានសតិជាប្រធាន ។ ឈ្មោះថា មានបញ្ញាជាកំពូល ព្រោះអត្ថថា មានបញ្ញាដ៏ប្រសើរ ។ ឈ្មោះថា មានវិមុត្តិជាខ្លឹម ព្រោះមានវិមុត្តិជាសារៈ ។ ក្នុងទីនេះ ព្រះមានព្រះភាគ ត្រាស់លោកិយធម៌ទាំង ៤ មានធន្ទៈជាមូលជាដើម ធម៌ដ៏សេស ទ្រង់ត្រាស់លាយគ្នា ដោយលោកិយផង និងលោកុត្តរផង ៕

អដ្ឋកថា មូលសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ចោរសូត្រទី ៤

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៨ ប្រការ រមែងវិនាសឆាប់ មិនតាំងនៅយូរឡើយ ។ ប្រកបដោយអង្គ ៨ ប្រការ តើដូចម្តេច ។ គឺប្រហារនូវបុគ្គលដែលមិនប្រហារតប ១ កាន់យកទ្រព្យរបស់គេមិនឲ្យមានសេសសល់ ១ នាំយកស្ត្រី ១ ប្រទូស្តនឹងក្មេងស្រ្តី ១ ប្លន់បព្វជិត ១ ប្លន់ព្រះរាជឃ្លាំង ១ ធ្វើចោរកម្មក្នុងទីជិត ( ស្រុកឬនិគមរាជធានីជាដើម ) ១ ជាអ្នកមិនឈ្លាសវៃ ក្នុងការកប់ទ្រព្យទុក ( ក្នុងទក្ខិណេយ្យបុគ្គល ) ១ ។ ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៨ ប្រការនេះឯង រមែងវិនាសឆាប់មិនតាំងនៅយូរឡើយ ។

*[ ១០១ ] ម្នាលភិក្ខុទាំងឡាយ មហាចោរ ប្រកបដោយអង្គ ៨ ប្រការ រមែងមិនវិនាសឆាប់ ជាអ្នកតាំងនៅយូរបាន ។ ប្រកបដោយអង្គ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺមិនប្រហារនូវបុគ្គល ដែលមិនប្រហារតប ១ មិនកាន់យកទ្រព្យរបស់គេមិនឲ្យមានសេសសល់ ១ មិននាំយកស្ត្រី ១ មិនប្រទូស្តក្មេងស្ត្រី ១ មិនប្លន់បព្វជិត ១ មិនប្លន់ព្រះរាជឃ្លាំង ១ មិនធ្វើចោរកម្មក្នុងទីជិត ១ ជាអ្នកឈ្លាសវៃ ក្នុងការកប់ទ្រព្យទុក ( ក្នុងទក្ខិណេយ្យបុគ្គល ) ១ ។ ម្នាលភិក្ខុទាំងឡាយ មហាចោរ ប្រកបដោយអង្គ ៨ ប្រការនេះឯង រមែងមិនវិនាសឆាប់ ជាអ្នកតាំងនៅយូរបាន ។*

# អដ្ឋកថា

## ចោរសូត្រ

*[ ១០០-១០១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចោរសូត្រទី ៤ ដូចតទៅនេះ បទថា* **មហាចោរោ** *បានដល់ មហាចោរដែលអាចប្រទូស្តរាជសម្បត្តិបាន ។ បទថា* **បរិយាបជ្ជតិ** *បានដល់ ដល់នូវការវិនាស ។ បទថា* **ន ចិរដ្ឋិតិកោ ហោតិ** *បានដល់ មិនអាចរក្សាឲ្យតាំងនៅយឺនយូរបាន ។ បទថា* **អប្បហារន្តស្ស បហារតិ** *សេចក្តីថា ប្រហារបុគ្គលដែលមិនមានពៀរដល់ខ្លួន ដែលមិនប្រហារខ្លួន បានដល់ បុគ្គលដែលមានគុណ បុគ្គលដែលចម្រើន*

ដោយវ័យ និងបុគ្គលកំលោះ ដែលមិនគួរប្រហារ ។ បទថា **អនវសេសំ អាទិយតិ** បានដល់ កាន់យកមិនឲ្យសល់ ។ ពិតហើយ ទំនៀមរបស់ចោរ ដែលជាអ្នកឈ្លាស មានដូច្នេះ គឺសំពត់ ២ ផ្ទាំងរបស់អ្នកដទៃ កាន់យកតែមួយផ្ទាំង បើមានមួយផ្ទាំង ទុកចំណែកដែលទ្រុឌទ្រោម កាន់យកតែចំណែកល្អ បណ្តាកញ្ចប់បាយ និងអង្ករជាដើម ឲ្យចំណែកមួយ កាន់យកចំណែកមួយ ។ បទថា **អច្ចាសន្នេ កម្មំ ករោតិ** សេចក្តីថា ធ្វើចោរកម្មក្នុងទីជិតគាមនិគម និងរាជធានី ។ បទថា **ន ច និធានកុសលោ ហោតិ** សេចក្តីថា រមែងមិនជាអ្នកឈ្លាស ក្នុងការកប់ទ្រព្យដែលបានមក ទុកក្នុងទក្ខិណេយ្យបុគ្គល គឺមិនជម្រះផ្លូវទៅកាន់បរលោក ។ល។

អដ្ឋកថា ចោរសូត្រទី ៤ ចប់

# សុត្តន្តបិដក

## សមណសូត្រទី ៥

[ ១០២ ] ម្នាលភិក្ខុទាំងឡាយ ពាក្យថា សមណៈ ( អ្នកស្ងប់រម្ងាប់ ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ ( អ្នកបន្សាត់បង់នូវបាប ) នេះ ជាឈ្មោះរបស់តថាគត ជា

អរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា វេទគូ ( អ្នកចេះចប់ត្រៃវេទ ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភិសក្កៈ ( គ្រូពេទ្យវះកាត់ ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា និម្មលៈ ( អ្នកគ្មានមន្ទិល ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា វិមលៈ ( អ្នកប្រាសចាកមន្ទិល ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្ត-សម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ញាណី ( អ្នកមានញាណ ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា វិមុត្ត ( អ្នកផុតស្រឡះ ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

គុណជាតណា ដែលតថាគតជាសមណៈ ជាព្រាហ្មណ៍ មាន
ព្រហ្មចរិយៈនៅរួចហើយ គប្បីសម្រេចក្តី គុណជាតណា
ដែលតថាគត អ្នកចេះចប់ត្រៃវេទ ជាគ្រូពេទ្យវះកាត់ គប្បី
សម្រេចក្តី គុណជាតនោះ ប្រសើរបំផុត គុណជាតណា
ដែលតថាគត គ្មានមន្ទិល ប្រាសចាកមន្ទិល មានព្រហ្មចរិយៈ
នៅរួចហើយ គប្បីសម្រេចក្តី គុណជាតណា ដែលតថាគត
មានញាណ អ្នករួចស្រឡះ គប្បីសម្រេចក្តី គុណជាតនោះ
ប្រសើរបំផុត តថាគតនោះ ជាអ្នកឈ្នះសង្គ្រាម រួចចាក
ចំណង ទាំងស្រាយមហាជន ឲ្យរួចចាកចំណង ជាបុគ្គល

ប្រសើរ មានខ្លួនទូន្មានហើយដោយប្រពៃ ជាអសេក្ខបុគ្គល បរិនិព្វានហើយ ។

# អដ្ឋកថា

## សមណសូត្រ

[ ១០២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមណសូត្រទី ៥ ដូចតទៅនេះ បទថា **យំ សមណេន** សេចក្តីថា គុណជាតណាដែលសមណៈគប្បីដល់ ។ បទថា **វុសិមតា** បានដល់ មានព្រហ្មចារ្យនៅចប់ហើយ ។ បទថា **មុត្តោ មោចេមិ ពន្ធនា** សេចក្តីថា តថាគតរួចផុតចំណងទាំងពួងដោយខ្លួនឯង ហើយញុំាងមហាជនឲ្យផុតចាកចំណង មានរាគៈជាដើមផងដែរ ។ បទថា **បរមទន្តោ** សេចក្តីថា ដែលបុគ្គលណាម្នាក់មិនបានឲ្យសិក្សា មិនបានឲ្យឱវាទ ដឹងច្បាស់នូវសយម្ភូញាណ ឈ្មោះថា ជាអ្នកទូន្មានហើយដ៏កំពូល ព្រោះទូន្មានហើយ ដោយប្រយោជន៍ដ៏ក្រៃលែង ។ បទថា **បរិនិព្វុតោ** បានដល់ បរិនិព្វានហើយ ដោយកិលេសបរិនិព្វាន ។ល។

**អដ្ឋកថា សមណសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## យសសូត្រទី ៦

[ ១០៣ ] សម័យមួយ ព្រះដ៏មានព្រះភាគ ព្រមដោយភិក្ខុសង្ឃច្រើនរូប ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងក្រុងកោសម្ពី បានស្តេចទៅដល់ព្រាហ្មណគ្រាម ឈ្មោះឥច្ឆានង្គលៈរបស់ពួកអ្នកដែនកោសល ។ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឥច្ឆានង្គលៈ ជិតស្រុកឥច្ឆានង្គលៈនោះ ។ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គលៈ បានឮដំណឹង ( ប្រកាសប្រាប់គ្នា ) ថា ម្នាលគ្នាយើង ឮថា ព្រះសមណគោតមជាសក្យបុត្ត ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ឥឡូវបានស្តេចមកដល់ស្រុកឥច្ឆានង្គលៈហើយ ទ្រង់គង់ក្នុងដងព្រៃឥច្ឆានង្គលៈជិតស្រុកឥច្ឆានង្គលៈ ។ កិត្តិសព្ទដ៏ពីរោះយ៉ាងនេះ របស់ព្រះគោតមដ៏ចម្រើនអង្គនោះ ល្បី ឮ សុសសាយទៅថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ។បេ។ ក៏ការដែលបានជួបប្រទះនឹងព្រះអរហន្តទាំងឡាយមានសភាពដូច្នោះ ជាការប្រពៃពេកណាស់ ។ គ្រានោះ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គលៈ កាលកន្លងរាត្រីនោះទៅហើយ ក៏នាំយកខាទនីយភោជនីយាហារដ៏ក្រាស់ក្រែល នាំគ្នាដើរចូលសំដៅទៅរកដងព្រៃឥច្ឆានង្គលៈ លុះចូលទៅដល់ហើយ ក៏ឈរស្រែកហៅនិយាយខ្លាំង ទៀបខ្លោងទ្វារខាងក្រៅ ។

សម័យនោះឯង ព្រះនាគិតៈដ៏មានអាយុ ជាឧបដ្ឋាកព្រះដ៏មានព្រះភាគ ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរព្រះនាគិតៈដ៏មានអាយុថា ម្នាល

នាគិតៈ ចុះពួកណាស្រែកហ៊ោ និយាយឮខ្លាំងម៉្លេះ ហាក់ដូចជាព្រានសំណាញ់ដណ្តើមត្រីគ្នា ។ ព្រះនាគិតៈដ៏មានអាយុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស អ្នកទាំងនុ៎ះ ជាព្រាហ្មណ៍ និងគហបតី នៅក្នុងស្រុកឥច្ឆានង្គលៈ នាំយកខាទនីយភោជនីយាហារដ៏ក្រាស់ក្រៃល ឧទ្ទិសចំពោះព្រះដ៏មានព្រះភាគផង ព្រះភិក្ខុសង្ឃផង ហើយឈរទៀបខ្លោងទ្វារខាងក្រៅ ។ ម្នាលនាគិតៈ តថាគតសូមកុំឲ្យជួបប្រសព្វនឹងយសបរិវារ ទាំងយសបរិវារ ក៏សូមកុំឲ្យជួបប្រសព្វនឹងតថាគតឡើយ ម្នាលនាគិតៈ បុគ្គលណា មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួលទេ បុគ្គលនោះឯង គប្បីត្រេកអរចំពោះសេចក្តីសុខ មិនស្អាត សុខក្នុងការដេកលក់ សុខកើតអំពីលាភសក្ការៈ និងពាក្យសរសើរ ។ ព្រះនាគិតៈ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគទទួលនិមន្តន៍ សូមព្រះសុគតទទួលនិមន្តន៍ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលនេះជាកាលគួរព្រះដ៏មានព្រះភាគទទួលនិមន្តន៍ហើយ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះដ៏មានព្រះភាគនឹងស្តេចទៅក្នុងទីណាៗ ក្នុងកាលឥឡូវនេះ ក៏គង់ពួកព្រាហ្មណ៍ និងគហបតី ជាអ្នកនិគមក្តី អ្នកជនបទក្តី នឹងតាមទៅក្នុងទីនោះៗ មិនខាន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើភ្លៀងមានតំណក់ទឹកធ្ងន់ៗ បង្អុរចុះមក ទឹក

ទាំងឡាយ តែងហូរធ្លាក់ទៅកាន់ទីទាប ដូចម្ដេចមិញ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះដ៏មានព្រះភាគ នឹងស្ដេចទៅក្នុងទីណាៗ ក្នុងកាលឥឡូវនេះ ក៏គង់ពួកព្រាហ្មណ៍និងគហបតី ជាអ្នកនិគមក្ដី អ្នកជនបទក្ដី នឹងតាមទៅក្នុងទីនោះៗ មិនខានដូច្នោះឯង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះដ៏មានព្រះភាគ ព្រះអង្គមានសីល និងប្រាជ្ញា ។ ម្នាលនាគិតៈ តថាគត សូមកុំឲ្យជួបប្រសព្វនឹងយសបរិវារ ទាំងយសបរិវារ ក៏សូមកុំឲ្យជួបប្រសព្វនឹងតថាគតឡើយ ម្នាលនាគិតៈ បុគ្គលណា មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធ-សុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួលទេ បុគ្គលនោះ គប្បីត្រេកអរចំពោះសេចក្ដីសុខមិនស្អាត សុខក្នុងការដេកលក់ សុខដែលកើតអំពីលាភសក្ការៈ និងពាក្យសរសើរ ។ ម្នាលនាគិតៈ សូម្បីទេវតាពួកខ្លះ ក៏មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិ-វេកសុខ ឧបសមសុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧប-សមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួលដែរ ម្នាលនាគិតៈ អ្នកទាំងឡាយ កាលមកប្រជុំសមាគមគ្នា ខ្វល់ខ្វាយខាងការនៅច្រឡូកច្រឡំដោយពួកហើយ រមែងមានសេចក្ដីត្រិះរិះយ៉ាងនេះថា លោកទាំងឡាយនេះ មុខជាមិនបានដូចប្រាថ្នា មិនបានដោយងាយ មិន

បានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបាន ដូចប្រាថ្នា បានដោយងាយ បានដោយស្រួល ដោយពិត ព្រោះថា លោកដ៏ មានអាយុទាំងនេះ មកប្រជុំសមាគមគ្នា ប្រកបរឿយៗ ខាងការនៅច្រឡូក ច្រឡំដោយពួក ។ ម្នាលនាគិត: ក្នុងទីឯណោះ តថាគតឃើញពួកភិក្ខុ កំពុង សើចក្អាកក្អាយ សើចប្រឡែងគ្នា ដោយការចាក់ដោយជន្ទួញ គឺម្រាមដៃទៅ វិញទៅមក ម្នាលនាគិត: តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកដ៏មាន អាយុទាំងនេះ មុខជាមិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយ ស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ ដូចជា នេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូច ប្រាថ្នា បានដោយងាយ បានដោយស្រួល ដោយពិត ព្រោះថា លោកដ៏មាន អាយុទាំងនេះ សើចក្អាកក្អាយ សើចប្រឡែងគ្នា ដោយការចាក់ដោយជន្ទួញ គឺម្រាមដៃ ទៅវិញទៅមក ។ ម្នាលនាគិត: មួយទៀត ក្នុងទីឯណោះ តថាគត ឃើញពួកភិក្ខុ បរិភោគជាបទាល់ផ្អែតពេញពោះ ហើយខ្វល់ខ្វាយខាង សេចក្តីសុខនឹងដំណេក សុខនឹងបង្អែក សុខនឹងការដេកលក់ ម្នាលនាគិត: តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកទាំងឡាយនេះ មុខជាមិន បានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ

ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួល ដោយពិត ព្រោះថា លោកទាំងឡាយនេះ បរិភោគជរាប ទាល់ឆ្អែតពេញពោះ ខ្វល់ខ្វាយខាងសេចក្ដីសុខនឹងដំណេក សុខនឹងបង្អែក សុខនឹងការដេកលក់ ។ ម្នាលនាគិតៈ ក្នុងទីឯណោះ តថាគតឃើញភិក្ខុមានចិត្តតម្កល់នៅនឹង អង្គុយក្នុងវិហារជិតស្រុក តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អារាមិកជន ឬក៏សមណុទ្ទេស នឹងមកបម្រើលោកនេះ ឯការបម្រើនោះ នឹងញុំាងលោកនេះ ឲ្យឃ្លាតចាកសមាធិនោះពុំខាន ម្នាលនាគិតៈ ព្រោះហេតុនោះ តថាគតមិនត្រេកអរនឹងភិក្ខុនោះ ដោយការនៅក្នុងទីជិតស្រុក ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុរត់ចេញទៅអង្គុយនៅក្នុងព្រៃ ម្នាលនាគិតៈ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ មុខជានឹងកម្ចាត់បង់នូវសេចក្ដីងោកងក់ និងសេចក្ដីលំបាកនេះហើយ នឹងធ្វើទុកក្នុងចិត្តនូវអរញ្ញសញ្ញា ជាធម្មជាតមានចិត្តមូលតែមួយពុំខាន ម្នាលនាគិតៈ ព្រោះហេតុនោះ តថាគតត្រេកអរនឹងភិក្ខុនោះ ដោយការនៅក្នុងព្រៃ ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុ មានចិត្តមិនទាន់តម្កល់នៅនឹងទេ អង្គុយនៅក្នុងព្រៃ ម្នាលនាគិតៈ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ នឹងតម្កល់ចិត្តដែលមិនទាន់តម្កល់ ឬនឹងរក្សាចិត្ត ដែលខ្ជួនបានតម្កល់ហើយពុំខាន ម្នាលនាគិតៈ ព្រោះហេតុនោះ តថាគតមានចិត្តត្រេកអរនឹងភិក្ខុនោះ

ដោយការនៅក្នុងព្រៃ ។ ម្នាលនាគិតៈ មួយវិញទៀត ក្នុងទីឯណោះ តថាគត ឃើញភិក្ខុមួយរូប អ្នកនៅក្នុងព្រៃ មានចិត្តតម្កល់នៅនឹង កំពុងអង្គុយ ម្នាលនាគិតៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ នឹងធ្វើចិត្តដែលមិនទាន់រួចឲ្យរួចស្រឡះ ឬនឹងរក្សាចិត្តដែលរួចស្រឡះហើយ ពុំខាន ម្នាលនាគិតៈ ព្រោះហេតុនោះ តថាគតមានចិត្តត្រេកអរនឹងភិក្ខុនោះ ដោយការនៅក្នុងព្រៃ ។ ម្នាលនាគិតៈ សម័យណា ដែលតថាគតដើរទៅកាន់ផ្លូវឆ្ងាយ មិនបានជួបប្រទះអ្វីតិចតួច ក្នុងខាងមុខក្តី ខាងក្រោយក្តី ម្នាលនាគិតៈ សម័យនោះ តថាគតមានតែសេចក្តីសប្បាយ ដោយហោចទៅ សូម្បីការធ្វើឧច្ចារៈ ឬបស្សាវៈក៏ស្រួល ។

# អដ្ឋកថា

## យសសូត្រ

[ ១០៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយសសូត្រទី ៦ ដូចតទៅនេះ បទថា **មា ច មយា យសោ** សេចក្តីថា យស កុំបីទៅជាមួយតថាគតឡើយ ។ បទថា **អកសិរលាភី** បានដល់ បានយ៉ាងបរិបូណ៌ ។ បទថា **សីលប្បញ្ញាណំ** បានដល់ សីល និងការដឹងទូទៅ ។ បទថា **សំគម្ម** ប្រែថា ប្រជុំហើយ ។ បទថា **សមាគម្ម** ប្រែថា មកប្រជុំគ្នាហើយ ។

បទថា **សង្គណិការាមោ** ប្រែថា ការនៅច្របូកច្របល់ដោយពួកគណៈ ។ បទថា **ឆ ហិ ឆ្វនមេ** កាត់បទជា **ឆ ហិ ឆ្វន ឥមេ។** បទថា **តថា ហិ បនមេ** កាត់បទជា **តថា ហិ បន ឥមេ។** បទថា **អង្គុលិប្បតោទកេន** បានដល់ ដោយយកម្រាមដៃធ្វើជងជន្ទួញ រួចចាក់ ។ បទថា **សព្ភាគទ្បន្តេ** បានដល់ សើចដោយសំឡេងខ្លាំង ។ បទថា **សង្ហីឡន្តេ** បានដល់ ធ្វើការប្រឡែងគ្នា ៕

## អដ្ឋកថា យសសូត្រទី ៦ ចប់

# សុត្តន្តបិដក

## បត្តសូត្រទី ៧

[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ ឧបាសក ប្រកបដោយអង្គ ៨ ប្រការ សង្ឃកាលប្រាថ្នា គប្បីផ្កាប់បាត្របាន ។ អង្គ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺឧបាសកព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានលាភ ១ ព្យាយាមដើម្បីមិនឲ្យភិក្ខុទាំងឡាយបានប្រយោជន៍ ១ ព្យាយាមដើម្បីមិនឲ្យភិក្ខុទាំងឡាយបានទីលំនៅ ១ជេរប្រទេចភិក្ខុទាំងឡាយ ១ បំបែកភិក្ខុទាំងឡាយឲ្យបែកចាកភិក្ខុទាំងឡាយ ១ តិះដៀលព្រះពុទ្ធ ១ តិះដៀលព្រះធម៌ ១ តិះដៀលព្រះ

សង្ឃ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយអង្គ ៨ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីផ្កាប់បាត្របាន ។

[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយអង្គ ៨ ប្រការ សង្ឃកាលប្រាថ្នា គប្បីផ្ងារបាត្របាន ។ ដោយអង្គ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺឧបាសក មិនព្យាយាមដើម្បីមិនឲ្យភិក្ខុទាំងឡាយបានលាភ ១ មិនព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយ បានប្រយោជន៍ ១ មិនព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានទីលំនៅ ១ មិនជេរប្រទេចភិក្ខុទាំងឡាយ ១ មិនបំបែកភិក្ខុទាំងឡាយឲ្យបែកចាកភិក្ខុទាំងឡាយ ១ ពោលសរសើរព្រះពុទ្ធ ១ ពោលសរសើរព្រះធម៌ ១ ពោលសរសើរព្រះសង្ឃ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយអង្គ ៨ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីផ្ងារបាត្របាន ។

# អដ្ឋកថា

## បត្តសូត្រ

[ ១០៤-១០៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបត្តសូត្រទី ៧ ដូចតទៅនេះ បទថា **និក្កុជ្ជេយ្យ** បានដល់ គប្បីផ្កាប់បាត្រដោយកម្មវាចា ដែលសូត្រក្នុងនិក្កុជ្ជនកម្មដើម្បីមិនឲ្យទទួលទេយ្យធម៌ ដែលឧបាសកនោះប្រគេន មិនមែនផ្កាប់បាត្រ ដោយយកបាត្រទៅផ្កាប់នោះឡើយ ។ បទថា **អលាភាយ** បាន

ដល់ ដើម្បីមិនឲ្យបានបច្ច័យ ៤ ។ បទថា **អនត្ថាយ** បានដល់ ដើម្បីអន្តរាយ គឺដើម្បីមិនចម្រើន ។ បទថា **ឧក្កុជ្ជេយ្យុ** បានដល់ គប្បីផ្ងារបាត្រដោយកម្មវាចា ដែលសូធ្យក្នុងឧក្កុជ្ជនកម្ម ។៙

## អដ្ឋកថាបត្តសូត្រទី ៧ ចប់

# សុត្តន្តបិដក

## អប្បសាទសូត្រទី ៨

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ ពួកឧបាសកកាលប្រាថ្នា គប្បីសម្តែងសេចក្តីមិនជ្រះថ្លាបាន ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ១ ព្យាយាមដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ ជេរប្រទេចពួកគ្រហស្ថ ១ បំបែកពួកគ្រហស្ថឲ្យបែកចាកពួកគ្រហស្ថ ១ តិះដៀលព្រះពុទ្ធ ១ តិះដៀលព្រះធម៌ ១ តិះដៀលព្រះសង្ឃ ១ ទាំងពួកទេវតា ក៏ឃើញនូវភិក្ខុនោះដោយហេតុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការនេះឯង ពួកឧបាសកកាលប្រាថ្នា គប្បីសម្តែងសេចក្តីមិនជ្រះថ្លាបាន ។

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ ពួក

ឧបាសក កាលប្រាថ្នា គប្បីសម្តែងសេចក្តីជ្រះថ្លាបាន ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុមិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ១ មិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ មិនជេរប្រទេចពួកគ្រហស្ថ ១ មិនបំបែកពួកគ្រហស្ថ ឲ្យបែកចាកពួកគ្រហស្ថ ១ ពោលសរសើរព្រះពុទ្ធ ១ ពោលសរសើរព្រះធម៌ ១ ពោលសរសើរព្រះសង្ឃ ១ ពួកទេវតាឃើញភិក្ខុនោះ ដោយហេតុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការនេះឯង ពួកឧបាសកកាលប្រាថ្នា គប្បីសម្តែងនូវសេចក្តីជ្រះថ្លាបាន ។

# អដ្ឋកថា

## អប្បសាទសូត្រ

[ ១០៦-១០៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអប្បសាទសូត្រទី ៨ ដូចតទៅនេះ បទថា **អប្បសាទំ បវេទេយ្យុំ** បានដល់ គប្បីធ្វើឲ្យចូលដល់ភាពជាអ្នកជ្រះថ្លា ។ សួរថា កាលនឹងប្រកាសការមិនជ្រះថ្លា ត្រូវធ្វើដូចម្តេច ។ ឆ្លើយថា មិនក្រោកចាកអាសនៈដែលខ្លួនអង្គុយ មិនធ្វើអញ្ជលី មិនចេញទៅធ្វើការទទួល មិនប្រគេនទេយ្យធម៌ ។ បទថា **អគោចរេ** បានដល់ អគោចរ ៥ យ៉ាង ។

# សុត្តន្តបិដក

## បដិសារណីយសូត្រទី ៩

[ ១០៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ សង្ឃកាលប្រាថ្នា គប្បីធ្វើបដិសារណីយកម្មបាន ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ១ ព្យាយាមដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ ជេរប្រទេចពួកគ្រហស្ថ ១ បំបែកពួកគ្រហស្ថឲ្យបែកចាកពួកគ្រហស្ថ ១ តិះដៀលព្រះពុទ្ធ ១ តិះដៀលព្រះធម៌ ១ តិះដៀលព្រះសង្ឃ ១ ញុំាងពាក្យនិមន្តរបស់គ្រហស្ថប្រកបដោយធម៌ឲ្យឃ្លៀងឃ្លាត ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីធ្វើបដិសារណីយកម្មបាន ។

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ សង្ឃកាលប្រាថ្នា គប្បីរម្ងាប់នូវបដិសារណីយកម្មបាន ។ ប្រកបដោយធម៌ ៨ ប្រការតើដូចម្តេចខ្លះ ។ គឺភិក្ខុមិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ១ មិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ មិនជេរប្រទេចពួកគ្រហស្ថ ១ មិនបំបែកពួកគ្រហស្ថឲ្យបែកចាកពួកគ្រហស្ថ ១ ពោលសរសើរព្រះពុទ្ធ ១ ពោលសរសើរព្រះធម៌ ១ ពោលសរសើរព្រះសង្ឃ ១ ញុំាងពាក្យនិមន្តរបស់ពួកគ្រហស្ថ ប្រកបដោយធម៌ឲ្យទៀងទាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីរម្ងាប់នូវបដិសារណីយកម្មបាន ។

# អដ្ឋកថា

## បដិសារណីយសូត្រ

[ ១០៨-១០៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបដិសារណីយសូត្រទី ៩ ដូចតទៅនេះ បទថា **ធម្មិកញ្ច គិហិប្បដិស្សវំ** សេចក្តីថា កាលគ្រហស្ថអារាធនាថា សូមលោកម្ចាស់នៅក្នុងទីនេះអស់ត្រៃមាស ក៏ទទួលដោយន័យជាដើមថា ចូរជាយ៉ាងនោះចុះ ឈ្មោះថា **បដិស្សវ** គឺទទួលពាក្យ ។ បទថា **ន សច្ចាបេតិ** បានដល់ មិនធ្វើនូវពាក្យសច្ចៈ គឺពោលឲ្យឃ្លៀងឃ្លាត ៗ។

**អដ្ឋកថា បដិសារណីយសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## វត្តសូត្រទី ១០

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើតស្សបាបិយសិកាកម្មរួចហើយ ត្រូវប្រព្រឹត្តឲ្យល្អ ក្នុងធម៌ ៨ ប្រការ គឺមិនត្រូវឲ្យឧបសម្បទា ១ មិនត្រូវឲ្យនិស្ស័យ ១ មិនត្រូវឲ្យសាមណេរបម្រើ ១ មិនត្រូវត្រេកអរនឹងការសន្មតជាអ្នកឲ្យឱវាទដល់ភិក្ខុនី ១ បើទុកជាសង្ឃសន្មតហើយ ក៏មិនត្រូវឲ្យឱវាទពួកភិក្ខុនី ១ មិនត្រូវត្រេកអរនឹងសង្ឃសម្មតិណាមួយ ១ មិនត្រូវនិយមខ្ទនក្នុងទីជាអធិបតីណាមួយ ១ មិនត្រូវឲ្យ ( ភិក្ខុ ) ចេញចាកអាបត្តិដោយ

មួលនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើតស្សបាបិយសិកាកម្ម រួចហើយ ត្រូវប្រព្រឹត្តឲ្យល្អ ក្នុងធម៌ ៨ ប្រការនេះឯង ។

សតិវគ្គ ចប់

## ឧទ្ទានក្នុងសតិវគ្គនោះ គឺ

និយាយអំពីសតិសម្បជញ្ញៈ ១ អំពីរឿងបុណ្ណិយភិក្ខុ ១ អំពីធម៌ជាមូល ១ អំពីមហាចោរ ១ អំពីព្រះនាមព្រះតថាគតមានព្រះនាមថា សមណៈជាដើម ១ ត្រូវជា ៥ អំពីព្រះអង្គមិនចង់ជួបនឹងយសបរិវារ ១ អំពីការផ្កាប់បាត្រ និងផ្ងារបាត្រ ១ អំពីសេចក្តីជ្រះថ្លា និងមិនជ្រះថ្លា ១ អំពីបដិសារណីយកម្ម ១ អំពីភិក្ខុប្រព្រឹត្តល្អ ១ ។

# អដ្ឋកថា

## វត្តសូត្រ

[ ១១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវត្តសូត្រទី ១០ ដូចតទៅនេះ បទថា **បច្ចេកដ្ឋានេ** បានដល់ ក្នុងតំណែងអធិបតីសង្ឃ គឺក្នុងតំណែងប្រធាន ។ ពិតហើយ មិនគួរធ្វើបុគ្គលនោះឲ្យជាប្រធាន ហើយធ្វើសង្ឃកម្មណាមួយឡើយ ។ បទថា **ន ច តេន មូលេន វុដ្ឋាបេតព្វំ** សេចក្តីថា ធ្វើកម្ម គឺ

*អញ្ញាន ហៅចូលជំនុំសង្ឃ និងវុដ្ឋាន គឺចេញចាកគរុកាបត្តិ ធ្វើបុគ្គលនោះឲ្យជាមូល គឺជាប្រធានមិនបាន ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ។*

**អដ្ឋកថា វគ្គសូត្រទី ១០ ចប់**

**សតិវគ្គទី ៤ ចប់**

# សុត្តន្តបិដក

## សាមញ្ញវគ្គទី៤

រឿងក្រៅពីនេះទៅ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងឧបោសថកម្មប្រកប ដោយអង្គ ៨ ប្រការ ដល់ពួកឧបាសិកាទាំងអម្បាលនេះ គឺពោជ្ឈាឧបាសិកា សិរិមាឧបាសិកា បទុមាឧបាសិកា សុធម្មាឧបាសិកា មណុជាឧបាសិកា ឧត្តរា-ឧបាសិកា មុត្តាឧបាសិកា ខេមាឧបាសិកា រុចីឧបាសិកា ចុន្ទីរាជកុមារី ពិម្ពី-ឧបាសិកា សុមនរាជកុមារី មល្លិកាទេវី តិស្សមាតាឧបាសិកា សោណមាតា-ឧបាសិកា កាណមាតាឧបាសិកា ឧត្តរានន្ទមាតាឧបាសិកា វិសាខាមិគារមាតា-ឧបាសិកា ខុជ្ជុត្តរាឧបាសិកា សាមាវតីឧបាសិកា សុប្បវាសាកោឡិយធីតា-ឧបាសិកា សុប្បិយាឧបាសិកា នកុលមាតាគហបតានីឧបាសិកា ។

[ ១១១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការ បុគ្គលត្រូវចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៨ ប្រការ តើដូចម្ដេចខ្លះ ។ គឺសម្មាទិដ្ឋិ ១ សម្មា-សង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលត្រូវចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១១២ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៨ ប្រការ តើដូចម្ដេចខ្លះ ។ គឺបុគ្គលមានសេចក្ដីសម្គាល់ ក្នុងរូបខាងក្នុង ( មានសក់ជាដើមរបស់ខ្លួន ) ឃើញរូបខាងក្រៅ គឺកសិណ មាននីលកសិណជាដើម ជារូបមានប្រមាណតិច មានសម្បុរ

ល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមានសេចក្ដីសម្គាល់ក្នុងរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណមិនបាន មានសម្បុរល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមិនមានសេចក្ដីសម្គាល់ ក្នុងរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមិនមានសេចក្ដីសម្គាល់ ក្នុងរូបខាងក្នុង តែងឃើញរូបខាងក្រៅ ជារូបប្រមាណមិនបាន មានសម្បុរល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមិនមានសេចក្ដីសម្គាល់ ក្នុងរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅ ជារូបខៀវ មានសម្បុរខៀវ ធ្លុះចេញនូវពណ៌ខៀវ មានពន្លឺខៀវ ១ ។បេ។ ជារូបលឿង មានសម្បុរលឿង ធ្លុះចេញនូវពណ៌លឿង មានពន្លឺលឿង ១ ។បេ។ ជារូបក្រហម មានសម្បុរក្រហម ធ្លុះចេញនូវពណ៌ក្រហម មានពន្លឺក្រហម ១ ។បេ។ ជារូបស មានសម្បុរស ធ្លុះចេញនូវពណ៌ស មានពន្លឺស ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលត្រូវពិចារណា

ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការ បុគ្គលត្រូវចម្រើនដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៨ ប្រការ តើដូចម្ដេចខ្លះ ។ បុគ្គលមានរូបជ្ឈានតែងឃើញរូប គឺកសិណទាំងឡាយ មាននីលកសិណជាដើម មិនមានសេចក្ដីសម្គាល់ក្នុងរូបខាងក្នុង ( មានសក់ជាដើមរបស់ខ្លួន ) តែងឃើញរូបខាងក្រៅ គឺកសិណ មាននីលកសិណជាដើម ជាអ្នកមានចិត្តចុះស៊ប់ថា វណ្ណកសិណបរិសុទ្ធ ១ ។ ព្រោះកន្លងបង់នូវរូបសញ្ញាដោយប្រការទាំងពួង វិនាសទៅនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ១ ។ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ១ ។ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ១ ។ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ ។ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈានដោយប្រការទាំងពួង ក៏ចូលកាន់សញ្ញាវេទយិតនិរោធ ( សេចក្ដីរលត់នៃសញ្ញានិងវេទនា ) ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១១៤ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលគប្បីចម្រើន ដើម្បីកំណត់ដឹង ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាសទៅ ដើម្បីរលត់ ដើម្បីលះលែង ដើម្បីរលាស់ចេញនូវរាគៈ ។ ធម៌ ៨ ប្រការនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាសទៅ ដើម្បីរលត់ ដើម្បីលះលែង ដើម្បីរលាស់ចេញនូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ ។

អដ្ឋកនិបាត ចប់

# អដ្ឋកថា

# សាមញ្ញវគ្គទី ៩

## សាមញ្ញវគ្គ

[ ១១១-១១៤ ] *បន្ទាប់អំពីនេះទៅ ពាក្យថា* **អថខោ ពោជ្ឈា ឧបាសិកា** *ដូច្នេះជាដើម ព្រះមានព្រះភាគត្រាស់ចំពោះឧបោសថកម្ម ដែលប្រកបដោយអង្គ ៨ ប៉ុណ្ណោះ សម្រាប់ឧបាសិកាមានចំនួនប៉ុណ្ណោះ គឺពោជ្ឈាឧបាសិកា ១ សិរិមាឧបាសិកា ១ បទុមាឧបាសិកា ១ សុធម្មាឧបាសិកា ១ មនុជាឧបាសិកា ១ ឧត្តរាឧបាសិកា ១ មុត្តាឧបាសិកា ១ ខេមាឧបាសិកា ១ រុចិឧបាសិកា ១ ចុន្ទីរាជកុមារី ១ ពិម្ពីឧបាសិកា ១ សុមនារាជកុមារី ១ មល្លិកាទេវី ១ តិស្សមាតាឧបាសិកា ១ សោណាឧបាសិកា ១ សោណមាតាឧបាសិកា ១ កាណាមាតាឧបាសិកា ១ ឧត្តរានន្ទមាតា ១ វិសាខាមិគារមាតា ១ ខុជ្ជុត្តរាឧបាសិកា ១ សាមាវតីឧបាសិកា ១ សុប្បវាសាកោលិយធីតា ១ សុប្បិយាឧបាសិកា ១ នកុលមាតាគហបតានី ១ ។ បុគ្គលដែលប្រាថ្នា គប្បីពោលឲ្យពិស្តារចុះ ។ ពាក្យដ៏សេស ក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ។*

**អដ្ឋកថា សាមញ្ញវគ្គទី ៩ ចប់**

**មនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ**

**អដ្ឋកនិបាត ចប់**

# ក្បាលទី ៣០

# សុត្តន្តបិដក-ចាលីប្រែ ៤៧

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


ធនវគ្គ

បឋមអប្បិយសូត្រ ...... ...... ...... ...... ២

អដ្ឋកថាបឋមអប្បិយសូត្រ ...... ...... ...... ...... ៤

ទុតិយអប្បិយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៥

បឋមពលសូត្រ ...... ...... ...... ...... ៦

អដ្ឋកថាបឋមពលសូត្រ ...... ...... ...... ...... ៧

ទុតិយពលសូត្រ ...... ...... ...... ...... ៧

អដ្ឋកថាទុតិយពលសូត្រ ...... ...... ...... ...... ១០

បឋមធនសូត្រ ...... ...... ...... ...... ១០

អដ្ឋកថាបឋមធនសូត្រ ...... ...... ...... ...... ១១

ទុតិយធនសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១១

ឧគ្គសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១៤

សំយោជនសូត្រ ...... ...... ...... ...... ១៧

អដ្ឋកថាសំយោជនសូត្រ ...... ...... ...... ...... ១៧

បហានសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១៨

មច្ឆរិយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ២០

អនុសយវគ្គ

បឋមអនុសយសូត្រជាដើម ( មិនមានអដ្ឋកថា ) ...... ...... ២១

កុលសូត្រ ...... ...... ...... ...... ២២

អដ្ឋកថាកុលសូត្រ ...... ...... ...... ...... ២៤

បុគ្គលសូត្រ ...... ...... ...... ...... ២៥

អដ្ឋកថាបុគ្គលសូត្រ ...... ...... ...... ...... ២៥

ឧទកូបមសូត្រ ...... ...... ...... ...... ៣០

អដ្ឋកថាឧទកូបមសូត្រ ...... ...... ...... ...... ៣៣

អនិច្ចសូត្រ ...... ...... ...... ...... ៣៥

អដ្ឋកថាអនិច្ចសូត្រ ...... ...... ...... ...... ៣៧

ទុក្ខសូត្រជាដើម ...... ...... ...... ...... ៣៩

អដ្ឋកថាទុក្ខសូត្រជាដើម ...... ...... ...... ...... ៤១

និទ្ទសវត្ថុសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៤២

**វជ្ជីវគ្គ**

សារន្ទសូត្រ ...... ...... ...... ...... ៤៤

អដ្ឋកថាសារន្ទសូត្រ ...... ...... ...... ...... ៤៧

វស្សការសូត្រ ...... ...... ...... ...... ៥៦

អដ្ឋកថាវស្សការសូត្រ ...... ...... ...... ...... ៦៤

ភិក្ខុសូត្រ ...... ...... ...... ...... ៦៨

អដ្ឋកថាភិក្ខុសូត្រ ...... ...... ...... ...... ៧០

កម្មសូត្រ ...... ...... ...... ...... ៧៨

អដ្ឋកថាកម្មសូត្រ ...... ...... ...... ...... ៧៩

សទ្ធិយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៨២

ពោធិយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៨៣

សញ្ញាសូត្រ ...... ...... ...... ...... ៨៤

អដ្ឋកថាសញ្ញាសូត្រ ...... ...... ...... ...... ៨៥
សេក្ខសូត្រ ...... ...... ...... ...... ៨៦
អដ្ឋកថាសេក្ខសូត្រ ...... ...... ...... ...... ៨៧
ហានិសូត្រ ...... ...... ...... ...... ៨៨
អដ្ឋកថាហានិសូត្រ ...... ...... ...... ...... ៩០
វិបត្តិសម្ភវសូត្រ ...... ...... ...... ...... ៩០
អដ្ឋកថាវិបត្តិសម្ភវសូត្រ ...... ...... ...... ...... ៩២

ទេវតាវគ្គ

អប្បមាទសូត្រ ...... ...... ...... ...... ៩៣
អដ្ឋកថាអប្បមាទសូត្រ ...... ...... ...... ...... ៩៥
ហិរីមាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៩៥
បឋមសុវចសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៩៧
ទុតិយសុវចសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៩៨
បឋមសខាសូត្រ ...... ...... ...... ...... ១០១
អដ្ឋកថាបឋមសខាសូត្រ ...... ...... ...... ...... ១០២
ទុតិយសខាសូត្រ ...... ...... ...... ...... ១០៣
អដ្ឋកថាទុតិយសខាសូត្រ ...... ...... ...... ...... ១០៤
បឋមបដិសម្ភិទាសូត្រ ...... ...... ...... ...... ១០៤
អដ្ឋកថាបឋមបដិសម្ភិទាសូត្រ ...... ...... ...... ...... ១០៥
ទុតិយបដិសម្ភិទាសូត្រ ...... ...... ...... ...... ១០៦
អដ្ឋកថាទុតិយបដិសម្ភិទាសូត្រ ...... ...... ...... ...... ១០៨
បឋមវសសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១០៨

ទុតិយវេសសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១០៩
បឋមនិទ្ទសសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១១០
ទុតិយនិទ្ទសសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១១៤

## មហាយញ្ញវគ្គ

ចិត្តសូត្រ ...... ...... ...... ...... ១១៩
អដ្ឋកថាចិត្តសូត្រ ...... ...... ...... ...... ១២១
បរិក្ខារសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១២៦
បឋមអគ្គិសូត្រ ...... ...... ...... ...... ១២៧
អដ្ឋកថាបឋមអគ្គិសូត្រ ...... ...... ...... ...... ១២៧
ទុតិយអគ្គិសូត្រ ...... ...... ...... ...... ១២៩
អដ្ឋកថាទុតិយអគ្គិសូត្រ ...... ...... ...... ...... ១៣៧
បឋមសញ្ញាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១៣៩
ទុតិយសញ្ញាសូត្រ ...... ...... ...... ...... ១៤០
អដ្ឋកថាទុតិយសញ្ញាសូត្រ ...... ...... ...... ...... ១៥២
មេថុនសូត្រ ...... ...... ...... ...... ១៥៣
អដ្ឋកថាមេថុនសូត្រ ...... ...... ...... ...... ១៥៦
សំយោគសូត្រ ...... ...... ...... ...... ១៥៨
អដ្ឋកថាសំយោគសូត្រ ...... ...... ...... ...... ១៦២
ទានសូត្រ ...... ...... ...... ...... ១៦៣
អដ្ឋកថាទានសូត្រ ...... ...... ...... ...... ១៦៨
នន្ទមាតាសូត្រ ...... ...... ...... ...... ១៧០
អដ្ឋកថានន្ទមាតាសូត្រ ...... ...... ...... ...... ១៧៦

## អព្យាកតវគ្គ


អព្យាកតសូត្រ ...... ...... ...... ...... ១៨៣

អដ្ឋកថាអព្យាកតសូត្រ ...... ...... ...... ...... ១៨៦

បុរិសគតិសូត្រ ...... ...... ...... ...... ១៨៨

អដ្ឋកថាបុរិសគតិសូត្រ ...... ...... ...... ...... ១៩៤

តិស្សសូត្រ និងអដ្ឋកថា ...... ...... ...... ...... ១៩៧

សីហសូត្រ ...... ...... ...... ...... ២០៤

អដ្ឋកថាសីហសូត្រ ...... ...... ...... ...... ២១០

រក្ខិតសូត្រ ...... ...... ...... ...... ២១១

អដ្ឋកថារក្ខិតសូត្រ ...... ...... ...... ...... ២១៤

កិម្មិលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ២១៤

សត្តធម្មសូត្រ និងអដ្ឋកថា ...... ...... ...... ...... ២១៦

មោគ្គល្លានសូត្រ ...... ...... ...... ...... ២១៧

អដ្ឋកថាមោគ្គល្លានសូត្រ ...... ...... ...... ...... ២២៣

បុញ្ញវិបាកសូត្រ ...... ...... ...... ...... ២២៩

អដ្ឋកថាបុញ្ញវិបាកសូត្រ ...... ...... ...... ...... ២៣២

ភរិយាសូត្រ ...... ...... ...... ...... ២៣៥

អដ្ឋកថាភរិយាសូត្រ ...... ...... ...... ...... ២៣៩

កោធនាសូត្រ ...... ...... ...... ...... ២៤១

អដ្ឋកថាកោធនាសូត្រ ...... ...... ...... ...... ២៤៩

ហិរិសូត្រ ...... ...... ...... ...... ២៥៣

## មហាវគ្គ


អដ្ឋកថាហិរិសូត្រ ...... ...... ...... ...... ២៥៥
សុរិយសូត្រ ...... ...... ...... ...... ២៥៥
អដ្ឋកថាសុរិយសូត្រ ...... ...... ...... ...... ២៦៣
នគរោបមសូត្រ ...... ...... ...... ...... ២៦៨
អដ្ឋកថានគរោបមសូត្រ ...... ...... ...... ...... ២៧៧
ធម្មញ្ញូសូត្រ ...... ...... ...... ...... ២៨៣
អដ្ឋកថាធម្មញ្ញូសូត្រ ...... ...... ...... ...... ២៨៩
បារិច្ឆត្តកសូត្រ ...... ...... ...... ...... ២៩០
អដ្ឋកថាបារិច្ឆត្តកសូត្រ ...... ...... ...... ...... ២៩៤
សក្កច្ចសូត្រ ...... ...... ...... ...... ២៩៧
អដ្ឋកថាសក្កច្ចសូត្រ ...... ...... ...... ...... ៣០៤
ភាវនាសូត្រ ...... ...... ...... ...... ៣០៥
អដ្ឋកថាភាវនាសូត្រ ...... ...... ...... ...... ៣០៨
អគ្គិក្ខន្ធោបមសូត្រ ...... ...... ...... ...... ៣១៥
អដ្ឋកថាអគ្គិក្ខន្ធោបមសូត្រ ...... ...... ...... ...... ៣២៧
សុនេត្តអនុសាសនីសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣២៨
អរកានុសាសនីសូត្រ ...... ...... ...... ...... ៣៣០
អដ្ឋកថាអរកានុសាសនីសូត្រ ...... ...... ...... ...... ៣៣៦


## វិនយវគ្គ


បឋមវិនយធរសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៣៧
ទុតិយវិនយធរសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៣៨
តតិយវិនយធរសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៤០

សត្តសាសនសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៤៣
អធិករណសមថសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៤៥
វគ្គាសង្គហិតសុត្តន្ត ...... ...... ...... ...... ៣៤៨
អដ្ឋកថាសូត្រដែលមិនសង្គ្រោះចូលក្នុងវគ្គ ...... ...... ...... ...... ៣៥៣

# សុត្តន្តបិដក-ចាលីប្រែ ៤៨

## មេត្តាវគ្គ

មេត្តាសូត្រ ...... ...... ...... ...... ៣៥៤
អដ្ឋកថាមេត្តាសូត្រ ...... ...... ...... ...... ៣៥៧
បញ្ញាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៦១
បឋមអប្បិយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៦៩
ទុតិយអប្បិយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៧១
បឋមលោកធម្មសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៧៣
ទុតិយលោកធម្មសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៧៥
ទេវទត្តសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៨០
ឧត្តរសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៨៣
នន្ទសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៣៩១
ករណ្ឌវសូត្រ ...... ...... ...... ...... ៣៩៥
អដ្ឋកថាករណ្ឌវសូត្រ ...... ...... ...... ...... ៤០០

## មហាវគ្គ

វេរញ្ជសូត្រ ...... ...... ...... ...... ៤០២
អដ្ឋកថាវេរញ្ជសូត្រ ...... ...... ...... ...... ៤១៤
សីហសូត្រ ...... ...... ...... ...... ៤៣៧
អដ្ឋកថាសីហសូត្រ ...... ...... ...... ...... ៤៥០

អស្សាជានីយសូត្រ ...... ...... ...... ...... ៤៦៦
អដ្ឋកថាអស្សាជានីយសូត្រ ...... ...... ...... ...... ៤៦៨
អស្សខេមសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៤៦៩
មលសូត្រ ...... ...... ...... ...... ៤៧៧
អដ្ឋកថាមលសូត្រ ...... ...... ...... ...... ៤៧៨
ទូតសូត្រ ...... ...... ...... ...... ៤៧៩
អដ្ឋកថាទូតសូត្រ ...... ...... ...... ...... ៤៨១
បឋមពន្ធសូត្រទី ៧ ជាដើម ...... ...... ...... ...... ៤៨២
អដ្ឋកថាបឋមពន្ធសូត្រទី ៧ ជាដើម ...... ...... ...... ...... ៤៨៣
បហារាទសូត្រ ...... ...... ...... ...... ៤៨៤
អដ្ឋកថាបហារាទសូត្រ ...... ...... ...... ...... ៤៩៤
ឧបោសថសូត្រ ...... ...... ...... ...... ៥០១
អដ្ឋកថាឧបោសថសូត្រ ...... ...... ...... ...... ៥០៨

### គហបតិវគ្គ

បឋមឧគ្គសូត្រ ...... ...... ...... ...... ៥១០
អដ្ឋកថាបឋមឧគ្គសូត្រ ...... ...... ...... ...... ៥១៦
ទុតិយឧគ្គសូត្រ ...... ...... ...... ...... ៥១៧
អដ្ឋកថាទុតិយឧគ្គសូត្រ ...... ...... ...... ...... ៥២៤
បឋមហត្ថកសូត្រ ...... ...... ...... ...... ៥២៥
អដ្ឋកថាបឋមហត្ថកសូត្រ ...... ...... ...... ...... ៥២៨
ទុតិយហត្ថកសូត្រ ...... ...... ...... ...... ៥២៩
អដ្ឋកថាទុតិយហត្ថកសូត្រ ...... ...... ...... ...... ៥៣១
មហានាមសូត្រ ...... ...... ...... ...... ៥៣៣

អដ្ឋកថាមហានាមសូត្រ ...... ...... ...... ...... ៥៣៥
ជីវកសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៥៣៦
បឋមពលសូត្រ ...... ...... ...... ...... ៥៣៨
អដ្ឋកថាបឋមពលសូត្រ ...... ...... ...... ...... ៥៣៩
ទុតិយពលសូត្រ ...... ...... ...... ...... ៥៣៩
អដ្ឋកថាទុតិយពលសូត្រ ...... ...... ...... ...... ៥៤៣
អក្ខណសូត្រ ...... ...... ...... ...... ៥៤៤
អដ្ឋកថាអក្ខណសូត្រ ...... ...... ...... ...... ៥៤៩
អនុរុទ្ធសូត្រ ...... ...... ...... ...... ៥៥១
អដ្ឋកថាអនុរុទ្ធសូត្រ ...... ...... ...... ...... ៥៦៤

ទានវគ្គ

បឋមទានសូត្រ ...... ...... ...... ...... ៥៧២
អដ្ឋកថាបឋមទានសូត្រ ...... ...... ...... ...... ៥៧៣
ទុតិយទានសូត្រ ...... ...... ...... ...... ៥៧៤
អដ្ឋកថាទុតិយទានសូត្រ ...... ...... ...... ...... ៥៧៥
ទានវត្ថុសូត្រ ...... ...... ...... ...... ៥៧៥
អដ្ឋកថាទានវត្ថុសូត្រ ...... ...... ...... ...... ៥៧៦
ខេត្តសូត្រ ...... ...... ...... ...... ៥៧៧
អដ្ឋកថាខេត្តសូត្រ ...... ...... ...... ...... ៥៨១
ទានូបបត្តិសូត្រ ...... ...... ...... ...... ៥៨៣
អដ្ឋកថាទានូបបត្តិសូត្រ ...... ...... ...... ...... ៥៨៧
បុញ្ញកិរិយាវត្ថុសូត្រ ...... ...... ...... ...... ៥៨៨
អដ្ឋកថាបុញ្ញកិរិយាវត្ថុសូត្រ ...... ...... ...... ...... ៥៩១

សប្បុរិសទានសូត្រ ...... ...... ...... ...... ៥៩៣
អដ្ឋកថាសប្បុរិសទានសូត្រ ...... ...... ...... ...... ៥៩៤
សប្បុរិសសូត្រ ...... ...... ...... ...... ៥៩៤
អដ្ឋកថាសប្បុរិសសូត្រ ...... ...... ...... ...... ៥៩៧
បុញ្ញាភិសន្ទសូត្រ ...... ...... ...... ...... ៥៩៨
អដ្ឋកថាបុញ្ញាភិសន្ទសូត្រ ...... ...... ...... ...... ៦០១
សព្វលហុសសូត្រ ...... ...... ...... ...... ៦០២
អដ្ឋកថាសព្វលហុសសូត្រ ...... ...... ...... ...... ៦០៤

ឧបោសថវគ្គ

សង្ខិត្តសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦០៧
វិត្ថតសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦១១
វិសាខសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦១៨
វាសេដ្ឋសូត្រ ...... ...... ...... ...... ៦២៤
អដ្ឋកថាវាសេដ្ឋសូត្រ ...... ...... ...... ...... ៦២៦
ពោជ្ឈាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦២៧
អនុរុទ្ធសូត្រ ...... ...... ...... ...... ៦៣២
អដ្ឋកថាអនុរុទ្ធសូត្រ ...... ...... ...... ...... ៦៣៨
វិសាខសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៤០
នកុលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៤២
បឋមឥធលោកសូត្រ ...... ...... ...... ...... ៦៤៤
អដ្ឋកថាបឋមឥធលោកសូត្រ ...... ...... ...... ...... ៦៤៨
ទុតិយឥធលោកសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៤៩

# បណ្ណាសការសង្គហិតវគ្គ

## សទ្ធានវគ្គ


គោតមីសូត្រ ...... ...... ...... ...... ៦៥៣

អដ្ឋកថាគោតមីសូត្រ ...... ...... ...... ...... ៦៦៣

ឱវាទសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៧១

សង្ខិត្តសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៧៣

ទីឃជាណុសូត្រ ...... ...... ...... ...... ៦៧៥

អដ្ឋកថាទីឃជាណុសូត្រ ...... ...... ...... ...... ៦៨២

ឧជ្ជយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៨៥

ភយសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៩២

បឋមអាហុនេយ្យសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៩៥

ទុតិយអាហុនេយ្យសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៩៦

បឋមអដ្ឋបុគ្គលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៩៨

ទុតិយអដ្ឋបុគ្គលសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៦៩៩


## ចាលវគ្គ


ឥច្ឆាសូត្រ ...... ...... ...... ...... ៧០២

អដ្ឋកថាឥច្ឆាសូត្រ ...... ...... ...... ...... ៧០៦

បឋមអលំសូត្រជាដើម ...... ...... ...... ...... ៧០៦

អដ្ឋកថាបឋមអលំសូត្រជាដើម ...... ...... ...... ...... ៧១២

សង្ខិត្តសូត្រ ...... ...... ...... ...... ៧១២

អដ្ឋកថាសង្ខិត្តសូត្រ ...... ...... ...... ...... ៧១៧

គយាសីសសូត្រ ...... ...... ...... ...... ៧២០

អដ្ឋកថាគយាសីសសូត្រ ...... ...... ...... ...... ៧២៤

អភិកាយតនសូត្រ ...... ...... ...... ...... ៧២៥
អដ្ឋកថាអភិកាយតនសូត្រ ...... ...... ...... ...... ៧២៧
វិមោក្ខសូត្រ ...... ...... ...... ...... ៧៣១
អដ្ឋកថាវិមោក្ខសូត្រ ...... ...... ...... ...... ៧៣៣
បឋមវោហារសូត្រជាដើម ...... ...... ...... ...... ៧៣៥
អដ្ឋកថាបឋមវោហារសូត្រជាដើម ...... ...... ...... ...... ៧៣៦
បរិសសូត្រ ...... ...... ...... ...... ៧៣៧
អដ្ឋកថាបរិសសូត្រ ...... ...... ...... ...... ៧៣៨
ភូមិចាលសូត្រ ...... ...... ...... ...... ៧៤១
អដ្ឋកថាភូមិចាលសូត្រ ...... ...... ...... ...... ៧៥០

យមកវគ្គ

បឋមបដិបទាសូត្រ ...... ...... ...... ...... ៧៦១
អដ្ឋកថាបឋមបដិបទាសូត្រ ...... ...... ...... ...... ៧៦៤
ទុតិយបដិបទាសូត្រ ...... ...... ...... ...... ៧៦៤
អដ្ឋកថាទុតិយបដិបទាសូត្រ ...... ...... ...... ...... ៧៦៦
តតិយបដិបទាសូត្រ ...... ...... ...... ...... ៧៦៧
អដ្ឋកថាតតិយបដិបទាសូត្រ ...... ...... ...... ...... ៧៧៣
ចតុត្ថបដិបទាសូត្រជាដើម ...... ...... ...... ...... ៧៧៣
អដ្ឋកថាចតុត្ថបដិបទាសូត្រជាដើម ...... ...... ...... ...... ៧៨៣
ឥច្ឆាសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៧៨៣
បឋមលច្ឆាសូត្រជាដើម ...... ...... ...... ...... ៧៨៨
អដ្ឋកថាបឋមលច្ឆាសូត្រជាដើម ...... ...... ...... ...... ៧៩៣

បរិហានសូត្រ ...... ...... ...... ...... ៧៩៣
អដ្ឋកថាបរិហានសូត្រ ...... ...... ...... ...... ៧៩៤
អបរិហានសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៧៩៤
កុសីតវត្ថុសូត្រជាដើម ...... ...... ...... ...... ៧៩៥
អដ្ឋកថាកុសីតវត្ថុសូត្រជាដើម ...... ...... ...... ...... ៨០២


## សតិវគ្គ


សតិសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៨០៤
បុណ្ណិយសូត្រ ...... ...... ...... ...... ៨០៧
អដ្ឋកថាបុណ្ណិយសូត្រ ...... ...... ...... ...... ៨០៩
មូលសូត្រ ...... ...... ...... ...... ៨០៩
អដ្ឋកថាមូលសូត្រ ...... ...... ...... ...... ៨១១
ចោរសូត្រ ...... ...... ...... ...... ៨១២
អដ្ឋកថាចោរសូត្រ ...... ...... ...... ...... ៨១៣
សមណសូត្រ ...... ...... ...... ...... ៨១៤
អដ្ឋកថាសមណសូត្រ ...... ...... ...... ...... ៨១៦
យសសូត្រ ...... ...... ...... ...... ៨១៧
អដ្ឋកថាយសសូត្រ ...... ...... ...... ...... ៨២២
បត្តសូត្រ ...... ...... ...... ...... ៨២៣
អដ្ឋកថាបត្តសូត្រ ...... ...... ...... ...... ៨២៤
អប្បសាទសូត្រ ...... ...... ...... ...... ៨២៥
អដ្ឋកថាអប្បសាទសូត្រ ...... ...... ...... ...... ៨២៦
បដិសារណីយសូត្រ ...... ...... ...... ...... ៨២៧
អដ្ឋកថាបដិសារណីយសូត្រ ...... ...... ...... ...... ៨២៨

វត្តសូត្រ ...... ...... ...... ...... ៨២៨
អដ្ឋកថាវត្តសូត្រ ...... ...... ...... ...... ៨២៩

## សាមញ្ញវគ្គ

សាមញ្ញវគ្គ ...... ...... ...... ...... ៨៣១
អដ្ឋកថាសាមញ្ញវគ្គ ...... ...... ...... ...... ៨៣៥